# រៀនភាសាបាលី

# បែបទំនើប

## ភាគ ២

រៀបរៀងដោយ

ញឹម ជារី

ព.ស.២៥៦០ គ.ស.២០១៦

# រៀនភាសាបាលី

# បែបទំនើប

# ភាគ ២

រៀបរៀងដោយ

ញឹម ជារី

ព.ស.២៥៦០ គ.ស.២០១៦

| | | |
|---|---|---|
| ឈ្មោះសៀវភៅ | : | រៀនភាសាបាលីបែបទំនើប |
| អ្នករៀបរៀង | : | ញ៉ឹម ថារី |
| អ្នកពិនិត្យផ្ទៀងផ្ទាត់ | : | ភិក្ខុញាណសារោ មុំ យ៉ារុំង<br>ញ៉ឹម ថារី<br>ទូច សុវណ្ណមុនី |
| ទីកន្លែងរៀបរៀង | : | ក្រុងស៊ីដនី ប្រទេសអូស្រ្តាលី |
| ខ្នាតសៀវភៅ | : | ១៥ សម x ២១ សម (A5) |
| បោះពុម្ពលើកទី ១ | : | ចំនួន ៦៥០ ក្បាល |
| កាលបរិច្ឆេទបោះពុម្ព | : | ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៦ |
| ទីកន្លែងបោះពុម្ព | : | រោងពុម្ពភ្នំពេញ សង្កាត់បឹងត្របែក,<br>ខណ្ឌចំការមន, រាជធានីភ្នំពេញ |
| ISBN | : | 978-99963-864 |
| Tel | : | 017 95 69 24 / 012 47 00 66 |

# សម្មោទនីយកថា

សៀវភៅ ***រៀនភាសាបាលីបែបទំនើបភាគ ២*** នេះជាស្នាដៃដ៏ពិសិដ្ឋថ្មីមួយទៀតដែលលោក ***ញឹម ថារី*** បានប្រឹងប្រែងស្រាវជ្រាវនិងរចនាដោយយកចិត្តទុកដាក់បំផុតនិងអស់ពីសមត្ថភាព ដើម្បីជាផលប្រយោជន៍នៃព្រះពុទ្ធសាសនានិងកុលបុត្រកុលធីតាខ្មែរទាំងអស់ ។ នៅពេលលោកបានធ្វើសៀវភៅនេះរួចស្រេចហើយ បានប្រគល់ឲ្យខ្ញុំដើម្បីជួយចាត់ចែងបោះពុម្ពផ្សាយតាំងពីឆ្នាំ ២០១៤ ម្ល៉េះ ។ ប៉ុន្តែដោយសារខ្ញុំមានធុរៈជាមួយនឹងការងារវត្តខ្លះ ៗ សង្គមខ្លះ ៗ និងការសិក្សាផ្ទាល់ខ្លួនដើម្បីបញ្ចប់ថ្នាក់អនុបណ្ឌិត ទើបមានភាពយឺតយ៉ាវក្នុងការបោះពុម្ព ។

ម្តងនេះ ខ្ញុំមិនបានជួយផ្ទៀងអក្ខរាវិរុទ្ធតាមប្រព័ន្ធអិនធើនែតជាមួយក្រុមលោកដូចសព្វដងទេ ប៉ុន្តែខ្ញុំបានឆ្លៀតឱកាសអាននិងពិនិត្យឃ្លាឃ្លោងទៅតាមសមត្ថភាពរបស់ខ្លួន ។ ខ្ញុំក៏បានយកសៀវភៅនេះទៅប្រគេនព្រះមហាថេរៈ ជាអតីតសមណៈសិស្សឱសផ្ទូមបាលី ***ព្រះមហាសុទវ៉ោ សុទេព សុរពង្ស*** ដើម្បីជួយពិនិត្យបន្ថែម ។ លោកមានសេចក្តីសោមនស្សរីករាយឥតឧបមាបន្ទាប់ពីបានឃើញសៀវភៅនេះ ហើយលោកក៏មានសេចក្តីប្រាថ្នាចង់ឲ្យសម្រេចជារូបរាងឡើងឆាប់ ៗ ។ ម្យ៉ាងទៀត លោកសាស្ត្រាចារ្យ ***ទូច សុវណ្ណមុនី*** និងព្រះសង្ឃអ្នកមានវិជ្ជាខាងភាសាបាលីនៅប្រទេសខ្មែរមានវត្តឧណ្ណាលោម វត្តបទុមវតី និងមហាមន្ត្រីជាដើម និងព្រះសង្ឃនៅប្រទេសដទៃទៀតក៏បានជួយពិនិត្យដែរ ។

ដូច្នេះ ខ្ញុំគិតថាសមគួរដល់វេលាបោះពុម្ពហើយ ទើបខិតខំប្រមូលថវិកា ដើម្បីបោះពុម្ព ។ ខ្ញុំក៏បានទទួលដំណឹងថា **សៀវភៅរៀនភាសាបាលី បែបទំនើបភាគទី ១** មានការពេញនិយមពីលោកអ្នកសិក្សា ជាពិសេស ពីសំណាក់សមណសិស្សភាសាបាលី ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងបានជាបករណ៍ថ្មីមួយទៀតសម្រាប់ បំពេញតម្រូវការរបស់សមណសិស្ស ដែលមានក្តីប្រាថ្នាក្នុងការសិក្សា ស្រាវជ្រាវនិងបង្កើននូវចំណេះដឹងក្នុងភាសាវិជ្ជានិងធម្មវិជ្ជា។ សៀវភៅ នេះទៀតសោតក៏នឹងបានជាសម្បត្តិនៃព្រះពុទ្ធសាសនាផង និងបានជា ប្រយោជន៍ដល់ខេមរជនប្រុសស្រីទូទៅក្នុងបច្ចុប្បន្ន និងអនាគតកាលដ៏ យូរអង្វែងផង ។

ខ្ញុំសូមអនុមោទនានូវសេចក្តីព្យាយាមដ៏ធំ និងសូមប្រសិទ្ធិពរ ដល់លោក **ញឹម ថារី** ឲ្យមានសុខភាពបរិបូណ៌និងអាយុយឺនយូរ ដើម្បី បន្តការងាររចនាគម្ពីរផ្សេង ៗ ទៀត ។

សូមលើកនូវមហាកុសលនេះឧទ្ទិសថ្វាយនិងប្រគេន ដល់បុព្វវីរ- សមណនិងវីរៈបុរសខ្មែរព្រមទាំងអ្នក ដែលមានឧបការគុណទាំងអស់ គ្រប់កាលសម័យ មានសម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត** ជាដើមផង និងលោកឯទៀត ៗ ដែលអស់សង្ខារទៅហើយផង អ្នកមាន ជន្មាយុសង្ខារផង មួយអន្លើដោយមាតាបិតានៃយើងទាំងអស់គ្នាផង ។

សូមថ្លែងអំណរគុណ និងប្រគេនមហាកុសលចំពោះសប្បុរស-

ជនទាំងអស់ ទាំងបព្វជិតទាំងគ្រហស្ថដែលនៅក្នុងនិងក្រៅប្រទេសព្រម ទាំងអ្នកមានឧបការៈដទៃទៀតដែលបានជ្រោមជ្រែងសព្វបែបយ៉ាងនិង ចូលរួមថវិកាដើម្បីបោះពុម្ពសៀវភៅវេយ្យាករណ៍បាលីមុន ៗ ក្តី គ្រានេះ ក្តី សូមលោកនិងអ្នកទាំងអស់នោះជួបនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមបានសម្រេចនូវព្រះនិព្វាននាឱសានជាតិកុំបីខានឡើយ ។

**នត្ថិ បញ្ញា សមា អាភា**

គ្មានពន្លឺអ្វីដទៃស្មើដោយពន្លឺប្រាជ្ញា (គាថាធម្មបទ)

វត្តពុទ្ធជ័យមហានាថ, ទីក្រុងវែល្លិងតុន, ញូហ្ស៊ីឡិនដ៍

ថ្ងៃ ០៤ កើត ខែ ស្រាពណ៍ ឆ្នាំ វក អដ្ឋស័ក ព.ស. ២៥៦០

ត្រូវនឹងថ្ងៃអាទិត្យ ទី ០៧ ខែ សីហា គ.ស. ២០១៦

**ភិក្ខុ ញាណសារោ មុំ យ៉ាភ៉ាំង**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណា ខ្ញុំបាទជាអ្នកចងក្រងមានសេចក្តីរីករាយចិត្តឥតឧបមាចំពោះការបានឃើញសៀវភៅ **រៀនភាសាបាលីបែបទំនើប** នេះទាំងពីរភាគបានបោះពុម្ពចេញជាសៀវភៅ ។ ប៉ុន្តែ ប្រសិនបើមិនមានជំនួយទេ សៀវភៅនេះក៏មិនអាចបោះពុម្ពបានដែរ ។ អាស្រ័យនេះ ក្នុងទីនេះខ្ញុំសូមថ្លែងអំណរគុណជាអនេកកប្បការចំពោះ

លោកសាស្ត្រាចារ្យ **ឌូច សុវណ្ណមុនី** លោកបានជួយអាននិងជួយពិនិត្យព្រមទាំងជួយណែនាំឲ្យដឹងនូវចំណុចខ្វះទៀតផង។ ព្រះភិក្ខុ **ញាណសារោ មុំ យ៉ារ៉ាំង** បានជួយរកថវិកាសម្រាប់ចំណាយនិងរៀបចំការបោះពុម្ព។ ឧបាសក **ប៉ុច រឿត** និង **កោវ ឌិសថា** និងឧបាសិកា **ពៅ ស៊ីអ៊ុម** បានជួយរកថវិកាសម្រាប់ចំណាយក្នុងការបោះពុម្ព ។ ព្រះតេជគុណ លោកយាយ លោកតា និងបងប្អូនប្រុសស្រីជាសប្បុរសជនទាំងអស់ ដែលមានសទ្ធាជ្រះថ្លា ជាអ្នកបានបរិច្ចាគថវិកា ។

អាស្រ័យហេតុនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមឧទ្ទិសនូវកុសលផលដែលកើតមានឡើងពីការធ្វើសៀវភៅនេះ ចំពោះព្រះតេជគុណ លោកយាយ លោកតា បងប្អូនប្រុសស្រីទាំងអស់ សូមមានសុខភាពល្អ អាយុយឺនយូរ និងសូមឲ្យបានសម្រេចតាមសេចក្តីប្រាថ្នា ជាពិសេសសូមឲ្យបានសម្រេចនូវព្រះនិព្វាននាអនាគតជាតិកុំបីខានឡើយ ។

ថ្ងៃទី ៨ កញ្ញា ២០១៦ ទីក្រុងស៊ីដនីយ៍ អូស្ត្រាលី

ញឹម ថារី

# មាតិកា


*សម្ភោទនីយកថា* ក

*មាតិកា* (១)

*អក្សរសង្ខេប* (១៣)

**មេរៀនទី ២៦** ១

*អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ (តចប់), វិធីបំបែកពួក ៤ (មនោគណៈ), វិកត្តិសម្រេចរូបនៃមនោគណស័ព្ទ, វិធីបំបែក* **មន** *ជាបុំលិង្គ, វិធីបំបែក* **មន** *ជានបុំសកលិង្គ, វិធីបំបែក* **កម្ម** *និង* **គោ** *ស័ព្ទ, វិកត្តិសម្រេចរូបនៃ* **កម្ម** *ស័ព្ទ, វិធីបំបែក* **កម្ម** *ស័ព្ទ, វិកត្តិសម្រេចរូបនិងវិធីបំបែកនៃ* **គោ** *ស័ព្ទ, វិធីប្រកបនាមស័ព្ទជាឥត្ថីលិង្គ, នាមស័ព្ទ* **អា** *ការន្តជាបុំលិង្គ, វិធីបំបែក* **សា**, *នាមស័ព្ទមានរូបជាបុំលិង្គតែអត្ថជាឥត្ថីលិង្គ, បធាននយកិរិយា, អព្ភន្តរកិរិយា, ឥត្ថម្ភូតកិរិយា, អនាទរកិរិយា, លក្ខណកិរិយា, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ២៦ ។*

**មេរៀនទី ២៧** ២៧

*អធិប្បាយអំពីអព្យយស័ព្ទ, ឧបសគ្គ, ឧបសគ្គបៀតបៀនអត្ថ*

របស់ធាតុ, ឧបសគ្គមានអត្ថស្របតាមធាតុ, ឧបសគ្គធ្វើអត្ថរបស់ធាតុឲ្យប្លែក, **និ** ឧបសគ្គ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ២៧ ។

**មេរៀនទី ២៨** ៥២

អធិប្បាយអំពីនិបាតស័ព្ទ, និបាតស័ព្ទ, អាលបនត្ថវាចកនិបាត, កាលត្ថវាចកនិបាត, ឋានត្ថវាចកនិបាត, បដិសេធនត្ថវាចកនិបាត, អនុស្សវនត្ថនិបាត, បរិកប្បនិបាត, បុច្ឆនត្ថនិបាត, សម្បដិច្ឆនត្ថនិបាត, ឧយ្យោជនត្ថនិបាត, អនេកត្ថនិបាត, បទបូរណនិបាត, លំហាត់នៃមេរៀនទី ២៨ ។

**មេរៀនទី ២៩** ៧៧

អធិប្បាយអំពីនិបាតស័ព្ទ (តចប់) និង ប្រយោគ ៣ យ៉ាង, នានត្ថនិបាត, ប្រយោគ ៣ ប្រភេទ, បរិកប្បនិបាត, ឧបមានុបមេយ្យត្ថនិបាត, បការត្ថនិបាត, និបាតប្រើជាបទប្រធាន, វិធីប្រែ **បិ** ឬ **អបិ** ស័ព្ទបន្ថែម, លំហាត់នៃមេរៀនទី ២៩ ។

**មេរៀនទី ៣០** ៩៩

អធិប្បាយអំពីការសរសេរនិងប្រើ **ឥតិ** ស័ព្ទ, វិធីសរសេរ **ឥតិ**

*ស័ព្ទ, របៀបប្រើនិងប្រែ* **ឥតិ** *ស័ព្ទដោយពិស្តារ,* **ឥតិ** *ប្រែថា "ជាដើម",* **ឥតិ** *ប្រែថា "ដូច្នេះ" "ដូចនេះ" ទី ១,* **ឥតិ** *ប្រែថា "ដូច្នេះ" ទី ២,* **ឥតិ** *ប្រែថា "ឈ្មោះថា",* **ឥតិ** *ប្រែថា "គឺ, ថា",* **ឥតិ** *ប្រែថា "ព្រោះហេតុដូច្នោះ, ហេតុដូច្នោះ",* **ឥតិ** *ប្រែថា "ដោយប្រការដូច្នេះ" "ដោយប្រការយ៉ាងនេះ",* **ឥតិ** *ប្រែថា "ដូច្នេះ" ទី ៣,* **ឥតិ** *ប្រែថា "ដូច្នេះឯង",* **ឥតិ** *ប្រែថា "គឺ...", លំហាត់នៃមេរៀនទី ៣០ ។*

**មេរៀនទី ៣១** ១២២

*អធិប្បាយអំពីអព្យយបច្ច័យ, ស័ព្ទកាលសត្តមី និង បុនរុត្តិស័ព្ទ, វិធីប្រើនិងប្រែអព្យយបច្ច័យពួកទី ១,* **តោ** *ចុះក្នុងអត្ថតតិយាវិភត្តិ,* **តោ** *ចុះក្នុងអត្ថបញ្ចមីវិភត្តិ, វិធីប្រើនិងប្រែអព្យយបច្ច័យពួកទី ២, វិធីប្រើនិងប្រែអព្យយបច្ច័យពួកទី ៣, ស័ព្ទកាលសត្តមី, បុនរុត្តិស័ព្ទ, លំហាត់នៃមេរៀនទី ៣១ ។*

**មេរៀនទី ៣២** ១៣៧

*អធិប្បាយអំពីនាមកិតកៈ, វិធីតាំងវិគ្គហៈនៃកត្តុរូប-កត្តុសាធនៈ, វិធីប្រែប្រយោគវិគ្គហៈ, វិធីចុះ* **ក្វិ** *បច្ច័យ, វិធីប្រើនាមកិតកៈក្នុងប្រយោគ, វិធីតាំងវិគ្គហៈនៃតស្សីលសាធនៈ, វិធីតាំង*

*វិគ្គហៈនៃកត្តុរូប-តស្សីលសាធនៈ, វិធីតាំងវិគ្គហៈនៃសមាសរូប-តស្សីលសាធនៈ, លំហាត់នៃមេរៀនទី ៣២ ។*

**មេរៀនទី ៣៣** ១៥៩

*អធិប្បាយអំពីនាមកិតកៈ (ត), វិធីចុះ* **ណី** *បច្ច័យ, វិធីចុះ* **ណ្វុ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **ណ្វុ** *បច្ច័យ, វិធីចុះ* **តុ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **តុ** *បច្ច័យ, វិធីចុះ* **រូ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **រូ** *បច្ច័យ, ធាតុគណៈទី ១ (ត), នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ៣៣ ។*

**មេរៀនទី ៣៤** ១៨៦

*អធិប្បាយអំពីនាមកិតកៈ (ត), វិធីតាំងវិគ្គហៈនៃកម្មសាធនៈ, វិធីតាំងវិគ្គហៈនៃកត្តុរូប-កម្មសាធនៈ, វិធីតាំងរូបវិគ្គហៈនៃកម្មរូប-កម្មសាធនៈ, វិធីចុះ* **ខ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **ខ** *បច្ច័យ, វិធីតាំងវិគ្គហៈជាភាវសាធនៈ, រូបវិគ្គហៈប្រើអាខ្យាតកិរិយា, រូបវិគ្គហៈដែលប្រើកិតកិរិយា, រូបវិគ្គហៈប្រើនាមកិតកៈ, វិធីចុះ* **ណ្យ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **ណ្យ** *បច្ច័យ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៣៤ ។*

មេរៀនទី ៣៥ ២១៦

*អធិប្បាយអំពីនាមកិតកៈ (ត), វិធីតាំងវិគ្គហៈនៃករណ-សាធនៈ, កត្តុរូប-ករណសាធនៈ, កម្មរូប-ករណសាធនៈ, វិធីតាំងវិគ្គហៈនៃសម្បទានសាធនៈ, កត្តុរូប-សម្បទានសាធនៈ, កម្មរូប-សម្បទានសាធនៈ, វិធីតាំងវិគ្គហៈនៃអបាទានសាធនៈ, កត្តុរូប-អបាទានសាធនៈ, វិធីតាំងវិគ្គហៈនៃអធិករណសាធនៈ, កត្តុរូប-អធិករណសាធនៈ, កម្មរូប-អធិករណសាធនៈ, វិធីចុះកិតកិច្ចបច្ច័យ, វិធីចុះ* **អ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **អ** *បច្ច័យ, វិធីចុះ* **ឥ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **ឥ** *បច្ច័យ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៣៥ ។*

មេរៀនទី ៣៦ ២៤២

*អធិប្បាយអំពីនាមកិតកៈ (ត), វិធីចុះ* **ណ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **ណ** *បច្ច័យ, ប្រែវិគ្គហៈជាគំរូ, វិធីចុះ* **តិ** *បច្ច័យ, វិធីតាំងវិគ្គហៈនៃ* **តិ** *បច្ច័យ, វិធីចុះ* **យុ** *បច្ច័យ, វិធីចុះ* **តវេ** *និង* **តុំ** *បច្ច័យ, នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ៣៦ ។*

មេរៀនទី ៣៧ ២៦៩

*អធិប្បាយអំពីនាមកិតកៈ (ត), បច្ចេកបច្ច័យ ឬ បច្ច័យដោយ-*

ឡៀក, វិធីចុះបច្ច័យមួយតួ ៗ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៣៧ ។

**មេរៀនទី ៣៨** ២៩០

អធិប្បាយអំពីនាមកិតកៈ (តចប់), វិធីសង្កេតបច្ច័យនៃនាម-កិតកៈមួយតួ ៗ, **អ** បច្ច័យតួពិត, **អ** បច្ច័យតួជំនួស, **ឮ** បច្ច័យតួជំនួស, **ឩ** បច្ច័យតួជំនួស, **អក អានក** បច្ច័យតួជំនួស, **អន អណា អានន** បច្ច័យតួជំនួស, **តុ** បច្ច័យតួពិត, **ឥ** បច្ច័យតួពិត, **តិ** បច្ច័យតួពិត, **តវេ** និង **តុំ** បច្ច័យតួពិត, **ឧណា ណុ** បច្ច័យ, **ជ** បច្ច័យ, **ម** បច្ច័យ, **ល** បច្ច័យ, **អល** បច្ច័យ, **យាណ លាន** បច្ច័យ, **ជុ ត្តិម ណិម** បច្ច័យ, **ណុ** បច្ច័យ, **ត្រណ ត** បច្ច័យ, **ង** បច្ច័យ, **ន ឥន្ទ** បច្ច័យ, **ក ឌ** បច្ច័យ, **ឥរ កិរ** បច្ច័យ, **ទុ** បច្ច័យ, **ឮវ** បច្ច័យ, **ឩរ** បច្ច័យ, **ឧស្ស ឆុស ឥស** បច្ច័យ, វិធីសង្កេតសាធនៈនីមួយ ៗ ។

**មេរៀនទី ៣៩** ៣២០

អធិប្បាយអំពីតទ្ធិត, តទ្ធិតដោយសង្ខេប, សាមញ្ញតទ្ធិត, គោត្តតទ្ធិត, ការប្រកបរូបស័ព្ទជាគោត្តតទ្ធិត, វិធីតាំងវិគ្គហៈនៃគោត្តតទ្ធិត, តរត្យាទិតទ្ធិត, វិធីតាំងវិគ្គហៈនៃតរត្យាទិតទ្ធិត,

ប្រភេទប្រើជំនួសអាខ្យាតកិរិយា, ប្រភេទប្រើជំនួសកិតកិរិយា, ប្រភេទប្រើជំនួសនាមនាម, ប្រភេទប្រើជំនួសគុណនាមសុទ្ធ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៣៩ ។

មេរៀនទី ៤០ ៣៥៤

អធិប្បាយអំពីតទ្ធិត (ត), រាគាទិតទ្ធិត, វិធីតាំងវិគ្គហៈនៃរាគាទិតទ្ធិត, ប្រើជំនួសកិតកិរិយា, ប្រើជំនួសអាខ្យាតកិរិយា, ប្រើជំនួសនាមនាម, ប្រើជំនួសគុណនាម, ជាតាទិតទ្ធិត, ប្រើជំនួសកិតកិរិយា, ប្រើជំនួសអាខ្យាតកិរិយា, សមូហតទ្ធិត, វិធីតាំងវិគ្គហៈនៃសមូហតទ្ធិត, ឋានតទ្ធិត, វិធីតាំងវិគ្គហៈនៃឋានតទ្ធិត, ពហុលតទ្ធិត, វិធីតាំងវិគ្គហៈនៃពហុលតទ្ធិត, សេដ្ឋតទ្ធិត, វិធីតាំងវិគ្គហៈនៃសេដ្ឋតទ្ធិត, បកតិតទ្ធិត, វិធីតាំងវិគ្គហៈនៃបកតិតទ្ធិត, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៤០ ។

មេរៀនទី ៤១ ៣៨៦

អធិប្បាយអំពីតទ្ធិត (ត), តទស្សត្ថិតទ្ធិត, វិធីតាំងវិគ្គហៈនៃតទស្សត្ថិតទ្ធិត, គំរូបំបែកទាំងបីលិង្គ, បូរណតទ្ធិត, វិធីតាំងវិគ្គហៈនៃបូរណតទ្ធិត, សំខ្យាតទ្ធិត, វិធីតាំងវិគ្គហៈនៃសំខ្យា-

តទ្ធិត, វិភាគតទ្ធិត, ឧបមាតទ្ធិត, និស្សិតតទ្ធិត, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៤១ ។

**មេរៀនទី ៤២** ៤១៣

អធិប្បាយអំពីតទ្ធិត (តចប់), ភាវតទ្ធិត, វិធីតាំងវិគ្គហៈនៃភាវតទ្ធិត, បច្ច័យពិសេស, អព្យយតទ្ធិត, វិធីតាំងវិគ្គហៈនៃអព្យយតទ្ធិត, សរុបចំណុចគួរចងចាំ, នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ៤២ ។

**មេរៀនទី ៤៣** ៤៣៧

អធិប្បាយអំពីសញ្ញាវិធាន, សញ្ញាវិធាន, សារៈសំខាន់របស់អក្ខរៈ, ចំនួននៃអក្ខរៈ, អត្ថន័យរបស់អក្ខរៈ, លក្ខណៈរបស់ស្រៈ, វណ្ណៈឬរូបរបស់ស្រៈ, លក្ខណៈរបស់ព្យញ្ជនៈ, និគ្គហិត, គរុ និង លហុ, ព្យាង្គ, គរុព្យាង្គនិងលហុព្យាង្គ, សថិល និង ធនិត, អឃោសៈ និង ឃោសៈ, សម្ព័ន្ធ និង វវត្ថិតៈ, វិមុត្តៈ, ឋានករណៈនិងបយតនៈ, ឋាននៃអក្ខរៈ, ឯកដ្ឋានអក្ខរៈ, ទ្វិដ្ឋាន-អក្ខរៈ, អឍ្ឍសរ, ករណៈនៃអក្ខរៈ, និស្សយៈនិងនិស្សិត, តារាងអំពីឋាននិងករណៈនៃអក្សរភាសាបាលី ។

មេរៀនទី ៤៤ ៤៥៨

អធិប្បាយអំពីសន្ធិ, ប្រភេទនៃសន្ធិ, សន្ធិកិរិយោបករណ៍, វិធីធ្វើសន្ធិ, សរសន្ធិ, ស្រៈស្មើគ្នានិងស្រៈមិនស្មើគ្នា, សរលោបសន្ធិ, សរាទេសសន្ធិ, សរាគមសន្ធិ, សរវិការសន្ធិ, សរបកតិសន្ធិ, សរទីឃសន្ធិ, សររស្សសន្ធិ, សរវិបរិតោសន្ធិ, អសន្ធិ, វិធីប្រែសន្ធិស័ព្ទ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៤៤ ។

មេរៀនទី ៤៥ ៤៨៥

អធិប្បាយអំពីសន្ធិ (តចប់) និង ព្យញ្ជនាគមវិធី ព្យញ្ជនាទេសវិធី, ព្យញ្ជនសន្ធិ, សរទីឃព្យញ្ជនសន្ធិ, សររស្សព្យញ្ជនសន្ធិ, សំយោគព្យញ្ជនសន្ធិ, បកតិព្យញ្ជនសន្ធិ, និគ្គហិតសន្ធិ ឬ វោមិស្សកសន្ធិ, និគ្គហិតាទេសសន្ធិ, និគ្គហិតបកតិសន្ធិ, និគ្គហិតលោបសន្ធិ, ព្យញ្ជនាគមវិធី, ព្យញ្ជនាទេសវិធី, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ៤៥ ។

មេរៀនទី ៤៦ ៥០៤

អធិប្បាយអំពីសមាស, ស័ព្ទនិងបទ, វិធីតាំងវិគ្គហៈសមាស, បុព្វបទនិងឧត្តរបទ, លុត្តសមាសនិងអលុត្តសមាស, ស្រៈ អា,

ឿ, ឳ ក្នុងបទសមាស, សន្ធិក្នុងសមាស, បុំលិង្គ ឬ ឥត្ថីលិង្គ, សមាស ៦ ប្រភេទ, កម្មធារយសមាស, កម្មធារយសមាស ៦ យ៉ាង, វិសេសនបុព្វបទកម្មធារយ, វិសេសនុត្តរបទកម្មធារយ, វិសេសនោភយបទកម្មធារយ, វិសេសនោបមបទកម្មធារយ, ឧបមាបុព្វបទកម្មធារយ, ឧបមានុត្តរបទកម្មធារយ, សម្ភាវនៈបុព្វបទកម្មធារយសមាស, អវធារណបុព្វបទកម្មធារយសមាស វិធីប្រែនិងតាំងវិគ្គហៈនៃកម្មធារយសមាស, លំហាត់នៃមេរៀន ទី ៤៦ ។

មេរៀនទី ៤៧ ៥៣៦

អធិប្បាយអំពីសមាស (ត), ទិគុសមាស, វិធីតាំងវិគ្គហៈរបស់ទិគុសមាស, តប្បុរិសសមាស, វិធីតាំងវិគ្គហៈនិងប្រែនៃតប្បុរិសសមាស, ទុតិយាតប្បុរិសសមាស, តតិយាតប្បុរិសសមាស, ចតុត្ថីតប្បុរិសសមាស, បញ្ចមីតប្បុរិសសមាស, ឆដ្ឋីតប្បុរិសសមាស, សត្តមីតប្បុរិសសមាស, ឧបបទសមាស ឬ ឧបបទតប្បុរិសសមាស, ទ្វន្ទសមាស, វិធីតាំងវិគ្គហៈនៃទ្វន្ទសមាស, សមាហារទ្វន្ទសមាស, អសមាហារទ្វន្ទសមាស, ឯកសេសសមាស, បុព្វេកសេសសមាស, បរេកសេសសមាស, សរូបេកសេសសមាស, វិរូបេកសេសសមាស, មជ្ឈេលោបសមាស,

ឧភយតប្បុរិសសមាស ឬ នបុព្វបទកម្មធារយសមាស, លំហាត់នៃមេរៀនទី ៤៧ ។

**មេរៀនទី ៤៨** ៥៦០

អធិប្បាយអំពីសមាស (ត), អព្យយីភាវសមាស, វិធីតាំងវិគ្គហៈនៃអព្យយីភាវសមាស, ឧបសគ្គបុព្វកាព្យយីភាវសមាស, និបាតបុព្វកាព្យយីភាវសមាស, ពហុព្វីហិសមាស, តុល្យាធិករណពហុព្វីហិសមាស, ទុតិយាពហុព្វីហិសមាស, តតិយាពហុព្វីហិសមាស, ចតុត្ថីពហុព្វីហិសមាស, បញ្ចមីពហុព្វីហិសមាស, ឆដ្ឋីពហុព្វីហិសមាស, សត្តមីពហុព្វីហិសមាស, ឥត្ថីលិង្គទៅជាបុំលិង្គ, វិធីចុះបច្ច័យក្នុងសមាស, លំហាត់នៃមេរៀនទី ៤៨ ។

**មេរៀនទី ៤៩** ៥៨៤

អធិប្បាយអំពីសមាស (ត), ឆដ្ឋីឧបមាពហុព្វីហិសមាស, ភិន្នាធិករណពហុព្វីហិសមាស, **ន**-បុព្វបទពហុព្វីហិសមាស, **សហ**-បុព្វបទពហុព្វីហិសមាស, ពហុព្វីហិសមាសពិសេស, សំខ្យាភយបទពហុព្វីហិសមាស, តិបទពហុព្វីហិសមាស, ព្យតិហារលក្ខណពហុព្វីហិសមាស, ទិសន្តរាឡត្តពហុព្វីហិសមាស, សរុបសេចក្តីរបស់សមាស, លំហាត់នៃមេរៀនទី ៤៩ ។

**មេរៀនទី ៥០** ៦០៣

*អធិប្បាយអំពីសមាស (តចប់), មិស្សកសមាស, វិធីញែកបទ មិស្សកសមាស, វិធីពិចារណា, វិធីតាំងវិគ្គហៈមិស្សកសមាស,* **អាទិ** *ស័ព្ទក្នុងសមាស,* **ភេទ** *ស័ព្ទក្នុងសមាស,* **បមាណ មត្ត** *ស័ព្ទក្នុងសមាស ។*

*វាក្យានុក្រម* ៦២៤

*អាខ្យាតកិរិយានុក្រម* ៦៦៦

*វេយ្យាករណតជ្ជនី☞* ៦៨៤

*ឈ្មោះសៀវភៅប្រើប្រាស់ក្នុងការរៀបរៀង* ៦៨៥

*នាមសប្បុរសជនចូលបច្ច័យ* ៦៨៦

# អក្សរសង្ខេប

| | |
|---|---|
| អព្យ. អព្យយស័ព្ទ | ន. នាមស័ព្ទ |
| អា. អាលបនវិភត្តិ | នបុំ. នបុំសកលិង្គ |
| ឧ.បុ. ឧត្តមបុរិសៈ | និ. និបាត |
| ឥ. ឥត្ថីលិង្គ | ប. បឋមាវិភត្តិ |
| កិ. កិរិយាស័ព្ទ | បញ្ច. បញ្ចមីវិភត្តិ |
| កិត. កិតកិរិយា | ប.បុ. បឋមបុរិសៈ |
| គុ. គុណនាម | បុំ. បុំលិង្គ |
| ច. ចតុត្ថីវិភត្តិ | ម.បុ. មជ្ឈិមបុរិសៈ |
| ឆ. ឆដ្ឋីវិភត្តិ | វិ. វិគ្គហៈ ឬ វិភត្តិ |
| ត. តតិយាវិភត្តិ | ស. សត្តមីវិភត្តិ |
| ទុ. ទុតិយាវិភត្តិ | សព្វ. សព្វនាម |

# មេរៀនទី ២៦

## អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ (តចប់)
## និង វិធីប្រកបនាមស័ព្ទជាឥត្ថីលិង្គ, បធាននយកិរិយា,
## អព្ភន្តរកិរិយា, ឥត្ថម្ភូតកិរិយា, អនាទរកិរិយា និង លក្ខណកិរិយា

### វិធីបំបែកពួក ៤ (មនោគណ:)

**មនោគណ** *ប្រែថា "ក្រុមឬពួកនៃមន:" ជានាមនាមពួកបកិណ្ណកស័ព្ទនៃក្រុម* **មន** *មាន ១២ ស័ព្ទគឺ*

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| មន | *ចិត្ត* | អយ | *ដែក* |
| ឧរ | *ទ្រូង* | ចេត | *ចិត្ត* |
| តប | *កម្តៅ, ភាពក្តៅ* | តម | *ភាពងងឹត* |
| តេជ | *ភ្លើង, តេជ:* | បយ | *ទឹកដោះ* |
| វច | *សម្តី, វាចា* | វយ | *ជំនាន់, វ័យ* |
| សិរ | *ក្បាល, សិរ* | យស | *កេរ្តិ៍ឈ្មោះ, យស* |

# វិភត្តិសម្រេចរូបនៃមនោគណាស័ព្ទ

## បុំលិង្គ

| វិភត្តិ | ឯក. | ពហុ. |
|---|---|---|
| ប. | ឱ | អា |
| ទុ. | អំ, | ឯ |
| ត. | អា | ឯហិ, ឯភិ |
| ច. | ឱ | អានំ |
| បញ្ច. | អា | ឯហិ, ឯភិ |
| ឆ. | ឱ | អានំ |
| ស. | ឥ, អស្មឹ | ឯសុ |
| អា. | អ, ឱ | អា |

## នបុំសកលិង្គ

| វិភត្តិ | ឯក. | ពហុ. |
|---|---|---|
| ប. | អំ | អានិ |
| ទុ. | អំ | អានិ |

*ចាប់ពីតតិយាដល់អាលបនវិភត្តិដូចគ្នានឹងបុំលិង្គទាំងអស់ ។*

# វិធីបំបែក មន ជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មនោ | មនា |
| ទុ. | មនោ, មនំ | មនេ |
| ត. | មនសា | មនេហិ, មនេភិ |
| ច. | មនសោ | មនានំ |
| បញ្ច. | មនសា | មនេហិ, មនេភិ |
| ឆ. | មនសោ | មនានំ |
| ស. | មនសិ, មនស្មឹ | មនេសុ |
| អា. | មន | មនា |

# វិធីបំបែក មន ជានបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មនំ | មនានិ |
| ទុ. | មនំ | មនានិ |

ចាប់ពីតតិយាដល់អាលបនវិភត្តិដូចគ្នានឹងបុំលិង្គទាំងអស់ ។

# កំណត់សម្គាល់

១. ពាក្យថា **មន** ប្រែថា "ចិត្ត" ជា អ ការន្តបុំលិង្គនិងនបុំសក-លិង្គ ។ សូមសង្កេតមើលក្នុងវិភត្តិជាច្រើនមានចុះ ស អាគមផងដែរ ។

ចាប់ពី **ឱរ** ដល់ **យស** ជាបុំលិង្គតែម្យ៉ាងប៉ុណ្ណោះ ។ វិធីបំបែកមានគតិដូច **បុរិស** និង **កុល** ស័ព្ទដែរ ប៉ុន្តែមានប្លែក ៥ វិភត្តិគឺពីតតិ-យាវិភត្តិដល់សត្តមីវិភត្តិខាងឯកវចនៈត្រូវចុះ ស អាគមទៅជា **មនស**, **អយស**, **ឱរស** ។ល។ សិនទើបបំបែករួមជាមួយវិភត្តិសម្រេច ។

២. **មន** ស័ព្ទដែលបំបែកពុំចាំបាច់ចុះ ស អាគមមាន ៣ វិភត្តិ គឺ បឋមា, ទុតិយា, អាលបនវិភត្តិខាងឯកវចនៈនិងពហុវចនៈទាំងអស់ ។

៣. ទុតិយាវិភត្តិឯកវចនៈអាចផ្លាស់ទីបំផុតស័ព្ទជា **ឱ** បានខ្លះនេះសម្រាប់តែមនោគណស័ព្ទប៉ុណ្ណោះ ។ ខាងក្រោមជាឧទាហរណ៍នៃការប្រើក្នុងប្រយោគ

**អធាតេ កុរុតេ <u>មនោ</u> (ជនោ) ។**

(ជន) តែងធ្វើ <u>នូវចិត្ត</u> ក្នុងកិរិយាមិនឱ្យ ។

**<u>យសោ</u> លទ្ធា ន មជ្ជេយ្យ (ជនោ) ។**

(ជន) បានហើយ <u>នូវយស</u> មិនគប្បីស្រវឹង ។

**ត្វំ មហាជនំ ទានេ <u>មនំ</u>/មនោ ការាបេហិ ។**

លោក ញុំាងមហាជន ឱ្យធ្វើ <u>នូវចិត្ត</u> ក្នុងទាន ។

៤. សត្តមីវិភត្តិឯកវចនៈបើចុះ **ស** អាគមហើយ ត្រូវផ្លាស់ **ស្មឹ** ជា **ឥ** ជា **មនសិ**, បើមិនចុះ **ស** អាគមទេ ត្រូវរក្សា **ស្មឹ** ឱ្យនៅដូចដើម ជា **មនស្មឹ** ។ នេះប្រាកដមាននៅក្នុង អាទិត្តបរិយាយសូត្រថា **មនស្មឹបិ និព្វិន្ទតិ** =នឿយណាយ ទាំងក្នុងចិត្ត ។

៥. ក្រុមមនោគណស័ព្ទទាំង ១២ ដែលពោលហើយនេះ ប្រសិនបើប្រើជាបទសមាសជាមួយស័ព្ទផ្សេង ៗ ទៀតនិងដែលពួកមនោគណៈនេះជាបទខាងដើម គឺត្រូវបំបែកឱ្យមានទីបំផុតជា **ឱ** ជានិច្ចដូចខាងក្រោមនេះ

**មន + គណ > មនោគណ** = ក្រុមនៃមនៈ ។

**មន + មយ > មនោមយ** = ធម្មជាតិដែលសម្រេចហើយដោយចិត្ត ។

**អយ + មយ > អយោមយ** = វត្ថុដែលគេធ្វើដោយដែក ។

**តេជ + ធាតុ > តេជោធាតុ** = ធាតុគឺភ្លើង(ធាតុភ្លើង), តេជោធាតុ ។

**បយ + ធាន > បយោធាន** = ទឹកគឺទឹកដោះ ។

**ចេត + បរិញ្ញាណ > ចេតោបរិញ្ញាណ** = សេចក្ដីដឹងដោយចិត្ត ។

៦. ស័ព្ទក្រៅពីមនោគណខ្លះទៀត វេលាផ្សំជាបទសមាសលោកឱ្យបំបែកជា **ឱ** បានដែរគឺ **អហ** (ថ្ងៃ), **វាយ** (ខ្យល់), **អាប** (ទឹក), **សរទ** (រដូវស្លឹកឈើជ្រុះ), **រជ** (ធូលី, លំអង) ដូចជា

**អហ + រត្តិ > អហោរត្ត** = ថ្ងៃនិងយប់ (លុប **ឥ**) ។

**អាប + ធាតុ > អាបោធាតុ** = ធាតុគឺទឹក ។

**វាយ** + **ធាតុ** > **វាយោធាតុ** = *ធាតុគឺខ្យល់* ។

**រជ** + **ជល** > **រជោជល** = *ធូលីនិងទឹក (ភក់)* ។

**អាប** + **សម** > **អាបោសម** = *ស្មើដោយទឹក* ។

**សារទ** + **សមយ** > **សារទោសមយ** = *វេលាស្លឹកឈើជ្រុះ* ។

*៧. សព្ទខ្លះទៀតមានទីបំផុតជា អ ការន្ត ទោះជាមនោគណក្តីឬ មិនមែនក្តី លោកឱ្យបំបែកសព្ទទាំងនេះជា* **សោ** *បានពីរវិភត្តិគឺ*

| | | | | | |
|---|---|---|---|---|---|
| **សុត្ត** | នបុំ. | *សូត្រ* | **ឋាន** | នបុំ. | *ទីតាំង,ទីឋាន* |
| **ព្យញ្ជន** | នបុំ. | *ព្យញ្ជនៈ* | **ថាម** | បុំ. | *កម្លាំង* |
| **អក្ខរ** | នបុំ. | *អក្សរ* | **ឧរ** | បុំ.,នបុំ. | *ទ្រូង* |
| **សព្វ** | សព្វ. | *ទាំងពួង* | **ទីឃ** | គុ.,បុំ. | *វែង, យូរ* |
| **បទ** | នបុំ. | *សំដី, បទ* | **អត្ថ** | បុំ. | *ប្រយោជន៍* |
| **ឧបាយ** | បុំ. | *មាយា, ឧបាយ* | **ឆន្ទ** | បុំ. | *សេចក្តីប្រាថ្នា* |

*៧.១ តតិយាវិភត្តិឯកវចនៈអាចផ្លាស់* **នា** > **សោ** *ប្រើអាយត-និបាតប្រែថា "ដោយ" ឧ.* **សុត្តសោ** =*ដោយសូត្រ*, **ព្យញ្ជនសោ** = *ដោយព្យញ្ជនៈ*, **ឧបាយសោ** =*ដោយឧបាយ*, **សព្វសោ** =*ដោយ... ទាំងពួង*, **ឋានសោ** =*ដោយឋាន*, **ថាមសោ** =*ដោយកម្លាំង* (**ថាម** = *កម្លាំង*) ។

*៧.២ បញ្ចមីវិភត្តិឯកវចនៈអាចផ្លាស់* **ស្មា** > **សោ** *ប៉ុន្តែបានតែ* **ទីឃ** *និង* **ឧរ** *ពីរសព្ទប៉ុណ្ណោះ ប្រើអាយតនិបាតថា "ពី" ឧ.* **ទីឃសោ** =

ពីផ្នែកវែង, **ឱរសោ** =ពីទ្រូង ។

៧.៣ មានស័ព្ទជា អ ការន្តខ្លះទៀតដែលអាចបំបែកត្រង់តតិយា និងបញ្ចមីវិភត្តិឯកវចនៈផ្លាស់ **នា**, **ស្មា** > **សា** និងសត្តមីវិភត្តិឯកវចនៈ **ស្មឹ** > **សិ** គឺ **ពិល** នបុំ. រន្ធ, **បទ** បុំ. ជើង ទៅជា **ពិលសា**, **ពិលសិ**, **បទសា**, **បទសិ** ជាដើម ។

## វិធីប្រែមនោគណស័ព្ទក្នុងប្រយោគ

**មន** ស័ព្ទដែលបំបែកជាតតិយាវិភត្តិឯកវចនៈក្នុងរូបជា **មនសា** មានវិធីប្រែបានពីរយ៉ាងគឺ

១. ប្រែថា "មាន" ក្នុងករណីដែលសម្ព័ន្ធចូលជាមួយបទប្រធានរបស់ប្រយោគដែលជាតួកត្តា ហៅតាមសម្ព័ន្ធថា **ឥត្ថម្ភូត** ឧ.

**<u>មនសា</u> ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា (បុគ្គលោ).......។**

ប្រសិនបើ (បុគ្គល) <u>មានចិត្ត</u> ត្រូវទោសប្រទូស្តហើយ និយាយក្តី ឬធ្វើក្តី...... ។

២. ប្រែថា "ដោយ" ក្នុងករណីដែលសម្ព័ន្ធចូលជាមួយកិរិយាហៅតាមសម្ព័ន្ធថា **ករណៈ** ឧ.

**អហំ អត្តនោ <u>មនសា</u> ពុទ្ធស្ស ធម្មំ សល្លក្ខេមិ ។**

ខ្ញុំ តែងកំណត់ នូវធម៌ របស់ព្រះពុទ្ធអង្គ <u>ដោយចិត្ត</u> របស់ខ្លួន ។

# វិធីបំបែក កម្ម និង គោ ស័ព្ទ

បកិណ្ណកនាមស័ព្ទ **កម្ម** និង **គោ** ជាឯកស័ព្ទមិនមានពួកទេ និងមានរបៀបបំបែកដោយឡែកពីគ្នា ។

១. ពាក្យថា **កម្ម** សម្រេចមកពី **ករ** ធាតុប្រែថា "ធ្វើ", ចុះ **រម្ម** បច្ច័យក្នុងនាមកិតក: ។ បច្ច័យណាមាន **រ** ជាអនុព័ន្ធអាចឱ្យលុបទីបំផុតធាតុចេញបាន នៅសល់តែ **ក** ហើយលុប **រ** របស់បច្ច័យទៀតនៅសល់តែ **ម្ម** រួបយកមកតភ្ជាប់គ្នាទៅជា **កម្ម** (**ករ** + **រម្ម** > **កម្ម**) ប្រែថា "ការងារ, អំពើដែលត្រូវធ្វើ" ។ ពាក្យថា **កម្ម** ជា **អ** ការន្តនបុំសកលិង្គ តែម៉្យាង មានវិធីបំបែកជារូបផ្សេង ៗ តាមវិភត្តិសម្រេចរូបរបស់ **អ** ការន្តនបុំសកលិង្គដូច **កុល** ក៏បាន ។ ប៉ុន្តែមិននិយមប្រើ គប្បីបំបែកតាមវិភត្តិសម្រេចរូបខាងក្រោមនេះ

## វិភត្តិសម្រេចរូបរបស់ កម្ម ស័ព្ទ

| វិភត្តិ | ឯកវចន: | ពហុវចន: | វិភត្តិ | ឯកវចន: | ពហុវចន: |
|---|---|---|---|---|---|
| ប. | អំ | អានិ | បញ្ច. | ឧនា | ឯហិ, ឯភិ |
| ទុ. | អំ | អានិ | ឆ. | ឧនោ | អានំ |
| ត. | ឧនា | ឯហិ, ឯភិ | ស. | អនិ | ឯសុ |
| ច. | ឧនោ | អានំ | អា | អ | អានិ |

## វិធីបំបែក កម្ម ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កម្មំ | កម្មានិ |
| ទុ. | កម្មំ | កម្មានិ |
| ត. | កម្មុនា | កម្មេហិ, កម្មេភិ |
| ច. | កម្មុនោ | កម្មានំ |
| បញ្ច. | កម្មុនា | កម្មេហិ, កម្មេភិ |
| ឆ. | កម្មុនោ | កម្មានំ |
| ស. | កម្មានិ | កម្មេសុ |
| អា. | កម្ម | កម្មា |

២. ពាក្យថា **គោ** ប្រែត្រាប់ស័ព្ទថា គោ ជាពាក្យមិនប្រាប់ឱ្យដឹងថាជាលិង្គអ្វីទេ គឺជាទ្វិលិង្គ ។ ដើម្បីឱ្យដឹងថាជាលិង្គអ្វី ក្នុងសេចក្តីថាបើចង់ឱ្យច្បាស់ជាបុំលិង្គ (គោឈ្មោល) ត្រូវផ្លាស់ **គោ** > **គោណ** ជា អ ការន្ត មានវិធីបំបែកក្នុងវិភត្តិផ្សេង ៗ ដូច **បុរិស** ។ ប្រសិនបើជាឥត្ថីលិង្គ (គោញី) វិញ ត្រូវផ្លាស់ **គោ** > **គាវ** និងចុះ **ឦ** បច្ច័យគ្រឿងសំគាល់ឥត្ថីលិង្គទៅជា **គាវី** បំបែកជារូបផ្សេង ៗ ដូច **នារី** ។

## វិភត្តិសម្រេចរូបនិងវិធីបំបែកនៃ គោ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឱ | ឱ |
| ទុ. | អំ, ឧំ | ឱ |
| ត. | ឯន | ឯហិ, ឯភិ, ហិ, ភិ |
| ច. | អស្ស | អានំ, ឱនំ, ឧន្នំ |
| បញ្ច. | អស្មា, អម្ហា, អា | ឯហិ, ឯភិ, ហិ, ភិ |
| ឆ. | អស្ស | អានំ, ឱនំ, ឧន្នំ |
| ស. | អស្មឹ, អម្ហិ, ឯ | ឯសុ, សុ |
| អា. | អ | ឱ |

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | គោ | គាវោ |
| ទុ. | គាវំ, គាវុំ | គាវោ |
| ត. | គាវេន | គាវេហិ, គាវេភិ, គោហិ, គោភិ |
| ច. | គាវស្ស | គាវានំ, គោនំ, គុន្នំ |
| បញ្ច. | គាវស្មា, គាវម្ហា, គាវា | គាវេហិ, គាវេភិ, គោហិ, គោភិ |
| ឆ. | គាវស្ស | គាវានំ, គោនំ, គុន្នំ |
| ស. | គាវស្មឹ, គាវម្ហិ, គាវេ | គាវេសុ, គោសុ |
| អា. | គាវ | គាវោ |

## កំណត់សម្គាល់

១. គោ ស័ព្ទកាលបើប្រើជាបទសមាស ត្រូវទុកឱ្យនៅតាមរូបដើម ឧ. គោបាល =អ្នកចិញ្ចឹមគោ, អ្នករក្សាគោ, គោបតិ =ម្ចាស់នៃគោ ជាដើម ។

២. គោ ស័ព្ទកាលបើផ្លាស់ជា គវ វិញមានវិធីបំបែកដូច បុរិស គ្រប់វិភត្តិជាពិសេសឆដ្ឋីវិភត្តិពហុវចនៈផ្លាស់ ណំ ជា អំ បាន មានរូបជា គវំ =របស់គោ, នៃគោ ។

វេលាផ្សំជាបទសមាសដែលមាន បតិ ជាបទខាងចុង ត្រូវផ្លាស់និគ្គហិតលើ វ ជា ម ឧ. គវំ + បតិ > គវម្បតិ =ម្ចាស់នៃគោ.ទ. (ដោយយោងតាមក្បួនព្យញ្ជនសំយោគ) ។

## ប្រយោគឧទាហរណ៍

**បុគ្គលោ អត្តនោ <u>កម្មុនោ</u> វិបាកំ អនុភោតិ ។**

*បុគ្គល រមែងសោយ នូវផល <u>នៃកម្ម</u> របស់ខ្លួន ។*

**បញ្ច <u>គាវោ</u> មេ អត្ថិ ទ្វេ គោណា, តិស្សោ គាវិយោ ។**

*គោ.ទ. ប្រាំក្បាល ជារបស់ខ្ញុំ, គោ.ទ. ពីរក្បាល ជាគោឈ្មោល គោ.ទ. បីក្បាល ជាគោញី ។*

***ខ្មែរថា*** *ខ្ញុំមានគោប្រាំក្បាល, គោឈ្មោលពីរក្បាលនិងគោញីបីក្បាល ។*

# វិធីប្រកបនាមសព្ទជាឥត្ថីលិង្គ

នាមសព្ទឥត្ថីលិង្គខ្លះអាចប្រកបរូបពីនាមសព្ទដែលជាបុំលិង្គដោយចុះបច្ច័យនានាគឺ **អា**, **ឥកា**, **ឦ**, **នី**, **ឥនី**, **អានី**, **តី**, **ឥកិនី** ។

១. បើនាមសព្ទបុំលិង្គជា អ ការន្តចុះ **អា**, **ឦ**, **ឥនី** បច្ច័យដូចជា

| បុំលិង្គ | ពាក្យប្រែ | ឥត្ថីលិង្គ | ពាក្យប្រែ |
|---|---|---|---|
| អជ | ពពែឈ្មោល | អជា | ពពែញី |
| អស្ស | សេះឈ្មោល | អស្សា | សេះញី |
| មូសិក | កណ្ដុរឈ្មោល | មូសិកា | កណ្ដុរញី |
| ទេវ | ទេវតាប្រុស | ទេវី | ទេវតាស្រី |
| ទាស | ខ្ញុំបំរើប្រុស | ទាសី | ខ្ញុំបំរើស្រី |
| នរ | ប្រុស | នារី | នារី |
| មនុស្ស | មនុស្សប្រុស | មនុស្សី | មនុស្សស្រី |
| មាណវ | ប្រុសកម្លោះ | មាណវី | ស្រីក្រមុំ |
| កុមារ | ក្មេងប្រុស | កុមារី | ក្មេងស្រី |
| រាជ | ស្ដេចប្រុស | រាជិនី | ស្ដេចស្រី |
| យក្ខ | យក្សប្រុស | យក្ខិនី | យក្សស្រី |

២. បើនាមសព្ទបុំលិង្គមានទីបំផុតជា **អក**, **ឥក** ត្រូវចុះ **ឥកា** បច្ច័យដូចជា

| បុំលិង្គ | ពាក្យប្រែ | ឥត្ថីលិង្គ | ពាក្យប្រែ |
|---|---|---|---|
| ឧបាសក | ឧបាសក | ឧបាសិកា | ឧបាសិកា |
| ទារក | ក្មេងប្រុស | ទារិកា | ក្មេងស្រី |
| បរិព្វាជក | បរិព្វាជក | បរិព្វាជិកា | បរិព្វាជិកា |
| នាវិក | នាវិកប្រុស | នាវិកា | នាវិកស្រី |
| ញាតក | ប្រុសជាញាតិ | ញាតិកា | ស្រីជាញាតិ |

៣. បើនាមស័ព្ទបុំលិង្គមានទីបំផុតជា **ឥ**, **ឦ** ការន្តនិង **អារ**, **អារី** បច្ច័យត្រូវចុះ **ឥនី** ដូចជា

| បុំលិង្គ | ពាក្យប្រែ | ឥត្ថីលិង្គ | ពាក្យប្រែ |
|---|---|---|---|
| មេធាវី | អ្នកប្រាជ្ញប្រុស | មេធាវិនី | អ្នកប្រាជ្ញស្រី |
| អាចរិយ | គ្រូប្រុស | អាចរិនី❁ | គ្រូស្រី |
| កុម្ភការ | ស្មូនឆ្នាំងប្រុស | កុម្ភការិនី | ស្មូនឆ្នាំងស្រី |
| ព្រហ្មចារី | អ្នកបួសប្រុស | ព្រហ្មចារិនី | អ្នកបួសស្រី |

❁ លុប យ នៃ អាចរិយ ចេញ ។

៤. បើនាមស័ព្ទបុំលិង្គមានទីបំផុតជា **ឥ**, **ឧ** ការន្តចុះ **នី** បច្ច័យដូច

| បុំលិង្គ | ពាក្យប្រែ | ឥត្ថីលិង្គ | ពាក្យប្រែ |
|---|---|---|---|
| ហត្ថិ | ដំរីឈ្មោល | ហត្ថិនី | ដំរីញី |
| ភិក្ខុ | ភិក្ខុ | ភិក្ខុនី | ភិក្ខុនី |

៥. មាននាមស័ព្ទខ្វះជា អ, ឥ ការន្តតែត្រូវចុះ **អានី** បច្ច័យដូចជា

| បុំលិង្គ | ពាក្យប្រែ | ឥត្ថីលិង្គ | ពាក្យប្រែ |
|---|---|---|---|
| **មាតុល** | មា(ខាងម្ដាយ) | **មាតុលានី** | មីង(ខាងម្ដាយ) |
| **គហបតិ** | គហបតីប្រុស | **គហបតានី** | គហបតីស្រី |
| **អាចរិយ** | គ្រូប្រុស | **អាចរិយានី** | គ្រូស្រី |
| **ខត្តិយ** | ក្សត្រប្រុស | **ខត្តិយានី** | ក្សត្រស្រី |
| **វរុណ** | នាមព្រះវរុណ | **វរុណានី** | នាមព្រះវរុណ |

៦. ចំពោះ **យុវ** និងស័ព្ទដែលមានទីបំផុតជា **-វន្តុ**, **-មន្តុ** បច្ច័យ ចុះ **តី**❁ បច្ច័យដូចជា

| បុំលិង្គ | ពាក្យប្រែ | ឥត្ថីលិង្គ | ពាក្យប្រែ |
|---|---|---|---|
| **យុវា** | ប្រុសកម្លោះ | **យុវតី** | ស្រីក្រមុំ |
| **គុណវា**❁ | ប្រុសអ្នកមានគុណ | **គុណវតី** | ស្រីអ្នកមានគុណ |
| **សីលវា** | ប្រុសអ្នកមានសីល | **សីលវតី** | ស្រីអ្នកមានសីល |
| **សតិមា**❁ | ប្រុសអ្នកមានសតិ | **សតិមតី** | ស្រីអ្នកមានសតិ |

❁តាមក្បួនវេយ្យាករណ៍ឱ្យផ្លាស់ **-ន្តុ** ជា **ត** រួចចុះ **ឦ** បច្ច័យ ប៉ុន្តែក្នុងទីនេះដើម្បីឱ្យងាយស្រួលដល់អ្នករៀនដំបូង ឱ្យលុប **-ន្តុ** ចេញរួចចុះ **តី** តែម្ដង ។ សូមរកមើលវិធីបំបែកស័ព្ទដែលចុះ **-វន្តុ**, **-មន្តុ** បច្ច័យក្នុងមេរៀនទី ២៤ បន្ថែមផង ។

# នាមស័ព្ទ អា ការន្តជាបុំលិង្គ

ដូចបានពោលរួចហើយថានាមស័ព្ទដែលជាបុំលិង្គមិនមានជា អា ការន្តទេ ប៉ុន្តែក្នុងភាសានីមួយ ៗ តែងមានការលើកលែងជានិច្ច ។ ក្នុងភាសាបាលីនាមស័ព្ទបុំលិង្គដែលជា អា ការន្តមានខ្លះដែរគឺ សា, មា ។

## វិធីបំបែក សា =ឆ្កែ, សុនខ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សា | សានោ, សា |
| ទុ. | សានំ | សានេ |
| ត. | សានា | សានេហិ, សានេភិ |
| ច. | សាស្ស | សានំ |
| បញ្ច. | សានា | សានេហិ, សានេភិ |
| ឆ. | សាស្ស | សានំ |
| ស. | សានេ | សានេសុ |
| អា. | សា | សានោ, សា |

មា =(ព្រះច័ន្ទ) ច្រើនប្រើជាបទសមាសដូចជា ចន្ទិមា =ព្រះច័ន្ទ, បុណ្ណមា =ព្រះច័ន្ទពេញបូណ៌មី ។

## នាមស័ព្ទមានរូបជាបុំលិង្គ តែអត្ថជាឥត្ថីលិង្គ

*នាមស័ព្ទខ្លះមានរូបជា អ ការន្តបុំលិង្គទេ ប៉ុន្តែមានអត្ថជាឥត្ថីលិង្គវិញ ។ ក្នុងភាសាបាលីហៅលិង្គរបស់នាមស័ព្ទប្រភេទនេះថា សម្មតិលិង្គ ដូចជា* **មាតុគាម** *=ស្ត្រី, មាតុគ្រាម (ស្រីមានស្រុកដូចស្រុកនៃម្តាយ),* **ទារ** *=ភរិយា,* **ឱរោធ** *=ស្រីស្នំ ។*

*បីស័ព្ទនេះមានវិធីបំបែកតាមបែប* **បុរិស** *គ្រប់វិភត្តិ សូមរកមើលវិធីបំបែកនៅក្នុងភាគ ១ ។*

## បធាននយកិរិយា

**បធាននយកិរិយា** *បានដល់ កិរិយាស័ព្ទណាដែលចុះ* **ត្វាទិ** *បច្ច័យដូចអព្យយកិរិយាដែរ ប៉ុន្តែខុសគ្នាត្រង់ថាអព្យយកិរិយាមានបទប្រធានតែមួយជាឯកវចនៈក៏បាន ជាពហុវចនៈក៏បានដែលធ្វើអំពើមួយចំនួនបន្តបន្ទាប់គ្នា ។ រីឯបធាននយកិរិយាវិញ មានបទប្រធានពីរផ្សេងគ្នា គឺថាក្នុងប្រយោគនោះ ៗ មានពីរសង្កាត់ ។ ក្នុងសង្កាត់ខាងដើមមានបទប្រធានជាពហុវចនៈ ចំណែកសង្កាត់ខាងចុងមានបទប្រធានជាឯក-វចនៈវិញ ។ បទប្រធាននេះទៀតសោត គឺដកយកចេញមកពីបណ្តាបទប្រធានដែលជាពហុវចនៈនោះ ។ ប៉ុន្តែកុំច្រឡំនឹងអព្យយកិរិយាដែលប្រើជាហេតុកាល (សូមរកមើលក្នុងមេរៀនទី ២០ ភាគ ១) ។*

១. ខាងក្រោមនេះជាឧទាហរណ៍នៃអព្យយកិរិយា

**តុម្ហេ អត្រ អាគន្ត្វា បចិត្វា ភុញ្ជិត្វា អជ្ជ ឥធ សយិត្វា សុវេ តត្ថ គច្ឆេយ្យាថ ។**

*អ្នក.ទ. មកហើយ កាន់ទីនេះ ចម្អិនហើយ បរិភោគហើយ ក្នុងថ្ងៃនេះ ដេកហើយ ក្នុងទីនេះ, (អ្នក.ទ.) គប្បីទៅ កាន់ទីនោះ ក្នុងថ្ងៃស្អែក ។*

*ក្នុងប្រយោគនេះបញ្ជាក់ឱ្យឃើញថាមានពីរសង្កាត់ដែរ គឺសង្កាត់ខាងដើមចាប់ពី* **តុម្ហេ** *ដល់* **សយិត្វា** *និងសង្កាត់ខាងចុងពី* **សុវេ** *ដល់* **គច្ឆេយ្យាថ** *ប៉ុន្តែមានបទប្រធានតែមួយប៉ុណ្ណោះគឺ* **តុម្ហេ** *ធ្វើអំពើជាប់បន្តគ្នា បែបនេះហៅថា* **អព្យយកិរិយា** *។*

*២. ខាងក្រោមនេះជាឧទាហរណ៍នៃបធាននយកិរិយា*

**តេ ភិរ ទ្វេ សហាយកា ធម្មស្សវនត្ថាយ គច្ឆន្តេន មហា-ជនេន សទ្ធឹ ជេតវនំ គន្ត្វា ឯកោ ធម្មកថំ អស្សោសិ ។**

*បានឮថា សំឡាញ់ទាំងឡាយ ពីរនាក់នោះ ទៅហើយ កាន់វត្តជេតវ័ន មួយអន្លើ ដោយមហាជន កាលទៅ ដើម្បីប្រយោជន៍ដល់កិរិយាស្តាប់នូវធម៌ សំឡាញ់ម្នាក់ បានស្តាប់ហើយ នូវធម្មកថា ។*

*ក្នុងប្រយោគនេះក៏បញ្ជាក់ឱ្យឃើញថាមានពីរសង្កាត់ដែរ សង្កាត់ខាងដើមចាប់ពី* **តេ ភិរ** *ដល់* **គន្ត្វា** *និងសង្កាត់ខាងចុងពី* **ឯកោ** *ដល់* **អស្សោសិ** *។ ប៉ុន្តែមានបទប្រធានពីរ គឺខុសពីប្រយោគទីមួយដែលមាន*

បទប្រធានតែមួយបទ ព្រោះបទប្រធាន **តេ** ជាប្រធានរបស់បធាននយ-កិរិយា **គន្ត្វា** ប៉ុណ្ណោះ ។ រីឯ **អស្សោសិ** មានបទប្រធានគឺ **ឯកោ** វិញ បែបនេះហៅថា **បធាននយកិរិយា** ។ សូមអ្នកសិក្សាជ្រាបតាមនេះផងចុះ ។ ហេតុដែលកិរិយាចុះត្វាបច្ច័យប្រើគ្រងប្រយោគដូច្នេះបាន ពីព្រោះកិរិយាអាខ្យាតមិនអាចប្រើខាងក្នុងប្រយោគបាន ។

## អព្ភន្តរកិរិយា

**អព្ភន្តរកិរិយា** បានដល់ កិតកិរិយាដែលចុះបច្ច័យ ៣ តួគឺ **អន្ត**, **មាន**, **ត** បច្ច័យនិងដែលនិយមរៀងខាងក្រោយបទនាមនាមជាប្រធាន ហើយនឹងត្រូវមានលិង្គ វចនៈ, វិភត្តិស្មើគ្នានឹងនាមនាមជាប្រធាន (វិធីបំ-បែកតាមវិភត្តិនោះ ៗ សូមរកមើលក្នុងមេរៀនខាងដើម) ដូចឧទាហរណ៍ខាងក្រោមនេះ

**១. ឧបាសកោ បទុមានិ អាទាយ វិហារំ <u>គច្ឆមានោ</u> ពុទ្ធំ ទិស្វា បសីទតិ ។** (**គម + មាន** បច្ច័យ) ។

ឧបាសក កាន់យកហើយ នូវផ្កាឈូក.ទ. <u>កាលទៅ</u> កាន់ព្រះវិហារ កំពុងជ្រះថ្លា ព្រោះឃើញហើយ នូវព្រះពុទ្ធ ។

**២. សកុណោ តុណ្ឌេន ផលំ <u>ហរន្តោ</u> រុក្ខស្មា ឧប្បតតិ ។** (ហរ + អន្ត បច្ច័យ) ។

*សត្វបក្សី <u>កាលពាំ</u> នូវផ្លែឈើ ដោយចំពុះ ហើរឡើង ចាកដើមឈើ ។*

៣. **ឯកោ វាណិជោ មញ្ជូសាសុ ធុស្សានិ <u>ឋបិតោ</u> តានិ ន វិក្កិណិស្សតិ** ។ (ឋា + ឥ + ត បច្ច័យ) ។

*ឈ្មួញ ម្នាក់ <u>ដាក់ហើយ</u> នូវសំពត់.ទ. ក្នុងហិប.ទ. នឹងមិនលក់ នូវសំពត់.ទ.នោះទេ ។*

៤. **អហំ មគ្គេ <u>គច្ឆន្តោ</u> តស្មឹ រុក្ខេ និសន្នំ សកុណំ បស្សឹ** ។ (**គម + អន្ត** *បច្ច័យ*) ។

*ខ្ញុំ <u>កាលទៅ</u> ក្នុងផ្លូវ ឃើញហើយ នូវបក្សី ដែលទុំហើយ លើដើមឈើ នោះ ។*

## ឥត្ថម្ភូតកិរិយា

**ឥត្ថម្ភូតកិរិយា** *បានដល់ កិរិយាមួយប្រភេទក្នុងពួកកិតកិរិយា ដែលចុះ* **អន្ត មាន ត** *បច្ច័យដែរ ដែលត្រូវបំបែកជាតតិយាវិភត្តិ ទាំងកិតកិរិយានិងទាំងនាមនាមជាប្រធាន ព្រមទាំងឱ្យមានលិង្គ, វចនៈស្មើគ្នាជានិច្ចផង ។ បទនាមជាប្រធាននោះ ៗ ត្រូវប្រែថា "មាន......" ដូចឧទាហរណ៍ខាងក្រោមនេះ*

**សា ធាសី <u>ភិន្នេន</u> សីសេន លោហិតេន <u>បគ្ឃរន្តេន</u> បដិវិស្ស-**

**កាកំ ឧជ្ឈាបេសិ*** ។

*ខ្ញុំបម្រើស្រី នោះ មានក្បាល <u>បែកហើយ</u> មានឈាម <u>កាលហូរចេញ</u> ញ៉ាំងអ្នកជិតជិត.ទ. ឱ្យពិនិត្យហើយ ។*

**ឧទាហរណ៍នេះដកស្រង់ពីសៀវភៅ សម្ពន្ធមាលា របស់លោកគ្រូ អ៊ុក ជា ទំព័រ ១៨៣ លោកប្រែ* **ឧជ្ឈាបេសិ** *ថា "ឱ្យ(រត់)ខ្វាត់ខ្វាយហើយ" ។ ប៉ុន្តែក្នុងបទានុក្រមនិងវចនានុក្រមប្រែថា "ឱ្យលើកទោស, ឱ្យពិនិត្យ, ឱ្យបារម្ភ ។ល។"*

## អនាទរកិរិយា

**អនាទរកិរិយា** *បានដល់ កិរិយាមួយប្រភេទក្នុងពួកកិតកិរិយា ដែលចុះ* **អន្ត មាន ត** *បច្ច័យដែរ ដែលត្រូវបំបែកជាឆដ្ឋីឬសត្តមីវិភត្តិ ទាំងកិតកិរិយាទាំងនាមនាមជាប្រធាន ព្រមទាំងឱ្យមាន លិង្គ, វចនៈស្មើគ្នាជានិច្ច ។ បទនាមជាប្រធាននោះ ៗ ត្រូវប្រែថា "កាល...", "កាលបើ...", "កាលដែល..." ដូចឧទាហរណ៍ខាងក្រោមនេះ*

**១. <u>រុទមានស្ស</u> បុត្តស្ស មាតា គាមស្មា និក្ខមិ ។**

*កាលដែលកូន <u>កំពុងយំ</u> ម្ដាយ ចេញហើយ ពីផ្ទះ ។*

**២. ទាយកស្ស ទឡ្ហំ ទានំ <u>ទទមានស្ស</u> តំ ទឡ្ហមេវ ផលំ ទទាតិ ។**

*កាលបើទាយក <u>ឱ្យ</u> នូវទាន យឺតយូរ ទាននោះ នឹងឱ្យ នូវផល យឺតយូរដែរ ។*

៣. ទុក្ខស្មឹ ចារតោ បព្វជិ ។

*កាលក្មេង កំពុងយំ គាត់បួសហើយ ។*

## លក្ខណកិរិយា

**លក្ខណកិរិយា** *បានដល់ កិរិយាមួយប្រភេទក្នុងពួកកិត-កិរិយាដែលចុះ អន្ត, មាន, ត បច្ច័យដែរ ដែលត្រូវបំបែកជាសត្តមីវិភត្តិ ទាំងកិតកិរិយាទាំងនាមនាមជាប្រធាន និងព្រមទាំងឱ្យមានលិង្គ, វចនៈ ស្មើគ្នាជានិច្ច ។ បទនាមជាប្រធាននោះ ៗ ត្រូវប្រែថា "នាកាល..." "កាលបើ...", "កាលដែល..." ដូចឧទាហរណ៍ខាងក្រោមនេះ*

១. មយិ គតេ សោ អាគតោ ។

*នាកាលខ្ញុំ ទៅហើយ គាត់ មកដល់ ។*

២. សព្វេ មគ្គា វិវជ្ជន្តិ គច្ឆន្តេ លោកនាយកេ ។

*កាលបើអ្នកនាំនូវសត្វលោក(=ព្រះពុទ្ធ) យាងទៅ សព្វសត្វទាំងពួង វៀរចេញ ពីមាគ៌ា ។*

៣. ភិក្ខុសង្ឃេសុ បូជិយមានេសុ គតោ ។

*នាកាលភិក្ខុសង្ឃ.ទ. (គឺឧបាសក) កំពុងបូជា (=កំពុងប្រគេនចង្ហាន់) (គេ) ទៅហើយ ។*

៤. មាតាបិតូសុ <u>រុទន្តេសុ</u> បព្វជិ ។

*កាលឪពុកនិងម្តាយ <u>កំពុងយំ</u> (កូន) បួសហើយ ។*

៥. កស្សកោ ហិ ខេត្តេ <u>កដ្ឋេ</u>(=កសិតេ) គហបតិនោ សេវកោ អាគន្ត្វា តិលេហិ វបឹសុ ។

*នាកាលស្រែ គឺកសិករ.ទ. <u>ភ្ជួរហើយ</u> ខ្ញុំបំរើ.ទ. របស់គហបតី មក ហើយ សាបហើយ នូវល្ង.ទ. ។*

## នាមស័ព្ទ (ត)

| | | | | | |
|---|---|---|---|---|---|
| សំវរ | បុំ. | *ការសង្រួម* | បទីប | បុំ. | *ចង្កៀង, ប្រទីប* |
| វិបស្សនា | ឥ. | *វិបស្សនា* | តប | បុំ. | *ការដុតកិលេស* |
| ភិត្តិ | ឥ. | *ជញ្ជាំង* | សម្មជ្ជនី | ឥ. | *អំបោស* |
| តបស្សី | បុំ. | *អ្នកមានតបៈ* | មល | នបុំ. | *ច្រែះ* |
| អបាយ | បុំ. | *នរក, អបាយ* | អវិទូរ | គុ. | *ជិត, ក្បែរ* |
| អង្គណ | នបុំ. | *ទីធ្លា, ទីលាន* | វិនា | និ. | *វៀរ, គ្មាន* |
| ទាឡិទ្ទិយ | នបុំ. | *ភាពក្រីក្រ* | រហោ | និ. | *ទីកំបាំង, ទីស្ងាត់* |

## ធាតុស័ព្ទ (ត)

| | | | |
|---|---|---|---|
| **វឌ្ឍ** | ចម្រើន, រុងរឿង | **បីឡ** | បៀតបៀន |
| **សប្ប** | វារ, លូន | **ជុត** | ភ្លឺ, រុងរឿង |
| **តប** | ដុតកម្តៅ, ចាំងពន្លឺ | **តុស** | ត្រេកអរ |
| **កិលិស** | សៅហ្មង | **សំ+ឧ+ហា** | តាំងឡើង, កើត |
| **មិលេ** | ស្រពោន, ស្វិត | **វិ + កាស** | រីក |
| **សំ + មជ្ជ** | បោស | **អន្តរ + ធេ** | បាត់ទៅ, សូន្យទៅ |
| **បរិ + កិរ** | ខ្ចាត់ខ្ចាយ | **បរិ + សុធ** | សម្អាត, បន្សុទ្ធ |
| **ឧ + ហា** | តាំងឡើង, ក្រោក | **ឧប + បជ** | ទៅកើត |

## លំហាត់នៃមេរៀនទី ២៦

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើមនោគណស័ព្ទមានប៉ុន្មានស័ព្ទ គឺស័ព្ទអ្វីខ្លះ ?

២. តើមនោគណស័ព្ទអាចប្រព្រឹត្តទៅបានប៉ុន្មានលិង្គ គឺលិង្គអ្វីខ្លះ ?

៣. តើមនោគណស័ព្ទដែលបំបែកមិនបាច់ចុះ **ស** អាគមក្នុងវិភត្តិអ្វីខ្លះ ?

៤. ប្រសិនបើប្រើជាបទសមាសតើត្រូវបំបែកមនោគណស័ព្ទដូចម្តេច ?

៥. តើមានបច្ច័យអ្វីខ្លះសម្រាប់ចុះក្នុងនាមបុំលិង្គឱ្យទៅជាឥត្ថីលិង្គ ?

៦. បើនាមជា **អក** ឬ **ឥក** តើត្រូវចុះបច្ច័យណា ? សូមឱ្យឧទាហរណ៍

៧. បើនាមជា ឥ, ឦ ការន្តនិង **អារ, អារី** ត្រូវចុះបច្ច័យណា ? សូមឱ្យឧទាហរណ៍ ។

៨. តើបធាននយកិរិយាជាកិរិយាស័ព្ទប្រភេទណា ? សូមឱ្យឧទាហរណ៍

៩. តើអព្ពន្តរកិរិយាជាកិរិយាចុះបច្ច័យអ្វីខ្លះ តើប្រើដូចម្តេច ? សូមឱ្យឧទាហរណ៍ ។

១០. តើការខុសគ្នារវាងឥត្ថម្ភូតកិរិយានិងអនាទរកិរិយា ហើយនិងលក្ខណកិរិយាដូចម្តេចខ្លះ ? សូមឱ្យឧទាហរណ៍ ។

ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. វយសា អហំ បញ្ចវីសតិ វស្សានិ ។

២. មនសា សំវរោ សាធុ ។

៣. តំ សាធុកំ សុណាហិ, មនសិ ករោហិ ។

៤. អម្ហាកំ សត្ថុនោ ចានេ មយំ សិរសា អវន្ទម្ហា ។

៥. តវ វចសា វា មនសា វា មា កិញ្ចិ ចាបកំ កម្មំ ករោតិ ។

៦. អយំ ធាវា អយសា កតា ។

៧. មយ្ហំ ភាតា គោណំ តិណ្ណំ អធា ។

៨. ពុទ្ធោ តេជសា តបតិ ។

៩. តា ភិក្ខុនិយោ មហាតា ថាមសា វិបស្សនំ វឌ្ឍេត្វា អរហត្តំ ចាបុណឹសុ ។

១០. រថេសុ ធាវន្តេសុ ឧដ្ឋិតេន រជសា គេហានំ ភិត្តិយោ
បរិកិណ្ណា កិលិដ្ឋា ជាតា ។

១១. អហិ ឧរសា សប្បតិ ។

១២. ចោរា រត្តិយំ គេហស្មាវិទូរេ រហសា សល្លបន្តា និសីទឹសុ ។

១៣. កថំ តុម្ហេ បទីបេន វា ឧក្កាយ វិនា រត្តិយំ តមសិ ឥធ វិចរថ ?

១៤. តេ មនុស្សា កាយេន វចសា មនសា ច ទុច្ចរិតំ ចរិត្វា
មរណា បរំ អបាយំ ឧប្បជ្ជឹសុ ។

១៥. សរសោ អវិទូរេ អរញ្ញស្មឹ តបស្សិនោ តបំ ចរន្តិ ។

## គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

*១. រីធូលី មិនមាន នៅលើថ្នល់ទេ ។*

*២. ឪពុក របស់ខ្ញុំ មានអាយុ សែសិបប្រាំ ឆ្នាំ ។*

*៣. យើង.ទ. គប្បីសម្អាត នូវចិត្ត របស់យើង ។*

*៤. ផ្លែឈើ មួយ នេះ ធ្លាក់ហើយ លើក្បាល ខ្ញុំ ។*

*៥. អ្នកស្រែ កាលញុំាងកូន ឱ្យឱ្យហើយ នូវស្មៅ ដល់គោ.ទ. ទៅហើយ
កាន់ក្រុង ។*

*៦. សូមឱ្យកេរ្តិ៍ឈ្មោះ របស់អ្នក ភ្លឺ ជាងដួងច័ន្ទ ។*

*៧. គោ.ទ. ផឹកហើយ នូវទឹក ក្នុងស្រះ គោ មួយទៀត ស៊ីស្មៅ ។*

*៨. ទឹកដោះ នេះ មិនមាន ឱជារសទេ ។*

៩. នាកាលព្រះអាទិត្យ រះឡើង ភាពងងឹត បាត់ទៅ ។

១០. ឥឡូវនេះ ផ្កាឈូក.ទ. កំពុងរីក ក្នុងស្រះ ។

១១. ព្រះពុទ្ធ ទ្រង់ចាំងពន្លឺ ព្រោះតេជៈ ។

១២. យើង រៀន ភាសាបាលី ដោយកម្លាំង ច្រើន ។

១៣. ផ្កាឈូក.ទ. ដែលយកមកហើយ ពីស្រះ ឥឡូវនេះ កំពុង-ស្រពោន ។

១៤. នាកាល ភិក្ខុនី បោស ទីធ្លា ដោយអំបោស ធូលី ដ៏ច្រើន ហុយឡើង ពីដី ។

១៥. ភិក្ខុ.ទ. និង ភិក្ខុនី.ទ. កាលឃើញ ព្រះពុទ្ធ យាងទៅហើយ កាន់ទីនោះ ក្រោកហើយ ពីទីអង្គុយ របស់ពួកគេ ថ្វាយបង្គំហើយ បង្អោនទៅហើយ នូវក្បាល.ទ. ដល់ព្រះបាទា របស់ព្រះអង្គ ។

១៦. ច្រេះ កើតហើយ ពីដែក ណា រមែងស៊ី នូវដែក នោះ ។

**(ចប់មេរៀនទី ២៦)**

# មេរៀនទី ២៧

## អធិប្បាយអំពីអព្យយស័ព្ទ

(Indeclinables)

*ពាក្យថា "**អព្យយសព្ទ**" តាមរូបស័ព្ទមានន័យថា "ស័ព្ទមិនវិនាស, ស័ព្ទមិនប្រែប្រួលចាករូបដើម" មិនកំណត់ឱ្យមានជាលិង្គណាមួយទេ បានសេចក្តីថា ស័ព្ទពួកនេះពុំចាំបាច់បំបែកតាមវិភត្តិផ្សេង ៗ ដូចនាមស័ព្ទទូទៅ ដែលបានរៀនរួចមកហើយទេ ។ ស័ព្ទខ្លះប្រើចុះខាងដើមនាមនាមឬគុណនាមឬក៏កិរិយាស័ព្ទ ស័ព្ទខ្លះជាស័ព្ទឯករាជ្យប្រើក្នុងចន្លោះនាមនាមឬចន្លោះកិរិយាស័ព្ទ ឬក៏រៀងខាងដើមនៃប្រយោគ និងខ្លះទៀតសម្រាប់ចុះខាងចុងនាមនាម, គុណនាមឬកិរិយាស័ព្ទ ។ វេលារៀងក្នុងប្រយោគ អព្យយស័ព្ទមានរូបយ៉ាងណា គឺទុកឱ្យគង់រូបយ៉ាងនោះដូចដើម ។ អព្យយស័ព្ទចែកជា ៣ ប្រភេទគឺ*

**១. ឧបសគ្គ, ២. និបាត, ៣. បច្ច័យ**

### ១. ឧបសគ្គ

(Prefixes)

*ពាក្យថា "**ឧបសគ្គ**" តាមរូបស័ព្ទមានសេចក្តីថា "សការចូលទៅ*

ជិតជាប់ គឺ អន្តរាយ, ការរឹបជាន់, ឧបសគ្គ ។ល។" មិនស្រួលដល់កិច្ចការទាំងពួង ។ ប្រសិនបើកើតមានអ្វីមិនស្រួលចំពោះមនុស្សណាមួយ ភាគច្រើនជននោះតែងនិយាយជាប់មាត់ថា "មានឧបសគ្គ" ។

ប៉ុន្តែឧបសគ្គក្នុងបាលីវេយ្យាករណ៍ សំដៅយកស័ព្ទដែលចុះភ្ជាប់ពីមុខឬពីខាងដើមនៃស័ព្ទមួយទៀត ដើម្បីធ្វើឱ្យមានសេចក្ដីប្លែកជាងស័ព្ទដើម ហើយដែលនឹងប្រើតាមទំនើងខ្លួនឯងជាស័ព្ទឯករាជ្យពុំបានឡើយ លុះត្រាតែចុះជាមួយស័ព្ទដទៃជានិច្ច (ក្នុងករណីពិសេសមានឧបសគ្គខ្លះអាចប្រើជាស័ព្ទឯករាជ្យបាន ប៉ុន្តែក្នុងទីនេះសូមអធិប្បាយត្រឹមតែការប្រើជាទូទៅប៉ុណ្ណោះ) ដែលមានវិធីប្រើ ២ យ៉ាងគឺ

១. បើប្រើប្រកបខាងដើមនាមនាមឬគុណនាម (មានពោលនៅខាងមុខ) មានលក្ខណៈជាគុណស័ព្ទក្នុងភាសាខ្មែរ ។

២. បើប្រើប្រកបខាងដើមធាតុឱ្យទៅជាកិរិយាស័ព្ទឬនាមស័ព្ទ (មានពោលនៅខាងមុខ) និងមានអត្ថវិសេសជាងស័ព្ទដើម ។

ឧបសគ្គទាំងអស់មាន ២០ ស័ព្ទគឺ

| **ស័ព្ទបាលី** | ពាក្យប្រែ |
|---|---|
| **អតិ** | ពេក, ក្រៃពេក, កន្លង, លើស ។ |
| **អធិ** | ធំ, ក្រៃលែង, ក្រៃពេក, លើសលប់, លើសលែង, សង្កត់ ។ |
| **អនុ** | តូច, តាម, បន្ទាប់, រង, ក្រោយ, បណ្ដោយ, លំដាប់ ។ |
| **អប** | ប្រាស, ចៀស, គេច ។ |

អបិ, បិ ជិត, ខាងលើ ។

អភិ ធំ, ក្រៃពេក, ចំពោះ, ឆ្ពោះ, ខាងមុខ ។

អវ ឬ ឱ ចុះ, ចុះក្រោម, ទាប, ស្រេច ។

អា ទូទៅ, សព្វ, ក្រៃលែង, (ធ្វើឲ្យមានអត្ថផ្ទុយនឹងអត្ថដើម) ។

ឧ ឡើង, ខ្ពស់, ក្រៅ ។

ឧប ជិត, ចូលទៅជិត, មាំ, ស៊ប់ ។

ទុ អាក្រក់, ក្រ, កម្រ, លំបាក, ពិបាក ។

និ ចូល, ចុះ ។

និ មិនមាន, ចេញ, ឥត ។

ប ទូទៅ, ខាងមុខ, ចេញ, កន្ទង់, មុន, ជាប្រធាន ។

បដិ, បតិ ចំពោះ, តប, ត, ប្រាស, ត្រឡប់ ។

បរា ខាងមុខ, (ធ្វើឲ្យមានអត្ថផ្ទុយនឹងអត្ថដើម) ។

បរិ ជុំ, ជុំវិញ, គ្រប់គ្រាន់, ស្រេច ។

វិ ផ្សេង, ប្លែក, ច្បាស់, ជាក់, ប្រាកដ, វិសេស ។

សំ ព្រម, ជាមួយ, ល្អ, ប្រពៃ ។

សុ ងាយ, ស្រួល, ស្រណុក, ល្អ, ប្រពៃ, ណាស់, ម៉្លេះ, អ្វីម៉្លេះ ។

☸ **អបិ, បិ, សុ** ប្រើជាឧបសគ្គផងជានិបាតផង ។

ពាក្យថា "ធ្វើឲ្យមានអត្ថផ្ទុយនឹងអត្ថដើម" មានសេចក្ដីដូចជាឧទា-
ហរណ៍ថា "ទៅ ផ្ទុយនឹង មក", "ទិញ ផ្ទុយនឹង លក់" ជាដើម ។ ស័ព្ទ

ឧបសគ្គទាំងនេះ អ្នកសិក្សាថ្មីគប្បីអានសាចុះសាឡើងឱ្យបានច្រើនដង ដូចជា **អតិ**, **អធិ**......**វិ**, **សំ**, **សុ** ដើម្បីនាំឱ្យកើតជំនាញពុំចាំបាច់សង្ស័យ មិនតែប៉ុណ្ណោះ ស័ព្ទដែលចុះឧបសគ្គជាភាសាបាលីក៏មានប្រើក្នុងភាសាខ្មែរយ៉ាងច្រើនដែរដូចជា ឧបរាជ, ឧបនាយក, អធិរាជ, អនុកម្មការ, បរាជ័យ, បរិវេណ, សុភាសិត ។ល។

## ឧទាហរណ៍នៃការប្រើឧបសគ្គនីមួយ ៗ

**អតិ** = ពេក, ក្រៃពេក, កន្លង, លើស ។

ចុះដើមគុណនាម ឧ. **អតិសុន្ទរ** =ល្អក្រៃពេក, ល្អណាស់ ។

ចុះដើមធាតុ ឧ. (**អតិ** + **កាម** + **អ** + **តិ**) **អតិក្កមតិ** =ឈានកន្លង ។

**អធិ** = ក្រៃលែង, ធំ, ...... សង្កត់។

ចុះដើមនាមនាម ឧ. (**អធិ** + **បតិ**) **អធិបតិ** =អ្នកធំ, អធិបតី ។

ឧ. (**អធិ** + **សក្ការ**) **អធិសក្ការ** =សេចក្តីគោរពក្រៃលែង ។

ចុះដើមធាតុ ឧ.(**អធិ** + **សី** + **អ** + **តិ**) **អធិសេតិ** =ដេកសង្កត់ ។

**អនុ** = តូច, បន្ទាប់, ...... លំដាប់ ។

ចុះដើមនាមនាម ឧ. (**អនុ** + **នាយក**) **អនុនាយក** =នាយករង ។

ចុះដើមធាតុ ឧ. (**អនុ** + **គម** + **អ** + **តិ**) **អនុគច្ឆតិ** =ទៅតាម ។

**អប** = ប្រាស, ចៀស, គេច ។

សព្ទនេះច្រើននិយមចុះដើមធាតុ

ឧ. (**អប** + **នី** + **អ** + **តិ**) **អបនេតិ** =នាំប្រាសទៅ, នាំចេញ ។

ឧ. (**អប** + **គម** + **អ** + **តិ**) **អបគច្ឆតិ** =ទៅប្រាស, គេចចេញ ។

**អបិ**, = ជិត, ខាងលើ ។

**បិ** ចុះដើមនាមនាម

ឧ. (**អបិ** + **កច្ឆ**) **អបិកច្ឆ** =ជិតក្លៀក ។

ឧ. (**អបិ** + **កណ្ណ**) **អបិកណ្ណ** =ជិតត្រចៀក ។

ឧ. (**អបិ** + **ធាន**) **អបិធាន** =គ្រឿងបិទ ។

ចុះដើមធាតុ (**បិ** + **ធហ** + **អ** + **តិ**) **បិធហាតិ** =បិទ, ដាក់ខាង

លើ ។ **អបិ** ឬ **បិ** មានប្រើតិចតួចទេ ។

**អភិ** = ក្រៃពេក, ធំ, ចំពោះ, ...... ខាងមុខ ។

ចុះដើមគុណនាម

ឧ. (**អភិ** + **បសន្ន**) **អភិប្បសន្ន** =ជ្រះថ្លាក្រៃពេក ។

ចុះដើមធាតុ

ឧ. (**អភិ** + **កម** + **អ** + **តិ**) **អភិក្កមតិ** =ដើរទៅមុខ ។

ឧ. (**អភិ** + **រុហ** + **អ** + **តិ**) **អភិរុហតិ** =ដុះឡើង, ចម្រើនឡើង ។

**អវ**, = ចុះ, ខាងក្រោម, ចុះក្រោម, ស្រេច ។

**ឱ** ចុះដើមនាមនាម ឧ.(**អវ** + **សិរ**)**អវំសិរ** =មានក្បាលសំយុងចុះ។

បុះដើមធាតុ

ឧ. (**ឱ** + **តរ** + **អ** + **តិ**) **ឱតរតិ** =ចូលចុះ, ចុះ ។

ឧ. (**ឱ** + **កាម** + **អ** + **តិ**) **ឱក្កមតិ** =ឈានចុះ ។

**អា** = ទូទៅ, ក្រៃលែង, ..., ធ្វើឲ្យមានអត្ថផ្ទុយនឹងអត្ថដើម ។

សព្ទនេះនិយមចុះដើមធាតុ

ឧ. (**អា** + **បុរ** + **អ** + **តិ**) **អាបូរតិ** =ពេញទូទៅ ។

ឧ. (**អា** + **ភា** + **អ** + **តិ**) **អាភាតិ** =រុងរឿងទូទៅ ។

ឧ. (**អា** + **គម** + **អ** + **តិ**) **អាគច្ឆតិ** =មក, (**គច្ឆតិ** =ទៅ) ។

ឧ. (**អា** + **នី** + **អ** + **តិ**) **អានេតិ** =នាំមក, (**នេតិ** =នាំទៅ) ។

**ឧ** = ឡើង, ខ្ពស់, ក្រៅ ។

បុះដើមនាមនាម ឧ. (**ឧ** + **បថ**) **ឧប្បថ** =ក្រៅផ្លូវ ។

បុះដើមធាតុ ឧ. (**ឧ** + **គម** + **អ** + **តិ**) **ឧគ្គច្ឆតិ** =ឡើងទៅលើ, រះឡើង ។

**ឧប** = ជិត, ចូលទៅជិត, មាំ, ស៊ប់ ។

បុះដើមនាមនាម ឧ. (**ឧប** + **អាធាន**) **ឧបាធាន** =កិរិយាប្រកាន់មាំ ។

បុះដើមធាតុ ឧ. (**ឧប** + **នី** + **អ** + **តិ**) **ឧបនេតិ** =នាំចូលទៅជិត

ឧ. (**ឧប** + **គម** + **អ** + **តិ**) **ឧបគច្ឆតិ** =ចូលទៅជិត ។

ឧ. (**ឧប** + **ហាន** + **យ** + **តិ**) **ឧបហាញ្ញតិ** =ចូលទៅបៀតបៀន ។

ទុ = អាក្រក់, កម្រ, លំបាក, ពិបាក ។

ចុះដើមនាមនាម ឧ. (ទុ + គន្ធ ) ទុគន្ធ =ក្លិនអាក្រក់ (ស្អុយ) ។

ចុះដើមធាតុ (ទុ + ករ + អ ) ទុក្ករ =ធ្វើដោយកម្រ (ដូចជាអំពើ

ល្អធ្វើបានដោយកម្រ) ។

និ = ចូល, ចុះ ។

ចុះដើមធាតុ ឧ. (និ + គម + អ + តិ ) និគច្ឆតិ =ចូលដល់ ។

ឧ. (និ + កុជ្ជ + អ + តិ ) និកុជ្ជតិ =ផ្កាប់ឬកោងចុះ ។

ឧ. (និ + ខន + អ + តិ ) និខនតិ =ជីកចុះ ។

ឧ. (និ + ទហ + អ + តិ ) និទហតិ =តាំងចុះ, កប់ ។

និ = មិនមាន, ចេញ, ឥត ។

ចុះដើមនាមនាម ឧ. (និ > និរ + អន្តរាយ ) និរន្តរាយ =មិនមាន

អន្តរាយ ។

ចុះដើមធាតុ ឧ. (និ + កឌ្ឍ + អ + តិ ) និកឌ្ឍតិ=ទាញចេញ។

ប =ទូទៅ, ខាងមុខ, ......ជាប្រធាន ។

ចុះដើមនាមនាម ឧ. (ប + មុខ ) បមុខ =ប្រមុខ, ប្រធាន ។

ចុះដើមធាតុ ឧ. (ប + ញា + នា + តិ ) បជានាតិ =ដឹងទូទៅ ។

ឧ. (ប + ភូ + អ + តិ ) បភវតិ =កើតមុន, មានមុន ។

ឧ. (ប + ឃរ + អ + តិ ) បគ្ឃរតិ =ហូរចេញ, ស្រកចេញ ។

បដិ = បំពោះ, តប, ......, ធ្វើឲ្យមានអត្ថផ្ទុយនឹងអត្ថដើម ។

ចុះដើមនាម ឧ. (**បដិ** + **វចន**) **បដិវចន** =សំដីតប ។

ចុះដើមធាតុ ឧ. (**បដិ** + **កាម** + **អ** + **តិ**) **បដិក្កមតិ** =ថយឬត្រឡប់ក្រោយ ។

**បរា** = ខាងមុខ, (ធ្វើឲ្យមានអត្ថផ្ទុយនឹងអត្ថដើម) ។

ចុះដើមនាមនាម

ឧ. (**បរា** + **ជយ** កិរិយាឈ្នះ) **បរាជយ** =បរាជ័យ, កិរិយាចាញ់។

ឧ. (**បរា** + **ភវ** សេចក្តីចម្រើន) **បរាភវ** =សេចក្តីហិនហោច ។

**បរិ** = ជុំវិញ, គ្រប់គ្រាន់, ស្រេច.........។

ចុះដើមនាមនាម ឧ. (**បរិ** + **ញា**) **បរិញ្ញា** =ដឹងឬចេះគ្រប់គ្រាន់។

ឧ. (**បរិ** + **និព្វាន**) **បរិនិព្វាន** =សេចក្តីរំលត់ជុំវិញ, បរិនិព្វាន ។

ឧ. (**បរិ** + **ចយ**) **បរិចយ** =កិរិយាសន្សំជុំវិញ, ការសន្សំ ។

ឧ. (**បរិ** + **យន្ត**) **បរិយន្ត** =ទីបំផុត, ជុំវិញ, ជាយ ។

ចុះដើមធាតុ (**បរិ** + **បុរ** + **អ** + **តិ**) **បរិបូរតិ** =ពេញជុំវិញ,បរិបូរ។

**វិ** = ច្បាស់, ផ្សេង, ......, វិសេស ។

ចុះដើមគុណនាម ឧ. (**វិ** + **វិធ**) **វិវិធ** =មានប្លែក ៗ ។

ចុះដើមនាមនាម ឧ. (**វិ** + **ចក្ខុណ**) **វិចក្ខុណ** =អ្នកមានបញ្ញាជាគ្រឿងឃើញច្បាស់ ។

ឧ. (**វិ** + **ទេស**) **វិទេស** =ប្រទេសផ្សេង ។

ឧ. (**វិ** + **ទេស** + **ឧបយ**) **វិទេសោបយ** =ឧបាយឬនយោបាយ

ក្រៅប្រទេស ។

ចុះដើមធាតុ ឧ. (វិ + ញា + ជា + តិ) វិជានាតិ =ដឹងច្បាស់, ដឹងវិសេស ។

សំ = ព្រម, ជាមួយ, ល្អ, ប្រពៃ ។

ចុះដើមនាមនាម ឧ. (សំ + ឆវិ) សញ្ឆវិ =ស្បែកល្អ ។

ឧ. (សំ + អា + គម) សមាគម =ការប្រជុំគ្នា, សមាគម ។

ចុះដើមធាតុ ឧ. (សំ + ចរ + អ + តិ) សញ្ចរតិ =ទៅព្រម, ដើរទៅជាមួយគ្នា ។

ឧ. (សំ + តុស + យ + តិ) សន្តុស្សតិ =ត្រេកអរព្រម ។

សុ = ល្អ, ស្អាត, ងាយ, ....., ម៉្លេះ, អ្វីម៉្លេះ។

ចុះដើមនាមនាមឬគុណនាម

ឧ. (សុ + នក្ខត្ត) សុនក្ខត្ត =ឫក្សល្អ ។

ឧ. (សុ + នេត្ត) សុនេត្ត =អ្នកមានភ្នែកស្អាត ។

ឧ. (សុ + គន្ធ) សុគន្ធ =មានក្លិនល្អ គឺក្លិនក្រអូប ។

ចុះដើមធាតុ

ឧ. (សុ + ករ) សុក្ករ =ធ្វើបានដោយងាយ ។

ឧ. (សុ + បុច្ឆ + អ + តិ) សុបុច្ឆតិ =រីកល្អ ។

ឧ. (សុ + សំ + អា + (ជា > ឧហា) + តិ) សុសមាឧហាតិ = តាំងមាំដោយល្អ ។

# កំណត់សម្គាល់

តាមដំណើរនៃវិធីប្រើឧបសគ្គដូចបានពោលរួចហើយនេះ បើចុះឧបសគ្គពីខាងដើមកិរិយាហើយឃើញថា ឧបសគ្គនេះមានអំណាចធ្វើឱ្យធាតុទាំងនោះប្រែប្រួលផ្លាស់អត្ថន័យទៅបានដែលមាន ៣ ប្រភេទគឺ ១. ឧបសគ្គបៀតបៀនអត្ថរបស់ធាតុ ២. ឧបសគ្គមានអត្ថស្របតាមធាតុ ៣. ឧបសគ្គធ្វើអត្ថរបស់ធាតុឲ្យប្លែក ។

១. ឧបសគ្គបៀតបៀនអត្ថរបស់ធាតុ បាលីថា **ធាត្វត្ថពាធកា** បានន័យថា ឧបសគ្គខ្លះកាលបើចុះមកហើយនឹងប្រែសព្ទនោះ ៗ តាមដើមទៀតពុំបានទេ ទោះបីជាអត្ថដើមប្រែថាយ៉ាងណាក៏ដោយ គឺត្រូវប្រែតាមបែបថ្មី ឬត្រូវប្រែផ្ទុយអត្ថគ្នាវិញ ដូចពាក្យខ្មែរថា បិទ គឺផ្ទុយនឹង បើក, ទៅផ្ទុយនឹង មក ។ សូមមើលឧទាហរណ៍ខាងក្រោមនេះ

**វរតិ** =បិទ, **វរ** ធាតុ, ចុះ **វិ** ឧបសគ្គខាងដើមទៅជា **វិវរតិ** =បើក (**វិ** + **វរ** + **អ** + **តិ**) ។

**ចរតិ** =ប្រព្រឹត្ត, **ចរ** ធាតុ, ចុះ **វិ** ឧបសគ្គខាងដើមទៅជា **វិចរតិ** = ដើរទៅ (**វិ** + **ចរ** + **អ** + **តិ**) ។

**ខមតិ** =អត់ធន់, **ខម** ធាតុ, ចុះ **និ** ឧបសគ្គខាងដើមមកទៅជា **និក្ខមតិ** =ចេញ (**និ** + **ខម** + **អ** + **តិ**) ។

**គច្ឆតិ** =ទៅ, **គម** ធាតុ, ចុះ **អា** ឧបសគ្គខាងដើមមកទៅជា **អាគច្ឆតិ** =មក (**អា** + **គម** + **អ** + **តិ**) ។

ឧបសគ្គណាប្រើរបៀបនេះហៅថា ឧបសគ្គបៀតបៀនអត្ថរបស់ធាតុ បានសេចក្ដីថាត្រូវប្រែតាមអត្ថថ្មីវិញ ។

២. ឧបសគ្គមានអត្ថស្របតាមធាតុ បាលីថា **ធាត្វត្ថានុវត្តក** ។ ពាក្យថាមានអត្ថស្របតាមធាតុ (ខុសពីពាក្យថា បៀតបៀនធាតុ) នេះបានន័យថាពុំចាំបាច់ប្រែផ្ទុយអត្ថទេ គឺថា បើចុះឧបសគ្គណាមួយខាងដើមធាតុហើយនឹងធ្វើឱ្យធាតុខ្លះប្រែប្លែកចាកដើមបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែនៅតែរក្សាអត្ថដើមជាគោល ដូចជា

**កមតិ** =ឈានទៅ, **កម** ធាតុ, ចុះ **បដិ** ឧបសគ្គខាងដើមទៅជា **បដិក្កមតិ** =ឈានថយ (**បដិ** + **កម** + **អ** + **តិ**) ។

**គច្ឆតិ** =ទៅ, ដល់, **គម** ធាតុ, ចុះ **អធិ** ឧបសគ្គខាងដើមទៅជា **អធិគច្ឆតិ** =លុះ, ត្រាស់ដឹង (**អធិ** + **គម** + **អ** + **តិ**) ។

**គណ្ហាតិ** =កាន់យក, **គហ** ធាតុ, ចុះ **ឧ** ឧបសគ្គខាងដើមទៅជា **ឧគ្គណ្ហាតិ** =រៀន (**ឧ** + **គហ** + **ណ្ហា** + **តិ**) ។

ឧបសគ្គណាប្រើក្នុងលក្ខណៈដូចខាងលើនេះ ដែលគ្រាន់តែធ្វើអត្ថរបស់ធាតុឱ្យប្រែប្រួលខ្លះ ៗ យ៉ាងនេះហៅថា ឧបសគ្គមានអត្ថស្របតាមធាតុ ។

៣. ឧបសគ្គធ្វើអត្ថរបស់ធាតុឲ្យប្លែក បាលីថា **ធាត្វត្ថវិសេសក** មានន័យថាធ្វើអត្ថរបស់ធាតុឲ្យវិសេសឡើងថែមទៀត ។ ធាតុខ្លះកាលបើចុះឧបសគ្គខាងដើមហើយមិនបានធ្វើឱ្យធាតុនោះ ៗ ប្រែប្រួលអត្ថទេ ប៉ុន្តែ

បែរជាទំនុកបំរុងជាតុនោះ ៗ ឱ្យច្បាស់លាស់ឡើងថែមទៀត ដូចជា

**ជានាតិ** =ដឹង, **ញា** ធាតុ ចុះ **វិ** ឧបសគ្គខាងដើមទៅជា **វិជានាតិ** =ដឹងច្បាស់, ដឹងជាក់ (**វិ** + **ញា** + **នា** + **តិ**) ។

**គច្ឆតិ** =ទៅ, **គម** ធាតុ, ចុះ **អប** ឧបសគ្គខាងដើមមកទៅជា **អបគច្ឆតិ** =ទៅប្រាស, គេចចេញ (**អប** + **គម** + **អ** + **តិ**) ។

**កាមតិ** =ឈានទៅ, **កាម** ធាតុ, ចុះ **អតិ** ឧបសគ្គខាងដើមទៅជា **អតិក្កាមតិ** =ឈានកន្លង, កន្លង (**អតិ** + **កាម** + **អ** + **តិ**) ។

ឧបសគ្គប្រើក្នុងលក្ខណៈនេះហៅថា ឧបសគ្គធ្វើអត្ថជាតុឲ្យប្លែក ។

សូមសង្កេតមើលតទៅទៀត ឧបសគ្គដែលប្រើប្រកបដើមពាក្យជាមួយនាមនាមក្តី, គុណនាមក្តី, ជាតុក្តី អាចចុះឧបសគ្គណាមួយក៏បានឱ្យតែសមន័យ ចុះតែឧបសគ្គមួយក៏បាន ពីរឬបីក៏បាន ស្រេចតែសេចក្តីក្នុងទីនោះ ៗ គឺមិនកំណត់ថាត្រូវតែចុះប៉ុន្មានទេ ។ សូមមើលខាងក្រោមនេះ

**អតិសុន្ទរ** (**អតិ** + **សុន្ទរ**) =ល្អក្រៃលែង ។

**បដិមោក្ខ** (**ប** + **អតិ** + **មោក្ខ** ) =បាតិមោក្ខ ។

**វិនេតិ** (**វិ** + **នី** + **អ** + **តិ**) =ទូន្មាន ។

**សមន្នាហរតិ** ( **សំ** + **អនុ** + **ហរតិ**) =យកមកទុក, រួបរួម ។

បទថា **សមន្នាហរតិ** ( **សំ** + **អនុ** + **ហរតិ**) នេះជាវិធីសន្ធិ (ដែល

នឹងអធិប្បាយនៅខាងមុខ ចូរមើលមេរៀនទី ៤៣) ពីព្រោះមានវិធីតតួអក្សរឱ្យជាប់គ្នា ដោយផ្លាស់និគ្គហិតនៃ សំ ជា ម, ផ្លាស់ ឳ នៃ អឱុ ជា អា ហើយតម្រួត ន ជា ន្ន ។

# និ ឧបសគ្គ

និ ឧបសគ្គមាន ២ ស័ព្ទ (ក្នុងបករណ៍ខ្លះប្រាប់ថា និ និង នី) មានវិធីប្រើនិងពាក្យប្រែខុសគ្នាដូចតទៅនេះ

១. និ ប្រែថា "ចូល, ចុះ" និយមចុះខាងដើមធាតុឱ្យទៅជានាមនិងកិរិយាស័ព្ទ ។ កាលបើចុះក្នុងស័ព្ទណាត្រូវទុក និ ឱ្យគង់រូបដដែលនិងពុំចាំបាច់តម្រួតជាព្យញ្ជនសំយោគ ឬចុះ រ អាគមទេ គឺពុំចាំបាច់ថែម រ ខាងក្រោយ និ ទេ ដូចខាងក្រោមនេះ

១.១ ប្រើចុះខាងដើមធាតុឱ្យទៅជានាមស័ព្ទ ឧ.

(និ + ធា + យុ) > និធាន =និទាន, ហេតុ ។

(និ + វស + ណ) > និវាស =ទីអាស្រ័យ, លំនៅ, ទីនៅ ។

១.២ ប្រើចុះខាងដើមធាតុឱ្យទៅជាកិរិយាស័ព្ទ ឧ.

(និ + គច្ឆតិ) > និគច្ឆតិ =ចូលដល់ (មិនមែន និគ្គច្ឆតិ ទេ) ។

(និ + កុជ្ជតិ) > និកុជ្ជតិ = កោងចុះ (មិនមែន និក្កុជ្ជតិ ទេ) ។

(និ + ខណតិ) > និខណតិ = កប់ទុក (មិនមែន និក្ខណតិ ទេ) ។

(**និ** + **ឧហតិ** ) > **និឧហតិ** = *តាំងទុក* (*មិនមែន* **និទ្ទហតិ** *ទេ*) ។

២. **និ** *ប្រែថា "មិនមាន, គ្មាន, ចេញ" និយមចុះខាងដើមនាមនិង កិរិយាស័ព្ទ ។ កាលបើចុះជាមួយស័ព្ទណាហើយ មានចំណុចសម្រាប់ សម្គាល់ដូច្នេះគឺ ត្រូវមានតួសំយោគគឺព្យញ្ជនៈតម្រួតគ្នាម្យ៉ាង ត្រូវចុះ រ ខាងចុង* **និ** *ម្យ៉ាង ឬត្រូវទីឃៈស្រៈ* **ឥ** *នៃ* **និ** *ជា* **នី** *ដូចមានឧទាហរណ៍ ខាងក្រោមនេះ*

២.១ *ប្រើចុះខាងដើមគុណនាមឬនាមនាមដែលត្រូវតម្រួតព្យញ្ជនៈ ដើមស័ព្ទដូចជា*

(**និ** + **ទុក្ខ** ) > **និទ្ទុក្ខ** *ប្រែថា មិនមានទុក្ខ* ។

(**និ** + **ភយ** ) > **និព្ភយ** *ប្រែថា មិនមានភ័យ* ។

២.២ *បើតួអក្សរដើមនាមឬគុណនាមជាស្រៈ* **អ**, **អា**, **ឧ** *នោះពុំចាំ បាច់តម្រួតព្យញ្ជនៈខាងចុងទេ ប៉ុន្តែត្រូវចុះ រ ជំនួសវិញដូចជា*

( **និ** + **រ** + **អន្តរាយ** ) > **និរន្តរាយ** =*អន្តរាយមិនមាន* ។

( **និ** + **រ** + **អាហារ** ) > **និរាហារ** =*អាហារមិនមាន* ។

( **និ** + **រ** + **ឧបការ** ) > **និរុបការ** =*ឧបការៈមិនមាន* ។

☸ (**និ** + **រ** ) > **និរ** *ជាស័ព្ទសម្រាប់ប្រកបខាងដើមពាក្យដទៃ ប្រែថា "មិនមាន, គ្មាន, ចេញ" ដែលត្រូវនឹងពាក្យថា* **និស** *ក្នុងភាសាសំស្ក្រឹត នោះនិយមយកមកប្រើក្នុងភាសាខ្មែរយើងខ្លះ ៗ ដែរដូចជា* **និរគុណ**, **និរទេស**, **និរទោស**, **និរភ័យ**, **និរទុក្ខ**, **និរមល** *។ល។ ដែលពោល*

មកនេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ។

២.៣ បើតួអក្សរដើមស័ព្ទជាព្យញ្ជនៈអវគ្គពុំចាំបាច់តម្រួតទេ តែត្រូវទីឃៈ **និ** > **នី** ដូចជា (**និ** + **រស**) > **នីរស** =រសមិនមាន ។

(**និ** + **វរណ**) > **នីវរណ** =ធម្មជាតិជាគ្រឿងរាំងចិត្ត ។

(**និ** + **ហរណ**) > **នីហរណ** =ការនាំចេញ ។

(**និ** + **ហរតិ**) > **នីហរតិ** =នាំចេញ ។

## (សូមរៀនសង្កេតមើលឲ្យបានល្អ)

ធាតុស័ព្ទទាំងឡាយអាចចុះឧបសគ្គណាមួយក៏បាន កាលបើចុះមកហើយ ពាក្យប្រែក៏នឹងផ្លាស់ប្តូរទៅតាមអត្ថរបស់ឧបសគ្គនោះ ៗ ផងដែរ ដូចមានឧទាហរណ៍ខាងក្រោមនេះ

១. **កម** ធាតុប្រែថា "ឈានទៅ" ចុះ **អ** បច្ច័យ **តិ** វត្តមានាវិភត្តិ ដូចជា

**កមតិ** =ឈានទៅ

**អក្កមតិ** =ជាន់

**អភិក្កមតិ** =ឈានទៅមុខ, ឈានចំពោះ

**ឧបក្កមតិ** =ព្យាយាម, ឈានចូលទៅ

**ឧបសង្កមតិ** =ចូលទៅជិត, ចូល

ឱក្កមតិ =ឈានចុះ

និក្ខមតិ =ចេញ, ចេញទៅ, លៀន

បក្កមតិ =ចៀសចេញទៅ

បដិក្កមតិ =ឈានថយ, ឈានត្រឡប់

វិក្កមតិ =ហ៊ាន, ល្មើសទៅរក

២. គម ធាតុ ប្រែថា "ទៅ" ផ្លាស់ទៅជា គច្ឆ ចុះ អ បច្ច័យ តិ វត្តមានាវិភត្តិដូចជា

គច្ឆតិ =ទៅ

អធិគច្ឆតិ =ដល់, លុះ, ត្រាស់

អនុគច្ឆតិ =ទៅតាម

អបគច្ឆតិ =ទៅប្រាស

អព្ភុគ្គច្ឆតិ =អណ្តែតឡើង

អាគច្ឆតិ =មក

ឧគ្គច្ឆតិ =ហោះឡើង, រះឡើង, ទៅខាងលើ

ឧបគច្ឆតិ =ចូលទៅជិត

និគច្ឆតិ =ដល់, ទៅដោយមិនសល់

បច្ចាគច្ឆតិ =ត្រឡប់មក

វិគច្ឆតិ =ទៅប្រាស

សមាគច្ឆតិ =មកជួបជុំ, មកប្រជុំ, ប្រជុំ

# កំណត់សម្គាល់

**អព្ភុគ្គច្ឆតិ** មកពី (**អភិ + ឧ + គម + អ + តិ**) តាមវិធីគឺផ្លាស់ (**អភិ > អព្ភ + ឧ + គច្ឆតិ**) ។

**បច្ចាគច្ឆតិ** មកពី (**បដិ + អា + គម + អ + តិ**) តាមវិធីឱ្យផ្លាស់ **ដ** នៃ **បដិ** ជា **ត** ហើយផ្លាស់ **ឥ** នៃ **ដិ** ជា **យ** បានជា **ត្យ > ច្ច** គឺតាមវិធីផ្លាស់ព្យញ្ជនៈខ្វះ ៗ ជាមួយ **យ** តាមវិធីរបស់សន្ធិ ។

**សមាគច្ឆតិ** មកពី (**សំ + អា + គម + អ + តិ**) តាមវិធីឱ្យផ្លាស់និគ្គហិតនៃ **សំ** ជា **ម** ទៅជា (**សម + អា + គច្ឆតិ**) ។

៣. **ញា** ធាតុ ប្រែថា ដឹង (ចូររកមើលត្រង់ **កី** ធាតុ) តាមវិធីឱ្យផ្លាស់ **ញា** ទៅជា **ជា** ចុះ **ណា** បច្ច័យ **តិ** វត្តមានាវិភត្តិ ដូចជា

**ជាណាតិ** =ដឹង

**អនុជាណាតិ** =ដឹងតាម, អនុញ្ញាត

**អភិជាណាតិ** =ដឹងច្បាស់, ដឹងចំពោះ

**អវជាណាតិ** =មើលងាយ

**អាជាណាតិ** =ដឹងទូទៅ

**បជាណាតិ** =ដឹងជាក់, ដឹងច្បាស់

**បដិជាណាតិ** =ដឹងតប, ប្ដេជ្ញា

**បរិជាណាតិ** =ដឹងជុំវិញ, កំណត់ដឹង

**វិជានាតិ** =ដឹងច្បាស់

**សញ្ជានាតិ** =ស្គាល់, យល់, ចាំបាន

**សញ្ជានាតិ** មកពី (**សំ** + **ញា** + **នា** + **តិ**) ផ្លាស់និគ្គហិតនៃ **សំ** > **ញ**, ផ្លាស់ **ញា** > **ជា**, រូបតម្រូតជា (**សញ្ជា** + **នា** + **តិ**) ។

## កំណត់សម្គាល់

កិរិយាអាខ្យាតដែលចុះឧបសគ្គខាងដើមដូចមានឧទាហរណ៍ខាងលើនេះ មានប្រើក្នុងបករណ៍ដទៃទៀតយ៉ាងច្រើនជាពិសេសក្នុង**ធម្មបទ** ដែលលោកអ្នកនឹងមានឱកាសជួបក្នុងគ្រាខាងមុខ ។ រីឯការប្រែនេះ ជួនកាលត្រូវប្រែឧបសគ្គមុនធាតុស័ព្ទក៏មាន ត្រង់នេះស្រេចតែតាមភាសានិយមទេ ដោយច្រើនក្នុងភាសាខ្មែរសង្កេតឃើញថានិយមប្រែធាតុស័ព្ទមុនប្រែឧបសគ្គ ។ ក្រៅពីការចុះឧបសគ្គដើមធាតុ នៅមានស័ព្ទខ្លះទៀតដែលអាចប្រើរបៀបឧបសគ្គស័ព្ទបានដែរ គឺចុះខាងដើមធាតុដូចមានឧទាហរណ៍តទៅនេះ

**គរុករោតិ** (**គរុ** + **ករោតិ**) =ធ្វើនូវសេចក្តីគោរព (ធ្វើឱ្យធ្ងន់)

**មនសិករោតិ** (**មនសិ** + **ករោតិ**) =ធ្វើទុកក្នុងចិត្ត (មនសិការ)

**សច្ឆិករោតិ** (**សច្ឆិ** + **ករោតិ**) =ធ្វើឱ្យជាក់ច្បាស់

**អលង្ករោតិ** (**អលំ** + **ករោតិ**) =ធ្វើគ្រឿងអលង្ការ (ធ្វើប្រដាប់)

កិរិយាប្រភេទនេះនឹងហៅថា **សមាសកិរិយា** ក៏បានដែរ ។

ឧទាហរណ៍ខាងលើនេះឃើញថាមានច្រើនល្មមហើយ ប្រសិនបើចង់ដឹងថែមទៀត ចូររកមើលក្នុងបទានុក្រមធម្មបទផងចុះ ។ ប៉ុន្តែរឿងសំខាន់ត្រូវចាំវិធីផ្សេង ៗ ដូចពោលហើយឱ្យល្អ ពីព្រោះជាឧទាហរណ៍ក្នុងការប្រែបាលីគ្រាដំបូង កាលបើបានជួបក្នុងគ្រាណាមួយនឹងអាចប្រែបានភ្លាមៗ ។ ភាគច្រើននៃកិរិយាស័ព្ទដែលលើកយកមកជាឧទាហរណ៍នេះជាកត្តុវាចកតែម្យ៉ាងប៉ុណ្ណោះ ។

(ចប់វិធីប្រើឧបសគ្គ)

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ |
|---|---|
| មាតាបិតុ បុំ. | ម្តាយនិងឪពុក |
| បុត្តធីតុ ឥ. | កូនប្រុសនិងកូនស្រី |
| ពោធិសត្ត បុំ. | ព្រះពោធិសត្វ |
| អន្តេវាសិក បុំ. | សិស្ស |
| អនិច្ចសញ្ញា ឥ. | សេចក្តីសម្គាល់ថាមិនទៀង |
| ទេវមនុស្ស បុំ. | ទេវតានិងមនុស្ស |

មនុស្សលោក បុំ. លោកជាទីនៅនៃមនុស្ស
ទេវលោក បុំ. លោកជាទីនៅនៃទេវតា
បដិលេខន នបុំ. សំបុត្រតបវិញ
គាមនិគម បុំ. ស្រុកនិងនិគម
មហាសេដ្ឋី បុំ. សេដ្ឋីធំ, មហាសេដ្ឋី
សេនាបតិបុត្ត បុំ. កូននៃសេនាបតី
អភិធម្ម បុំ. ធម៌ដ៏ក្រៃលែង, អភិធម្ម
បណ្ឌិតសោតុ បុំ. អ្នកស្ដាប់ជាបណ្ឌិត
បដិរាជ បុំ. ស្ដេចជាសត្រូវ
ឧបនគរ នបុំ. ទីជិតក្រុង, ទីជិតនគរ
ចោរភយ នបុំ. ភ័យអំពីចោរ
សត្តាហ នបុំ. សប្ដាហ៍, ប្រាំពីរថ្ងៃ
សប្បុរិស បុំ. បុរសអ្នកស្ងប់, សប្បុរស
បុត្តទារ ឥ. កូននិងប្រពន្ធ
ទុរនុពោធ គុ. ដឹងដោយកម្រ
អនុបុព្វ គុ. លំដាប់, តមក
និរាហារ គុ. មិនមានអាហារ
ទុគ្គម គុ. ដែលទូន្មានដោយលំបាក
ឧទយ បុំ. ការរះ, ការកើត

| | | |
|---|---|---|
| សុរិយោទយ | បុំ. | ពេលព្រះអាទិត្យរះ |
| សុជន | បុំ. | មនុស្សល្អ |
| ទុជ្ជន | បុំ. | មនុស្សអាក្រក់ |
| អស្សុ | នបុំ. | ទឹកភ្នែក |
| ទីបិ | បុំ. | ខ្លាដំបង(ឈ្មោល) |
| អច្ចិ | ឥ. | អណ្ដាតភ្លើង |
| ជណ្ណុ | នបុំ. | ជង្គង់ |
| ជាណុ | នបុំ. | ជង្គង់ |
| អម្ពុ | នបុំ. | ទឹក |
| វសុ | នបុំ. | ទ្រព្យ, សម្បត្តិ |
| បត្ថនា | ឥ. | សេចក្តីប្រាថ្នា |
| សម្មា | និ. | ត្រូវ, ត្រឹមត្រូវ |
| ខិប្បំ | និ. | យ៉ាងរហ័ស, ប្រញាប់ |
| យថាវុឌ្ឍំ | កិ.វិ. | តាមវ័យ |
| យថាសត្តិ | កិ.វិ. | តាមសមត្ថភាព |
| យថាជីវំ | កិ.វិ. | តាមការរស់នៅ |
| យថាកម្មំ | កិ.វិ. | តាមកម្ម, តាមអំពើ |
| យថាសុខំ | កិ.វិ. | តាមស្រួល |
| យថាពលំ | កិ.វិ. | តាមកម្លាំង |

## ធាតុស័ព្ទ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| វិ + ប + ភិរ | ភេយភាយ, | បដិ + យត | ចាត់ចែង,តាក់តែង |
| អនុ + កម្ប | អាណិត | ធា> ធាយេ | ឱ្យផឹក |
| អនុ+ សាស | ប្រៀនប្រដៅ | ឧប + លិប | ប្រឡាក់, ជាប់ |
| អភិ + កម | ឈានទៅមុខ | សំ + ឥជ | ប្រមូល |
| សំ + គហ | សង្គ្រោះ | បរា + ជិ | ចាញ់ |
| សំ+ប+អាប | ដល់ព្រម, ទាន់ | ប + វត្ត | ប្រព្រឹត្តទៅ |
| សំ + ហរ | លាយ | វិ + ភជ | ចែក,រំលែក,ញែក |
| សុ + ទិស | សម្ដែងល្អ | វត្ត | ប្រព្រឹត្ត |
| អភិ + ភូ | ញាំញី,គ្របសង្កត់ | វិទ | ប្រសព្វ, បាន |
| និ + វត្ត | ត្រឡប់, វិលវិញ | វឌ្ឍ | ចម្រើន |
| វិ + ចរ | ត្រាច់ទៅ,ប្រព្រឹត្ត | | |

## លំហាត់នៃមេរៀនទី ២៧

### *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើពាក្យថា **អព្យយស័ព្ទ** ប្រែថាដូចម្ដេច, មានប៉ុន្មានយ៉ាងគឺអ្វីខ្លះ ?*

*២. តើឧបសគ្គជាស័ព្ទប្រភេទណា, មានប៉ុន្មានតួ គឺអ្វីខ្លះ ?*

៣. តើឧបសគ្គមានវិធីប្រើដូចម្ដេចខ្លះ ? សូមឱ្យឧទាហរណ៍ ។

៤. តើឧបសគ្គមានប៉ុន្មានប្រភេទ, គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

៥. តើស័ព្ទដទៃក្រៅពីឧបសគ្គអាចប្រើប្រកបខាងដើមធាតុបានឬទេ ?

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. មា និវត្ត អភិក្កម ។

២. ឥធ អាគច្ឆថ, ភិក្ខវោ យថាវុឌ្ឍំ វន្ទថ ។

៣. បុត្តធីតូហិ មាតាបិតរោ យថាសត្តិ សង្គហេតព្វា ។

៤. សចេ ទុជ្ជនា យាវជីវំ សុជនេ ភជេយ្យុំ តេសំ កោចិ អត្ថោ ន ភវេយ្យ ។

៥. សុទេសិតំ ពុទ្ធធម្មំ ឧគ្គណ្ហាមិ យថាពលំ ។

៦. សព្វេ ទេវមនុស្សា មនុស្សលោកេ វា ទេវលោកេ វា យថាកម្មំ ឧប្បជ្ជន្តិ ។

៧. អហំ បាលិភាសំ ឧគ្គណ្ហាមិ ។

៨. តស្សា ភាសាយ បដិលេខនំ លិខិតុំ វាយាមិ ។

៩. តស្ស អន្តេវាសិកា គាមនិគមេសុ វិចរិត្វា សុរិយោទយេ នគរំ សម្បាបុណឹសុ ។

១០. សេនាបតិបុត្តោ អនុបុព្វេន តស្ស រដ្ឋេ សេនាបតិ អហោសិ។

១១. ឧបរាជា បដិរាជានំ អភិភវិតុំ ឧបនគរំ គតោ ។

១២. សត្តសត្តាហំ សោ និរាហារោ វ វនេ វសិ ។

១៣. មហាសេដ្ឋិនោ ចោរភយេន យថាសុខំ ន សុបីសុ ។

១៤. អត្តា ហិ អត្តនោ នាថោ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ឃើញហើយ នូវពស់ ដែលចូលទៅ កាន់ផ្ទះ កញ្ញា ភ័យហើយ ផ្ដើមហើយ ដើម្បីយំ ដែលប្រព្រឹត្ត ដោយទឹកភ្នែក ។*

*២. ឯង លាយហើយ នូវល្វ ផង ទឹកឃ្មុំ ផង នឹងស៊ី នូវបាយ ។*

*៣. ភិក្ខុ កាលឃើញ នូវអណ្ដាតភ្លើង លើកោះ កាលចម្រើនហើយ នូវអនិច្ចសញ្ញា អង្គុយហើយ ។*

*៤. ព្រាន ដែលជាបាបការី យកហើយ នូវធ្នូ និង សរ ចូលទៅហើយ កាន់ព្រៃ ។*

*៥. ចៅ ឃើញហើយ នូវស្មូម ដែលកំពុងទៅ ដោយជង្គង់.ទ. និង ដៃ.ទ. កាលអាណិត ឱ្យហើយ នូវសំពត់ និង ភោជន ។*

*៦. ស្ត្រី.ទ. ដែលកំពុងប្រមូល នូវឱស.ទ. កាលដើរទៅ ក្នុងព្រៃ ច្រៀងហើយ ។*

*៧. មនុស្ស.ទ. ធ្វើហើយ នូវការងារ សន្សំទុកហើយ នូវសម្បត្តិ ប្រឹងប្រែង ដើម្បីផ្ញើ ដល់កូននិងប្រពន្ធ ។*

*៨. ផ្កាឈូក.ទ. ដែលកើតហើយ ក្នុងទឹក មិនជាប់ ដោយទឹកទេ ។*

*៩. ឪពុក ចែកហើយ នូវស្រែ.ទ. ដល់កូន.ទ. និង ចៅ.ទ. ទៅហើយ កាន់វត្ត បួសហើយ ។*

១០. លោកគ្រូ កាលបង្រៀន នូវសិល្បៈ ដល់សិស្ស.ទ. កាលអាណិត ដល់គេ.ទ. បង្រៀនហើយ ដើម្បីរស់នៅ ដោយធម៌ ។

១១. សមណៈ របស់ព្រះពោធិសត្វ ញ៉ាំងមារ ឱ្យចាញ់ហើយ កើតហើយ ជាព្រះពុទ្ធ ។

១២. ម្ដាយ ដែលបៀតបៀនហើយ ដោយជំងឺ កាលប្រព្រឹត្តទៅ ដោយទឹកភ្នែក មកហើយ កាន់ផ្ទះ របស់កូនស្រី ដេកហើយ លើគ្រែ សុំហើយ នូវបបរ ។

១៣. កូនស្រី ដែលអាណិត នូវម្ដាយ ចាត់ចែងហើយ យ៉ាងរហ័ស នូវបបរ លាងហើយ នូវមុខ របស់ម្ដាយ ឱ្យហុត(ពិសារ)ហើយ ។

១៤. ប្ដី ញែកហើយ យ៉ាងត្រឹមត្រូវ នូវសំនួរ ដែលសួរហើយ ដោយឪពុក ពន្យល់ហើយ នូវសេចក្ដី ដោយញញឹម ។

**(ចប់មេរៀនទី ២៧)**

# មេរៀនទី ២៨

# អធិប្បាយអំពីនិបាតស័ព្ទ

*ពាក្យថា "**និបាត**" បើតាមរូបស័ព្ទសម្រេចមកពីពាក្យថា (**និ** =ចុះ (ឧបសគ្គ) + **បត** =ធ្លាក់ + **អ**) ទៅជា **និបាត** ប្រែថា "ធ្លាក់ចុះ" ។*

*និបាតស័ព្ទពុំចាំបាច់ចុះពីខាងដើមនាមស័ព្ទឬកិរិយាស័ព្ទ ដូចឧបសគ្គទេ ជាស័ព្ទអាចប្រើទោលតែឯងបាន គឺប្រើត្រង់ចន្លោះនាមនាម និងនាមនាម ឬត្រង់ចន្លោះកិរិយាស័ព្ទនិងកិរិយាស័ព្ទ ឬក៏ប្រយោគនិងប្រយោគ និងខ្លះអាចរៀងនៅខាងដើមបង្អស់ (ទី ១)នៃប្រយោគ ឬទី ២, ឬទី ៣, ឬក៏ទី ៤ និង ខ្លះទៀតអាចរៀងដាក់ចុងបំផុតនៃប្រយោគក៏បាន ដើម្បីធ្វើឱ្យឃ្លាឬប្រយោគនោះ ៗ មានសេចក្ដីច្បាស់លាស់ពីរោះងាយស្រួលស្ដាប់ថែមទៀតដែលមាន ១៥ ប្រភេទ ។*

## និបាតស័ព្ទ (Particles)

| *ឈ្មោះនិបាត* | *អត្ថរបស់និបាតនីមួយ ៗ* |
|---|---|
| ១. អាលបនត្ថវាចកា | *ប្រាប់សេចក្ដីអាលបនៈ* |
| ២. កាលត្ថវាចកា | *ប្រាប់កាល* |
| ៣. ឋានត្ថវាចកា | *ប្រាប់ទីឋាន* |
| ៤. បរិច្ឆេទត្ថវាចកា | *ប្រាប់សេចក្ដីកំណត់* |

| | |
|---|---|
| ៥. ឧបមានុបមេយ្យត្ថវាចក | ប្រាប់សេចក្ដីប្រៀបធៀប, ប្រដូច |
| ៦. បការត្ថវាចក | ប្រាប់ប្រការផ្សេងៗ |
| ៧. បដិសេធនត្ថវាចក | ប្រាប់សេចក្ដីឃាត់, ហាម |
| ៨. អនុស្សវនត្ថវាចក | ប្រាប់សេចក្ដីដែលបានឮ |
| ៩. បរិកប្បត្ថវាចក | ប្រាប់សេចក្ដីសង្ស័យ, ប្រមើល, ស្មាន |
| ១០. សម្បដិច្ឆនត្ថវាចក | ប្រាប់សេចក្ដីទទួល, ឆ្លើយ |
| ១១. ឧយ្យោជនត្ថវាចក | ប្រាប់សេចក្ដីតឿន |
| ១២. អនេកត្ថវាចក | ប្រាប់សេចក្ដីច្រើនយ៉ាង |
| ១៣. បទបូរណត្ថវាចក | និបាតបំពេញបទ |
| ១៤. បុច្ឆនត្ថវាចក | ប្រាប់សេចក្ដីសួរ |
| ១៥. ឯានត្ថវាចក | ប្រាប់សេចក្ដីផ្សេងៗ |

## ១. អាលបនត្ថវាចកនិបាត

(ពាក្យហៅរកគ្នា)

| *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|
| យគ្ឃេ | *សូមព្រះរាជតេជៈ (ដំកល់លើត្បូង),*<br>*សូមទានមេត្តាប្រោស, ទានប្រោស* |
| ភន្តេ, ភទន្តេ | *បពិត្រព្រះអង្គដ៏ចម្រើន, បពិត្រព្រះអង្គ* |

| | |
|---|---|
| ភណេ | *នែនាយ* |
| អម្ភោ | *អ្នកដ៏ចំរើន* |
| អាវុសោ | *ម្នាលលោកដ៏មានអាយុ* |
| រេ, អរេ | *អាចម្រែ, មេចម្រែ, រីយ, រ៉ឺ* |
| ហេ, អហេ | *ហឺយ, រឺយ* |
| ជេ | *នែមេ, នែហង៍* |

***វិធីប្រើ*** *និយមរៀងដាក់ទី ១, ទី ២ ឬ ទី ៣ ត្រូវប្រែលេខ ១ តាមលំដាប់លេខប្រែ ។*

១. <u>ភន្តេ</u> មយា តេលំ បចិត្វា បេសេសិ ។

*<u>បពិត្រលោកម្ចាស់ដ៏ចំរើន</u> ប្រេង គឺខ្ញុំម្ចាស់ ស្ងោហើយ បញ្ជូនទៅហើយ ។*

២. កាតមំ បន <u>ភន្តេ</u> គន្ធជុរំ ?

*<u>បពិត្រព្រះអង្គដ៏ចំរើន</u> ក៏ រីគន្ធជុរៈ ដូចម្ដេច ?*

*(ចូរមើលវិធីប្រើនិងប្រែអាលបនៈក្នុងមេរៀនទី ២៥ ភាគ ១)*

## ២. កាលត្ថវាចកនិបាត

*(និបាតប្រាប់កាល)*

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| អថ | គ្រានោះ, កាលនោះ, តមក |
| ចាតោ | ពេលព្រឹក, អំពីព្រឹក |
| ទិវា | ថ្ងៃ, ក្នុងវេលាថ្ងៃ |
| សាយំ | ល្ងាច, ក្នុងពេលល្ងាច |
| សុវេ | ថ្ងៃស្អែក, ក្នុងថ្ងៃស្អែក |
| ស្វេ | ថ្ងៃស្អែក, ក្នុងថ្ងៃស្អែក |
| បរសុវេ, បរស្វេ | ខានស្អែក, ថ្ងៃខានស្អែក |
| ហិយ្យោ, ហីយោ | ម្សិលមិញ |
| សម្បតិ | អម្បាញ់មិញ |
| អាយតឹ, អាយតិ | តទៅមុខ, ក្នុងពេលខាងមុខ |

***វិធីប្រើ*** និបាតពួកនេះប្រើប្រាប់កាលវេលា ពេលប្រើក្នុងប្រយោគមានទំនងដូចកិរិយាវិសេសន៍ក្នុងភាសាខ្មែរ ។ ចំពោះ **អថ** និយមប្រើជាមួយ **ខោ** និងរៀងដាក់ខាងដើមប្រយោគ ។ **អថ** ដែលនៅដើមប្រយោគត្រូវប្រែលេខ ២ បន្ទាប់ពីបទអាលបនៈ ក្រៅពីនេះអាចរៀងដាក់ខាងដើមកិរិយាសព្ទឬទីណាដែលសមគួរដូចខាងក្រោមនេះ

**១. <u>អថ</u> ខោ ភគវា ភិក្ខូ អាមន្តេសិ ។**

<u>គ្រានោះ</u> ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅហើយ នូវភិក្ខុ.ទ. ។

២. **សោ <u>ចាតោវ</u>** (=ចាតោ + វ) **អាគតោ ។**

*គាត់ មកហើយ <u>តាំងពីព្រលឹម</u> ។*

៣. **<u>សាយំ</u> សាយមាសាយ <u>ចាតោ</u> ចាតរាសាយ គាមនិគម-រាជធានិយោ ឱសរន្តិ។** (*គេ.ទ.*) *ចូលទៅ កាន់ភូមិនិងនិគមនិងរាជធា-នី.ទ. ដើម្បីបាយល្ងាច <u>ក្នុងពេលល្ងាច</u> ដើម្បីបាយព្រឹក <u>ក្នុងពេលព្រឹក</u> ។*

៤. **ឯកេ សមណព្រាហ្មណា "រត្តិយេវ សមានំ <u>ទិវា</u>"តិ សញ្ជានន្តិ ។** *សមណនិងព្រាហ្មណ៍.ទ. ពួកខ្លះ គិតថា "<u>ពេលថ្ងៃ</u> ដូចជាពេលយប់ដែរ" ។*

៥. **<u>សម្បតិ</u> ជាតោ ពោធិសត្តោ សមេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរាភិមុខោ សត្តបទវីតិហារេន គច្ឆតិ ។**

*<u>អម្បាញ់មិញ</u> ព្រះពោធិសត្វ ទ្រង់ប្រសូត្រហើយ ប្រថាប់ចំពោះហើយ ដោយព្រះបាទ.ទ. ដ៏រាបស្មើ ទ្រង់យាងទៅ ដោយបោះជំហានប្រាំពីរជំហាន មានព្រះភក្ត្រឆ្ពោះទៅទិសខាងជើង ។*

៦. **តថាគតស្ស ខោ សីហ <u>អាយតឹ</u> គព្ភសេយ្យា បហីណា ។**

*ម្នាលសីហៈ ការដេកត្រាំក្នុងគភ៌ របស់តថាគត <u>ក្នុងពេលខាងមុខនោះ</u> អស់ហើយ ។*

៧. **អថស្ស <u>សាយំបិ</u> <u>បុនទិវសេបិ</u> មធុរកត្តំ បចិត្វា អទាសិ ។**

*គ្រានោះ (គេ) ចម្អិនហើយ នូវបាយមានរស់ផ្អែម <u>ក្នុងពេលល្ងាច</u> ផង <u>ក្នុងថ្ងៃស្អែក</u> ផង ឱ្យហើយ ដល់(គេ)នេះ ។*

៨. **ហីយោ អរញ្ញំ គតោ សោ បុរិសោ អហិនា ឌដ្ឋោ មរិ ។**

*ម្សិលមិញ បុរស នោះ ទៅហើយ កាន់ព្រៃ ត្រូវចឹកហើយ ដោយពស់ ស្លាប់ហើយ ។*

*ស័ព្ទខ្លះក៏អាចជានិបាតក្នុងពួកឯទៀតដែរដូចជា* **អថ** *ជាដើម បើប្រែថា "បើ" គឺជាពួកបិរិកប្បត្ថវាចកនិបាត ។* **ទិវា** *បើប្រែថា "វេលាថ្ងៃ" ក៏ក្លាយជានាមវិញដែរ ។*

## ៣. ឋានត្ថវាចកនិបាត

(និបាតប្រាប់ទីឋាន)

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| ឧទ្ធំ | ខាងលើ | អធោ | ខាងក្រោម |
| ឧបរិ | ខាងលើ | ហេដ្ឋា | ខាងក្រោម, ខាងក្រោយ |
| អន្តរា | ចន្លោះ, រវាង | ឱរំ | ត្រើយអាយ, ខាងអាយ |
| អន្តោ | ខាងក្នុង | ចារំ | ត្រើយនាយ, ខាងនាយ |
| តិរោ | ខាងក្រៅ | ហុរំ | លោកដ៏ទៃ, លោកខាងមុខ |
| ពហិ | ខាងក្រៅ | សម្មុខា | ចំពោះមុខ, នៅមុខ |
| ពហិទ្ធា | ខាងក្រៅ | បរម្មុខា | កំបាំង, កំបាំងពីមុខ |
| ពហិរា | ខាងក្រៅ | រហោ | ទីស្ងាត់ |

*មានវិធីប្រើច្រើនបែបដូចខាងក្រោមនេះ*

*ក. ចំពោះ* **អន្តោ** *ប្រើក្រោយនាមជានិច្ច និងនាមបទដែលនៅខាងដើមត្រូវបំបែកជាឆដ្ឋីវិភត្តិ ។ ក្រៅពី* **អន្តោ** *នេះច្រើនប្រើខាងដើមនាមស័ព្ទដូចឧទាហរណ៍ខាងក្រោមនេះ*

១. **ភិក្ខុ គេហស្ស អន្តោ បវិដ្ឋោ ។**

*ភិក្ខុ ចូលទៅហើយ ខាងក្នុង នៃផ្ទះ ។*

២. **ឯវំ ចាសាទស្ស អន្តោ ច ពហិ ច គាឡ្ហារក្ខា អហោសិ ។**

*ការរក្សាមាំមួន ទាំង ខាងក្នុង និង ខាងក្រៅ នៃប្រាសាទ មានហើយ យ៉ាងនេះ ។*

៣. **ឧទ្ធំ អធោ ច តិរិយំ ទិសាស្វនុទិសាស្វហំ អន្វេសំ នាធិគច្ឆាមិ គោធិកោ សោ កុហឹ គតោ ។**

*ខ្ញុំ កាលតាមរក ខាងលើ និង ខាងក្រោម ខាងក្រៅ ក្នុងទិសធំ.ទ. និងទិសតូច.ទ. មិនដឹង គោធិកៈ នោះ ទៅហើយ ក្នុងទីណា ។*

៤. **ឱរំ សមុទ្ទស្ស អតិត្តរូបោ ចារំ សមុទ្ទស្ស បិ បត្ថយេថ ។**

*(បើ)មិនរីករាយក្នុងរូប នៃសមុទ្រ ខាងអាយ អ្នក.ទ. គង់ប្រាថ្នា នូវត្រើយនាយ នៃសមុទ្រ ដែរ ។*

*ខ. ប្រើជាបទប្រធានរបស់អព្យយីភាវសមាស (មានអធិប្បាយនៅខាងមុខ) ឧ.*

១. **នគរស្ស ពហិ** > **ពហិនគរ** *ប្រែថា "ខាងក្រៅនៃនគរ" ។*

២. **តាមស្ស អន្តោ** > **អន្តោតាម** *ប្រែថា "ខាងក្នុងនៃស្រុក" ។*

*គ. មានអំណាចឱ្យប្រែវិបល្លាសនាមសព្ទពីទុតិយាវិភត្តិទៅជាឆដ្ឋីវិភត្តិបាន ឱ.*

**១. ឯកំ សមយំ ភគវា អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។**

*សម័យមួយ ព្រះមានព្រះភាគ ទ្រង់យាងទៅហើយតាមផ្លូវឆ្ងាយ ក្នុងចន្លោះ នៃក្រុងរាជគ្រឹះ ផង ក្នុងចន្លោះ នៃស្រុកនាលន្ទា ផង មួយអន្លើដោយ ភិក្ខុសង្ឃ ដ៏ប្រសើរ មានរយ នៃភិក្ខុទ. ប្រាំជាប្រមាណ ។*

***ប្រែតាមសំដីខ្មែរថា*** *សម័យមួយព្រះមានព្រះភាគទ្រង់យាងទៅតាមផ្លូវក្នុងចន្លោះក្រុងរាជគ្រឹះនិងស្រុកនាលន្ទា មួយអន្លើដោយដោយភិក្ខុសង្ឃទាំងឡាយដ៏ប្រសើរមានប្រមាណ ៥០០ រូប ។*

*ឃ. ប្រើជាបឋមាវិភត្តិឬទុតិយាវិភត្តិបាន ឱ.*

**១. នត្ថិ លោកេ រហោ នាម បាបកម្មំ បកុព្វតោ ។**

*បាបកម្ម ដែលបុគ្គលធ្វើហើយឈ្មោះថា ទីស្ងាត់(សេចក្តីកំបាំង) ក្នុងលោកនេះ មិនមានទេ ។*

២. **អន្តោ** ...... =*វិខាងក្នុង* ..... ។

៣. **ចារំ** ..... =*នូវគ្រើយនាយ ។*

*និបាតពួកទី ៤, ៥, ៦ និង ១៥ សូមមើលក្នុងមេរៀនទី ២៩ ខាងមុខ ។*

## ៧. បដិសេធនត្ថវាចកនិបាត

(និបាតប្រាប់សេចក្ដីហាមឃាត់)

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| ន | មិន, មិនមែន, ពុំ, ឥត, ខាន |
| នោ | មិន, មិនមែន, ពុំ, ឥត, ខាន |
| មា | កុំ |
| វ | ពិត, មែន, គ្រាន់តែ, ប៉ុណ្ណោះ |
| ឯវ | មែន, មែនពិត |
| វិនា | វៀរតែ, វៀរលែង, លើកលែង |
| អលំ | កុំ, កុំឡើយ, ល្មមហើយ, ណ្ហើយ |

**វិធីប្រើ ន** =មិន, **នោ** =មិន, **មា** =កុំ

*ក. ន, នោ បើប្រើបដិសេធកិរិយាសព្ទបទណា ត្រូវរៀងដាក់ខាងដើមបទកិរិយានោះ ៗ ឧ.*

**១. មយំ អជ្ជ បុព្វណ្ហេ ន ឧគ្គណ្ហាម្ហា ។**

*ថ្ងៃនេះ វេលាព្រឹក យើង មិនរៀនទេ ។*

**២. រត្តិយំ តេ អដវីសុ ន វសិស្សន្តិ ។**

*គេ.ទ. នឹងមិននៅ ក្នុងព្រៃ.ទ. ក្នុងពេលយប់ទេ ។*

**៣. កឹ ត្វំ ឧជ្ឈាតុំ ន សក្កោសិ ?**

ហេតុអ្វី អ្នក មិនអាច ដើម្បីក្រោកឡើង ?

ខ. បើប្រើបដិសេធសេចក្ដីនៃប្រយោគទាំងអស់ ត្រូវរៀងដាក់ខាងដើមប្រយោគនោះ ៗ ដូចជា

១. ន ភជេ បាបកេ មិត្តេ ។ មិនគប្បី គប់រក មិត្តអាក្រក់ទេ ។

២. ន ជច្ចា វសលោ ហោតិ ។

មិនមាន អ្នកទាបថោក អំពីកំណើតទេ ។

៣. ន ជច្ចា ហោតិ ព្រាហ្មណោ ។

មិនមាន ព្រាហ្មណ៍ ពីកំណើតទេ ។

គ. មា ស័ព្ទនិយមប្រើបដិសេធមហាកិរិយាដែលជាវត្តមានាវិភត្តិ, ហើយត្តនីនិងអជ្ជត្តនីវិភត្តិប៉ុណ្ណោះ ។ មានរបៀបប្រើដូច ន ដែរ គឺប្រើនៅខាងដើមកិរិយាស័ព្ទ ឬខាងដើមនៃប្រយោគក៏បាន ឧ.

១. តុម្ហេ ឥធ មា និសីទថ ។ អ្នក.ទ. ចូរកុំអង្គុយ ទីនេះ ។

២. មា តេ ឯវំ ករឹសុ ។ គេ.ទ. កុំធ្វើឡើយ យ៉ាងនេះ ។

ឃ. រីឯ វ, ឯវ និយមប្រើជាបទសន្ធិខាងចុងបទដទៃ បើនៅខាងចុងបទណា វេលាប្រែត្រូវអានគួបនឹងបទនោះ ៗ ដូចជា

១. ទារកោ ចាតោវ តស្ស ចាជសាលំ អគមិ ។

កូនក្មេង ទៅហើយ កាន់សាលា របស់វា តាំងពីព្រឹកព្រលឹម ។

២. កស្មា តុម្ហេយេវ មម អាចរិយស្ស លេខនានិ ន លិខិត្ថ។

ហេតុអ្វី អ្នក.ទ.ហ្នឹង មិនសរសេរ សំបុត្រ.ទ. ដល់លោកគ្រូ

*របស់ខ្ញុំ ។*

៣. **អហា<u>មេវ</u> គិលានានំ អជ្ជ ឱសថំ អទាសឹ ។**

*ថ្ងៃនេះ ខ្ញុំហ្នឹង<u>ឯង</u> ឱ្យហើយ នូវឱសថ ដល់អ្នកជំងឺ.ទ. ។*

៤. **កម្មុនា <u>ឃវ</u> វសលោ ហោតិ ព្រាហ្មណោបិ ហោតិ ។**

*ព្រាហ្មណ៍ផង អ្នកទាបថោកផង រមែងមាន ព្រោះកម្ម <u>មែន</u> <u>ពិត</u> ។*

❁ *បើប្រើជាបទសន្ធិគឺអាចប្រែទៅជាដ៏ទៃបានតាមការគួរ ឧ.*

**ឃកោ<u>រ</u>** *=ម្នាក់<u>គត់</u>,* **ចាតោ<u>រ</u>** *=<u>តាំងពី</u>ព្រឹកព្រលឹម ។*

*(ចំពោះរបៀបសន្ធិសូមរកមើលក្នុងមេរៀនខាងមុខ)*

*ង. ចំពោះ* **វិនា** *ឃើញនិយមប្រើក្រោយបទដែលជាតតិយាវិភត្តិ ដូចជា*

១. **អហំ មិត្តេន <u>វិនា</u> គាមំ ន គមិស្សាមិ ។**

*ខ្ញុំ នឹងមិនទៅ កាន់ស្រុក <u>វៀរតែ</u> មិត្តទេ ។*

*ច. ចំណែកឯ* **អលំ** *ជានិបាតក៏ពិតមែន ប៉ុន្តែអាចប្រើក្នុងអត្ថជាបឋមាវិភត្តិ គឺជាបទប្រធានបាន បើប្រើបែបនេះអាចប្រើអាយតនិបាតថា* **វី** *បាន ឧ.* **អលំ** *=រីល្មមហើយ, រីកុំឡើយ ដូចជា*

១. **<u>អលំ</u> ពាលស្ស មោហាយ, នោ ច ចារកវេសិនោ ។**

*<u>រីល្មមហើយ</u> សម្រាប់(បុគ្គល)ពាល វង្វេង ប៉ុន្តែ មិនសម្រាប់អ្នកស្វែងរកត្រើយ (=និព្វាន)ទេ ។*

**២. <u>អលំ</u> អាវុសោ មា សោចិត្ថ មា បរិទេវិត្ថ ។**

*ម្នាលលោកដ៏មានអាយុ <u>ល្មើយចុះ</u> ចូរលោកកុំសោកសៅនិងកុំខ្សឹកខ្សួល ។*

៣. **ឯវមេតំ សុមនេ <u>អល</u>មេវ ធាជានិ ធាតុំ <u>អលំ</u> បុញ្ញានិ កាតុំ ។** *ម្នាលនាងសុមនា <u>រីល្មមហើយ</u> មែនពិត ដើម្បីឱ្យនូវទាន.ទ. <u>រីល្មមហើយ</u> ដើម្បីធ្វើ នូវបុណ្យ.ទ. ដោយប្រការដូច្នេះ ។*

## ៨. អនុស្សវនត្ថនិបាត

*(និបាតប្រាប់សេចក្តីបានឮ)*

**កិរ, ខលុ, សុទំ** *ទាំងបីស័ព្ទនេះប្រែដូចគ្នាថា "បានឮថា, ឮថា, មានសេចក្តីដំណាលថា" ។*

***វិធីប្រើ*** *និយមរៀងដាក់ទី ២ ឬទី ៣ ក្នុងប្រយោគនិងប្រែលេខ ២ បន្ទាប់ពីអាលបនៈ ឱ.*

**១. សាវត្ថិយំ <u>កិរ</u> ឯកោ មហាសុវណ្ណោ ធាម កុដុម្ពិកោ អហោសិ អឌ្ឍោ មហទ្ធនោ មហាភោគោ អបុត្តកោ ។**

*បានឮថា ក្នុងក្រុងសាវត្ថី មាន កុដុម្ពិក៍ មួយរូប ឈ្មោះថា មហាសុវណ្ណ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគច្រើន (តែ)មិនមានបុត្រ ។*

២. តត្រ <u>សុទំ</u> សុប្បិយោ បរិព្វាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ......... <u>បានឮថា</u> ក្នុងផ្លូវឆ្ងាយនោះ សុប្បិយ-បរិព្វាជក ពោល នូវទោស របស់ព្រះពុទ្ធ ដោយអនេកបរិយាយ ....... ។

៣. ជដិលស្ស <u>កិរ</u> គេហេ ភូមឹ ភិន្ទិត្វា សុវណ្ណបព្វតោ ឧដ្ឋិតោ សុត្វា ។ <u>បានឮថា</u> (ព្រះរាជា) បានឮហើយថា ភ្នំមាស ផុះឡើងហើយ ទម្លាយហើយ នូវដី ក្នុងផ្ទះ របស់ជដិល ។

## ៩. បរិកប្បនិបាត

(និបាតប្រាប់សេចក្តីសញ្ជឹង, ប្រមើល, ស្មាន, ណាត់, សម្រេច)

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| ចេ | បើ | អថ | បើ,បើជា (ជំនួស សចេ ) |
| សចេ | បើ, ប្រសិនបើ | អប្បេវ នាម | កាលបើ, ដូចម្តេចហ្ន៎ |
| យទិ | បើ, ប្រសិនបើ, ទោះបី | យន្នូន | បើដូច្នោះ, ដូចម្តេចហ្ន៎ |

***វិធីប្រើ*** និបាតពួកនេះប្រើក្នុងសេចក្តីណាមួយដែលមិនទាន់ដឹងច្បាស់លាស់ គឺថា អំពើនោះ ៗ អាចក្លាយជាការពិតក៏មាន ឬក៏មិនអាចកើតឡើងបានផងនាពេលអនាគតនោះក៏មានដែរ ។ ដូច្នេះប្រយោគ

នោះ ៗ ត្រូវមានពីរសង្កាត់ដូចឧទាហរណ៍ខាងក្រោម

ចេ សព្ទនេះមិនអាចរៀងដាក់ខាងដើមបំផុតនៃប្រយោគបានទេ ត្រូវរៀងទី ២ ជាដាច់ខាត ក្រៅពីនេះអាចរៀងដាក់ទី ១ ខាងដើមបង្អស់នៃប្រយោគបាន ។ ចេ, សចេ, យទិ ប្រែលេខ ២ តាមលំដាប់ប្រែដូចពោលហើយក្នុងមេរៀនទី ២៥ ។ និបាត ៣ សព្ទនេះច្រើនប្រើជាមួយប្រយោគដែលមានមហាកិរិយាជាអនាគតកាល ពីព្រោះជាការរិះគិតដល់កាលខាងមុខ ។ បើជាបច្ចុប្បន្នកាល គឺជាបច្ចុប្បន្នជិតអនាគត ឧ.

១. សោ <u>ចេ</u> យានំ លភិស្សា អគច្ឆិស្សា ។

<u>ប្រសិនបើ</u> គេ បានហើយ នូវយាន(ពាហនៈ), (គេ) នឹងបានទៅហើយ ។

២. <u>សចេ</u> សត្ថា ធម្មំ ទេសេយ្យ វិញ្ញាតារោ ភវិស្សន្តិ ។

<u>ប្រសិនបើ</u> ព្រះសាស្តា សំដែង នូវព្រះធម៌, អ្នកប្រាជ្ញ.ទ. នឹងមាន ។

៣. <u>យន្នូនាហំ</u> (=យន្នូន + អហំ) បព្វជ្ជេយ្យំ ។

<u>ដូចម្តេចហ្ន៎</u> អញ គួរតែបួស ។

៤. <u>អប្បេវ</u> <u>នាម</u> ភគវា អវន្តិទក្ខិណាបថេ កាម្មានិ អត្ថរណានិ អនុជានេយ្យ ។

<u>ដូចម្តេចហ្ន៎</u> ព្រះមានព្រះភាគ ទើបអនុញ្ញាត នូវការប្រើព្រំក្នុងអវន្តីនៃទក្ខិណាបថ (ដែនខាងត្បូង) ។

*ប្រសិនបើប្រើកិរិយា ពួកកិរិយាស័ព្ទ ឬកាលាតិបត្តិ ប្រាប់អនាគតកាល និយមប្រើនិបាតពីរស័ព្ទគឺ ចេ និង សចេ រៀងដាក់ទី ១ ឬទី ២ ។*

*(ចូររកមើលមេរៀនទី ៥ ក្នុងភាគ ១)*

## ១០. បុច្ឆនត្ថនិបាត

*(និបាតប្រាប់សេចក្ដីសួរ)*

| *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|
| កឹ | *ឬ, អ្វី, ហេតុអ្វី, ដូចម្ដេច* |
| កថំ | *យ៉ាងណា, ដូចម្ដេច* |
| កច្ចិ | *ឬ, ដែរឬ, ខ្លះដែរ* |
| នុ | *ហ្ន៎, អេះ, ...ទេដឹង* |
| ននុ | *មិនមែនឬ, ក្រែង, ...ទេដឹង* |
| ឧទាហុ | *ឬថា, ឬក៏* |
| អាទុ | *ឬថា, ឬក៏* |
| សេយ្យថីទំ | *យ៉ាងណានេះ, ដូចម្ដេចនេះ, គឺអ្វីខ្លះ ?* |

***វិធីប្រើ*** *និយមរៀងដាក់ខាងដើមបង្អស់នៃប្រយោគ ។*

១. កឹ គច្ឆាម, ឧទាហុ ចេ ?

*ពួកយើង នឹងទៅឬ ? ឬក៏នឹងមិនទៅទេ ?*

២. **<u>កច្ចិ</u> តេ វក្កលិ ខមនីយំ ? <u>កច្ចិ</u> យាបនីយំ ?**

*ម្នាលវក្កលិ តើអ្នកអត់ទ្រាំបានឬ ? និងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅបាន<u>ដែរឬ</u> ?*

៣. **<u>កថំ</u> តុម្ហេ ឧទកំ តរិតុំ អាកង្ខថ ?**

*តើអ្នក.ទ. ប៉ុនប៉ង ដើម្បីឆ្លង នូវទឹក <u>យ៉ាងម៉េច</u> ?*

៤. **<u>កឹ</u> ជាមេតំ សត្ថារា កតំ ? ញាតំ នុ ខោ កតំ ? <u>ឧទាហុ</u> អជានិត្វា** ? *តើ(កម្ម)នោះ ដែលព្រះសាស្តា ធ្វើហើយ ឈ្មោះ<u>ដូចម្តេច</u> ? (កម្មនោះ ឈ្មោះដូចម្តេច ដែលព្រះសាស្តា) ធ្វើហើយ ដឹងហើយឬ ? <u>ឬក៏</u> មិនទាន់ដឹងទេ ?*

៥. **ទេវតា នុសិ ? គន្ធព្វោ ? <u>អាទុ</u> សក្កោ បុរិន្ទទោ ?**

*អ្នក ជាទេវតាឬ ? ឬជាគន្ធព្វ ? <u>ឬក៏</u> ជាសក្កទេវរាជ ឈ្មោះបុរិន្ទទោ (=អ្នកឱ្យនូវទានក្នុងកាលមុន) ។*

៦. **សត្ថា តស្ស ធម្មំ ទេសេន្តោ អនុបុព្វីកថំ កថេសិ <u>សេយ្យថីទំ</u> ? ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សំកិលេសំ** ។ *ព្រះសាស្តា កាលសម្តែង នូវធម៌ ដល់គាត់ ទើបត្រាស់សម្តែងនូវអនុបុព្វីកថា (សួរថា អនុបុព្វីកថា)គឺអ្វីខ្លះ ? (អនុបុព្វីកថាគឺ) ទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយនិង កិលេសដ៏ថោកទាប ។*

*ក្នុងឧទាហរណ៍ទី ១ ប្រយោគក្រោយគឺ* **ឧទាហុ ទោ** ? មិនមាន

កិរិយាស័ព្ទ **គច្ឆាម** ប្រាកដរូបឱ្យឃើញទេ ប៉ុន្តែសេចក្តីវិញគឺប្រាប់ឱ្យដឹងរួចហើយ និងជាពិសេស **ក៏** ស័ព្ទនេះមានវិធីប្រើក្នុងប្រយោគនានាបាន ៦ យ៉ាង ។ សូមរកមើលក្នុងមេរៀនទី ១១ ភាគ ១ ។

## ១១. សម្បដិច្ឆនត្ថនិបាត

(និបាតប្រាប់សេចក្តីទទួល, ឆ្លើយ)

**អាម**, **អាមន្តា** ប្រែដូចគ្នាថា "អើ, ចាស, បាទ, ករុណាវិសេស, ករុណា, ព្រះករុណា," ជាដើម ដូច្នេះត្រូវលើកយកណាមួយប្រែឱ្យសមគួរតាមឋានៈខ្ពស់កណ្តាលឬទាប ។

***វិធីប្រើ*** និយមរៀងដាក់ដើមប្រយោគនិងប្រែលេខ ២ បន្ទាប់ពីអាលបនៈ ឧ.

១. **<u>អាម</u> ភន្តេ គច្ឆាមិ ។**

បពិត្រលោកម្ចាស់ដ៏ចម្រើន <u>បាទ</u> (ខ្ញុំ) នឹងទៅ ។

២. **<u>អាម</u> ភន្តេ ន សក្កា តត្ថ វសិតុំ ។**

បពិត្រលោកម្ចាស់ដ៏ចម្រើន <u>ចាស</u> (គឺនាងខ្ញុំ) មិនអាច ដើម្បីរស់នៅ ក្នុងទីនោះទេ ។

៣. **<u>អាម</u> ភន្តេ** ។ <u>ព្រះករុណា</u> លោកម្ចាស់ (នេះជាពាក្យទទួលក្នុងពិធីសមាទានសីល ។

## ១២. ឧយ្យោជនត្ថនិបាត

(និបាតប្រាប់សេចក្តីតឿន, អញ្ជើញ)

| ស័ព្ទបាលី | ពាក្យប្រែ |
|---|---|
| ឥង្ឃ | ដូចជាតឿន, ហ៎ំ, ហ៎ំចុះ, ចុះ, អញ្ជើញ |
| តគ្ឃ | ហ៎ំ, ហ៎ំចុះ, ចុះ |
| ហន្ទ | ហ៎ំ, បើដូច្នោះ, អញ្ជើញ |
| តេនហិ | ហ៎ំ, បើដូច្នោះ, អញ្ជើញ, ព្រោះហេតុនោះ |

**វិធីប្រើ** *រៀងដាក់ដើមប្រយោគនិងប្រែលេខ ២ បន្ទាប់អាលបនៈ ឧ.*

១. ឥង្ឃ ភន្តេ សាបេហិ ។

បពិត្រលោកដ៏ចម្រើន សូមអញ្ជើញលោក (ញុំាង...) ឱ្យរឭក មើលចុះ ។

២. តគ្ឃ អាវុសោ អច្ចយោ អច្ចគមា ។

ម្នាលលោកដ៏មានអាយុ ហ៎ំ ទោស បានកន្លងហួសហើយ ។

៣. តេនហិ ថេរោ ភិក្ខូ ឱចិនតុ ។

បើដូច្នោះ ព្រះថេរៈ ចូរជ្រើសរើស នូវភិក្ខុ.ទ.ចុះ ។

## ១៣. អនេកត្ថនិបាត

(និបាតប្រាប់សេចក្តីច្រើនយ៉ាង)

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| ច | ផង, ក៏, មែនពិត, មួយទៀត |
| វា | ក្តី, ឬ, ខ្លះ, ក៏ដោយ, ក៏បាន, ពុំនោះសោត |
| បន | ក៏, ចំណែកឯ, ប៉ុន្តែ, ប៉ុន្តែថា |
| អបិ, បិ | ដែរ, ខ្លះ, ក៏បាន, ក៏មាន, ក៏ដោយ, ក្រែង, ថ្វីបើ, ជួនជា |
| ហិ | ក៏, ពិត, មែន, មែនពិត, ព្រោះ, ដ្បិត, សេចក្តីថា |
| តុ | ក៏, ប៉ុន្តែ, ចំណែកឯ, មួយវិញទៀត |
| អបិច | អើក៏, មួយវិញទៀត, ពុំនោះសោត |
| អថវា | ឬ, មួយវិញទៀត, ម្យ៉ាងទៀតថា |

**វិធីប្រើ** និយមរៀងដាក់ទី ២ ខ្លះ, ទី ៣ ខ្លះ, ទី ៤ ខ្លះ ។

សព្ទទាំងនេះ ខ្លះសម្រាប់ប្រើតភ្ជាប់បទមួយនិងបទមួយទៀតដែលត្រូវរៀងដាក់ខាងចុងបទនោះ ៗ, ខ្លះទៀតសម្រាប់ប្រើតភ្ជាប់ប្រយោគនិងប្រយោគ គឺតភ្ជាប់ឯកត្ថប្រយោគចាប់ពីពីរប្រយោគឡើងទៅឱ្យទៅជាអនេកត្ថប្រយោគ គឺប្រយោគដែលមានអត្ថច្រើនយ៉ាង ។ និបាតពួកនេះមានលក្ខណៈដូចសន្ធានសព្ទក្នុងភាសាខ្មែរ ។

**ធនំ មេ អត្ថិ, វិជ្ជា <u>បន</u> មេ នត្ថិ ។**

ទ្រព្យ របស់ខ្ញុំ មាន, <u>ប៉ុន្តែ</u> វិជ្ជា របស់ខ្ញុំ មិនមាន ។

**ប្រែតាមសំដីខ្មែរថា** ខ្ញុំមានទ្រព្យ ប៉ុន្តែខ្ញុំមិនមានការចេះដឹងទេ ។

ច និង វា សម្រាប់ប្រើភ្ជាប់បទមួយនិងបទមួយទៀត បទនោះ ៗ អាចជានាមនាមឬជាកិរិយាស័ព្ទ និងត្រូវរៀង ច និង វា ខាងចុងរាល់ ៗ បទ ។ ប៉ុន្តែក៏អាចប្រើ ច ឬ វា ត្រឹមតែមួយបទនៅខាងចុងបំផុតនៃនាម ឬកិរិយាស័ព្ទទាំងនោះក៏បាន ឧ.

១. នរា ច នារិយោ ច បុញ្ញំ កត្វា សុគតីសុ ឧប្បជ្ជិស្សន្តិ ។

*នរៈ.ទ ផង នារី.ទ. ផង ធ្វើហើយ នូវបុណ្យ នឹងទៅកើត ក្នុង សុគតិ ។*

២. អម្ហេសុ តុម្ហេសុ ច គហបតិយោ ន កុជ្ឈេយ្យុំ ។

*គហបតី.ទ. មិន គប្បីក្រោធ ក្នុងអ្នក.ទ. និង យើងខ្ញុំ.ទ. ។*

៣. អហំ កសាមិ ច វបាមិ ច ។ ឬ អហំ កសាមិ វបាមិ ច ។

*ខ្ញុំ ភ្ជួរ ផង ខ្ញុំ សាប ផង ។ ឬ ខ្ញុំ ភ្ជួរ និង សាប ។*

៤. ឋិតោ វា និសិន្នោ វា គច្ឆន្តោ វា សយន្តោ(សយានោ) វា អហំ សព្វេសុ សត្តេសុ មេត្តំ ករោមិ ។

*ខ្ញុំ ទោះឈរ ក្តី ទោះអង្គុយ ក្តី ទោះដើរ ក្តី ទោះដេក ក្តី តែង ធ្វើ នូវមេត្តា ក្នុងសត្វ.ទ. ទាំងពួង ។*

៥. ទុតិយម្បិ (=ទុតិយំ + បិ) ពុទ្ធំ សរណំ គច្ឆាមិ ។

*ខ្ញុំព្រះករុណា សូមដល់ នូវព្រះពុទ្ធ ពីរដងផង ។*

៦. អហំ ហិ សមណ កសាមិ ច វបាមិ ច ។

*ម្នាលសមណៈ មែនពិត ខ្ញុំ ភ្ជួរ ផង សាប ផង ។*

៧. យោ ពុទ្ធំ បរិភាសតិ <u>អថវា</u> តស្ស សាវកំ ...

*ជនណា ជេរ ព្រះពុទ្ធ <u>ឬ</u> សាវក របស់ព្រះអង្គ ... ។*

៨. សោ កីឡតិ អហំ <u>តុ</u> បឋាមិ ។

*វា កំពុងលេង <u>ចំណែក</u> ខ្ញុំ កំពុងអាន ។*

## ១៨. បទបូរណនិបាត

*(និបាតបំពេញបទ)*

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| នុ | ហ្ន, ហ៎, ហ៎ះ, ហ្ន៎ះ | នូន | នែ |
| សុ | ហ៎, ហ៎ះ, ហ្ន៎ះ | ខោ | ឯង |
| វេ | ឡើយ, ហើយ, ហ៎ះ | វត | ហ្ន៎, អើហ្ន៎, យី, យីអើ |
| វោ | វើយ, យី, ហ្ន៎ះ, ហ្ន៎ | ហាវេ | ហើយ, វើយ, យី, ហ៎ះ, ហ្ន៎ះ |
| ហិ | ឯង, ហ្នឹងឯង | សេ | ហ្ន៎ះ, ហ៎ះ, ហ៎, សិន |

***វិធីប្រើ*** *និយមប្រើបំពេញបទនៅក្នុងគាថា ត្រូវការបំពេញបទណាក៏រៀងដាក់ចុងបទនោះ ៗ ដើម្បីឱ្យគ្រប់អក្ខរៈឬគ្រប់ព្យាង្គ ឬឱ្យពីរោះតាមភាសានិយម វេលាប្រែត្រូវអានគួបជាមួយបទដែលខ្លួនបំពេញ ។*

*ចំពោះពាក្យប្រែរបស់និបាតទាំងឡាយនេះ វេលាប្រែពុំចាំបាច់ប្រែ*

ក៏បាន ពីព្រោះនិបាតដែលប្រើជាបទបូរណៈនេះ ស័ព្ទខ្លះហាក់ដូចជាមិនមានអត្ថក្នុងភាសាខ្មែរយើងទេ ។ សូមមើលឧទាហរណ៍ខាងក្រោមនេះ

១. សច្ចំ <u>វេ</u> អមតា វាចា ។ ពាក្យពិត ជាវាចា មិនស្លាប់ ។

២. ធម្មោ <u>ហវេ</u> រក្ខតិ ធម្មចារឹ ។ ធម៌ តែងរក្សា អ្នកប្រព្រឹត្តធម៌ ។

៣. ន <u>វេ</u> រុទន្តិ សតិមន្តោ សបញ្ញា ។
អ្នកមានបញ្ញា.ទ. ដែលមានសតិ មិនយំទេ ។

៤. តត្រ <u>ខោ</u> ភគវា ភិក្ខូ អាមន្តេសិ ។
ព្រះមានព្រះភាគ ត្រាស់ហៅហើយ នូវភិក្ខុ.ទ. ក្នុងទីនោះ ។

៥. កាថំ អម្ហេ ការោម <u>សេ</u> ? យើង.ទ. នឹងធ្វើ ដូចម្តេច ?

៦. យេហិ <u>វោ</u> អរិយា បរិសុទ្ធកាយកម្មន្តា... ។
ព្រះអរិយៈ.ទ. មានកាយកម្មស្អាតហើយ ដោយ(ធម៌.ទ.) ឯណា ... ។

## លំហាត់នៃមេរៀនទី ២៨

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើពាក្យថា **និបាត** ប្រែថាដូចម្តេច ?

២. តើនិបាតស័ព្ទជាស័ព្ទប្រភេទយ៉ាងណា ? មានប៉ុន្មានយ៉ាង ?

៣. តើនិបាតស័ព្ទខុសពីឧបសគ្គយ៉ាងដូចម្ដេចខ្លះ ?

៤. តើនិបាតឈ្មោះអ្វីប្រើប្រាប់កាលវេលា ? សូមឱ្យឧទាហរណ៍ ។

៥. តើនិបាតឈ្មោះអ្វីប្រើប្រាប់ទីកន្លែង ? សូមឱ្យឧទាហរណ៍ ។

៦. តើនិបាតឈ្មោះអ្វីប្រើប្រាប់សេចក្ដីហាមឃាត់ ? សូមឱ្យទាហរណ៍ ។

៧. តើនិបាតឈ្មោះអ្វីប្រើប្រាប់សេចក្ដីថាបានឮ ? សូមឱ្យឧទាហរណ៍ ។

៨. តើនិបាតឈ្មោះអ្វីប្រើប្រាប់សេចក្ដីសញ្ជឹង ? សូមឱ្យឧទាហរណ៍។

៩. តើនិបាតឈ្មោះអ្វីប្រើប្រាប់សេចក្ដីសួរ ? សូមឱ្យឧទាហរណ៍ ។

១០. តើនិបាតឈ្មោះអ្វីប្រើប្រាប់សេចក្ដីអញ្ជើញ ? សូមឱ្យឧទាហរណ៍ ។

១១. តើនិបាតឈ្មោះអ្វីប្រើប្រាប់សេចក្ដីច្រើនយ៉ាង? សូមឱ្យឧទាហណ៍។

១២. តើនិបាតឈ្មោះអ្វីប្រើគ្រាន់តែបំពេញបទ ? សូមឱ្យឧទាហរណ៍ ។

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. អត្តនោ សខារំ ជេតា មិត្តោ ន ហោតិ ។

២. ទូតោ អាគម្ម រញ្ញោ សង្គាមស្ស បវត្តឹ បដិវេទេសិ ។

៣. ចោរេសុ ពលវន្តេសុ ជាតេសុ រាជានោ ទុព្វលា ហោន្តិ ។

៤. តទា ពារាណសិយំ រជ្ជំ អបុត្តកោ រាជា នាម នាហោសិ ។

៥. សក្កោសិ នុ ខោ ត្វំ តាត បច្ចាមិត្តេន រាជិនា សទ្ធឹ យុទ្ធំ កាតុំ ?

៦. ឯតំ ហិ បុព្វនិមិត្តំ ព្រហ្មុនោ បាតុភាវាយ ។

៧. អហំ បិតរា ច មាតុយា ច ភាតរេហិ ច សខារេហិ ច សទ្ធឹ

ចេតិយានិ វន្ទមានោ ជម្ពុទីបេ តត្រ តត្រ វិចរឹ ។

៨. មម បិតរិ តហឹ អគច្ឆន្តេ អហម្បិ តហឹ គន្តុំ ន សក្កោមិ ។

៩. មាតរិ ច ទុហិតរិ ច វសវតិយំ ឱទនំ បចន្តីសុ បុត្តោ កុមារេហិ សទ្ធឹ អង្គណេ កីឡតិ ។

១០. តថាគតេ បរិនិព្វុតេ ពហូ ទេវា មនុស្សា ច មហតា សោកេន កម្បិតា អហេសុំ ។

១១. ភិក្ខូសុ វិត្ថិយំ បិណ្ឌាយ ចរន្តេសុ ឧបាសកា ច ឧបាសិកាយោ ច នានាវិធានិ ខជ្ជានិ ភោជ្ជានិ ច គហេត្វា មគ្គស្ស បស្សេ អដ្ឋំសុ ។

១២. សត្ថរិ ធម្មំ ទេសេន្តេ ភិក្ខូ ច ភិក្ខុនិយោ ច ឧបាសកា ច ឧបាសិកាយោ ច សោតំ ឱទហន្តា និសីទឹសុ ។

១៣. ទីឃេន មគ្គេន កន្តារានំ ភណ្ឌានិ ចោរា អបហរឹសុ ។

១៤. បិតរិ កាលំ កតេ មាតា ច បុត្តា ច ទុហិតរោ ច ភាតរោ ច សមីបេ កន្ទមានា អដ្ឋំសុ ។

១៥. ភគវា ព្រហ្មុនា យាចិតោ ឥសិបតនំ គន្ត្វា ធម្មំ ទេសេសិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. នាកាលក្មេងប្រុស.ទ. កំពុងច្រៀង ក្មេងស្រី.ទ. រាំ ។*

*២. ធម៌ តែងរក្សា នូវអ្នកប្រព្រឹត្តនូវធម៌ ។*

*៣. នរៈ.ទ. ផង នារី.ទ. ធ្វើហើយ នូវបុណ្យ រមែងកើត ក្នុងសុគតិ ។*

៤. ដំរីឈ្មោល.ទ. ផង ដំរីញី.ទ. ផង កំពុងដើរ ក្នុងព្រៃ ផង ក្នុងភ្នំ ផង ។
៥. បងស្រី មួយអន្ទើ ដោយប្ដី របស់គាត់ នឹងទៅ ដើម្បីឃើញ ឪពុក
ក្នុងថ្ងៃស្អែក ។
៦. ម្សិលមិញ ខ្ញុំ នៅហើយ ឯផ្ទះ របស់បងប្រុស ថ្ងៃនេះ មកហើយ
ទីនេះ តាំងពីព្រឹក ។
៧. ព្រះថេរៈ កំពុងសំដែង នូវធម៌ ក្នុងវិហារ ក្នុងកាលឥឡូវនេះ
តើអ្នក.ទ. មិនទៅ ដើម្បីស្ដាប់ នូវធម៌ ក្នុងទីនោះ ទេឬ ?
៨. នែកូន ភ្លៀង កំពុងបង្អុរចុះ ក្នុងកាលឥឡូវនេះ (អ្នក.ទ.) ចូរកុំទៅ
ខាងក្រៅ ។
៩. ព្រះពុទ្ធ ត្រូវភិក្ខុ.ទ. ផង ឧបាសក.ទ. ផង ថ្វាយបង្គំ និង
បូជាហើយ ។
១០. យើង.ទ. រស់នៅ ដោយធម៌ ប៉ុន្តែ មិនដោយអធម៌ទេ ។
១១. ម៉ែ, តើឥឡូវនេះ យើង ទៅ ទីណា ?
១២. បពិត្រលោកដ៏ចំរើន យើងខ្ញុំ.ទ. មិនឃើញ នូវបាប ដោយភ្នែក.ទ.។
១៣. ម្នាលលោកដ៏មានអាយុ (អ្នក.ទ.) កុំឈរ ខាងមុខ នៃភិក្ខុ.ទ. ។

**(ចប់មេរៀនទី ២៨)**

# មេរៀនទី ២៩

## អធិប្បាយអំពីនិបាតស័ព្ទ (តចប់)
## និង ប្រយោគ ៣ យ៉ាង

### ១៨. នានត្ថនិបាត

*(និបាតប្រាប់សេចក្ដីផ្សេង ៗ)*

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| អថោ | មួយវិញទៀត | សហ | ជាមួយ, មួយអន្លើ |
| អទ្ធា | ដោយពិត, ប្រាកដ | បដ្ឋាយ | ចាប់ដើម, តាំងពី |
| អវស្សំ | ដោយពិត, មែន | អាវិ | ច្បាស់, ប្រាកដ, ជាក់ |
| អហោ | ឱ, ក្រៃពេក | ឧច្ចំ | ខ្ពស់ |
| អារា | ឆ្ងាយ, ពីចម្ងាយ | ក្វចិ | ខ្វះ |
| នីចំ | ទាប | មិច្ឆា | ខុស |
| ននុ | ដោយពិត, មែន | មុធា | ទទេ |
| នានា | ផ្សេង ៗ, ទីទៃ ៗ | មុសា | កុហក, មិនពិត |
| បច្ឆា | ខាងក្រោយ | បុន | ទៀត |
| សកឹ | មួយគ្រា, ម្ដង | សទ្ធឹ | ជាមួយ, មួយអន្លើ |
| បភុតិ | ចាប់ដើម, តាំងពី | សយំ | ឯង, ខ្លួនឯង |

| | |
|---|---|
| **បុនប្បុនំ** | *រឿយ ៗ, ញឹកញយ* |
| **សាមំ** | *ឯង, ខ្លួនឯង* |
| **កិយ្យោសោ** | *ក្រៃលែង* |
| **កិយ្យោ** | *ក្រៃលែង* |
| **ឥតិ** | *ព្រោះហេតុនោះ, ដូចនេះថា* |
| **កិញ្ចាបិ** | *ប្រាកដហើយ, សូម្បីតិចតួច* |
| **សតក្ខត្តុំ** | *មួយរយដង, មួយរយលើក* |
| **សណិកា** | *តិច ៗ, លប ៗ, សន្សឹម ៗ, ថ្នម ៗ* |

*និបាតពួកនេះមានវិធីប្រើក្នុងប្រយោគផ្សេង ៗ បានច្រើនប្រការដូចតទៅនេះ*

*១. ប្រើជាបទបំពេញព្យាង្គក្នុងគាថាក៏បាន ឧ.*

**ជិព្ពុតា នូន សា មាតា ។បេ។.**

*មាតា នោះ រលត់ហើយ មែន ។ល។*

*២. ប្រើធ្វើកិរិយាស័ព្ទឱ្យមានសេចក្ដីប្លែកឡើង បើទាក់ទងជាមួយបទណាត្រូវរៀងដាក់ខាងដើមបទនោះ ៗ ឧ.*

**មា បុន ករោហិ** ។ *ឯង ចូរកុំធ្វើ ទៀត ។*

**ជនា បុនប្បុនំ បុញ្ញំ ករេយ្យុំ** ។ *ជន.ទ. គួរធ្វើ នូវបុណ្យ រឿយ ៗ ។*

*៣. ចំពោះ* **ឧច្ចំ, នីចំ** *ជានិបាតក្លាយពីគុណនាម ។*

៤. **ឥតិ** មួយស័ព្ទនេះប្រែបាន ១០ យ៉ាងនិងមានវិធីសរសេរចូលជាបទសន្ធិដែលគប្បីដឹងផងដែរ (ចូរមើលក្នុងមេរៀនទី ៣០ ខាងមុខ) ។

៥. ប្រើចុះពីខាងដើមបទដទៃជាបទសមាស (ចូរមើលក្នុងមេរៀនទី ៤៥) ឧ.

(**មិច្ឆា** + **ទិដ្ឋិ**) > **មិច្ឆាទិដ្ឋិ** =ការឃើញខុស ។

(**មុសា** + **វាទ**) > **មុសាវាទ** =ការពោលពាក្យកុហក ។

៦. **សទ្ធឹ** និង **សហ** ពីរស័ព្ទនេះនិយមរៀងដាក់ខាងចុងបទដទៃ ហើយបទនាមដែលនៅខាងដើមត្រូវបំបែកជាតតិយាវិភត្តិជានិច្ច ឧ.

**អហំ ភន្តេ តុម្ហេហិ សទ្ធឹ ន គច្ឆាមិ ។**

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំម្ចាស់ នឹងមិនទៅ ជាមួយ លោក.ទ.ទេ ។

**មយំ ភន្តេ តិសរណេន សហ បញ្ច សីលានិ យាចាម ។**

បពិត្រលោកម្ចាស់ដ៏ចំរើន យើងខ្ញុំ.ទ. សូមសុំ នូវសីល.ទ. ប្រាំមួយអន្លើ ដោយសរណៈ ៣ ។

៧. **សហ** ស័ព្ទអាចប្រើជាបទសមាសបាន បើប្រើដូច្នេះត្រូវលុប **ហ** ចេញទុកត្រឹមតែ **ស** ឧ. (**សហ** + **បរិវារំ**) > **សបរិវារំ** ប្រែថា ព្រមដោយបរិវារ ឬ មានបរិវារ ។ **សហ** នេះមានយកមកប្រើក្នុងភាសាខ្មែរយ៉ាងច្រើនដូចជា សហករណ៍, សហគមន៍, សហរដ្ឋ ជាដើម ។ល។

៨. **សយំ** បើប្រើជាបទសមាសអាចផ្លាស់ជា **សក** ឬ **ស** ក៏បាន

ឬទុកឱ្យគង់រូបដើមក៏បានដែរដូចជា

(**សយំ** + **ភាវោ**) > **សភាវោ** =*ភាវៈកើតឯង ។*

(**សយំ** + **អត្ថោ**) > **សកត្ថោ** =*អត្ថរបស់ខ្លួន ។*

(**សយំ** + **កត្តា**) > **សយកត្តា**, **សយំកត្តា** =*អ្នកធ្វើខ្លួនឯង ។*

(**សយំ** + **ភូ**) > **សយម្ភូ** =*អ្នកកើតឯង (ព្រះសយម្ភូ) ។*

*សូមសង្កេតមើល និបាតមួយពួកនេះមានវិធីប្រើក្នុងប្រយោគបានច្រើនយ៉ាងដូចបានពោលរួចមកហើយ ។ សូមសង្កេតមើលវិធីប្រើនិងវិធីរៀង កាលបើបានជួបក្នុងទីណា ៗ នឹងអាចប្រែបានភ្លាម ៗ ។*

## ប្រយោគ ៣ ប្រភេទ

*មុននឹងពោលពីនិបាតដែលនៅសល់ ក្នុងទីនេះសូមអធិប្បាយអំពីរឿងប្រយោគបន្តិចដើម្បីឱ្យអ្នកសិក្សាងាយស្រួលយល់ចូលចិត្ត ពីព្រោះនិបាតពួកខ្លះ វេលាប្រើ ច្រើនប្រើជាគូគ្នា ដូចការប្រើ* **យ-ត** *សព្វនាមដែរ ។ បើនិយាយដោយពិស្ដារមានប្រយោគច្រើនយ៉ាង ប៉ុន្តែបើរាប់តាមវាចកៈ មាន ៥ យ៉ាង ហើយប្រយោគទាំងអស់នោះបើពោលតាមអត្ថមានត្រឹមតែ ៣ ប្រភេទប៉ុណ្ណោះគឺ* **ឯកត្ថប្រយោគ**, **សង្ករប្រយោគ**, **អនេកត្ថប្រយោគ** ។

ប្រយោគនីមួយ ៗ អាចចែកជាពីរភាគគឺ **ភាគប្រធាន** និង **ភាគ-កិរិយាស័ព្ទ** ឱ.

**បុរិសោ ខេត្តំ កសតិ ។**

ភាគប្រធាន ភាគកិរិយាស័ព្ទ

ក. **ឯកត្តប្រយោគ** បានដល់ ប្រយោគណាដែលមានត្រឹមតែមួយអត្ថប៉ុណ្ណោះ គឺមានត្រឹមតែភាគប្រធាននិងភាគកិរិយាស័ព្ទ ឱ.

១. **កុមារោ រោទតិ ។** ក្មេងប្រុស យំ ។

២. **កោ ត្វំ ឯតំ បុច្ឆសិ ។** ឯង ជានរណា សួរ (នូវបញ្ហា)នេះ ?

៣. **ន ភជេ បាបកេ មិត្តេ ។** (គេ) មិនគប្បីគប់ ក្នុងមិត្ត អាក្រក់ ។

៤. **គច្ឆ ។** (ឯង) ចូរទៅ ។

ក្នុងប្រយោគខាងលើនេះ **កុមារោ, ត្វំ** ជាភាគប្រធាន ។ រីឯក្នុងឧទាហរណ៍ទី ៣ និងទី ៤ បទប្រធានមិនប្រាកដរូបទេ តែអាចដឹងបានថាជា **សោ** និង **ត្វំ** ដោយសារវិភត្តិរបស់កិរិយាស័ព្ទប្រាប់ ។ ភាគប្រធានក៏អាចមានបទវិសេសនៈអធិប្បាយដែរ ។

សល់ពីនេះជាភាគកិរិយាស័ព្ទទាំងអស់គឺ ... **រោទតិ ។ កោ ... ឯតំ បុច្ឆសិ ។ ន ភជេ បាបកេ មិត្តេ ។ គច្ឆ ។**

ខ. **សង្ករប្រយោគ** បានដល់ ប្រយោគណាដែលមានពីរប្រយោគនិងក្នុងប្រយោគនីមួយ ៗ មានភាគប្រធាននិងភាគកិរិយាស័ព្ទដូចក្នុង

*ឯកត្តប្រយោគដែរ ប៉ុន្តែមានប្រយោគមួយត្រូវពឹងផ្អែកលើប្រយោគមួយទៀតដើម្បីធ្វើសេចក្តីឱ្យពេញលេញ ឧ.*

**សចាហំ គេហំ គមិស្សតិ, មាតាបិតាហោ មំ តជ្ជេស្សន្តិ ។**

*ប្រសិនបើ ខ្ញុំ ទៅ ផ្ទះ, ម៉ែនិងពុក នឹងគម្រាម ខ្ញុំ ។*

*ឧទាហរណ៍ខាងលើនេះសឱ្យឃើញថា*

*ប្រយោគខាងដើម* **សចាហំ គេហំ គមិស្សតិ** *ជាប្រយោគទី ១ ។*

*ប្រយោគខាងចុង* **មាតាបិតាហោ មំ តជ្ជេស្សន្តិ** *ជាប្រយោគទី ២ ។*

*ក្នុងឧទាហរណ៍នេះ ប្រយោគទី ១* **សចាហំ គេហំ គមិស្សតិ** *មិនអាចខ្វះ ប្រយោគទី ២* **មាតាបិតាហោ មំ តជ្ជេស្សន្តិ** *បានទេ ពីព្រោះស្តាប់ទៅមិនទាន់អស់សេចក្តី ត្រូវពឹងប្រយោគមួយទៀតមកបំពេញឱ្យពេញលេញ ប្រយោគប្រភេទនេះ ហៅថា* **អនុប្រយោគ** *។ រីឯប្រយោគ* **មាតាបិតាហោ មំ តជ្ជេស្សន្តិ** *ចាត់ជា* **មហាប្រយោគ** *ព្រោះស្តាប់បានសេចក្តីគ្រប់គ្រាន់ល្អហើយ ។*

*យ៉ាងណាមិញប្រយោគ* **យ** *ក៏ត្រូវតែពឹងប្រយោគ* **ត** *ដែរ ឧ.*

**យេ បុញ្ញំ ករោន្តិ តេ សគ្គេ និព្វត្តន្តិ ។**

*បុគ្គល.ទ.ណា តែងធ្វើ នូវបុណ្យ បុគ្គល.ទ.នោះ រមែងកើត ក្នុងឋានសួគ៌ ។*

*ប្រយោគ* **យេ បុញ្ញំ ករោន្តិ** *ជាអនុប្រយោគ ។*

*ប្រយោគ* **តេ សគ្គេ និព្វត្តន្តិ** *ជាមហាប្រយោគ ។*

៣. **អនេកត្ថប្បយោគ** បានដល់ ប្រយោគណាដែលមានអត្ថច្រើនយ៉ាង គឺការយកឯកត្ថប្រយោគឬសង្ករប្រយោគចាប់ពីពីរប្រយោគឡើងទៅ មកចងឱ្យចូលគ្នាជាប្រយោគមួយដោយប្រើនិបាតដែលដូចជាសន្ធានស័ព្ទក្នុងភាសាខ្មែរ ឧ.

**១. ថេរោ មូលសិរឹ បគ្គោសាបេសិ <u>អថ</u> មហាជនកាយោ សន្និបតិ ។**

*ព្រះថេរៈ ញ៉ាំងមូលសិរី ឲ្យស្រែកហៅហើយ <u>កាលនោះ</u> ក្រុមមនុស្សដ៏ច្រើន កំពុងប្រជុំគ្នា ។*

*ឧទាហរណ៍នេះក្រុមបទថា* **ថេរោ មូលសិរឹ បគ្គោសាបេសិ** *ជាប្រយោគមួយនិងក្រុមបទថា* **មហាជនកាយោ សន្និបតិ** *ជាប្រយោគមួយដែរ ទាំងពីរប្រយោគនេះជាឯកត្ថប្រយោគដូចគ្នា ស្តាប់បានសេចក្តីពេញលេញល្អហើយ តែត្រូវបានយកមកតភ្ជាប់គ្នាដោយ* **អថ** *ស័ព្ទដែលជានិបាត ទើបចាត់ជាអនេកត្ថប្រយោគ ។*

**២. សចស្ស គេហទ្វារំ គមិស្សាមិ, ឥមស្ស ភរិយា មំ ទត្ថុំ ន សក្ខិស្សតិ, យាវស្ស ភត្តំ អាទាយ មគ្គំ បដិបជ្ជតិ តាវ ឥធេវ ភវិស្សាមិ ។** *ប្រសិនបើ អញ ទៅ កាន់ទ្វារផ្ទះ របស់វា ប្រពន្ធ របស់វា នឹងមិនអាច ឃើញ អញទេ, (ព្រោះហេតុនោះ) គេ យកហើយ នូវបាយ របស់វា និងកំពុងដើរទៅ ក្នុងផ្លូវ ដរាបណា ដរាបនោះ អញ នឹងនៅ ក្នុងទីនេះឯង ។*

ឧទាហរណ៍នេះមានសង្ករប្រយោគ ២ ប្រយោគដែលតភ្ជាប់គ្នាដោយ **តស្មា** (<u>ព្រោះហេតុនោះ</u>) ដែលមិនមានក្នុងប្រយោគទេ តែអាចដឹងបាន ។ ប្រយោគនេះក្រុមបទថា **សចស្ស** ...... **ន សក្ខិស្សតិ** ជាសង្ករប្រយោគមួយនិងក្រុមបទថា **យាវស្ស** ...... **ករិស្សាមិ** ជាសង្ករ-ប្រយោគមួយទៀត ។ សូមអធិប្បាយអំពីរឿងប្រយោគក្នុងទីនេះត្រឹមតែប៉ុណ្ណេះចុះ ។

## ៤. បរិកប្បនិបាត

(និបាតប្រាប់សេចក្ដីកំណត់)

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| **យាវ** | ដរាបណា, ត្រឹមណា | **តាវ** | ដរាបនោះ, ត្រឹមនោះ |
| **យាវតា** | មានប្រមាណប៉ុនណា | **តាវតា** | មានប្រមាណប៉ុណ្ណោះ |
| **យាវទេវ** | កំណត់ត្រឹមណា | **តាវទេវ** | កំណត់ត្រឹមនោះ |
| **កីវ** | ប៉ុន្មាន, ប៉ុនណា | **សមន្តា** | ជុំវិញ |
| **កិត្តាវតា** | មានប្រមាណប៉ុន្មាន | **ឯត្តាវតា** | មានប្រមាណប៉ុណ្ណោះ |

១. និបាតពួកនេះនិយមប្រើជាគូគ្នា និងរៀងដាក់ខាងដើមនៃប្រ-យោគនីមួយ ៗ គឺក្នុងសង្ករប្រយោគដូចជា

**<u>យាវ</u>ហំ** < ( **យាវ** + **អហំ** ) **គច្ឆាមិ**, **<u>តាវ</u> ឥធ តិដ្ឋ** ។

ខ្ញុំ ដើរទៅ <u>ដរាបណា</u> <u>ដរាបនោះ</u> (អ្នក.ទ.) ចូរឈរនៅ ទីនេះ ។

<u>យាវ</u> ជំ អានេមិ <u>តាវ</u> ឥធេវ តិដ្ឋាហិ ។

*ខ្ញុំ នឹងនាំមក នូវវា <u>ដរាបណា</u> <u>ដរាបនោះ</u> (អ្នក)ចូររង់ចាំ ក្នុងទីនេះឯង ។*

*២. មិនប្រើជាគូគ្នាក៏បាន និងនិយមរៀង* **យាវ** *ដាក់ខាងដើមបទនាម ហើយបទនាមដែលនៅខាងចុងនោះត្រូវមានរូបជាបញ្ចមីវិភត្តិ ឱ.*

**អជស្ស (= អជ + អស្ស) សត្ថា <u>យាវ</u> អរហត្តា កម្មដ្ឋានំ កថេសិ ។** *គ្រានោះ ព្រះសាស្តា ត្រាស់សម្តែងហើយ នូវព្រះកម្មដ្ឋាន <u>ដរាបដល់</u>ព្រះអរហន្ត ដល់(មហាបាលភិក្ខុ)នោះ ។*

**ឥតិហ តេន ខណេន មុហុត្តេន <u>យាវ</u> ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ ។** *សំឡេង លាន់ឮហើយ <u>ដរាបដល់</u>ព្រហ្មលោក ដោយរំពេចនោះ ក្នុងខណៈនោះឯង ដោយប្រការយ៉ាងនេះ ។*

*៣.* **តាវ** *=ដរាបនោះ ប្រសិនបើនៅទោលតែឯងហើយរៀងនៅខាងដើមកិរិយាស័ព្ទច្រើនប្រើសម្រាប់អធិប្បាយកិរិយាស័ព្ទ ប្រែថា "...សិន" ឱ.*

**ភាតិក តុំ តរុណាយេវ <u>តាវ</u> តិដ្ឋ, មហល្លកកាលេ បព្ពជិស្សេថ ។** *បពិត្របងប្រុស បងជាមនុស្សក្មេងពិតមែន ចូរបងឈប់<u>សិន</u> សូមបងបួស ក្នុងកាលនៃខ្លួនចាស់ចុះ ។*

*៤. ប្រើក្នុងបុច្ឆនត្ថប្រយោគដែលរៀងដាក់ខាងដើមបទដទៃឬជាបទសន្ធិជាមួយគុណនាមក៏បាន ឱ.*

**<u>កីវ</u> <u>ចិរំ</u> វិមានស្មឹ ឥធ វស្សសុបោសថេ** (**វស្សសិ** + **ឧបោ-សថេ**) ? *ម្នាលឧបោសថ ថាតើ អ្នក នឹងនៅ(ចូលវស្សា) ក្នុងវិមាន ក្នុងទីនេះ <u>យូរប៉ុន្មាន</u>* ?

( **កីវ** + **មហន្ត** ) > **កីវមហន្ត** =*ធំប៉ុនណា*, **យាវមហន្ត** =*ធំប៉ុនណា* ឧ. ១. **<u>កីវមហន្តំ</u> មេ ចក្កយុគំ ករិស្សសិ ។**

*អ្នកនឹងធ្វើ នូវគូនៃកង់ <u>ធំប៉ុនណា</u> សម្រាប់ខ្ញុំ* ?

២. **<u>យាវមហន្តំ</u> អាកង្ខសិ ។**

*អ្នក ប្រាថ្នា <u>ធំប៉ុនណា</u>* ?

## ៥. ឧបមានុបមេយ្យត្ថនិបាត

(*និបាតប្រាប់សេចក្តីប្រៀបប្រដូច*)

| **បាលី** | ***ពាក្យប្រែ*** |
|---|---|
| **វិយ** | *ដូច, បីដូច, ប្រហែលដូច* |
| **ឥវ** | *ដូច, ដូចជា, ប្រដូច* |
| **យថា** | *ដូចជា, យ៉ាងណា, យ៉ាងណាមិញ* |
| **សេយ្យថា** | *ដូចជា, ដូចម្តេចមិញ, យ៉ាងណាមិញ* |
| **តថា** | *ដូច្នោះ, យ៉ាងនោះ* |
| **ឯវំ** | *យ៉ាងនេះ, យ៉ាងនោះ, ដូច្នោះ* |

មានវិធីប្រើដូចខាងក្រោមនេះ

១. ប្រើប្រៀបប្រដូចនាមបទមួយទៅនឹងនាមបទមួយទៀត ។ នាមបទណាដែលត្រូវធ្វើការប្រៀបប្រដូចជាមួយនោះត្រូវរៀង **វិយ** **ឥវ** ដាក់ខាងចុង ។ វេលាប្រែត្រូវអានគួបជាមួយបទនោះ ៗ គឺថាគួបឬរួបដោយអំណាចនៃឧបមានុបមេយ្យ ឧ.

**តស្សា ទ្វេ អក្ខីនិ ទីបសិខា _វិយ_ ជិញ្ជាសិសុ ។**

ភ្នែក.ទ. ពីរ របស់ស្រីនោះ រលត់ហើយ _បីដូច_ អណ្ដាតភ្លើង.ទ. ។

**សមណា _វិយ_ មយម្បិ សទ្ធាយ ធម្មំ សុណាម្ហា ។**

យើង.ទ. ស្ដាប់ នូវធម៌ ដោយសេចក្ដីជ្រះថ្លា _ដូច_សមណ.ទ. ។

**ពាលា ទុម្មេធា ចរាការ កម្មានិ កាពេន្តា អមិត្តេន អត្តនា _ឥវ_ ចរន្តិ ។** ជនពាល.ទ. ជាមនុស្សខ្លៅ កាលធ្វើ នូវអំពើ អាក្រក់ តែងប្រព្រឹត្ត មានខ្លួនឯង _ដូចជា_ ជាសត្រូវ ។

**ឥវ** ក៏និយមប្រើជាបទចុងក្នុងបទសន្ធិដោយលុប **ឥ** ចោលសល់នៅត្រឹមតែ វ ប៉ុណ្ណោះដែរ ។ វេលាប្រែត្រូវញែកតាមស័ព្ទដើមវិញ ឧ.

**សត្តេហិ កតានិ បុញ្ញានិ កម្មានិ ឆាយា_វ_ តេ អនុគច្ឆន្តិ ។**

អំពើ.ទ. ដែលជាកុសល គឺសត្វ.ទ. ធ្វើហើយ រមែងទៅតាម គេ.ទ. _ដូច_ស្រមោល ។

............ **ចក្កំ_វ_ វហតោ បទំ ។** (**ចក្កំ_វ_** < **ចក្កំ ឥវ**) =_ដូច_កង់ដែលកំពុងអូស តាមដានជើង (នៃគោ) ........ ។

*២. ប្រើប្រៀបប្រដូចសេចក្ដីនៃប្រយោគមួយជាមួយនឹងប្រយោគមួយទៀត ដែលនិយមរៀងដាក់ដើមប្រយោគ ។ បើ* **យថា, សេយ្យថា** *ប្រើក្នុងអនុប្រយោគ ។ រីឯ* **តថា, ឯវំ** *ប្រើក្នុងមហាប្រយោគ ឧ.*

**យថា ច អបគតកណ្ហមោ រហទោ បសន្នោទកោ ហោតិ, ឯវំ អបគតក្កិលេសតាយ រាគកណ្ហមាទីហិ អបគតកណ្ហមោ វិប្បសន្នោវ ហោតិ ។**

*"* **ហិ, ច, បន** *" ស័ព្ទនៅខាងចុង* **យថា** *ក្នុងប្រយោគឧបមាឧបមេយ្យត្រូវប្រែថា "ឧបមាថា" គ្រប់កន្លែងបែបដូច្នេះ*

**ច** *ឧបមាថា* **រហទោ** *រីអន្លង់ទឹក* **អបគតកណ្ហមោ** *មានភក់ទៅប្រាសហើយ* **បសន្នោទកោ ហោតិ** *ជាទឹកដ៏ថ្លា* <u>**យថា**</u> <u>*យ៉ាងណា*</u> (**សោ ខីណាសវភិក្ខុ** *រីភិក្ខុជាខីណាស្រព នោះ* **អបគតកណ្ហមោ** *ឈ្មោះថាមានភក់ទៅប្រាសហើយ)* **រាគកណ្ហមាទីហិ** *ចាកភក់.ទ.មានភក់គឺរាគៈជាដើម* **អបគតក្កិលេសតាយ** *ព្រោះភាវជាអ្នកមានកិលេសទៅប្រាសហើយ* **វិប្បសន្នោ វ ហោតិ** *ជាអ្នកថ្លាផូរផង់ មែនពិត* <u>**ឯវំ**</u> <u>*យ៉ាងនោះ*</u> *។*

**ចន្ទិមោ លោហិតេន ផុដោ អហោសិ <u>សេយ្យថា</u>បិ គវាឃាតានំ ។**

*ការចង្រ្កម (របស់សោណៈ) ផ្សាយទៅហើយ (=ប្រឡាក់) ដោយឈាម* <u>*ដូចជា*</u> *(ការប្រឡាក់ដោយឈាម) របស់អ្នកសម្លាប់គោ.ទ. ។*

## ៦. បការត្ថនិបាត

*(និបាតប្រាប់ប្រការ)*

| *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|
| **ឯវំ** | *ដោយប្រការនេះ, ដោយប្រការដូច្នេះ* |
| **តថា** | *ដោយប្រការដូច្នោះ* |
| **កថំ** | *ដោយប្រការដូចម្ដេច* |
| **យថា** | *ដោយប្រការណា* |

***វិធីប្រើ*** *និយមរៀងដាក់ខាងដើមប្រយោគ មានដំណើរដូចនិបាតប្រាប់បរិច្ឆេទនិងនិបាតប្រាប់ឧបមានុបមេយ្យដែរ ។ បើប្រើអធិប្បាយកិរិយាស័ព្ទណារៀងដាក់ខាងដើមនៃស័ព្ទនោះ ៗ ទៅនិងជាពិសេស* **យថា-តថា** *និយមប្រើក្នុងសង្ការប្រយោគដែលមានពីរសេចក្ដី ឧ.*

**<u>យថា</u> សោ បុរិសោ ន ជានាតិ, <u>តថា</u> ករោមិ ។**

*រីបុរស នោះ មិនដឹង <u>ដោយប្រការណា</u>, ខ្ញុំ នឹងធ្វើ <u>ដោយប្រការដូច្នោះ</u> ។*

*ចំណែកឯ* **ឯវំ** *និយមរៀងខាងដើមប្រយោគ ឬបើប្រើអធិប្បាយកិរិយាស័ព្ទណា ក៏រៀងដាក់ខាងដើមកិរិយាស័ព្ទនោះ ៗ ឧ.*

**<u>ឯវំ</u> ខោ អានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ ។**

*ម្នាលអានន្ទ ទាន រមែងបរិសុទ្ធ ពីខាងអ្នកឱ្យ <u>ដោយប្រការដូច្នេះ</u> ។*

<u>ឯវំ</u> វទេហិ ។ (ឯង) *ចូរពោល <u>ដោយប្រការយ៉ាងនេះ</u> ។*

មា <u>ឯវំ</u> អកាសិ។ (ឯង) *កុំបានធ្វើហើយ <u>ដោយប្រការយ៉ាងនេះ</u>។*

*បើមាន* **ឯវ** *ស័ព្ទនៅខាងចុងវិញនិយមធ្វើសន្ធិចូលគ្នាដោយផ្លាស់និគ្គហិតទៅជា* **ម** *និងចុះ* **ម** *អាគមទៅជា* **ឯវម្មេ** *រៀងដាក់ខាងដើមប្រយោគ ឧ.*

<u>ឯវម្មេ</u> ឥមេ សត្តា ទីបជាលា វិយ ឧប្បជ្ជន្តិ ចេវ និរុជ្ឈន្តិ ច ។

*វីសត្វ.ទ. នេះ តែងកើតឡើងដោយពិតផង តែងរលត់ផង បីដូច វីអណ្តាត នៃប្រទីប.ទ. (=កំពុងកើតកំពុងរលត់) <u>ដោយប្រការដូច្នេះ</u> <u>មែនពិត</u> ។*

<u>ឯវំ</u> មេ សុតំ *ទៅជា* <u>ឯវម្មេ</u> សុតំ ។

*ខ្ញុំម្ចាស់ បានស្តាប់ មកហើយ <u>យ៉ាងនេះ</u> ។*

*ប្រយោគនេះបានដល់វាចារបស់ព្រះអានន្ទ ដែលបានពោលឡើងនៅខាងដើមនៃសូត្រនីមួយ ៗ ក្នុងសុត្តន្តបិដក ។*

## និបាតប្រើជាបទប្រធាន

**ឯវំ, តថា, អលំ, អជ្ជ** *បួនស័ព្ទនេះជានិបាតមែនពិត តែអាចប្រើជាបទប្រធានក្នុងអត្ថជាបឋមាវិភត្តិបាន ដូចឧទាហរណ៍ខាងក្រោមនេះ*

<u>ឃរំ</u> **តិរ អាវុសោ ?**

ម្នាលលោកដ៏មានអាយុ បានឮថា <u>រីយ៉ាង់នោះ</u> ឬ?

<u>ឃរមេវ</u> **ភន្តេ ?** បពិត្រលោកដ៏ចម្រើន <u>រីយ៉ាង់ហ្នឹងឯង</u> ឬ?

## វិធីប្រែ បិ ឬ អបិ ស័ព្ទបន្ថែម

**បិ** ឬ **អបិ** ពីរស័ព្ទនេះនិយមប្រើភ្ជាប់ខាង់ចុងបទដទៃ មិននិយមប្រើតែឯង់ទេ និង់អាចប្រែបានច្រើនយ៉ាង់ដូចជា "មែន, សូម្បី, ទុកជា, ដែរ, ខ្លះ, ក៏បាន, ក៏មាន, ក៏ដោយ, ថ្វី, ក្រែង់, ជួនជា, ក៏" ។ ពាក្យប្រែនីមួយ ៗ ប្រើបានសេចក្តីផ្សេង់ ៗ គ្នាដែលមានឈ្មោះហៅតាមសម្ពន្ធដូចតទៅនេះ

១. ហៅថា **អបេក្ខត្ថ** គឺសំដៅដល់ **បិ** ឬ **អបិ** ដែលប្រើភ្ជាប់ជាមួយបទនាមនាមឬសព្វនាមដែលជាប្រធានតែមួយបទដូច

**អានន្ទត្ថេរោ<u>បិ</u>** = <u>សូម្បីព្រះ</u>អានន្ទ ។

**អហម្<u>បិ</u>** (**អហំ** + **បិ**) **គមិស្សាមិ** ។ <u>សូម្បីខ្ញុំ</u> នឹង់ទៅ ។

ក្រៅពីនេះ **បិ** ស័ព្ទក៏អាចប្រើភ្ជាប់ជាមួយស័ព្ទនិបាតដូចគ្នាបានដែរដូចជា **ឥតិ<u>បិ</u>** =<u>សូម្បី</u>ព្រោះហេតុនោះ, **កិញ្ចា<u>បិ</u>** =<u>សូម្បី</u>ដោយពិត, **យថា<u>បិ</u>** =<u>សូម្បី</u>ដូចនោះ ។ល។

*២. ហៅថា* **សម្ភាវនត្ថ** *បានដល់* **បិ** *ឬ* **អបិ** *ស័ព្ទដែលប្រើភ្ជាប់ជាមួយបទវិកតិកត្តា ដែលនៅខាងចុងបទប្រធាន ប្រើក្នុងសេចក្ដីស្ទើច, សរសើរ និងអាចប្រែថា "សូម្បី...ម្ទឹងហើយ, ទុកជា...ម្ទឹងហើយ, ទោះបី...ម្ទឹងហើយ....." ឧ.*

**អយំ ជាតិសម្បន្នោ<u>បិ</u> មានំ ន ករោតិ ។**

*រីបុគ្គលនេះ <u>សូម្បី</u>ជាអ្នកដល់ព្រមហើយដោយជាតិ<u>ម្ទឹងហើយ</u> រមែងមិនធ្វើនូវមានៈ(ការប្រកាន់ខ្លួន) ។*

**អម្ហាកំ ពហុស្សុតោ <u>អបិ</u> អាចរិយោ បមាណំ ជានាតិ ។**

*លោកគ្រូ របស់យើង <u>ទុកជា</u>លោកជាអ្នកមានចំណេះច្រើន<u>ម្ទឹងហើយ</u> តែងដឹង នូវប្រមាណ ។*

*៣. ហៅថា* **គរហត្ថ** *មានលក្ខណៈដូចលេខ ២ ដែរ ប៉ុន្តែប្រើក្នុងសេចក្ដីតិះដៀល, បន្ទុះបង្អាប់ វិញដូចជា*

**អយំ ពលិទ្ទោ<u>បិ</u> បមាណំ ន ជានាតិ ។** *បុគ្គលនេះ <u>សូម្បី</u>ជាអ្នកក្រីក្រ<u>ម្ទឹងហើយ</u> រមែងមិនដឹង នូវប្រមាណ(របស់ខ្លួន) ។*

**អយំ អប្បសុតោ <u>អបិ</u> អត្តនោ បមាណំ ន ជានាតិ ។**

*បុគ្គលនេះ <u>សូម្បី</u>តែ ចេះតិច<u>ម្ទឹងហើយ</u> មិនដឹង នូវប្រមាណ នៃខ្លួនទៀត ។*

*៤. ហៅថា* **សមុច្ចយត្ថ** *បានដល់* **បិ** *ស័ព្ទដែលភ្ជាប់ជាមួយបទប្រធានច្រើនតួដែលមានបទកិរិយាជាពហុវចនៈ និងប្រែយកតែសេចក្ដី*

និយមប្រែថា "ទាំង" មានសេចក្ដីដូច ច ស័ព្ទដែលប្រែថា "ផង" ឧ.

**អនាថបិណ្ឌិកោបិ វិសាខាបិ មហាឧបាសិកា និពទ្ធំ ទិវសស្ស ទ្វេ វារេ តថាគតស្ស ឧបដ្ឋានំ គច្ឆន្តិ ។**

ទាំងអនាថបិណ្ឌិក ទាំងមហាឧបាសិកាឈ្មោះវិសាខា រមែងទៅកាន់ទីឧបដ្ឋាក របស់ព្រះតថាគត អស់វារៈ.ទ. ពីរដង នៃថ្ងៃ ជានិច្ច ។

៥. ហៅថា **វិកប្បត្ថ** បានដល់ **បិ** ស័ព្ទដែលប្រើគួបជាមួយបទប្រធានច្រើនបទ ប៉ុន្តែមានបទកិរិយាជាឯកវចនៈវិញ ដើម្បីធ្វើឱ្យសេចក្ដីញែកចេញជាប្រភេទ ៗ ។ វេលាប្រែយកតែសេចក្ដីនិយមប្រែថា "ខ្លះ" មានសេចក្ដីដូច វា ស័ព្ទដែលប្រែថា "ឬ" ដែរ ឧ.

**គព្ភាមីនំ ឝមីនំ បុណ្ណកាលោបិ ឝនកាលោបិ សុក្ខកា-លោបិ បញ្ញាតិ ។**

កាលជាទីពេញខ្លះ កាលជាទីកន្ទះខ្លះ កាលជាទីស្ងួតខ្លះ រមែងប្រាកដ ដល់ស្ទឹងនិងទន្លេ.ទ. មានទន្លេគង្គាជាដើម ។

## សេចក្ដីរំលឹក

ចំណុចផ្សេង ៗ ដូចបានពោលហើយទាំងអស់នេះ ត្រូវសិក្សាឱ្យយល់ចូលចិត្តមួយចំណុចម្ដង ៗ ។ លុះដល់វេលារៀនប្រែ **ធម្មបទដ្ឋកថា** (ធម្មបទ)លោកអ្នកនឹងបានជួបប្រយោគដែលប្រកបដោយលក្ខណៈដូច

ពោលហើយនេះមិនខាន គឺមាននៅទូទៅពេញធម្មបទទាំង ៨ ភាគ ។ ប្រសិនបើយើងយល់សេចក្ដីអធិប្បាយផ្សេង ៗ នេះល្អហើយ នោះជឿក្នុងចិត្តចុះថា លោកអ្នកនឹងប្រែធម្មបទបានភ្លាម ៗ ។

ការរៀនអំពីក្រិត្យក្រមផ្សេង ៗ (វេយ្យាករណ៍) តាំងពីដើមរហូតដល់ពេលនេះនិងតទៅខាងមុខទៀត គឺត្រូវរៀនឱ្យយល់ដឹងឱ្យបានល្អទុកមុន ទើបអាចប្រែធម្មបទទាំង ៨ ភាគបាន ។ ប្រសិនបើខ្វះជំនាញទុកមុន នោះការរៀនថ្នាក់ខ្ពស់ឡើងតទៅទៀតគង់មានការលំបាក ពីព្រោះខ្វះគ្រឹះ គឺមានការយល់ដឹងមិនគ្រប់គ្រាន់ នាំឱ្យកើតសេចក្ដីនឿយណាយ ធ្វើឲ្យមានអារម្មណ៍ថាពិបាករៀន ។ ផ្ទុយទៅវិញ បើយើងមានការយល់ដឹងរាល់ចំណុចដូចបានពោលហើយ នោះឃើញថាពុំលំបាកហួសពេកទេ ជាពិសេសពាក្យអធិប្បាយត្រង់ណានៅមិនទាន់យល់ សូមអានហើយអានទៀតឱ្យបានច្រើនដង និងត្រិះរិះមើលពាក្យអធិប្បាយនោះ ៗ យឺត ៗ ពិចារណាអំពីវិធីធ្វើ(គឺសេចក្ដីពន្យល់)ឱ្យត្រឹមត្រូវ ហើយកន្លែងណាជាចំណុចសំខាន់ត្រូវមើលឱ្យចាំ ។

លោកអ្នកខ្វះបណ្ដោតបណ្ដោយខ្លួន ហើយមិនមានការយល់ដឹងនិងចងចាំសេចក្ដីអធិប្បាយឱ្យបានល្អទេ ។ ការធ្វើយ៉ាងហ្នឹងហៅថាមិនមានការយល់ចូលចិត្តក្នុងវិជ្ជាដែលខ្លួនកំពុងរៀន រួចបែរជាយល់ថាជាវិជ្ជាដែលពិបាករៀនទៅវិញ ។

# លំហាត់នៃមេរៀនទី ២៩

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើនិបាតប្រាប់សេចក្តីផ្សេង ៗ ឈ្មោះអ្វី ?

២. តើនិបាតប្រាប់សេចក្តីកំណត់ ឈ្មោះអ្វី ?

៣. តើនិបាតប្រាប់សេចក្តីប្រៀបប្រដូច ឈ្មោះអ្វី ?

៤. តើនិបាតប្រាប់ប្រការ ឈ្មោះអ្វី ?

៥. បើរាប់ដោយសង្ខេបតើប្រយោគមានប៉ុន្មាន ឈ្មោះប្រយោគអ្វីខ្លះ ?

៦. ប្រយោគនីមួយ ៗ មាន ២ ចំណែក គឺអ្វីខ្លះ ?

៧. តើឯកត្តប្រយោគជាប្រយោគដូចម្តេច ?

៨. តើសង្ករប្រយោគជាប្រយោគដូចម្តេច ?

៩. តើអនេកត្តប្រយោគជាប្រយោគដូចម្តេច ?

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. តុម្ហាកំ បុត្តា ច ធីតរោ ច ឧជុំ តរិត្វា ភណ្ឌានិ មូលំ
បរិយេសិតុំ ឥច្ឆន្តិ ។

២. អម្ហេហិ កតានិ កម្មានិ ឆាយា យោ វិយ អម្ហេ អនុពន្ធន្តិ ។

៣. សចេ ត្វំ ទ្វារំ ឋកេសិ អហំ បវិសិតុំ ន សក្កោមិ ។

៤. សព្វេ តេ សប្បុរិសា តេសំ បញ្ញោ វិស្សជ្ជេតុំ វាយមន្តា
សាលាយំ និសិន្នា ហោន្តិ ។

៥. យថា ភគវា ធម្មំ ទេសេតិ តថា តុម្ហេហិ បដិបជ្ជតព្វំ ។

៦. ពហូ មនុស្សា ធម្មេ បសន្នា ធម្មំ ចរិត្វា សគ្គេ ឧប្បន្នា អហេសុំ

៧. តុម្ហេ រាគស្ស បហានំ បញ្ញាបេថ ទោសស្ស បហានំ បញ្ញាបេថ មោហស្ស បហានំ បញ្ញាបេថ ។

៨. អកុសលំ ភិក្ខវេ បជហថ សក្កា ភិក្ខវេ អកុសលំ បជហិតុំ ។

៩. រថំ វហតោ អស្សស្ស បាទេ អនុគច្ឆន្តានិ ចក្កានិ វិយ បាបានំ កម្មានំ វិបាកា តានិ ការកេ អនុគច្ឆន្តិ ។

១០. អរញ្ញេ សេនាសនេ វិហរន្តេសុ ភិក្ខូសុ មនុស្សា ភិយ្យោ បសីទន្តិ ។

១១. សិទ្ធត្ថោ កុមារោ រថេន ឧយ្យានំ គច្ឆន្តោ មគ្គស្ស បស្សេ សេមានំ គិលានំ បុរិសំ អទ្ទក្ខិ ។

១២. គីតំ គាយន្តិយា ធញ្ញានិ ឧទ្ធរន្តិយា ឥត្ថិយា សទ្ទំ សុណន្តា តេ មហតោ រុក្ខស្ស ឆាយាយំ វិស្សមឹសុ ។

១៣. ភិក្ខុនី វីថិយំ បិណ្ឌាយ ចរមានា អាគច្ឆន្តំ រថំ ទិស្វា មគ្គតោ អបក្កមិ ។

១៤. សោ ផលិនោ រុក្ខស្ស អាមំ ផលំ ឆិន្ទតិ តស្ស រសំ ន ជានាតិ តេន តស្ស ពីជំ បិ វិនស្សតិ ។

១៥. ស្វាក្ខាតោ ភគវតា ធម្មោ ធម្មំ នមស្សាមិ ។

### គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. កូនប្រុស សូម្បីម្ដាយហាមម៉ឺងហើយ ទៅហើយ បួសហើយ ។

២. បុគ្គល អ្នកប្រព្រឹត្តនូវធម៌ រមែងដេក ជាសុខ, អ្នកប្រព្រឹត្តនូវអំពើ-បាប រមែងដេក ជាទុក្ខ ។

៣. អ្នកដឹកនាំ ជាអ្នកប្រកបដោយធម៌ មាន ក្នុងទីឯណា មនុស្ស.ទ. តែងរស់នៅ ជាសុខ ក្នុងទីនោះ ។

៤. សេចក្ដីប្រាថ្នា សេចក្ដីតាំងទុក គឺយើង.ទ. តែងសម្រេច ក្នុងកាល-ណា គឺយើង.ទ. តែងរីករាយ ក្នុងកាលនោះ ។

៥. កូនប្រុស របស់គហបតី មួយរូប ឪពុក កាលស្លាប់ ធ្វើហើយ នូវកិច្ច.ទ. ទាំងពួង ក្នុងផ្ទះ ផង ក្នុងស្រែ ផង ដោយខ្លួនឯង ម្នាក់ឯង ។

៦. កូនប្រុស សួរហើយ នឹងម្ដាយ ថា "ម៉ែ, តើម៉ែ គប្បីទៅ កាន់ត្រកូលឈ្មោះ ណាមួយ ?"

៧. សម័យ មួយ អគ្គសាវ័ក.ទ. របស់ ព្រះមានព្រះភាគ សុំលាហើយ ចេញហើយ ពីក្រុងសាវត្ថី ទៅហើយ កាន់ក្រុងរាជគ្រឹះ ។

៨. ក្នុងសម័យ មួយ ទេវតា មួយព្រះអង្គ ចូលទៅជិតហើយ នូវព្រះពុទ្ធ ក្នុងរាត្រី ថ្វាយបង្គំហើយ ដោយសេចក្ដីជ្រះថ្លា ឈរហើយ លើដី ។

៩. ទេវតា នោះ ឈរហើយ សួរហើយ នូវប្រស្នា មួយ នឹងព្រះពុទ្ធ ។

១០. អ្នក អាចដើម្បីរាស់ នូវទឹក ក្នុងសមុទ្រ ដោយអាឡ្ហកៈ ម្នាលអ្នក-ដឹងសព្វ អ្នក មិនអាច ដើម្បីរាស់ ចំណោះដឹងឡើយ ។

**យទា** =*ក្នុងកាលឯណា*, **តទា** =*ក្នុងកាលនោះ ។*
**អាបុច្ឆិត្វា** =*លាហើយ, សុំអនុញ្ញាតហើយ ។*
**បត្តិត** =*សេចក្តីតាំងទុក*, ( **សំ** + **ឥជ** + **យ** ) **សមិជ្ឈ** =*សម្រេច*,
**មុជ** ឬ **មោជ** =*រីករាយ, ត្រេកអរ,* **បមេតុំ**, **បមេតវេ** =*ដើម្បីរាស់ ។*
**កិច្ច** =*ការងារ, កិច្ច ។*
**អាឡ្ហក** =*មាត្រាវង្វាស់មួយប្រភេទ (មួយអាឡ្ហកស្មើនឹង ៤ នាឡិ) ។*

***(ចប់មេរៀនទី ២៩)***

# មេរៀនទី ៣០

# អធិប្បាយអំពីការសរសេរនិងប្រើ ឥតិ ស័ព្ទ

## វិធីសរសេរ ឥតិ ស័ព្ទ

**ឥតិ** *ជានិបាតស័ព្ទប្រាប់សេចក្ដីផ្សេង ៗ ដែលអាចប្រែបានច្រើនយ៉ាងនិងជាអព្យយស័ព្ទ ហើយនិយមប្រើជាបទសន្ធិជាមួយស័ព្ទដទៃ (ប្រើទោលតែឯងមានតិចតួច) គឺអាចធ្វើសន្ធិចូលក្នុងបទនាមក៏បាន ឬបទកិរិយាសព្ទ័ក៏បាន ។ បើនៅខាងចុងបទណាត្រូវសរសេរចូលជាមួយបទនោះ ៗ តាមវិធីសន្ធិដូចមានគោលការណ៍ ៣ យ៉ាងដូចខាងក្រោមនេះ*

*១.* **ឥតិ** *ស័ព្ទបើនៅខាងចុងបទនាមឬបទកិរិយាដែលមានទីបំផុតជាស្រៈរស្សៈគឺ* អ, ឥ, ឧ *វេលាសរសេរចូលគ្នាត្រូវលុបស្រៈ* ឥ *នៃ* **ឥតិ** *ចេញទុកនៅត្រឹមតែ* **តិ** *ហើយទីឃៈស្រៈបទដើមគឺ* អ > អា, ឥ > ឦ, ឧ > ឩ *ឱ.*

មាណវ (ន.) + ឥតិ > មាណវាតិ (អ > អា)

ការោតិ (កិ.) + ឥតិ > ការោតីតិ (ឥ > ឦ)

ហោតុ (កិ.) + ឥតិ > ហោតូតិ (ឧ > ឩ)

២. ឥតិ ស័ព្ទបើនៅខាងចុងបទនាមឬបទកិរិយាដែលមានទីបំផុតជាស្រៈវែងគឺ អា, ឦ, ឩ, ឯ, ឱ ដែលជាស្រៈទីឃៈស្រាប់ ត្រូវលុប ឥ នៃ ឥតិ ចេញទុកនៅតែ តិ ហើយសរសេរចូលគ្នាដោយពុំចាំបាច់ទីឃៈស្រៈទៀតទេ ឧ.

កាសិតា + ឥតិ > កាសិតាតិ
ឥត្ថី + ឥតិ > ឥត្ថីតិ
វធូ + ឥតិ > វធូតិ
ភិក្ខវេ + ឥតិ > ភិក្ខវេតិ
ចាលោ + ឥតិ > ចាលោតិ

៣. ឥតិ ស័ព្ទបើនៅខាងចុងបទនាមឬបទកិរិយាដែលមានទីបំផុតជានិគ្គហិតនៅលើស្រៈឬលើព្យញ្ជនៈក៏ដោយ ត្រូវលុប ឥ នៃ ឥតិ ចេញទុកនៅតែ តិ ហើយផ្លាស់និគ្គហិតនោះជា ន ដែលជាវគ្គន្តព្យញ្ជនៈរបស់ ត វគ្គ រួចហើយយកមកសរសេរចូលគ្នាដោយតម្រួតជា ន្តិ ឧ.

កាតំ > កាតន + ឥតិ > កាតន្តិ
តស្មឹ > តស្មិន + ឥតិ > តស្មិន្តិ
កាតុំ > កាតុន + ឥតិ > កាតុន្តិ

## កំណត់សម្គាល់

*វិធីសរសេរ* **ឥតិ** *ស័ព្ទដូចពោលហើយនេះ សូមចងចាំឱ្យបានល្អ ពីព្រោះមានប្រើក្នុងគម្ពីរផ្សេង ៗ ទូទៅ ដូចជាក្នុងព្រះត្រៃបិដកជាដើម និងជាពិសេសត្រូវរៀនមើលឱ្យស្គាល់ថាបទនោះ ៗ មាន* **ឥតិ** *ស័ព្ទ ឬគ្មានទេ ពីព្រោះបទខ្លះមើលទៅមានរូបដូច* **តិ**, **អត្ថិ** *វត្តមានាវិភត្តិដែរ ។ វេលាប្រែជាភាសាខ្មែរត្រូវអានញែក* **ឥតិ** *ស័ព្ទចេញពីគ្នា ។*

*នៅក្នុងអត្ថបទឬសូត្រនីមួយ ៗ រមែងមានប្រយោគគ្រប់ប្រភេទលាយឡំគ្នា គឺប្រយោគនិទ្ទេស, ប្រយោគបដិសេធ, ប្រយោគបុច្ឆា(សួរ) ជាដើម ។ ចំពោះប្រយោគដែលមាន* **ឥតិ** *ស័ព្ទនៅផង គឺជាប្រយោគដែលជនម្នាក់លើកយករឿងរ៉ាវអ្វីមួយមកពោល ដោយស្រង់យកសំដីនៃតួអង្គណាមួយក្នុងរឿងនោះមកនិយាយ ដូចជាយកសំដីរបស់តួអង្គមួយមកនិយាយឡើងវិញថាយ៉ាងនេះឬយ៉ាងនោះ ឧ.*

*ម្ដាយនិយាយទៅកាន់កូនស្រីថា "កូនត្រូវខិតខំរៀនណ៎ា" ។*

*កូនស្រីតបវិញថា "ចាំម៉ែ" ។*

*ពាក្យនៅក្នុងអញ្ញប្រកាសសញ្ញា "..." នេះជាសំដីដែលគេនាំមកនិយាយឡើងវិញ គឺជាសំដីផ្ទាល់របស់ម្ដាយនិងកូននិយាយគ្នា ។*

*ក្នុងគម្ពីរភាសាបាលីជាភាសាខ្មែរយើង ដូចជាគម្ពីរព្រះត្រៃបិដកជាដើម សំដីបែបដូច្នេះ លោកមិនប្រើអញ្ញប្រកាសសញ្ញាទេ លោកប្រើត្រឹមតែ* **ឥតិ** *ស័ព្ទប៉ុណ្ណោះខ័ណ្ឌនៅខាងចុង ដែលអាចធ្វើឱ្យអ្នកមិនទាន់ស្ទាត់ក្នុងរឿងនេះមានការលំបាកមិនល្មមទេ ។*

## វិធីប្រែ ឥតិ ស័ព្ទ

**.................. ឥតិ, ............ ឥតិ, ........... ឥតិ ....... ។**

*វេលាប្រែប្រយោគមាន* **ឥតិ** *ស័ព្ទនៅផង ត្រូវរកមើលថាបទណាខ្លះជាបទរបស់ប្រយោគក្នុងនិងបទណាខ្លះជាបទរបស់ប្រយោគក្រៅ ។ ពាក្យថាប្រយោគក្នុង បានដល់ ប្រយោគទាំងឡាយណាដែលនៅខាងក្នុងអញ្ញប្រកាសសញ្ញា (“...”) ។ រីឯប្រយោគក្រៅ បានដល់ប្រយោគទាំងឡាយណាដែលនៅខាងក្រៅអញ្ញប្រកាសសញ្ញា ។ សូមរៀនពិនិត្យមើលឧទាហរណ៍ខាងក្រោមនេះ*

**១. ឯកស្មឹ សមយេ ភគវា រាជគហតោ និក្ខមិត្វា ឆ ជិសា ឆមស្សន្តំ សិគាលកំ មាណវំ ជិស្វា “កិស្ស ត្វំ គហបតិបុត្ត ជិសា ឆមស្សី”ត្តិ តំ បុច្ឆិ?**

## វិធីប្រែ

*មុននឹងប្រែត្រូវមើលឱ្យដឹងច្បាស់ថាតើ បទណាជាវិភត្តិអ្វី បទណាជាប្រធាននិងបទកិរិយារបស់ប្រធានចប់នៅត្រង់ណា ស័ព្ទណាប្រែទី ១-២-៣... ជាដើម ។ តើមាន* **ឥតិ** *ស័ព្ទខណ្ឌនៅត្រង់ណាប៉ុន្មានដង ។ បើអ្នកសិក្សាមើលយល់ចូលចិត្តដូចពោលមកនេះ ក៏អាចប្រែបានភ្លាម ។*

*ក្នុងឧទាហរណ៍ទី ១ នេះ ប្រយោគក្នុងមានបទថា*

**“កិស្ស ត្វំ គហបតិបុត្ត ជិសា ឆមស្សិ”**

*សល់ពីនេះជាប្រយោគក្រៅទាំងអស់ ។ ត្រូវប្រែប្រយោគក្រៅមុន ប្រែដូច្នេះ* **ឯកស្មឹ សមយេ** *ក្នុងសម័យមួយ* **ភគវា** *រីព្រះមានព្រះភាគ* **និក្ខមិត្វា** *ទ្រង់យាងចេញហើយ* **រាជគហាតោ** *ចាកក្រុងរាជគ្រឹះ* **ឆ ទិសា នមស្សន្តំ សិគាលកំ មាណវំ ទិស្វា** *ឃើញហើយនូវមាណព ឈ្មោះសិង្គាលកៈកំពុងថ្វាយបង្គំនូវទិសទាំងឡាយ ៦* **បុច្ឆិ** *ត្រាស់សួរ ហើយ* **តំ** (**ការណំ** *នូវហេតុ*) *នោះ* "**កិស្ស ត្វំ គហបតិបុត្ត ទិសា នមស្សិ**" <u>**ឥតិ**</u> <u>*ដូច្នេះ*</u> "**គហបតិបុត្ត** *ម្នាលគហបតិបុត្រ* **ត្វំ** *រីអ្នក* **នមស្សិ** *ថ្វាយបង្គំ* **ទិសា** *នូវទិសទាំងឡាយ* **កិស្ស** *ដើម្បីប្រយោជន៍អ្វី*" ។

*ប្រយោគក្នុងនេះ ព្រះមានព្រះភាគបានត្រាស់សួរដូច្នេះថា "ម្នាលគហបតិបុត្រ តើអ្នកថ្វាយបង្គំនូវទិសទាំងឡាយដើម្បីប្រយោជន៍អ្វី"* ។

**២. តំ សុត្វា សិគាលកោ មាណវោ "បិតា មេ ភន្តេ កាលំ ករោន្តោ ឯវំ អវច "ទិសា តាត នមស្សេយ្យាសី"<u>តិ</u> សោ អហំ បិតុ វចនំ ករោន្តោ ទិសា នមស្សាមី"<u>តិ</u> អាហ ។**

*ក្នុងឧទាហរណ៍ទី ២ នេះមាន* **ឥតិ** *ស័ព្ទខណ្ឌពីរកន្លែង គឺបាន សេចក្ដីថាមានប្រយោគក្នុង ២ ប្រយោគ ។*

*ប្រយោគក្នុងនេះមានបទថា* **"បិតា មេ ភន្តេ កាលំ ករោន្តោ ឯវំ អវច "ទិសា តាត នមស្សេយ្យាសី"<u>តិ</u> សោ អហំ បិតុ វចនំ ករោន្តោ ទិសា នមស្សាមិ"** ។ *ខាងក្នុងនៃប្រយោគក្នុងនេះមានបង្កប់ ប្រយោគក្នុងមួយ មានបទថា* "**ទិសា តាត នមស្សេយ្យាសិ**" ។

*ប្រែដូច្នេះ* **មាណវោ** *រីមាណព* **សិគាលកោ** *ឈ្មោះសិង្គាលកៈ* **សុត្វា** *ស្តាប់ហើយ* **តំ** (*វចនំ នូវពាក្យ*) *នោះ* **អាហ** *ក្រាបទូលហើយ* **"បិតា ភន្តេ ... ។បេ។ ... ឯមស្សាមិ" ឥតិ** *ដូច្នេះ* **"ភន្តេ** *បពិត្រព្រះអង្គដ៏ចម្រើន* **បិតា** *រីបិតា* **មេ** *របស់ខ្ញុំព្រះអង្គ* **កាលំ** *កាលធ្វើ* **ករោន្តោ** *នូវកាល (ស្លាប់)* **អវច** *បានប្រាប់ហើយ* **ឯវំ** *យ៉ាងនេះ* **"ទិសា តាត ឯមស្សេយ្យាសិ" ឥតិ** *ថា "ម្នាលកូនប្រុស អ្នកគប្បីថ្វាយបង្គំនូវទិសាទាំងឡាយ"* **សោ អហំ** *រីខ្ញុំនោះ* **ករោន្តោ** *កាលធ្វើ(តាម)* **វចនំ** *នូវពាក្យ* **បិតុ** *របស់បិតា* **ឯមស្សាមិ** *ទើបថ្វាយបង្គំ* **ទិសា** *នូវទិសទាំង-ឡាយ ។*

*ប្រយោគក្នុងនេះមានសេចក្តីថា "បពិត្រព្រះអង្គដ៏ចម្រើន រីបិតារបស់ខ្ញុំព្រះអង្គ កាលធ្វើនូវមរណកាលបានប្រាប់ហើយយ៉ាងនេះ "......" រីខ្ញុំនោះ កាលធ្វើ(តាម)នូវពាក្យរបស់បិតា ទើបថ្វាយបង្គំនូវទិសទាំង-ឡាយ" ។*

*រីប្រយោគខាងក្នុងមួយទៀតមានសេចក្តីថា "ម្នាលកូនប្រុស អ្នកគប្បីថ្វាយបង្គំនូវទិសទាំងឡាយ" ។*

៣. **អថ នំ ភគវា "ន ខោ គហបតិបុត្ត អរិយស្ស វិនយេ ឯវំ ទិសា ឯមស្សិតព្វា"តិ វត្វា តេន បុច្ឆិតោ គិហិវិនយំ កថេសិ ។**

*ក្នុងឧទាហរណ៍ទី ៣ នេះ ប្រយោគក្នុងមានបទថា*

"ន ខោ គហបតិបុត្ត អរិយស្ស វិនយេ ឯវំ ទិសា នមស្សិតព្វា"

<u>*ប្រែដូច្នេះ*</u> អថ *គ្រានោះ* ភគវា *រីព្រះមានព្រះភាគ* វត្វា *ទ្រង់ត្រាស់ហើយ* តំ (មាណវំ *នឹងមាណព*) *នោះ* "ន ខោ ...... ។បេ។ ...... នមស្សិតព្វា" <u>ឥតិ</u> <u>*ដូច្នេះ*</u>, តេន (មាណវេន) បុច្ឆិតោ *ត្រូវមាណពនោះសួរហើយ* កថេសិ *ទ្រង់សម្ដែងហើយ* គិហិវិនយំ *នូវវិន័យរបស់គ្រហស្ថ*, "គហបតិបុត្ត *ម្នាលគហបតិបុត្ត* (តយា *គឺអ្នក*) ន ខោ អរិយស្ស វិនយេ ឯវំ ទិសា នមស្សិតព្វា *មិនគប្បីថ្វាយបង្គំនូវទិសទាំងឡាយយ៉ាងនេះទេ ក្នុងវិន័យរបស់ព្រះអរិយៈ"* ។

*ប្រយោគក្នុងនេះមានសេចក្ដីថា "ម្នាលគហបតិបុត្ត(គឺអ្នក)មិនគប្បីថ្វាយបង្គំនូវទិសទាំងឡាយយ៉ាងនេះទេ ក្នុងវិន័យរបស់ព្រះអរិយៈ"* ។

## របៀបប្រើនិងប្រែ ឥតិ ស័ព្ទដោយពិស្ដារ

ឥតិ *ស័ព្ទនេះមានវិធីប្រែច្រើនយ៉ាង ។ ឧទាហរណ៍នៅខាងលើជាការប្រើជាទូទៅ សូមយកធ្វើជាគំរូសម្រាប់ជាផ្លូវពិចារណាប្រៀបធៀបក្នុងទីឯទៀត ៗ នាពេលខាងមុខ ។*

ឥតិ *ជានិបាតស័ព្ទប្រាប់សេចក្ដីផ្សេង ៗ និយមប្រើជាសន្ធិជាមួយស័ព្ទដទៃទៀត ដូចដែលបានពោលរួចហើយនៅខាងលើ ។ បើមាននៅ*

ក្នុងប្រយោគណា តើយើងនឹងប្រែតាមវិធីណា ? ប្រែថាយ៉ាងម៉េច ? ហេតុអ្វីទើបប្រែដូច្នេះ ? ជឿថាពិតជាមានបញ្ហាលំបាកពន់ពេកចំពោះអ្នកប្រែភាសាបាលីដំបូង ៗ ពីព្រោះ **ឥតិ** ស័ព្ទមានវិធីប្រែដល់ទៅ ១០ យ៉ាងគឺ

| | | | | | |
|---|---|---|---|---|---|
| ១. | ប្រែថា | ជាដើម | ៦. | ប្រែថា | ព្រោះហេតុដូច្នោះ |
| ២. | ប្រែថា | ដូច្នេះ | ៧. | ប្រែថា | ដោយប្រការដូច្នេះ |
| ៣. | ប្រែថា | ដូច្នេះ | ៨. | ប្រែថា | ដូច្នេះ |
| ៤. | ប្រែថា | ឈ្មោះថា | ៩. | ប្រែថា | ដូច្នេះឯង |
| ៥. | ប្រែថា | គឺ, ថា | ១០. | ប្រែថា | គឺ, ...គឺថា |

## ១. ឥតិ ប្រែថា "ជាដើម"

**ឥតិ** ស័ព្ទដែលប្រែថា "ជាដើម" នេះបានដល់សេចក្តីដែលលោកលើកយកមកអធិប្បាយដោយសង្ខេប គឺមិនប្រាថ្នាពោលទាំងអស់ទេ ទើបដាក់ **ឥតិ** ខណ្ឌទុកក្នុងទីដែលយល់ចូលចិត្តបាន ។

ប្រសិនបើជាប្រយោគពាក្យរាយ អាចដាក់រាំងបានត្រឹមមួយម៉ាត់, ពីរម៉ាត់ឬបីម៉ាត់ និងបើជាគាថាវិញអាចដាក់រាំងបានត្រឹមតែកន្លះបាទឬមួយបាទប៉ុណ្ណោះ ខាងសម្ពន្ធហៅថា **អាឍ្យត្ថ** ។

ពាក្យថា **អាទ្យត្ថ** មកពីពាក្យថា (**អាទិ** =ជាដើម + **អត្ថ** =សេចក្តី) ផ្លាស់ **ឥ** នៃ **ទិ** ជា **យ** ទៅជា (**អាទយ** > **អាទ្យ**) + **អត្ថ** > **អាទ្យត្ថ** ។

វេលាប្រែត្រូវថែមឃ្លាថា "មានសេចក្តីថា, មានពាក្យថា, មានបទថា" ណាមួយនៅខាងដើមប្រយោគក្នុងដូច្នេះ (...មានពាក្យថា "...." **ឥតិ**) បន្ទាប់មកត្រូវអានពាក្យខាងក្នុងសញ្ញាដោយញែកយក **ឥតិ** ចេញទុកប្រែក្រោយបង្អស់ ឱ.

**"បរេ ច ន វិជានន្តី"តិ ឥមំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ កោសម្ពិកេ ភិក្ខូ អារព្ភ កថេសិ ។**

ប្រែ= **សត្ថា** រីព្រះសាស្តា **វិហរន្តោ** កាលប្រថាប់នៅ **ជេតវនេ** ក្នុងវត្តជេតវន **កថេសិ** ត្រាស់ហើយ **ឥមំ ធម្មទេសនំ** នូវព្រះធម្មទេសនា នេះ "**បរេ ច ន វិជានន្តិ**" **ឥតិ** **មានពាក្យថា** "**បរេ ច ន វិជានន្តិ**" ជាដើម **អារព្ភ** ប្រារព្ធហើយ **កោសម្ពិកេ ភិក្ខូ** នូវភិក្ខុ.ទ. ដែលរស់នៅក្នុងក្រុងកោសម្ពី ។

បើប្រែយកសេចក្តីថា ព្រះបរមសាស្តាកាលប្រថាប់នៅឯវត្តជេតវ័ន ព្រះអង្គប្រារព្ធដល់ពួកភិក្ខុអ្នកក្រុងកោសម្ពី ទើបបានត្រាស់នូវព្រះធម្មទេសនាដូច្នេះថា "**បរេ ច ន វិជានន្តិ**" ។

នេះគឺជាគាថាដែលព្រះសម្មាសម្ពុទ្ធព្រះអង្គបានត្រាស់ទុក ប៉ុន្តែអ្នកពោលបានលើកយកមកពោលត្រឹមតែ ១ បាទខាងដើមប៉ុណ្ណោះ ។ គាថានេះនៅមានតទៅទៀតថា

"........................." មយមេត្ថ យមាម សេ,
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគាតិ ។

*ឧទាហរណ៍នេះជាគាថា ចូររកមើលគាថាធម្មបទភាគ ១ រឿងកោសម្ពិកវត្ថុផង៍ចុះ ។*

"អក្កោច្ឆិ មំ អវធិ មន្តិ......" ឥមំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ តិស្សត្ថេរំ អារព្ភ កថេសិ ។

*ប្រែថា* សត្ថា *វីព្រះសាស្ដា* វិហរន្តោ *កាលប្រថាប់នៅ* ជេតវនេ *ក្នុងវត្តជេតវន* កថេសិ *សំដែងហើយ* ឥមំ ធម្មទេសនំ *នូវព្រះធម្មទេសនា នេះ* "អក្កោច្ឆិ មំ អវធិ មំ..." ឥតិ <u>*មានពាក្យថា*</u> "អក្កោច្ឆិ មំ អវធិ មំ..." ឥតិ <u>*ជាដើម*</u> អារព្ភ *ទ្រង់ប្រារព្ធហើយ* តិស្សត្ថេរំ *នូវព្រះថេរឈ្មោះតិស្សៈ ។*

*សូមសង្កេតមើលក្នុងធម្មបទទាំង ៨ ភាគត្រង់ចាប់ផ្ដើមរាល់ ៗ រឿងនឹងឃើញមាន* ឥតិ *ស័ព្ទគ្រប់គ្រង់ដូចគ្នាទាំងអស់ គប្បីចាំទុកធ្វើជាគន្លឹះ គឺអាចប្រែបានគ្រប់ ៗ រឿង ព្រោះលោករៀងទុកនៅក្នុងប្រយោគជារបៀបតែមួយ មានលក្ខណៈស្រដៀងគ្នាដោយគ្រាន់តែផ្លាស់រឿងតែប៉ុណ្ណោះ ។*

## ២. ឥតិ ប្រែថា "ដូច្នេះ", "ដូចនេះ" (ទី ១)

**ឥតិ** *ស័ព្ទប្រែថា "ដូច្នេះ", "ដូចនេះ" បានដល់សេចក្ដីក្នុងកន្លែងខ្លះដែលលើកយកមកថ្លែងទាំងអស់មិនមានកាត់ទុកកន្លែងណាទេ គឺមានពាក្យពេចន៍ពេញលេញបរិបូរណ៍ ។ ពេលប្រែត្រូវចាំថា ប្រសិនបើគ្មានប្រយោគក្រៅទេ មានត្រឹមតែប្រយោគក្នុង ត្រូវថែមប្រយោគក្រៅចូលមកដើម្បីឱ្យទាក់ទងនឹងសេចក្ដីខាងដើម ។ ខាងសម្ពន្ធហៅថា* **អាការ** *ឬ* **អាការត្ថ** *ចុះក្នុងអត្ថនៃអាការកិរិយា (***អាការ** + **អត្ថ** > **អាការត្ថ***) និយមប្រើក្នុងប្រយោគសន្ទនាចរចារគ្នា ឧ.*

**ថេរោ កិរ តស្ស សន្តិកំ គន្ត្វា អាហ "កិន្នុ ខោ ព្រាហ្មណ កិញ្ចិទេវ កុសលំ ករោសី"តិ ។ "ករោមិ ភន្តេ"តិ ។ "កឹ ករោសី"តិ ។**

*ប្រែថា=* **កិរ** *បានឮថា* **ថេរោ** *រីព្រះថេរៈ* **គន្ត្វា** *និមន្តទៅហើយ* **សន្តិកំ** *កាន់សំណាក់* **តស្ស** (**ព្រាហ្មណស្ស** *របស់ព្រាហ្មណ៍*) *នោះ* **អាហ** *បានពោលហើយ* "**កិន្នុ ខោ ព្រាហ្មណ កិញ្ចិ ឯវ កុសលំ ករោសិ**" **ឥតិ** *ដូច្នេះ "ម្នាលព្រាហ្មណ៍ (លោក) ធ្វើ នូវកុសល ឯណានីមួយ មែនពិត ឬហ្ន៎" ។*

*ត្រង់* "**ករោមិ ភន្តេ**"**តិ** *នេះជាប្រយោគថ្មីនិងដែលជាសម្ដីរបស់ព្រាហ្មណ៍ពោលតបវិញ មិនមានប្រយោគក្រៅទេ ដូច្នេះពេលប្រែត្រូវថែមប្រយោគក្រៅថា* **ព្រាហ្មណោ "ករោមិ ភន្តេ"តិ អាហ ។**

*ប្រែ* **ព្រាហ្មណោ** *រីព្រាហ្មណ៍* **អាហ** *ពោលតបហើយ* "**ករោមិ**

ករោម" <u>ឥតិ</u> ដូច្នេះ "បពិត្រលោកម្ចាស់ដ៏ចម្រើន (ខ្ញុំ) កំពុងធ្វើ" ។

ត្រង់ "**កឹ ករោសី**"<u>តិ</u> ប្រយោគនេះជាពាក្យរបស់ព្រះថេរៈសួរថែមទៀត មិនមានប្រយោគក្រៅដែរទេ ដូច្នេះត្រូវថែមប្រយោគក្រៅថា **ថេរោ "កឹ ករោសី"<u>តិ</u> បុច្ឆិ ។**

ប្រែថា **ថេរោ** រីព្រះថេរៈ **បុច្ឆិ** សួរហើយ "**កឹ ករោសិ**"<u>ឥតិ</u> <u>ដូច្នេះ</u> "រីអ្នក កំពុងធ្វើ នូវអ្វី" ។

**ឥតិ** ស័ព្ទដែលប្រើក្នុងសេចក្ដីដូចពោលហើយនេះហៅថា **អាការ** ឬ **អាការត្ថ** ចូលជាមួយ **អាហ** ឬ **បុច្ឆិ** គឺជាកិរិយាទទួលដែលជាប្រយោគក្រៅ ។ ប៉ុន្តែក្នុងករណីខ្លះ **ឥតិ** ស័ព្ទដែលប្រែថា "ដូច្នេះ" ពុំចាំបាច់សម្ពន្ធចូលជាមួយស័ព្ទដទៃណាមួយក៏បាន ឧ.

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ-បស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហី"<u>តិ</u> ។**

ប្រែថា **ធម្មោ** រីធម៌ **ភគវតា** ដែលព្រះមានព្រះភាគ **ស្វាក្ខាតោ** ត្រាស់ល្អហើយ **សន្ទិដ្ឋិកោ** ជាធម៌ដែលអ្នកប្រតិបត្តិគប្បីឃើញបានដោយខ្លួនឯង **អកាលិកោ** ជាធម៌មិនប្រកបដោយកាល (ជារបស់ដែលប្រតិបត្តិនិងឱ្យផលបានមិនរង់ចាំកាល) **ឯហិបស្សិកោ** ជាធម៌គួរពោលដល់អ្នកដទៃថាសូមអ្នកមកមើលចុះ **ឱបនយិកោ** ជាធម៌ដែលគួរបង្អោន **បច្ចត្តំ** ជាធម៌ដែលបង្អោនចូលមកទុកក្នុងខ្លួន **វិញ្ញូហិ** គឺវិញ្ញូជនទាំងឡាយ (អ្នកចេះ) **វេទិតព្វោ** គប្បីដឹងបាន <u>ឥតិ</u> ដូច្នេះ ។

## ៣. ឥតិ ប្រែថា "ដូច្នេះ" (ទី ២)

ឥតិ ស័ព្ទដែលប្រែថា "...ដូច្នេះ" ក៏មានគតិដូច ឥតិ ស័ព្ទដែលពោលហើយក្នុងលេខ ២ ដែរ ។ តែមានខុសគ្នាតែត្រង់ ឥតិ ស័ព្ទនេះត្រូវសម្ពន្ធចូលជាមួយបទនាម ខាងសម្ពន្ធមានឈ្មោះថា សរូប ដូចជា

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ <u>បទន្តិ</u> ។

អយំ ធម្មទេសនា កត្ថ ភាសិតា ?

(បុច្ឆា វិសំនួរ) អយំ ធម្មទេសនា វិព្រះធម៌ទេសនានេះ "មនោបុព្វង្គមា ធម្មា ។បេ។ ចក្កំវ វហតោ បទំ" <u>ឥតិ</u> <u>ដូច្នេះ</u> (ភគវតា គឺព្រះមានព្រះភាគ) ភាសិតា ត្រាស់ហើយ កត្ថ ក្នុងទីណា ?

(វិសជ្ជនា វិចម្លើយ) អយំ ធម្មទេសនា វិព្រះធម៌ទេសនា "មនោបុព្វង្គមា ធម្មា ។បេ។ ចក្កំវ វហតោ បទំ" <u>ឥតិ</u> <u>ដូច្នេះ</u> ។ ធម្មា វិធម៌ទាំងឡាយ មនោបុព្វង្គមា មានចិត្តដល់មុន មនោសេដ្ឋា មានចិត្តប្រសើរបំផុត មនោមយា សម្រេចអំពីចិត្ត ចេ បើ (បុគ្គលោ វិបុគ្គល) មនសា មានចិត្ត បទុដ្ឋេន ត្រូវទោសប្រទូសហើយ ភាសតិ វា ពោលក្តី ករោតិ វា ធ្វើក្តី ទុក្ខំ វិសេចក្តីទុក្ខ អន្វេតិ តែងជាប់តាម នំ (បុគ្គលំ

នូវបុគ្គល)នោះ **តតោ** ព្រោះ(ទុច្ចរិតមាន ៣ ប្រការ)នោះ **ចក្កំ ឥវ** ដូចជារីកង់ **អន្វេតិ** កាលវិលតាម **បទំ** នូវស្នាមជើង (**ពលិពទ្ទស្ស** នៃគោ) **វហតោ** កាលអូសទៅ (**ធុរំ** នូវនឹម) ។

**ឥតិ** ស័ព្ទប្រើក្នុងលក្ខណៈនេះ ខាងសម្ពន្ធហៅថា **សរូប** សម្ពន្ធចូលនឹង **អយំ ធម្មទេសនា** ។

(**អនុ** + **ឥ** + **អ** + **តិ**) > **អន្វេតិ**,

(**ទុក្ខំ** + **អន្វេតិ**) > **ទុក្ខមន្វេតិ**,

(**បទំ** + **ឥតិ**) > **បទន្តិ** ។

និងបើប្រាថ្នាប្រាប់ឈ្មោះអ្នកណាម្នាក់ ត្រូវសរសេរដាក់ខាងចុងឈ្មោះនោះ ៗ ជាសញ្ញាដើម្បីឱ្យស្គាល់ងាយ វេលាប្រែត្រូវញែកយក **ឥតិ** ចេញពីប្រយោគក្នុងនិងត្រូវប្រែបន្ទាប់ពីប្រែអស់លេខក្រៅ ។

## ៤. ឥតិ ប្រែថា "ឈ្មោះថា"

**ឥតិ** ស័ព្ទដែលប្រែថា "ឈ្មោះថា" គឺប្រើដើម្បីប្រាប់ឈ្មោះ ឧ.

១. **ឯកោ កិរ កោសម្ពិវាសី កុលបុត្តោ សត្ថុ សាសនេ បព្វជិត្វា លទ្ធូបសម្បទោ "កោសម្ពីវាសិតិស្សត្ថេរោ"<u>តិ</u> បញ្ញាយិ។**

ប្រែថា **កិរ** បានឮថា **ឯកោ កោសម្ពិវាសី កុលបុត្តោ** វីកុលបុត្រ ជាអ្នកមានប្រក្រតីរស់នៅក្រុងកោសម្ពី មួយរូប **បព្វជិត្វា** បាន

បួសហើយ **សាសនេ** ក្នុងសាសនា **សត្ថុ** របស់ព្រះសាស្តា **លទ្ធូប-សម្បទោ** ជាអ្នកមានឧបសម្បទាគឺបានហើយ **បញ្ញាយិ** ប្រាកដហើយ "**កោសម្ពិវាសិតិស្សត្ថេរោ**" ឥតិ ឈ្មោះថា "កោសម្ពីវាសិតិស្សថេរៈ" ។

**២. សា លទ្ធូបសម្បទា "កិសាគោតមីថេរី"តិ បញ្ញាយិ ។**

ប្រែថា **សា** វិនាង **លទ្ធូបសម្បទា** មានឧបសម្បទាបានហើយ **បញ្ញាយិ** ប្រាកដហើយ "**កិសាគោតមីថេរី**" ឥតិ ឈ្មោះថា "កិសាគោតមីថេរី" ។

**ឥតិ** ស័ព្ទដែលប្រើក្នុងលក្ខណៈនេះ ខាងសម្ពន្ធហៅថា **សញ្ញា-ជោតក** សម្ពន្ធចូលជាមួយបទនាមដែលនៅខាងក្នុង **ឥតិ** ជាចាំបាច់ ។

## ៥. ឥតិ ប្រែថា "គឺ, ថា"

**ឥតិ** ស័ព្ទដែលប្រែថា "គឺ, ថា" បានដល់ **ឥតិ** ស័ព្ទដែលពុំចាំបាច់ធ្វើសន្ធិចូលជាមួយបទដទៃក៏មាន ឬរៀងដាច់តែឯងក៏មាន ខាងសម្ពន្ធហៅថា **និបាតសព្ទ** ឬ **និបាតសព្ទត្ថ** មិនសម្ពន្ធចូលជាមួយបទណាទេ ឧ.

**១. ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។បេ។**

ប្រែថា **សោ ភគវា** វិព្រះមានព្រះភាគអង្គនោះ **ឥតិបិ អរហំ** ព្រះនាមថា អរហន្ត **ឥតិបិ សម្មាសម្ពុទ្ធោ** ព្រះនាមថា សម្មាសម្ពុទ្ធ ។ល។

២. គោ **ឥ**ច្ចេតស្ស ឱការស្ស អាវាទេសោ ហោតិ យោសុ ។ *ប្រយោគនេះប្រែបាន ២ យ៉ាងគឺ*

*ក.ប្រែ=* អាវាទេសោ *វិការផ្លាស់ជា* អាវ, ឱការស្ស *នៃ ឱអក្សរ* ឯតស្ស (*សទ្ទស្ស របស់ស័ព្ទ*) *នុ៎ះ* គោ ឥតិ *គឺគោ* ហោតិ *រមែងមាន* យោសុ *ព្រោះយោវិភត្តិទាំងឡាយ ។*

*ខ.ប្រែ=* យោសុ *ព្រោះយោវិភត្តិទាំងឡាយ* អាវាទេសោ *វិការផ្លាស់ជា* អាវ, ឱការស្ស *នៃ ឱអក្សរ* ឯតស្ស (*សទ្ទស្ស របស់ស័ព្ទ*) *នេះ* គោ ឥតិ *គឺគោ* ហោតិ *រមែងមាន ។*

ឥច្ចេតស្ស < (ឥតិ + ឯតស្ស)

## ៦. ឥតិ ប្រែថា

## "ព្រោះហេតុដូច្នោះ, ហេតុដូច្នោះ"

**ឥតិ** *ស័ព្ទដែលប្រែថា "ព្រោះហេតុដូច្នោះ, ហេតុដូច្នោះ" នេះប្រើក្នុងប្រយោគវិគ្គហៈ (ពាក្យជាវិគ្គហៈនឹងមានពោលក្នុងនាមកិតកៈនៅខាងមុខ) ហៅតាមសម្ពន្ធថា* ហេត្វត្ថ *ឬ* ហេត្វត្ថវាចកា *ចុះក្នុងអត្ថជាហេតុ មិនសម្ព័ន្ធចូលក្នុងបទណាទេ ។* ហេត្វត្ថ *មកពី* ((ហេតុ > ហេត្វ + អត្ថ), *ព្រឹទ្ធិ* ឧ *នៃ* តុ *ជា* ឱ > អវ > តវ > ត្វ) *ឱ.*

១. ពុទ្ធវចនំ ចាលេតីតិ ចាលិ (ភាសា) ។

*ប្រែថា* (យា ភាសា *វីភាសា ណា*) ចាលេតិ *រមែងរក្សា* ពុទ្ធវចនំ *នូវព្រះពុទ្ធវចនៈ* ឥតិ *ព្រោះហេតុដូច្នោះ* (សា ភាសា *វីភាសា នោះ*) ចាលិ *ឈ្មោះថា* ចាលិ (បាលី) = *ភាសាដែលរក្សានូវព្រះពុទ្ធវចនៈ ។*

២. សហ ករិយាយ យោ វត្តតីតិ សករិយោ (បុរិសោ) ។

(យោ បុរិសោ *វីបុរស ណា*) វត្តតិ *ប្រព្រឹត្តទៅ* សហ *មួយអន្លើ* ករិយាយ *ដោយករិយា* (សោ បុរិសោ *វីបុរស នោះ*) សករិយោ *ឈ្មោះថា* សករិយោ = (*ប្រុស*)*អ្នកប្រព្រឹត្តទៅមួយអន្លើដោយករិយា ។*

*វិធីរៀងវិគ្គហៈមានច្រើនរបៀប សូមរកមើលក្នុងមេរៀនស្តីពីនាម-កិតកៈនៅខាងមុខ ។*

## ៧. ឥតិ ប្រែថា "ដោយប្រការដូច្នេះ" "ដោយប្រការយ៉ាងនេះ"

ឥតិ *ស័ព្ទដែលប្រែថា "ដោយប្រការដូច្នេះ" ឬ "ដោយប្រការយ៉ាងនេះ" និយមប្រើសរុបសេចក្តីដែលថ្លែងមកយ៉ាងយូរ ដើម្បីឱ្យស្តាប់បានច្បាស់លាស់ជាក់លាក់ស្តីពីរឿងរ៉ាវដែលពោលមកពីខាងដើមនិងបញ្ចប់ដោយល្អ ហៅតាមសម្ពន្ធថា* បការ *ឬ* បការត្ថ *មិនសម្ពន្ធចូលក្នុង*

*បទណាទេ និយមរៀងខាងដើមបំផុតនៃប្រយោគ និងត្រូវប្រែក្រោយគេបង្អស់ ដូចមាននៅក្នុងធម្មចក្កប្បវត្តនសូត្រ ត្រង់ជិតទីបញ្ចប់ថា*

**<u>ឥតិ</u>ហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ ។**

*ប្រែថា* **សទ្ទោ** *សំឡេង* **អព្ភុគ្គច្ឆិ** *បានលាន់ឮឡើងហើយ* **យាវ ព្រហ្មលោកា** *ដរាបដល់ព្រហ្មលោក* **តេន ខណេន** *ក្នុងខណៈ នោះ* **តេន មុហុត្តេន** *ក្នុងមួយរំពេច នោះ* **<u>ឥតិ</u>ហ** *<u>ដោយប្រការដូច្នេះឯង</u>* ។

## ៨. ឥតិ ប្រែថា "ដូច្នេះ" (ទី ៣)

**ឥតិ** *ស័ព្ទដែលប្រែថា "ដូច្នេះ" បានដល់* **ឥតិ** *ស័ព្ទដែលនឹងសម្ពន្ធចូលក្នុងកិរិយាមិនបាន ។ ពីព្រោះ* **ឥតិ** *ស័ព្ទដែលធ្វើសន្ធិជាមួយស្រៈទីបំផុតនៃប្រយោគក្នុង មានសេចក្ដីជាប់ទាក់ទងគ្នានឹងកិរិយានៃប្រយោគក្រៅ ។ ក្នុងករណីនេះមុននឹងប្រែប្រយោគក្នុងត្រូវថែមបទថា* **ញាបនហេតុកំ** *ឬ* **ញាបនហេតុកាយ** *ប្រែថា "ជាហេតុឱ្យដឹង" និងត្រូវញែក* **ឥតិ** *ចេញពីប្រយោគក្នុង ។ ការប្រើបែបនេះត្រូវប្រកបជាមួយនឹងកាយវិការខ្លះដូចជា ការវាយគងប្រកាសឱ្យដឹង ការធ្វើដៃយ៉ាងណាមួយជាសញ្ញាដែលអាចយល់គ្នាបាន ឧ.*

**ថេរោ ... "តវ បមាណំ ន ជានាសី"ติ អច្ឆរំ បហរិ ។**

*ប្រែថា* **ថេរោ** *ព្រះថេរៈ* **បហរិ** *ផ្ទាត់ហើយ* **អច្ឆរំ** *នូវម្រាមដៃ* (**ញាបនហេតុកំ** *ជាហេតុឲ្យដឹង*) "**តវ បមាណំ ន ជានាសិ**" **ឥតិ** *ដូច្នេះ*, "(**ត្វំ** *លោក*) **ន ជានាសិ** *មិនដឹង* **បមាណំ** *នូវប្រមាណ* **តវ** *របស់អ្នក*" ។

*វេលាសម្ពន្ធគឺ* **ឥតិ** *សព្ទសម្ពន្ធចូលក្នុង* **ញាបនហេតុកំ** *ឬ* **ញាបនហេតុកាយ** ។

## ៩. ឥតិ ប្រែថា "ដូច្នេះឯង"

**ឥតិ** *សព្ទដែលប្រែថា "ដូច្នេះឯង" និយមប្រើក្នុងទីបញ្ចប់សេចក្ដីឬត្រង់កន្លែងចប់រឿងនីមួយ ៗ ដែលតែងមាន* **ឥតិ** *សព្ទសម្រាប់ប្រាប់ឲ្យដឹងថាចប់សេចក្ដីគ្រប់កន្លែង ហៅតាមសម្ពន្ធថា* **សមាបន្ន** *ឬ* **បរិសមាបន្ន** *ក៏បាន ដូចឧទាហរណ៍ក្នុងធម្មបទទាំង ៨ ភាគត្រង់ចប់ដូចនេះ*

**ទេសនាវសានេ ពហូ ភិក្ខូ អរហត្តំ បាបុណិំសូតិ ។**

*ប្រែថា* **ទេសនាវសានេ** *ក្នុងកាលជាទីបញ្ចប់នៃទេសនា* **ពហូ ភិក្ខូ** *ភិក្ខុ ច្រើនរូប* **បាបុណិំសុ** *បានដល់ហើយ* **អរហត្តំ** *នូវអរហត្ត* **ឥតិ** *ដូច្នេះឯង* ។

**ឥតិ** *សព្ទដែលប្រើរបៀបនេះហៅថា* **សមាបន្ន** *មិនសម្ពន្ធចូលជាមួយបទដទៃទេ ។ ប្រសិនបើមាន* **ឥតិ** *សព្ទពីរកន្លែង,* **ឥតិ** *សព្ទ ទី ១ ជា* **សមាបន្ន**, **ឥតិ** *សព្ទទី ២ ជា* **បរិសមាបន្ន** ។

*សូមសង្កេតមើលត្រង់ទីដែលបញ្ចប់រឿងនីមួយ ៗ ក្នុងធម្មបទ ។*

## ១០. ឥតិ ប្រែថា "គឺ..."

**ឥតិ** *សព្ទដែលប្រែថា "គឺ..." និយមប្រើក្នុងការរាប់សេចក្តីយ៉ាងណាមួយ ដើម្បីឱ្យយល់ដឹងច្បាស់លាស់ ។ ពេលប្រែត្រូវញែកយក* **ឥតិ** *មកប្រែមុនប្រយោគក្នុង ឧ.*

**ទេវលោកតោ ហិ ទេវបុត្តា "អាយុក្ខយេន បុញ្ញក្ខយេន អាហារក្ខយេន កោបេនា"<u>តិ</u> ចតូហិ ការណេហិ ចវន្តិ ។**

**ហិ** *ព្រោះថា* **ទេវបុត្តា** *ទេវបុត្រទាំងឡាយ* **ចវន្តិ** *តែងច្យុត(ស្លាប់)* **ទេវលោកតោ** *ចាកទេវលោក* **ចតូហិ ការណេហិ** *ដោយហេតុ ៤ យ៉ាង* <u>**ឥតិ**</u> <u>*គឺ*</u> "**អាយុក្ខយេន** *ដោយអស់អាយុ* **បុញ្ញក្ខយេន** *ដោយអស់បុណ្យ* **អាហារក្ខយេន** *ដោយអស់អាហារ* **កោបេន** *និងដោយសេចក្តីក្រោធ*" ។

(*ចប់វិធីប្រើនិងប្រែ* **ឥតិ** *សព្ទត្រឹមនេះ*)

## លំហាត់នៃមេរៀនទី ៣០

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. ឥតិ ស័ព្ទមានវិធីធ្វើជាបទសន្ធិបាន ៣ យ៉ាង តើធ្វើដូចម្ដេចខ្លះ?*

*២. ឥតិ ស័ព្ទនេះមានវិធីប្រែដល់ទៅ ១០ យ៉ាង តើប្រែដូចម្ដេចខ្លះ?*

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. អថ ខោ សោ ភិក្ខុ តំ ភិក្ខុនឹ ឯតទវោច "គច្ឆ ភគិនិ អមុកស្មឹ ឱកាសេ ភិក្ខា ជីយតី"តិ ។

២. បុន ច បរំ សារិបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ "ភាវិតា នុ ខោ សមថោ ច វិបស្សនា ចា"តិ ។

៣. សចេ សារិបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ "អភាវិតា ខោ មេ សមថោ ច វិបស្សនា ចា"តិ តេន សារិបុត្ត ភិក្ខុនា សមថវិបស្សនានំ ភាវនាយ វាយមិតព្វំ ។

៤. នោ ចេតំ ភិក្ខវេ សក្កា អភវិស្ស អកុសលំ បជហិតុំ នាហំ ឯវំ វទាមិ "អកុសលំ ភិក្ខវេ បជហថា"តិ ។

៥. រាជា បុត្តស្ស វចនំ សុត្វា "គច្ឆ ភទ្ទេ តវ សិវិកាយ និសីទិត្វា ចាសាទំ យេវ អភិរូហា"តិ អាហ ។

៦. យស្ស មុហុត្តេន សហស្សធា លោកោ សំវិទិតោ សា ព្រហ្មកប្បោ ។

៧. មា ភោ ខណំ វិរាជេថ ខណាតីតា ហិ សោចរេ ។

៨. ភន្តេ ឧភតោមុក្ខំ អស្សុំ អទ្ធសំ តស្ស ទ្វីសុ បស្សេសុ យវសំ ទេន្តិ ។

៩. រូបំ ភិក្ខវេ អនត្តា រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស ន យិទំ រូបំ អាភាធាយ សំវត្តេយ្យ ។

១០. សា តស្ស វចនំ សុត្វា ហាតុំ អសក្កោន្តី នារីគណបរិវុតា កន្ទា បាសាទំ អារុយ្ហ "កោ នុ ខោ បុត្តស្ស បវត្តី"តិ វិនិច្ឆយដ្ឋានំ ឱលោកេន្តី អដ្ឋាសិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ព្រោះហេតុដូច្នោះ ចូរយើង និយាយ យ៉ាងនេះ "អ្នក.ទ. ចូរថ្វាយបង្គំ ព្រះគោតម ព្រះអង្គជាអ្នកឈ្នះ យើង ចូរថ្វាយបង្គំ ព្រះគោតម ព្រះអង្គជាអ្នកឈ្នះ" ។*

*២. លំដាប់នោះ ព្រះថេរៈ បង្គាប់ ដល់ភិក្ខុ ក្មេង មួយរូប ថា "អ្នក ចូរទៅ, ចូរប្រាប់ ដល់សំឡាញ់(**សុហាទ**) ថា "លោក ចូរក្រាល នូវសេនាសនៈ មួយ សម្រាប់អ្នកមកថ្មី" ។*

*៣. ភិក្ខុ នោះ ស្តាប់ហើយ នូវពាក្យ របស់ព្រះថេរៈ នោះ តបថា "លោកម្ចាស់ដ៏ចម្រើន" ដូច្នេះ ទៅហើយ ប្រាប់ហើយ ដល់ភិក្ខុជាសំឡាញ់ ។*

*៤. ភិក្ខុ ជាសំឡាញ់ នោះ ក្រាលហើយ នូវសេនាសនៈ មកហើយ កាន់*

សំណាក់ របស់ព្រះថេរៈ ប្រាប់ហើយដល់លោក ថា "សេនាសនៈ
នោះ ខ្ញុំករុណា ក្រាលហើយ" គ្រានោះ ព្រះថេរៈ ពោលថា
"បើដូច្នោះ ចូរអ្នក នាំទៅ នូវភិក្ខុ នេះ កាន់សេនាសនចុះ"
ព្រះថេរៈ ពោលហើយ បានធ្វើហើយ យ៉ាងនោះ ។

៥. វិធុរភិក្ខុ សួរហើយ ដល់ភិក្ខុជាសំឡាញ់ ថា "លោកម្ចាស់ដ៏ចម្រើន
កតិកា ក្នុងអាវាស នេះ មាន ឬ?" "លោកដ៏មានអាយុ មាន" ។

៦. "កតិកា ដូចម្ដេច លោកដ៏មានអាយុ" គ្រានោះ រគាំង គឺភិក្ខុ
វាយហើយ ភិក្ខុ.ទ. ប្រជុំគ្នាហើយ ថ្វាយបង្គំហើយ ចំពោះព្រះ
រតនត្រ័យ ក្នុងព្រះវិហារ ។

(ចប់មេរៀនទី ៣០)

# មេរៀនទី ៣១

# អធិប្បាយអំពីអព្យយបច្ច័យ, កាលសត្តមីស័ព្ទ និង បុនរុត្តិស័ព្ទ

*បច្ច័យក្នុងភាសាបាលីមានចំនួនច្រើននិងច្រើនប្រភេទ ។ បច្ច័យខ្លះសម្រាប់ចុះក្នុងអាខ្យាតកិរិយា ខ្លះសម្រាប់ចុះក្នុងកិតកិរិយាដូចបានសិក្សារួចហើយ ខ្លះសម្រាប់ចុះក្នុងនាមកិតកនិងខ្លះទៀតសម្រាប់ចុះក្នុងតទ្ធិត ។*

## អព្យយបច្ច័យ

(Indeclinable Suffixes)

*ក្នុងពេលនេះនឹងអធិប្បាយអំពីអព្យយបច្ច័យ ដែលជាបច្ច័យមួយពួក កាលបើចុះខាងចុងស័ព្ទណាហើយ ស័ព្ទនោះ ៗ មិនប្រែប្រួលរូបឡើយនៅពេលប្រើក្នុងប្រយោគ មាន ២២ តួគឺ*

តោ, ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហិ, ហិញ្ចនំ, វ, ទា, ទាចិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ, តវេ, តុំ, ត្វា, ត្វាន, ត្វូន ។

*បច្ច័យទាំងនេះមានរបៀបប្រើផ្សេង ៗ គ្នាដែលចែកចេញជា ៤ ពួកដូចតទៅនេះ*

១. ពួកទី ១ មានតែមួយតួទេគឺ តោ ។

២. ពួកទី ២ មាន ៩ តួគឺ ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហិ, ហិញ្ចនំ, វ ។

៣. ពួកទី ៣ មាន ៧ តួគឺ ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ ។

៤. ពួកទី ៤ មាន ៥ តួគឺ តវេ, តុំ, ត្វា, ត្វាន, តូន ។

## វិធីប្រើនិងប្រែអព្យយបច្ច័យពួកទី ១

ពួកទីមួយគឺ **តោ** បច្ច័យសម្រាប់ចុះខាងចុងនាមនាម, គុណនាម និងសព្វនាម ចុះក្នុងអត្ថនៃវិភត្តិពីរយ៉ាងគឺតតិយាវិភត្តិមានពាក្យប្រែថា "ខាង, ដោយ" ឧ. (**ឯក** + **តោ**) > **ឯកតោ** ប្រែថា "ខាងម្ខាង" និង បញ្ចមីវិភត្តិមានពាក្យប្រែថា "អំពី, ចាក" ឧ. (**កឹ** + **តោ**) > **កុតោ** ប្រែថា "អំពី...ណា" ។

### តោ ចុះក្នុងអត្ថតតិយាវិភត្តិ

| ស័ព្ទដើម | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ឧភ + តោ | > ឧភតោ | ខាងទាំងពីរ |
| បរ + តោ | > បរតោ | ខាងដទៃ |
| អបរ + តោ | > អបរតោ | ខាងដទៃទៀត |
| បុរ + តោ | > បុរតោ | ខាងមុខ |
| បច្ឆា + តោ | > បច្ឆតោ | ខាងក្រោយ |

| | | |
|---|---|---|
| ទក្ខិណា + តោ | > ទក្ខិណាតោ | ខាងស្តាំ |
| វាម + តោ | > វាមតោ | ខាងឆ្វេង |
| ឧត្តរ + តោ | > ឧត្តរតោ | ខាងជើង |
| អធរ + តោ | > អធរតោ | ខាងក្រោម |
| បិតុ + តោ | > បិតិតោ | ខាងឪពុក |
| មាតុ + តោ | > មាតិតោ | ខាងម្តាយ |
| អត្ត + តោ | > អត្តតោ | ដោយអត្ត |
| សង្ខេប + តោ | > សង្ខេបតោ | ដោយសង្ខេប |
| វិត្ថារ + តោ | > វិត្ថារតោ | ដោយពិស្តារ |
| វិសេស + តោ | > វិសេសតោ | ដោយវិសេស |

## តោ ចុះក្នុងអត្ថបញ្ចមីវិភត្តិ

| *សព្ទដើម* | *សម្រេចជា* | *ពាក្យប្រែ* |
|---|---|---|
| សព្វ + តោ | > សព្វតោ | អំពី...ទាំងពួង |
| អញ្ញ + តោ | > អញ្ញតោ | អំពី...ដទៃ |
| អញ្ញតរ + តោ | > អញ្ញតរតោ | អំពី...ណាមួយ |
| ឥតរ + តោ | > ឥតរតោ | អំពី...ក្រៅនេះ |
| ត + តោ | > តតោ | អំពី...នោះ |

| | | |
|---|---|---|
| ឥម + តោ | > ឥតោ | អំពី...នេះ |
| យ + តោ | > យតោ | អំពី...ឯណា |
| អមុ + តោ | > អមុតោ | អំពី...ឯណោះ |
| កតរ + តោ | > កតរតោ | អំពី...អ្វី |
| កឹ + តោ | > កុតោ | អំពី...ណា |
| ឯត + តោ | > ឯត្តោ | អំពី...នុ៎ះ |
| ឯត + តោ | > អតោ | អំពី...នុ៎ះ |
| រុក្ខ + តោ | > រុក្ខតោ | អំពីដើមឈើ |
| គាម + តោ | > គាមតោ | អំពីភូមិ |
| បុរិស + តោ | > បុរិសតោ | អំពីប្រុស |
| កាម + តោ | > កាមតោ | អំពីកាម |

## កំណត់សម្គាល់

*សូមសង្កេតមើលនិងចំណាំស័ព្ទខាងលើទុកឱ្យដឹងផងថា តើស័ព្ទណាមានរូបដើមយ៉ាងម៉េច ? វេលាចុះ* តោ *បច្ច័យមកមានរូបប្រែប្រួលទៅជាយ៉ាងម៉េចវិញ និងជាពិសេស* កឹ *ផ្លាស់ប្តូររូបបានច្រើនយ៉ាង ។ ចំពោះពាក្យប្រែដែលមានសល់ចន្លោះ វេលាប្រែត្រូវថែមពាក្យថ្មីឱ្យត្រូវនឹងសេចក្តីក្នុងទីនោះ ៗ ។*

## វិធីប្រើក្នុងប្រយោគ

*សព្ទទាំងឡាយនេះជាអព្យយសព្ទ ។ កាលណាយកមករៀងក្នុងប្រយោគមានរូបយ៉ាងណា គឺទុកឱ្យគង់រូបជាយ៉ាងនោះ ដូចឧទាហរណ៍ខាងក្រោមនេះ*

**១. ឯកោ ឧបាសកោ ភគវតោ បច្ឆតោ និសីទិ ។**

*ឧបាសក ម្នាក់ អង្គុយហើយ ខាងក្រោយ នៃព្រះមានព្រះភាគ ។*

**២. បញ្ច ជនា កុតោ អាគមិំសុ ។**

*ជន.ទ. ប្រាំនាក់ មកហើយ អំពីទីណា ?*

**៣. រុក្ខតោ ឱតិណ្ណា បក្ខី ទារកេន សក្ខរាហិ ហតា ហោន្តិ ។**

*បក្សី.ទ. ដែលធ្លាក់ អំពីដើមឈើ គឺក្មេង សម្លាប់ហើយ នឹងគ្រាប់ក្រួស.ទ. ។*

**៤. កាមតោ ជាយតិ សោកោ ។**

*សេចក្ដីសោក កើត អំពីកាម(សេចក្ដីស្រឡាញ់) ។*

## វិធីប្រើនិងប្រែអព្យយបច្ច័យពួកទី ២

*ពួកទី ២ គឺ* ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហំ, ហិញ្ចនំ, វ *បច្ច័យ ប្រើចុះតែខាងចុងសព្វនាមប៉ុណ្ណោះ ប្រើចុះក្នុងអត្ថជាសត្តមីវិភត្តិដែលប្រាប់ទីកន្លែង ត្រូវប្រែថា "ក្នុង..." ដូចខាងក្រោមនេះ*

| ស័ព្ទដើម | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| សព្វ + ត្រ | > សព្វត្រ | ក្នុង...ទាំងពួង |
| អញ្ញ + ត្រ | > អញ្ញត្រ | ក្នុង...ដទៃ |
| យ + ត្រ | > យត្រ | ក្នុង...ឯណា |
| ត + ត្រ | > តត្រ | ក្នុង...នោះ |
| ឥម + ត្រ | > អត្រ | ក្នុង...នេះ (ឥម > អ) |
| ឯក + ត្រ | > ឯកត្រ | ក្នុង...មួយ |
| ឧភយ + ត្រ | > ឧភយត្រ | ក្នុង...ទាំងពីរ |
| កឹ + ត្រ | > កុត្រ | ក្នុង...ណា (កឹ > កុ) |
| សព្វ + ត្ថ | > សព្វត្ថ | ក្នុង...ទាំងពួង |
| អញ្ញ + ត្ថ | > អញ្ញត្ថ | ក្នុង...ដទៃ |
| យ + ត្ថ | > យត្ថ | ក្នុង...ឯណា |
| ត + ត្ថ | > តត្ថ | ក្នុង...នោះ |
| ឥម + ត្ថ | > អត្ថ | ក្នុង...នេះ (ឥម > អ) |
| ឯក + ត្ថ | > ឯកត្ថ | ក្នុង...មួយ |
| ឧភយ + ត្ថ | > ឧភយត្ថ | ក្នុង...ទាំងពីរ |
| ឥម + ត្ថ | > ឯត្ថ | ក្នុង...នេះ (ឥម > ឯ) |
| កឹ + ត្ថ | > កត្ថ | ក្នុង...ណា (កឹ > ក) |
| ឥម + ហ | > ឥហ | ក្នុង...នេះ |

| | | |
|---|---|---|
| ឥម + ជ | > ឥជ | ក្នុង...នេះ |
| សព្វ + ជិ | > សព្វជិ | ក្នុង...ទាំងពួង |
| យ + ហឹ | > យហឹ | ក្នុង...ណា |
| កឹ + ហឹ | > កុហឹ | ក្នុង...ឯណា (កឹ > កុ) |
| ត + ហឹ | > តហឹ | ក្នុង...នោះ |
| យ + ហំ | > យហំ | ក្នុង...ណា |
| ត + ហំ | > តហំ | ក្នុង...នោះ |
| កឹ + ហំ | > កុហំ | ក្នុង...ឯណា ( កឹ > កុ ) |
| កឹ + ហិញ្ចនំ | > កុហិញ្ចនំ | ក្នុង...ឯណា (កឹ > កុ) |
| កឹ + វ + ចិ | > ក្វចិ | ក្នុង...ឯណាខ្លះ ( កឹ > ក ) |

## កំណត់សម្គាល់

*សព្វទាំងឡាយដែលមានបច្ច័យដូចជា ត្រ ជាដើមនេះ វេលាប្រែជាខ្មែរ បើប្រាថ្នាថែមអញ្ញបទ(នាមបទដទៃ)ចូលមក នាមជាអញ្ញបទដែលថែមចូលមកនោះ ត្រូវបំបែកឱ្យមានរូបជាសត្តមីវិភត្តិដែលប្រែថា "ក្នុង..." ជានិច្ច ដូចជា* សព្វត្រ *ហានេ =ក្នុងទីទាំងពួង,* ឥជ *លោកេ = ក្នុងលោកនេះ ។ ស័ព្ទដទៃ ៗ ទៀតក៏គប្បីយកតាមលំនាំបែបនេះដូចគ្នានិងអ្វី ៗ គឺសម្រេចតែសេចក្ដីនៅក្នុងទីនោះ ៗ ។*

# វិធីប្រើនិងប្រែអព្យយបច្ច័យពួកទី ៣

ពួកទី ៣ គឺ **ទា**, **ទានិ**, **រហិ**, **ធុនា**, **ទាចនំ**, **ជ្ជ**, **ជ្ជុ** បច្ច័យសម្រាប់ប្រើចុះខាងចុងសព្វនាម ចុះក្នុងអត្ថជាសត្តមីវិភត្តិដែរ ប៉ុន្តែសំដៅដល់កាលវេលាដែលហៅតាមសម្ពន្ធថា **កាលសត្តមី** ។ សព្ទខ្លះប្រែមុនបទប្រធានក៏បាន ប្រែថា "ក្នុង..., ក្នុងកាល..." ដូចជា

| សព្ទដើម | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| សព្វ + ទា | > សព្វទា | ក្នុងកាលទាំងពួង, សព្វកាល |
| សព្វ + ទា | > សទា | ក្នុងកាលទាំងពួង, សព្វកាល(លុប ព្វ ) |
| ឯក + ទា | > ឯកទា | ក្នុងកាលមួយ |
| យ+ ទា | > យទា | ក្នុងកាលណា, អង្កាល |
| ត + ទា | > តទា | ក្នុងកាលនោះ, គ្រានោះ |
| កឹ + ទា | > កទា | ក្នុងកាលណា, អង្កាល |
| កឹ + ទា | > កទាចិ | ក្នុងកាលខ្លះ, ជួនកាល (ចុះ ចិ) |
| ឥម + ទានិ | > ឥទានិ | ក្នុងកាលនេះ, ឥឡូវនេះ |
| ឥម + រហិ | > ឯតរហិ | ក្នុងកាលឥឡូវនេះ, ឥឡូវនេះ |
| កឹ + រហិ | > ករហចិ | ក្នុងកាលណា ៗ, ជួនកាល |
| ឥម + ធុនា | > អធុនា | ក្នុងកាលនេះ, អម្បាញ់មិញ |
| កឹ + ទាចនំ | > កុទាចនំ | ក្នុងកាលខ្លះ, ជួនកាល |

| | | |
|---|---|---|
| ឥម + ជ្ជ | > អជ្ជ | ក្នុងកាលនេះ, ថ្ងៃនេះ |
| សមាន + ជ្ជុ | > សជ្ជុ | ក្នុងថ្ងៃនេះ (លុប មាន ចេញ) |
| បរ + ជ្ជុ | > បរជ្ជុ | ក្នុងកាលដទៃ, ក្នុងថ្ងៃឯទៀត |
| អបរ + ជ្ជុ | > អបរជ្ជុ | ក្នុងថ្ងៃដទៃទៀត |

## កំណត់សម្គាល់

១. តាំងពី **តោ** រហូតដល់ **ជ្ជុ** ប្រើចុះចុងសព្វនាមទាំងនិយមនិងអនិយម ។

២. ចាប់ពី **ត្រ** ដល់ **វ** បច្ច័យពេលប្រែត្រូវថែមស័ព្ទដទៃ(អញ្ញបទ) ចូលមក ។

៣. ចាប់ពី **ធា** ដល់ **ជ្ជុ** បច្ច័យចុះក្នុងអត្ថនៃសត្តមីវិភត្តិដែលពុំចាំបាច់ថែមនាមបទដទៃចូលមកទេ ។ រីឯ **សមាន** សម្រេចមកពី **អស** ធាតុ ចុះ **មាន** បច្ច័យ ។

ពួកទី ៤ គឺ **តវេ**, **តុំ**, **តូន**, **ត្វា**, **ត្វាន** បច្ច័យទាំងនេះសម្រាប់ចុះជាមួយធាតុប៉ុណ្ណោះ និងប្រើជាកិរិយាស័ព្ទដូចបានអធិប្បាយរួចហើយក្នុងមេរៀនទី ២០ និងទី ២២ ក្នុងភាគ ១ ។

# កាលសត្តមីស័ព្ទ

*កាលសត្តមីជាស័ព្ទដែលប្រាប់ឱ្យដឹងកាលវេលាមាន ៣ ប្រភេទគឺ*

*១.* **នាមនាម***ខ្លះដែលបំបែកក្នុងរូបជាសត្តមីវិភត្តិដូចជា* **សមយេ** *=ក្នុងសម័យ,* **កាលេ** *=ក្នុងកាល,* **វេលាយំ** *=ក្នុងវេលា, ជាដើម ។*

*២. និបាតស័ព្ទពួកកាលត្ថនិបាតដូចជា* **អថ** *=កាលនោះ,* **ទិវា** *= វេលាថ្ងៃ ។ល។*

*៣. ស័ព្ទទាំងឡាយដែលចុះអព្យយបច្ច័យពួកទី ៣ គឺ* **ទា**, **ទានិ**, **រហិ**, **ចុទា**, **ទាចនំ**, **ជ្ជ**, **ជ្ជុ** *ដូចជា* **សព្វទា**, **ឥទានិ**, **អចុទា**, **អជ្ជ** *ជា-ដើម (ពាក្យប្រែសូមមើលខាងលើ) ។*

*ដូចបានពោលរួចហើយថាកាលសត្តមីត្រូវប្រែលេខ ៣ បន្ទាប់ពីបទអាលបននិងបទនិបាត ។ សូមជ្រាបថាមិនមែនស័ព្ទនិបាតទាំងអស់ត្រូវតែប្រែមុនបទប្រធានទេ គឺមាននិបាតស័ព្ទខ្លះក៏អាចប្រែខាងក្រោយក៏បានដែរ ។*

## វិធីប្រើក្នុងប្រយោគ

**<u>ហិយ្យោ</u> <u>សាយំ</u> ពន្ធុមន្តោ យសវន្តំ គាមំ គច្ឆឹសុ ។**

*<u>កាលពីម្សិលមិញ</u> <u>ក្នុងវេលាល្ងាច</u> ញាតិ.ទ. ទៅហើយ កាន់ភូមិ នៃអ្នកមានយស.ទ. ។*

ឥទានិ សព្វេបិ តេ ភិក្ខូ ឧត្តរាយ ទិសាយ អញ្ញតរស្មឹ អារាមេ វសន្តិ ។

*ក៏ ក្នុងកាលឥឡូវនេះ ភិក្ខុ.ទ. ទាំងពួង នោះ កំពុងរស់នៅ ក្នុងអារាម ដទៃ នៃទិស ខាងជើង ។*

កទា ត្វំ ខេត្តំ តត្រ គច្ឆិស្សសិ ។

*តើលោក នឹងទៅ ក្នុងទីនោះ ដើម្បីសំដែង ក្នុងកាលណា ?*

មនុស្សា អជ្ជ ឥធ វសិត្វា សុវេ តហឹ គច្ឆិស្សន្តិ ។

*ក្នុងថ្ងៃនេះ មនុស្ស.ទ. នៅហើយ ក្នុងទីនេះ នឹងទៅ ក្នុងទីនោះ ក្នុងថ្ងៃស្អែក ។*

## បុនរុត្តិសព្ទ

(*ការប្រើពាក្យផ្ទួន*)

*ក្នុងភាសាបាលី ការពោលពាក្យឬសំនួនពាក្យឱ្យផ្ទួនគ្នាមានញឹកញាប់ណាស់ ការប្រើដូច្នេះគឺដើម្បីសង្កត់សំដីឬដើម្បីប្រាប់ពីពហុភាព, អនេកភាព, សរុបភាព, ភាពផ្សេង ៗ ។ល។ ការប្រើបែបនេះ មានរបៀបប្រែច្រើនយ៉ាងតាមតែសេចក្ដីក្នុងទីនោះ ៗ ។ ក្នុងទីខ្លះពេលប្រែមកមានទំនងដូចការនិយាយនៃភាសាខ្មែរដែរ ដូចជា*

ភទ្ទានិ ភទ្ទានិ យានានិ = *យាន.ទ. ល្អ ៗ ។*

**តេសុ តេសុ ឋានេសុ** =*ក្នុងឋាន នោះ ៗ ។*

**តំ តំ កថយមានា** =*កំពុងនិយាយ នោះ ៗ ។*

**សីឃំ សីឃំ** =*លឿនណាស់, យ៉ាងលឿន ។*

*ប្រសិនបើជាសព្វនាមដូចជា* **យ** *ឬ* **ត** *ច្រើនប្រែថា "......ណាក៏ដោយ" ដូចជា* **យំ យំ គាមំ** =*ស្រុកណាក៏ដោយ ។*

**ឥតរា តេនេវ និយាមេន យា យា កិញ្ចិ កថេតិ តស្សា តស្សា ឧបរិ កចវរំ ឆឌ្ឌេសិ ។**

*ដោយនិយាម(=ទំនង) នោះ ស្រីណា ៗ ក៏ដោយ ពោល នូវអ្វីមួយ (ស្រីម្នាក់ទៀត) ចោលហើយ នូវសំរាម លើ ស្រីនោះ ៗ ។*

*ជួនកាលប្រើជាសមាសដូចជា*

**គតគតដ្ឋានេ** =*ក្នុងទីដែលទៅហើយ ៗ ។*

**សណ្ហសណ្ហា សាលិយោ** =*ស្រូវ.ទ.មានគុម្ពក្រាស់ ៗ ។*

**សោ ទិដ្ឋទិដ្ឋមនុស្សេ ជីវិតក្ខយំ ចាបេតិ ។** *គេ ញ៉ាំងមនុស្ស.ទ. ដែលបានឃើញហើយ ៗ ឱ្យដល់ នូវការអស់ទៅនៃជីវិត(ក្ស័យជីវិត) ។*

*ប្រើប្រាប់ពីការរំជួលចិត្ត បើប្រើដូច្នេះច្រើនជាឃ្លាផ្ទួនគ្នាដូចជា*

**អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ ។**

*បពិត្រលោកដ៏ចម្រើន ពិរោះណាស់ ៗ (ពោលសរសើរ) ។*

**ចិន្នា កោ សត្ត ជីវសិ ចិន្នា កោ សត្ត ជីវសិ ។**

*នៃសត្វដ៏ចម្រើន រីករាយណាស់ បានឃើញ (អ្នក) នៅរស់ ។*

*នៃសត្វដ៏ចម្រើន រីករាយណាស់ បានឃើញ (អ្នក) នៅរស់ ។*

**អាយាមិ អាវុសោ អាយាមិ អាវុសោ ។**

*ម្នាលលោកដ៏មានអាយុ ខ្ញុំ នឹងមក ខ្ញុំ នឹងមក (ប្រាប់ការសន្យា) ។*

## លំហាត់នៃមេរៀនទី ៣១

***ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ***

*១. តើអព្យយបច្ច័យចែកជាប៉ុន្មានពួក ?*

*២. តើពួកទី ១ មានបច្ច័យអ្វីខ្លះ ? តើចុះក្នុងអត្ថនៃវិភត្តិណាខ្លះនិងប្រែដូចម្ដេច ?*

*៣. តើពួកទី ២ មានបច្ច័យអ្វីខ្លះ ? តើចុះក្នុងអត្ថនៃវិភត្តិណាខ្លះនិងប្រែដូចម្ដេច ?*

*៤. តើពួកទី ៣ មានបច្ច័យអ្វីខ្លះ ? តើចុះក្នុងអត្ថនៃវិភត្តិណាខ្លះនិងប្រែដូចម្ដេច ?*

*៥. តើពួកទី ៤ មានបច្ច័យអ្វីខ្លះ ?*

*៦. តើកាលសត្តមីស័ព្ទមានប៉ុន្មានប្រភេទ ?*

*៧. តើពួកទី ១ ជាស័ព្ទប្រភេទណា ? សូមឱ្យឧទាហរណ៍ ។*

៨.. តើពួកទី ២ ជាស័ព្ទប្រភេទណា ? សូមឱ្យឧទាហរណ៍ ។

៩. តើពួកទី ៣ ជាស័ព្ទប្រភេទណា ? សូមឱ្យឧទាហរណ៍ ។

ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. យាវ តុម្ហេ មុត្តឹ លភេយ្យាថ តាវ អប្បមាទេន វាយមេយ្យាថ ។

២. យំ តេ ករោន្តិ តមេវ តហោត្វា បរំ លោកំ គច្ឆន្តិ ។

៣. កុតោ ត្វំ ធេនុយោ កិណិស្សសិ ។

៤. កត្ថ តវ ភគិនិយោ នហាយិត្វា បចិត្វា ភុញ្ជឹសុ ។

៥. អសនិ រុក្ខស្ស ឧបរិ បតិត្វា សាខា ឆិន្ទិត្វា តរុំ មារេសិ ។

៦. នារិយា ទុហិតរោ គេហស្ស អន្តោ មញ្ចេសុ សយិស្សន្តិ ។

៧. អម្ហាកំ បិតរោ តទា វនម្ហា មធុំ អាហរិត្វា ធីតរា សហ ភុញ្ជឹសុ ។

៨. យាវ មយ្ហំ បិតា នហាយិស្សតិ តាវ អហំ ឥធ តិដ្ឋាមិ ។

៩. យថា ភូបតិ អាណាបេតិ តថា ត្វំ កាតុំ ឥច្ឆសិ ។

១០. យោ មគ្គេ គច្ឆតិ តស្ស បុត្តោ សុរំ បិវិត្វា ឯត្ថ សយតិ ។

១១. យាចកា ភត្តំ បចន្តី ឥត្ថី ទិស្វា តំ អាហារំ យាចន្តា តត្ថ និសីទឹសុ ។

១២. ឥទានិ ថេរោ វិហារស្មឹ ធម្មំ ទេសេតិ កឹ តុម្ហេ ធម្មំ សោតុំ តហឹ ន គច្ឆថ ។

១៣. អហំ ហិយ្យោ ភាតិកស្ស គេហេ វសិត្វា អជ្ជ ចាតោវ

ឥជាតច្ឆឹ ។

១៤. កាស្មា ត្វំ អជ្ជ រាបឹ តត្វា បុន ងឌឹ តដ្តុំ ឥច្ឆសិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ម្សិលមិញ បុរស នោះ ទៅហើយ កាន់ព្រៃ ចឹកហើយ ដោយពស់ ស្លាប់ហើយ ។*

*២. សំពត់.ទ. នេះ និង ផ្កាឈូក.ទ. នោះ គឺអ្នក.ទ. ទិញហើយ ពីទីណា ?*

*៣. ក៏ បើ លោក គប្បីធ្វើ នូវអំពើល្អ លោក នឹងទៅ កាន់សុគតិ ។*

*៤. រីជន រមែងទៅ កាន់ទុគ្គតិ ក្តី សុគតិ ក្តី ដោយអំណាច នៃកម្ម របស់ខ្លួន ។*

*៥. អ្នកគ្វាលគោ កៀង នូវគោ.ទ. កាន់ទីគោចរ ដោយដំបង ដោយប្រការណា ភាពចាស់ ផង សេចក្តីស្លាប់ ផង តែងកៀង នូវអាយុ នៃសត្វមានជីវិត.ទ. ដោយប្រការដូច្នេះ ។*

**(ចប់មេរៀនទី ៣១)**

# មេរៀនទី ៣២

## អធិប្បាយអំពីនាមកិតក:

(Primary Derivatives)

*ពាក្យថា* **កិតក** *បានសេចក្ដីដូចម្ដេចនោះ សូមមើលក្នុងភាគ ១ មេរៀនទី ១៨ ។* **នាមកិតក** *ឬ* **កិតនាម** *ជាសព្ទមួយប្រភេទដែលប្រកបរូបចេញពីធាតុដូចកិតកិរិយាដែរ ប៉ុន្តែប្រើបច្ច័យផ្សេងគ្នា ដែលសម្រេចបានជានាមនាមខ្លះ ជាគុណនាមខ្លះ ។*

ធាតុនីមួយ ៗ ក្នុងភាសាបាលី

*១. បើផ្សំជាមួយបច្ច័យនិងវិភត្តិអាខ្យាតហៅថា* **អាខ្យាតកិរិយា** *។*

*២. បើផ្សំជាមួយបច្ច័យរបស់កិរិយាកិតក:ហៅថា* **កិតកិរិយា** *។*

*៣. បើផ្សំជាមួយបច្ច័យរបស់នាមកិតក:ហៅថា* **កិតនាម** *។*

## គោលសំខាន់ ៧ ប្រការ

*ក្នុងភាសាខ្មែរយើង ក៏មានយកពាក្យកិតក:នៃភាសាបាលីមកប្រើយ៉ាងច្រើនណាស់ដែរ ពាក្យកិតក:ដែលយកមកប្រើក្នុងភាសាខ្មែរ ភាគច្រើនជានាមកិតក:ដូចជា បញ្ញត្តិ, សម្បត្តិ, សម្មតិ, សញ្ញា, ទាន, នាយក, ឧបាសក, ការណ៍, សញ្ញាណ, ឧទាហរណ៍, កត្តា ជាដើម ។ល។*

ពាក្យទាំងឡាយដែលលើកយកមកបង្ហាញខាងលើនេះ បើប្រាថ្នាចង់ដឹងថាសម្រេចមកពីធាតុអ្វីនិងប្រែដូចម្ដេច គឺត្រូវអាស្រ័យលើធាតុ, បច្ច័យនិងវិធីប្រកបរូបស័ព្ទឱ្យទៅជានាមកិតកៈរបស់ភាសាបាលី និងជាពិសេសដែលនឹងប្រែពាក្យទាំងនោះឱ្យត្រឹមត្រូវបានតាមអត្ថន័យរបស់វាគឺពឹងលើគោលសំខាន់ៗ ៧ យ៉ាងគឺ

១. ធាតុ
២. បច្ច័យ
៣. រូបវិគ្គហៈ
៤. សាធនៈ
៥. វិភត្តិ (វិភត្តិនាម)
៦. បច្ច័យណាមានរូបវិគ្គហៈ និងជាសាធនៈអ្វី
៧. វិធីតាំងវិគ្គហៈ

១. **ធាតុ** បានដល់ ស័ព្ទប្រភេទណាសូមមើលក្នុងអាខ្យាតកិរិយា និងកិតកិរិយាក្នុងភាគ ១ ។

២. **បច្ច័យ**, បច្ច័យនៃនាមកិតកៈមាន ៣ ពួកដូចកិតកិរិយាដែរ

ពួកទី ១ ហៅថា **កិតបច្ច័យ** មាន ៥ តួគឺ **ក្វិ**, **ណី**, **ណ្វុ**, **តុ**, **រូ** ។

ពួកទី ២ ហៅថា **កិច្ចបច្ច័យ** មាន ២ តួគឺ **ខ**, **ណ្យ** ។

ពួកទី ៣ ហៅថា **កិតកិច្ចបច្ច័យ** មាន ៧ តួគឺ **អ**, **ឥ**, **ណ**, **តវេ**, **តិ**, **តុំ**, **យុ** ។

បូករួមមាន ១៤ តួ, ចូរចាំឱ្យបានល្អ ពីព្រោះនឹងមានប្រើផ្សំជាមួយធាតុដែលនឹងអធិប្បាយនៅខាងមុខ ។

៣. **រូបវិគ្គហ** ពាក្យថា **វិគ្គហ** ប្រែថា ប្រយោគឬអត្ថជាគ្រឿងសម្ដែងនូវអត្ថរបស់និប្ផន្នបទ ។ វិគ្គហៈជាប្រយោគមួយប្រភេទចងឡើងសម្រាប់ស្រាយបំភ្លឺនាមកិតកៈនោះ ៗ (នៅក្នុងភាសាខ្មែរជាការពន្យល់ពាក្យ) សូមមើលឧទាហរណ៍នៅខាងមុខ ។ ដើម្បីឱ្យដឹងថានាមកិតកៈនោះ ៗ សម្រេចមកពីធាតុនិងបច្ច័យអ្វី ត្រូវមើលវិគ្គហៈដែលចែកចេញជារូបមាន ៤ រូបគឺ **កត្តុរូប**, **កម្មរូប**, **ភាវរូប** និង **សមាសរូប** ។

រូបវិគ្គហៈខាងលើនេះ មានឈ្មោះហៅតាមវាចកៈទាំង ៥ របស់អាខ្យាតកិរិយានិងកិតកិរិយានោះឯងគឺ

៣.១. **កត្តុរូប**, រូបវិគ្គហៈណាមានបទកិរិយាស័ព្ទជាកត្តុវាចកៈ ឬហេតុកត្តុវាចកៈ រូបវិគ្គហៈនោះ ហៅថា **កត្តុរូប** សូមមើលឧទាហរណ៍នៅខាងមុខ ។

៣.២ **កម្មរូប**, រូបវិគ្គហៈណាមានបទកិរិយាស័ព្ទជាកម្មវាចកៈ ឬហេតុកម្មវាចកៈ រូបវិគ្គហនោះ ហៅថា **កម្មរូប** សូមមើលឧទាហរណ៍នៅខាងមុខ ។

៣.៣ **ភាវរូប**, រូបវិគ្គហៈណាមានបទកិរិយាស័ព្ទជាភាវវាចកៈ រូបវិគ្គហៈនោះហៅថា **ភាវរូប** សូមមើលឧទាហរណ៍នៅខាងមុខ ។

៣.៤ **សមាសរូប**, សមាសរូបមានអធិប្បាយនៅខាងមុខ ។

៤. **សាធន** ពាក្យថា សាធនៈ បានដល់ ស័ព្ទដែលសម្រេចមកពីរូបវិគ្គហៈ និងដែលត្រូវបានកាត់បទឬលុបអក្ខរៈចេញ ហៅថា **សាធិត**

ក៏បាន ប៉ុន្តែនិយមហៅថា សាធនៈ ។ ស័ព្ទដែលសម្រេចមកពីរូបវិគ្គហៈដូចពោលហើយ ហៅតាមសាធនៈនេះមាន ៧ យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែបើរាប់តស្សីលសាធនៈមួយទៀតត្រូវជា ៨ ដែលមានឈ្មោះហៅដូច្នេះ

១. កត្តុសាធន
២. កម្មសាធន
៣. ភាវសាធន
៤.ករណសាធន
៥. សម្បទានសាធន
៦. អបាទានសាធន
៧. អធិករណសាធន
៨. តស្សីលសាធន

រូបវិគ្គហៈនីមួយ ៗ ខាងលើមានសាធនៈដូចតទៅនេះ

ក. **កត្តុរូប** មានសាធនៈ ៧ យ៉ាងគឺ

១. កត្តុរូប-កត្តុសាធន
២. កត្តុរូប-កម្មសាធន
៣. កត្តុរូប-តស្សីលសាធន
៤. កត្តុរូប-ករណសាធន
៥. កត្តុរូប-សម្បទានសាធន
៦. កត្តុរូប-អបាទានសាធន
៧. កត្តុរូប-អធិករណសាធន

ខ. **កម្មរូប** មានសាធនៈ ៤ យ៉ាងគឺ

១. **កម្មរូប-កម្មសាធន**

២. **កម្មរូប-ករណសាធន**

៣. **កម្មរូប-សម្បទានសាធន**

៤. **កម្មរូប-អធិករណសាធន**

*គ. ភាវរូប មានសាធនៈ ១ យ៉ាងគឺ*

**ភាវរូប-ភាវសាធន ។**

*ឃ. សមាសរូបមាន ១ យ៉ាងគឺ*

**សមាសរូប-តស្សីលសាធន ។**

*ឈ្មោះរូបវិគ្គហៈនិងឈ្មោះសាធនៈពោលហើយខាងលើនេះ គប្បីចាំឱ្យច្បាស់ ពីព្រោះត្រូវការប្រើក្នុងការចងវិគ្គហៈរបស់សាធនៈនោះ ៗ ដែលនឹងមានពោលនៅខាងមុខ ។*

*៥.* **វិភត្តិ** *ស័ព្ទដែលប្រកបឡើងពីធាតុនិងបច្ច័យនៃនាមកិតកៈនិងសម្រេចចេញពីវិគ្គហៈបានជាស័ព្ទថ្មីមួយទៀតគឺសាធនៈនោះ ត្រូវតែចុះវិភត្តិ ។ រីវិភត្តិដែលត្រូវប្រើគឺវិភត្តិរបស់នាមនាមដែលមាន* **សិ-យោ** *ជាដើម ។ សាធនៈណាមានការន្តនិងលិង្គអ្វី ត្រូវបំបែកតាមការន្តនិងលិង្គនោះ ៗ ទៅ ។*

៦. ***តើបច្ច័យណាចុះក្នុងរូបវិគ្គហៈនិងជាសាធនៈណា?***

*៦.១ ពួកកិតបច្ច័យគឺ* **ក្វិ, ណី, ណ្វុ, តុ, រូ** *ចុះក្នុងរូបវិគ្គហៈជា* **កត្តុរូប-កត្តុសាធន** *និង* **កត្តុរូប-តស្សីលសាធន** *។*

*៦.២ ពួកកិច្ចបច្ច័យគឺ* **ខ, ណ្យ** *ចុះក្នុងរូបវិគ្គហៈជា* **កម្មរូប-កម្មសាធន** *និង* **ភាវរូប-ភាវសាធន** *តែប៉ុណ្ណោះ ។*

*៣. ពួកកិតកិច្ចបច្ច័យគឺ* **អ, ឥ, ណ, តវេ, តិ, តុំ, យុ** *ចុះក្នុងរូបវិគ្គហៈគ្រប់រូបគ្រប់សាធនៈមិនកំណត់ទេ វៀរតែ* **តវេ, តុំ** *បច្ច័យចេញមិនមានរូបវិគ្គហៈ ពីព្រោះជាអព្យយបច្ច័យ (ចូរមើលមេរៀនទី ២២ ក្នុងភាគ ១) ។*

*៧.* ***វិធីតាំងវិគ្គហៈ*** *ស័ព្ទសាធនៈមួយបទ ៗ កាលបើប្រកបរូបឡើងពីធាតុនិងបច្ច័យហើយ* ***ត្រូវតែតាំងវិគ្គហៈ*** *មើលសិនទើបប្រែត្រូវ ។ ពេលប្រែត្រូវញែកចេញតាមរូបដើមនៃស័ព្ទនោះ ៗ ។ ដោយសារតែមានរូបវិគ្គហៈនិងសាធនៈច្រើនយ៉ាង ដូច្នេះវិធីតាំងវិគ្គហៈក៏មានច្រើនបែបដែរ ។ ដើម្បីឱ្យងាយយល់ ត្រូវចែកវិគ្គហៈជាពីរចំណែកគឺ* **ភាគឥតិ** *និង* **ភាគសាធន** *។ ភាគឥតិគឺបទទាំងឡាយនៅខាងដើម* **ឥតិ** *និងភាគសាធនៈគឺបទសាធនៈនោះឯង ដូចអធិប្បាយដូចតទៅនេះ*

## ១. វិធីតាំងវិគ្គហៈនៃកត្តុរូប-កត្តុសាធនៈ

*ក. ភាគឥតិស័ព្ទ ត្រូវមាន*

*១.* **សទ្ទបបទ** *បានដល់* **បទកម្ម** *ជាដើម ។*

*២.* **បទកិរិយាស័ព្ទ** *ក្នុងរូបជាកត្តុវាចក:ឬហេតុកត្តុវាចក:ជានិច្ច ។*

*៣.* **ឥតិ** *ត្រូវសរសេរចូលនឹងកិរិយាស័ព្ទ ។*

*ខ. ភាគសាធន: ត្រូវមាន*

*៤.* **សាធនស័ព្ទ** *សម្រេចមកពីរូបវិគ្គហ:បំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* *ភាគសាធន:*

*(១. បទអធិប្បាយ, ២. បទកិរិយាស័ព្ទ +  ៣.* **ឥតិ***) (៤. សាធនស័ព្ទ)*

**វិគ្គហ:**

*ឧទាហរណ៍ទី ១*

```
១    ២   ៣     ៤
|    |   |     |
```

**កម្មំ ករោតីតិ > កម្មការោ ។**

*ក្នុងឧទាហរណ៍ខាងលើនេះឃើញថាក្នុងរូបវិគ្គហ:មានពាក្យត្រឹមតែ ៣ បទគឺ* **កម្មំ ករោតីតិ កម្មការោ** *។ ខាងភាគឥតិស័ព្ទមាន ២ បទគឺ* **កម្មំ ករោតីតិ***, រីភាគសាធន:មាន* **កម្មការោ** *ជាសាធនស័ព្ទបំបែកក្នុងរូបជាបឋមាវិភត្តិរបស់* **អ** *ការន្ត ។ ចំពោះបទថា* **ករោតីតិ** *មាន* **ឥតិ** *ស័ព្ទនៅផងដែរ ពេលប្រែត្រូវញែកចេញជា* **ករោតិ ឥតិ** *។*

# វិធីប្រែប្រយោគវិគ្គហៈ

*វេលាប្រែប្រយោគវិគ្គហៈនីមួយ ៗ ត្រូវយកតាមគោលការណ៍ប្រែរបស់ប្រយោគនោះ ៗ ដែលអធិប្បាយក្នុងភាគ ១ មេរៀនទី ២៥ ។*

*ក្នុងឧទាហរណ៍ខាងលើនេះជា* **កត្តុរូប-កត្តុសាធនៈ** *ដើម្បីឱ្យងាយយល់ ពេលប្រែត្រូវថែម* **យ** *ស័ព្ទចូលមកខាងដើមភាគឥតិស័ព្ទដោយបំបែកឱ្យជារូបណាមួយ សម្រាប់ប្រើជាបទប្រធានរបស់កិរិយាស័ព្ទ ក្នុងទីនេះបទកិរិយាស័ព្ទគឺ* **ករោតិ** *។ រីឯភាគសាធនៈ ត្រូវថែម* **ត** *ស័ព្ទចូលមកខាងដើមបទសាធនៈ ដែលត្រូវបំបែកឱ្យស្មើគ្នានឹង* **យ** *ស័ព្ទនៅខាងដើម ប្រើជាប្រធានដើម្បីទទួល គឺមានលំនាំដូចជាការប្រែប្រយោគ* **យ-ត** *ដូច្នោះដែរ ។ ក្នុងភាគសាធនៈអាចយោគបទដទៃណាមួយចូលមកបាន ។ ប្រសិនបើមានអញ្ញបទ* **យ-ត** *ស័ព្ទត្រូវបំបែកឱ្យស្មើគ្នានឹងអញ្ញបទនោះ ៗ ។ ដូច្នេះប្រយោគពេញលេញនៃឧទាហរណ៍ខាងលើមានរូបដូចខាងក្រោមនេះ*

**យោ កម្មំ ករោតីតិ សោ កម្មការោ** (ជនោ) ។

*ប្រែលោតប្រយោគមួយបទ ៗ ដើម្បីឱ្យងាយយល់ដូច្នេះ*

(**យោ ជនោ** *រីជន ណា*) **ករោតិ** *រមែងធ្វើ* **កម្មំ** *នូវការងារ* **ឥតិ** *ព្រោះហេតុនោះ* (**សោ ជនោ** *រីជន នោះ*) **កម្មការោ** *ឈ្មោះថា* **កម្មការោ**, **កម្មការោ** *=អ្នកធ្វើការងារ (ខ្មែរថា កម្មករ ហ្នឹងឯង)* ។

*រូបវិគ្គហៈនេះជា* **កត្តុរូប-កត្តុសាធន** *និងដែលហ៊ានហៅឈ្មោះថាយ៉ាងនេះ ក៏ព្រោះតែក្នុងរូបវិគ្គហៈមានបទប្រធាននៃប្រយោគមានរូបជាបឋមាវិភត្តិជាតួកត្តា គឺ* **យោ ជនោ** ។ *ចំពោះកិរិយាស័ព្ទទៀតសោត* **ករោតិ** *ក៏មានរូបជាកត្តុវាចកៈ ។ ប្រសិនបើកិរិយាស័ព្ទជាហេតុកត្តុវាចកៈវិញទៅជា* **ការាបេតិ** *សូមមើលឧទាហរណ៍ខាងក្រោមនេះ*

*ឧទាហរណ៍ទី ២*

១ ២ ៣ ៤

**កម្មំ ការាបេតីតិ កម្មការាបកោ ។**

*ប្រយោគពេញមានដូចខាងក្រោមនេះ*

**យោ កម្មំ ការាបេតីតិ សោ កម្មការាបកោ** (**ជនោ**) ។

*ប្រែលោតប្រយោគមួយបទ ៗ ដើម្បីឱ្យងាយយល់ដូច្នេះ*

(**យោ ជនោ** *វីជន ណា*) (......) **ការាបេតិ** *ឱ្យធ្វើ* **កម្មំ** *នូវអំពើ* **ឥតិ** *ព្រោះហេតុនោះ* (**សោ ជនោ** *វីជន នោះ*) **កម្មការាបកោ** *ឈ្មោះថា* **កម្មការាបកោ**, **កម្មការាបកោ** =*អ្នកឱ្យធ្វើនូវអំពើ ។*

*រូបវិគ្គហៈនេះក៏ជាកត្តុរូប-កត្តុសាធនៈដែរ ព្រោះក្នុងរូបវិគ្គហៈមានបទប្រធាននៃប្រយោគជាបឋមាវិភត្តិជាតួកត្តាគឺ* **យោ ជនោ** *និងមានកិរិយាស័ព្ទ* **ការាបេតិ** *ជាកិរិយាហេតុកត្តុវាចកៈ ។*

សូមចំណាំថា វេលាប្រែប្រយោគ **យ-ត** គប្បីថែមស័ព្ទដទៃចូលមកដើម្បីឱ្យងាយយល់ តែស័ព្ទនោះ ៗ ត្រូវឱ្យសមតាមសេចក្ដីដែរ ក្នុងប្រយោគខាងលើគឺសំដៅដល់មនុស្ស ដូច្នេះត្រូវថែមបទថា **ជនោ** ឬ **បុគ្គលោ** ប៉ុន្តែបើជាសត្វត្រូវថែមថា **សត្តោ** វិញ ។ សូមជ្រាបតាមន័យដូច្នេះផងចុះ ។

ចំពោះស័ព្ទសាធនៈនៃឧទាហរណ៍ខាងលើនេះ ពុំដឹងថាសម្រេចមកពីបច្ច័យអ្វីនៅឡើយទេ ។ រីឯធាតុអាចដឹងបានថាមកពី **ករ** ធាតុ ។ ដូច្នេះត្រូវសិក្សាពីសាធនៈនិងបច្ច័យម្ដងមួយ ៗ ដូចនឹងមានអធិប្បាយជាបន្តបន្ទាប់ទៅនេះ

## ១. វិធីចុះ **ក្វិ** បច្ច័យ

**ក្វិ** ជាកិតបច្ច័យមានរូបវិគ្គហៈជា **កត្តុរូប-កត្តុសាធនៈ** តែម្យ៉ាងមានវិធីប្រកបរូបស័ព្ទឱ្យទៅជានាមកិតកៈដូចតទៅនេះ

**ក្វិ** បច្ច័យនិយមចុះជាមួយធាតុដែលមានស័ព្ទដទៃនាំមុខហៅថា **សឧបបទ** ។ បើចុះ **ក្វិ** បច្ច័យជាមួយធាតុណាមួយហើយចំបាច់ត្រូវលុប **ក្វិ** ចោលជានិច្ច ។ ដោយសារតែ **ក្វិ** បច្ច័យត្រូវលុបបាត់ទៅមិនមានរូបឱ្យឃើញ តើយើងអាចដឹងថាពាក្យនោះ ៗ ជា **ក្វិ** បច្ច័យឬមិនមែននោះដូចម្ដេច ? គឺត្រូវអាស្រ័យលើគោល ៤ យ៉ាងជាផ្លូវពិចារណា

ដូចតទៅនេះ

១. ត្រូវមានសទ្ទុបបទនាំមុខជានិច្ច ដែលអាចជានាមនាម, គុណ-នាម, សព្វនាម, ឧបសគ្គ ឬក៏ និបាតស័ព្ទ ។

២. បើផ្សំជាមួយធាតុ ២ តួ, ត្រូវលុបទីបំផុតធាតុនោះ ៗ ចេញដូចខាងក្រោមនេះ

| សទ្ទុ. | + ធាតុ | + បច្ច័យ | សម្រេច | ពាក្យប្រែ |
|---|---|---|---|---|
| កុជ ន. | + គម | + ក្វិ | > កុជគ | សត្វទៅដោយល្បត់ (នាគ) |
| ឧរ ន. | + គម | + ក្វិ | > ឧរគ | សត្វទៅដោយទ្រូង (ពស់) |
| តុរ គុ. | + គម | + ក្វិ | > តុរគ | សត្វទៅដោយរួសរាន់ (សេះ) |

៣. បើផ្សំជាមួយធាតុទោល ១ តួ, ត្រូវទុកធាតុឱ្យគង់រូបដើមដូចខាងក្រោមនេះ

| សទ្ទុបបទ | + ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| អភិ ឧប. | + ភូ | + ក្វិ | > អភិភូ | អ្នកជាធំ |
| មារ ន. | + ជិ | + ក្វិ | > មារជិ | អ្នកឈ្នះនូវមារ |
| សយំ និ. | + ភូ | + ក្វិ | > សយម្ភូ | អ្នកកើតឯង (ព្រះសយម្ភូ) |

៤. ចំពោះ វិទ ធាតុប្រែថា "ចេះ, ដឹង" ទោះបីជាធាតុពីរតួក៏ដោយមិនឱ្យលុបទីបំផុតធាតុចេញទេ ប៉ុន្តែឱ្យចុះ ឩ អាគមថែមដូចខាងក្រោម

| សទ្ទុបបទ | + ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| **សព្វ** សព្វ. | + **វិទ** | + **ក្វិ** | > **សព្វវិទូ** | អ្នកជ្រាបសព្វ |
| **លោក** ន. | + **វិទ** | + **ក្វិ** | > **លោកវិទូ** | អ្នកជ្រាបនូវលោក |

ចំពោះ **វិទ** នេះក្នុងកន្ទេផខ្លះពន្យល់ថា **វិទ** ធាតុចុះ **រូ** បច្ច័យ ។ បច្ច័យណាដែលមានតួ **រ** ត្រូវលុប **រ** ចោលនៅសល់តែស្រៈ **ឩ** ហើយយកមកធ្វើសន្ធិទៅជា (**លោក** + **វិទ** + **រូ**) > **លោកវិទូ** និងវេលាតាំងវិគ្គហៈលោកនិយមប្រើ **ញា** ធាតុ ។ ក្នុងរូបវិគ្គហៈមាន **វិ** ឧបសគ្គខាងដើមជា (**វិ** + **ញា** + **ជា** + **តិ**) > **វិជានាតិ** =រមែងដឹងច្បាស់ ។ មានរូបវិគ្គហៈជាកត្តុរូប-កត្តុសាធនៈដូចខាងក្រោមនេះ

**លោកំ វិជានាតីតិ លោកវិទូ** =អ្នកដឹងច្បាស់នូវលោក ។

## កំណាត់សម្គាល់

១. **ក្វិ** បច្ច័យបើចុះជាមួយធាតុណាត្រូវតែមានសទ្ទុបបទជានិច្ចជានាមនាម, គុណនាម, សព្វនាម, ឧបសគ្គ ឬ និបាតក៏បាន ។ ពេលចុះហើយត្រូវលុប **ក្វិ** បច្ច័យចោល ។

២. បើចុះជាមួយធាតុពីរតួត្រូវលុបទីបំផុតធាតុចេញជានិច្ច ។

៣. បើចុះជាមួយធាតុទោល ១ តួត្រូវរក្សាធាតុឱ្យគង់រូបដើម ។

៤. ចំពោះ **វិទ** ធាតុ ទោះជាធាតុពីរតួក៏ដោយ ក៏ពុំចាំបាច់លុបទីបំផុតធាតុចេញទេ តែត្រូវចុះ **ឧ** អាគមថែមឬផ្សំជាមួយ **រូ** បច្ច័យក៏បានដូចពោលក្នុងខាងលើ ។

៥. បើប្រើក្នុងន័យបដិសេធត្រូវចុះ **ន** ដែលត្រូវផ្លាស់ជា **អ** ឬ **អន** ប្រែថា "មិន" ពីខាងដើមស័ព្ទដែលសម្រេចរូបហើយនោះ ដូចក្នុងកិតកិរិយាគ្រប់ប្រការ ។

៦. **ក្វិ** បច្ច័យជាកត្តុរូប-កត្តុសាធនៈតែម៉្យាងប៉ុណ្ណោះ ។

ខាងក្រោមនេះជាការតាំងវិគ្គហៈ

**ឧរេន គច្ឆតីតិ ឧរគោ** =សត្វទៅដោយទ្រូង (ពស់) ។

**តុរំ គច្ឆតីតិ តុរគោ** =សត្វទៅដោយរួសរាន់ (សេះ) ។

**(អភិ-វិសិដ្ឋេន) ភវតីតិ អភិភូ** =អ្នកកើតដោយវិសេស (ព្រះភគវា)។

**មារំ ជិនាតីតិ មារជិ** =អ្នកឈ្នះនូវមារ ។

**សយំ ភវតីតិ សយម្ភូ** =អ្នកកើតដោយខ្លួនឯង (ព្រះមានជោគ)។

**សព្វំ វិទតីតិ សព្វវិទូ** = អ្នកជ្រាបនូវហេតុទាំងពួង (ព្រះភគវា)។

**លោកំ វិទតីតិ លោកវិទូ** =អ្នកជ្រាបនូវលោក (ព្រះមានជោគ)។

**លោកំ វិជានាតីតិ លោកវិទូ** =អ្នកដឹងច្បាស់នូវលោក ។

**កុម្ភំ ករោតីតិ កុម្ភការោ** =អ្នកធ្វើនូវឆ្នាំង (ស្មូនឆ្នាំង) ។

*ដើម្បីឱ្យកើតជំនាញ សូមយកសព្ទសាធនៈនោះ ៗ មកតាំងវិគ្គហៈឱ្យពេញ រួចហើយហាត់ប្រែតាមបែបឧទាហរណ៍ខាងលើ ដូច្នេះ*

**យោ មារំ ជិនាតីតិ សោ មារជិ ( ជនោ ) ។**

(*ប្រែថា*) (**យោ ជនោ** *វិជន ណា*) **ជិនាតិ** *តែងឈ្នះ* **មារំ** *នូវមារ* **ឥតិ** *ព្រោះហេតុនោះ* (**សោ ជនោ** *វិជន នោះ*) **មារជិ** *ឈ្មោះថា* **មារជិ**, **មារជិ** =*អ្នកឈ្នះមារ ។*

## កំណាត់សម្គាល់

**យោ-សោ** *តាមប្រក្រតីមិនមានក្នុងរូបវិគ្គហៈទេ តែវេលាប្រែត្រូវថែមមកដើម្បីឱ្យងាយយល់ ។ ដើម្បីឱ្យមានជំនាញគួរហាត់ប្រែនិងចាំទុក ពីព្រោះអាចយកទៅប្រើជាមួយសព្ទឯទៀត ៗ បានយ៉ាងច្រើនណាស់ ។ សូមសាកល្បងប្រែខ្លួនឯងផងចុះ គឺសង្ឃឹមថាលោកអ្នកគង់ប្រែបានមិនខាន ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ

*ការប្រើនាមកិតកៈក្នុងប្រយោគនានា មានដំណើរដូចនាមនាម*

ដែលបានរៀនរួចហើយដែរ ដែលត្រូវតែបំបែកតាមវិភត្តិផ្សេង ៗ ។ រីឯការបំបែកគឺត្រូវយកការន្តនៃស័ព្ទសាធនៈនោះ ៗ ជាគោល ។

ពាក្យដែលសម្រេចមកពី **ក្វិ** បច្ច័យដូចមាននៅខាងលើចាត់ជាគុណនាម ប៉ុន្តែអាចប្រើជានាមនាមបានដែរ ។ បើប្រើជាបទវិសេសនៈរបស់នាមនាមបទណា ត្រូវបំបែកឱ្យមានលិង្គ, វចនៈ, វិភត្តិ ឱ្យស្មើគ្នានឹងបទប្រធានដូចខាងក្រោមនេះ

## ប្រយោគឧទាហរណ៍

ក. ប្រើជាបទវិសេសនៈ

អម្ហាកំ សត្ថា <u>សយម្ភូ</u> ចេវ <u>សព្វវិទូ</u> ច អហោសិ ។

ព្រះសាស្ដា របស់យើង.ទ. ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯង (<u>ព្រះសយម្ភូ</u>) ដោយពិតផង និងជាអ្នកដឹងនូវហេតុទាំងពួង (ព្រះ<u>សព្វវិទូ</u>) ផង ។

ខ. ប្រើជានាមបទ

បញ្ច <u>តុរគា</u> បញ្ចង្គំ រាជង្គំ អហោសុំ ។

<u>សេះ.ទ.</u> ប្រាំក្បាល ជាសេះរបស់ព្រះរាជា.ទ. ប្រាំព្រះអង្គ ។

(ចប់ ក្វិ បច្ច័យ)

## វិធីតាំងវិគ្គហៈនៃតស្សីលសាធនៈ

*ពាក្យថា* **តស្សីលសាធន** *មកពី* (**ត** + **សីល** + **សាធន**) *តែតម្រូត* **សី** *ជា* **ស្សី** *មានសេចក្ដីថា រូបវិគ្គហៈក្នុងភាគឥតិស័ព្ទត្រូវប្រកបដោយ* **ត** *សព្វនាម ហើយនឹង* **សីល** *។ ពាក្យថា* **សីល** *ប្រែថា "ប្រក្រតី" ឬប្រែត្រាប់សព្ទថា "សីល" ។ ក្នុងតស្សីលសាធនៈត្រូវតែមានពាក្យថា* **សីល** *នៅក្នុងវិគ្គហៈជានិច្ច ។ តស្សីលសាធនៈមាន ២ យ៉ាងគឺ* **កត្តុរូប-តស្សីលសាធន** *និង* **សមាសរូប-តស្សីលសាធន** *។*

*វេលាប្រែស័ព្ទដែលសម្រេចមកពីរូបវិគ្គហៈតស្សីលសាធនៈ ត្រូវប្រែថា "អ្នក...ជាប្រក្រតី" ។*

## វិធីតាំងវិគ្គហៈនៃកត្តុរូប-តស្សីលសាធនៈ

*១. កត្តុរូប-តស្សីលសាធនៈ មានស័ព្ទសំខាន់ក្នុងរូបវិគ្គហៈដូចនេះ*

*ក.* ***ភាគឥតិស័ព្ទ ត្រូវមាន***

*១.* **សទ្ធុបបទ** *មានរូបជា ទុតិយាឬតតិយាវិភត្តិ ។*

*២.* **បទកិរិយាស័ព្ទ** *មានរូបជាកត្តុ. ឬ ហេតុកត្តុវាចកៈជានិច្ច ។*

*៣.* **សីល** *ស័ព្ទបំបែកជាតតិយាវិភត្តិទៅជា* **សីលេន** *ប្រែថា "ជា-ប្រក្រតី" ។*

៤. **ឥតិ** ត្រូវសរសេរចូលនឹង **សីល** ស័ព្ទទៅជា **សីលេណាតិ** ។

២. ភាគសាធនៈ ត្រូវមាន

៥. **សាធនស័ព្ទ** ដែលសម្រេចមកពីរូបវិគ្គហៈបំបែកជាបឋមាវិភត្តិ ។

ភាគឥតិស័ព្ទ — ភាគសាធនៈ

១. សទ្ទុបបទ, ២. បទកិរិយាស័ព្ទ, ៣. **សីល**, ៤. **ឥតិ** ៥. សាធនស័ព្ទ

វិគ្គហៈ

ឧទាហរណ៍

១ ២ ៣ ៤ ៥

**ធម្មំ ចរតិ សីលេណាតិ > ធម្មចារី ។**

ប្រែថា (**យោ ជនោ** ជន ណា) **ចរតិ** រមែងប្រព្រឹត្ត **ធម្មំ** នូវធម៌ **សីលេន** ជាប្រក្រតី **ឥតិ** ព្រោះហេតុនោះ (**សោ ជនោ** ជន នោះ) **ធម្មចារី** ឈ្មោះថា **ធម្មចារី**, **ធម្មចារី** =អ្នកប្រព្រឹត្តនូវធម៌ជាប្រក្រតី ។

ប្រសិនបើលុបពាក្យថា **សីល** ចេញគឺទៅជា កត្តុរូប-កត្តុសាធនៈ វិញហើយដែលមានរូបវិគ្គហៈថា ( **យោ** ) **ធម្មំ ចរតីតិ** ( **សោ** ) **ធម្មចារី** ( **ជនោ** ) =(ជន) អ្នកប្រព្រឹត្តនូវធម៌ ។

(សូមសង្កេតមើលមិនមានពាក្យថា **ប្រក្រតី**ទេ)

# វិធីតាំងវិគ្គហៈនៃសមាសរូប-តស្សីលសាធនៈ

២. *សមាសរូប-តស្សីលសាធនៈ មានស័ព្ទសំខាន់ក្នុងរូបវិគ្គហៈដូចនេះ*

*ក. ភាគឥតិស័ព្ទ ត្រូវមាន*

១. **សទ្ទុបបទ** *មានរូបជា ទុតិយាឬតតិយាវិភត្តិ ។*

២. **បទកិរិយាស័ព្ទ** *ត្រូវចុះ តុំ បច្ច័យប្រែថា កិរិយា..., ការ... ។*

៣. **សីល** *ស័ព្ទបំបែកជា* **សីលំ** ។

៤. **ត** *សព្វនាមត្រូវបំបែកជាឆដ្ឋីវិភត្តិមានរូបជា* **អស្ស** *រួចសរសេរចូលនឹង* **សីលំ** *ទៅជា* **សីលមស្ស** *ឬក៏ប្រើ* **យ** *បំបែកជា* **យស្ស** *រួចសរសេរចូលជាមួយ* **ឥតិ** *ទៅជា* **យស្សាតិ** *ក៏បាន ។*

៥. **ឥតិ** *សរសេរចូលនឹង* **សីលមស្ស** *ស័ព្ទទៅជា* **សីលមស្សាតិ** ។

*ខ. ភាគសាធនៈ ត្រូវមាន*

៦. **សាធនស័ព្ទ** *បំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* *ភាគសាធនៈ*

*១. សទ្ទុបបទ, ២. បទកិរិយា, ៣.* **សីល**, *៤.* **ត/យ**, *៥.* **ឥតិ** *៦. សាធនៈ*

*វិគ្គហៈ*

*ឧទាហរណ៍*

១ ២ ៣ ៤ ៥ ៦

**ធម្ម (ចរ + តុំ) (សីលំ + អស្ស) ឥតិ (ធម្ម + ចរ + ណី)**

មានរូបវិគ្គហៈពេញដូច្នេះ

១ ២ ៣ ៤ ៥ ៦

**១. ធម្មំ ចរិតុំ សីលមស្សាតិ (សោ) ធម្មចារី (ជនោ) ។**

១ ២ ៣ ៤ ៥ ៦

**២. ធម្មំ ចរិតុំ សីលំ យស្សាតិ (សោ) ធម្មចារី (ជនោ) ។**

*វេលាប្រែត្រូវញែកចេញពីគ្នាដើម្បីឱ្យងាយយល់ ។*

*ប្រែថា* **ចរិតុំ** *រីកិរិយាប្រព្រឹត្ត* **ធម្មំ** *នូវធម៌* **សីលំ** *ជាប្រក្រតី* **អស្ស ជនស្ស** *របស់ជន នោះ* **ឥតិ** *ព្រោះហេតុនោះ* (**សោ ជនោ** *រីជន នោះ*) **ធម្មចារី** *ឈ្មោះថា* **ធម្មចារី**, **ធម្មចារី** *=អ្នកមានកិរិយាប្រព្រឹត្តនូវធម៌ជាប្រក្រតី, ឬ អ្នកមានប្រក្រតីប្រព្រឹត្តនូវធម៌ ។*

*ចំណុចសំខាន់គឺត្រូវមានពាក្យថា "អ្នកមាន........." ។*

*នៅក្នុងវិគ្គហៈទី ២ ត្រង់* **យស្សាតិ** *ត្រូវប្រែថា* **យស្ស ជនស្ស** *ប្រែថា "របស់ជន ណា" វិញ ។ សូមសង្កេតតទៅទៀត វិគ្គហៈនេះមិនមានប្រើ* **យោ** *ក្នុងរូបវិគ្គហៈទេ ពីព្រោះមាន* **ចរិតុំ** *ជាបទប្រធានស្រេចហើយ ។ ចំណែកឯសាធនៈវិញត្រូវចុះ* **សោ** *មកទទួលជានិច្ច ។*

# លំហាត់នៃមេរៀនទី ៣២

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើនាមកិតកៈមានគោលសំខាន់ ៗ ខ្វះមិនបានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

២. តើនាមកិតកៈមានបច្ច័យទាំងអស់ប៉ុន្មានតួ ?

៣. តើបច្ច័យពួកទី ១ មានប៉ុន្មានតួ គឺអ្វីខ្លះ ?

៤. តើបច្ច័យពួកទី ២ មានប៉ុន្មានតួ គឺអ្វីខ្លះ ?

៥. តើបច្ច័យពួកទី ៣ មានប៉ុន្មានតួ គឺអ្វីខ្លះ ?

៦. តើពាក្យថា "វិគ្គហៈ" ប្រែថាដូចម្ដេច ?

៧. តើរូបវិគ្គហៈមានប៉ុន្មានរូប គឺអ្វីខ្លះ ?

៨. ប្រសិនបើក្នុងរូបវិគ្គហៈមានបទកិរិយាសព្ទជាកត្តុវាចកៈ ឬហេតុកត្តុវាចកៈ តើរូបវិគ្គហៈនោះហៅថារូបវិគ្គហៈអ្វី ?

៩. ប្រសិនបើក្នុងរូបវិគ្គហៈមានបទកិរិយាសព្ទជាកម្មវាចកៈឬហេតុ-កម្មវាចកៈ តើរូបវិគ្គហៈនោះហៅថារូបវិគ្គហៈអ្វី ?

១០. ប្រសិនបើក្នុងរូបវិគ្គហៈមានបទកិរិយាសព្ទជាភាវវាចកៈ តើរូបវិគ្គហៈនោះហៅថារូបវិគ្គហៈអ្វី ?

១១. តើពាក្យថា "សាធនៈ" ជាអ្វី ?

១២. តើសាធនៈទាំងអស់មានប៉ុន្មានយ៉ាង គឺសាធនៈអ្វីខ្លះ ?

១៣. តើ **ត្វា**, **ណី**, **ណ្វុ**, តុ, រូ សម្រាប់ចុះក្នុងរូបវិគ្គហៈនិងសាធនៈអ្វីខ្លះ

*១៤. តើ ខ, ណ្យ សម្រាប់ចុះក្នុងរូបវិគ្គហៈនិងសាធនៈអ្វីខ្លះ ?*

*១៥. តើ អ, ឥ, ណ, តវេ, តិ, តុំ, យុ សម្រាប់ចុះក្នុងរូបវិគ្គហៈនិងសាធនៈអ្វីខ្លះ ?*

*១៦. តើតស្សីលសាធនៈមានប៉ុន្មានយ៉ាង គឺតស្សីលសាធនៈអ្វីខ្លះ ?*

*១៧. តើមានអ្វីជាគ្រឿងសម្គាល់ថាស័ព្ទនោះៗ សម្រេចមកពី កិច្ច បច្ច័យ ?*

*១៨. ចូរតាំងវិគ្គហៈជាកត្តុរូប-កត្តុសាធនៈនិងប្រែលោតប្រយោគដោយប្រើ យ-ត ស័ព្ទ ចំពោះ ឧរគ, តុរគ ។*

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. តា ធារិយោ ភត្តំ បចិត្វា ធារកស្ស តំ ភត្តំ ទត្វា កុមារិកា គេហេ និសីទន្តិ ។

២. កទា វិទេសំ សិក្ខាយ គមិស្សសិ ? សចេ ត្វំ វិទេសំ គមិស្សសិ អហម្បិ តមេវ គមិស្សាមិ ។

៣. សចេ តុម្ហេ ចាចា កាយេយ្យាថ មា ចាណំ វធេថ ច មា ថេយ្យចិត្តេន បរេសំ ធនាធំ វត្ថូនិ អាធាយថ ច កាមេសុ មិច្ឆាចារំ មា ករោថ ច មុសាវាទា បដិវិរមថ ច មជ្ជំ មា បិវថ ច ។

៤. យា លតា យស្មឹ អរញ្ញេ រូហតិ សា លតា តស្មឹ អរញ្ញេ ភវតុ។

៥. តស្ស បុរិសស្ស ចតុត្ថោ កាជិដ្ឋោ វីរិយេន ច ឧស្សាហេន ច ខេត្តេ កាម្មំ អការិ ។

៦. មនុស្សស្ស តស្មា ព្រហ្មានំ ន រុច្ចតិ តស្មា ព្រហ្មានោ
មនុស្សលោកំ នាគច្ឆន្តិ ។

៧. យោ ជនោ ឆ ឥន្ទ្រិយានិ សំវរេយ្យ សេយ្យថីទំ ចក្ខុន្ទ្រិយំ
សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជីវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ
ទុក្ខំ តស្ស ន ឧប្បជ្ជតិ តស្មា មយំ តានិ ឥន្ទ្រិយានិ
សំវរេយ្យាម ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. សេះ អាច ដើម្បីរត់ អស់២៥ យោជន៍ ក្នុងមួយថ្ងៃ ។*

*២. ព្រះពុទ្ធជាអ្នកដឹងសព្វ ជាអ្នកជ្រាបច្បាស់នូវលោក ទ្រង់ជាសាស្តា
នៃមនុស្ស និង ទេវតា ផង ។*

*៣. ស្រី នេះ កាលប្តី ស្លាប់ហើយ បានហើយ នូវប្តី ឯទៀត ។*

*៤. កិលេស.ទ. ទាំងពួង ជា(ទោស) គឺព្រះអរហន្ត.ទ. លះហើយ ។*

*៥. ភិក្ខុ មួយរូប ចូលទៅរកហើយ នូវឧបជ្ឈាយ៍ របស់ខ្លួន ថ្វាយបង្គំ-
ហើយ អង្គុយហើយ លើអាសនៈ ដ៏សមគួរ សួរហើយ នូវប្រស្នា ។*

*៦. ឧបជ្ឈាយ៍ នោះ សំដែងហើយ នូវប្រស្នា ដល់ភិក្ខុ នោះ បញ្ជូនទៅ
ហើយ នូវភិក្ខុនោះ ។*

**(ចប់មេរៀនទី ៣២)**

# មេរៀនទី ៣៣

# អធិប្បាយអំពីនាមកិតក: (ត)

## វិធីចុះ ណី បច្ច័យ

*១. ធាតុដែលចុះ* **ណី** *បច្ច័យមានវិធីប្រែនិងតាំងវិគ្គហ:បាន ៣ រូបគឺ កត្តុរូប-កត្តុសាធន: (ចូរមើល* **ក្វិ** *បច្ច័យ), កត្តុរូប-តស្សីលសាធន: និងសមាសរូប-តស្សីលសាធន: ។ ចំពោះកត្តុរូប-កត្តុសាធន:មានរូបវិគ្គហ:ដូច* **ក្វិ** *បច្ច័យគ្រប់យ៉ាង ។*

*២.* **ណី** *បច្ច័យអាចចុះជាមួយធាតុបាន ដោយមិនកំណត់ថាត្រូវឱ្យមានសទ្ទុបបទទេ មិនមានសទ្ទុបបទក៏បានដែរ ។ ស័ព្ទសាធន:ដែលសម្រេចមកពីកត្តុរូប-កត្តុសាធន:ប្រែថា "អ្នក..." ។ បើសម្រេចមកអំពីកត្តុរូប-តស្សីលសាធន: ប្រែថា "អ្នកមាន......ជាប្រក្រតី" ។ បើសម្រេចមកពីសមាសរូប-តស្សីលសាធន: ប្រែថា "អ្នកមានប្រក្រតី......" ឬថា "អ្នកមានកិរិយា......ជាប្រក្រតី" ។*

*៣.* **ណី** *ជាបច្ច័យមានតួ* **ណ** *ជាអនុពន្ធ ដូច្នេះត្រូវតែលុបតួ* **ណ** *ចេញ ទុកឱ្យនៅត្រឹមតែស្រៈ* **ឦ** *ដែលអាចធ្វើឱ្យធាតុប្រែប្រួលរូបបានខ្លះ ។*

*៤. បើស្រៈដើមធាតុជាស្រៈទីឃៈឬចុងធាតុជាព្យញ្ជនសំយោគ ពុំ*

ចាំបាច់ផ្លាស់ទេ ឧទាហរណ៍

១. (**សុភាសិត** + **ភាស** + **ណី**) > **សុភាសិតភាសី** =អ្នកពោលនូវសុភាសិតជាប្រក្រតី ។

២. (**វាចា** + **អនុ** + **រក្ខ** + **ណី**) > **វាចានុរក្ខី** =អ្នករក្សានូវវាចាជាប្រក្រតី, អ្នកមានប្រក្រតីរក្សានូវវាចា, អ្នកមានកិរិយារក្សានូវវាចាជាប្រក្រតី ។ សូមមើលវិគ្គហៈនៅខាងមុខ ។

៣ បើស្រៈដើមធាតុជាស្រៈរស្សៈ ត្រូវតែទីឃៈឬព្រឹទ្ធិជានិច្ចគឺស្រៈ **អ** > **អា**, **ឥ** > **ឯ**, **ឧ** >**ឱ** ឬ **ឪ** ឧ.

(**បុញ្ញ** + **ករ** + **ណី**) > **បុញ្ញការី** =អ្នកធ្វើនូវបុណ្យជាប្រក្រតី ។

(**សន្ធិ** + **ឆិទ** + **ណី**) > **សន្ធិច្ឆេទី** =អ្នកផ្ដាច់នូវតំណជាប្រក្រតី ។

(**ធម្ម** + **រុច** + **ណី**) > **ធម្មរូចី** =អ្នកពេញចិត្តនូវធម៌ជាប្រក្រតី ។

(**កាម** + **ភុជ** + **ណី**) > **កាមភោគី** =អ្នកបរិភោគនូវកាមជាប្រក្រតី ។

សូមមើលរូបវិគ្គហៈនៅខាងមុខ ។

៥. បើស្រៈនៃធាតុជាស្រៈ **អា** ត្រូវផ្លាស់ជា **អាយ** ជានិច្ច ឧ.

(**អធិដ្ឋ** + **អា** + **ធា** + **ណី**) > **អធិដ្ឋាធាយី** = អ្នកកាន់យកនូវវត្ថុដែលគេមិនបានឱ្យជាប្រក្រតី ។

៦. **ណី** បច្ច័យមានអំណាចផ្លាស់ប្ដូររូបនៃធាតុឬព្យញ្ជនៈទីបំផុតធាតុបាន ធ្វើឱ្យធាតុផ្លាស់ចាករូបដើម ឧទាហរណ៍

(**ភយ** + **ទិស** + **ណី**) > **ភយទស្សី** =អ្នកឃើញនូវភ័យជាប្រក្រតី (ផ្លាស់ **ទិស** > **ទស្ស**) ។

(**បាណ** + **ហន** + **ណី**) > **បាណឃាតី** =អ្នកសម្លាប់នូវសត្វជាប្រក្រតី, (ផ្លាស់ **ហន** > **ឃាត**) ។

៧. **ណី** បច្ច័យក្រៅពីប្រើជា**កត្តុរូប** (អ្នកធ្វើដោយខ្លួនឯង) នៅអាចប្រើជា**ហេតុកត្តុរូប** (អ្នកបង្គាប់គេឱ្យធ្វើ) បានដែរ ដោយប្រែថា "អ្នកញ៉ាំង......ឱ្យ..." ប៉ុន្តែត្រូវចុះហេតុបច្ច័យជាមួយធាតុមុនសិន ឧ.

(**បត** + **ណេ** + **ណី**) > **បាតី** =អ្នកញ៉ាំងសត្វឱ្យធ្លាក់ចុះឬអ្នកឱ្យធ្លាក់ចុះ (អ្នកសម្លាប់សត្វ) ។

៨. ស័ព្ទដែលសម្រេចមកពី **ណី** បច្ច័យជានាមស័ព្ទ ឦ ការន្តអាចបំបែកបានទាំងបីលិង្គ ។ ប្រសិនបើប្រើជាបទវិសេសនៈរបស់នាមបទបុំលិង្គ ត្រូវបំបែកតាម ឦ ការន្តបុំលិង្គដូច **សេដ្ឋី** ។ បើប្រើជាឥត្ថីលិង្គត្រូវចុះ **ឥនី** ដូចជា **បុញ្ញការិនី** ហើយបំបែកតាមបែប **នារី** ។ បើប្រើជាមួយនបុំសកលិង្គត្រូវរស្សៈ ឦ > ឥ ដូចជា **បាណឃាតិ** ហើយបំបែកដូច **មុនិ** ។

## ខាងក្រោមជាវិគ្គហៈគំរូ

### ១. សុភាសិតភាសី

*មានរូបវិគ្គហៈទាំងបីសាធនៈដូចខាងក្រោមនេះ*

សុភាសិតំ ភាសតីតិ សុភាសិតភាសី (ជនោ) ។ *កត្តុ.កត្តុ.*
សុភាសិតំ ភាសតិ សីលេនាតិ សុភាសិតភាសី(ជនោ) *កត្តុ.តស្សី*
សុភាសិតំ ភាសិតុំ សីលមស្សាតិ សុភាសិតភាសី ។ *សមា.តស្សី*

## ២. វាចានុរក្ខី

(យោ) វាចំ អនុរក្ខតីតិ (សោ) វាចានុរក្ខី (ជនោ) ។ *កត្តុ.កត្តុ.*
(យោ) វាចំ អនុរក្ខតិ សីលេនាតិ (សោ) វាចានុរក្ខី (ជនោ) ។ *កត្តុ.តស្សី*
វាចំ អនុរក្ខិតុំ សីលមស្សាតិ វាចានុរក្ខី ។ *សមា.តស្សី*

*ចូររៀនតាំងរូបវិគ្គហៈនិងប្រែសព្ទសាធនៈខាងក្រោមនេះ ឱ្យត្រូវតាមឧទាហរណ៍ខាងលើ*

| | | | |
|---|---|---|---|
| កម្មការី | អធិដ្ឋាធាយី | មជ្ជចាយី | រុក្ខមូលវាសី |
| កាមភោគី | ភយទស្សី | នគរវាសី | នេរនគរវាសី |
| បុញ្ញការី | ចាណឃាតី | គាមវាសី | ពោធិរុក្ខវាសី |
| សន្ធិច្ឆេទី | ធម្មវាទី | អរញ្ញវាសី | រជ្ជចាលី |
| ធម្មចារី | កោសម្ពិវាសី | វនវាសី | រជ្ជមន្តី |

# កំណាត់សម្គាល់

ដើម្បីឱ្យដឹងថាស័ព្ទណាជាសាធនៈអ្វី យើងត្រូវប្រែឱ្យត្រូវតាមក្រិត្យក្រមនៃសាធនៈនោះ ៗ ពីព្រោះសាធនៈមួយ ៗ មានរូបវិគ្គហៈរៀង ៗ ខ្លួន ដូចឃើញហើយថាស័ព្ទសាធនៈពោលខាងលើនេះជា **ណី** បច្ច័យ មានស្រះទីបំផុតជា ៦ ការន្ត ។ វេលាយកទៅប្រើរៀងក្នុងប្រយោគត្រូវបំបែកក្នុងរូបវិភត្តិផ្សេង ៗ តាមបែប ៦ ការន្ត ។

ដូច្នេះកាលណាយើងជួបស័ព្ទផ្សេង ៗ ដូចពោលហើយ ដើម្បីឱ្យដឹងថាស័ព្ទណាប្រែយ៉ាងណានោះ គឺត្រូវយកមកតាំងវិគ្គហៈមើលក៏នឹងដឹងភ្លាម ៗ ដូចជា **រដ្ឋចាលី**, **រដ្ឋមន្ត្រី** មានរូបវិគ្គហៈនិងប្រែដូចខាងក្រោមនេះ

**រដ្ឋចាលី** *ក្នុងរូបវិគ្គហៈទាំងបីសាធនៈ*

(យោ) **រដ្ឋំ ចាលេតីតិ** (សោ) **រដ្ឋចាលី** (ជនោ) ។ *កត្តុ.កត្តុ.*

(យោ) **រដ្ឋំ ចាលេតិ សីលេនាតិ** (សោ) **រដ្ឋចាលី** (ជនោ) *ក.តស្សី.*

**រដ្ឋំ ចាលិតុំ សីលមស្សាតិ រដ្ឋចាលី** ។ *សមា.តស្សី*

*ប្រែថា (ជន)អ្នករក្សានូវដែនឬរដ្ឋ, អ្នកមានការរក្សានូវដែនឬរដ្ឋជាប្រក្រតី, អ្នកមានប្រក្រតីរក្សានូវដែនឬរដ្ឋ ។*

**រដ្ឋមន្ត្រី** *ក្នុងរូបវិគ្គហៈទាំងបីសាធនៈ*

(យោ) **រដ្ឋំ មន្តេតីតិ** (សោ) **រដ្ឋមន្ត្រី** (ជនោ) ។ *កត្តុ.កត្តុ.*

(យោ) រដ្ឋំ មន្តេតិ សីលេជាតិ (សោ) រដ្ឋមន្ត្រី (ជនោ) ។ *កត្តុ.តស្សី*

រដ្ឋំ មន្តិតុំ សីលមស្សាតិ រដ្ឋមន្ត្រី ។ *សមា.តស្សី*

*ប្រែថា អ្នកប្រឹក្សានូវដែនឬរដ្ឋ, ........... ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (ត)

*នាមកិតកៈដែលសម្រេចមកពី* **ណី** *បច្ច័យអាចប្រើជានាមនាមក៏បាន ឬជាគុណនាមក៏បាន ។ បើប្រើជាបទវិសេសនៈនៃបទនាមណាត្រូវរៀងដាក់ខាងដើមបទនាមនោះ ៗ ដោយត្រូវបំបែកឱ្យមាន លិង្គ, វចនៈ និងវិភត្តិឱ្យស្មើគ្នា ។*

***ក. ប្រើជាបទវិសេសនៈ***

<u>បុញ្ញការី</u> ជនោ សុគតឹ គច្ឆតិ ។ *ជន <u>អ្នកធ្វើនូវបុណ្យជាប្រក្រតី</u>(បុញ្ញការី) រមែងទៅ កាន់សុគតិ ។*

***ខ. ប្រើជានាមបទ***

<u>ធម្មចារី</u> សុខំ សេតិ ។ *<u>អ្នកប្រព្រឹត្តនូវធម៌ជាប្រក្រតី</u>(ធម្មចារី) រមែងដេក ជាសុខ ។*

***(ចប់ ណី បច្ច័យ)***

# វិធីចុះ ណ្វុ បច្ច័យ

ណ្វុ ជាបច្ច័យដែលមានតួ ណ គឺមានអំណាចឱ្យទីឃៈដើមធាតុខ្លះ, ផ្លាស់ធាតុឱ្យទៅជារូបផ្សេងខ្លះ, មានក្រិត្យក្រមដូច ណី បច្ច័យគ្រប់ប្រការ ។ ប៉ុន្តែពេលចុះហើយត្រូវផ្លាស់ ណ្វុ បច្ច័យជា អក ជានិច្ច រូប លុប អ ចោលទុកឱ្យនៅត្រឹមតែ ក ប៉ុណ្ណោះ ។ ស័ព្ទដែលសម្រេចរូបមកប្រែថា "អ្នក..." ដូចមានវិធីចុះដូចតទៅនេះ

១. ប្រសិនបើចុះជាមួយធាតុដែលមានស្រៈដើមធាតុជាស្រៈរស្សៈត្រូវតែទីឃៈឬព្រឹទ្ធិជានិច្ចគឺស្រៈ អ > អា, ឥ > ឯ, ឧ > ឱ ឬ ឱ ដូចខាងក្រោមនេះ

| ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ភុជ | + (ណ្វុ > អក) | > ភោជក | =អ្នកបរិភោគ ។ |
| ករ | + (ណ្វុ > អក) | > ការក | =អ្នកធ្វើ ។ |
| បដិ + គហ | + (ណ្វុ > អក) | > បដិគ្គាហក | =អ្នកទទួល ។ |

២ បើចុះជាមួយធាតុមួយព្យាង្គដែលជាស្រៈរស្សៈឬទីឃៈក៏ដោយអាចព្រឹទ្ធិស្រៈបានដូចខាងក្រោមនេះ

| ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សុ > សាវ | + (ណ្វុ > អក) | > សាវក | =អ្នកស្តាប់ ។ |
| នី > នាយ | + (ណ្វុ > អក) | > នាយក | =អ្នកដឹកនាំ ។ |

៣. បើទីបំផុតធាតុជាស្រៈ អា, ត្រូវផ្លាស់ជា អាយ ឬក៏ថាត្រូវចុះ យ បច្ច័យដែលជាអាខ្យាតបច្ច័យក្នុងទីបំផុតធាតុដូចខាងក្រោមនេះ

| ធាតុ + | បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| បា | + យ + (ណ្វុ > អក) | > បាយក | =អ្នកផឹក ។ |
| ទា | + យ + (ណ្វុ > អក) | > ទាយក | =អ្នកឱ្យ ។ |

៤. អាចផ្លាស់ធាតុឱ្យទៅជារូបផ្សេង ៗ ដូច ណី បច្ច័យបានដែរ

| ធាតុ + | បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ហន > ឃាត | + (ណ្វុ > អក) | >ឃាតក | =អ្នកសម្លាប់ ។ |
| ហន > វធ | + (ណ្វុ > អក) | > វធក | =អ្នកសម្លាប់ ។ |

៥. បើប្រើជាមួយ ញា ធាតុត្រូវផ្លាស់ ណ្វុ ជា អាននក

ញា > ជា + (ណ្វុ > អាននក) > ជាននក =អ្នកបេះ ។

៦. បើដើមធាតុជាស្រៈទីឃៈ ត្រូវទុកធាតុឱ្យគង់រូបដើម ឧ.

យាច + (ណ្វុ > អក) > យាចក =អ្នកសុំ ។

៧. បើទីបំផុតធាតុជាព្យញ្ជនសំយោគ ត្រូវទុកធាតុឱ្យគង់រូបដើមដែរ ឧ.

| ធាតុ + | បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| រក្ខ | + (ណ្វុ > អក) | > រក្ខក | =អ្នករក្សា ។ |
| តច្ឆ | + (ណ្វុ > អក) | > តច្ឆក | =អ្នកឈូស (ជាងឈើ) ។ |

៨. **ណ្ហុ** បច្ច័យក្រៅពីប្រកបរូបជាកត្តុរូប-កត្តុសាធនៈក៏អាចប្រកបរូបជាហេតុរូប-កត្តុសាធនៈបានដែរ ប្រើជាអ្នកបង្គាប់គេឱ្យធ្វើ ប្រែថា "អ្នកញុំាង.....ឱ្យ" ឬ "អ្នកឱ្យ..." ដោយចុះហេតុបច្ច័យថែមមកទៀត ឧ.

**ការ** + **ណាបេ** + (**ណ្ហុ** > **អក**) > **ការាបក** =អ្នកញុំាងជនឱ្យធ្វើ, អ្នកឱ្យគេធ្វើ ។

៩. ស័ព្ទដែលចុះ **ណ្ហុ** បច្ច័យនិងដែលផ្លាស់ជា **អក** អាចបំបែកបានទាំង ៣ លិង្គ ។ បើប្រើជាបទវិសេសនៈនៃនាមបុំលិង្គ ត្រូវបំបែកតាម **បុរិស** គ្រប់ប្រការ ។ បើប្រើជាបទវិសេសនៈនៃនាមឥត្ថីលិង្គ ត្រូវចុះ **ឥ** អាគមជា **ឥក** និងចុះស្រៈ **អា** បច្ច័យគ្រឿងសម្គាល់ឥត្ថីលិង្គទៅជា **ឥកា** ដូចជា **សារិកា**, **យាចិកា**, **ទាយិកា** ជាដើម រួចបំបែកតាមបែប **កញ្ញា** គ្រប់ប្រការ ។ បើប្រើជាបទវិសេសនៈនៃនាមនបុំសកលិង្គ ត្រូវបំបែកតាម **កុល** ។

## វិធីតាំងវិគ្គហៈនៃ ណ្ហុ បច្ច័យ

ក. **ណ្ហុ** បច្ច័យជាកត្តុរូប-កត្តុសាធនៈតែម៉្យាង មានគោលការណ៍រៀងវិគ្គហៈនិងប្រែដូច **ត្វុ** បច្ច័យគ្រប់ប្រការ (ចូររកមើលគោលការណ៍តាំងវិគ្គហៈរបស់កត្តុរូប-កត្តុសាធនៈក្នុងមេរៀនទី ៣២) ខាងក្រោមនេះជាឧទាហរណ៍ខ្លះ ៗ

១. **អនុសាសក** *មានវិគ្គហៈថា*

(**យោ**) **អនុសាសតីតិ** (**សោ**) **អនុសាសកោ** (**ជនោ**) ។

*ប្រែថា ជនណា រមែងបង្រៀន ព្រោះហេតុនោះ ជននោះ ឈ្មោះថា* **អនុសាសកោ, អនុសាសកោ** = *អ្នកបង្រៀន ។*

២. **ជានក** *វិគ្គហៈថា*

(**យោ**) **ជានាតីតិ** (**សោ**) **ជានកោ** (**ជនោ**) ។

*ប្រែថា ជនណា ចេះ ព្រោះហេតុនោះ ជននោះ ឈ្មោះថា* **ជានកោ, ជានកោ** = *អ្នកចេះ ។*

៣. **ភោជក** *មានវិគ្គហៈថា*

(**យោ**) **ភុញ្ជតីតិ** (**សោ**) **ភោជកោ** (**ជនោ**) ។

*ប្រែថា ជនណាស៊ី ព្រោះហេតុនោះ ជននោះ ឈ្មោះថា* **ភោជកោ, ភោជកោ** = *អ្នកស៊ី, អ្នកបរិភោគ ។*

៤. **យាចក** *មានវិគ្គហៈថា*

(**យោ**) **យាចតីតិ** (**សោ**) **យាចកោ** (**ជនោ**) = *អ្នកសុំ ។*

៥. **រក្ខក** *មានវិគ្គហៈថា*

(**យោ**) **រក្ខតីតិ** (**សោ**) **រក្ខកោ** (**ជនោ**) =*អ្នករក្សា ។*

៦. **ទាយក** *មានវិគ្គហៈថា*

(**យោ**) **ទេតីតិ** (**សោ**) **ទាយកោ** (**ជនោ**) =*អ្នកឱ្យ ។*

៧. ធាយក មានវិគ្គហៈថា

(យោ) បិវតីតិ (សោ) ធាយកោ (ជនោ) =អ្នកផឹក ។

៨. សាវក មានវិគ្គហៈថា

(យោ) សុណាតីតិ (សោ) សាវកោ (ជនោ) =អ្នកស្តាប់ ។

៩. ជាយក មានវិគ្គហៈថា

(យោ) នេតីតិ (សោ) ជាយកោ (ជនោ) =អ្នកដឹកនាំ ។

១០. ឃាតក មានវិគ្គហៈថា

(យោ) ហនតីតិ (សោ) ឃាតកោ (ជនោ) =អ្នកសម្លាប់ ។

១១. វធក មានវិគ្គហៈថា

(យោ) ហនតីតិ (សោ) វធកោ (ជនោ) =អ្នកសម្លាប់ ។

ខ. ណ្វុ បច្ច័យប្រកបរូបកិរិយាជាហេតុរូប-កត្តុសាធនៈ

១. សម្បហំសក មានវិគ្គហៈថា

(យោ) សម្បហំសេតីតិ (សោ) សម្បហំសកោ (ជនោ) = អ្នកញុំាងជនឱ្យរីករាយ (មកពី សំ + ប + ហំស + ណេ + ណ្វុ) ។

២. ការាបក មានវិគ្គហៈថា

(យោ) ការាបេតីតិ (សោ) ការាបកោ (ជនោ) =អ្នកញុំាងជនឱ្យធ្វើ (ករ + ណាបេ + ណ្វុ) ។

# វិធីប្រើនាមកិតកៈក្នុងប្រយោគ (ត)

*នាមកិតកៈដែលសម្រេចមកពី **ណ្វុ** បច្ច័យ ជាគុណនាមបំបែកបានទាំង ៣ លិង្គ ។ បើប្រើជាបទវិសេសនៈរបស់នាមណា ត្រូវរៀងដាក់ខាងដើមបទនាមនោះ ៗ និងត្រូវឱ្យមានលិង្គ, វចនៈ, វិភត្តិស្មើគ្នា ។*

## ប្រយោគឧទាហរណ៍

*ក. ប្រើជាបទវិសេសនៈ*

<u>យាចកោ</u> បុរិសោ មគ្គេ ឯកំ បុគ្គលំ ទិស្វា តំ អនុគច្ឆតិ ។

*បុរស <u>ជាអ្នកសុំ</u> ឃើញហើយ នូវបុគ្គល ម្នាក់ ក្នុងផ្លូវ ទើបទៅតាមបុគ្គលនោះ ។*

*ខ. ប្រើជានាមបទ*

<u>សាវកោ</u> ចេវ <u>សាវិកា</u> ច ធម្មំ សុណន្តិ ។

*<u>អ្នកស្តាប់ប្រុស</u> ផងមែនពិត <u>អ្នកស្តាប់ស្រី</u> ផង កំពុងស្តាប់ នូវធម៌ ។*

*ម៉្យាងទៀតស័ព្ទដែលសម្រេចមកពី **ណ្វុ** បច្ច័យក៏អាចមានបទកម្មផងដែរ ប៉ុន្តែបទកម្មនោះត្រូវបំបែកជាឆដ្ឋីវិភត្តិតាមវចនៈនោះ ៗ និងដល់វេលាប្រែ ត្រូវប្រើពាក្យប្រែ(អាយតនិបាត)របស់ទុតិយាវិភត្តិ គឺប្រែកាច់ថា **នូវ** ជំនួសវិញ (ហៅថា ឆដ្ឋីកម្ម) ឧ.*

<u>ធម្មស្ស</u> ទេសកោ មហន្តំ បុញ្ញំ បសវតិ ។

(ភិក្ខុ)អ្នកសំដែង <u>នូវធម៌</u> រមែងប្រសព្វ នូវបុណ្យ ច្រើន ។

(**ទេសកោ** ពុំមែនបានដល់តែ ភិក្ខុ ទេ ។ អ្នកណាក៏ដោយឱ្យតែសំដែងធម៌បានគឺឈ្មោះថា ទេសកបុគ្គល =បុគ្គលអ្នកសំដែង) ។

(ចប់ ណ្វុ បច្ច័យ)

## វិធីចុះ តុ បច្ច័យ

១. តុ ជាបច្ច័យមានតួ ត ដូច្នេះវិធីប្រកបរូបមិនខុសប្លែកពីបច្ច័យដែលមានតួ ត ឯទៀតទេ ។ ស័ព្ទដែលចុះ តុ បច្ច័យនេះអាចប្រព្រឹត្តទៅបាន ៣ សាធនៈគឺ កត្តុរូប-កត្តុសាធនៈ, កត្តុរូប-តស្សីលសាធនៈ, សមាសរូប-តស្សីលសាធនៈ ។

២. វិធីតាំងវិគ្គហៈគឺមានគតិដូច **ណី** បច្ច័យគ្រប់ប្រការ ។ ប៉ុន្តែនិយមប្រែតាមរូបវិគ្គហៈនៃកត្តុរូប-កត្តុសាធនៈច្រើនជាង ប្រែថា "អ្នក..." មានឬមិនមានសទ្ទុបបទនាំមុខក៏បាន ។ ប្រសិនបើចុះជាមួយធាតុពីរតួដែលមានទីបំផុតជាព្យញ្ជនៈ ច, ជ, ទ, ធ, ប, រ ត្រូវផ្លាស់ទីបំផុតធាតុទាំងនេះជា ត ឬជាលុបទីបំផុតធាតុចេញ ហើយតម្រួតជា ត្តុ តាមវិធី

ព្យញ្ជនសំយោគវិញក៏បាន ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សិច | + តុ | > សិត្តុ | អ្នកស្រោច |
| ភុជ | + តុ | > ភុត្តុ | អ្នកបរិភោគ |
| វច | + តុ | > វត្តុ | អ្នកពោល |
| ខណ | + តុ | > ខត្តុ | អ្នកជីក |
| គុប | + តុ | > គុត្តុ | អ្នកគ្រប់គ្រង |
| ការ | + តុ | > កាត្តុ | អ្នកធ្វើ, |

៣. បើចុះជាមួយធាតុមានទីបំផុតជា ម ត្រូវផ្លាស់ ម > ណ, បើទីបំផុតធាតុជា ណ ស្រាប់ត្រូវទុក ណ ឱ្យគង់រូបនិងតម្រួតជា ណ្ត ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ហណ | + តុ | > ហណ្តុ | អ្នកសម្លាប់ |
| ជណ | + តុ | > ជណ្តុ | អ្នកកើត |
| គម | + តុ | > គណ្តុ | អ្នកទៅ |
| សម | + តុ | > សណ្តុ | អ្នកស្ងប់ |

៤. បើទីបំផុតធាតុជាស្រៈ ឦ ឬ ឧ ត្រូវព្រឹទ្ធិ ឦ > ឯ, ឧ > ឱ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ជី | + | តុ | > ជេតុ | អ្នកនាំទៅ |
| សុ | + | តុ | > សោតុ | អ្នកស្តាប់ |

៥. បើទីបំផុតធាតុជាស្រៈ **អា** និងជាធាតុមួយព្យាង្គត្រូវទុកធាតុឱ្យគង់រូបដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ធា | + | តុ | > ធាតុ | អ្នកឱ្យ |
| ញា | + | តុ | > ញាតុ | អ្នកចេះឬដឹង |

៦. បើមិនផ្លាស់ប្តូរធាតុឱ្យទៅជារូបផ្សេងដូចខាងលើទេ ត្រូវចុះ **ឥ** អាគមលើទីបំផុតធាតុដូចខាងក្រោមនេះ

| ធាតុ | | អាគម | +បច្ច័យ | | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|---|
| ការ | + | ឥ | + | តុ | > ការិតុ | អ្នកធ្វើ |
| គម | + | ឥ | + | តុ | > គមិតុ | អ្នកទៅ |
| លភ | + | ឥ | + | តុ | > លភិតុ | អ្នកបាន |
| សរ | + | ឥ | + | តុ | > សរិតុ | អ្នករលឹក |

៧. ប្រសិនបើជាសកម្មធាតុក៏អាចប្រកបរូបជាហេតុរូប-កត្តុសាធនៈបានដែរ តែត្រូវចុះហេតុបច្ច័យផងដូចខាងក្រោមនេះ

| ធាតុ + | បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ករ | + ណេ + តុ | > ការេតុ | អ្នកឱ្យ...ធ្វើ |
| ហរ | + ណេ + តុ | > ហារេតុ | អ្នកឱ្យ...នាំទៅ |
| មរ | + ណេ + តុ | > មារេតុ | អ្នកឱ្យ...សម្លាប់ |

## កំណត់សម្គាល់

*សព្ទដែលប្រកបចេញពី តុ បច្ច័យដូចពោលនេះជា ឱ ការន្តមែនពិត តែមិនត្រូវបំបែកតាមវិធីបំបែករបស់នាមនាម ឱ ការន្តជម្មតាទេ ត្រូវបំបែកតាមបែប* **សត្ថុ** *វិញ (ចូររកមើលវិធីបំបែក* **សត្ថុ** *ក្នុងមេរៀនទី ២៥ ភាគ ១) និងអាចបំបែកបានទាំងបីលិង្គ តែនិយមប្រើជាបុំលិង្គ ។ រីឯជាឥត្ថីលិង្គនិងនបុំសកលិង្គមិននិយមប្រើទេ ។*

## វិធីតាំងវិគ្គហៈនៃ តុ បច្ច័យ

*តុ បច្ចយ័ប្រព្រឹត្តទៅបាន ៣ សាធនៈនិងមានវិធីតាំងវិគ្គហៈដូច* **ណី** *បច្ច័យគ្រប់ប្រការ ប៉ុន្តែនិយមប្រើក្នុងវិគ្គហៈជា កត្តុរូប-កត្តុសាធនៈ តែម៉្យាងដូចខាងក្រោមនេះ*

១. **កត្តុ** *មានវិគ្គហៈថា* (**យោ**) **ករោតីតិ** (**សោ**) **កត្តា** (**ជនោ**) ។
*ប្រែថា រីជន ណា រមែងធ្វើ ព្រោះហេតុនោះ រីជន នោះ ឈ្មោះ*
*ថា* **កត្តា**, **កត្តា** = *អ្នកធ្វើ* ។

២. **ខត្តុ** *វិ.* (**យោ**) **ខនតីតិ** (**សោ**) **ខត្តា** (**ជនោ**) =*អ្នកជីក* ។

៣. **វត្តុ** *វិ.* (**យោ**) **វទតីតិ** (**សោ**) **វត្តា** (**ជនោ**) =*អ្នកពោល* ។

៤. **នេតុ** *វិ.* (**យោ**) **នេតីតិ** (**សោ**) **នេតា** (**ជនោ**) =*អ្នកនាំទៅ* ។

៥. **សោតុ** *វិ.*(**យោ**) **សុណាតីតិ** (**សោ**) **សោតា** (**ជនោ**)=*អ្នកស្តាប់*

៦. **ជន្តុ** *វិ.* (**យោ**) **ជាយតីតិ** (**សោ**) **ជន្តុ**❋ (**សត្តោ**) =*អ្នកកើត* ។

៧. **ហន្តុ** *វិ.* (**យោ**) **ហនតីតិ** (**សោ**) **ហន្តា** (**ជនោ**) =*អ្នកសម្លាប់* ។

៨. **សរិតុ** *វិ.* (**យោ**) **សរតីតិ** (**សោ**) **សរិតា** (**ជនោ**) =*អ្នករលឹក* ។

៩. **គមិតុ** *វិ.* (**យោ**) **គច្ឆតីតិ** (**សោ**) **គមិតា** (**ជនោ**) =*អ្នកទៅ* ។

១០. **ទាតុ** *វិ.* (**យោ**) **ទេតីតិ** (**សោ**) **ទាតា** (**ជនោ**) =*អ្នកឱ្យ* ។

១១. **ញាតុ** *វិ.*(**យោ**) **ជានាតីតិ** (**សោ**) **ញាតា** (**ជនោ**) =*អ្នកដឹង* ។

❋ **ជន្តុ** *ជានាមនាមប្រែថា "សត្វកើត" ជា* **ឧ** *ការន្តបុម្លិង្គ ទើប*
*បំបែកក្នុងរូបជាបឋមាវិភត្តិដូច* **គរុ** ។

## កំណត់សម្គាល់

១. *ស័ព្ទឯទៀតៗ ដែលប្រកបចេញពី* **តុ** *បច្ច័យ ក៏មានវិធីតាំង*

*វិគ្គហៈដូចគ្នា ។ បើចង់តាំងតាមវិគ្គហៈជាកត្តុរូប-តស្សីលសាធនៈ ត្រូវតាំងវិគ្គហៈថា*

**(យោ) សុណាតិ សីលេនាតិ (សោ) សោតា (ជនោ) ។**

*ជនណា រមែងស្តាប់ ជាប្រក្រតី ព្រោះហេតុនោះ ជននោះ ឈ្មោះថា អ្នកស្តាប់ជាប្រក្រតី ។*

*២. រីឯសមាសរូប-តស្សីលសាធនៈក៏ដូចគ្នាដែរតែមិននិយមប្រើ ។*

*៣. ចំណុចសំខាន់គឺថា* **តុ** *បច្ច័យ កាលបើបំបែកតាមវិភត្តិផ្សេង ៗ* **តុ** *ក៏បាត់រូបទៅ គឺបំបែកតាមលំនាំដូចគ្នានឹង* **សត្ថុ** *ឬ* **បិតុ** *ដែរ ។*

*៤. ស័ព្ទដែលសម្រេចមកពី* **តុ** *បច្ច័យក៏អាចមានបទកម្មដែរដែលត្រូវរៀងដាក់ខាងដើមនាមជាប្រធាន និងបទកម្មនោះ ៗ ត្រូវបំបែកជាឆដ្ឋីវិភត្តិជានិច្ច ។ ប៉ុន្តែវេលាប្រែ ត្រូវកាច់ជាទុតិយាវិភត្តិ ប្រែថា "នូវ..." ជំនួសវិញ ហៅថា ឆដ្ឋីកម្ម ឧ.*

**<u>ធម្មស្ស</u> អញ្ញាតា សេដ្ឋោ ហោតិ ។**

*អ្នកចេះដឹងទូទៅ <u>នូវធម៌</u> ជាអ្នកប្រសើរបំផុត ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (គ)

*១. ប្រើជាបទវិសេសនៈ*

**តថាគតា <u>អក្ខាតារោ</u> ហោន្តិ ។**

*ព្រះតថាគត.ទ. <u>ជាអ្នកប្រាប់</u> ។*

២. *ប្រើជានាមនាម*

**<u>វត្តារោ</u> សុភាសិតមេវ វត្តព្វំ ។**

*ពាក្យសុភាសិតមែនពិត (ប៉ុណ្ណោះ) <u>គឺអ្នកពោល</u> គប្បីពោល។*

(**សុភាសិតមេវ** = **សុភាសិតំ** + **ឯវ**)

**(ចប់ តុ បច្ច័យ)**

# វិធីចុះ រូ បច្ច័យ

*រូ ជាបច្ច័យមានតួ រ ជាអនុពន្ធដែរ ។ គ្រប់វេលាចុះក្នុងទីបំផុតនៃធាតុ ត្រូវលុប រ ចេញ ទុកសល់នៅតែស្រៈ ឩ និងប្រព្រឹត្តទៅបាន ៣ សាធនៈដែរ ។ រូបស័ព្ទដែលប្រកបដោយ រូ បច្ច័យមានចំណុចសង្កេតគួរដឹងដូចខាងក្រោមនេះ*

*១. សទ្ទុបបទ (មានឬមិនមានក៏បាន) + ធាតុ + រូ > ឩ បច្ច័យ(លុប រ សល់នៅតែស្រៈ ឩ) ។*

*២. បើចុះជាមួយធាតុ ១ ព្យាង្គត្រូវទុកធាតុឱ្យគង់រូបដើម ឧ.*

មត្ត (សទ្ទុ.) + ញ្ញា + រូ > មត្តញ្ញូ = អ្នកដឹងនូវប្រមាណ (លុប ស្រៈ អា នៃ ញ្ញា, លុប រ ចេញហើយតម្រួតជា ញ្ញូ) ។

៣. បើចុះជាមួយធាតុពីរតួ ត្រូវលុបទីបំផុតធាតុចេញនិងលុប រ ទុកតែស្រៈ ឩ ឧ.

អន្ត (សទ្ទុ.)+ គម + រូ > អន្តគូ = អ្នកដល់នូវទីបំផុត ។

៤. បើមិនលុបទីបំផុតធាតុដូចលេខ ៣ ទេ ត្រូវរស្សៈស្រៈ ឩ > ឧ ដូចជា ភិក្ខ + រូ > ភិក្ខុ = អ្នកសុំជាប្រក្រតី ។ ឬក៏

ភយ (សទ្ទុ.)+ ឥក្ខ (ឃើញ) + រូ > ភិក្ខុ =អ្នកឃើញនូវភ័យ ។ (លុប យ នៃ ភយ ចេញ (ភយ > ភ + ឥក្ខ + រូ) > ភិក្ខុ ។

៥. ស័ព្ទដែលសម្រេចមកពី រូ បច្ច័យជា ឩ ការន្ត បំបែកតាមវិភត្តិនានាបានទាំងបីលិង្គគឺ

៥.១ បើទុកស្រៈ ឩ ឱ្យគង់រូបអាចប្រព្រឹត្តទៅបានតែ ២ លិង្គទេគឺ បុំលិង្គនិងឥត្ថីលិង្គ ។ បើជាបទវិសេសនៈរបស់នាមជាបុំលិង្គត្រូវបំបែកតាម **វេទគូ** គ្រប់ប្រការ បើជាបទវិសេសនៈនៃនាមជាឥត្ថីលិង្គត្រូវបំបែកតាម **វធូ** គ្រប់ប្រការ ។

៥.២ បើរស្សៈស្រៈ ឩ > ឧ អាចប្រព្រឹត្តទៅបាន ៣ លិង្គ ។ បើប្រើជាបទវិសេសនៈនៃនាមបុំលិង្គត្រូវបំបែកតាម **គរុ** ។ បើប្រើជាវិសេសនៈនៃនាមឥត្ថីលិង្គត្រូវបំបែកតាម **យាគុ** និងបើប្រើជាបទវិសេសនៈនៃនាមនបុំសកលិង្គត្រូវបំបែកតាម **វត្ថុ** គ្រប់ប្រការ ។

# វិធីតាំងវិគ្គហៈនៃ រូ បច្ច័យ

*រូ បច្ច័យអាចប្រព្រឹត្តទៅបាន ៣ សាធនៈ ក្នុងទីនេះនឹងនិយាយតែវិធីតាំងវិគ្គហៈជាកត្តុរូប-កត្តុសាធនៈប៉ុណ្ណោះ ។ វិសមាសរូប-តស្សីលសាធនៈនិងកត្តុរូប-តស្សីលសាធនៈមានគតិដូច* **ណី** *គ្រប់ប្រការ ។*

*ដូច្នេះ រូ បច្ច័យមានវិធីប្រែបានតាមរូបវិគ្គហៈដូចតទៅនេះ*

**១. កតញ្ញូ, (យោ) <u>កតំ</u> ជានាតីតិ (សោ) កតញ្ញូ (ជនោ) ។**

*ជនណា <u>ដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ</u> ព្រោះហេតុនោះ ជននោះ ឈ្មោះថា* **កតញ្ញូ** *=អ្នកដឹងនូវឧបការៈដែលជនដទៃធ្វើហើយ ។*

**២. កាលញ្ញូ** *វិ.* **(យោ) កាលំ ជានាតីតិ (សោ) កាលញ្ញូ (ជនោ)** *=អ្នកដឹងនូវកាល ។*

**៣. ចារគូ** *វិ.* **(យោ) ចារំ គច្ឆតីតិ (សោ) ចារគូ (ជនោ)** *= អ្នកដល់នូវត្រើយ ។*

**៤. មត្តញ្ញូ** *វិ.* **(យោ) មត្តំ ជានាតីតិ (សោ) មត្តញ្ញូ (ជនោ)** *= អ្នកដឹងនូវប្រមាណ ។*

**៥. ភិក្ខុ** *វិ.* **(យោ) ភយំ ឥក្ខតីតិ (សោ) ភិក្ខុ (ជនោ)** *=អ្នកឃើញនូវភ័យ ។*

**៦. វេទគូ** *វិ.* **(យោ) វេទំ គច្ឆតីតិ (សោ) វេទគូ (ជនោ)** *=*

*អ្នកដល់នូវវេទ ។*

*ស័ព្ទឯទៀត ៗ ដែលសម្រេចពី រូ បច្ច័យគឺមានវិធីតាំងវិគ្គហៈដូចខាងលើនេះដែរ ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (ត)

១. *ប្រើជាបទវិសេសនៈ*

<u>មត្តញ្ញូ</u> ភិក្ខុ ពុទ្ធេន បសដ្ឋោ ហោតិ ។

*ភិក្ខុ <u>ជាអ្នកដឹងនូវប្រមាណ</u> ជាបុគ្គលដែលព្រះពុទ្ធ សរសើរហើយ ។*

២. *ប្រើជានាមនាម*

<u>ភិក្ខុ</u> គាមំ បិណ្ឌាយ បវិដ្ឋោ ។

*<u>ភិក្ខុ</u>(អ្នកសុំ) ចូលទៅហើយ កាន់ភូមិ ដើម្បីបិណ្ឌបាត្រ ។*

*ពាក្យថា* ភិក្ខុ *និយមប្រែត្រាប់ស័ព្ទថា ភិក្ខុ ។*

*(ចប់ រូ បច្ច័យ)*

## ធាតុគណៈទី ១ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| សំ + វស | នៅរួម | បរិ + ភាស | ប្រទេច, ជេរ |
| អធិ + អា + វស | នៅគ្រប់គ្រង | បរិ + ចរ | បំរើ |
| អធិ + គម | បាន, លុះ | បរិ + វិស | បំរើ, អង្គាស |
| អា + កុស | ជេរ | បត | រលំ, ធ្លាក់, ជ្រុះ |

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ |
|---|---|
| ឆវ បុំ. | សព, ខ្មោច |
| ថុតិ ឥ. | សេចក្ដីសរសើរ |
| ចាណាតិបាតី បុំ. | អ្នកសម្លាប់សត្វ |
| មិច្ឆាចារី បុំ. | អ្នកប្រព្រឹត្តខុស |
| បិសុណាវាច បុំ. | ពាក្យញុះញង់ |
| ផរុសវាច បុំ. | ពាក្យបៀតបៀន |
| អភិជ្ឈាលុ គុ. | លោភ |
| ព្យាបន្នចិត្ត នបុំ. | ចិត្តព្យាបាទ |
| ទុស្សីល គុ. | ទ្រុស្តសីល |

ចាបជម្ម បុំ. ធម៌អាក្រក់
អក្កោសក បុំ. អ្នកជេរ
បរិភាសក បុំ. អ្នកប្រទេច
សមណព្រាហ្មណ បុំ. សមណនិងព្រាហ្មណ៍
ជម្មជរ បុំ. អ្នកទ្រទ្រង់នូវធម៌
សច្ចវាទី បុំ. អ្នកមានវាចាពិត
កន្តុកាម បុំ. អ្នកប្រាថ្នាដើម្បីទៅ
ជម្មស្សវនដ្ឋាន បុំ. ទីជាទីស្តាប់នូវធម៌
រថការក បុំ. ជាងធ្វើរទេះ
មុសាវាទី បុំ. អ្នកពោលពាក្យកុហក
មិច្ឆាទិដ្ឋិក បុំ. អ្នកយល់ឃើញខុស
សម្ផប្បលាបី បុំ. អ្នកពោលពាក្យរោយរាយ
មច្ឆេរមលបរិយុដ្ឋិត បុំ. មន្ទិលគឺសេចក្តីកំណាញ់សង្កត់ហើយ

## លំហាត់នៃមេរៀនទី ៣៣

### *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើវិធីតាំងវិគ្គហៈជាកត្តុរូប-កត្តុសាធនៈត្រូវមានស័ព្ទអ្វីខ្លះ ?*

២. តើបទកិរិយាស័ព្ទនៃវិគ្គហៈជាកត្តុរូប-កត្តុសាធនៈត្រូវជាវាចកៈអ្វី ?
៣. តើ **ឥតិ** ស័ព្ទត្រូវសរសេរយ៉ាងម៉េចខ្លះក្នុងវិគ្គហៈ ?
៤. តើស័ព្ទសាធនៈត្រូវបំបែកក្នុងរូបវិកត្តិអ្វី ?
៥. ចូរតាំងវិគ្គហៈជាកត្តុរូប-កត្តុសាធនៈមួយវិគ្គហៈ ។
៦. តើវិធីតាំងវិគ្គហៈជាកត្តុរូប-តស្សីលសាធនៈត្រូវតែមានស័ព្ទអ្វីខ្លះ ?
៧. ចូរតាំងវិគ្គហៈជាកត្តុរូប-តស្សីលសាធនៈមួយវិគ្គហៈ ។
៨. តើវិធីតាំងវិគ្គហៈជាសមាសរូប-តស្សីលសាធនៈត្រូវមានស័ព្ទអ្វីខ្លះ ?
៩. ចូរតាំងវិគ្គហៈជាសមាសរូប-តស្សីលសាធនៈមួយវិគ្គហៈ ។
១០. តើស័ព្ទសាធនៈដែលសម្រេចពី **ណី** បច្ច័យជាសាធនៈអ្វីខ្លះ ?
១១. តើ **ណ្វុ** បច្ច័យពេលចុះក្នុងទីបំផុតធាតុត្រូវធ្វើដូចម្ដេច ?
១២. តើ **តុ** បច្ច័យពេលចុះក្នុងទីបំផុតធាតុត្រូវធ្វើដូចម្ដេច ?
១៣. តើ **រូ** បច្ច័យពេលចុះក្នុងទីបំផុតធាតុត្រូវធ្វើដូចម្ដេច ?
១៤. ចូរតាំងវិគ្គហៈក្នុងរូបជាកត្តុរូប-តស្សីលសាធនៈ ឬ សមាសរូប-តស្សីលសាធនៈនិងប្រែលោតប្រយោគដោយប្រើ យ-ត ស័ព្ទចំពោះនាមកិតកៈទាំងនេះ **កម្មការី, ជាយក, ជាតុ, ចារកូ** ។

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. សុខស្ស ជាតា មេធាវី សុខំ សោ អធិគច្ឆតិ ។
២. កាចញ្ច ភិក្ខវេ ធរោ ធវាយ សទ្ធឹ សំវសតិ ឥធ ភិក្ខវេ សាមិ-កោ ហោតិ ចាណាតិចាតី អធិន្នាធាយី កាមេសុ មិច្ឆាចារី

មុសាវាទី បិសុណវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិកោ ទុស្សីលោ ចាបធម្មោ មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសកបរិភាសកោ សមណព្រាហ្មណំ, ភរិយាបិស្ស ហោតិ ចាណាតិចាតិនី អទិន្នាទាយិនី កាមេសុ មិច្ឆាចារិនី មុសាវាទិនី បិសុណវាចា ផរុសវាចា សម្ផប្បលាបិនី អភិជ្ឈាលុនី ព្យាបន្នចិត្តា មិច្ឆាទិដ្ឋិកា ទុស្សីលា ចាបធម្មា មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ អក្កោសកបរិភាសកា សមណព្រាហ្មណំ, ឯវំ ខោ ភិក្ខវេ ឆវោ ឆវាយ សទ្ធឹ សំវសតិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. អ្នកស្តាប់ ឯណា មិនធ្វើ នូវអំពើ អាក្រក់ ណាមួយ ដោយចិត្ត ក្តី ដោយវាចា ក្តី ដោយកាយ ក្តី បុគ្គល នោះ ជាអ្នកទ្រទ្រង់នូវធម៌ ជាអ្នកពោលនូវធម៌ ។*

*២. សេចក្តីសរសើរ របស់អ្នក មិនមាន ប្រយោជន៍ ចំពោះខ្ញុំទេ ។*

*៣. អ្នកមានវាចាពិត គប្បីបូជា ជានិច្ច ។*

*៤. អ្នកស្តាប់.ទ. បានចេញហើយ ពីក្រុង ជាអ្នកប្រាថ្នាទៅ កាន់អារាម ដើម្បីស្តាប់នូវធម៌ ។*

*៥. ជាងធ្វើរទេះ ប្រាថ្នា ដើម្បីធ្វើ នូវរទេះ រំលំហើយ នូវដើមឈើ ខ្ពស់ មួយដើម ក្នុងព្រៃ ។*

(ចប់មេរៀនទី ៣៣)

# កំណាព្យដាស់តឿនស្មារតី

អក្សរសាស្ត្រខ្មែរ ខ្មែរត្រូវថែជួន
អោយបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប. ៣.

(ដកស្រង់ពីទស្សនាវដ្ដី "កម្ពុជសុរិយា" លេខ ៣ គ.ស ១៩៩៩ ទំព័រ៤៦)

# មេរៀនទី ៣៨

# អធិប្បាយអំពីនាមកិតក: (ត)

## វិធីតាំងវិគ្គហ:នៃកម្មសាធន:

**កម្មសាធន** *ជាសាធន:មួយប្រភេទទៀតសម្រាប់ហៅស័ព្ទណាសម្រេចមកពីរូបវិគ្គហ: ដែលមានកិរិយាស័ព្ទក្នុងភាគឥតិស័ព្ទជាកត្តុវាចក: ឬក៏កម្មវាចក: មិនថាជាអាខ្យាតកិរិយាឬកិតកិរិយាទេ ។ កម្មសាធន:នេះខុសពីកត្តុសាធន: (ដែលមានរូបវិគ្គហ:ជាកត្តុរូបតែម៉្យាង) ពីព្រោះកម្មសាធន: មានរូបជាកត្តុរូបផងនិងកម្មរូបផង ហើយស័ព្ទនៃសាធន:ពួកនេះក៏មានន័យជាកត្តុវាចក:និងកម្មវាចក:ផងដែរ គឺមានរូបវិគ្គហ: ២ យ៉ាង ។ វិធីប្រែក៏មានពីរបែបដែរគឺ បើសម្រេចរូបជា* **កត្តុរូប-កត្តុសាធន** *ប្រែថា "ជាទី......" និងបើសម្រេចរូបជា* **កម្មរូប-កម្មសាធន** *ប្រែថា "ដែលជនឬគេ...","ជាអ្នកដែលគេ..." ដូចនឹងអធិប្បាយតទៅនេះ*

## វិធីតាំងវិគ្គហ:នៃកត្តុរូប-កម្មសាធន:

*ក. ភាគឥតិស័ព្ទ ត្រូវមាន*

១. **បទកិរិយាស័ព្ទ** *ជាកត្តុវាចក: ជានិច្ច ។*

២. **បទកម្ម** *ត្រូវប្រើ* **ត** *សព្វនាមដោយបំបែកជា* **តំ** *។*

៣. **ឥតិ** *ស័ព្ទសរសេរចូលជាមួយ* **ត** *សព្វនាមទៅជា* **តន្តិ** *។*

*ខ. ភាគសាធនៈ* **ត្រូវមាន**

៤. **សាធនស័ព្ទ** *បំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* *ភាគសាធនៈ*

*១. បទកិរិយាស័ព្ទ ២.* **តំ** *៣.* **ឥតិ** *៤. សាធនស័ព្ទ*

*វិគ្គហៈ*

*១. ឧទាហរណ៍នៃ* **បិយ**

១ ២ ៣ ៤

**បិយេតិ តន្តិ > បិយោ ។**

*បើវិគ្គហៈពេញគឺដូចខាងក្រោមនេះ*

**( បិតា ) បិយេតិ** *ឬ* **បិយតិ តន្តិ ( សោ ) បិយោ ( បុត្តោ ) ។**

*ប្រែលោតប្រយោគថា* (**បិតា** *បិតា*) **បិយេតិ** *ឬ* **បិយតិ** *រមែងស្រឡាញ់* **តំ** (**បុត្តំ** *នូវកូនប្រុស*) *នោះ* **ឥតិ** *ព្រោះហេតុនោះ* (**សោ បុត្តោ** *កូនប្រុស នោះ*) **បិយោ** *ឈ្មោះថា* **បិយោ**, **បិយោ** (**បុត្តោ**) = (*កូនប្រុស*) *ជាទីស្រឡាញ់ ។*

## ២. ឧទាហរណ៍នៃ រស

**រសតិ តន្តិ > រសោ ។**

*បើវិគ្គហៈពេញគឺដូចខាងក្រោមនេះ*

**( ជនោ ) រសតិ តន្តិ ( សោ ) រសោ ( វិសយោ ) ។**

*ប្រែថា* (ជនោ *រីជន*) **រសតិ** *រមែងត្រេកអរ* **តំ** (**វិសយំ** *នូវអារម្មណ៍*) *នោះ* **ឥតិ** *ព្រោះហេតុនោះ* (**សោ វិសយោ** *រីអារម្មណ៍ នោះ*) **រសោ** *ឈ្មោះថា* **រសោ**, **រសោ** (**វិសយោ**) (*រីអារម្មណ៍*) *ជាទីត្រេកអរ ។*

## ៣. ឧទាហរណ៍នៃ និស្សយ

**និស្សយតិ តន្តិ > និស្សយោ ។**

*បើវិគ្គហៈពេញគឺដូចខាងក្រោមនេះ*

**( សិស្សោ ) និស្សយតិ តន្តិ ( សោ ) និស្សយោ ( អាចរិយោ ) ។**

*ប្រែថា* (**សិស្សោ** *រីសិស្ស*) **និស្សយតិ** *រមែងអាស្រ័យ* **តំ** (**អាចរិយំ** *នូវគ្រូ*) *នោះ* **ឥតិ** *ព្រោះហេតុនោះ* (**សោ អាចរិយោ** *រីគ្រូ នោះ*) **និស្សយោ** *ឈ្មោះថា* **និស្សយោ**, **និស្សយោ** (**អាចរិយោ**) =(*រីគ្រូ*) *ជាទីអាស្រ័យ* (*នៃសិស្ស*) *។*

## កំណត់សម្គាល់

*សព្ទសាធនៈណាដែលប្រាប់ឱ្យដឹងអំពីអ្វីមួយដែលត្រូវគេធ្វើ មានអញ្ញបទប្រកបចូលមកជាមួយ* **តំ** *ក្នុងរូបជាទុតិយាវិភត្តិ ដូចជា* **តំ បុត្តំ, តំ វិសយំ, តំ អាចរិយំ** *និងដែលជា***បទកម្ម** *រងអំពើរបស់កិរិយាសព្ទក្នុងវិគ្គហៈដូចជាបទ* **បិយេតិ** *ប្រែថា "ស្រឡាញ់",* **រសតិ** *ប្រែថា "ត្រេកអរ" និង* **និស្សយតិ** *ប្រែថា "អាស្រ័យ" ដូចនៅខាងលើនេះ គឺជា* **កត្តុរូប-កម្មសាធនៈ** *។ ក្នុងសេចក្តីថា មានអ្នកណាមួយស្រឡាញ់ ដូចជា កូនត្រូវមាតាបិតាស្រឡាញ់, មានអ្នកណាមួយបរិភោគនិងត្រេកអរក្នុងរសដូចជារសជាតិនៃអាហារ ឬក៏មានអ្នកណាមួយអាស្រ័យ ដូចជា សិស្សត្រូវអាស្រ័យនឹងគ្រូជាដើម ។ ក្នុងលក្ខណៈនេះហៅថា* **កត្តុរូប** *ពីព្រោះបទកិរិយាក្នុងវិគ្គហៈមានរូបជាកត្តុវាចកៈ។ ប៉ុន្តែដោយសារសព្ទសាធនៈមានអត្ថជា***កម្មទទួលរងនូវអំពើ***ទៅវិញ ទើបហៅថា* **កម្មសាធន** *គឺថាខាងវិគ្គហៈជាកត្តុវាចកៈ ប៉ុន្តែខាងសព្ទសាធនៈជាកម្ម ដូច្នេះត្រូវហៅថា* **កត្តុរូប-កម្មសាធន** *។ វេលាប្រែត្រូវរកអញ្ញបទណាមួយដែលសមនឹងសេចក្តីមកបំពេញផង ។ រីឯកត្តុសាធនៈជាតួកត្តាធ្វើអំពើខ្លួនឯង ។*

## វិធីតាំងវិគ្គហៈនៃកម្មរូប-កម្មសាធនៈ

*ក. ភាគឥតិសព្ទ ត្រូវមាន*

១. **បទអនភិហិតកត្តា** *គឺបទនាមបំបែកជាតតិយាវិភត្តិ ។*

២. **បទកិរិយាស័ព្ទ** *គឺអាខ្យាតឬកិតកិរិយាក្នុងរូបជាកម្មវាចកៈ ។*

៣. **ឥតិ** *ស័ព្ទត្រូវសរសេរចូលជាមួយកិរិយាស័ព្ទ ។*

***ខ. ភាគសាធនៈ ត្រូវមាន***

៤. **សាធនស័ព្ទ** *ត្រូវបំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* *ភាគសាធនៈ*

*១. បទអនភិហិតកត្តា ២. បទកិរិយាស័ព្ទ ៣.* **ឥតិ** *៤. សាធនស័ព្ទ*

*វិគ្គហៈ*

*ឧទាហរណ៍ទី ១*

*១ ២ ៣ ៤*

**(តេន) បិយិយតេតិ > បិយោ ។**

*មានវិគ្គហៈពេញដូចខាងក្រោមនេះ*

**(យោ តេន) បិយិយតេតិ (សោ) បិយោ (បុគ្គលោ) ។**

*ប្រែលោតប្រយោគថា* (**យោ បុគ្គលោ** *រីបុគ្គល ណា* **តេន** *ដែលគេ*) **បិយិយតេ** *រមែងស្រឡាញ់* **ឥតិ** *ព្រោះហេតុនោះ* (**សោ បុគ្គលោ** *រីបុគ្គល នោះ*) **បិយោ** *ឈ្មោះថា* **បិយោ, បិយោ (បុគ្គលោ)** =(*រីបុគ្គល*) *ដែលគេស្រឡាញ់ ។*

ឧទាហរណ៍ទី ២

១ ២ ៣ ៤

**(ជនេន) ជិយ្យតេតិ > ជានំ ។**

*មានវិគ្គហៈពេញដូចខាងក្រោមនេះ*

**(យំ ជនេន) ជិយ្យតេតិ (តំ) ជានំ (វត្ថុ) ។**

*ប្រែលោតប្រយោគ* (**យំ** *វត្ថុ រឺវត្ថុ ណា* **ជនេន** *ដែលជន*) **ជិយ្យតេ** *ឱ្យ* **ឥតិ** *ព្រោះហេតុនោះ* (**តំ** *វត្ថុ រឺវត្ថុ នោះ*) **ជានំ** *ឈ្មោះថា* **ជានំ**, **ជានំ** (*វត្ថុ*) =(*រឺវត្ថុ*) *ដែលជនឱ្យ ។*

*វិគ្គហៈនេះប្រើកិរិយាអាខ្យាតកម្មវាចកៈគឺ* **ជិយ្យតេ** ។

ឧទាហរណ៍ទី ៣

១ ២ ៣ ៤

**(ជនេន) ជាតព្វន្តិ > ជានំ ។**

*មានវិគ្គហៈពេញដូចខាងក្រោមនេះ*

**(យំ ជនេន) ជាតព្វន្តិ (តំ) ជានំ (វត្ថុ) ។**

*ប្រែលោតប្រយោគ* (**យំ** *វត្ថុ រឺវត្ថុ ណា* **ជនេន** *ដែលជន*) **ជាតព្វំ** *គប្បីឱ្យ* **ឥតិ** *ព្រោះហេតុនោះ* (**តំ** *វត្ថុ រឺវត្ថុ នោះ*) **ជានំ** *ឈ្មោះថា* **ជានំ**, **ជានំ** (*វត្ថុ*) =(*រឺវត្ថុ*) *ដែលជនគប្បីឱ្យ ។*

*វិគ្គហៈនេះប្រើកិតកិរិយាគឺ* **ជាតព្វំ** ។

## កំណាត់សម្គាល់

*សាធនៈណាប្រាប់ពីកិច្ចឬអ្វីមួយដែលត្រូវគេធ្វើនិងមានបទអនភិហិតកត្តាជាអ្នកធ្វើនូវអំពើនោះ ៗ ដូចជា* **ធាធ** *ប្រែថា "វត្ថុដែលជនគប្បីឱ្យ" ក្នុងលក្ខណៈនេះហៅថា កម្មរូប-កម្មសាធនៈ ពីព្រោះក្នុងរូបវិគ្គហៈមានបទកិរិយាជាកម្មវាចកៈ ចំណែកខាងសាធនៈទៀតសោតក៏មានអត្ថជាកម្មដោយចំ ៗ តែម្ដង ត្រូវប្រែថា "ដែលជនឬគេ......" ។*

## វិធីចុះ ឧ បច្ច័យ

**ឧ** *បច្ច័យនេះជាកិច្ចបច្ច័យមានរូបវិគ្គហៈជាកម្មរូប-កម្មសាធនៈនិងភាវរូប-ភាវសាធនៈ នឹងមានជាសាធនៈផ្សេងទៀតពុំបានទេ ដែលមានវិធីប្រកបស័ព្ទជាកិតនាមតាមគោលការណ៍ដូចតទៅនេះ*

*១.* **ឧ** *បច្ច័យសម្រាប់ចុះក្នុងទីបំផុតធាតុណា ដែលមានឧបសគ្គឬនិបាតជាសន្ធបបទ ។ បើមិនមានស័ព្ទណាមួយក្នុងបណ្ដាស័ព្ទ ៣ តួគឺ ឧបសគ្គ ២ តួគឺ* **ទុ** *(=អាក្រក់, លំបាក, កម្រ)* **សុ** *(=ល្អ, ងាយ, ស្រួល) និងនិបាត ១ តួគឺ* **ឦសំ** *(=តិចតួច) នៅខាងដើមទេ នោះមិនមែនជាស័ព្ទចុះ* **ឧ** *បច្ច័យឡើយ ។ ពេលចុះជាមួយធាតុណាត្រូវលុប* **ឧ** *បច្ច័យចោលគ្រប់កាលនិងពុំចាំបាច់ផ្លាស់ប្តូរទីបំផុតធាតុទេ ដូចខាងក្រោមនេះ*

| ឧប. | + ធាតុ | + ប. | សម្រេច | ពាក្យប្រែ |
|---|---|---|---|---|
| ទុ | + ជីវ | + ខ | > ទុជ្ជីវ | ការរស់នៅដោយលំបាក |
| ទុ | + ទិស | + ខ | > ទុទ្ទស | ការឃើញបានដោយលំបាក |
| សុ | + ជីវ | + ខ | > សុជីវ | ការរស់នៅដោយស្រួល |
| សុ | + វច | + ខ | > សុវច | ដែលគេស្ដីថាបានដោយងាយ |
| ទុ | + ការ | + ខ | > ទុក្ការ | ដែលគេធ្វើបានដោយកម្រ |
| ទុ | + ទម | + ខ | > ទុទ្ទម | ដែលគេហ្វឹកបានដោយលំបាក |
| ទុ | + រក្ខ | + ខ | > ទុរក្ខ | ដែលគេរក្សាបានដោយលំបាក |
| ទុ | + វច | + ខ | > ទុព្វច | ដែលគេស្ដីថាបានដោយលំបាក |
| ឦសំ | + ការ | + ខ | > ឦសក្ការ | ដែលគេធ្វើតិចតួច |

## កំណត់សម្គាល់

១. សូមសង្កេតមើលស័ព្ទនីមួយ ៗ នៅខាងលើសុទ្ធតែមាន ទុ, សុ, ឦសំ នៅខាងដើមទាំងអស់ ។ ប៉ុន្តែ ទុ និង សុ នេះក៏អាចប្រើជាមួយស័ព្ទដែលមិនមែនជា ខ បច្ច័យបានដែរដូចជា ( សុ + ខម + រ ) > សុខ =សុខ, ងាយ, សប្បាយ ។ ( ទុ + ខម + រ ) > ទុក្ខ =ទុក្ខ, លំបាក ។ ( សុ + គម + តិ ) > សុគតិ =ភូមិជាទីទៅដោយល្អ, ( ទុ + គម + តិ ) > ទុគ្គតិ =ភូមិជាទីទៅដោយលំបាក ជាដើម ។

២. អាស្រ័យហេតុនេះតើធ្វើយ៉ាងណាឱ្យដឹងថាជា ១ បច្ច័យឬមិនមែននោះ ? ចំណុចសំខាន់ដែលត្រូវចាំគឺត្រូវស្គាល់ធាតុនោះ ៗ ឱ្យបានច្បាស់លាស់និងប្រសិនបើជា ១ បច្ច័យមែន ធាតុនោះ ៗ មិនមានលុបទីបំផុតធាតុចេញឬផ្លាស់ប្តូរទីបំផុតធាតុទៅជារូបអ្វីឡើយ ។

៣. ស័ព្ទដែលសម្រេចពី ១ បច្ច័យដូចពោលហើយនេះ អាចប្រើជានាមនាមឬជាគុណនាមក៏បាន ។ ចំពោះស័ព្ទណាដែលសម្រេចមកពីរូបវិគ្គហៈភាវរូប-ភាវសាធនៈ (មានអធិប្បាយនៅខាងមុខ) ស័ព្ទនោះ ៗ ជានាមនាម ប្រែថា "ការ...", "កិរិយា...", "សេចក្តី...", "ដំណើរ...", និងដែលអាចសម្គាល់បានគឺថា ស័ព្ទពួកនេះច្រើនប្រកបរូបជាមួយតែអកម្មធាតុប៉ុណ្ណោះ ។

៤. បើសម្រេចមកពីរូបវិគ្គហៈកម្មរូប-កម្មសាធនៈជាគុណនាម ប្រែថា "ដែល..." ដែលអាចប្រកបរូបពីអកម្មធាតុឬពីសកម្មធាតុក៏បាន ។

៥. បើសម្រេចមកអំពីរូបវិគ្គហៈនៃកត្តុរូប-កម្មសាធនៈ ត្រូវប្រែថា "ជាទី..." ។

៦. បើប្រើជាគុណនាមប្រើអធិប្បាយនាមនាម គឺអាចប្រព្រឹត្តទៅបានទាំង ៣ លិង្គគឺ បើអធិប្បាយបទនាមជាបុំលិង្គត្រូវបំបែកតាមបែប **បុរិស** គ្រប់វិភត្តិ ។ បើអធិប្បាយបទនាមជាឥត្ថីលិង្គត្រូវចុះ **អា** បច្ច័យនិងបំបែកតាមបែប **កញ្ញា** ។ បើអធិប្បាយបទនាមជានបុំសកលិង្គគឺបំបែកដូច **កុល** គ្រប់វិភត្តិ ។

# វិធីតាំងវិគ្គហៈនៃ ខ បច្ច័យ

ការតាំងវិគ្គហៈចំពោះស័ព្ទដែលចុះ ខ បច្ច័យមានកំណត់ថាត្រូវតែមានឧបសគ្គឬនិបាត ៣ ស័ព្ទគឺ ទុ, សុ, ឦសំ ជាសទ្ទុបបទជាដាច់ខាត ។ ប៉ុន្តែដោយសារស័ព្ទទាំងបីនេះមិនអាចបំបែកបាន លោកឱ្យតាំងវិគ្គហៈដូចតទៅនេះ

ក. ទុ ត្រូវប្រើ ទុក្ខ ជំនួសនិងត្រូវបំបែកជាតតិយាវិភត្តិទៅជា ទុក្ខេន ប្រែថា "ដោយលំបាក, ដោយកម្រ" រៀងដាក់ខាងដើមកិរិយាគឺខាងភាគឥតិស័ព្ទ ។

ខ. សុ ត្រូវប្រើ សុខ ជំនួសនិងត្រូវបំបែកជាតតិយាវិភត្តិទៅជា សុខេន ប្រែថា "ដោយងាយ, ដោយស្រួល" រៀងដាក់ខាងដើមកិរិយាគឺខាងភាគឥតិស័ព្ទ ។

គ. ឦសំ ប្រែថា "តិចតួច" ជាកិរិយាវិសេសនៈរៀងដាក់ខាងដើមកិរិយាគឺខាងភាគឥតិស័ព្ទដែរ ដូចមានឧទាហរណ៍ខាងក្រោមនេះ

១. ទុទ្ទស មានវិគ្គហៈថា

**ទុក្ខេន ទិស្សិយតេតិ > ទុទ្ទសំ ។**

មានវិគ្គហៈពេញដូចខាងក្រោមនេះ

**( យំ ជនេន ) ទុក្ខេន ទិស្សិយតេតិ ( តំ ) ទុទ្ទសំ ( ចិត្តំ ) ។**

ប្រែថា (យំ ចិត្តំ វចិត្ត ណា ជនេន ដែលជន) ជិស្សិយតេ រមែង ឃើញ ទុក្ខេន ដោយលំបាក ឥតិ ព្រោះហេតុនោះ (តំ ចិត្តំ វចិត្ត នោះ) ទុទ្ទសំ ឈ្មោះថា ទុទ្ទសំ, ទុទ្ទសំ (ចិត្តំ) (ចិត្ត)ដែលបុគ្គលឃើញបាន ដោយលំបាក ។

២. សុលភ មានវិគ្គហៈថា

**សុខេន លព្ភតេតិ > សុលភា ។**

មានវិគ្គហៈពេញដូចខាងក្រោមនេះ

**( យា ជនេន ) សុខេន លព្ភតេតិ ( សា ) សុលភា ( ភិក្ខា ) ។**

ប្រែថា (យា ភិក្ខា វអាហារ ណា ជនេន ដែលជន) លព្ភតេ រមែងបាន សុខេន ដោយងាយ ឥតិ ព្រោះហេតុនោះ (សា ភិក្ខា វអាហារ នោះ) សុលភា ឈ្មោះថា សុលភា, សុលភា (ភិក្ខា) (អាហារ)ដែលជនបានដោយងាយ ។

៣. ឡសក្ករ មានវិគ្គហៈថា

**ឡសំ ការិយតេតិ > ឡសក្ករំ ។**

មានវិគ្គហៈពេញដូចខាងក្រោមនេះ

**( យំ តេន ) ឡសំ ការិយតេតិ ( តំ ) ឡសក្ករំ ( កម្មំ ) ។**

*ប្រែថា* (**យំ កម្មំ** *រីអំពើ ណា* **ជនេន** *ដែលជន*) **ការិយតេ** *រមែង ធ្វើ* **ឦសំ** *តិចតួច* **ឥតិ** *ព្រោះហេតុនោះ* (**តំ កម្មំ** *រីអំពើ នោះ*) **ឦស-ក្ករំ** *ឈ្មោះថា* **ឦសក្ករំ**, **ឦសក្ករំ** (**កម្មំ**) (*អំពើ*)*ដែលជនធ្វើតិចតួច ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (គ)

១. ពុទ្ធោ ហិ <u>ទុក្ករំ</u> កម្មំ ករោតិ ។

*មែនពិត ព្រះពុទ្ធ ទ្រង់ធ្វើ នូវកម្ម <u>ដែលបុគ្គលធ្វើបានដោយកម្រ</u> ។*

២. រាជោ ជាម ភិក្ខុ <u>សុវចោ</u> អហោសិ ។

*ភិក្ខុ ឈ្មោះ រាធៈ <u>ជាអ្នកដែលជនស្តីថាបានដោយងាយ</u> ។*

*ឧទាហរណ៍ទាំងពីរខាងលើនេះជា កម្មរូប-កម្មសាធនៈ ព្រោះមានរូបវិគ្គហៈជាកម្មវាចកៈទើបស័ព្ទសាធនៈជាគុណនាម ។*

***(ចប់ ខ បច្ច័យ)***

# វិធីតាំងវិគ្គហៈនៃការសាធនៈ

*ការសាធនៈមានរូបវិគ្គហៈតែមួយរូបទេគឺ* **ការរូប** *។ វិធីតាំងវិគ្គហៈនៃសាធនៈនេះមានភាពប្លែកពីសាធនៈដទៃទៀត ពីព្រោះបទនោះ ៗ សម្រេចមកជាការស័ព្ទ ដែលគ្រាន់តែប្រាប់ឱ្យដឹងថាជាសការៈប៉ុណ្ណោះ ដូចមានរបៀបតាំងខាងក្រោមនេះ*

***ក. ភាគឥតិស័ព្ទ ត្រូវមាន***

១. **បទអនភិហិតកត្តា** *មានក៏បាន មិនមានក៏បាន ។*

២. **បទកិរិយាស័ព្ទ** *ត្រូវមានរូបជាការវាចកៈ ។ បើជាអាខ្យាតកិរិយាត្រូវប្រើតែបឋមបុរិសវត្តមានាវិភត្តិខាងអត្តនោបទគឺ* **តេ** *វិភត្តិ ។ បើជាកិតកិរិយាត្រូវប្រើ* **តព្វ** *បច្ច័យបំបែកតាមបែប* **កុល** *នបុំសកលិង្គ ជា* **តព្វំ** *ជានិច្ច ។*

៣. **ឥតិ** *ស័ព្ទមានក៏បាន មិនមានក៏បាន (បើមានត្រូវសរសេរចូលជាមួយស្រៈទីបំផុតនៃបទកិរិយា) ។*

***ខ. ភាគសាធនៈ ត្រូវមាន***

៤. **សាធនស័ព្ទ** *បំបែកជាបឋមាវិភត្តិនបុំសកលិង្គ ។*

*ភាគឥតិស័ព្ទ* *ភាគសាធនៈ*

*(១. បទអនភិហិតកត្តា) ២. បទកិរិយាស័ព្ទ (៣.* **ឥតិ** *) ៤. សាធនស័ព្ទ*

*វិគ្គហៈ*

## ១. រូបវិគ្គហៈដែលប្រើអាខ្យាតកិរិយា

១. គមន *មានវិគ្គហៈថា*

១ ២ ៣ ៤
| | | |
(តេន) គច្ឆយតេតិ គាមនំ ។

*ប្រែថា* (តេន *ដែលគេ*) គច្ឆយតេ *រមែងទៅ* ឥតិ *ព្រោះហេតុនោះ* គមនំ *ឈ្មោះថា* គមនំ, គមនំ *=ការទៅ ។*

២. ចិន្តន *មានវិគ្គហៈថា*

(តេន) ចិន្តយតេតិ ចិន្តនំ ។

*ប្រែថា* (តេន *ដែលគេ*) ចិន្តយតេ *រមែងគិត* ឥតិ *ព្រោះហេតុនោះ* ចិន្តនំ *ឈ្មោះថា* ចិន្តនំ, ចិន្តនំ *=កិរិយាគិត, ចិត្ត ។*

## ២. រូបវិគ្គហៈដែលប្រើកិតកិរិយា

១. គមនំ *មានវិគ្គហៈថា*

(ជនេន) គន្តព្វន្តិ > គមនំ ។

*ប្រែថា* (ជនេន *ដែលជន*) គន្តព្វំ *គប្បីទៅ* ឥតិ *ព្រោះហេតុនោះ* គមនំ *ឈ្មោះថា* គមនំ, គមនំ *=កិរិយាទៅ, ដំណើរទៅ ។*

២. **ហាន** *មានវិគ្គហៈថា*

(**ជនេន**) **ហាតព្វន្តិ** > **ហានំ** =*កិរិយាឈរ ។*

៣. **សយន** *មានវិគ្គហៈថា*

(**ជនេន**) **សយិតព្វន្តិ** > **សយនំ** =*កិរិយាដេក ។*

## ៣. រូបវិគ្គហៈប្រើនាមកិតកៈ

*មានវិធីចងវិគ្គហៈមួយបែបទៀតដែលប្រើនាមកិតកៈនិងពុំចាំបាច់ប្រើបទអនភិហិតកត្តានិងបទកិរិយាស័ព្ទទេ ដូចខាងក្រោមនេះ*

១. **និសជ្ជា** *មានវិគ្គហៈថា*

**និសីទនំ** > **និសជ្ជា** ។

*ប្រែថា* **និសីទនំ** *វីកិរិយាអង្គុយ* **និសជ្ជា** *ឈ្មោះថា* **និសជ្ជា**, **និសជ្ជា** = *កិរិយាអង្គុយ ។*

**ចាក** *មានវិគ្គហៈថា*

**បចនំ** > **ចាកោ** ។

*ប្រែថា* **បចនំ** *វីការចម្អិន* **ចាកោ** *ឈ្មោះថា* **ចាកោ**, **ចាកោ** = *ការចម្អិន ។*

នៅក្នុងកច្ចាយនទូបត្ថម្ភកភាគ ២ ទំព័រ ៥១០ លេខយោងទី ៣ ហាមការចងវិគ្គហៈចំពោះនាមកិតកៈណាដែលមានរូបដូចគ្នា ដូចខាងក្រោមនេះ

**គមនំ > គមនំ ។ ហានំ > ហានំ ។ សយនំ > សយនំ ។**

ប៉ុន្តែក្នុងគម្ពីរដទៃទៀតពុំឃើញហាមការចងបែបនេះទេ ។

## វិធីចុះ ណ្យ បច្ច័យ

**ណ្យ** បច្ច័យអាចមានរូបវិគ្គហៈជាកម្មរូប-កម្មសាធនៈ និងភាវរូប-ភាវសាធនៈដូចគ្នានឹង **ឲ** បច្ច័យដែរ ។ **ណ្យ** ជាបច្ច័យជាប់ដោយតួ **ណ** ដូច្នេះត្រូវលុប **ណ** ចេញឱ្យនៅសល់ត្រឹមតែ **យ** និងដែលមានអំណាចឱ្យទីឃៈដើមធាតុឬផ្លាស់ប្តូរទីបំផុតធាតុទៅជារូបផ្សេង ៗ ដូច **ណឹ** បច្ច័យដែរ ឬថាមានគតិប្រហែល **ណយ** បច្ច័យអាខ្យាតក្នុងធាតុពួកទី ៨ គឺ **ចុរ** ធាតុដែលមានវិធីផ្លាស់ប្តូរទីបំផុតធាតុជាមួយ **យ** បច្ច័យឱ្យទៅជារូបផ្សេង ៗ បាន និងដូចគ្នានឹង **យ** បច្ច័យក្នុងអាខ្យាតធាតុពួកទី ៣ គឺ **ទិវ** ធាតុ (ចូររកមើលក្នុងមេរៀនទី ៣ ភាគ ១) ។

តាមសេចក្តីនេះឃើញថា **ណ្យ** បច្ច័យឬបច្ច័យមានតួ **ណ** មិនថានឹងត្រូវចុះជាមួយធាតុណាមួយទេ គឺមានអំណាចធ្វើធាតុឱ្យប្រែប្រួលបានច្រើនយ៉ាង ។ បើសង្កេតមើលមិនបានច្បាស់លាស់អាចវង្វេងយ៉ាង

ងាយ ប៉ុន្តែមានក្រិត្យដែលលោកចែងទុកឱ្យដូចតទៅនេះ

១. ផ្លាស់ទីបំផុតធាតុជាមួយនឹង យ ទៅជារូបដទៃដូចតទៅនេះ

១.១ បើទីបំផុតធាតុជា ជ ឬ ទ ត្រូវផ្លាស់ទៅជា ជ្ជ (ជ + ណ្យ) ឬ (ទ + ណ្យ) > ជ្ជ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេច | ពាក្យប្រែ |
|---|---|---|---|
| ប + វជ | + ណ្យ | > បព្វជ្ជា | ការបួស (វ > ព) |
| វទ | + ណ្យ | > វជ្ជ | ដែលជនគប្បីពោល (ទោស) |
| មទ | + ណ្យ | > មជ្ជ | ដែលជនគប្បីស្រវឹង, សេចក្តីស្រវឹង |
| វិទ | + ណ្យ | > វិជ្ជា | ដែលជនគប្បីចេះ, ការចេះដឹង |

ប៉ុន្តែធាតុខ្លះមានទីបំផុតជា ជ មែន តែផ្លាស់ជា គ្គ វិញដូចជា

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| យុជ | + ណ្យ | > យោគ្គ | ដែលជនគប្បីប្រកប (ឧ ជា ឱ) |

១.២ បើទីបំផុតធាតុជា ម ត្រូវផ្លាស់ជា ម្ម (ម + ណ្យ) > ម្ម ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| កម | + ណ្យ | > កម្ម | ដែលជនគប្បីដល់, ការទៅ, កិរិយាទៅ |
| ទម | + ណ្យ | > ទម្ម | ដែលជនគប្បីទូន្មាន, ការទូន្មាន |
| រម | + ណ្យ | > រម្ម | ដែលជនគប្បីរីករាយ, សេចក្តីរីករាយ |
| សម | + ណ្យ | > សម្ម | ដែលជនគប្បីរម្ងាប់, សេចក្តីស្ងប់ |

១.៣ បើទីបំផុតធាតុជា ធ ត្រូវផ្លាស់ជា ជ្ឈ (ធ + ណ្យ) > ជ្ឈ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| កុធ | + ណ្យ | > កុជ្ឈ | ដែលជនគប្បីក្រោធ, សេចក្តីក្រោធ |
| ពុធ | + ណ្យ | > ពុជ្ឈ | ដែលជនគប្បីចេះ, ការចេះដឹង |
| វធ | + ណ្យ | > វជ្ឈ | ដែលជនគប្បីសម្លាប់, ការសម្លាប់ |

១.៤ បើទីបំផុតធាតុជា ស, ត្រូវផ្លាស់ ស និង យ ទៅជា ច្ឆ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឥស | + ណ្យ | > ឥច្ឆា | សេចក្តីប្រាថ្នា |

២. បែបទុក យ ឱ្យគង់រូបគឺពុំចាំបាច់ផ្លាស់ប្តូរដូចខាងក្រោមនេះ

២.១ ត្រូវចុះ ឥ អាគមលើចុងធាតុនិងទីឃៈដើមធាតុ ដូចខាងក្រោមនេះ

| ធាតុ | +អា. | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ករ | + ឥ | + ណ្យ | > ការិយ | ដែលជនគប្បីធ្វើ |
| ចរ | + ឥ | + ណ្យ | > ចរិយ | ការប្រព្រឹត្តិ (ពុំចាំបាច់ទីឃៈ) |

២.២ ត្រូវតម្រួត យ ជា យ្យ បែបព្យញ្ជនសំយោគដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| នី > នេ | + ណ្យ | > នេយ្យ | ដែលជនគប្បីនាំទៅ |
| វិ + នី | + ណ្យ | > វេនេយ្យ | ដែលជនគប្បីណែនាំ |

២.៣ បើទីបំផុតធាតុជា ហ, ត្រូវផ្លាស់ (ហ + ណ្យ) ទៅជា យ្ហ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| គរហ | + ណ្យ | > គារយ្ហ | ដែលជនគប្បីទិតៀន |
| និ + គហ | + ណ្យ | > និគ្គយ្ហ | ដែលជនគប្បីជិះជាន់ |
| ប + សហ | + ណ្យ | > បសយ្ហ | ដែលជនគប្បីសង្កត់សង្កិន |
| ប + គហ | + ណ្យ | > បគ្គយ្ហ | ដែលជនគប្បីសរសើរ |

២.៤ ផ្លាស់ ច ទីបំផុតធាតុទៅជា ក ហើយទីឃៈដើមធាតុដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| អតិ + វច | + ណ្យ | > អតិវាក្យ | ដែលជនគប្បីពោលកន្លង |

៣. បំពោះ ភូ ធាតុត្រូវផ្លាស់ ឩ នៃ ភូ ជាមួយ ណ្យ ជា អព្វ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ភូ | + ណ្យ | > ភព្វ | ការមាន, ការកើត |

៤. បើទីបំផុតធាតុជាស្រៈ **អា** អាចផ្លាស់ **ណ្យ** ទៅជា **ឯយ្យ** បានដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឆា | + ណ្យ | > ឆេយ្យ | ដែលជនគប្បីឱ្យ |
| បា | + ណ្យ | > បេយ្យ | ដែលជនគប្បីផឹក |
| វិ + ញា | + ណ្យ | > វិញ្ញេយ្យ | ដែលជនគប្បីដឹងឱ្យច្បាស់ |

❁ **ឯយ្យ** នេះខុសពី **ឯយ្យ** របស់សត្តមីអាខ្យាតវិភត្តិ ព្រោះមានវិធីប្រកបរូបផ្សេងគ្នា ។

## វិធីតាំងវិគ្គហៈនៃ ណ្យ បច្ច័យ

**ណ្យ** បច្ច័យមានរូបវិគ្គហៈជាកម្មរូប-កម្មសាធនៈ និងភាវរូប-ភាវសាធនៈដូច **ឲ** បច្ច័យដែរ ។ វិធីតាំងវិគ្គហៈរបស់កម្មសាធនៈនិងភាវ-សាធនៈត្រូវអនុវត្តតាមដែលពោលរួចហើយខាងលើ ខាងក្រោមនេះជាឧទាហរណ៍ខ្លះទៀត

ក. **គម្ម** ក្នុងរូបវិគ្គហៈ ៣ បែបគឺ

១. កម្មរូប-កម្មសាធនៈក្នុងរូបវិគ្គហៈប្រើកិតកិរិយាថា

**(យោ ជនេន) គមិតព្វោតិ (សោ) គម្មោ (ជម្មោ) ។**

(ធម៌ណា ដែលជន) គប្បីដល់ ព្រោះហេតុនោះ (ធម៌នោះ) ឈ្មោះថា **គម្មោ** =ដែលជនគប្បីដល់ ។

២. ការរូប-ការសាធនៈក្នុងរូបវិគ្គហៈប្រើកិតកិរិយាថា

**(ជនេន) គន្តព្វន្តិ > គម្មំ ។**

(ដែលជន) គប្បីទៅ ព្រោះហេតុនោះ ឈ្មោះថា **គម្មំ** =ការទៅ ។

៣. ការរូប-ការសាធនៈក្នុងរូបវិគ្គហៈប្រើអាខ្យាតកិរិយា

**(ជនេន) គច្ឆយតេតិ > គម្មំ ។**

(ដែលជន) រមែងទៅ ព្រោះហេតុនោះ ឈ្មោះថា **គម្មំ** =ការទៅ ។

ខ. **ខម្ម** ក្នុងរូបវិគ្គហៈប្រើកិតកិរិយាថា

(តាំងវិគ្គហៈឱ្យមើលតែមួយបែបទេ ក្រៅពីនេះសូមមើលក្នុង **គម្ម**)

**(យោ ជនេន) ខមិតព្វោតិ (សោ) ខម្មោ (ជនោ) ។**

(អ្នក ណា ដែលជន) គប្បីទូន្មាន (អ្នក នោះ) ឈ្មោះថា **ខម្មោ** = ដែលជនគប្បីទូន្មាន ។

គ. **ការិយ** មានវិគ្គហៈថា

**(យំ តេន) កាតព្វន្តិ (តំ) ការិយំ (កម្មំ) ។**

(អំពើណា ដែលជន) គប្បីធ្វើ ព្រោះហេតុនោះ (អំពើនោះ) ឈ្មោះថា **ការិយំ** =ដែលជនគប្បីធ្វើ ។

ឃ. **ការយ្ហ** មានវិគ្គហៈថា

**( យំ ជនេន ) ករហិតព្វន្តិ ( តំ ) ការយ្ហំ ( កម្មំ ) ។**

(អំពើ ណា ដែលជន) គប្បីទិតៀន ព្រោះហេតុនោះ (អំពើ នោះ) ឈ្មោះថា **ការយ្ហំ** =ដែលជនគប្បីទិតៀន ។

ង. **វេនេយ្យ** មានវិគ្គហៈថា

**( យោ តេន ) វិនេតព្វោតិ ( សោ ) វេនេយ្យោ ( ជនោ ) ។**

(អ្នកណា ដែលជន) គប្បីណែនាំ ព្រោះហេតុនោះ (អ្នក នោះ) ឈ្មោះថា **វេនេយ្យោ** =ដែលជនគប្បីណែនាំ ។

ច. **ទេយ្យ** មានវិគ្គហៈថា

**( យំ តេន ) ទាតព្វន្តិ ( តំ ) ទេយ្យំ ( វត្ថុ ) ។**

(វត្ថុ ណា ដែលជន) គប្បីឱ្យ ព្រោះហេតុនោះ (វត្ថុ នោះ) ឈ្មោះថា **ទេយ្យំ** =ដែលជនគប្បីឱ្យ ។

## កំណាត់សម្គាល់

ចំពោះស័ព្ទដទៃទៀតដែលសម្រេចពី **ណ្យ** បច្ច័យក៏មានវិធីតាំងវិគ្គហៈនិងប្រែដូចបែបខាងលើនេះដែរ ។

រូបស័ព្ទដែលប្រកបពី **ណ្យ** បច្ច័យ បើជានាមនាមអាចប្រើបាន ២ យ៉ាងគឺ

១. បើសម្រេចពីរូបវិគ្គហៈដែលជាភាវរូប-ភាវសាធនៈ អាចប្រើជានាមនាមបានពីរលិង្គគឺ ឥត្ថីលិង្គនិងនបុំសកលិង្គ ។ បើជាឥត្ថីលិង្គត្រូវចុះ **អា** បច្ច័យខាងចុងស័ព្ទដូចជា **បព្វជ្ជ** > **បព្វជ្ជា** =ការបួស, **វិជ្ជ** > **វិជ្ជា** =ការចេះដឹង, **ឥច្ឆ** > **ឥច្ឆា** =សេចក្តីប្រាថ្នា, មានវិធីបំបែកតាមបែប **កញ្ញា** គ្រប់ប្រការ ។ បើជានបុំសកលិង្គមានវិធីបំបែកតាមបែប **កុល** ដូចជា **គមនំ** =ការទៅ, **ភវនំ** =ការកើត ជាដើម ។

២. បើសម្រេចពីរូបវិគ្គហៈដែលជាកម្មរូប-កម្មសាធនៈ ត្រូវប្រែថា "ដែលជន......" ដែលអាចប្រើជាគុណនាមបានទាំង ៣ លិង្គ ។ បើប្រើអធិប្បាយនាមជាលិង្គអ្វី ត្រូវបំបែកឱ្យស្មើគ្នានឹងនាមជាប្រធានដូចបានអធិប្បាយក្នុង ១ បច្ច័យដូច្នោះដែរ ។

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (ត)

១. សាធុ ខោ <u>បព្វជ្ជា</u> ។

<u>ការបួស</u> ជាការប្រពៃ ណាស់ ។

២. ឧន្តោ សេដ្ឋោ មនុស្សេសុ យោ អតិវាក្យំ តិតិក្ខតិ ។

ប្រែលោតប្រយោគ មនុស្សេសុ បណ្តាមនុស្ស.ទ. យោ (បុគ្គលោ) (វីបុគ្គល) ណា តិតិក្ខតិ រមែងអត់ទ្រាំ អតិវាក្យំ នូវពាក្យដែលជនគប្បីពោលកន្លង (សោ បុគ្គលោ វីបុគ្គល នោះ) ឧន្តោ ជាអ្នកមានឥន្ទ្រីយ៍

*ទូន្មានហើយ* **សេដ្ឋោ** *ជាអ្នកប្រសើរបំផុត ។*

*ក្នុងសេចក្តីថា បណ្តាមនុស្សទាំងឡាយ ជនណាអត់ទ្រាំនូវពាក្យដែលគេពោលលូកលាន់លើសលោះបាន ជននោះទើបជាអ្នកទូន្មានហើយ និងជាអ្នកប្រសើរបំផុត ។*

*ម៉្យាងទៀតស័ព្ទដែលប្រកបពី* **ណ្យ** *បច្ច័យនេះស័ព្ទខ្លះក៏អាចប្រើជាកិរិយាស័ព្ទបានដែរ ឱ.*

៣. តេ ច បុគ្គលា គារយ្ហា ។

*ក៏ បុគ្គល.ទ. នោះ គឺជនគប្បីទិតៀន ។*

(*ចប់ ណ្យ បច្ច័យ*)

## នាមស័ព្ទ (ត)

| | |
|---|---|
| ***ស័ព្ទបាលី*** | *ពាក្យប្រែ* |
| មហាចាល *បុំ.* | *នាយមហាបាល* |
| អរិយសាវកា *បុំ.* | *អរិយសាវ័ក* |
| សេយ្យា *ឥ.* | *ការដេក, ដំណេក* |
| បេតសេយ្យា *ឥ.* | *ដំណេកនៃប្រេត* |

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| សីហសេយ្យា ឥ. | ដំណេកនៃសិង្ហ |
| តថាគតសេយ្យា ឥ. | ដំណេកនៃតថាគត |
| ធម្មស្សវន នបុំ. | ការស្តាប់ធម៌ |
| បុញ្ញក្ខេត្ត នបុំ. | ស្រែបុណ្យ |
| អន្តរសត្ថិ ឥ. | ចន្លោះនៃភ្លៅ |
| នង្គុដ្ឋ នបុំ. | កន្ទុយសត្វ |
| បីតិសុខ នបុំ. | សុខកើតពីបីតិ |
| បរិសបរិយន្ត បុំ. | ជាយនៃបរិស័ទ |
| កាមភោគី បុំ. | អ្នកបរិភោគកាម |
| មនុស្សភាវ បុំ. | ភាពជាមនុស្ស |
| បស្ស បុំ. នបុំ. | ខាង, ម្ខាង |
| ឈាន នបុំ. | ការសម្លឹងនូវអារម្មណ៍, ឈាន |
| ពុទ្ធមាមក បុំ. | អ្នករាប់អាននូវព្រះពុទ្ធ |
| សប្បុរិស បុំ. | សប្បុរស |
| សមន្នាគត គុ. | ដែលប្រកបព្រមហើយ |
| អាហុនេយ្យ គុ. | ដែលគួរសក្ការបូជា |
| បាហុនេយ្យ គុ. | ដែលគួរដល់ការរាប់រក |
| ទក្ខិណេយ្យ គុ. | ដែលគួរនូវទក្ខិណាទាន |

| | | |
|---|---|---|
| វិក្ខិត្ត | គុ. | រាយមាយហើយ |
| វិសដ | គុ. | ដោះជន់ឬផ្សាយហើយ |
| វិវេកជ | គុ. | ដែលកើតហើយព្រោះភាពស្ងាត់ |
| អញ្ជលីករណីយ | គុ. | ដែលគួរនូវអញ្ជលីកម្ម |
| សវិតក្ក | គុ. | មានការត្រិះរិះ |
| សវិចារ | គុ. | មានការពិចារណា |
| អនុត្តរ | គុ. | មិនមានបុគ្គលក្រៃលែងជាង |
| កាមភោគិសេយ្យា | | ដំណេកនៃអ្នកបរិភោគកាម |
| កន្ទមាលាធិហត្ថ | គុ. | មានគ្រឿងសក្ការៈគឺកម្រងផ្កាជាដើមក្នុងដៃ |
| ធម្មញ្ញូ | គុ. | អ្នកដឹងនូវធម៌ |
| អត្ថញ្ញូ | គុ. | អ្នកដឹងនូវប្រយោជន៍ |
| អនត្តមន | គុ. | អ្នកមានចិត្តមិនជារបស់ខ្លួន |
| បុគ្គលបរោបរញ្ញូ | គុ. | អ្នកចេះជ្រើសរើសនូវបុគ្គល |
| អត្តមន | គុ. | មានចិត្តជារបស់ខ្លួន |
| ឧត្តានា | គុ. | ផ្ងារ, រាក់, រីករាយ |
| យេភុយ្យេន | និ. | ដោយច្រើន, ច្រើនតែ |
| អជ្ជេកាធីវសំ | អព្យ. | ចុងផុតនៃថ្ងៃ |
| កាតម | វិ.ស. | ដូចម្ដេច, អ្វីខ្លះ |
| បរិសញ្ញូ | គុ. | អ្នកដឹងនូវការធ្វើខ្លួនជាបរិស័ទ |

## ធាតុស័ព្ទ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|
| អតិ + អា + ជា | គង់លើគ្នា, ត្រួត |
| អនុ + ប + ខិប | ស៊ក, សៀត |
| អនុ + វិ + លោក | ដើរតាមមើល |
| ឧប + សំ + បទ | ចូលទៅដល់ព្រម |
| វិ + វិច | ញែកចេញ, រិះគន់ |
| បដិ + ពុធ | ភ្ញាក់, រលឹក |
| អភិ + ឧ + ទម | ទាញ, ចាប់ទុក |
| កាប្ប | សម្រេច, ចិញ្ចឹម |

## លំហាត់នៃមេរៀនទី ៣៤

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើកម្មសាធនៈមានប៉ុន្មានរូប គឺរូបអ្វីខ្លះ ?

២. តើវិធីតាំងវិគ្គហៈជាកម្មរូប-កត្តុសាធនៈត្រូវតែមានស័ព្ទអ្វីខ្លះ ?

៣. ចូរតាំងវិគ្គហៈពេញមួយក្នុងរូបជាកម្មរូប-កត្តុសាធនៈ និងប្រែលោតប្រយោគ ។

៤. តើវិធីតាំងវិគ្គហៈជាកម្មរូប-កម្មសាធនៈត្រូវតែមានស័ព្ទអ្វីខ្លះ ?

៦. ចូរតាំងវិគ្គហៈពេញមួយក្នុងរូបជាកម្មរូប-កត្តុសាធនៈ និងប្រែលោតប្រយោគ ។

៧. តើ ខ បច្ច័យអាចប្រើបានប៉ុន្មានសាធនៈ ?

៨. តើធាតុដែលអាចចុះ ខ បច្ច័យបាន លុះត្រាតែមានស័ព្ទអ្វីខ្លះនៅខាងដើម ?

៩. វេលាតាំងវិគ្គហៈតើត្រូវធ្វើដូចម្ដេចជាមួយស័ព្ទនៅខាងដើមនោះ ?

១០. តើការសាធនៈមានប៉ុន្មានយ៉ាង ?

១២. ចូរតាំងវិគ្គហៈជាការរូប-ការសាធនៈមួយវិគ្គហៈ ។

១៣. តើ ណ្យ បច្ច័យប្រព្រឹត្តទៅបានប៉ុន្មានសាធនៈ គឺសាធនៈអ្វីខ្លះ ?

**ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ**

១. សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ចាហុនេយ្យោ ទក្ខិនេយ្យោ អញ្ជលីករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ សត្តហិ ឥធ ភិក្ខវេ ភិក្ខុ ធម្មញ្ញូ ច ហោតិ អត្ថញ្ញូ ច អត្តញ្ញូ ច មត្តញ្ញូ ច កាលញ្ញូ ច បរិសញ្ញូ ច បុគ្គលបរោបរញ្ញូ ច ។

២. អថេកាជីវសំ មហាចាលោ អរិយសាវកោ គន្ធមាលាទិហត្ថោ វិហារំ គច្ឆន្តេ ទិស្វា "អយំ មហាជនោ កុហឹ គច្ឆតី"តិ បុច្ឆិត្វា "ធម្មស្សវនាយា"តិ សុត្វា "អហំបិ គមិស្សាមី"តិ គន្ត្វា សត្ថារំ វន្ទិត្វា បរិសបរិយន្តេ និសីទិ ។

៣. ចតស្សោ ឥមា ភិក្ខវេ សេយ្យា កាតមា ចតស្សោ បេត-សេយ្យា កាមភោគិសេយ្យា សីហសេយ្យា តថាគតសេយ្យា ។

៤. កាតមា ច ភិក្ខវេ បេតសេយ្យា យេភុយ្យេន ភិក្ខវេ បេតា ឧត្តានា សេន្តិ ។ អយំ វុច្ចតិ ភិក្ខវេ បេតសេយ្យា ។

៥. កាតមា ច ភិក្ខវេ កាមភោគិសេយ្យា យេភុយ្យេន ភិក្ខវេ កាមភោគី វាមេន បស្សេន សេន្តិ ។ អយំ វុច្ចតិ ភិក្ខវេ កាមភោ-គិសេយ្យា ។

៦. កាតមា ច ភិក្ខវេ សីហសេយ្យា សីហោ ភិក្ខវេ មិគរាជា ទក្ខិណេន បស្សេន សេយ្យំ កប្បេតិ បាទេន បាទំ អច្ចាធាយ អន្តរសត្ថិម្ហិ នង្គុដ្ឋំ អនុបក្ខិបិត្វា សោ បដិពុជ្ឈិត្វា បុរិមំ កាយំ អព្ភុន្នាមេត្វា បច្ឆិមំ កាយំ អនុវិលោកេតិ ។ សចេ ភិក្ខវេ សីហោ មិគរាជា កិញ្ចិ បស្សតិ កាយស្ស វិក្ខិត្តំ វា វិសដំ វា តេន ភិក្ខវេ សីហោ មិគរាជា អនត្តមនោ ហោតិ ។ សចេ បន សីហោ មិគ-រាជា ន កិញ្ចិ បស្សតិ កាយស្ស វិក្ខិត្តំ វា វិសដំ វា តេន ភិក្ខវេ សីហោ មិគរាជា អត្តមនោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សីហ-សេយ្យា ។

៧. កាតមា ច ភិក្ខវេ តថាគតសេយ្យា ឥធ ភិក្ខវេ វិវិច្ចេវ កា-មេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិ-សុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។បេ។ ចតុត្ថំ ឈានំ

ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ តថាគតសេយ្យា ។ ឥមា ខោ ភិក្ខវេ ចតស្សោ សេយ្យា ។

អច្ចាជាយ (អតិ + អា + ជា + ត្វា)

អនុបក្ខិបិត្វា (អនុ + ប + ខិប + ត្វា)

បដិពុជ្ឈិត្វា (បដិ + ពុជ + ត្វា)

អព្ភុដ្ឋាមេត្វា (អភិ + ឧ + ឋម + ត្វា)

អនុវិលោកេតិ (អនុ + វិ + លោក + ណេ + តិ)

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ជនណា ជាអ្នកដឹងនូវប្រមាណ ជននោះ ជាសប្បុរស ។*

*២. កិរិយាដេក បែបប្រេត មិនល្អ កិរិយាដេកដូចតថាគត ជាការដេក ប្រសើរបំផុត ។*

*៣. ជន.ទ. ទាំងពួង គប្បីជាអ្នកប្រដៅងាយ មិនគប្បីជាអ្នកប្រដៅ លំបាក ។*

*៤. ជនណា អាច ដើម្បីរក្សា នូវសីល ៥ ក្នុងព្រះពុទ្ធសាសនា ជននោះ ឈ្មោះថា ជាពុទ្ធមាមក: ។*

(ចប់មេរៀនទី ៣៤)

# មេរៀនទី ៣៨

# អធិប្បាយអំពីនាមកិតក: (ត)

## វិធីតាំងវិគ្គហ:នៃករណសាធន:

*សព្ទដែលសម្រេចមកពីករណសាធន:នេះ បានដល់អ្វីដែលជាឧបករណ៍សម្រាប់ប្រើក្នុងកិច្ចការអ្វីមួយមានដូចជា "ខ្សែ, ដាវ" ជាដើម ទើបហៅថា ករណសាធន: ។ ឈ្មោះនេះគឺហៅតាមឈ្មោះវិភត្តិរបស់* ត *សព្វនាមនៅខាងក្នុងរូបវិគ្គហ: ដែលបំបែកក្នុងរូបជាតតិយាវិភត្តិមានរូបជា* តេន *និងដែលរៀងដាក់នៅខាងចុងកិរិយាសព្ទជានិច្ច ទាំងដែលជាកត្តុរូបនិងកម្មរូបនោះឯង ។*

*សាធន:នេះមាន ២ យ៉ាងគឺ កត្តុរូប-ករណសាធន: និង កម្មរូប-ករណសាធន: ។*

*១. បើជា កត្តុរូប-ករណសាធន: បានដល់សព្ទណាដែលសម្រេចពីរូបវិគ្គហ:ដែលមានបទកិរិយាសព្ទជាកត្តុវាចក: ប្រែថា "ជាគ្រឿង...", "ជាហេតុ..." ។*

*២. បើជា កម្មរូប-ករណសាធន: បានដល់សព្ទណាដែលសម្រេចពីរូបវិគ្គហ:ដែលមានបទកិរិយាសព្ទជាកម្មវាចក: ប្រែថា "ជាគ្រឿងគឺ... ឬ ជាគ្រឿងដែល...", "ជាហេតុគឺ... ឬ ជាហេតុដែល..." ។*

## ១. កត្តុរូប-ករណសាធនៈ

### *ក. ភាគឥតិស័ព្ទ ត្រូវមាន*

*១.* **បទកិរិយាស័ព្ទ** *មានរូបជាកត្តុវាចកៈឬហេតុកត្តុវាចកៈជានិច្ច ។*

*២.* **ត** *សព្វនាមបំបែកជា* **តេន** *ប្រែថា "ដោយ......នោះ"។*

*៣.* **ឥតិ** *សរសេរចូលនឹង* **តេន** *ទៅជា* **តេនាតិ** *ជានិច្ច ។*

### *ខ. ភាគសាធនៈ ត្រូវមាន*

*៤.* **សាធនស័ព្ទ** *បំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* | *ភាគសាធនៈ*

*១. បទកិរិយាស័ព្ទ ២.* **តេន** *៣.* **ឥតិ** | *៤. សាធនស័ព្ទ*

*វិគ្គហៈ*

*វេលាប្រែរូបវិគ្គហៈ ភាគឥតិស័ព្ទត្រូវថែមនាមដែលជាបទប្រធាន របស់កិរិយាស័ព្ទចូលមក ដើម្បីឱ្យត្រូវតាមគោលការណ៍ប្រែប្រយោគ កត្តុវាចកៈជានិច្ច ។ ចំពោះស័ព្ទសាធនៈត្រូវបំបែកជាបឋមាវិភត្តិតាម លិង្គនិងការន្តនោះ ៗ ដូចខាងក្រោមនេះ*

**ពន្ធន** *មានវិគ្គហៈថា*

*១ ២ ៣ ៤*

**(ជនោ) ពន្ធតិ តេនាតិ (តំ) ពន្ធនំ (វត្ថុ) ។**

*ប្រែថា* (ជនោ *រីជន*) **ពន្ធតិ** *រមែងចង* **តេន** **វត្ថុនា** *ដោយវត្ថុនោះ* **ឥតិ** *ព្រោះហេតុនោះ* (**តំ** **វត្ថុ** *រីវត្ថុ នោះ*) **ពន្ធនំ** *ឈ្មោះថា* **ពន្ធនំ**, **ពន្ធនំ** (**វត្ថុ**) = (*វត្ថុ*) *ជាគ្រឿងចង ។ សម្រេចមកពី* ( **ពន្ធ** + **យុ** > **អន** ) *ទៅជា* **ពន្ធន** ។

## ២. កម្មរូប-ករណសាធនៈ

*ក. ភាគឥតិស័ព្ទ ត្រូវមាន*

១. **បទកិរិយាស័ព្ទ** *មានរូបជាកម្មវាចកៈជានិច្ច ។*

២. **ត** *សព្វនាមបំបែកជា* **តេន** ។

៣. **ឥតិ** *សរសេរចូលនឹង* **តេន** *ទៅជា* **តេនាតិ** *ជានិច្ច ។*

***ខ. ភាគសាធនៈ***

៤. **សាធនស័ព្ទ** *បំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* *ភាគសាធនៈ*

*១. បទកិរិយាស័ព្ទ* ២. **តេន** ៣. **ឥតិ** *៤. សាធនស័ព្ទ*

*វិគ្គហៈ*

**ពន្ធន** *មានវិគ្គហៈថា*

( **សត្ថោ** ) **ពជ្ឈិយតិ** **តេនាតិ** ( **តំ** ) **ពន្ធនំ** ( **វត្ថុ** ) ។

*ប្រែថា (**សត្ថោ** រីសត្វ **ជនេន** ដែលជន)* **ពន្ធិយតិ** *តែងចង* **តេន** **វត្ថុនា** *ដោយវត្ថុ នោះ* **ឥតិ** *ព្រោះហេតុនោះ (**តំ វត្ថុ** រីវត្ថុ នោះ) ឈ្មោះថា* **ពន្ធនំ**, **ពន្ធនំ** (**វត្ថុ**) =*(វត្ថុ) ជាគ្រឿងដែលជនចង ។*

*កម្មរូប-ករណសាធនៈនេះមានវិធីតាំងវិគ្គហៈដូចកត្តុរូបដែរ ប្លែកគ្នាតែត្រង់ការប្រកបរូបកិរិយាស័ព្ទជាកម្មវាចកៈដែលត្រូវចុះ* **យ** *បច្ច័យ និងចុះ* **ឥ** *អាគមប៉ុណ្ណោះ ។ ការប្រែលោតប្រយោគ រាល់កម្មរូប-ករណសាធនៈត្រូវយល់និងប្រែតាមប្រយោគកម្មវាចកៈ ។ ស័ព្ទដែលសម្រេចរូបពីបច្ច័យឯទៀត ៗ ក៏មានវិធីតាំងវិគ្គហៈដូចគ្នាដែរ ។*

## វិធីតាំងវិគ្គហៈនៃសម្បទានសាធនៈ

*ការហៅថាសម្បទានសាធនៈនេះ មានដំណើរដូចការហៅករណសាធនៈដែរ ពីព្រោះខាងក្នុងរូបវិគ្គហៈត្រូវមាន* **ត** *ឬ* **ឯត** *សព្វនាមដែលបំបែកជាចតុត្ថីវិភត្តិ ឱ្យមានរូបជា* **អស្ស**, **ឯតស្ស** *ប្រែថា "ដល់..." រៀងខាងក្រោយកិរិយាស័ព្ទ ហើយត្រូវសរសេរ* **អស្ស**, **ឯតស្ស** *ចូលជាមួយ* **ឥតិ** *ស័ព្ទទៅជា* **អស្សាតិ**, **ឯតស្សាតិ** *តែដល់វេលាប្រែត្រូវញែកចេញពីគ្នាវិញ ។ ស័ព្ទនៃសាធនៈនេះច្រើនតែសំដៅដល់ការឱ្យ ។*

*សម្បទានសាធនៈក៏មាន ២ បែបដែរគឺ*

១. **កត្តុរូប-សម្បទានសាធន** បានដល់ស័ព្ទដែលសម្រេចពីរូបវិគ្គហៈណាមានបទកិរិយាស័ព្ទជាកត្តុវាចកៈ ប្រែថា "ជាទី......" ។

២. **កម្មរូប-សម្បទានសាធន** បានដល់ស័ព្ទដែលសម្រេចពីរូបវិគ្គហៈណាមានបទកិរិយាស័ព្ទជាកម្មវាចកៈ ប្រែថា "ជាទីដែល......", "ជាអ្នកគឺ......" ។

## ១. កត្តុរូប-សម្បទានសាធនៈ

*ក. ភាគឥតិស័ព្ទ ត្រូវមាន*

១. **បទកិរិយាស័ព្ទ**មានរូបជាកត្តុវាចកៈឬហេតុកត្តុវាចកៈជានិច្ច ។

២. **ត** ឬ **ឯត** សព្វនាមបំបែកជាចតុត្ថីវិភត្តិមានរូប **អស្ស**, **ឯតស្ស** ។

៣. **ឥតិ** សរសេរចូលនឹង **ត** ឬ **ឯត** ទៅជា **អស្សាតិ**, **ឯតស្សាតិ** ។

*ខ. ភាគសាធនៈ*

៤. **សាធនស័ព្ទ** បំបែកជាបឋមាវិភត្តិ ។

ភាគឥតិស័ព្ទ ភាគសាធនៈ

១. បទកិរិយាស័ព្ទ ២. **អស្ស**, **ឯតស្ស** ៣. **ឥតិ** ៤. សាធនស័ព្ទ

វិគ្គហៈ

សម្បទាន មានវិគ្គហៈថា

(ជនោ) សម្បទេតិ ឯតស្សាតិ (ឯសោ) សម្បទានោ (យា-ចកោ) ។

*ប្រែថា* (ជនោ *រីជន*) សម្បទេតិ *រមែងប្រគល់ឱ្យ* ឯតស្ស (យាចកស្ស *ដល់អ្នកសូម*) *នុ៎ះ* ឥតិ *ព្រោះហេតុនោះ* (ឯសោ យាចកោ *រីអ្នកសូម នុ៎ះ*) សម្បទានោ *ឈ្មោះថា* សម្បទានោ, សម្បទានោ *=ជាទីប្រគល់ឱ្យ ។ មកពី* (សំ + ប + ទា + យុ) ។

## ២. កម្មរូប-សម្បទានសាធនៈ

*ក. ភាគឥតិស័ព្ទ ត្រូវមាន*

១. **បទកិរិយាស័ព្ទ** *មានរូបជាកម្មវាចកៈជានិច្ច ។*

២. ឯត *សព្វនាមបំបែកជាចតុត្ថីវិភត្តិមានរូបជា* ឯតស្ស ។

៣. ឥតិ *សរសេរចូលនឹង* ឯត *ទៅជា* ឯតស្សាតិ *ជានិច្ច ។*

***ខ. ភាគសាធនៈ:***

៤. **សាធនស័ព្ទ** *បំបែកជាបឋមាវិភត្តិ ។*

*ភាគឥតិស័ព្ទ* *ភាគសាធនៈ*

*១. បទកិរិយាស័ព្ទ* *២.* ឯតស្ស *៣.* ឥតិ *៤. សាធនស័ព្ទ*

*វិគ្គហៈ*

**សម្បទាន** *មានវិគ្គហៈថា*

(**វត្ថុ**) **សម្បទីយតេ ឯតស្មាតិ** (**ឯសោ**) **សម្បទានោ** (**យាចកោ**) ។

*ប្រែថា* (**វត្ថុ** *រីវត្ថុ* **ជនេន** *ដែលជន*) **សម្បទីយតេ** *រមែងប្រគល់ឱ្យ* **ឯតស្ស** (**យាចកស្ស** *ដល់អ្នកសូម*) *នុ៎ះ* **ឥតិ** *ព្រោះហេតុនោះ* (**ឯសោ យាចកោ** *រីអ្នកសូម នុ៎ះ*) **សម្បទានោ** *ឈ្មោះថា* **សម្បទានោ**, **សម្បទានោ** *=ជាទីដែលជនប្រគល់ឱ្យ ។*

*កម្មរូប-សម្បទានសាធនៈនេះ មានវិធីតាំងវិគ្គហៈដូចកត្តុរូប-សម្បទានសាធនៈដែរ ប្លែកគ្នាតែត្រង់ការប្រកបរូបកិរិយាស័ព្ទជាកម្មវាចកៈដែលត្រូវចុះ* **យ** *បច្ច័យនិង* **ឥ** *អាគមប៉ុណ្ណោះ ។ ពេលប្រែលោតប្រយោគពាល់កម្មរូប-សម្បទានសាធនៈ គឺត្រូវប្រែតាមប្រយោគកម្មវាចកៈ ។ សាធនស័ព្ទដែលសម្រេចរូបពីបច្ច័យឯទៀត ៗ មានវិធីតាំងវិគ្គហៈដូចគ្នាដែរ ។*

## វិធីតាំងវិគ្គហៈនៃអបាទានសាធនៈ

*ស័ព្ទសាធនៈដែលសម្រេចមកពីរូបវិគ្គហៈនេះ ប្រាប់ឱ្យដឹងនូវអ្វីមួយដែលឃ្លាតចាកទី ដូចជា ការចេញចាកពីព្រៃឬពីផ្ទះ ជាដើមទើបហៅថា អបាទានសាធនៈ មានរូបជាកត្តុរូបតែម៉្យាងប៉ុណ្ណោះ មានពាក្យ*

ប្រែថា "ជាដែន..." ។ ក្នុងរូបវិគ្គហៈត្រូវមាន **ត** ឬ **ឯត** សព្វនាមដែលបំបែកឱ្យមានរូបជាបញ្ចមីវិភត្តិ មានរូបជា **តស្មា** ឬ **ឯតស្មា** រៀងខាងចុងកិរិយាស័ព្ទ ហើយត្រូវសរសេរចូលជាមួយ **ឥតិ** ស័ព្ទទៅជា **តស្មាតិ**, **ឯតស្មាតិ** វេលាប្រែត្រូវញែកចេញពីគ្នា ។

អបាទានសាធនៈមានតែ ១ បែបទេគឺ កត្តុរូប-អបាទានសាធនៈ ។

## កត្តុរូប-អបាទានសាធនៈ

ក. ភាគឥតិស័ព្ទ ត្រូវមាន

១. **បទកិរិយាស័ព្ទ**មានរូបជាកត្តុវាចកៈឬហេតុកត្តុវាចកៈជានិច្ច ។

២. **ត**, **ឯត** សព្វនាមបំបែកជាបញ្ចមីវិភត្តិក្នុងរូបជា **តស្មា**, **ឯតស្មា**។

៣. **ឥតិ** សរសេរចូលនឹង **ត**, **ឯត** ទៅជា **តស្មាតិ**, **ឯតស្មាតិ** ។

ខ. ភាគសាធនៈ

៤. **សាធនស័ព្ទ** បំបែកជាបឋមាវិភត្តិ ។

ភាគឥតិស័ព្ទ ភាគសាធនៈ

១. បទកិរិយាស័ព្ទ ២. **តស្មា**, **ឯតស្មា** ៣. **ឥតិ** ៤. សាធនស័ព្ទ

វិគ្គហៈ

បកស្សរ មានវិគ្គហៈថា

(បកា) សរតិ តស្មាតិ (សោ) បកស្សរោ (ទេវកាយោ) ។

ប្រែថា បកា រីពន្លឺ សរតិ ផ្សាយចេញ តស្មា (ទេវកាយា អំពីកាយរបស់ទេវតា) នោះ ឥតិ ព្រោះហេតុនោះ (សោ ទេវកាយោ កាយរបស់ទេវតា នោះ) បកស្សរោ ឈ្មោះថា បកស្សរោ, បកស្សរោ =ជាដែនផ្សាយចេញនៃពន្លឺ ។

បកស្សរ មកពី (បកា + សរ + អ) (លុបស្រៈ អា នៃ បកា ចេញហើយតម្រួត ស នៃ សរ ធាតុ ។

បករោ មានវិគ្គហៈថា

(ជនី) បឋមំ ករតិ តស្មាតិ (សោ) បករោ (បទេសោ) ។

ប្រែថា (ជនី រីទន្លេ) ករតិ តែងកើត បឋមំ ដំបូង តស្មា (បទេសា ពីប្រទេស) នោះ ឥតិ ព្រោះហេតុនោះ (សោ បទេសោ ប្រទេសនោះ) បករោ ឈ្មោះថា បករោ, បករោ =ជាដែនកើតមុន (ប្រភព) ។

បករ សម្រេចមកពី (ប + ក្ង + អ) ផ្លាស់ ឱ នៃ ក្ង ជា ឱ > អរ ។ ចំពោះ ប ដែលជាឧបសគ្គ វេលាតាំងវិគ្គហត្រូវប្រើ បឋម ប្រែថា "មុន, ដំបូង" ។

# វិធីតាំងវិគ្គហៈនៃអធិករណសាធនៈ

*សព្ទនៃសាធនៈនេះ បានដល់ស្ថានទីដែលមានពាក្យដូចជា* **ឋាន** *=ទីតាំង, ទីឈរ,* **អាសន** *=ទីអង្គុយ,* **សយន** *=ទីដេក ជាដើម ទើបហៅថាអធិករណសាធនៈ ពីព្រោះក្នុងរូបវិគ្គហៈមាន* **យត** *សព្វនាមបំបែកជាសត្តមីវិភត្តិតែនិយមចុះ* **ត្ថ** *អព្យយបច្ច័យ ប្រើជំនួសសត្តមីវិភត្តិប្រែថា "ក្នុង..." ។* **យត + ត្ថ** *បានរូបជា* **យត្ថ** *ប្រែថា "ក្នុងទីនោះ" រៀងចុងកិរិយាស័ព្ទសរសេរចូលជាមួយ* **ឥតិ** *ស័ព្ទទៅជា* **យត្ថាតិ** *។*

*អធិករណសាធនៈមាន ២ បែបគឺ*

*១.* **កត្តុរូប-អធិករណសាធន** *បានដល់ ស័ព្ទសាធនៈដែលសម្រេចពីរូបវិគ្គហៈមានបទកិរិយាស័ព្ទជាកត្តុវាចកៈ ប្រែថា "ជាទី..." ។*

*២.* **កម្មរូប-អធិករណសាធន** *បានដល់ ស័ព្ទសាធនៈដែលសម្រេចពីរូបវិគ្គហៈមានបទកិរិយាស័ព្ទជាកម្មវាចកៈ ប្រែថា "ជាទីគឺ...", "ជាទីដែល..." ។*

## ១. កត្តុរូប-អធិករណសាធនៈ

*ក. ភាគឥតិស័ព្ទត្រូវមាន*

១. បទកិរិយាស័ព្ទ មានរូបជាកត្តុវាចក:ឬហេតុកត្តុវាចក:ជានិច្ច។
២. ឋត (សព្វនាម) + ត្ត បានរូបជា ឋត្ត ។
៣. ឥតិ សរសេរចូលនឹង ឋត្ត ទៅជា ឋត្តាតិ ជានិច្ច ។

ខ. ភាគសាធន:

៤. សាធនស័ព្ទ បំបែកជាបឋមាវិភត្តិ ។

ភាគឥតិស័ព្ទ — ភាគសាធន:

១. បទកិរិយាស័ព្ទ, ២. ឋត្ត ៣. ឥតិ ៤. សាធនស័ព្ទ

វិគ្គហ:

សយន មានវិគ្គហ:ថា

(ជនោ) សយតិ ឋត្តាតិ (ឋតំ) សយនំ (ឋានំ) ។

ប្រែថា (ជនោ រីជន) សយតិ រមែងដេក ឋត្ត (ឋានេ ក្នុងទី) នុ៎ះ ឥតិ ព្រោះហេតុនោះ (ឋតំ ឋានំ ទី នុ៎ះ) សយនំ ឈ្មោះថា សយនំ, សយនំ = (ទី)ជាទីដេក ។ (សី + យុ > សយន ) ។

## ២. កម្មរូប-អធិករណសាធន:

ក. ភាគឥតិស័ព្ទត្រូវមាន

១. **បទកិរិយាស័ព្ទ** មានរូបជាកម្មវាចកៈជានិច្ច ។

២. **ឯត** (សព្វនាម) + **ត្ថ** បានរូបជា **ឯត្ថ** ។

៣. **ឥតិ** សរសេរចូលនឹង **ឯត** ទៅជា **ឯត្ថាតិ** ជានិច្ច ។

ខ. ភាគសាធនៈ

៤. **សាធនស័ព្ទ** បំបែកជាបឋមាវិភត្តិ ។

ភាគឥតិស័ព្ទ ភាគសាធនៈ

១. បទកិរិយាស័ព្ទ, ២. ឯត្ថ ៣. ឥតិ ៤. សាធនស័ព្ទ

វិគ្គហៈ

**គមន** មានវិគ្គហៈថា

**(គាមោ តេន) គច្ឆិយតេ ឯត្ថាតិ (ឯតំ) គមនំ (ឋានំ) ។**

ប្រែថា (**គាមោ** វីស្រុក **តេន** ដែលគេ) **គច្ឆីយតេ** តែងទៅ **ឯត្ថ** (**ឋានេ** ក្នុងទី) នុ៎ះ **ឥតិ** ព្រោះហេតុនោះ (**ឯតំ ឋានំ** ទី នុ៎ះ) **គមនំ** ឈ្មោះថា **គមនំ**, **គមនំ** =(ទី)ជាទីទៅ ។

**គមន** សម្រេចមកពី (**គម**+ **យុ**) > **គមន** ។

❁ ភាពខុសគ្នារវាងកម្មរូបនិងកត្តុរូបគឺត្រង់កិរិយាស័ព្ទប៉ុណ្ណោះ ។ បើជាកម្មរូបបទកិរិយាស័ព្ទក្នុងវិគ្គហៈជាកម្មវាចកៈ ។

# វិធីចុះកិតកិច្ចបច្ច័យ

*សព្ទនានាដែលសម្រេចចេញមកពីពួកកិតកិច្ចបច្ច័យតួណាមួយក៏ដោយ គឺមានរូបវិគ្គហៈតែមួយបែបគ្រប់រូបនិងគ្រប់សាធនៈ ។ ពួកកិតកិច្ចបច្ច័យមានរូបវិគ្គហៈគ្រប់រូបគ្រប់សាធនៈគឺ កត្តុរូប-កត្តុសាធនៈ, កត្តុរូប-កម្មសាធនៈ, កត្តុរូប-ករណសាធនៈ, កត្តុរូប-សម្បទានសាធនៈ, កត្តុរូប-អបាទានសាធនៈ, កត្តុរូប-អធិករណសាធនៈ, កត្តុរូប-តស្សីលសាធនៈ, សមាសរូប-តស្សីលសាធនៈ, កម្មរូប-កម្មសាធនៈ, កម្មរូប-ករណសាធនៈ, កម្មរូប-សម្បទានសាធនៈ, កម្មរូប-អធិករណសាធនៈ, និង ភាវរូប-ភាវសាធនៈ ។*

*សព្ទសាធនៈដែលសម្រេចមកពីពួកកិតកិច្ចបច្ច័យ ៧ តួគឺ* **អ**, **ឥ**, **ណ**, **តវេ**, **តិ**, **តុំ**, **យុ** *(វៀរតែ* **តវេ**, **តុំ***) ប្រើជានាមនាមក៏បាន ជាគុណនាមក៏បាន មានពាក្យប្រែបានច្រើនយ៉ាង ស្រេចតែសេចក្តីក្នុងទីនោះ ៗ ថាតើបានដល់សាធនៈណា ដែលបច្ច័យនីមួយ ៗ មានវិធីប្រកបរូបសព្ទជានាមកិតកៈដូចតទៅនេះ*

# វិធីចុះ អ បច្ច័យ

*អ បច្ច័យវេលាចុះខាងចុងធាតុណាមួយហើយតួអក្សរ អ នេះនឹង*

បាត់រូបទៅ សល់នៅតែសំឡេងស្រៈ អៈ, អិៈ ប៉ុណ្ណោះ និងសម្រេចបានជានាមនាមដែលប្រែថា "ការ......" ឬ "សេចក្ដី......" ។ បើជាគុណនាមប្រែបានច្រើនយ៉ាងដោយយោងតាមរូបវិគ្គហៈនោះ ៗ និងស្រេចតែសេចក្ដីនៃសាធនៈនីមួយ ៗ ។ បច្ចយ័នេះមានចំណុចដែលអាចឱ្យស្គាល់ថាស័ព្ទនោះ ៗ សម្រេចមកពី អ បច្ច័យនេះបានក្នុងលក្ខណៈ ៤ យ៉ាងគឺ

១ បើប្រកបរូបអំពីសកម្មធាតុដែលហៅរកកម្ម ត្រូវមានសទ្ទុបបទជាតួកម្មនៅខាងដើម និងត្រូវចុះ **មុ** អាគមក្នុងទីបំផុតនៃសទ្ទុបបទនោះសិន រួចផ្លាស់ **មុ** ជានិគ្គហិត (ឬនឹងពោលឱ្យចំគឺត្រូវចុះនិគ្គហិតអាគម) ហើយផ្លាស់និគ្គហិតនោះជាព្យញ្ជនៈចុងវគ្គគឺតួទី ៥ នៃព្យញ្ជនៈដើមធាតុជានិច្ច ដូចជា ករ ធាតុគឺ ករវគ្គ ដូច្នេះត្រូវផ្លាស់និគ្គហិតជា **ង៍** ជាដើមដូចខាងក្រោមនេះ

| សទ្ទុបបទ | +ធាតុ | +បច្ច | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ទីប > ទីបំ | + ករ | + អ | > ទីបង្ករ | អ្នកធ្វើនូវទីពឹង |
| ខេម > ខេមំ | + ករ | + អ | > ខេមង្ករ | អ្នកធ្វើនូវសេចក្ដីក្សេម |
| ឋាន > ឋានំ | + ករ | + អ | > ឋានង្ករ | អ្នកធ្វើនូវទីឈរ |
| វេស្ស > វេស្សំ | + តរ | + អ | > វេស្សន្តរ | អ្នកឆ្លងនូវផ្លូវ |
| អរិ > អរឹ | + ទម | + អ | > អរិន្ទម | ទ្រង់ទូន្មាននូវសត្រូវ |

២. ទោះបីជាមានសទ្ទុបបទក្ដី សទ្ទុបបទនោះ ៗ (ខ្លះជាឧបសគ្គ

ស័ព្ទ) មិនរាប់ថាជាបទកម្មទេ ឬក៏គ្មានសទ្ទុបបទក្តី មិនត្រូវចុះនិគ្គហិតឡើយ គឺប្រកបរូបតាមធម្មតា ៗ ដូចខាងក្រោមនេះ

| សទ្ទុបបទ | +ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| | នី | + អ | > នយ | ការនាំទៅ |
| | ជិ | + អ | > ជយ | ការឈ្នះ |
| វន | + ចរ | + អ | > វនច | អ្នកត្រាច់ទៅក្នុងព្រៃ |
| អន្តលិក្ខ | + ចរ | + អ | > អន្តលិក្ខចរ | អ្នកហោះក្នុងអាកាស |
| សំ + និ | + ចិ | + អ | > សន្និចយ | ការសន្សំ |
| បដិ + សំ | + ភិទ | + អ | > បដិសម្ភិទារ | បញ្ញាជាគ្រឿងបែក-ព្រមចំពោះ |

៣. មានសទ្ទុបបទជាបទកម្មមែន ប៉ុន្តែមិនចុះនិគ្គហិតអាគមទេ តែត្រូវតម្រួតព្យញ្ជនៈដើមជាតុតាមវិធីព្យញ្ជនៈសំយោគវិញ ដូចជា ការ ទៅជា ក្ការ ជាដើម ដូចខាងក្រោមនេះ

| សទ្ទុបបទ | +ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ហិត | + ការ | + អ | > ហិតក្ការ | អ្នកធ្វើនូវប្រយោជន៍ |
| ត | + ការ | + អ | > តក្ការ | អ្នកធ្វើនូវកិច្ចនោះ |

៤. ចំពោះ ធា ធាតុដែលអក្ខាសជា ធធា មាន បុរ (=កាលមុន) ជាសទ្ទុបបទត្រូវផ្លាស់ស្រៈអៈនៃ រ របស់ បុរ ជា តំ ហើយផ្លាស់និគ្គហិត

របស់ ត៌ ជា ឌ តាមរបៀបលេខ ១ ដូចខាងក្រោមនេះ

| សទ្ទុបបទ | +ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| បុរ > បុរឹ | + ធា | + អ | > បុរិន្ទទ | អ្នកឱ្យទានក្នុងកាលមុន (ព្រះឥន្ទ) ។ |

## កំណាត់សម្គាល់

សព្ទដែលប្រកបពី អ បច្ច័យដូចពោលហើយនេះ អាចប្រើជានាមនាមខ្លះ ជាគុណនាមខ្លះ ។ បើជានាមត្រូវបំបែកតាមការន្តនិងលិង្គនោះ ៗ ដូចជា **សន្និចយោ** =ការសន្សំ, បំបែកតាម **បុរិស** បុំលិង្គជាដើម ។ បើជាគុណនាមប្រើជាគុណបទរបស់នាមបានទាំងបីលិង្គ ។ ចំណែកឯវិគ្គហៈមានវិធីតាំងបានគ្រប់រូបគ្រប់សាធនៈដូចតទៅនេះ

## វិធីតាំងវិគ្គហៈនៃ អ បច្ច័យ

**១. ទីបង្ករ** មានវិគ្គហៈថា

**( យោ ) ទីបំ ករោតីតិ ( សោ ) ទីបង្ករោ ( ជនោ ) ។**

ប្រែថា (ជនណា) រមែងធ្វើ នូវទីពឹង ព្រោះហេតុនោះ ជននោះឈ្មោះថា **ទីបង្ករោ, ទីបង្ករោ** =អ្នកធ្វើនូវទីពឹង (កត្តុរូប-កត្តុសាធន = កត្តុ.កត្តុ.) ។

២. វេស្សន្តរ *វិ.* វេស្សំ តរតីតិ វេស្សន្តរោ (ជនោ) ។

៣. ហិតក្ករ *វិ.* ហិតំ ករោតីតិ ហិតក្ករោ (ជនោ) ។

៤. តក្ករ *វិ.* តំ ករោតីតិ តក្ករោ (ជនោ) ។

៥. អន្តលិក្ខចរ *វិ.* អន្តលិក្ខេ ចរតីតិ អន្តលិក្ខចរោ (សកុណោ)

៦. នយ *វិ.* នយនំ នយោ =*ការនាំទៅ (ន័យ) (ភាវ.ភាវ.)* ។

៧. ជយ *វិ.* ជយនំ ជយោ =*កាឈ្នះ (ជ័យ) (ភាវ.ភាវ.)* ។

៨. សិក្ខ *វិ.* សិក្ខនំ សិក្ខា =*ការសិក្សា (សិក្ខា) (ភាវ.ភាវ.)* ។

*បើជាកម្មរូបមានវិគ្គហៈថា* សិក្ខិយតេតិ សិក្ខា (ធម្មជាតិ) ។

៩. វិនយ *វិ.* (បណ្ឌិតោ) វិនេតិ (សោ) វិនយោ (ឧចាយោ)

*(កត្តុ.ករ.)* ។

១០. បដិសម្ភិទា *វិ.* បដិ សំ ភិជ្ជតីតិ បដិសម្ភិទា (បញ្ញា) ។

១១. សន្និចយ *វិ.* សន្និចយំ សន្និចយោ =*ការសន្សំ (សន្និច័យ)* ។

១២. បុរិន្ទទ *វិ.* បុរេ (ទានំ) ទទាតីតិ បុរិន្ទទោ (សក្កោ)។

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (គ)

១. យោ ចាបកំ កម្មំ អកាសិ សោ អន្តលិក្ខចរោបិ សមានោ ចាបកម្មា ន មុច្ចេយ្យ ។

អ្នកណា បានធ្វើហើយ នូវកម្ម អាក្រក់, ជននោះ សូម្បីជាអ្នកត្រាច់ទៅក្នុងអាកាស មិនគប្បីរួច ពីកម្មទាំងឡាយ អាក្រក់ឡើយ ។

**២. សន្និចយោ មេ នត្ថិ ។**

ការសន្សំ តែងមិនមាន សំរាប់ខ្ញុំ ។

**(ចប់ អ បច្ច័យ)**

# វិធីចុះ ឥ បច្ច័យ

ឥ បច្ច័យអាចចុះបានគ្រប់រូបគ្រប់សាធនៈ មានកំណត់សម្គាល់ថា បើចុះក្នុងធាតុណាត្រូវប្រើរូប (ិ) នេះវិញ និងសម្រេចរូបបានជានាម-នាមក៏មាន ជាគុណនាមក៏មាន ។ ឥ បច្ច័យមិនមានអំណាចឱ្យផ្លាស់ប្ដូរធាតុទៅជារូបផ្សេង ៗ បានទេ និងត្រូវទុកស្រៈ ឥ ឱ្យគង់រូបដើម ដូចខាងក្រោមនេះ

| ធាតុស័ព្ទ | +បច្ច. | សម្រេច | ពាក្យប្រែ |
|---|---|---|---|
| ឆជ្ជ | + ឥ | > ឆជ្ជិ | សេចក្ដីត្រេកអរឬភ្ញើតភ្ញើន |
| និ + ធា | + ឥ | > និធិ | សម្បត្តិដែលកប់ទុក,កំណប់ទ្រព្យ |
| មុន | + ឥ | > មុនិ | អ្នកដឹង, មុនី |

| | | | | |
|---|---|---|---|---|
| សំ + ធា | + ឥ | > សន្ធិ | ទីដែលគេត, ការត |
| សំ+អា+ធា | + ឥ | > សមាធិ | ការតាំងចិត្ត, សមាធិ |
| រុច | + ឥ | > រុចិ | ភាពរុងរឿង, សេចក្ដីគាប់ចិត្ត |
| ឧទ | + ឥ | > ឧទធិ | ការទ្រទ្រង់នូវទឹក, សមុទ្រ |

(ចំពោះ ធា ធាតុកាលបើផ្សំជាមួយ ឥ បច្ច័យត្រូវលុបស្រៈ អា ចេញ)

## វិធីតាំងវិគ្គហៈនៃ ឥ បច្ច័យ

១. នន្ទិ *មានវិគ្គហៈថា* នន្ទនំ នន្ទិ =*សេចក្ដីត្រេកអរ ។*

២. មុនិ *វិ.* (យោ) មុនាតីតិ (សោ) មុនិ (ជនោ) =*អ្នកដឹង ។*

៣. សន្ធិ *វិ.* (យា) សន្ធិយតីតិ (សា) សន្ធិ (វាចា) =*ដែលជនត ។*

៤. និធិ *វិ.* (យា) និធិយតីតិ (សា) និធិ (សម្បត្តិ) =*ដែលជនកប់ ។*

៥. រុចិ *វិ.* (យោ) រោចតីតិ (សោ) រុចិ (ជនោ) =*អ្នករុងរឿង ។*

*ឬថា* រុចនំ រុចិ =*ការគាប់ចិត្ត (ភាវ.ភាវ.) ។*

៦. ឧទធិ *វិ.* (យោ) ឧទកំ ទធាតីតិ (សោ) ឧទធិ (បទេសោ) =

*អ្នកទ្រទ្រង់នូវទឹក (សមុទ្រ) ។*

## កំណត់សម្គាល់

*សព្ទដែលប្រកបជាមួយ ឥ បច្ច័យដូចពោលមកនេះមានទីបំផុតជា ឥ ការន្ត អាចប្រព្រឹត្តទៅបានទាំងបីលិង្គ ។ បើជាបុំលិង្គត្រូវបំបែកតាមបែប* **មុនិ**, *ឥត្ថីលិង្គបំបែកតាមបែប* **ភូមិ**, *នបុំសកលិង្គបំបែកតាមបែប* **អក្ខិ** *គ្រប់វិភត្តិទាំងអស់ ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (ត)

**អហំ ឧដ្ឋិយា ធម្មំ សុណាមិ ។**

*ខ្ញុំ កំពុងស្ដាប់ នូវធម៌ ដោយសេចក្ដីត្រេកអរ ។*

*សព្ទឯទៀត ៗ គប្បីយល់តាមសេចក្ដីនេះផងចុះ ។*

**(ចប់ ឥ បច្ច័យ)**

## នាមសព្ទ (ត)

| *សព្ទបាលី* | *ពាក្យប្រែ* |
|---|---|
| **អជេយ្យ** *គុ.* | *មិនអាចឈ្នះ* |
| **អនុគាមិក** *គុ.* | *អ្នកទៅតាម* |
| **ឥត្ថន្នាម** *គុ.* | *មានឈ្មោះយ៉ាងនេះ* |

**កាសីតាមក** បុំ. *អ្នកស្រុកកាសី*

**កុម្ភការកុល** នបុំ. *ត្រកូលស្មូនឆ្នាំង*

**កុម្ភការកម្ម** នបុំ. *កិច្ចការស្មូនឆ្នាំង*

**បុត្តទារ** បុំ. *បុត្រនិងភរិយា*

**មាលាការ** បុំ. *អ្នកធ្វើទ្រូវកម្រងផ្កា*

**សុវណ្ណការ** បុំ. *ជាងមាស*

**ភណ្ឌាគារិក** បុំ *អ្នករក្សាឃ្លាំង*

**បលុទ្ធការ** បុំ. *ការជាប់នៅហើយ*

**អនុក្កម** បុំ. *លំដាប់, អនុក្រម*

**មរណភយ** នបុំ. *ភ័យដល់ការស្លាប់*

**ទិនករ** បុំ. *ព្រះអាទិត្យ*

**និសាករ** បុំ. *ព្រះច័ន្ទ*

**ចាលក** បុំ. *អ្នករក្សា*

**ទាយក** បុំ. *អ្នកឱ្យ*

**យាចក** បុំ. *អ្នកសុំ, ស្នូម*

**សមណ** បុំ. *អ្នកស្ងប់*

**ផាណិតខណ្ឌ** បុំ. *ដុំស្ករអំពៅ*

**ឧទុក្ខល** បុំ. *វែក*

**ឆាជ** បុំ. *អ្នកគ្រប់គ្រង*

| | | |
|---|---|---|
| កិលញ្ជ | បុំ. | កន្ទេល |
| ឧយ្យានចាល | បុំ. | អ្នករក្សាសួន |
| មជ្ឈមក្ខិតតិណា | បុំ. | ឃ្មុំនិងរុយនិងស្មៅ |
| អន្តោនិវេសនដ្ឋណា | បុំ. | ខាងក្នុងនៃនិវេសន៍ |
| អត្ថង្គច្ឆន្ត | កិត. | កាលលិច, អស្តង្គត |
| ឧជ្ឈេន្ត | កិត. | កាលរះ |
| សិប្បី | បុំ. | សិប្បករ |
| ថោកាំ | គុ. | តិចតួច, បន្តិចបន្តួច |
| ពាឡ្ហតិលាន | គុ. | ឈើធូន់, ឈើខ្លាំង |
| ចាជីយ | | ទឹកផឹក |

## ធាតុស័ព្ទ (ត)

| ធាតុ | ពាក្យប្រែ | ធាតុ | ពាក្យប្រែ |
|---|---|---|---|
| កម្ប | ញ័រ, កក្រើក | អា + ធាវ | រត់ទៅមក |
| ប + សំស | សរសើរ | បរិ + ធាវ | រត់ជុំវិញ |
| សុ+និ+ធា | កប់ទុក | និ + វត្ត | បង្កើត, ប្រព្រឹត្ត |
| អភិ + ថុ | ស្ងើចសរសើរ | អបិ + (ធា > ធហ) | បិទ, ឃ្លុំ |
| សំ + មជ្ជ | បោស | | |

# លំហាត់នៃមេរៀនទី ៣៥

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើករណសាធនៈមានប៉ុន្មានរូប គឺរូបអ្វីខ្លះ ?

២. តើវិធីតាំងវិគ្គហៈជាកត្តុរូប-ករណសាធនៈត្រូវតែមានស័ព្ទអ្វីខ្លះ ?

៣. ចូរតាំងវិគ្គហៈពេញជាកត្តុរូប-ករណសាធនៈនិងប្រែលោត ប្រយោគ ។

៤. តើវិធីតាំងវិគ្គហៈជាកម្មរូប-ករណសាធនៈត្រូវតែមានស័ព្ទអ្វីខ្លះ ?

៥. ចូរតាំងវិគ្គហៈពេញជាកម្មរូប-ករណសាធនៈនិងប្រែលោត ប្រយោគ ។

៦. តើសម្បទានសាធនៈមានប៉ុន្មានរូប គឺរូបអ្វីខ្លះ ?

៧. ចូរតាំងវិគ្គហៈពេញជាកត្តុរូប-សម្បទានសាធនៈនិងប្រែលោត ប្រយោគ ។

៨. ចូរតាំងវិគ្គហៈពេញជាកម្មរូប-សម្បទានសាធនៈនិងប្រែលោត ប្រយោគ ។

៩. តើអបាទានសាធនៈមានប៉ុន្មានរូប គឺរូបអ្វីខ្លះ ?

១០. ចូរតាំងវិគ្គហៈពេញជាកត្តុរូប-អបាទានសាធនៈនិងប្រែលោត ប្រយោគ ។

១១. តើអធិករណសាធនៈមានប៉ុន្មានរូប គឺរូបអ្វីខ្លះ ?

១២. *ចូរតាំងវិគ្គហៈពេញជាកត្តុរូប-អធិករណសាធនៈ និងប្រែលោតប្រយោគ ។*

១៣. *ចូរតាំងវិគ្គហៈពេញជាកម្មរូប-អធិករណសាធនៈ និងប្រែលោតប្រយោគ ។*

១៤. *តើ អ បច្ច័យអាចចុះក្នុងធាតុដោយវិធីប៉ុន្មានយ៉ាង ? សូមឱ្យឧទាហរណ៍ក្នុងវិធីនីមួយ ៗ ។*

### *ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ ។

២. ឥត្ថន្នាមា ភន្តេ ភិក្ខុនី អាពាធិនី ទុក្ខិតា ពាឡ្ហគិលានា អាយស្មតោ អានន្ទស្ស បាទេសុ សិរសា វន្ទតិ ។

៣. អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ ពោធិសត្តោ កាសិគាមកេ កុម្ភការកុលេ និព្វត្តិត្វា កុម្ភការកម្មំ កត្វា បុត្តទារំ បោសេតិ ។

៤. សោ អរញ្ញតា អាគច្ឆន្តេ មាលាការេ ទិស្វា ថោកំ ថោកំ ផាណិតខណ្ឌំ ទត្វា ឧឡុង្កេន បានីយំ អទាសិ ។

៥. ឧយ្យានបាលោ តស្ស មធុមក្ខិតតិណេសុ បលុទ្ធភាវំ ញត្វា អនុក្កមេន អត្តានំ ទស្សេសិ ។

៦. មិគេ អន្តោ បវិដ្ឋេ ទ្វារំ បិទហឹសុ មិគោ មនុស្សេ ទិស្វា កម្បមានោ មរណភយភីតោ អន្តោនិវេសនង្គណេ អាធាវតិ

បរិចារតិ ។

៧. ជិនកាយេ អត្តជ្ឈត្តេ និសាកាយេ ច ឧទេន្តេ រដ្ឋស្ស ចាលកោ ពុទ្ធស្ស សាវកោ មហាភជោ យាចកានំ មហាទានំ អទាសិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. អ្នកឱ្យ ឱ្យហើយ នូវអាហារ ផង សំពត់ ផង វត្ថុ ដទៃ ផង ដល់ស្មូម.ទ. គឺមនុស្ស.ទ. រស់នៅ ក្នុងស្រុក នោះ សរសើរហើយ ។*

*២. សត្វ.ទ. ទាំងពួង រស់នៅ ក្នុងទឹក ក្តី លើដី ក្តី មិនអាច ដើម្បីរស់ ដោយគ្មាន អាហារទេ ។*

*៣. ម្សិលមិញ កាលអ្នកស្ងប់.ទ. ចូលហើយ កាន់ភូមិ ឃើញហើយ គឺ មិនបានបោស នូវសាលា គឺមិនបានក្រាល នូវកន្ទេល.ទ. មិនបាន ដាក់ នូវទឹកផឹក.ទ. ទេ ។*

*៤. នាកាល នាងវិសាខា បានឮហើយ នូវពាក្យ ថា "អរហន្ត" ស្ញើច សរសើរ...... ប៉ុន្តែ នាកាល នាង មកហើយ កាន់ទី, គេ.ទ. កំពុង បរិភោគ នូវអាហារ និង បានឃើញ នូវគេ.ទ. នោះ នាង ក្រោធខឹង នឹងអ្នករក្សានូវឃ្លាំង ។*

*៥. ម្នាលអានន្ទ អស់កាល យូរហើយ មាន ស្តេចមួយអង្គ ព្រះនាម មហាសុទស្សន ទ្រង់ជាស្តេច នៃស្តេច.ទ. ...... ទ្រង់ជាម្ចាស់ នៃ ទិស.ទ. បួន ជាអ្នកឈ្នះ ជាអ្នករក្សា នូវប្រជារាស្ត្រ របស់ព្រះអង្គ ។*

*៦. ក្នុងអតីតកាល ស្មូនឆ្នាំង ក្តី អ្នកធ្វើនូវកម្រងផ្កា ក្តី ជាងឈើ ក្តី*

ដាំងមាស ក្តី និង សិប្បករ.ទ. ដទៃ ក្តី មិនរស់នៅ ក្នុងនគរ គេ.ទ. រស់នៅ ឯក្រៅ នៃនគរ ។

(ចប់មេរៀនទី ៣៥)

## កំណាព្យដាស់តឿនស្មារតី

មើលសត្វកណ្តៀរកពូនដី   មើលសត្វបក្សីក្រងសម្បុក
មើលឃ្មុំជាដើមសាងក្តីសុខ   ព្យាយាមសម្រុកបានសម្រេច ។

ទឹកស្រក់តក់ ៗ ទម្លុះថ្ម   រលកត ៗ ថ្មសឹកដាច់
កាន់ការងារអ្វីត្រូវប្តូរផ្តាច់   ផលល្អសម្រេចព្រោះព្យាយាម ។

# មេរៀនទី ៣៦

## អធិប្បាយអំពីនាមកិតក: (ត)

### វិធីចុះ ណ បច្ច័យ

*ណ បច្ច័យប្រើបានគ្រប់រូបវិគ្គហ:និងគ្រប់សាធន:ដូច អ បច្ច័យដែរ មានសទ្ទុបបទក៏បាន មិនមានក៏បាន តែត្រូវលុប ណ បច្ច័យចោលគ្រប់កន្លែង ។ កាលបើលុប ណ ហើយត្រូវទីឃ:ស្រ:ដើមធាតុឬផ្លាស់ប្តូរធាតុឱ្យទៅជាដទៃ ដូចគ្នានឹងបច្ច័យឯទៀត ៗ ដែលជាណានុព័ន្ធគឺមានជាប់ដោយតួ ណ ដូចជា ណី, ណេ, ណ្យ, ណ្វុ ដូចបានពោលរួចហើយខាងដើម ។ រូបស័ព្ទដែលសម្រេចមកពី ណ បច្ច័យប្រើជានាមក៏បានជាគុណនាមក៏បាននិងមានចំណុចឱ្យស្គាល់ ៦ ប្រការដូចតទៅនេះ*

*១. បើស្រ:ដើមធាតុជាស្រ:រស្ស: និងបើមិនមានព្យញ្ជនសំយោគនៅខាងចុងទេ ត្រូវផ្លាស់ អ > អា, ឥ > ឯ, ឧ > ឱ ឬ អវ ដូចខាងក្រោមនេះ*

| សទ្ទុ. | + ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| កម្ម | + ករ | + ណ | > កម្មការ | អ្នកធ្វើនូវការងារ |
| បរិ | + វរ | + ណ | > បរិវារ | អ្នកហែរហម, បរិវារ |
| ប | + វិស | + ណ | > បវេស | កិរិយាចូលទៅ |

| ធាតុ | +បច្ច. | សម្រេជា | ពាក្យប្រែ |
|---|---|---|---|
| គហ | + ណ | > គាហ | អ្នកយក, ការយក |
| វហ | + ណ | > វាហ | ដែលជននាំទៅ |
| ទុស | + ណ | > ទោស | សេចក្តីប្រទូស្ត, ទោស |
| មុហ | + ណ | > មោហ | សេចក្តីវង្វេង, អ្នកវង្វេង |
| ភូ | + ណ | > ភាវ | ការកើត |

២. ធាតុខ្លះទីឃៈស្រៈដើមធាតុហើយត្រូវផ្លាស់ព្យញ្ជនៈទីបំផុតទៅជារូបផ្សេងទៀត ដូចជា ក > ច, ជ > គ ជាដើម ដូចខាងក្រោមនេះ

| ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| បច | + ណ | > បាក | ការចម្អិន |
| សុច | + ណ | > សោក | សេចក្តីសោកសៅ |
| ចជ | + ណ | > ចាគ | សេចក្តីលះ |
| ភុជ | + ណ | > ភោគ | អ្នកបរិភោគ, ភោគ |
| រជ | + ណ | > រាគ | សេចក្តីត្រេកត្រអាល, តម្រេក, រាគៈ |
| រុជ | + ណ | > រោគ | រោគ |

៣. បើទីបំផុតធាតុជាព្យញ្ជនសំយោគ ត្រូវទុកធាតុឱ្យគង់រូបដើម និងត្រូវលុប ណ ចេញដូចខាងក្រោមនេះ

| សទ្ទ. | + ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ធម្ម | + តក្ក | + ណ | > ធម្មតក្ក | អ្នកត្រិះរិះនូវធម៌ |

៤. បើដើមធាតុជាស្រៈទីឃៈស្រាប់ ពុំចាំបាច់ផ្លាស់ប្ដូរអ្វីទេ និងត្រូវទុកធាតុឱ្យគង់រូបដើម ប៉ុន្តែត្រូវលុប ណ ចេញដូចខាងក្រោមនេះ

| សទ្ទ. | + ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| អា | + ពាធ | + ណ | > អាពាធ | អាពាធ, ជំងឺ |
| រដ្ឋ | + បាល | + ណ | > រដ្ឋបាល | អ្នករក្សានូវដែនដី |
| ធម្ម | + ភាស | + ណ | > ធម្មភាស | អ្នកពោលនូវធម៌ |

៥. ធាតុខ្លះមានព្យញ្ជនសំយោគនៅខាងចុងដូចក្នុងចំណុច ២ ដែរ ប៉ុន្តែត្រូវផ្លាស់ទីបំផុតធាតុទៅជាតួផ្សេងដូចជាផ្លាស់ ជ > គ ហើយចុះនិគ្គហិតសិន បន្ទាប់មកផ្លាស់និគ្គហិតនោះជា ង ដែលជាវគ្គន្តព្យញ្ជនៈនៃ កវគ្គ រួចទើបតម្រួតជា (ជ > គំ > ង្គ) ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| រញ្ជ | + ណ | > រង្គ | រោង, វេទិកា, ឆាក |
| សញ្ជ | + ណ | > សង្គ | ការសុំ, ការជាប់ជំពាក់ |

៦. ធាតុមានស្រៈទីបំផុតជា អា ត្រូវចុះ យ បច្ច័យឬក៏ថាព្រឹទ្ធិ អា > អាយ ក៏បាន រួចលុប ណ បច្ច័យចេញដូចខាងក្រោមនេះ

| ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទា | + យ + ណ | > ទាយ | ដែលជនគួរឱ្យ, ការឱ្យ |
| ធា | + យ + ណ | > ធាយ | ដែលជនគួរផឹក, ការផឹក |
| ញា | + យ + ណ | > ញាយ | ដែលជនគួរដឹង |

៧. ធាតុខ្លះអាចផ្លាស់ដើមធាតុទៅជារូបផ្សេង ៗ បានដូចជា ឌហ ធាតុ "ដុត" អាចផ្លាស់ដើមធាតុ ឌ > ឡ ហើយទីឃៈ អ ជា អា ដូចខាង ក្រោមនេះ

| សទ្ទ. | + ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| បរិ | + ឌហ | + ណ | > បរិឡាហ | ការដុតកំដៅ |

៨. ផ្លាស់ធាតុទាំងមូលជារូបផ្សេង ៗ គឺ ករ > ខរ, គហ > ឃរ, ហន > វធ ឬ ឃាត ដូចខាងក្រោមនេះ

| សទ្ទ. | + ធាតុ | + បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| សំ | + ករ | + ណ | > សង្ខារ | សង្ខារ |
| អភិ+សំ | + ករ | + ណ | > អភិសង្ខារ | ការតាក់តែង |
| បរិ | + ករ | + ណ | > បរិក្ខារ | គ្រឿងសម្ភារៈ, បរិក្ខារ |
| បុរ | + ករ | + ណ | > បុរេក្ខារ | ការដាក់ក្នុងខាងមុខ |
| ឧប | + ហន | + ណ | > ឧបឃាត | ការសម្លាប់ |
| | គហ | + ណ | > ឃរ | ផ្ទះ |

# វិធីតាំងវិគ្គហៈនៃ ណ បច្ច័យ

១. កម្មការ វិ. (យោ) កម្មំ ករោតីតិ
(សោ) កម្មការោ (ជនោ)។
២. គហ វិ. (យោ) គណ្ហាតីតិ (សោ) គាហោ (ជនោ) ។
៣. បរិភរ វិ. (យោ) បរិភរតីតិ (សោ) បរិភារោ (ជនោ) ។
៤. មាតុគាម វិ. (យោ) មាតុយា (សមការំ) គច្ឆតីតិ
(សោ) មាតុគាមោ (ជនោ) ។
៥. វហ វិ. (យោ) វហិតព្វោតិ (សោ) វាហោ (ភារោ) ។
៦. ទោស វិ. (យោ) ទុស្សតិ តេនាតិ
(សោ) ទោសោ (កិលេសោ) ។
៧. មោហ វិ. (យោ) មុយ្ហតីតិ (សោ) មោហោ (ជនោ) ។
៨. ចាគ វិ. បចជំ ចាគោ (*ការ.ការ*) ។
៩. អាវាស វិ. (ភិក្ខូ) អាវាសន្តិ ឯត្ថាតិ
(ឯសោ) អាវាសោ (បទេសោ) ។
១០. សោក វិ. (យោ) សោចតីតិ (សោ) សោកោ (ជនោ) ។
*ឬថា* វិ. សោចនំ សោកោ ។
១១. ចាគ វិ. (យោ) ចជតីតិ  ចាគោ (ជនោ) ។
*ឬថា* វិ. ចជនំ ចាគោ ។

១២. រោគ *វិ.* (យោ) រុជ្ជតីតិ រោគោ (អាពោធា) ។

១៣. អាពាធ *វិ.* (យោ) អាពាធតីតិ (សោ) អាពោធា (សភាវោ) ។

១៤. រជ្ជចាល *វិ.* (យោ) រជ្ជំ ចាលេតីតិ (សោ) រជ្ជចាលោ (ជនោ) ។

១៥. ជម្ពុតក្កា *វិ.* (យោ) ជម្ពុំ តក្កេតីតិ ជម្ពុតក្កោ (ជនោ) ។

១៦. វង្គ *វិ.* វញ្ចតីតិ វង្គោ (ជនោ) ។ *ឬថា*
*វិ.* (ជនោ) វញ្ចតិ ឯត្ថាតិ វង្គោ (បទេសោ) ។

១៧. សង្គ *វិ.* (យោ) សញ្ចតីតិ (សោ) សង្គោ (ជនោ) ។
*ឬថា វិ.* សញ្ចនំ សង្គោ ។

១៨. បរិឡាហ *វិ.* (យោ) បរិឌហតីតិ (សោ) បរិឡាហោ (ជនោ)

១៩. ធាយ *វិ.* (យំ-តេន) ធាតព្វន្តិ (តំ) ធាយំ (វត្ថុ) ។
*ឬថា វិ.* ធានំ ធាយោ ។
(ចាយ, ញាយ *មានគតិដូច* ធាយ *ដែរ ។*)

២០. សង្ខារ *វិ.* (យេ) សំ សុដ្ឋុ ការិយន្តេតិ (តេ) សង្ខារា (ធម្មា)។

២១. អភិសង្ខារ *វិ.* (យោ) អភិ វិសិដ្ឋេន សំ សុដ្ឋុ ការោតីតិ (សោ) អភិសង្ខារោ (សភាវោ) ។

២២. បរិក្ខារ *វិ.* (ជនោ) បរិ សមន្តតោ ការោតិ តេនាតិ (សោ)

បរិក្ខារោ (អលង្ការោ) ។

២៣. បុរេក្ខារ វិ. បុរេ ការណំ បុរេក្ខារោ ។

## ប្រែវិគ្គហៈជាគំរូ

### មាតុគាម

(យោ) មាតុយា (សមការំ) គច្ឆតីតិ (សោ) មាតុគាមោ (ជនោ) ។ *(ជនណា) រមែងដល់ (នូវការជាអ្នកស្មើ) ដោយមាតា ព្រោះហេតុនោះ (ជននោះ) ឈ្មោះថា* មាតុគាមោ, មាតុគាមោ *= អ្នកដែលមានស្រុកដូចជាស្រុករបស់មាតា, មាតុគ្រាម ។*

*(ជាស្រីប៉ុន្តែសន្មតិទៅជាបុំលិង្គ) ។*

### សង្ខារ

(យេ) សំ សុដ្ឋុ ការិយន្តេតិ (តេ) សង្ខារា (ធម្មា) ។

*(ធម៌.ទ.ណា)* (បច្ចយេហ *ដែលបច្ច័យ) រមែងធ្វើ* សំ *ព្រម* សំ *គឺថា* សុដ្ឋុ *ដោយល្អ* ឥតិ *ព្រោះហេតុនោះ (ធម៌.ទ.នោះ) ឈ្មោះថា* សង្ខារា, សង្ខារា *=គឺបច្ច័យធ្វើព្រមដោយល្អ (ដែលបច្ច័យតាក់តែងដោយល្អ) ។*

## អភិសង្ខារ

(យោ) អភិ វិសិដ្ឋេន សំ សុដ្ឋុ ករោតីតិ (សោ) អភិសង្ខារោ (សភាវោ) ។

(យោ សភាវោ *វិសភាវ ណា*) ករោតិ *រមែងធ្វើ* អភិ *ក្រៃពេក* អភិ *គឺថា* វិសិដ្ឋេន *ដោយវិសេស* សំ *ល្អ* សំ *គឺថា* សុដ្ឋុ *ដោយល្អ* ឥតិ *ព្រោះហេតុនោះ* (សោ សភាវោ *វិសភាវ នោះ*) អភិសង្ខារោ, អភិ-សង្ខារោ =*អ្នកធ្វើល្អក្រៃពេក* ។

*សូមសង្កេតមើល* អភិ *ត្រូវខែសេចក្តីជា* វិសិដ្ឋេន, សំ *ខែសេចក្តីជា* សុដ្ឋុ ។

## បរិក្ខារ

(ជនោ) បរិ សមន្តតោ ករោតិ តេនាតិ (សោ) បរិក្ខារោ (អលង្ការោ) ។

(ជន) *តែងធ្វើ* បរិ *ជុំវិញ គឺថា* សមន្តតោ *ដោយជុំវិញ (ដោយគ្រឿងប្រដាប់នោះ) ព្រោះហេតុនោះ (គ្រឿងប្រដាប់នោះ) ឈ្មោះថា* បរិក្ខារោ, បរិក្ខារោ =*ជាគ្រឿងធ្វើជុំវិញនៃជន, បរិក្ខារ* ។

## បុរេក្ខារ

បុរេ ករណំ បុរេក្ខារោ ។

*ការធ្វើ ក្នុងកាលមុន ឈ្មោះថា* **បរេក្ខារោ, បុរេក្ខារោ** *=កិរិយាដាក់ក្នុងខាងមុខ (ការរូបការសាធនៈ) ។*

*(ស័ព្ទខ្លះមិនបានតាំងវិគ្គហៈនិងប្រែទុកទេ ព្រោះសង្ឃឹមថាអ្នក-សិក្សាអាចប្រែបានហើយ) ។*

## កំណត់សម្គាល់

*ស័ព្ទដែលសម្រេចមកពី* **ណ** *បច្ច័យដូចពោលរួចហើយនេះ ស័ព្ទខ្លះនៅពេលប្រែត្រូវប្រែត្រាប់ស័ព្ទចំ ៗ តែម្តង បើមិនប្រែដូច្នោះទេ អ្នកស្តាប់អាចមិនយល់រឿងរ៉ាវក៏មានដែរ ព្រោះថាបុរាណលោកបានប្រើយ៉ាងនោះរួចមកហើយដូចជា* **រោគោ** *ប្រែថា រោគ,* **សង្ខារា** *=សង្ខារទាំងឡាយ,* **អាពាធោ** *=អាពាធ, ឈឺ,* **រដ្ឋបាលោ** *= រដ្ឋបាល ជាដើម ។*

*បើជានាមនាម ភាគច្រើនសម្រេចមកពីរូបវិគ្គហៈរបស់ការរូបការ-សាធនៈ ។ បើជាគុណនាមសម្រេចមកពីគ្រប់សាធនៈ មានវិធីបំបែកតាមវិភត្តិផ្សេង ៗ បានទាំង ៣ លិង្គគឺ*

*បើបុំលិង្គបំបែកតាមបែប* **បុរិស** *។ បើឥត្ថីលិង្គ ត្រូវចុះ* **អា** *បច្ច័យបំបែកតាមបែប* **កញ្ញា** *។ បើជានបុំសកលិង្គបំបែកតាមបែប* **កុល** *។ ជាពិសេសបើប្រើជាគុណបទនៃនាមណាត្រូវបំបែកឱ្យមាន លិង្គ, វចនៈ, វិភត្តិឱ្យស្មើគ្នានឹងនាមជាប្រធាននោះ ៗ ពីព្រោះការនាំយកទៅប្រើក្នុង*

*ប្រយោគគឺយកតែស័ព្ទសាធនៈប៉ុណ្ណោះ ។*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (ត)

១. សោ ធម្មតក្កោ បុរិសោ ពុទ្ធសាសនេ ករំ ហោតិ ។

*បុរស ជាអ្នកត្រិះរិះនូវធម៌ នោះ រមែងជាអ្នកចម្រើន ក្នុងព្រះពុទ្ធសាសនា ។*

២. សោកោ តេ មា ហោតុ ។

*សេចក្ដីសោក សូមកុំមាន ដល់លោក ។*

៣. "សព្វេ សង្ខារា អនិច្ចា"តិ យទា បញ្ញាយ បស្សតិ, អថ និព្វិន្ទតិ ទុក្ខេ, ឯស មគ្គោ វិសុទ្ធិយា ។

*ក្នុងកាលណា បុគ្គលឃើញ ដោយបញ្ញា ថា "សង្ខារទាំងឡាយទាំងពួង មិនទៀង" ក្នុងកាលនោះ រមែងនឿយណាយ ក្នុងទុក្ខ, ធម៌នេះ ជាផ្លូវ នៃសេចក្ដីហ្មត់ចត់វិសេស(បរិសុទ្ធ) ។*

☸ អនិច្ចាតិ =(អនិច្ច + ឥតិ), ឯស =(ឯសោ ឯម្មោ) ។

*(ចប់ ណ បច្ច័យ)*

# វិធីចុះ តិ បច្ច័យ

**តិ** បច្ច័យប្រើបានគ្រប់រូបគ្រប់សាធនៈ ចុះចុងធាតុមានសទ្ទុបបទក៏បាន ឬមិនមានក៏បាន ។ បើប្រកបជាមួយធាតុណាត្រូវរក្សា **តិ** ឱ្យគង់រូបដើម ។ ស័ព្ទដែលចុះ **តិ** បច្ច័យនេះសម្រេចរូបជានាមនាមក៏បាន ជាគុណនាមក៏បាន ។ **តិ** ជាបច្ច័យមានតួ **ត** វេលាចុះជាមួយធាតុមានវិធីផ្លាស់ប្តូរទីបំផុតធាតុទៅជាផ្សេង ៗ ដូច **ត** បច្ច័យក្នុងកិតកិរិយាដែរដែលមានវិធីចុះដូចតទៅនេះ

១. បើទីបំផុតធាតុជា **ន**, **ម**, **រ** លុបទីបំផុតធាតុចេញដូចការលុបក្នុង **ត** បច្ច័យនៃកិតកិរិយាដែរ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| **ប + ករ** | + **តិ** | > **បកតិ** | ប្រក្រតី, ការធ្វើរឿយ ៗ |
| **វិ + ករ** | + **តិ** | > **វិកតិ** | ការធ្វើឱ្យផ្សេងគ្នា |
| **សរ** | + **តិ** | > **សតិ** | សេចក្តីរលឹក, សតិ |
| **គម** | + **តិ** | > **គតិ** | គតិ, ការទៅ, ភូមិជាទីទៅ |
| **រម** | + **តិ** | > **រតិ** | សេចក្តីត្រេកអរ |
| **មន** | + **តិ** | > **មតិ** | អ្នកចេះ, ការចេះ |
| **សំ + តន** | + **តិ** | > **សន្តតិ** | ការបន្ត, សេចក្តីបន្ត |

២. ផ្លាស់ស្រៈ **អា** > **ឥ** ឬ **ឦ** ។ ប្រសិនបើជាស្រៈដទៃទៀត ទុក

ស្រៈ ឱ្យគង់រូបដើមដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឋា | + តិ | > ឋិតិ | ការឋិតនៅ, ការតាំងនៅ |
| បា | + តិ | > បីតិ | ការផឹក, សេចក្តីឆ្អែត |

ជួនកាលធាតុមានទីបំផុតជាស្រៈ **អា** ឱ្យរស្សៈជាស្រៈ **អ** វិញដូចជា

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| បា | + តិ | > បតិ | អ្នករក្សា, ម្ចាស់, ប្តី, នាយ |
| វិ + ញា | + តិ | > វិញ្ញត្តិ | កិរិយាសុំ (រស្សៈ **អា** នៃ **ញា** ជា **អ**, តម្រួត **ញ** > **ញ្ញ**, តម្រួត **តិ** ជា **ត្តិ**) |

ធាតុមួយពួកទៀតរក្សាឱ្យគង់រូបដើមដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| វិ + ភូ | + តិ | > វិភូតិ | អ្នកកើតដោយពិសេស |
| ថុ | + តិ | > ថុតិ | សេចក្តីសរសើរ, សេចក្តីស្ងើច |

៣. ផ្លាស់ទីបំផុតធាតុដែលជា **ច**, **ជ**, **ទ**, **ប** ទៅជា **ត** ដូចខាងក្រោមនេះ

| ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| វិ + មុច | + តិ | > វិមុត្តិ | ការរួចស្រឡះ |
| ភជ | + តិ | > ភត្តិ | ការគប់រក |
| វិ + ភជ | + តិ | > វិភត្តិ | ការចែក, វិភត្តិ |

| | | | |
|---|---|---|---|
| អា + បទ | + តិ | > អាបត្តិ | ការត្រូវ(ទោស), អាបត្តិ |
| សំ + បទ | + តិ | > សម្បត្តិ | ការដល់ព្រម, សម្បត្តិ |
| គុប | + តិ | > គុត្តិ | កាគ្រប់គ្រង, ការរក្សា |
| តិប | + តិ | > តិត្តិ | ការឆ្អែត, សេចក្តីឆ្អែត |

៤. ផ្លាស់ តិ ជាព្យញ្ជនៈដទៃតាមគោលការណ៍នៃ ត បច្ច័យដែរ ដូចតទៅនេះ

៤.១ បើទីបំផុតធាតុជា ធ, ភ ផ្លាស់ (ធ ឬ ភ + តិ) > ទ្ធិ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេច | ពាក្យប្រែ |
|---|---|---|---|
| ពុធ | + តិ | > ពុទ្ធិ | ការបេះ, បញ្ញា |
| វិ + សុធ | + តិ | > វិសុទ្ធិ | សេចក្តីហ្មត់ចត់, សេចក្តីស្អាត |
| សំ + ឥធ | + តិ | > សមិទ្ធិ | ការសម្រេចព្រម |
| លភ | + តិ | > លទ្ធិ | ជាហេតុបាន, លទ្ធិ, ទំនៀម |

៤.២ បើទីបំផុតធាតុជា ន, ម ផ្លាស់ (ន ឬ ម + តិ) > ន្តិ ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ហន | + តិ | > ហន្តិ | ការបៀតបៀន, ការសម្លាប់ |
| ខម | + តិ | > ខន្តិ | សេចក្តីអត់ធន់, ខន្តី |

| | | | | |
|---|---|---|---|---|
| និ + កាម | + | តិ | > និកាន្តិ | សេចក្តីប្រាថ្នា, តណ្ហា |
| សម | + | តិ | > សន្តិ | សេចក្តីស្ងប់ |

៤.៣ បើទីបំផុតធាតុជា ស ផ្លាស់ (ស + តិ) > ដ្ឋិ ដូចខាងក្រោម

| ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទិស | + តិ | > ទិដ្ឋិ | ការឃើញ |
| អនុ + សាស | + តិ | > អនុសិដ្ឋិ | ការបង្រៀន |
| សំ + តុស | + តិ | > សន្តុដ្ឋិ | សេចក្តីត្រេកអរព្រម |

៥. ចំពោះ ជន ធាតុប្រែថា "កើត" ត្រូវផ្លាស់ ជន ធាតុទៅជា ជា ដូចខាងក្រោមនេះ

| ធាតុ | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ជន > ជា | + តិ | > ជាតិ | ការកើត, ជាតិ |

បើជា ត បច្ច័យបានរូបជា ជាត =កើតហើយ ។

## វិធីតាំងវិគ្គហៈនៃ តិ បច្ច័យ

១. វិកតិ — វិ. វិរចេន អាការេន ករណំ វិកតិ ។ (ភាវ.ភាវ.)

២. សតិ — វិ. សរតីតិ សតិ (ឧម្មជាតិ) ។

វិ. សរតិ ឯតាយាតិ សតិ ។ ឬ វិ. សរណំ សតិ ។

៣. គតិ វិ. គច្ឆន្តិ ឯតាយាតិ គតិ (ភូមិ) ។

៤. រតិ វិ. រមតិ ឯតាយាតិ រតិ (ធម្មជាតិ) ឬ វិ. រមនំ រតិ ។

៥. មតិ វិ. មញ្ញតីតិ មតិ (បញ្ញា) ។

ឬ វិ. មញ្ញតិ ឯតាយាតិ មតិ (បញ្ញា) ។

៦. សន្តតិ វិ. សន្តននំ សន្តតិ ។

៧. វិមុត្តិ វិ. វិមុច្ចនំ វិមុត្តិ ។

៨. ភត្តិ វិ. ភជនំ ភត្តិ ។ វិភត្តិ វិ. វិភជនំ វិភត្តិ ។

៩. អាបត្តិ វិ. អាបជ្ជនំ អាបត្តិ ។

១០. សម្បត្តិ វិ. សម្បជ្ជិតព្វាតិ សម្បត្តិ (ធម្មជាតិ) ។

១១. គុត្តិ វិ. គុបនំ គុត្តិ ។

១២. តិត្តិ វិ. តិបនំ តិត្តិ ។

១៣. ឋិតិ វិ. ឋានំ ឋិតិ ។

១៤. បីតិ វិ. បីរនំ បីតិ ។

១៥. វិញ្ញត្តិ វិ. វិញ្ញាបនំ វិញ្ញត្តិ ។

១៦. វិកូតិ វិ. វិសេសតោ ករតីតិ វិកូតិ ។ ឬ វិ. វិករនំ វិកូតិ ។

១៧. ពុទ្ធិ វិ. (ជនោ) ពុជ្ឈតិ ឯតាយាតិ ពុទ្ធិ (បញ្ញា) ។

១៨. វិសុទ្ធិ វិ. វិសុជ្ឈនំ វិសុទ្ធិ ។

១៩. លទ្ធិ វិ. (ជនោ) លភតិ ឯតាយាតិ លទ្ធិ (ធម្មជាតិ) ។

២០. សមិទ្ធិ វិ. សមិជ្ឈនំ សមិទ្ធិ ។

២១. ខន្តិ វិ. ខមនំ ខន្តិ ។

២២. និកន្តិ វិ. និកាមនំ និកន្តិ ។

២៣. សន្តិ វិ. សមនំ សន្តិ ។

២៤. ឥទ្ធិ វិ. ឥស្សនំ ឥទ្ធិ ។

២៥. សន្តុដ្ឋិ វិ. សន្តុស្សនំ សន្តុដ្ឋិ ។

២៦. ជាតិ វិ. ជននំ ជាតិ ។

## កំណត់សម្គាល់

*វិគ្គហៈណាជាសាធនៈអ្វី សូមរកមើលឡើងវិញក្នុងគោលការណ៍តាំងវិគ្គហៈរបស់សាធនៈទាំង ៧ ដែលបានពោលរួចហើយផងចុះ ។ ស័ព្ទដែលសម្រេចមកពី* **តិ** *បច្ច័យនិយមប្រើជានាមនាមបំបែកតាមវិភត្តិផ្សេង ៗ តាមបែប* **ភូមិ** *ឥការន្តឥត្ថីលិង្គតែម្យ៉ាង ដូចប្រយោគខាងក្រោមនេះជាឧទាហរណ៍*

**អហំ ទុក្ខា <u>វិមុត្តិយា</u> ធម្មំ បដិបជ្ជាមិ ។**

*ខ្ញុំ កំពុងបដិបត្តិ នូវធម៌ <u>ដើម្បីការរួច</u> ចាកទុក្ខ ។*

**(ចប់ តិ បច្ច័យ)**

# វិធីចុះ យុ បច្ច័យ

យុ បច្ច័យប្រើបានគ្រប់រូបគ្រប់សាធនៈដូច អ បច្ច័យដែរ មានសទ្ទុបបទក៏បាន មិនមានក៏បាន ចុះខាងចុងធាតុណាក៏ដោយ ត្រូវផ្លាស់ យុ បច្ច័យទៅជា អន, អណ, អានន ។ ដូច្នេះឃើញថា យុ បច្ច័យបាត់រូបទៅ នៅសល់តែ អន, អណ, អានន ប៉ុណ្ណោះ ។ កាលណាបានជួបបច្ច័យទាំងបីនេះ សូមចាំទុកចុះថាជា យុ បច្ច័យនេះហើយ ។ អាស្រ័យហេតុនេះដើម្បីឱ្យងាយយល់ក្នុងការប្រកបរូបរបស់ យុ បច្ច័យត្រូវគិតថាជា អន, អណ, អានន បច្ច័យវិញ ។ បច្ច័យនេះមានគោលការណ៍ប្រកបជាមួយធាតុផ្សេង ៗ គ្នាដែលមាន ៣ វិធីគឺ

១. យុ > អន ប្រើចុះជាមួយធាតុទូទៅ (វៀរតែធាតុដែលមានទីបំផុតជា រ, ហ ប៉ុណ្ណោះ) ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| កុធ | + យុ | > កោធន | សេចក្ដីក្រោធ, កំហឹង |
| គម | + យុ | > គមន | ការទៅ |
| ចិត | + យុ | > ចេតនា | ចេតនា |
| ភុជ | + យុ | > ភោជន | ការបរិភោគ, អាហារ |
| វច | + យុ | > វចន | ការពោល, ពាក្យ, សំដី |
| វិ + រុច | + យុ | > វិរោចន | ការរុងរឿង |

| | | | | |
|---|---|---|---|---|
| វិទ | + យុ | > វេទនា | | ការដឹង, វេទនា |
| ទា | + យុ | > ទាន | | ការឱ្យ, ទាន |
| ឋា | + យុ | > ឋាន | | ការឋិតនៅ, ការឈរ, ទីតាំង |
| សំ + វណ្ណ | + យុ | > សំវណ្ណនា | | ការពណ៌នា, ការអធិប្បាយ |
| សុ | + យុ | > សវន | | ការស្តាប់ |
| សិវ | + យុ | > សេវនាន | | ការគប់រក |

២. យុ > អណ បច្ច័យប្រើចុះជាមួយធាតុមានទីបំផុតជា រ, ហ (ហ មិនប្រាកដជានិច្ចទេ) ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ករ | + យុ | > ករណ | ការធ្វើ |
| មរ | + យុ | > មរណ | ការស្លាប់, សេចក្តីស្លាប់, មរណៈ |
| បូរ | + យុ | > បូរណ | ភាពពេញ |
| សរ | + យុ | > សរណ | សេចក្តីរលឹក, ទីពឹង, ទីរលឹក |

៣. យុ > អានន បច្ច័យប្រើចំពោះតែ ញា ធាតុមួយប៉ុណ្ណោះ ត្រូវផ្លាស់ ញា > ជា ជានិច្ច (វៀរតែក្នុងករណីខ្លះ) ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ញា | + យុ | > ជានន | សេចក្តីដឹង |
| វិ + ញា | + យុ | > វិជានន | សេចក្តីដឹងច្បាស់ |

ធាតុខ្លះមិនអនុវត្តតាមគោលការណ៍ដូចខាងលើនេះជានិច្ចទេ ។

១. ធាតុណាមានទីបំផុតជា **ហ** និយមផ្លាស់ជា **អង** តាមខលេខ ១ ក៏បានដូចជា

**ឧប** + (**ងហ** + **យ** > **ងយ្ហ**) + **អង** ) > **ឧបងយ្ហង** =ការបង ។ (ចុះ **យ** បច្ច័យអាខ្យាត) ។

២. បើទីបំផុតធាតុជាព្យញ្ជនៈក្រៅពី **រ**, **ហ** អាចផ្លាស់ **យុ** > **អណ** ដូចលេខ ២ បាន ដូចជា **សម** + **យុ** > **សមណ** =អ្នកស្ងប់ ។

៣. **ញា** ធាតុពុំចាំបាច់ផ្លាស់ទៅជា **ជា** ទេ ប៉ុន្តែត្រូវផ្លាស់ **យុ** > **អណ** ដូចខាងក្រោមនេះ

| ធាតុ | +បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ញា | + យុ | > ញាណ | ការដឹង |
| វិ + ញា | + យុ | > វិញ្ញាណ | ការដឹងច្បាស់, វិញ្ញាណ |

៤. **ញា** ធាតុបើផ្លាស់ទៅជា **ជា** អាចផ្លាស់ **យុ** > **អង** ក៏បាន

| ធាតុ | +បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សុ + វិ + ញា | + យុ | > សុវិជាង | អ្នកដឹងបានដោយងាយ |
| ទុ + វិ + ញា | + យុ | > ទុវិជាង | អ្នកដឹងបានដោយលំបាក |

## ប្រយោគគំរូ

**សុវិជានោ ភវំ ហោតិ, ទុវិជានោ បរាភវោ ។**

*អ្នកដឹងបានដោយល្អ ជាអ្នកចំរើន,*

*អ្នកដឹងបានដោយលំបាក ជាអ្នកវិនាស ។*

*សរុបសេចក្តីមកការផ្លាស់* **យុ** > **អន** *មានប្រើច្រើនជាង* **អណា** *និង* **អានន** *។*

*៥. រូបស័ព្ទដែលសម្រេចមកពី* **យុ** *បច្ច័យនិងដែលផ្លាស់រូបទៅជាផ្សេង ៗ នេះ ឃើញថាជាស័ព្ទ អ ការន្តដែលអាចបំបែកតាមវិភត្តិបានទាំង ៣ លិង្គគឺ បុំលិង្គ បំបែកតាមបែប* **បុរិស** *។ ឥត្ថីលិង្គ ត្រូវចុះ* **អា** *បច្ច័យខាងចុងហើយបំបែកតាមបែប* **កញ្ញា** *។ នបុំសកលិង្គ បំបែកតាមបែប* **កុល** *។ បើប្រើជាគុណនាមត្រូវបំបែកឱ្យមាន លិង្គ, វចនៈនិងវិភត្តិស្មើគ្នានឹងនាមជាប្រធានដូចខាងក្រោមនេះ*

## វិធីប្រើនាមកិតកៈក្នុងប្រយោគ (គ)

**១. យោ ធម្មំ ចរតិ, សោ សុខំ និបជ្ជតិ ច តស្ស ជីវតំ <u>វិរោចនំ</u> ហោតិ ច ។**

*(បុគ្គល)ណា ប្រព្រឹត្ត នូវធម៌, (បុគ្គល)នោះ រមែងដេក ជាសុខ ផង ជីវិត របស់(បុគ្គល)នោះ <u>រមែងជាទីរុងរោចន៍</u> ផង ។*

២. ឥមស្មឹ លោកេ សព្វេសំ មរណំ ភវិស្សតិ ។

សេចក្ដីស្លាប់ នឹងមាន ដល់ជនទាំងឡាយ ទាំងពួង ក្នុងលោកនេះ ។

ម្យ៉ាងទៀត ស័ព្ទដែលសម្រេចមកពី យុ > អណ ប្រសិនបើមានបទកម្ម តួកម្មនោះត្រូវបំបែកជាឆដ្ឋីវិភត្តិ តែត្រូវប្រែកាច់ជាទុតិយាវិភត្តិ ថា "នូវ" ជំនួសវិញ ឧ.

៣. សព្វបាបស្ស អករណំ សេដ្ឋំ ។

ការមិនធ្វើ នូវបាបទាំងពួង ជាអំពើដ៏ប្រសើរបំផុត ។

(ចប់ យុ បច្ច័យ)

# វិធីចុះ តវេ និង តុំ បច្ច័យ

ចំពោះបច្ច័យទាំងពីនេះមិនអធិប្បាយក្នុងទីនេះទៀតទេ ពីព្រោះបានអធិប្បាយក្នុងមេរៀនទី ២២ នៃភាគ ១ រួចហើយ ។ ដូច្នេះសូមរកមើលក្នុងភាគ ១ ផងចុះ ។

## នាមសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| បទនិក្ខេប នបុំ. | ដាក់ជើង |
| អទស្សន នបុំ. | កិរិយាមិនឃើញ |
| គតិ ឥ. | កិរិយាទៅ, គតិ |
| ទេវទេវ បុំ. | ទេវតាធំជាងទេវតាទាំងឡាយ |
| សក្ក បុំ. | សក្កទេវរាជ |
| វេទនា ឥ. | ការដឹង, ការសោយ, វេទនា |
| ពុទ្ធវចន នបុំ. | ព្រះពុទ្ធវាចា, ពុទ្ធវចនៈ, ព្រះត្រៃបិដក |
| គោប បុំ. | អ្នករក្សានូវគោ |
| សាមញ្ញ នបុំ. | ការនៃសមណៈ |
| ភាគ បុំ. | តម្រេក, រាគៈ |
| ទោស បុំ. | សេចក្ដីប្រទូស្ត, ទោស |
| មោហ បុំ. | សេចក្ដីវង្វេង, មោហៈ |
| សមាបត្តិ ឥ. | សមាបត្តិ |
| សម្បទា ឥ. | ការដល់ព្រម, សម្បទា |
| ជនតា ឥ. | ប្រជុំនៃជន |
| វុដ្ឋិតកាល បុំ. | វេលាចេញ |
| ឋានកាល បុំ. | កាលជាទីឋិ្យ |
| គន្ថធុរ នបុំ. | ធុរៈគឺការរៀនគម្ពីរ, គន្ថធុរៈ |

| | | |
|---|---|---|
| អាពាធ | បុំ. | ឈឺ, អាពាធ |
| វិសុទ្ធិ | ឥ. | សេចក្ដីស្អាត |
| វត្ថុសម្បទា | ឥ. | ការដល់ព្រមគឺវត្ថុ |
| បច្ចយសម្បទា | ឥ. | ការដល់ព្រមគឺបច្ច័យ |
| ចេតនាសម្បទា | ឥ. | ការដល់ព្រមគឺចេតនា |
| បច្ឆាភាគ | បុំ. | កាលជាចំណែកខាងក្រោយ |
| វិបស្សនាធុរ | នបុំ. | ធុរៈគឺការចម្រើនវិបស្សនា |
| បស្សតា | គុ. | កាលឃើញឬមើល |
| សម្មាសម្ពុទ្ធ | គុ. | ដែលត្រាស់ដឹងឯងនិងដោយប្រពៃ |
| អនាគាមី | គុ. | ជាអ្នកនឹងមិនមកជាប្រក្រតី |
| ទក្ខិណេយ្យ | គុ. | ជាអ្នកគួរនូវទក្ខិណាទាន |
| សម | គុ. | ស្មើ |
| តក្ការ | គុ. | ជាអ្នកធ្វើនូវ... |
| គណ្ហាយ | គុ. | កាលកាប់ |
| បមត្ត | គុ. | ដែលប្រមាទហើយ |
| អប្បមត្ត | គុ. | ដែលមិនប្រមាទហើយ |
| ទុរន្នយ | គុ. | ដែលដឹងបានដោយលំបាក |
| មនុស្សភូត | គុ. | ដែលកើតជាមនុស្ស |
| អទុក្ខមសុខ | គុ. | ដែលមិនជាទុក្ខមិនជាសុខ |

| | | |
|---|---|---|
| អនុធម្មចារី | បុំ. | អ្នកមានកិរិយាប្រព្រឹត្តតាមធម៌ជាប្រក្រតី |
| ធម្មានុបស្សី | បុំ. | អ្នកឃើញតាមនូវធម៌ជាប្រក្រតី |
| សង្ខត | គុ. | ដែលបច្ច័យតាក់តែងហើយ |
| សម្មក្ខាត | គុ. | ដែល...ពោលហើយដោយល្អ |
| បដិច្ចសមុប្បន្ន | គុ. | ដែលអាស្រ័យបច្ច័យកើតឡើងហើយ |
| ខយធម្ម | គុ. | ដែលមានការអស់ទៅជាធម្មតា |
| វយធម្ម | គុ. | ដែលមានការអន់ថយទៅជាធម្មតា |
| វិរាគធម្ម | គុ. | ដែលមានការប្រាសចាកតម្រេកជាធម្មតា |
| និរោធធម្ម | គុ. | ដែលមានការរលត់ទៅជាធម្មតា |
| និរោធសមាបត្តិរហា | គុ. | ដែលជាអ្នកគួរដល់នូវនិរោធ |
| សុវិមុត្តចិត្តោ | គុ. | មានចិត្តផុតស្រឡះល្អហើយ |
| អន្តលិក្ខចរ | គុ. | ជាអ្នកត្រាច់ទៅក្នុងអាកាស |
| គុណាតិរេកសម្បទា | ឥ. | ការដល់ព្រមដោយគុណក្រៃលែង |
| បុរិន្ទទ | បុំ. | អ្នកឱ្យហើយក្នុងកាលមុន |
| បច្ចយសន្និចយ | បុំ. | ការសន្សំនូវបច្ច័យ |
| សោមនស្សសហគត-ញាណសម្បយុត្តភាវ | បុំ. | ភាវប្រកបដោយការដឹងប្រព្រឹត្តទៅ-មួយអន្លើដោយសេចក្ដីរីករាយ |

# លំហាត់នៃមេរៀនទី ៣៦

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើ ណា បច្ច័យអាចចុះខាងចុងធាតុបានប៉ុន្មានយ៉ាង ?*

*២. តើ តិ បច្ច័យអាចចុះក្នុងចុងធាតុបានប៉ុន្មានយ៉ាង ?*

*៣. តើ យុ បច្ច័យអាចផ្លាស់ទៅជាអ្វីខ្លះ ?*

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. អាកាសេន គតានំ សកុណានំ បទនិក្ខេបស្ស អទស្សនេន គតិ ទុរន្នយា ។

២. សក្កោ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ បុរេ ទានំ អទាសិ តស្មា បុរិន្ទទោតិ វុច្ចតិ ។

៣. យស្មឹ សមយេ អទុក្ខមសុខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ សុខំ វេទនំ វេទេតិ ន ទុក្ខំ វេទនំ វេទេតិ អទុក្ខមសុខំ យេវ តស្មឹ សមយេ វេទនំ វេទេតិ ។

៤. សុខាបិ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា ទុក្ខាបិ វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្ម ។បេ។

៥. យោ នរោ បមត្តោ ហុត្វា ពហុម្បិ ពុទ្ធវចនំ ភាសមានោ ន តក្ករោ ហោតិ សោ បរេសំ គាវោ គណយំ គោបោ

វិយ សាមញ្ញស្ស ន ភាគវា ហោតិ ។

៦. យោ នរោ អប្បមត្តោ ច អនុធម្មចារី ច ហុត្វា អប្បម្បិ ពុទ្ធវចនំ ភាសមានោ រាគញ្ច ទោសញ្ច មោហញ្ច បហាយ សុវិមុត្ត-ចិត្តោ ហោតិ សោ សាមញ្ញស្ស ភាគវា ហោតិ ។

៧. ឯវំ ខោ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ អយំ ខោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកាយនោ មគ្គោ សម្មទក្ខាតោ សត្តានំ វិសុទ្ធិយា (វត្តតិ)។

៨. ចតស្សោ ហិ សម្បទា នាម វត្ថុសម្បទា បច្ចយសម្បទា ចេតនាសម្បទា គុណាតិរេកសម្បទា តត្ថ (សម្បទាសុ) និរោធសមាបត្តរហោ អរហា វា អនាគាមី វា ទក្ខិណេយ្យោ វត្ថុសម្បទា នាម ។ បច្ចយានំ ធម្មេន សមេន ឧប្បត្តិ បច្ចយសម្បទា នាម ។

៩. ទានតោ បុព្វេ ទានកាលេ បច្ឆាភាគេតិ តេសុ កាលេសុ ចេតនាយ សោមនស្សសហគតញាណសម្បយុត្តភាវោ ចេតនាសម្បទា នាម ។ ទក្ខិណេយ្យស្ស បន សមាបត្តិតោ វុដ្ឋិតកាលោ គុណាតិរេកសម្បទា នាម ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ជន.ទ. ទាំងពួង ក្នុងទីនេះ តែងរៀន នូវភាសាបាលី ដោយសេចក្តី-រីករាយ ផង ដោយសេចក្តីភ្លើតភ្លើន ផង ។*

២. សូមឱ្យសេចក្ដីស្ងប់ មាន ដល់ជន.ទ. ក្នុងលោកនេះ ។

៣. បើ បុគ្គល ញុំាងសេចក្ដីមិនស្ងប់ ឱ្យកើតឡើង រមែងមិនគួរ ពីព្រោះ សេចក្ដីសុខ រមែងមាន ព្រោះសេចក្ដីស្ងប់ ។

៤. សេចក្ដីសុខ ដទៃ ប្រសើរជាង សេចក្ដីស្ងប់ មិនមាន ។

៥. អាពាធ ចូរកុំមាន ដល់ជន.ទ. សូមជន.ទ. រស់នៅ យ៉ាងសប្បាយ ។

៦. ជនណា ជាអ្នកត្រាច់ទៅក្នុងអាកាស ជននោះ មិនអាច ដើម្បី រួចផុត ពីសេចក្ដីស្លាប់ឡើយ ។

៧. ភិក្ខុ អ្នកប្រាថ្នានូវការចាកទុក្ខ មិនគួរធ្វើ នូវការសន្សំបច្ច័យ ។

៨. ក្នុងសាសនា នេះ មាន ធុរៈ ប៉ុន្មានយ៉ាង ? មាន ២ គឺ គន្ថធុរៈ, វិបស្សនាធុរៈ, ក៏ គន្ថធុរៈ ជា អ្វី ? វិបស្សនាធុរៈ ជាអ្វី ?

**(ចប់មេរៀនទី ៣៦)**

# មេរៀនទី ៣៧

## អធិប្បាយអំពីនាមកិតកៈ (ត)

### បច្ចេកបច្ច័យ ឬ បច្ច័យដោយឡែក

*បច្ចេកបច្ច័យ ឬ បច្ច័យដោយឡែក បានដល់ បច្ច័យ ១៤ តួគឺ* **អាវី**, **ឥន**, **ឥក**, **ណុក**, **តេយ្យ**, **តុក**, **ម**, **រ**, **រត្ថុ**, **រម្ម**, **រិច្ច**, **រិតុ**, **រិរិយ**, **រាតុ** *។ បច្ច័យពួកនេះ ប្រើចុះជាមួយធាតុតែមួយ ៗ ប៉ុណ្ណោះ មិនប្រើជាទូទៅដូចបច្ច័យមុន ៗ ទេ ។ នៅក្នុងកច្ចាយនូបត្ថម្ភកៈបានរាប់បញ្ចូលក្នុងពួកតែម្តង ។ បច្ច័យទាំងនេះមានវិធីប្រកបរូបស័ព្ទជាសាធនៈដូចបច្ច័យក្នុងនាមកិតកៈគ្រប់ប្រការដូចតទៅនេះ*

### វិធីចុះបច្ច័យមួយតួ ៗ

*១.* ***អាវី*** *បច្ច័យនេះប្រើបានតែជាកត្តុសាធនៈ ក្នុងអត្ថជាកត្តុរូប-តស្សីលសាធនៈ ឬក៏ សមាសរូប-តស្សីលសាធនៈប៉ុណ្ណោះ ឧ.*

**ភយទស្សាវី** *មានវិគ្គហៈថា*

(យោ) ភយំ បស្សតីតិ (សោ) ភយទស្សាវី (ជនោ)។ *កត្តុ.*

*កត្តុ. ។*

**(យោ) ភយំ បស្សតិ សីលេនាតិ (សោ) ភយទស្សាវី (ជនោ)** ។ *កត្តុ.តស្ស* ។

**ភយំ បស្សតុំ សីលមស្សាតិ (សោ) ភយទស្សាវី (ជនោ)** ។ *សម. តស្ស.* ។

*ប្រែថា "អ្នកឃើញនូវភ័យ, អ្នកឃើញនូវភ័យជាប្រក្រតី, អ្នកមានប្រក្រតីឃើញនូវភ័យ ។ សម្រេចមកពី* (**ភយ** + (**ទិស** > **ទស្ស**) + **អាវី**) ។ *(មានវិធីប្រែវិគ្គហៈដូច* **ណី** *បច្ច័យគ្រប់ប្រការ)* ។

*២.* **ឥន** *បច្ច័យប្រើបានពីរសាធនៈគឺ កត្តុសាធនៈនិងភាវសាធនៈប៉ុណ្ណោះ ហើយនិយមប្រើក្នុង ២ សព្ទគឺ* **ជិន** *=អ្នកឈ្នះ,* **សុបិន** *=ការយល់សប្តិ, សុបិន* ។

**ជិន** *វិ.* **(យោ) ជិនាតីតិ (សោ) ជិនោ (ភគវា)** ។ *កត្តុ.កត្តុ.* ។ *សម្រេចមកពី* (**ជិ** + **ឥន**) > **ជិន** *=អ្នកឈ្នះ)* ។

**សុបិន** *វិ.* **(តេន) សុបយតេតិ សុបិនំ** ។ *ភាវ.ភាវ* ។

*ប្រែថា* **តេន** *ដែលគេ* **សុបយតេ** *តែងដេក* **ឥតិ** *ព្រោះហេតុនោះ* **សុបិនំ** *ឈ្មោះថា* **សុបិនំ, សុបិនំ** *ការដេក, ការយល់សប្តិ (សំដៅដល់ការដេក ឬប្រែត្រាប់សព្ទថា* **សុបិន** *នោះឯង)* ។ *សម្រេចមកពី* (**សុប** + **ឥន**) > **សុបិន** ។

*៣.* **ឥក** *បច្ច័យភាគច្រើនជា កត្តុរូប-កត្តុសាធនៈ មានស័ព្ទជាច្រើនដែលកំពុងប្រើដូចជា* **គមិក** *=អ្នកទៅ,* **ឱបនយិក** *=គួរដើម្បីនាំ*

ចូលទៅក្នុងខ្លួន, **ឌីបិកា** =អ្នកភ្លឺស្វាង (ប្រទីប), **មូសិកា** = (កណ្ដុរ) អ្នកលួច, **វិច្ឆិកា** =សត្វខ្ទួយ ។ ស័ព្ទនីមួយ ៗ មានវិគ្គហៈដូចតទៅ នេះ

**គមិកា វិ. ( យោ ) គន្តុំ ភព្វោតិ ( សោ ) គមិកោ ( ភិក្ខុ ) ។**

ប្រែថា (ភិក្ខុណា) ជាអ្នកគួរ ដើម្បីទៅ ព្រោះហេតុនោះ (ភិក្ខុ នោះ) ឈ្មោះថា **គមិកោ** =អ្នកគួរដើម្បីទៅ ។

**គមិកា វិ. ( យោ ) គន្តុំ ឥច្ឆតីតិ ( សោ ) គមិកោ ( ភិក្ខុ )** =អ្នកប្រាថ្នាដើម្បីទៅ ។

**គមិកា វិ. ( យោ ) គច្ឆតីតិ ( សោ ) គមិកោ ( ភិក្ខុ )**=អ្នកទៅ ។ សម្រេចមកពី ( **គម + ឥកា** ) > **គមិកា** ។

**ឱបនយិកា វិ. ( យោ ) អត្តនិ ឧបនេតុំ ភព្វោតិ ( សោ ) ឱបនយិកោ ( ធម្មោ )** ។ (ធម៌ណា) ជាសភាវៈគួរដើម្បីនាំចូលទៅ ក្នុងខ្លួន ព្រោះហេតុនោះ (ធម៌នោះ) ឈ្មោះថា **ឱបនយិកា** =គួរដើម្បីនាំចូលទៅក្នុងខ្លួន ។ សម្រេចមកពីមកពី ( **ឧប + នី + ឥកា** ) > **ឱបនយិកា** ។

**ឌីបិកា វិ. ( យា ) ឌិប្បតីតិ ( សា ) ឌីបិកា ( ធម្មជាតិ ) ។**

(ធម្មជាតិ ណា) តែងភ្លឺស្វាង ព្រោះហេតុនោះ (ធម្មជាតិ នោះ) ឈ្មោះថា **ឌីបិកា** =អ្នកភ្លឺស្វាង (ប្រទីប គោម ពិល) ។ សម្រេចមកអំពី ( **ឌិប + ឥកា** ) > **ឌីបិកា** ចុះ អា បច្ច័យទៅជា **ឌីបិកា** ។

**មូសិកា វិ. ( យោ ) មុសតិ ថេនេតីតិ ( សោ ) មូសិកោ ( សត្តោ ) ។**

(សត្វ ណា) តែងលួច ព្រោះហេតុនោះ (សត្វ នោះ) ឈ្មោះថា **មូសិកោ** =អ្នកលួច (កណ្ដុរ) ។ សម្រេចមកអំពី (**មុស** + **ឥក**) > **មូសិក** ។

**វិច្ឆិក** វិ. (**យោ**) **វិច្ឆតិ យាតីតិ** (**សោ**) **វិច្ឆិកោ** (**សត្តោ**) ។

(សត្វ ណា) តែងទៅ ព្រោះហេតុនោះ (សត្វ នោះ) ឈ្មោះថា **វិច្ឆិកោ** =អ្នកតែងទៅ (ខ្ទួយ) ។ សម្រេចមកពី (**វិច្ឆ** + **ឥក**) > **វិច្ឆិក** ។

**ឥក** បច្ច័យមានពាក្យប្រើតិចទេ ។ សូមប្រយ័ត្នច្រឡំជាមួយនឹង **ណិក** និង **ឥក** បច្ច័យក្នុងតទ្ធិត ដែលមានអធិប្បាយនៅខាងមុខ ។ ចំណុចខុសគ្នាគឺ **ឥក** បច្ច័យក្នុងនាមកិតក:ចុះចុងធាតុ ។ រីឯ **ណិក** ឬ **ឥក** បច្ច័យក្នុងតទ្ធិតវិញចុះចុងនាមស័ព្ទ ដើម្បីជំនួសសេចក្ដីយ៉ាងណាមួយ ។

៤. **ណុក** បច្ច័យជាកត្តុរូប-កត្តុសាធនៈ ចុះក្នុងអត្ថនៃតស្សីលៈ ប៉ុណ្ណោះ ។ បច្ច័យដែលជាប់ដោយតួ **ណ** ត្រូវលុប **ណ** ចេញនៅសល់តែ **ឧក** ហើយត្រូវទីឃៈដើមធាតុ វៀរតែធាតុណាដែលមានស្រៈទីឃៈស្រេចពុំចាំបាច់ទីឃៈទៀតទេ ដូចជា

**ការុក** វិ. (**យោ**) **ករោតីតិ សីលេនាតិ** (**សោ**) **ការុកោ** (**ជនោ**) =អ្នកធ្វើជាប្រក្រតី ។ សម្រេចមកពី (**ករ** + **ណុក**) > **ការុក** ។

**កាមុក** វិ. (**យោ**) **កាមតិ សីលេនាតិ** (**សោ**) **កាមុក**

(ជនោ) =អ្នកប្រាថ្នាជាប្រក្រតី ។ សម្រេចមកពី (**កាម + ណុក**) > **កាមុក** ។

៥. **តេយ្យ** បច្ច័យនេះប្រើបានពីរសាធនៈគឺ កម្មសាធនៈ និង ភាវ-សាធនៈ ។ បច្ច័យនេះមានតួ **ត** មានវិធីប្រកបរូបជាមួយធាតុដូចគ្នានឹង **ត** បច្ច័យនៃកិតកិរិយាដែរ មាន ៣ ប្រការដូចតទៅនេះ

៥.១ ធាតុមួយព្យាង្គ ទុកធាតុឱ្យគង់រូបដើម ឧ.

**ញាតេយ្យ** វិ. (**យំ តេន**) **ញាតព្វន្តិ** (**តំ**) **ញាតេយ្យំ** (**ធម្មជា-តំ**) ។ (ធម្មជាតិណា) ដែលជន គប្បីដឹង ព្រោះហេតុនោះ (ធម្មជាតិនោះ) ឈ្មោះថា **ញាតេយ្យំ** =ដែលជនគប្បីដឹង ។ **ញាតេយ្យ** សម្រេចមកពី (**ញា + តេយ្យ**) > **ញាតេយ្យ** ជាកម្មរូប-កម្មសាធនៈ ។

**ចាតេយ្យ** វិ. (**យំ តេន**) **ចាតព្វន្តិ** (**តំ**) **ចាតេយ្យំ** (**ឧទកំ**) ។

(ទឹកឯណា ដែលជន) គប្បីផឹក ព្រោះហេតុនោះ (ទឹកនោះ) ឈ្មោះថា **ចាតេយ្យំ** =ដែលជនគប្បីផឹក ។ **ចាតេយ្យ** សម្រេចមកពី (**ចា + តេយ្យ**) > **ចាតេយ្យ** ជាកម្មរូប ។

៥.២ ធាតុមានពីរព្យាង្គ ត្រូវផ្លាស់ទីបំផុតធាតុ ឧ.

**បត្តេយ្យ** វិ. (**យំ តេន**) **បត្តព្វន្តិ** (**តំ**) **បត្តេយ្យំ** (**ឋានំ**) ។

(ទីណា ដែលជន) គប្បីដល់ ព្រោះហេតុនោះ (ទីនោះ) ឈ្មោះថា **បត្តេយ្យំ** = ដែលជនគប្បីដល់ ។ សម្រេចមកពី (**បទ + តេយ្យ**) > **បត្តេយ្យ**, ជាកម្មរូប-កម្មសាធនៈ ។

៥.៣ ត្រូវផ្លាស់ ត នៃ តេយ្យ បច្ច័យទៅជារូបផ្សេង ហើយលុបទីបំផុតធាតុដោយអនុលោមតាម ត បច្ច័យនៃកិតកិរិយាដូចតទៅនេះ

ក. បើទីបំផុតធាតុជា ភ ត្រូវផ្លាស់ (ភ + ត) > ទ្ធ ឧ.

**លទ្ធេយ្យ** វិ. (**យំ តេន**) **លភិតព្វន្តិ** (**តំ**) **លទ្ធេយ្យំ** (**វត្ថុ**) ។

(វត្ថុណា ដែលជន) គប្បីបាន ព្រោះហេតុនោះ (វត្ថុនោះ) ឈ្មោះថា **លទ្ធេយ្យំ** =ដែលជនគប្បីបាន ។ **លទ្ធេយ្យ** សម្រេចមកពី (**លភ** + **តេយ្យ**) > **លទ្ធេយ្យ** ជាកម្មរូប-កម្មសាធនៈ ។

ខ. បើទីបំផុតធាតុជា ស ត្រូវផ្លាស់ (ស + ត) > ដ្ឋ ឧ.

**ទដ្ឋេយ្យ** វិ. (**យំ តេន**) **ទដ្ឋព្វន្តិ** (**តំ**) **ទដ្ឋេយ្យំ** (**រូបំ**) ។

(រូបណា ដែលជន) គប្បីឃើញ ព្រោះហេតុនោះ (រូបនោះ) ឈ្មោះថា **ទដ្ឋេយ្យំ** =ដែលជនគប្បីឃើញ ។ **ទដ្ឋេយ្យ** សម្រេចមកពី (**ទិស** + **តេយ្យ**) > **ទដ្ឋេយ្យ**, លុបស្រៈ ឥ នៃធាតុចេញ ។

៦. **តុក** បច្ច័យនេះមិនមានប្រើច្រើនទេ និយមប្រកបជាមួយ **គម** ធាតុក្នុងន័យថា "ទៅ" ដូចជា

**អាគន្តុក** វិ. (**យោ**) **អាគច្ឆតីតិ** (**សោ**) **អាគន្តុកោ** (**ជនោ**)។

(ជនណា) រមែងមក ព្រោះហេតុនោះ (ជននោះ) ឈ្មោះថា **អាគន្តុកោ** =អ្នកមក, អ្នកមកលេង (ភ្ញៀវ) ។ ជាកត្តុរូប-កត្តុសាធនៈ សម្រេចមកពី (**អា** + **គម** + **តុក**) > **អាគន្តុក**, ផ្លាស់ **ម** > **ន** ។

៧. **ម** បច្ច័យប្រើបានគ្រប់សាធនៈ ប្រើប្រកបជាមួយធាតុជាទូទៅ

*សម្រេចជានាមនាមក៏បាន ជាគុណនាមក៏បាន ឱ.*

**ទុម** *វិ.* ( **យោ** ) **ទវតីតិ** ( **សោ** ) **ទុមោ** ( **រុក្ខោ** ) ។

(*ឈើណា*) *កំពុងចម្រើន ព្រោះហេតុនោះ* (*ឈើនោះ*) *ឈ្មោះថា* **ទុមោ** =*អ្នកចម្រើន* (*ឈើ*) ។ *សម្រេចមកពី* ( **ទុ** + **ម** ) > **ទុម** *ជាកត្តុរូប-កត្តុសាធនៈ* ។

**ទុម** *វិ.* ( **យោ តេន** ) **ទុនិយតីតិ** ( **សោ** ) **ទុមោ** ( **រុក្ខោ** ) ។

(*ឈើណា ដែលជន*) *តែងបៀតបៀន ព្រោះហេតុនោះ* (*ឈើនោះ*) *ឈ្មោះថា* **ទុមោ**= *ដែលជនបៀតបៀន* (*ឈើ*) ។ *កម្មរូប-កម្មសាធនៈ* ។

**ថាម** *វិ.* ( **យោ** ) **ឋាតីតិ** ( **សោ** ) **ថាមោ** ( **សភាវោ** ) ។

(*សភាវៈណា*) *រមែងតាំងនៅ ព្រោះហេតុនោះ* (*សភាវៈនោះ*) *ឈ្មោះថា* **ថាមោ** =*អ្នកតាំងនៅ* (*កម្លាំង*) ។ *សម្រេចមកពី* ( **ឋា** > **ថា** + **ម** ) > **ថាម** ។

*មាននាមស័ព្ទជាច្រើនដែលចុះ* **ម** *បច្ច័យនេះដូចជា*

**កម្ម** =*កម្ម, អំពើ ។ សម្រេចមកពី* ( **ករ** + **ម** ) *ផ្លាស់ទីបំផុតធាតុជា* **ម** *តាមបច្ច័យឬថាចុះ* **រម្ម** *បច្ច័យក៏បាន មានអធិប្បាយនៅខាងមុខ* ។

**ខេម** *វិ.* ( **យំ** ) **ខយន្តិ ឯតេន រាគគ្គិអាទយោតិ** ( **សោ** ) **ខេមំ** ( **ធម្មជាតំ** ) ។

(*ធម្មជាតណា*) *ជាគ្រឿង ដែលអស់ទៅនៃភ្លើងគឺភ្លើងរាគៈ ព្រោះហេតុនោះ* (*ធម្មជាតនោះ*) *ឈ្មោះថា* **ខេមំ** =*សេចក្តីក្សេម ។ សម្រេមកពី*

( ខី + ម ) > ខេម ។

**គាម** *វិ.* ( ជនោ ) **គាយន្តិ ឯត្ថាតិ** ( សោ ) **គាមោ** ( បទេសោ ) ។

*(ជន) តែងពោល ក្នុងប្រទេសនោះ ព្រោះហេតុនោះ (ប្រទេសនោះ) ឈ្មោះថា* **គាមោ** *=ស្រុក ។ សម្រេចមកពី* ( **គេ** > **គាយ** + **ម** ) > **គាម**។

**ជម្ម** *វិ.* ( យោ ) **ជាបេតីតិ** ( សោ ) **ជម្មោ** ( *សភាវោ* ) ។

*(សភាវៈណា) តែងទ្រទ្រង់ ព្រោះហេតុនោះ (សភាវៈនោះ) ឈ្មោះថា* **ជម្មោ** *=ធម៌ ។ សម្រេចមកពី* ( **ជរ** + **ម** ) > **ជម្មោ** *ផ្លាស់ទីបំផុតធាតុជា* **ម** *តាមបច្ច័យ ។*

**ជុម** *វិ.* ( យោ ) **ជុជាតីតិ** ( សោ ) **ជុមោ** ( *សភាវោ* ) ។

*(សភាវៈណា) រមែងញាប់ញ័រ ព្រោះហេតុនោះ (សភាវៈនោះ) ឈ្មោះថា* **ជុមោ** *=ផ្សែង ។ សម្រេចមកពី* ( **ជុ** + **ម** ) > **ជុម** ។

**យាម** *វិ.* ( យោ ) **យាតិ គច្ឆតីតិ** ( សោ ) **យាមោ** ( *សភាវោ* ) ។

*(សភាវៈណា) រមែងទៅ ព្រោះហេតុនោះ (សភាវៈនោះ) ឈ្មោះថា* **យាមោ** *=វេលា, យាម ។ សម្រេចមកពី* ( **យា** + **ម** ) > **យាម** ។

*៨.* **រ** *បច្ច័យជាបច្ច័យមានតួ* **រ** *មានអំណាចឱ្យលុបទីបំផុតធាតុនិងលុបតួ* **រ** *ខ្លួនឯងផងដូច* **ណ** *បច្ច័យដែរ ។ បើលុបហើយនៅសល់តែសំឡេង អ ប៉ុណ្ណោះ និយមប្រើជាមួយធាតុមានសទ្ទុបបទនាំមុខដូចជា*

**ភិតក** *វិ.* ( យោ ) **ភិតបច្ចយេន ភិរតីតិ** ( សោ ) **ភិតកោ** ( *សត្តោ* ) ។

(ស័ព្ទណា) រមែងរាត់រាយ ដោយបច្ច័យកិតក: ព្រោះហេតុនោះ (ស័ព្ទនោះ) ឈ្មោះថា **កិតកោ** ។ សម្រេចមកពី **កិត** (សទ្ទុបបទ) + **កិរ** + រ) ជាកត្តុរូប-កត្តុសាធនៈ ។ **កិរ** ធាតុក្នុងសេចក្តីថា រាត់រាយ, ខ្ចាយ, ចុះ រ បច្ច័យ, ព្រោះ រ បច្ច័យនៅខាងចុងត្រូវលុប រ ទីបំផុតធាតុចេញនិងលុប រ បច្ច័យផងដែរហើយនឹងត្រូវលុប ឥ នៃ **កិរ** ចោលទៀតសល់តែ **ក** ។

**អន្តក** វិ. (**យោ**) **អន្តំ ករោតីតិ** (**សោ**) **អន្តកោ** (**សភាវោ**)

(សភាវណា) រមែងធ្វើ នូវទីបំផុត ព្រោះហេតុនោះ (សភាវនោះ) ឈ្មោះថា **អន្តកោ** =អ្នកធ្វើនូវទីបំផុត បាននយ័ថា "សេចក្តីស្លាប់" ។ សម្រេចមកពី (**អន្ត** + **ករ** + រ), ព្រោះ រ បច្ច័យនៅខាងចុងត្រូវលុប រ ទីបំផុតធាតុសល់នៅតែ **ក** ហើយលុប រ បច្ច័យចោលទៀត ជាកត្តុរូប-កត្តុសាធនៈ ។

## កំណត់សម្គាល់

សូមសង្កេតមើលស័ព្ទដែលចុះ រ បច្ច័យហើយលុបបាត់ទៅ ប្រើជាគុណនាមតែម៉្យាង ។ បើប្រើជានាមនាមវិញមិនលុប រ បច្ច័យចោលទេ គឺគង់រូបនៅដូចដែលយើងនឹងជួបក្នុងនាមស័ព្ទទូទៅដូចខាងក្រោមនេះ

**ខីរ** =ទឹកដោះ ( **ខី** + រ ) > **ខីរ** ។

**តីរ** =ច្រាំង ( **តា** + រ ) > **តីរ** ផ្លាស់ **អា** នៃ **តា** ជា **ឦ** ។

**ធីរ** =អ្នកប្រាជ្ញ ( **ធា** + រ ) > **ធីរ** ផ្លាស់ **អា** នៃ **ធា** ជា **ឦ** ។

**នីរ** =ទឹក ( **នី** + រ ) > **នីរ** ។

**វីរ** =អ្នកក្លាហាន, វីរជន ( **វី** + រ ) > **វីរ** ។

**សិរ** =ក្បាល, សីស ( **សិ** + រ ) > **សិរ** ។

**សុរ** =ទេវតា ( **សុ** + រ ) > **សុរ** ។

**សូរ** =អ្នកក្លា, ព្រះអាទិត្យ ( **សូ** + រ ) > **សូរ** ។ល។

៩. **រត្ថុ** បច្ច័យជាបច្ច័យមានតួ **រ** ដែរ បើចុះជាមួយធាតុណាត្រូវលុបទីបំផុតនៃធាតុនោះ ។ ហើយលុប **រ** ទៀតនៅសល់ត្រឹមតែ **ត្ថុ** ឬ **ថុ** ប៉ុណ្ណោះដូចជា

**វត្ថុ** វិ. ( ជនោ ) វសតិ ឯត្ថាតិ ( ឯតំ ) វត្ថុ ( ឋានំ ) ។

(ជនណា) រមែងនៅ ក្នុងទីនោះ ព្រោះហេតុនោះ (ទីនោះ) ឈ្មោះថា **វត្ថុ** =ជាទីនៅនៃជន ។ សម្រេចមកពី (**វស** + **រត្ថុ**) > **វត្ថុ** ជាកត្តុរូប-អធិករណសាធនៈ ។

**សត្ថុ** វិ. ( យោ ) សាសតីតិ ( សោ ) សត្ថា ( ជនោ ) ។

(ជនណា) តែងបង្រៀន ព្រោះហេតុនោះ (ជននោះ) ឈ្មោះថា **សត្ថា** =អ្នកបង្រៀន ។ **សត្ថុ** និយមប្រើជានាមបំបែកជាបឋមាវិភត្តិកត្តុការកៈមានរូបជា **សត្ថា**=ព្រះសាស្តា ។សម្រេចមកពី ( **សាស** + **រត្ថុ** ) > **សត្ថុ** ជា កត្តុរូប-កត្តុសាធនៈ ។

១០. **រម្ម** បច្ច័យជាបច្ច័យមានតួ រ មានគតិដូច **រត្ថុ** បច្ច័យដែរ ។ កាលបើលុប រ បាត់ទៅ នៅសល់តែ ម្ម ឬ ម ដូចជា

**កម្ម** វិ. ( **យំ តេន** ) **កាតព្វន្តិ** ( **តំ** ) **កម្មំ** ( **កិច្ចំ** ) ។

(កិច្ចណា ដែលជន) គប្បីធ្វើ ព្រោះហេតុនោះ (កិច្ចនោះ) ឈ្មោះថា **កម្មំ** =ដែលជនគប្បីធ្វើ (កម្ម, អំពើ) ។ សម្រេចមកពី ( **ករ** + **រម្ម** ) > **កម្ម**, លុបទីបំផុតធាតុនិងលុប រ ជាកម្មរូប-កម្មសាធនៈ ។

**ធម្ម** វិ. ( **យោ** ) **ធារេតីតិ** ( **សោ** ) **ធម្មោ** ( **សភាវោ** ) ។

(សភាវៈណា) តែងទ្រទ្រង់ ព្រោះហេតុនោះ (សភាវៈនោះ) ឈ្មោះថា **ធម្មោ** =អ្នកទ្រទ្រង់ (ធម៌) ។ សម្រេចមកពី ( **ធរ** + **រម្ម** ) > **ធម្ម**, ជាកត្តុរូប-កត្តុសាធនៈ ។

ទាំងពីរស័ព្ទនេះប្រើជានាមនាមនិយមប្រែត្រាប់ស័ព្ទថា កម្ម, ធម្ម= ធម៌, ព្រះធម៌, ជា អ ការន្តបុំលិង្គនិងនបុំសកលិង្គ ។

១១. **រិច្ច** បច្ច័យជាបច្ច័យមានតួ រ បើលុប រ បាត់ទៅហើយនៅសល់តែ **ឥច្ច** មានអំណាចលុបទីបំផុតធាតុបាន និងនិយមចុះជាមួយ **ករ** ធាតុ មួយប៉ុណ្ណោះ

**កិច្ច** វិ. ( **យំ តេន** ) **កាតព្វន្តិ** ( **តំ** ) **កិច្ចំ** ( **កម្មំ** ) ។

(អំពើណា ដែលជន) គប្បីធ្វើ ព្រោះហេតុនោះ (អំពើនោះ) ឈ្មោះថា **កិច្ចំ** =ដែលជនគប្បីធ្វើ ។ សម្រេចមកពី ( **ករ** + **រិច្ច** ) > **កិច្ច** ជាកម្ម.កម្ម., ជា អ ការន្តនបុំសកលិង្គបំបែកតាមវិភត្តិនានាដូច **កុល** ។

១២. **រិតុ** បច្ច័យមានគតិដូច **រិច្ច** បច្ច័យដែរគឺត្រូវលុប រ ចេញនៅសល់តែ **ឥតុ** ហើយអាចលុបទីបំផុតជាតុទៀតដូចជា

**ជីតុ វិ. ( យា មាតាបិតូហិ ) ជរីយតេតិ ( សា ) ជីតា ( ឥត្ថី ) ។**

(ស្រីណា ដែលម្តាយនិងឪពុកទាំងឡាយ) តែងទ្រទ្រង់ ព្រោះហេតុនោះ (ស្រីនោះ) ឈ្មោះថា **ជីតា** =អ្នកដែលម្តាយនិងឪពុកទ្រទ្រង់ (ធីតាឬកូនស្រី)។ សម្រេចមកពី ( **ជរ** + **រិតុ** ) > **ជីតុ** (លុបទីបំផុតជាតុនិងទីឃៈ ឥ នៃ **រិតុ** ជា ឦ) ជាកម្មរូប-កម្មសាធនៈ មានវិធីបំបែកដូច **មាតុ** ស័ព្ទ ។

**បិតុ វិ. ( យោ ) ( បុត្តំ ) ចាតីតិ ( សោ ) បិតា ( បុរិសោ ) ។**

(បុរសណា) តែងរក្សា (នូវបុត្រ) ព្រោះហេតុនោះ (បុរសនោះ) ឈ្មោះថា **បិតា** =អ្នករក្សានូវបុត្រ (បិតាឬឪពុក) ។

និយមប្រើជានាមនាមនិងប្រែត្រាប់ស័ព្ទថា បិតា ។ សម្រេចមកពី ( **ចា** + **រិតុ** ) > **បិតុ** (លុប **អា** នៃ **ចា**) ជាកត្តុរូប-កត្តុសាធនៈ ។

១៣. **រិរិយ** បច្ច័យជាបច្ច័យមានតួ រ ដូចគ្នាដែរដែលត្រូវលុប រ ចេញនៅសល់តែ **ឥរិយ** ហើយក៏ត្រូវលុបទីបំផុតជាតុដែរ និយមប្រើជាមួយ **ករ** ធាតុដូចជា

**កិរិយា វិ. ( យំ តេន ) កាតព្វន្តិ ( សា ) កិរិយា ( ធម្មជាតិ ) ។**

(ធម្មជាតិណា ដែលជន) គប្បីធ្វើ ព្រោះហេតុនោះ (ធម្មជាតិនោះ) ឈ្មោះថា **កិរិយា** =ដែលជនគប្បីធ្វើ ។

បើជាការសាធនៈមានវិគ្គហៈថា **ករណំ កិរិយា**=ការធ្វើ ឈ្មោះថា **កិរិយា** ។ សម្រេចមកពី ( **ករ** + **រិយ** ) > **កិរិយ** (ចុះ **អា** បច្ច័យ និងជាកម្មរូប-កម្មសាធនៈ ។

១៤. **រាតុ** បច្ច័យមានគតិដូចបច្ច័យដែលមានតួ **រ** ឯទៀត ៗ ដែលពោលហើយខាងលើ គឺត្រូវលុប **រ** នៅសល់តែ **អាតុ** និងអាចលុបទីបំផុតធាតុបានដូចជា

**ភាតុ** វិ. ( **យោ** ) ( **បុព្វេ** ) **ភាសតីតិ** ( **សោ** ) **ភាតា** ( **ជនោ** ) ។

(ជនណា) តែងពោល (ក្នុងកាលមុន) ព្រោះហេតុនោះ (ជននោះ) ឈ្មោះថា **ភាតា** =អ្នកពោលមុន គឺ បងប្រុស ។ សម្រេចមកពី ( **ភាស** + **រាតុ** ) > **ភាតុ** ជាកត្តុរូប-កត្តុសាធនៈ (លុប **ស** ទីបំផុតធាតុចេញនៅសល់តែ **ភា** ) ។ កាលបើមានស្រៈពីរតួស្មើគ្នាត្រូវលុបស្រៈមួយតួចេញសិន មុនធ្វើសន្ធិបានជា **ភាតុ** ។ ពាក្យថា **ភាតុ** និយមប្រើជានាមនាម ប្រែថា "បងឬប្អូនប្រុស" បើចង់បំបែកជាបឋមាវិភត្តិពហុវចនៈ ទៅជា **ភាតរោ** ប្រែថា "បងប្អូនប្រុសទាំងឡាយ" ដូចប្រយោគឧទាហរណ៍ថា **បរលោកំ គច្ឆន្តំ បុត្តធីតរោ វា ភាតរោ វា ភោគា វា ឧានុគច្ឆន្តិ** ។ បុត្រនិងធីតា.ទ. ក្តី បងប្អូនប្រុស.ទ. ក្តី ទ្រព្យ.ទ. ក្តី តែងមិនជាប់ទៅតាមនូវបុគ្គលដែលទៅកាន់ បរលោក (បានទេ) ។

បើចង់ឱ្យមានសេចក្តីច្បាស់ជាងនេះត្រូវថែមសព្ទផ្សេងនៅខាងដើមដូច្នេះ

**ជេដ្ឋ** *(ប្រសើរបំផុត)* + **ភាតុ** > **ជេដ្ឋភាតុ** *=បងប្រុស*

**កនិដ្ឋ** *(តូចបំផុត)* + **ភាតុ** > **កនិដ្ឋភាតុ** *=ប្អូនប្រុស*

**មាតុ** *វិ.* **( យា ) ( ជម្មេន បុត្តំ ) មានេតីតិ ( សា ) មាតា ( ឥត្ថី )** ។

*(ស្ត្រីណា) តែងរាប់រក (នូវបុត្រ ដោយធម៌) ព្រោះហេតុនោះ (ស្ត្រីនោះ) ឈ្មោះថា* **មាតា** *=អ្នករាប់រកនូវកូន (ម្ដាយ) ជាកត្តុ.កត្តុ.* ។

*សម្រេចមកពី* **( មាន + រាតុ ) មាតុ** *(លុប* **ន** *ទីបំផុតធាតុ)* ។ *ស័ព្ទនេះនិយមប្រែត្រាប់ស័ព្ទថា មាតា ជានាមនាមមានវិធីបំបែកក្នុងរូបវិកត្តិនានាដូចមាននៅក្នុងភាគ ១ ចូររកមើលត្រង់* **បិតុ, មាតុ** *ស័ព្ទ* ។

## កំណត់សម្គាល់

*បច្ចេកបច្ច័យទាំងឡាយនេះនៅមានច្រើនទៀត បើនឹងយកមកអធិប្បាយឱ្យអស់ ក្រែងបណ្ដាលឱ្យមានភាពស្រពិចស្រពិល ទើបបានពោលតែបច្ច័យណាដែលកំពុងមានប្រើនិងបានជួបប្រទះញយ ៗ ដូចប្រាកដមានរួចហើយនៅខាងលើនេះ ។ ដើម្បីឱ្យជ្រាបដើមនិងចុងហេតុថាស័ព្ទនោះ ៗ សម្រេចមកពីធាតុនិងបច្ច័យអ្វី គ្រាន់តែអានចុះឡើង ៗ ឱ្យបានច្រើនដងទៅ គឺឱ្យយល់ចូលចិត្ត នោះនឹងកើតជំនាញជ្រាបចូលក្នុងខ្លួនដក់ជាប់ក្នុងចិត្តពុំខាន គឺពុំចាំបាច់ទន្ទេញទេ ។*

ចំពោះរឿងនាមកិតកៈនេះ មានចំណុចខ្លី ៗ គួរចងចាំទុក គឺថា

១. គួរចាំឈ្មោះសាធនៈទាំង ៧ ឱ្យបាន ។

២. ចាំបច្ច័យមួយតួ ៗ ទាំង ៣ ពួកឱ្យបានច្បាស់លាស់ ។

៣. ចាំវិធីចុះបច្ច័យមួយតួ ៗ និងត្រូវចាំថាបច្ច័យណាធ្វើឱ្យធាតុផ្លាស់ប្តូររូបទៅជាយ៉ាងណាខ្លះ ។

៤. គួរចាំរបៀបតាំងវិគ្គហៈនិងវិធីប្រែត្រឹមតែ ៧ បែបក៏គ្រប់គ្រាន់ ។

ចំពោះវិគ្គហៈគំរូទាំងឡាយដែលលើកយកមកបង្ហាញយ៉ាងច្រើននោះ គឺគ្រាន់តែអធិប្បាយប្រកបដោយគោលសំខាន់ ៗ ប៉ុណ្ណោះ ដើម្បីឱ្យអ្នកដែលសិក្សាដោយខ្លួនឯងបានពិចារណា និងគប្បីអានចុះឡើង ៗ ឱ្យបានច្រើនដងរហូតកើតការយល់ចូលចិត្ត ។ លុះដល់កាលបានជួបក្នុងទីណាមួយក៏ដោយអាចចាប់ចំណុចសំខាន់នៃពាក្យនោះ ៗ ហើយយល់ថាមានសេចក្តីយ៉ាងណា និងអាចប្រែបានភ្លាម ។

**(ចប់បច្ចេកបច្ច័យត្រឹមនេះ)**

# នាមស័ព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| សន្និចយ បុំ. | ការសន្សំ |
| កម្មសន្និចយ បុំ. | ការសន្សំនូវកម្ម |
| បច្ចយសន្និចយ បុំ. | ការសន្សំនូវបច្ច័យ |
| និកាយ បុំ. | ពួក, ក្រុម, និកាយ |
| តេបិដក នបុំ. | ព្រះត្រៃបិដក |
| កថន នបុំ. | ការពោល |
| អករណ នបុំ. | កិរិយាមិនធ្វើ |
| សព្វបាប នបុំ. | បាបទាំងពួង |
| កុម្មាស បុំ. | នំកុម្មាស |
| កុហក បុំ. | អ្នកកុហក |
| បុនទិវស បុំ. | ក្នុងថ្ងៃស្អែក |
| សញ្ញោជន នបុំ. | ការប្រកប, ការចង |
| ធុរ នបុំ. | ធុរៈ |
| ឧន្នឡ គុ. | មានមានះ |
| មាមក គុ. | អ្នករាប់រក |
| បញ្ញានុរូប គុ. | សមគួរដល់ប្រាជ្ញា |
| សកល គុ. | ទាំងអស់, ទាំងស្រុង |
| និរុបធិ គុ. | ដែលមិនមានឧបធិ |

អកិញ្ចន គុ. មិនមានកិលេស

ស្វាតន គុ. នឹងមានក្នុងថ្ងៃស្អែក

អត្តភាវ បុំ. ភាពនៃខ្លួន, អត្តភាព

ថទ្ធ គុ. រឹងប៉ឹង, រឹងរូស

លប បុំ. អ្នកនិយាយឥតបានការ

សិង្គី គុ. អ្នកមានស្នែង, វាងវៃ

ញាតិទាសី ឥ. នាងបំរើជាញាតិ

ឆឌ្ឌេតុកាម បុំ. ប្រាថ្នាដើម្បីបោះចោល

អភិទោសិក បុំ. យប់នៃថ្ងៃម្សិល

ព្រហ្មទេវ បុំ. ទេវតាក្នុងឋានព្រហ្ម

អតិទេវ បុំ. ទេវតាជាប្រមុខ

អតិទេវបុត្ត បុំ. បុត្រនៃទេវតាជាប្រមុខ

អនញ្ញោបាសី បុំ. អ្នកមិនចិញ្ចឹមអ្នកដទៃ

ពុទ្ធប្បមុខ នបុំ. មានព្រះពុទ្ធជាប្រធាន

និរុបធិក បុំ. អ្នកមិនមានកិលេស

វេសាលិក បុំ. អ្នកស្រុកវេសាលី

បាតលិបុត្តក បុំ. អ្នកស្រុកបាតលីបុត្រ

អង្គក បុំ. ដែនអង្គៈ

អង្គកនាគរ បុំ. អ្នកនគរអង្គៈ

សហត្ថ បុំ. ដៃនៃខ្លួន

កាតិ និ. ប៉ុន្មាន, ចំនួនប៉ុន្មាន

ធារណា នបុំ. ការទ្រទ្រង់, ការចេះចាំ

កុសលាកុសលកម្ម នបុំ. កម្មជាកុសលនិងអកុសល

សល្លហុកវុត្តី គុ. អ្នកមានកិរិយាប្រព្រឹត្តស្រាល

បន្តសេនាសនាភិរត គុ. អ្នករីករាយក្នុងសេនាសនៈដ៏ស្ងាត់

ខយវយ បុំ. កិរិយាអស់ទៅនិងកិរិយាសូន្យទៅ

សាតច្ចកិរិយាវស បុំ. សមត្ថភាពនៃការធ្វើបន្តគ្នា

វិបស្សនា ឥ. បញ្ញាជាគ្រឿងឃើញច្បាស់

វិបស្សនាធុរ នបុំ. ធុរៈគឺការចម្រើនវិបស្សនា

អរហត្តគ្គហណ នបុំ. កិរិយាកាន់យកនូវព្រះអរហត្ត

អសមាហិត គុ. មិនជាអ្នកមានចិត្តដំកល់មាំ

សចិត្តបរិយោទបន នបុំ. ការធ្វើចិត្តនៃខ្លួនឱ្យល្អស្អាត

អរិយមគ្គញាណគ្គិ បុំ. ភ្លើងគឺអរិយមគ្គញាណ

សោតាបត្តិផល នបុំ. សោតាបត្តិផល

កុសលស្សូបសម្បទា ឥ. ការញ៉ាំងកុសលឲ្យដល់ព្រម

## ធាតុស័ព្ទ (ត)

| ធាតុសព្ទ | ពាក្យប្រែ | ធាតុសព្ទ | ពាក្យប្រែ |
|---|---|---|---|
| ឌហ | ឆេះ, ដុត, រលាក | បរិ + វិស | អង្គាស, ថ្វាយ |
| វឌ្ឍ | ចម្រើន | ប + ហា | តម្កល់ទុក, តាំងទុក |
| សំ+ប+វរ | ថ្វាយ, ប្រគេន | សំ + តប្ប | រីករាយ, ពេញចិត្ត |

## លំហាត់នៃមេរៀនទី ៣៧

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើបច្ចេកបច្ច័យមានប៉ុន្មានតួ គឺអ្វីខ្លះ ?

២. តើបច្ច័យមានតួ រ វេលាចុះខាងចុងធាតុតើត្រូវធ្វើដូចម្ដេចខ្លះ ?

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. ទ្វេ សន្និចយា កម្មសន្និចយោ ច បច្ចយសន្និចយោ ច តេសុ (សន្និចយេសុ) កុសលាកុសលកម្មំ កម្មសន្និចយោ នាម ។

២. ចត្តារោ បច្ចយា បច្ចយសន្និចយោ នាម ។

៣. ឥមស្មឹ សាសនេ កតិ ធុរានិ? ទ្វេ ធុរានិ គន្ថធុរំ វិបស្សនាធុរំ។ កតមំ បន គន្ថធុរំ ? កតមំ វិបស្សនាធុរំ ?

៤. អត្តនោ បញ្ញានុរូបេន ឯកំ វា ទ្វេ វា និកាយេ សកលំ វា បន តេបិដកំ ពុទ្ធវចនំ ឧគ្គណ្ហិត្វា តស្ស ធារណំ កថនំ វាចនន្តិ

(វាចនំ + ឥតិ) ឥទំ គន្ថធុរំ នាម ។

៥. សល្លហុកវុត្តិនោ បន បន្តសេនាសនាភិរតស្ស អត្តភាវេ ខយវយំ បដ្ឋបេត្វា សាតច្ចកិរិយាវសេន វិបស្សនំ វឌ្ឍេត្វា អរហត្តគ្គហណន្តិ (អរហត្តគ្គហណំ + ឥតិ) ឥទំ វិបស្សនាធុរំ នាម ។

៦. ឯកោបិ ខោ សេដ្ឋី សត្ថារំ ឧបសង្កមិត្វា ធម្មំ សុត្វា សោតាបត្តិផលេ បតិដ្ឋាយ ស្វាតនាយ និមន្តេត្វា បុនទិវសេ អត្តនោ និវេសនេ បណីតេន ខាទនីយេន ភោជនីយេន ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បរិវិសិត្វា ឯតេន ឧបាយេន អឌ្ឍមាសំ មហាទានំ អទាសិ ។

៧. ឯវំ អរិយមគ្គញាណគ្គិនាបិ មហន្តានិ ច ខុទ្ទកានិ ច សញ្ញោជនានិ ឌហន្តេន គន្តព្វំ ភវិស្សតិ ។

៨. សព្វបាបស្ស អករណំ   កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ   ឯតំ ពុទ្ធាន សាសនំ ។
(កុសលស្ស + ឧបសម្បទា)

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ម្នាលភិក្ខុ.ទ. ភិក្ខុ.ទ. ណា ជាអ្នកកុហក ជាអ្នករឹងរូស ជាអ្នកនិយាយ ជាអ្នកមានស្នែង ជាអ្នកមានមានៈ មិនជាអ្នកមានចិត្តដម្កល់មាំ ភិក្ខុ.ទ. នោះ មិនជាអ្នកជាទីស្រឡាញ់ របស់យើង(តថាគត)ទេ ។*

២. ក៏ ក្នុងសម័យ នោះ ទាសីជាញាតិ របស់រដ្ឋបាល ដ៏មានអាយុ ប្រាថ្នា ដើម្បីបោះចោល នូវនំកុម្មាស ដែលចម្អិនហើយ ក្នុងយប់ថ្ងៃម្សិល ។

៣. ក៏ ក្នុងសម័យ នោះ ពួកសក្យៈ.ទ. អ្នកនគរចាតុមា បានជួបប្រជុំ ហើយ ក្នុងរោងទទួលភ្ញៀវ ។

៤. ក៏ ព្រហ្មទេវ នេះ ក្នុងបណ្ដាព្រហ្ម.ទ. នោះ បុត្ររបស់ទេវតាជា ប្រមុខ(ព្រះពុទ្ធ) អ្នកមិនមាន កិលេស ឈ្មោះឧបធិ ភិក្ខុ អ្នកមិន-ចិញ្ចឹមអ្នកដទៃ បានចូលទៅហើយ កាន់ផ្ទះ របស់អ្នក ក្នុងទីនេះ ដើម្បីដុំបាយ ។

៥. កាលនោះ គហបតី ទសមៈ ជាអ្នកនគរអដ្ឋកៈ បានឱ្យប្រជុំហើយ នូវភិក្ខុ.ទ. អ្នកស្រុកបាតលិបុត្រ ផង អ្នកស្រុកវេសាលី ផង ថ្វាយ ហើយ ដោយវត្ថុគឺបុគ្គលគប្បីបរិភោគ(ភោជន) ដោយវត្ថុគឺបុគ្គល គប្បីទំពារស៊ី (បង្អែមឬចំណី) ដែលប្រណីត ដោយដៃ.ទ.របស់ លោក (រហូតភិក្ខុ.ទ.) ពេញព្រះទ័យហើយ (ប្រកែកមិនទទួលយក ទៀត) ។

**(ចប់មេរៀនទី ៣៧)**

# មេរៀនទី ៣៨

# អធិប្បាយអំពីនាមកិតក: (តចប់)

## វិធីសង្កេតបច្ច័យនៃនាមកិតក:មួយតួ ៗ

*បច្ច័យទាំងឡាយក្នុងនាមកិតក: ដែលពោលហើយទាំងអស់នេះ មានច្រើនតួគឺពិបាកដល់ការចងចាំ ។ ដើម្បីឱ្យងាយចាំបាន សូមសង្កេតមើលនិងធ្វើការកត់ចំណាំដូច្នេះថា មានបច្ច័យ ២ ប្រភេទគឺ មួយប្រភេទវេលាចុះរួចហើយត្រូវលុបបាត់ទៅ និងមួយប្រភេទទៀតមិនលុបទេ ។*

១. **ប្រភេទដែលត្រូវលុបបាត់រូបទៅ** *បានដល់* **ក្វិ**, **ណី**, **ណ្វុ**, **រូ**, **ខ**, **ណ្យ**, **ណ**, **យុ** (*វៀរតែ* **ណ្យ** *បច្ច័យបើលុប* **ណ** *មាន* **យ** *គង់រូបនៅហើយផ្លាស់ទីបំផុតធាតុនិង* **យ** *ឱ្យទៅជារូបផ្សេង ៗ បានច្រើនយ៉ាងដូចបានអធិប្បាយរួចហើយនោះ*) ។

២. **ប្រភេទដែលមិនលុបគឺទុកឱ្យគង់រូប** *គឺថា បើលុបបច្ច័យតួដើមបាត់ទៅហើយ ត្រូវតែមានតួថ្មីមកជំនួសវិញ មាន ៩ តួគឺ* **អ**, **ឿ**, **ឩ**, **អក**, **អន**, **អាននក**, **អណ**, **អនន** *។ ពួកនេះសម្រាប់ប្រើជំនួសពួកបច្ច័យដែលត្រូវលុបបាត់ទៅក្នុងចំណុចលេខ ១ ខាងលើនិង* **ត**, **តវេ**, **តិ**, **តុ**, **តុំ** *ដែលរក្សារូបដើម ។ ពួកថ្មី ៩ តួនេះ បើចុះជាមួយធាតុណាមួយក៏នឹងប្រាកដរូបរាងឱ្យអាចសង្កេតឃើញយ៉ាងងាយដែលមិនត្រូវបានផ្លាស់ប្តូរ*

តទៅទៀតទេ ។ បន្ទាប់នេះមានចំណុចសំខាន់ដែលត្រូវដឹងទៀត គឺថា តើបច្ច័យតួណាប្រើជំនួសបច្ច័យណា ? ដូចមានវិធីសង្កេតតទៅនេះ

## អ បច្ច័យតួពិត

អ នេះជាបច្ច័យតួពិតប្រើប្រកបជាមួយធាតុបានទូទៅ មានសព្ទដទៃជាសទ្ទុបបទក៏បាន មិនមានក៏បានដែរ និងពុំចាំបាច់ទីឃៈស្រៈដើមធាតុឬផ្លាស់ប្តូរទៅជាអ្វីឡើយ ដូចខាងក្រោមនេះ

(**កាម** + **ឱ** + **ចរ** + **អ**) > **កាមាវចរ** =ដែលជាទីត្រាច់ចុះក្នុងកាមភព, មានវិគ្គហៈថា **កាមោ អវចរតិ ឯត្ថាតិ កាមាវចរោ** (**លោកោ**) ។

(**ជិន** + **ករ** + **អ**) > **ជិនករ** =អ្នកធ្វើនូវថ្ងៃ (ព្រះអាទិត្យ), មានវិគ្គហៈថា (**យោ**) **ជិនំករោតីតិ** (**សោ**) **ជិនករោ** (**សភាវោ**) ។

(**ធម្ម** + **ធរ** + **អ**) > **ធម្មធរ** =អ្នកទ្រទ្រង់នូវធម៌, មានវិគ្គហៈថា (**យោ**) **ធម្មំ ធរតីតិ** (**សោ**) **ធម្មធរោ** (**ជនោ**) ។

ពាក្យថា **វិនយធរ** =អ្នកទ្រទ្រង់នូវវិន័យ, មានវិគ្គហៈដូច **ធម្មធរ** ដែរ ។

ការប្រែវិគ្គហៈចូររកមើលគំរូនៃសាធនៈនោះ ៗ ដែលបានអធិប្បាយនៅខាងដើម ។

# ណ បច្ច័យតួជំនួស

ណ បច្ច័យតួជំនួសនេះជាតួថ្មីប្រើជំនួសបច្ច័យ ៣ តួគឺ **ក្វិ**, **ខ**, **ណ** ព្រោះបច្ច័យបីតួនេះត្រូវលុបបាត់ទៅសល់នៅតែសំឡេងស្រៈ អ ចូលមកជំនួស ដូច្នេះ ក៏មានអំណាចទីឃៈស្រៈដើមធាតុ ឬក៏ផ្លាស់ទីបំផុតធាតុបានតាមអំណាចរបស់ **ក្វិ**, **ខ**, **ណ** គឺ

១. បើប្រើជំនួស **ក្វិ** បច្ច័យ មានចំណុចសំខាន់ឱ្យសង្កេតឃើញបានដូច្នេះ

ក. មានសទ្ទុបបទនាំមុខជានិច្ចដូចជា **<u>តុរ</u>គ**, **<u>ភុជ</u>គ** ។

ខ. បើជាធាតុទោល និងមានឧបសគ្គនាំមុខតែងទុកធាតុឱ្យគង់រូបដូច **សយ<u>ម្ភូ</u>**, **អភិ<u>ភូ</u>** ។

គ. បើជាធាតុពីរតួ តែងលុបទីបំផុតធាតុចេញដូចជា **តុរគ**, **ភុជគ**, **ឧរគ** មកពី **គ<u>ម</u>** ធាតុទាំងអស់ ។ សព្ទទាំងបីនេះត្រូវបានលុប **ម** ចេញបាត់ហើយ ។

ឃ. ចំពោះ **វិធ** ធាតុត្រូវចុះ **ឱ** អាគមឬ **រូ** បច្ច័យជំនួសឬនឹងហៅថាចុះ **ឱ** បច្ច័យក៏បានដែរ ។

២. បើប្រើជំនួស **ខ** មានចំណុចដែលអាចឱ្យស្គាល់បាន គឺត្រូវតែមានសព្ទ ៣ ម៉ាត់គឺ **ទុ**, **សុ**, **ឦសំ** នៅខាងដើមនិងពុំចាំបាច់ទីឃៈស្រៈដើមធាតុទេដូចជា

(ទុ + រក្ខ + ខ) > **ទុរក្ខ វិ. ទុក្ខេន រក្ខិយតីតិ <u>ទុ</u>រក្ខំ (ចិត្តំ)**

=(ចិត្ត) ដែលបុគ្គលរក្សាបានដោយលំបាក ។

(សុ + ករ + ខ) > សុករ វិ. សុខេន ករិយតីតិ សុករំ (កម្មំ) =(អំពើ) គឺបុគ្គលធ្វើបានដោយងាយ ។

(ឦសស្សយ + ខ) > ឦសស្សយ វិ. ឦសំ សីយតេតិ ឦសស្សយោ ឬ ឦសំ សយនំ ឦសស្សយោ =ការដេកតិចតួច ។ មកពី (ឦស + សី) ផ្លាស់ស្រៈ ឦ លើ សី ជា អយ, ហើយតម្រួត ស ជា ស្ស) ។

ពាក្យថា ទុក្ករោ, សុករោ, សុវចោ ក៏មានវិគ្គហៈដូចគ្នានឹងខាងលើនេះដែរ ។

៣. បើប្រើជំនួស ណ មានគោលការណ៍ថា ណ ត្រូវតែលុបចោលគ្រប់កាល ។ ដូច្នេះមានអំណាចទីឃៈនឹងផ្លាស់ប្តូរទីបំផុតធាតុឱ្យទៅជាផ្សេង ៗ បានដូចជា

(កម្ម + ករ + ណ) > កម្មការ

វិ. (យោ) កម្មំ ករោតីតិ (សោ) កម្មការោ (ជនោ) =អ្នកធ្វើនូវការងារ ។

(សុវណ្ណ + ករ + ណ) > សុវណ្ណការោ

វិ. (យោ) សុវណ្ណំ ករោតីតិ (សោ) សុវណ្ណការោ (ជនោ) =អ្នកធ្វើមាស, ជាងមាស ។

(ចជ > ចគ + ណ) > ចាគ វិ. ចជនំ ចាគោ =ការលះ ។

ដូច្នេះឃើញថា ឱរក (ចុះ ក្វិ បច្ច័យក្តី), ឧក្ការ (ចុះ ខ បច្ច័យក្តី), សុវណ្ណការ (ចុះ ណ បច្ច័យក្តី) សុទ្ធតែមានទីបំផុតជាស្រៈ អ ។ រីឯ ក្វិ, ខ, ណ បច្ច័យមិនមានរូបឱ្យឃើញទេ មានតែសំឡេងប៉ុណ្ណោះ ។

សូមពិនិត្យមើលសាឡើងវិញដើម្បីឱ្យឃើញច្បាស់ពីភាពខុសគ្នានៃបច្ច័យទាំង ៣ តួ ពីដើមគឺ ក្វិ, ខ, ណ ។

## ២. ឦ បច្ច័យតួជំនួស

ឦ បច្ច័យនេះជាតួជំនួស ណី បច្ច័យ ។ ដោយសារ ណី បច្ច័យត្រូវលុបតួ ណ បាត់ទៅ នៅសល់តែស្រៈ ឦ កាលបើចុះជាមួយធាតុណាមួយ មានអំណាចឲ្យទីឃៈឬផ្លាស់ប្តូរធាតុទៅជារូបផ្សេង ៗ ទៀត ដូចតួ អ ប្រើជំនួស ណ បច្ច័យគ្រប់ប្រការដូចជា

(ព្រហ្ម + ចរ + ណី) > ព្រហ្មចារី

វិ. ព្រហ្មំ ចរតិ សីលេនាតិ ព្រហ្មចារី =អ្នកប្រព្រឹត្តនូវព្រហ្មចរិយៈដោយប្រក្រតី (កត្តុ. តស្សី) ។ ឬតាំងវិគ្គហៈថា

ព្រហ្មំ ចរតិ សីលមស្សាតិ ព្រហ្មចារី =អ្នកមានប្រក្រតីប្រព្រឹត្តនូវព្រហ្មចរិយៈ (សមា. តស្សី) ។

ពាក្យថា កាយានុបស្សី មកពី (កាយ + អនុ + ទិស + ណី) =អ្នកមានប្រក្រតីពិចារណាឃើញកាយ ។ ពាក្យថា ធម្មវាទី, សច្ចវាទី,

**បណ្ឌិតមានី**, **មាលាការី**, **បរវាទី** ក៏មានវិធីប្រកបរូបដូច **ព្រហ្មចារី** គ្រប់ប្រការ ។ ចំពោះតួ **ឦ** បច្ច័យឬ **ឦ** ការន្តអាចប្រព្រឹត្តទៅបាន ៣ លិង្គ ។ បើជានបុំសកលិង្គត្រូវរស្សៈ **ឦ** > **ឥ**, បើជាឥត្ថីលិង្គត្រូវចុះ **ឥនី** ដូចខាងក្រោមនេះ

| | | | | |
|---|---|---|---|---|
| បុំ. | ជា | **បណ្ឌិតមានី** | បំបែកតាមបែប | **សេដ្ឋី** |
| នបុំ. | ជា | **បណ្ឌិតមានិ** | បំបែកតាមបែប | **អក្ខិ** |
| ឥត្ថី. | ជា | **បណ្ឌិតមានិនី** | បំបែកតាមបែប | **ជារី** |

## ៣. ឩ បច្ច័យតួជំនួស

**ឩ** ប្រើជំនួស **រូ** បច្ច័យ ។ ព្រោះតែតួ **រ** ត្រូវលុបបាត់ទៅនៅសល់តែស្រៈ **ឩ** ដូចជា (**វិទ** + **រូ**) > **វិទូ** មានវិគ្គហៈថា **វិទតីតិ វិទូ**=អ្នកបេះ, អ្នកប្រាជ្ញ ។ ពាក្យថា **លោកវិទូ**, **សព្វវិទូ** ក៏មានគតិដូចគ្នា ។

## ៤. អក, អានក បច្ច័យតួជំនួស

**អក** និង **អានក** ជាតួជំនួស ប្រើជំនួស **ណ្វុ** បច្ច័យ ព្រោះលោកប្រាប់ថាត្រូវផ្លាស់ **ណ្វុ** បច្ច័យជា **អក** និង **អានក** ។ ចូរមើលត្រង់ **ណ្វុ** បច្ច័យនៅខាងដើម ។ កាលបើ **អក** និង **អានក** ជាតួ

ជំនួសរបស់ **ណ្វុ** នុំះ គឺមានអំណាចទីឃៈស្រៈដើមធាតុក៏បាន មិនបាច់ទីឃៈស្រៈក៏បាន ផ្លាស់ប្តូរធាតុឱ្យមានរូបផ្សេង ៗ ក៏បាន ព្រោះជាបច្ច័យដែលមានតួ ណ ជាពិសេសច្រើនប្រើក្នុងរូបជាកត្តុសាធនៈដូចជា

(**ធា** > **ធាយ** + **ណ្វុ**) > **ធាយក** =អ្នកឱ្យ ។

(**ធី** > **ធាយ** + **ណ្វុ**) > **ធាយក** =អ្នកនាំទៅ, អ្នកដឹកនាំ ។

សូម្បីពាក្យថា **ឧបាសក** ក៏សម្រេចមកពី **ណ្វុ** បច្ច័យដែរគឺ

(**ឧប** + **អាស** (អង្គុយ) + **ណ្វុ**) > **ឧបាសក**,

វិគ្គហៈថា (**យោ**) **រតនត្តយំ ឧបាសតីតិ** (**សោ**) **ឧបាសកោ** (**ជនោ**) ប្រែថា អ្នកចូលទៅអង្គុយជិតព្រះរតនត្រ័យ, ឧបាសក (ទីឃៈដើមធាតុជា **អា**) ។ បើជាឥត្ថីលិង្គត្រូវចុះ **អា** បច្ច័យនិងចុះ **ឥ** អាគមសម្រេចបានជា **ឧបាសិកា** មានវិគ្គហៈដូចគ្នា ។ ដូច្នេះជនណាឈ្មោះថា ឧបាសក, ឧបាសិកា ជាអ្នកអង្គុយជិតព្រះរតនត្រ័យគ្រប់វេលា ។

រីឯ **អក** ដែលចុះជាមួយ **ជន** ធាតុមិនបាច់ទីឃៈស្រៈទេ ទុកធាតុឱ្យគង់រូបដើមដូច (**ជន** + **ណ្វុ**) > **ជនក**,

វិ. (**យោ**) **ជនេតីតិ** (**សោ**) **ជនកោ** (**ជនោ**) =អ្នកឱ្យបុត្រកើត (ឪពុក, បិតា) ។ បើឥត្ថីលិង្គទៅជា **ជនិកា** =ម្តាយ, មាតា ។ ចំពោះ **ញា** ធាតុត្រូវផ្លាស់ជា **ជា** សិនទើបចុះ **អានក** សម្រេចបានជា **ជានក**, **សញ្ជានក** (ចូរមើលក្នុង **ណ្វុ** បច្ច័យខាងដើម) ។

## ៥. អន, អណ, អានន

## បច្ច័យតួជំនួស

អន, អណ, អានន នេះជាតួជំនួស យុ បច្ច័យ (ចូរមើលត្រង់ យុ បច្ច័យនៅខាងដើម) ។ ជាពិសេស យុ បច្ច័យដែលផ្លាស់ជា អន មានប្រើច្រើនជាងបច្ច័យឯទៀត ៗ ដូចមានគំរូប្រាកដនៅខាងដើម ក្នុងមេរៀនទី ៣៧ រួចហើយ ។

## ៦. តុ បច្ច័យតួពិត

តុ ជាបច្ច័យតួពិតដែលមានអំណាចដូច ត បច្ច័យគឺអាចផ្លាស់ប្តូរទីបំផុតធាតុបាន ឬវិការៈបាន វៀរតែធាតុដែលមានទីបំផុតជាស្រៈ អា ដូចជា

(ជា + តុ) > ជាតុ, វិ. ជាយតីតិ > ជាតុ =ជាតុ ។ ពាក្យ ថា ញាតុ, ជាតុ ក៏មានគតិដូចគ្នា ។

(ហិ + តុ) > ហេតុ, វិ. ហិនោតិ បវត្តតិ ផលំ ឯតេនាតិ ហេតុ (ការណំ) =ហេតុ, ការណ៍ (វិការៈ ឥ នៃ ហិ ទៅជា ឯ) ។

(សិ + តុ) > សេតុ, វិ. សិយតិ ពជ្ឈិយតីតិ សេតុ =ស្ពាន (វិការៈ ឥ នៃ សិ ទៅជា ឯ) ។

សូមរកមើលក្នុងមេរៀនទី ៣៣ សាឡើងវិញ ។

ចំពោះ តុ បច្ច័យដែលប្រើជំនួស រិតុ និង រាតុ មិនមានក្នុងមេរៀននេះទេ សូមមើលក្នុងមេរៀនទី ៣៧ សាឡើងវិញទៀតផង ។

## ៧. ឥ បច្ច័យតទ្ធិត

ឥ ជាបច្ច័យតទ្ធិត វេលាចុះមកហើយអាចឃើញយ៉ាងងាយ និងមានស័ព្ទដែលសម្រេចមកពីបច្ច័យនេះច្រើនទៀតផងដូចជា

(មុន + ឥ) > **មុនិ** =អ្នកបេះ, អ្នកប្រាជ្ញ, អ្នកដឹងនូវធម៌ទាំងពួង, វិ. (យោ) **សព្វធម្មេ មនតិ ជានាតីតិ (សោ) មុនិ (ជនោ) ។**

(ឥស + ឥ) > **ឥសិ** =ឫសី, ឥសី, អ្នកស្វែងរកនូវសីលាទិគុណ វិ. (យោ) **សីលាទិគុណេ ឯសតីតិ (សោ) ឥសិ (ជនោ) ។**

ពាក្យថា **អគ្គិ** =ភ្លើង, **អក្ខិ** =ភ្នែក, **វិធិ** =វិធី, របៀប, **សមាធិ** = ការតាំងចិត្ត, **អច្ចិ** =អណ្តាតភ្លើង ។ ទាំងនេះសុទ្ធតែជា ឥ បច្ច័យទាំងអស់ ជាពិសេស ឥ បច្ច័យក្នុងនាមកិតក:ដែលពោលរួចហើយនេះអាចប្រព្រឹត្តទៅបានទាំងបីលិង្គហៅថា ឥ ការន្ត ក៏បាន ។

## ៨. តិ បច្ច័យតទ្ធិត

**តិ** ជាបច្ច័យតទ្ធិតមិនបាច់លុបទេ ប៉ុន្តែមានអំណាចលុបទីបំផុត

ជាតុនិងផ្លាស់ប្តូររូបទៅជាផ្សេង ៗ ដូច ត បច្ច័យបាន ។ ស័ព្ទដែលចុះ តិ បច្ច័យជានាមនាមដូចជា

(**សរ** + **តិ**) > **សតិ** =សេចក្តីរលឹក ។

(**កិត** + **តិ**) > **កិត្តិ** មានវិគ្គហៈថា **កិត្តិយតេ កាថិយតេតិ កិត្តិ** =កេរ្តិ៍, សេចក្តីសរសើរ ។

(**តន** + **តិ**) > **តន្តិ**, មានវិគ្គហៈថា **តនោតីតិ តន្តិ** =បែបផែន, សរសៃ, ខ្សែពិណ ។

(**ភរ** + **តិ**) > **ភតិ**, មានវិគ្គហៈថា **ភរតិ កម្មករេ ឯតាយាតិ ភតិ** =ថ្លៃឈ្នួល, ការស៊ីឈ្នួល (លុប រ ទីបំផុតធាតុចេញ) ។

## ៩. តវេ និង តុំ បច្ច័យត្អពិត

ចំពោះបច្ច័យទាំងពីនេះមានអធិប្បាយក្នុងមេរៀនទី ២២ ក្នុងភាគ ១ រួចហើយ ដូច្នេះសូមរកមើលផងចុះ ។

## ឧណាទិបច្ច័យ

ពាក្យថា **ឧណាទិ** ញែកទៅជា (**ឧណ** + **អាទិ**) ប្រែថាបច្ច័យដែលមាន **ឧណ** បច្ច័យនៅខាងដើមគឺទី ១ ឬបើនឹងញែកបន្តទៅទៀត

ជា (ឧ + ណ) > **ឧណ** ។ បើដាក់ **ឧ** នៅខាងក្រោយវិញគង់បានរូបជា (ណ + ឧ) > **ណុ** ។ ទោះជា **ឧណ** ឬ **ណុ** បច្ច័យក៏ដោយ ក៏ជាបច្ច័យមានតួ **ណ** ហៅថា ណានុពន្ធបច្ច័យ ត្រូវតែលុប **ណ** ចេញឱ្យនៅសល់តែបច្ច័យតួ **ឧ** (មាន **ណុ** បច្ច័យមួយតួទៀតដែលពុំចាំបាច់លុបទេ មានអធិប្បាយនៅខាងមុខ) ។

ឧណាទិបច្ច័យជាបច្ច័យដោយឡែក ខ្លះសម្រាប់ចុះក្នុងកិតកិរិយានិងខ្លះសម្រាប់ចុះក្នុងនាមកិតកៈនេះដែរ ក្នុងទីនេះលើកយកមកពោលតែបច្ច័យណាដែលប្រើក្នុងនាមកិតកៈប៉ុណ្ណោះ ។

នៅក្នុងកច្ចាយនូបត្ថម្ភកប្រាប់ថាមានបច្ច័យ ២៥ តួគឺ **ឧណ** ឬ **ណុ, ថ, ម, ល, យ, យណ, លាឝ, ថុ, ត្តិម, ណិម, ណុ, ត្រណ, ឝ, ឝ, ឥន្ទ, ក, ឥរ, អល, ឝុ, ឡៀរ, ឃរ, ឝុ, ណុ, ឧស្ស, ឝុស, ឥស** ។ ប៉ុន្តែនៅក្នុងបករណ៍ផ្សេង ៗ ទៀតឃើញប្រាប់ថាមានបច្ច័យច្រើនជាងនេះនិងបច្ច័យទាំងនោះមិនចុះក្នុងជាតុជាទូទៅទេគឺចុះចំពោះធាតុខ្លះ ៗ ប៉ុណ្ណោះ ដូចឧទាហរណ៍តទៅនេះ

## ១. ឧណ ឬ ណុ បច្ច័យ

បច្ច័យពីរតួនេះមានអំណាចទីឃៈឬផ្លាស់ប្តូរធាតុដូច **ណ** បច្ច័យបានដែរ គឺមាន ៣ ប្រការដូចខាងក្រោមនេះ

១.១ ប្រភេទទីយ:ស្រ:ដើមធាតុជាដូចជា

(កស + ណុ) > កាសុ, វិ. កសិយតីតិ កាសុ =រណ្ដៅ ។

(ករ + ណុ) > ការុ, វិ. ករោតីតិ ការុ =ជាង, អ្នកធ្វើ ។

(ចរ + ណុ) > ចារុ, វិ. ចរតិ ហទយេ មនុញ្ញភាវេនាតិ ចារុ = ស្រស់, ជាទីគាប់ចិត្ត (=ត្រាច់ទៅក្នុងចិត្តដោយកើតទីចម្រើនរុងរឿងនៃចិត្ត) ។

(ជន + ណុ) > ជានុ, វិ. ជាយតិ គមនាគមនមេនាតិ ជានុ = ជង្គង់ (=គ្រឿងឱ្យកើតនៃការទៅការមក) ។

(តល + ណុ) > តាលុ, វិ. តលន្តិ បតិដ្ឋហន្តិ ឯត្ថ ឧណ្ហាតិ តាលុ =ពិតាននៃក្រអូមមាត់ (=ជាទីតាំងនៃធ្មេញ) ។

(ទរ + ណុ) > ទារុ, វិ. ទរិយតីតិ ទារុ =ឧស, ឈើ ។

(រហ + ណុ) > រាហុ, វិ. រហតិ ចន្ទាទីនំ សោភាវិសេសំ ជាសេតីតិ រាហុ (អសុរិន្ទោ) =រាហ៊ូ, អសុរធំ ។

(អយ + ណុ) > អាយុ, វិ. អយន្តិ បវត្តន្តិ សត្តា ឯតេនាតិ អាយុ (ជីវិតំ) =អាយុ (ជីវិត) ។

១.២ បើដើមធាតុជាស្រ:ទីយ:ស្រាប់ ទុកធាតុឱ្យគង់រូបដើមដូចជា

(សាធ + ណុ) > សាធុ, វិ. សាធេតិ អត្តបរហិតន្តិ សាធុ = ជនល្អ, ប្រពៃ (ញ៉ាំងប្រយោជន៍និងអ្នកដទៃឱ្យសម្រេច) ។

(វា + យ + ណុ) > វាយុ, វិ. វាតិ គច្ឆតីតិ វាយុ =ព្យុះ (បក់ទៅ)។

១.៣ ប្រភេទមិនបាច់ទីឃៈដើមធាតុ តែខ្វះវិការៈ ឥ > ឯ បានដូច

(កិត+ណុ) > កេតុ, វិ. កេតតិ ឧច្ចំ គច្ឆតិ ឧបរិ និវសតីតិ កេតុ =ទង់ (= ធជោ) ។

(គរ + ណុ) > គរុ, វិ. (យោ) គរតិ សិញ្ចតិ គិរតិ វមតិ វា សិស្សេសុ សិនេហន្តិ (សោ) គរុ (អាចរិយោ) =អាចារ្យ, គ្រូ, (អ្នកប្រោះនូវសេចក្តីស្រឡាញ់ក្នុងសិស្ស) ។

ប្រែដូច្នេះ (យោ អាចរិយោ អាចារ្យ ណា) គរតិ វា តែងប្រោះ ក្តី សិញ្ចតិ វា តែងស្រោច ក្តី គិរតិ វា តែងស្តោះ ក្តី វមតិ វា តែងកើចេញ ក្តី សិនេហំ នូវសេចក្តីស្រឡាញ់ សិស្សេសុ ក្នុងសិស្ស.ទ. ឥតិ ព្រោះហេតុនោះ (សោ អាចរិយោ អាចារ្យ នោះ) គរុ ឈ្មោះថា គរុ, គរុ =គ្រូ (អ្នកប្រោះនូវសេចក្តីស្រឡាញ់ក្នុងសិស្សទាំងឡាយ) ។

(ចក្ខ + ណុ) > ចក្ខុ, វិ. ចក្ខតិ រូបន្តិ ចក្ខុ =ភ្នែក, ចក្ខុ, ការឃើញ ។

(តន + ណុ) > តនុ, វិ. តនោតិ សំសារទុក្ខន្តិ តនុ (សរីរំ) = កាយ, ស្បែក,។

(ជន + ណុ) > ជនុ, វិ. ជនតិ សទ្ទំ ករោតីតិ ជនុ =ធ្នូ, (ចាបោ =ផ្លែធ្នូ, កូនសរ) ។

(បស + ណុ) > បសុ, វិ. បសិយតិ ពាធិយតិ សាមិកេហីតិ បសុ (ចតុប្បាទោ) =សត្វចិញ្ចឹម, ម្ចាស់ខ្សែតី ។

( ពន្ធ + ណុ ) > ពន្ធុ, វិ. ពន្ធយតិ សិនេហាការេនាតិ ពន្ធុ = ញាតិ, ពួក, ពន្ធុ ។

( ភម + ណុ ) > ភមុ, វិ. ភមតិ ចលតីតិ ភមុ = រោមចិញ្ចើម ។

( អម្ពុ + ណុ ) > អម្ពុ, វិ. អម្ពតិ អភិជាធំ គាភេតីតិ អម្ពុ (វារិ) = ទឹក ។

## ២. ៨ បច្ច័យ

ថ ជាបច្ច័យតួពិតមិនបាច់លុបទេ និងមានវិធីចុះជាមួយធាតុ ៥ យ៉ាងដូចតទៅនេះ

២.១ រក្សាធាតុឱ្យគង់រូបដើមដូចជា

( ទម + ថ ) > ទមថ, វិ. ទមនំ ទនថោ = ការទូន្មាន, ការហ្វឹក ។

( សម + ថ ) > សមថ វិ. កិលេស សមេតីតិ សមថោ = សេចក្តីស្ងប់ ។

( ទរ + ថ ) > ទរថ, វិ. ទរណំ ទរថោ = សេចក្តីខ្វល់ខ្វាយ ។

( សប + ថ ) > សបថ, វិ. សបនំ សបថោ = ការស្បថ, សម្បថ ។

( អា + វស + ថ ) > អាវាសថ, វិ. អាវសន្តិ តស្មិន្តិ អាវសថោ = ទីនៅ ។

( ឧប + វស + ថ ) > ឧបោសថ, វិ. ឧបវសន្តិ ឯត្ថាតិ ឧបោសថោ = ថ្ងៃឧបោសថ (ផ្លាស់ វ នៃ វស ទៅជា ឱ) ។

( យុ + ថ ) > យូថ, វិ. យវតិ មិស្សីភវតីតិ យូថោ =ហ្វូងសត្វ ។

២.២ លុបទីបំផុតនៃធាតុខ្លះ ៗ ដូចជា

(រហ + ថ ) > រថ, វិ. រហិយតិ ឧចាជិយតីតិ រថោ =រទេះ, រថ ។

(រម + ថ ) > រថ, វិ. រមន្តិ កីឡន្តិ ឯតេនាតិ រថោ =រទេះ, រថ ។

២.៣ ផ្លាស់ស្រៈ ឧ នៃ សុ, វុ និង អស ធាតុទាំងមូលជា អត ដូចជា

(សុ > សត + ថ ) > សត្ថ, វិ. សវតិ ហឹសតិ ឯតេនាតិ សត្ថំ = អាវុធ ។

(វុ > វត + ថ ) > វត្ថ, វិ. ហិរតប្បោ សំវរតិ ឯតេនាតិ វត្ថំ = សំពត់ ។

(អស > អត + ថ ) > អត្ថ, វិ. សង្ខានុរូបំ អសតិ ភវតីតិ អត្ថោ =អត្ថ, សេចក្តី ។

២.៤ ផ្លាស់ទីបំផុតជាតុជា ត ដូចជា

( សស > សត + ថ ) > សត្ថ =សាស្ត្រា, តម្រា ។

( សាស > សត + ថ ) > សត្ថ =សាស្ត្រា, តម្រា ។

(វស > វត + ថ ) > វត្ថ = សំពត់ ។

(អរ > អត + ថ ) > អត្ថ =ទ្រព្យ, សម្បត្តិ ។

ថ បច្ច័យអាចយកមកប្រើក្នុងប្រយោគផ្សេង ៗ ដូចបច្ច័យឯទៀត បានដូចជា

១. <u>សមថោ</u> ច វិបស្សនា ច សមថវិបស្សនំ ។

<u>សេចក្ដីស្ងប់</u> ផង ការឃើញច្បាស់ ផង ឈ្មោះថា សមថវិបស្សនា ។

២. ចិត្តស្ស <u>ទមថោ</u> សាធុ ។ <u>ការទូន្មាន</u> នូវចិត្ត ជាការប្រពៃ ។

ចិត្តស្ស ជាឆដ្ឋីវិភត្តិពិតមែនតែប្រែកាច់ថា "នូវ" ពីព្រោះ ថ បច្ច័យមានអំណាចបង្គាប់ដូចគ្នានឹង ណ្ហុ, តុ, យុ បច្ច័យដែលពោលរួចហើយដែរដូចជា សព្វទាបស្ស អកាណំ សេដ្ឋំ នោះឯង ។

## ៣. ម បច្ច័យ

ម ជាបច្ច័យតួពិតមិនបាច់លុបទេ ដែលមានវិធីប្រកបរូប ២ បែបដូចតទៅនេះ

៣.១ វិធីទុកធាតុឱ្យគង់រូបដើមដូចជា

(ហិ + ម) > ហិម វិ. ហិនោតីតិ ហិមោ =ទឹកសន្សើម ។

(ភី + ម) > ភីម វិ. ភាយន្តិ ឯតស្មាតិ ភីមោ =យក្ស ។

(ធា + ម) > ធាម វិ. ធាតិ អវខណ្ឌំ ករោតីតិ ធាមោ =ខ្សែ, ក្លងផ្កា ។

(យា + ម) > យាម វិ. យាតីតិ យាមោ =យាម, វេលា ។

(ឋា > ថា + ម) > ថាម វិ. តិដ្ឋន្តិ ឯតេនាតិ ថាមោ =កម្លាំង ។

៣.២ វិធីព្រឹទ្ធិស្រៈរបស់ធាតុដូចជា

(សុ + ម) > សោម វិ. សុណាតីតិ សោមោ =*ព្រះច័ន្ទ ។*

(លូ + ម) > លោម វិ. លូយតេតិ លោមោ =*រោម ។*

(ហិ + ម) > ហេម វិ. ហិនោតិ បវត្តតីតិ ហេមំ =*មាស ។*

(វី + ម) > វេម វិ. វាយន្តិ ឯតេនាតិ វេមោ =*ត្រល់ត្បាញ ។*

(ព្រូហ + ម) > ព្រហ្ម វិ. តេហិ តេហិ គុណេហិ ព្រូហាតិ វឌ្ឍតីតិ ព្រហ្មា =*ព្រះព្រហ្ម (លុបស្រៈដើមធាតុ) ។*

## ៤. ល បច្ច័យ

ល *ជាបច្ច័យតួពិតមានប្រើចំពោះតែធាតុ ៤ តួគឺ* អល, កល, សល *និង* មជ *ដូចមានវិធីខាងក្រោមនេះ*

(អល + ល) > អល្ល វិ. អលតិ សមត្ថេតីតិ អល្លំ =*ទទឹក, ថ្មី, ខ្ចី ។*

(កល + ល) > កល្ល វិ. កលិតព្វំ សំខ្យាតព្វន្តិ កល្លំ =*ធ្វាត, សុខស្រួល ។*

(សល + ល) > សល្ល វិ. សលតិ គច្ឆតិ បវិសតីតិ សល្លំ =*កូនសរ, ព្រួញ ។*

*ចំពោះ* មជ *ធាតុ, ផ្លាស់* ជ *ជា* ល *ទើបចុះ* ល *បច្ច័យ*

(មជ > មល + ល) > មល្ល វិ. មជតិ វិលោឡតីតិ មល្លោ =*អ្នកប្រដាល់ចំបាប់ ។*

## កំណត់សម្គាល់

អល្វ, កាល្វ, សល្វ ទាំង ៣ ស័ព្ទនេះអាចថាចុះ យ បច្ច័យក៏បានដែរ ពីព្រោះ (ល + យ) > ល្យ = ល្វ ដូច្នេះទៅជា អល្យ, កាល្យ, សល្យ ប្រែដូចខាងលើ ។ សូមរកមើលវិធីផ្លាស់ប្តូរទីបំផុតធាតុជាមួយ យ បច្ច័យក្នុងមេរៀនទី ១៤ នៃភាគ ១ ។

## ៥. អល បច្ច័យ

អល បច្ច័យវេលាចុះមកត្រូវលុបតួ អ ចេញឱ្យសល់នូវត្រឹមតែ ល ប៉ុណ្ណោះ ដូចខាងក្រោមនេះ

(កុស + អល) > កុសល វិ. កុសតិ ឆិន្ទតិ ចាបកោ ឥមេ្មតិ កុសលំ =អំពើល្អ, កុសល ។

(កាឥ + អល) > កាឥល វិ. កាឥតិ មជ្ជតិ ឯតេឥ កាឥលំ = ដើមចេក ។

(ពហ + អល) > ពហល វិ. ពហាតិ វុឌ្ឍឹ គច្ឆតីតិ ពហលំ = ច្រើន, ក្រាស់ ។

(មណ្ឌ + អល) > មណ្ឌល វិ. មណ្ឌិយតិ ភូសីយតិ មណ្ឌលំ =បរិវេណ, វង់មូល ។

(មេខ + អល) > មេខល វិ. មេខតិ កាដិវិចិត្តំ ករោតិ មេខលំ,

**មេខលា** =*សំលៀកបំពាក់ទ្រនាប់របស់ស្រី ។*

(មង្គ + អល) > មង្គល. វិ. មង្គន្តិ វុទ្ធឹ គច្ឆន្តិ ឯតេនាតិ មង្គលំ = *មង្គល (សេចក្តីចម្រើន) ។*

(សក + អល) > សកល វិ. សក្កោតិ វត្តុន្តិ សកលំ = *ទាំងមូល, ទាំងស្រុង, ទាំងអស់ ។*

## ៦. យាណ, លាន បច្ច័យ

*បច្ច័យ ២ តួនេះសម្រាប់ចុះក្នុងធាតុ ២ តួគឺ* កល និង សល *ដូចខាងក្រោមនេះ*

(កល + យាណ) > កល្យាណ ។

(កល + លាន) > កល្លាន ។

*វិ.* កលតិ យថាសុខំ បវត្តតីតិ កល្យាណោ *ឬ* កល្លានោ = *សេចក្តីល្អ, ពីរោះ ។*

(បដិ + សល + យាណ) > បដិសល្យាណ ។

(បដិ + សល + លាន) > បដិសល្លាន ។

*វិ.* នានារម្មណតោ បដិសំហរិត្វា សលតីតិ បដិសល្យាណោ *ឬ* បដិសល្លានោ = *ទីសម្ងំពួនទៅ ។*

# ៧. ថុ, ត្តិម, ណិម បច្ច័យ

បច្ច័យទាំងបីតួនេះមានរបៀបប្រែពេញថា "កើតហើយ" ដូចគ្នា ។ ប៉ុន្តែក្នុងទីនេះប្រែត្រឹមសេចក្តីសង្ខេបប៉ុណ្ណោះ ដូចជា

(វេបុ + ថុ) > វេបថុ វិ. វេបនេ និព្វត្តោ វេបថុ =ការញាប់ញ័រ ។

(សី + ថុ) > សយថុ វិ. សយេន និព្វត្តោ សយថុ =ការដេក ។

(ទវ + ថុ) > ទវថុ វិ. ទវេន និព្វត្តោ ទវថុ =សេចក្តីក្តៅក្រហាយ។

(វមុ + ថុ) > វមថុ វិ. វមេន និព្វត្តោ វមថុ =ការចង្អោរ ។

បើប្រែឱ្យពេញប្រែថា "កើតហើយព្រោះការញាប់ញ័រ" ជាដើម ។

(វស > វត + ថុ) > វត្ថុ វិ. វសន្តិ ឯត្ថាតិ វត្ថុ =រឿង ។

(មស > មត + ថុ) > មត្ថុ វិ. ទធឹ អាមសតីតិ មត្ថុ =ទឹកដោះពរថ្លា ។

(កុស > កោត + ថុ) > កោត្ថុ វិ. កុសីយតិ អក្កោសីយតិ ភេរវនាទត្តាតិ កោត្ថុ =កញ្ជ្រោង ។

(ករ > កុ + ត្តិម) > កុត្តិម វិ. ករណេន និព្វត្តំ កុត្តិមំ =ការធ្វើ ។

(ទា + ត្តិម) > ទត្តិម វិ. ទានេន និព្វត្តំ ទត្តិមំ =ការឱ្យ ។

(ភូ + ត្តិម) > ភោត្តិម វិ. ភវេន និព្វត្តំ ភោត្តិមំ =ការមាន ។

(ឱ + ហុ + ណិម) > ឱហារិម វិ. អវនេន និព្វត្តំ ឱហារិមំ = ការបូជា ។

## ៨. ណុ បច្ច័យ

ណុ នេះជាបច្ច័យតួពិតនិងមានតួ ណ ប៉ុន្តែមិនចាត់ចូលក្នុងណានុពន្ធបច្ច័យទេ ដូច្នេះវេលាចុះក្នុងធាតុណា ត្រូវទុកឱ្យគង់រូបដើមដូចខាងក្រោមនេះ

(ហន + ណុ) > ហណុ, ហនុ វិ. កោជនំ ហនតិ ហឹសតិ ឯតេនាតិ ហណុ, ហនុ វា =ចង្កា, ថ្គាម ។

(ជន + ណុ) > ជាណុ វិ. គមនំ ជនេតីតិ ជាណុ =ជង្គង់ ។

(ភា + ណុ) > ភាណុ, ភានុ វិ. ភាតិ ទិព្វតីតិ ភាណុ, ភានុ វា =ព្រះអាទិត្យ ។

(រិ + ណុ) > រេណុ វិ. និវាតេ រយតិ គច្ឆតីតិ រេណុ =ធូលី, លំអង ។

(ខន + ណុ) > ខាណុ វិ. ខនិតព្វោ អវទារិតព្វោតិ ខាណុ = ជង្គត់ឈើ ។

(វេ + ណុ) > វេណុ វិ. វេតិ តន្តសន្តានេ ករតីតិ វេណុ, ពហិសារេ អលន្តិ វា វេណុ =ឫស្សី ។

(អម + ណុ) > អណុ វិ. អង្គមង្គស្ស រុជ្ជនការំ វិជ្ឈនការំ អមតិ គច្ឆតីតិ អណុ =បំណែកសែនល្អិត (អាតូម), អណូ, (១ អណុ = ៣៦ បរមាណូ) ។

## ៩. ត្រណ ឬ ត បច្ច័យ

ត្រណ បច្ច័យវេលាចុះមកត្រូវលុប ណ ចេញហើយសម្រេចរូបជា ត្រ ខាងចុង ដែលមានរូបដូចជាភាសាសំស្ក្រឹត អាស្រ័យហេតុនេះគួរតែជា ត បច្ច័យទៅវិញទេ ។ (បច្ច័យដែលមានតួ ត ត្រូវធ្វើយ៉ាងណាមិនអធិប្បាយទៀតទេ) ។ ប៉ុន្តែក្នុងកច្ចាយនព្យាករណ៍ លោកបានឱ្យឧទាហរណ៍ទាំងពីរបែបដូចខាងក្រោមនេះ

(ឆទ + ត ឬ ត្រណ) > ឆត្ត, ឆត្រ វិ. អាតបំ ឆាទេតីតិ ឆត្តំ, ឆត្រំ = *ឆ័ត្រ* ។

(ចិត + ត ឬ ត្រណ) > ចិត្ត, ចិត្រ វិ. អារម្មណំ ចិន្តេតីតិ ចិត្តំ, ចិត្រំ ចិន្តេន្តិ សម្បយុត្តធម្មា ឯតេនាតិ វា ចិត្តំ, ចិត្រំ =*ចិត្ត, ចិត្រ* ។

(សុ, សូទ + ត ឬ ត្រណ) > សុត្ត, សុត្រ វិ. អត្ថេ អភិស្សវេតីតិ សុត្តំ, សុត្រំ អត្ថេ សូទេតីតិ វា សុត្តំ, សុត្រំ =*សូត្រ* ។

(នី + ត ឬ ត្រណ) > នេត្ត, នេត្រ វិ. សត្តេ នេតីតិ នេត្តំ, នេត្រំ ឥច្ឆិតដ្ឋានំ នេន្តិ ឯតេនាតិ វា នេត្តំ, នេត្រំ =*ភ្នែក* ។

(បទ + ត ឬ ត្រណ) > បត្ត, បត្រ វិ. អាហារា បតន្តិ ឯត្ថាតិ បត្តំ, បត្រំ =*បាត្រ* ។

មានសព្ទច្រើនដែរដែលចុះ ត បច្ច័យនេះ ប៉ុន្តែសូមកុំច្រឡំជាមួយ ត បច្ច័យក្នុងកិតកិរិយា ។

## ១០. ឌ បច្ច័យ

ឌ ជាបច្ច័យតួពិត កាលបើចុះមកអាចឃើញរូបបានយ៉ាងផាយដូចខាងក្រោមនេះ

(រម + ឌ) > រណ្ឌ វិ. រមន្តិ ឯត្ថ សប្បាណយោតិ រណ្ឌំ =រូង, រន្ធ ។

(មុឌ + ឌ) > មុណ្ឌ វិ. មោឌន្តិ ឯត្ថ ឩកាឌយោតិ មុណ្ឌា =ក្បាល។

(អរ + ឌ) > អណ្ឌ វិ. អរន្តិ យន្តិ ឯត្ថាតិ អណ្ឌា =ផ្លូវ ។

(តិឌ + ឌ) > តណ្ឌ វិ. តេឌតីតិ តណ្ឌោ =សត្វត្មាត ។

(វិឌ + ឌ) > វិណ្ឌ វិ. បរិវិឌ្ឍតីតិ វិណ្ឌំ =ស្អាត ។

សូមសង្កេតមើលនិងកត់ចំណាំរបៀបតម្រួតទីបំផុតជាតុផង ។

## ១១. ឌ, ឥណ្ឌ បច្ច័យ

បច្ច័យពីរតួនេះក៏ជាតួពិតដែរ កាលបើចុះមកអាចឃើញរូបបានដូចខាងក្រោមនេះ

(សំ + ឩឌិ + ឌ) > សមុណ្ឌ វិ. អត្តនិ សន្និស្សិតានំ មច្ឆមការានំ បីតិសោមនស្សំ ឩណ្ឌតិ បសវតិ ជនេតីតិ សមុណ្ឌោ =សមុទ្រ ។

(ឥឌិ + ឌ) > ឥណ្ឌ វិ. ឥណ្ឌតិ បរមិស្សរិយំ ការោតីតិ ឥណ្ឌោ =អ្នកជាធំ ។

(ចឌិ + ឌ) > ចណ្ឌ វិ. ចន្ទិតញ្ញោ ឥច្ឆិតញ្ញោតិ ចណ្ឌោ =ព្រះច័ន្ទ ។

(ខុទ + ទ) > **ខុទ្ទ** វិ. **ខុទតិ បិថាសេតីតិ ខុទ្ទោ** =តូច ។

(សប + ទ) > **សទ្ទ** វិ. **សបត្តិ ឯនេនាតិ សទ្ទោ** =សូរ, សំឡេង។

(ទល + ទ) > **ទលិទ្ទ** វិ. **ទលតិ ទុគ្គតភាវំ គច្ឆតីតិ ទលិទ្ទោ** = ក្រ, ទ័ល ។

សូមសង្កេតមើលនិងកត់ចំណាំរបៀបតម្រួតទីបំផុតធាតុផង ។

## ១២. **ក ឬ ឥ បច្ច័យ**

**ក** បច្ច័យនេះមានការប្រើប្លែកគ្នាបន្តិចគឺក្នុងគម្ពីរកច្ចាយនព្យាករណ៍និងសទ្ទនីតិបករណ៍ ប្រាប់ថាសម្រាប់ចុះក្នុងពួកធាតុដូចជា **កឌិ**, **ឃដិ**, **កុបិ** ជាដើមគឺធាតុណាដែលមានតួ **ឌិ**, **ដិ** ឬ **បិ** ជាទីបំផុតនិងឱ្យចុះនិគ្គហិតលើដើមធាតុសិន រួចផ្លាស់និគ្គហិតនោះជា **ណ** និងលុប **ក** បច្ច័យចោល ហើយតម្រួតជា **ណ្ឌ** ។

រីឯក្នុងគម្ពីរមោគ្គល្លានព្យាករណ៍វិញ ប្រាប់ថា សម្រាប់ចុះក្នុងធាតុដែលមានទីបំផុតជា **ម** ឬ **ឌ** ដែលផ្លាស់ជា **ណ** ។ ដូច្នេះវិធីតាំងវិគ្គហៈត្រូវប្រើកិរិយាអាខ្យាត ដូចមានឧទាហរណ៍ខាងក្រោមនេះ

(កឌិ + ក) > **កណ្ឌ** វិ. **កណ្ឌិតព្វោ ឆិន្ទិតព្វោតិ កណ្ឌោ** =កូនសរ ។

(ឃដិ + ក) > ឃណ្ដ វិ. ឃណ្ដិតព្វោ ឃដេតព្វោតិ ឃណ្ដោ =*រគាំង* ។

(កុឋិ + ក) > កុដ្ឋ វិ. អង្គមង្គានិ កុណ្ឋាតិ កុដ្ឋំ =*រោគឃ្លង់* ។

(ទឌិ + ក) > ទណ្ឌ វិ. ទណ្ឌាតិ អាណំ ករោតិ ឯតេនាតិ ទណ្ឌោ =*ដំបង, ទណ្ឌកម្ម* ។

(អឌិ + ក) > អណ្ឌ វិ. អណ្ឌីយតិ និព្វត្តីយតិ អណ្ឌោ =*ពង, ស៊ុត* ។

(កម > កណ + ឌ) > កណ្ឌ វិ. កាមតិ យាតីតិ កណ្ឌោ = *កូនសរ* ។

(ទម > ទណ + ឌ) > ទណ្ឌ វិ. ទម្យន្តេយេនាតិ ទណ្ឌោ = *ដំបង* ។

(អម > អណ + ឌ)> អណ្ឌ វិ. អមន្តិ ឧប្បជ្ជន្តិ ឯតេនាតិ អណ្ឌោ =*ស៊ុត* ។

(ខជ > ខណ + ឌ) > ខណ្ឌ វិ. ខញ្ញតីតិ ខណ្ឌោ =*កំណាត់, ចំណែក* ។

*នៅមានសព្ទប្រើបច្ច័យនេះច្រើនទៀតដែលអាចស្គាល់បាន ។*

## ១៣. ឥរ ឬ កិរ បច្ច័យ

ចំពោះ កិរ បច្ច័យវេលាចុះក្នុងទីបំផុតធាតុត្រូវលុបតួ ក ចេញ ដូចខាងក្រោមនេះ

(តិម + ឥរ ឬ កិរ) > តិមរ វិ. តេមេតីតិ តិមិរំ =ភាពងងឹត, ទឹក ។

(រុហ + ឥរ ឬ កិរ) > រុហិម វិ. រុហាតិ បវត្តតីតិ រុហិរំ =ឈាម ។

(មទ + ឥរ ឬ កិរ) > មទិរ វិ. ជនា មជ្ជន្តិ ឯតេនាតិ មទរា = ស្រា ។

(អជ + ឥរ ឬ កិរ) > អជិរ វិ. អជន្តិ គច្ឆន្តិ ឯតេនាតិ អជិរំ = ទីលាន ។

## ១៨. ណុ បច្ច័យ

ណុ នេះក៏ជាបច្ច័យតួពិតដែរ កាលបើចុះមកអាចឃើញរូបបានដូចខាងក្រោមនេះ

(ធន + ណុ) > ធនុ វិ. ណុក្ខំ ធនាតីតិ ធនុ =ពាក់ស្រែង ។

(អន + ណុ) > អនុ វិ. ណុក្ខេន អនតិ ភក្ខតិ ឯត្ថាតិ អនុ =ខ្ទោះ, គុក ។

(មន + ណុ) > មនុ វិ. មនតិ ឧម្មត្តំ ករោតីតិ មនុ =អ្នកស្រវឹង ។

## ១៩. ឡារ បច្ច័យ

(ចិ + ឦរ) > ចីរ វិ. ចីយតីតិ ចីរំ =បីរ, បីពរ ។

(តា + ឦរ) > តីរ វិ. យេន កោនចិ អត្តានំ តាយតីតិ តីរោ =ជនទាបថោក ។

(ជា + ឦរ) > ជីរ វិ. ជាលកាមិជាជីនិ ជាបេតីតិ ជីរោ =អ្នកនេសាទ ។

(នី + ឦរ) > នីរ វិ. នយន្តិ ឯត្ថ សត្តាតិ នីរំ =ផ្ទះ ។

(សម + ឦរ) > សំរីរ វិ. បរិឡាហំ សមេតីតិ សំរីរ =យប់, រាត្រី ។

## ១៦. ឩរ បច្ច័យ

(វិទ + ឩរ) > វិទូរ, វេទូរ វិ. វិទិតុំ អលន្តិ វិទូរោ =អ្នកចេះដឹង ។

(ទុ + ឩរ) > ទូរ វិ. គមិតុំ អលំ អជាសន្នត្តាតិ ទូរោ =ឆ្ងាយ ។

(មយ + ឩរ) > មយូរ វិ. មហិយំ យាតិ គច្ឆតីតិ មយូរោ =ក្ងោក ។

(ឧជិ + ឩរ) > ឧជ្ឈូរ វិ. បំសុំ ឧជ្ឈតិ បសវតីតិ ឧជ្ឈូរោ =កណ្ដុរ ។

## ១៧. ឧស្ស, ឩស, ឥស បច្ច័យ

*បច្ច័យទាំងបីតួនេះមានទីបំផុតជា ស ដូចគ្នាទាំងអស់ ខាងក្រោមនេះជាឧទាហរណ៍ខ្លះ ៗ*

(មន + ឧស្ស ឬ ណុស) > មនុស្ស វិ. កុសលាកុសលេ ធម្មេ មនតិ ជានាតីតិ មនុស្សោ, មានុសោ =*មនុស្ស* ។

(បូរ + ឥស) > បុរិស វិ. មាតាបិតូនំ ហទយំ បូរេតីតិ បុរិសោ =*ប្រុស* ។

(សុណ + ឥស) > សុណិស វិ. សសុរេហិ សុណិតព្វា ហឹសិតព្វាតិ សុណិសា =*កូនប្រសារ* ។

(មហ + ឥស) > មហិស វិ. មហិតព្វោ បូជេតព្វោតិ មហិសោ =*ក្របី* ។

(សុ + ឥស) > សុរិយ វិ. តមន្ធការវិធមនេន សត្តានំ ភយំ សុរតិ ហឹសតីតិ សុរិយោ =*ព្រះអាទិត្យ (ចុះ រ អាគមនិងផ្លាស់ ស ជា យ)* ។

*នៅមានឧណាទិបច្ច័យច្រើនទៀត ប៉ុន្តែមិនបាននាំមកអធិប្បាយទេ ព្រោះយល់ថាពោលមកប៉ុណ្ណេះសមល្មមដែរហើយ ។*

## វិធីសង្កេតសាធនៈនីមួយ ៗ

សាធនៈនេះជារឿងពិបាក ពីព្រោះមានរហូតដល់ទៅ ៧ សាធនៈ (ចូរមើលត្រង់សាធនៈទាំង ៧ ខាងដើមក្នុងមេរៀនទី ៣២) និងឃើញថា ស័ព្ទមួយម៉ាត់ ៗ អាចមានសាធនៈដល់ទៅពីរឬបីផងក៏មាន ។ ធាតុមួយតួ ៗ អាចប្រកបដល់ទៅ ៣ ឬ ៤ សាធនៈ គឺស្រេចតែសេចក្ដីនៃសាធនៈនោះ ៗ ប៉ុណ្ណោះ ពីព្រោះសាធនៈនីមួយ ៗ មានសេចក្ដីខុសប្លែកគ្នាដូចតទៅនេះ

## ១. ពន្ធ ធាតុប្រែថា "ចង"

(**ពន្ធ** + **យុ**) > **ពន្ធន**

**ពន្ធន** បើប្រែថា "ខ្សែ" នោះជាករណសាធនៈ ពីព្រោះជាគ្រឿងដែលគេប្រើសម្រាប់ចង ។ មានវិគ្គហៈថា (**ជនោ**) **ពន្ធតិ តេនាតិ** (**តំ**) **ពន្ធនំ** (**វត្ថុ**) =(វត្ថុ) ជាគ្រឿងចងរបស់ជន ។

**ពន្ធន** បើប្រែថា "ទីឃុំឃាំង" នោះជាអធិករណសាធនៈ ព្រោះជាទីកន្លែង បានដល់ ស្ថានទី ។ មានវិគ្គហៈថា (**ជនោ**) **ពន្ធតិ ឯត្ថាតិ** (**តំ**) **ពន្ធនំ** (**អាគារំ**) =(ផ្ទះ) ជាទីចងរបស់ជន (កន្លែងឃុំឃាំង) ។

## ២. ទា ធាតុប្រែថា "ឱ្យ"

**ទា** ធាតុបើផ្សំជាមួយ **ណ្វុ** ទៅជា **ទាយក** =អ្នកឱ្យ ។

**ទាយក** "អ្នកឱ្យ" ជាអ្នកធ្វើនូវការឱ្យ គឺជា កត្តុរូប-កត្តុសាធនៈ ។ មានវិគ្គហៈថា (**យោ**) **ទេតីតិ** (**សោ**) **ទាយកោ** (**ជនោ**) =អ្នកឱ្យ, ទាយក ។

**ទា** ធាតុបើផ្សំជាមួយ **យុ** ទៅជា **ទាន** =ដែលជនគប្បីឱ្យ ។

**ទាន** បើជា "វត្ថុ" ដែលគេឱ្យ គឺជា កម្មរូប-កម្មសាធនៈ ពីព្រោះជាវត្ថុ ។ មានវិគ្គហៈថា (**យំ តេន**) **ទាតព្វន្តិ** (**តំ**) **ទានំ** (**វត្ថុ**) =(វត្ថុ)ដែលជនគប្បីឱ្យ, ទាន, អំណោយ ។

**ទាន** បើជា "អំពើឱ្យ" គឺជា ភាវរូប-ភាវសាធនៈ ពីព្រោះជាទង្វើ ។ មានវិគ្គហៈថា **ទីយតេតិ ទានំ** =ការឱ្យ ។

**ទាន** បើជា "ចេតនា" គឺជា កត្តុរូប-ករណសាធនៈ ព្រោះឱ្យដោយចេតនា ។ មានវិគ្គហៈថា (**ជនោ**) **ទេតិ តេនាតិ** (**តំ**) **ទានំ** (**ចេតនាកម្មំ**) = (ចេតនាកម្ម)ជាគ្រឿងឱ្យនៃជន (ទាន) ។

**ទាន** បើជា "ទីកន្លែង" គឺជា អធិករណសាធនៈ ពីព្រោះគេឱ្យនូវទីកន្លែង ។ មានវិគ្គហៈថា (**ជនោ**) **ទេតិ ឯត្ថាតិ** (**តំ**) **ទានំ** (**ឋានំ**) =(ឋាន)ជាទីឱ្យនៃជន ។

(ចប់នាមកិតកៈត្រឹមនេះ)

(ចប់កិតកៈទាំងពីរប្រភេទត្រឹមនេះ)

(ចប់មេរៀនទី ៣៨)

# មេរៀនទី ៣៩

# អធិប្បាយអំពីតទ្ធិត

(Secondary Derivatives)

**តទ្ធិត** *ជាស័ព្ទមួយប្រភេទដែលសម្រេចមកពីនាមនានាដោយចុះបច្ច័យរបស់តទ្ធិតនេះ និងបង្កើតបានជាគុណស័ព្ទ តែនិយមប្រើជានាមស័ព្ទទៅវិញ ។*

*ពាក្យថា* **តទ្ធិត** *សម្រេចមកពី* **ត** + **ហិត** *ជាស័ព្ទសមាសដែលផ្សំចូលគ្នាតាមវិធីអាទេសព្យញ្ជនសន្ធិ ។ ព្យញ្ជនៈនៅដើមនៃបទចុងអាចអាទេស* **ហ** > **ធ** *ហើយតម្រួត* **ទ** *លើ* **ធ** *ជា* **ទ្ធ** *ទៅជា* **តទ្ធិត** *។* **ត** *ស័ព្ទដើមបានដល់* **ត** *សព្វនាម,* **ហិត** *ប្រែថា "ប្រយោជន៍, ការទំនុកបម្រុង, ជួយ" ។ កាលបើបញ្ចូលគ្នាហើយក៏ទៅជាបទ សមាស (ការសិក្សាអំពីសមាសនឹងមានអធិប្បាយនៅខាងមុខ) ប្រែយកតាមសេចក្ដីនៃរូបវិគ្គហៈរបស់ចតុត្ថីតប្បុរិសសមាសដូច្នេះ*

**( យំ ) តស្ស អត្ថស្ស ហិតំ ( តំ ) តទ្ធិតំ ( បច្ចយជាតំ ) ។**

*ប្រែ (***យំ បច្ចយជាតំ** *របច្ច័យ ឯណា)* **ហិតំ** *ជាប្រយោជន៍* **តស្ស អត្ថស្ស** *ដល់សេចក្ដី នោះ (***តំ បច្ចយជាតំ** *របច្ច័យ នោះ)* **តទ្ធិតំ** *ឈ្មោះថា* **តទ្ធិត, តទ្ធិត** *បច្ច័យជាប្រយោជន៍ដល់សេចក្ដីនោះ ។*

*វិគ្គហៈបែបនេះ* **ហិត** *ស័ព្ទជាគុណនាម ។*

បើចង់ឱ្យ **ហិត** ស័ព្ទជានាមនាម ពុំចាំបាច់ថែមនាមស័ព្ទដទៃគឺ អញ្ញបទចូលមកទេ មានវិគ្គហៈដូច្នេះ **តស្ស អត្ថស្ស ហិតំ តទ្ធិតំ ។**

ប្រែ **ហិតំ** វីប្រយោជន៍ **តស្ស អត្ថស្ស** ដល់សេចក្តី នោះ **តទ្ធិតំ** ឈ្មោះថា **តទ្ធិត**, **តទ្ធិត** បច្ច័យជាប្រយោជន៍ដល់សេចក្តីនោះ ។

ក្នុងសេចក្តីនេះ **តទ្ធិត** ជាស័ព្ទដែលចុះបច្ច័យសម្រាប់ប្រើជំនួសឱ្យអត្ថណាមួយ គឺធ្វើស័ព្ទនោះ ៗ ឱ្យរួញខ្លី ។ បច្ច័យរបស់តទ្ធិតនេះមានច្រើនតួនិងប្រហាក់ប្រហែលគ្នា បើសង្កេតមិនបានល្អទេនឹងកើតកង្វល់ពុំខានឡើយ ។ អាស្រ័យហេតុនេះទើបគួរតាំងជាសំនួរសួរថា តើបច្ច័យក្នុងតទ្ធិតប្រើជំនួសស័ព្ទប្រភេទណាខ្លះ ?

សូមជ្រាបថា បច្ច័យក្នុងបាលីវេយ្យាករណ៍មាន ៤ ប្រភេទគឺ

| | |
|---|---|
| ១. **អាខ្យាតបច្ច័យ** | ២. **កិតបច្ច័យ** |
| ៣. **អព្យយបច្ច័យ** | ៤. **តទ្ធិតបច្ច័យ** |

១. **អាខ្យាតបច្ច័យ** សម្រាប់ប្រើចុះក្នុងទីបំផុតនៃធាតុតួណាមួយ ហើយប្រកបនឹងវិភត្តិអាខ្យាតទៀតសម្រេចជាអាខ្យាតកិរិយា អធិប្បាយរួចហើយក្នុងមេរៀនខាងដើម ។

២. **កិតបច្ច័យ** សម្រាប់ប្រើចុះក្នុងទីបំផុតនៃធាតុតួណាមួយដែរ តែសម្រេចបាន ២ យ៉ាងគឺ កិតកិរិយា និង នាមកិតកៈ អធិប្បាយរួចហើយក្នុងមេរៀនខាងដើម ។

សូមមើលឧទាហរណ៍នៃ **ករ** ធាតុ

**ឱ** អាខ្យាតបច្ច័យ (**ករ+ឱ+តិ**) > **ករោតិ** ជាអាខ្យាតកិរិយា ។

**ត** កិតកិរិយាបច្ច័យ (**ករ + ត**) > **កត** ជាកិតកិរិយា ។

**យុ** កិតនាមបច្ច័យ (**ករ + យុ**) > **ករណ** ជានាមកិតកៈ ។

៣. អព្យយបច្ច័យសម្រាប់ប្រើចុះខាងចុងនាមនាម, គុណនាមនិង សព្វនាមដើម្បីធ្វើឱ្យស័ព្ទនោះ ៗ ក្លាយជាអព្យយស័ព្ទដូចជា **រុក្ខតោ**, **កុហឹ**, **យត្រ** ជាដើម អធិប្បាយរួចហើយក្នុងមេរៀនខាងដើម ។

៤. តទ្ធិតបច្ច័យសម្រាប់ប្រើចុះក្នុងចុងស័ព្ទច្រើនយ៉ាង ដើម្បីប្រើជំនួសស័ព្ទដូចជានាមនាម, គុណនាម, អាខ្យាតកិរិយា, កិតកិរិយា (ប៉ុន្តែមិនចុះជំនួសស័ព្ទដែលជាតទ្ធិតដូចគ្នាទេ) គឺប្រើជំនួសស័ព្ទណាដែលត្រូវលុបបាត់រូបទៅ ។ សូមចងចាំថា ស្រៈទីបំផុតនៃបទដើមរមែងលុបចោលជានិច្ច ។

ឧទាហរណ៍ **ធម្មិក**

បើញែកចេញពីគ្នាដើម្បីឱ្យដឹងថាជាបច្ច័យអ្វីគឺដូច្នេះ

(**ធម្ម + ឥក**) > **ធម្មិក**

យើងក៏អាចដឹងភ្លាមថាជា **ធម្ម** ចុះ **ឥក** ឬ **ណិក** បច្ច័យក៏បាន

ពីព្រោះបច្ច័យដែលមានតួ **ណ** អាចលុបតួ **ណ** ចេញសល់នៅតែស្រៈដែល **ណ** អាស្រ័យ (នឹងមានអធិប្បាយនៅខាងមុខ) ។ សូមសង្កេតមើលតទៅទៀតថាតើ **ឥក** ឬ **ណិក** បច្ច័យនេះនៅក្នុងតទ្ធិតណា ប្រើជំនួសស័ព្ទអ្វី ។ ក្នុងទីនេះជា **ណិក** បច្ច័យនៅក្នុង **តរត្យាទិតទ្ធិត** ។ ដើម្បីឱ្យដឹងបានថាតើប្រើជំនួសស័ព្ទអ្វីនោះ ត្រូវអាស្រ័យលើពាក្យប្រែដោយការតាំងវិគ្គហៈមើលសិន ។ **ធម្មិក** អាចប្រែបានពីរបែបគឺប្រែថា "អ្នកតាំងនៅហើយក្នុងធម៌ ឬ អ្នកប្រកបហើយក្នុងធម៌" ក៏បានដូចមានវិគ្គហៈខាងក្រោមនេះ

វិគ្គហៈថាទី ១. **ធម្មេ ឋិតោ ធម្មិកោ** (ជនោ) ។

វិគ្គហៈថាទី ២. **ធម្មេ និយុត្តោ ធម្មិកោ** (ជនោ) ។

ក្នុងវិគ្គហៈទី ១ **ណិក** បច្ច័យប្រើជំនួស **ឋិតោ** ប្រែថា "តាំងនៅហើយ" ។

ក្នុងវិគ្គហៈទី ២ **ណិក** បច្ច័យប្រើជំនួស **និយុត្តោ** ប្រែថា "ប្រកបហើយ" ។

ទាំង **ឋិតោ** និង **និយុត្តោ** ជាកិតកិរិយាត្រូវលុបបាត់ទៅ ហើយប្រើ **ណិក** បច្ច័យជំនួសវិញសម្រេចរូបជា **ធម្មិក** ។ ព្រោះហេតុដូច្នេះសឱ្យឃើញថាជារឿងពិបាក និងប្រសិនបើយើងចាប់ចំណុចសំខាន់មិនត្រូវទេ ក៏មិនយល់និងធ្វើឱ្យនឿយណាយបាន ។

## តទ្ធិតដោយសង្ខេបមាន ៣ យ៉ាងគឺ

### ១. សាមញ្ញតទ្ធិត, ២. ភាវតទ្ធិត, ៣. អព្យយតទ្ធិត

*តទ្ធិតទាំងបីប្រភេទនេះមានបច្ច័យរៀង ៗ ខ្លួន ដូចនឹងអធិប្បាយពីប្រភេទនីមួយ ៗ តទៅនេះ*

## ១. សាមញ្ញតទ្ធិត

*សាមញ្ញតទ្ធិតមាន ១៥ ប្រភេទគឺ*

| | | |
|---|---|---|
| ១. គោត្តតទ្ធិត | ៦. ឋានតទ្ធិត | ១១. បូរណតទ្ធិត |
| ២. តរត្យាទិតទ្ធិត | ៧. ពហុលតទ្ធិត | ១២. សំខ្យាតទ្ធិត |
| ៣. រាគាទិតទ្ធិត | ៨. សេដ្ឋតទ្ធិត | ១៣. វិភាគតទ្ធិត |
| ៤. ជាតាទិតទ្ធិត | ៩. តទស្សត្ថិតទ្ធិត | ១៤. ឧបមាតទ្ធិត |
| ៥. សមុហតទ្ធិត | ១០. តទស្សត្ថិតទ្ធិត | ១៥. និស្សិតតទ្ធិត |

*ពាក្យថា* **សាមញ្ញ** *ប្រែថា "ទូទៅ" មានសេចក្តីទូលំទូលាយមិនមានកម្រិត មិនមានកំណត់ថាមានសេចក្តីប៉ុនណាទេទើបសាមញ្ញតទ្ធិតមានរហូតដល់ទៅ ១៥ ដូចមានឈ្មោះខាងលើស្រាប់ ។*

*សាមញ្ញតទ្ធិតទាំង ១៥ យ៉ាងនេះអាចចែកជាពួកទៀត មាន ២*

ពួក មានឈ្មោះថា **អបច្ចត្ថសាមញ្ញតទ្ធិត**, **អនេកត្ថសាមញ្ញតទ្ធិត**, **អត្ថយត្ថសាមញ្ញតទ្ធិត** និង **សំខ្យាសាមញ្ញតទ្ធិត** ។

១. **អបច្ចត្ថសាមញ្ញតទ្ធិត** បានដល់ តទ្ធិតណាចុះបច្ច័យប្រាប់ថាជាផៅពង្សឬត្រកូលគឺ **គោត្តតទ្ធិត** ។

២. **អនេកត្ថសាមញ្ញតទ្ធិត** បានដល់ តទ្ធិតណាចុះបច្ច័យប្រាប់សេចក្ដីផ្សេង ៗ មាន ១០ គឺ **តរត្យាទិតទ្ធិត**, **រាគាទិតទ្ធិត**, **ជាតាទិតទ្ធិត**, **សមុហតទ្ធិត**, **ឋានតទ្ធិត**, **ពហុលតទ្ធិត**, **បកតិតទ្ធិត**, **វិការតទ្ធិត**, **ឧបមាតទ្ធិត** និង **និស្សិតតទ្ធិត** ។

៣. **អត្ថយត្ថសាមញ្ញតទ្ធិត** បានដល់ តទ្ធិតណាចុះបច្ច័យប្រាប់ថាមាននូវអ្វីមួយមាន ២ គឺ **សេដ្ឋតទ្ធិត** និង **តទស្សត្ថិតទ្ធិត** ។

៤. **សំខ្យាសាមញ្ញតទ្ធិត** បានដល់ តទ្ធិតណាចុះបច្ច័យប្រាប់នូវចំនួនមាន ២ គឺ **បូរណតទ្ធិត** និង **សំខ្យាតទ្ធិត** ។

## ១. គោត្តតទ្ធិត

គោត្តតទ្ធិត បានដល់ តទ្ធិតណាដែលសម្រេចមកអំពីនាមស័ព្ទដើមជានាមសំដៅដល់ គោត្ត, ត្រកូល, ពូជពង្ស, ផៅពង្ស និងដែលចុះបច្ច័យខ្វះរបស់តទ្ធិតនេះ ទើបហៅថា **គោត្តតទ្ធិត** ។ គោត្តតទ្ធិតនេះមានបច្ច័យ ៨ តួគឺ **ណ**, **ណវ**, **ណេរ**, **ណាយន**, **ណិ**, **ណិក**,

ណេយ្យ, ណេរ ។ បច្ច័យទាំងនេះជាបច្ច័យមានតួ ណ ទាំងអស់ លុះដល់វេលាចុះខាងចុងស័ព្ទណាតួ ណ នេះក៏ត្រូវលុបបាត់រូបទៅ នៅសល់តែស្រៈជា អ, អវ, អាន, អាយន, ឥ, ឥក, ឯយ្យ, ឯរ និង ដែលប្រើជំនួសពាក្យថា អបច្ច ប្រែថា "ពូជពង្ស, ត្រកូល" មួយស័ព្ទ ប៉ុណ្ណោះ បើប្រែផ្សេងពីនេះគឺជាតទ្ធិតដទៃហើយ ។

| | |
|---|---|
| ណ > អ | ណិ > ឥ |
| ណវ > អវ | ណិក > ឥក |
| ណាន > អាន | ណេយ្យ > ឯយ្យ |
| ណាយន > អាយន | ណេរ > ឯរ |

ចំពោះតួអក្សរ អ ដែលសរសេរមកនេះគឺគ្រាន់តែឱ្យស្រៈនិស្ស័យអានបញ្ចេញសំឡេងតែប៉ុណ្ណោះ វេលាប្រើត្រូវលុបចេញនិងស្រៈពេញតួត្រូវផ្លាស់ជាស្រៈនិស្ស័យវិញ ។

## ការប្រកបរូបស័ព្ទជាគោត្តតទ្ធិត

តទ្ធិតនេះមានបច្ច័យជាណានុព័ន្ធទាំងអស់ តាមក្រឹត្យជាទូទៅទាំងក្នុងអាខ្យាតនិងកិតកៈត្រូវលុប ណ ចេញជានិច្ច នៅសល់តែស្រៈដែល ណ អាស្រ័យ ។ ប៉ុន្តែសូម្បីតែលុបបាត់ទៅហើយក៏ដោយ ក៏នៅ

តែមានអំណាចឱ្យផ្លាស់ប្តូររូបរបស់ស័ព្ទដែលនៅខាងដើមបាន ដែលមានក្រឹត្យ ២ ប្រការគឺ

១. បើព្យាង្គដើមបំផុតនៃបទដើមជាស្រៈរស្សៈនិងមិនមានព្យញ្ជនសំយោគនៅខាងចុងទេ ត្រូវទីឃៈ អ > អា, ព្រឹទ្ធិ ឥ, ឦ > ឯ, និងព្រឹទ្ធិ ឧ, ឩ > ឱ ដូចខាងក្រោមនេះ

សមណ + ឯរ ( ណេរ ) > សាមណេរ

វិជា + ឯរ ( ណេរ ) > វេជេរ

ឧបកុ + អរ ( ណរ ) > ឱបការ

២. បើព្យាង្គដើមបំផុតនៃនាមស័ព្ទនោះ ៗ ជាស្រៈទីឃៈស្រាប់ ឬជារស្សៈតែមានព្យញ្ជនសំយោគតាមក្រោយ នោះពុំចាំបាច់ទីឃៈឬព្រឹទ្ធិស្រៈទេ ដូចខាងក្រោមនេះ

ជាជបុត្ត + ឥក ( ណិក ) > ជាជបុត្តិក

ឧក្ខ + ឥ ( ណិ ) > ឧក្ខិ

## កំណត់សម្គាល់

នេះគឺជាក្រឹត្យនៃការប្រកបរូបស័ព្ទជាមួយណានុព័ន្ធបច្ច័យ ទោះជាតទ្ធិតអ្វីក៏ដោយ ៗ បើប្រកបជាមួយណានុពន្ធ័បច្ច័យគឺបិតក្នុងគោល

ការណ៍ ២ ប្រការនេះប៉ុណ្ណោះ ។ ប្រសិនបើមិនមាន **ឈា** ទេត្រូវទុកឱ្យគង់រូបដើម ពុំចាំបាច់ទីឃៈឬព្រឹទ្ធិអ្វីឡើយ ។ សូមចងចាំឱ្យបានច្បាស់លាស់ ពីព្រោះឥតមានពោលម្ដងទៀតទេ ។

## វិធីតាំងវិគ្គហៈនៃគោត្តតទ្ធិត

ការតាំងវិគ្គហៈគឺដើម្បីស្វែងរកឫសគល់នៃពាក្យថា តើជាស័ព្ទអ្វី ? ប្រែដូចម្ដេច ? ដូចគ្នានឹងវិគ្គហៈរបស់នាមកិតកៈនិងវិគ្គហៈនៃសមាសដែរ (សមាសនឹងមានអធិប្បាយនៅខាងមុខ) ។ គោត្តតទ្ធិតមានវិធីតាំងវិគ្គហៈដូចតទៅនេះ

១. បទខាងដើមនិយមប្រើអសាធារណនាម ជាឈ្មោះរបស់បុគ្គលតែម្យ៉ាង បំបែកជាឆដ្ឋីវិភត្តិ(វិភត្តិនាម) ឱ្យត្រូវតាមការន្តនិងលិង្គនោះ ៗ ដែលប្រែថា "របស់..., នៃ..." ជានិច្ច រៀងដាក់ទី ១ ។

២. បទខាងចុងប្រើ **អបច្ច** ស័ព្ទដែលជានាមស័ព្ទបំបែកជាបឋមាវិភត្តិគឺបំបែកដូច **កុល** ទៅជា **កុលំ** ដូច្នេះ **អបច្ច** ទៅជា **អបច្ចំ** ប្រែថា "ត្រកូល" រៀងដាក់ទី ២ ។

៣. បទតទ្ធិត ត្រូវយកបទខាងដើមមកចុះបច្ច័យតួណាមួយក្នុងបច្ច័យទាំង ៨ តួនោះ ដើម្បីជំនួស **អបច្ច** ដែលត្រូវលុបបាត់ទៅ និងត្រូវបំបែកជាបឋមាវិភត្តិឱ្យត្រូវតាមការន្តនិងលិង្គនោះ ៗ រៀងដាក់ទី ៣ ។

លុះដល់វេលាប្រែត្រូវប្រែបទប្រធានគឺ **អបច្ច** ប្រែទី ១ ។ បន្ទាប់មកប្រែបទអធិប្បាយរបស់បទប្រធាន គឺបទដែលបំបែកជាឆដ្ឋីវិភត្តិនោះ ប្រែទី ២ គឺប្រែពីខាងចុងទៅរកខាងដើម រួចទើបប្រែបទតទ្ធិតទី ៣ តាមលំដាប់ ដូចឧទាហរណ៍ខាងក្រោមនេះ

## ១. ណ បច្ច័យ

(*វសិដ្ឋ អសាធារណនាម* + **ណ**) > **វាសិដ្ឋ**

| ១ | ២ | ៣ |
|---|---|---|
| វិ. **វសិដ្ឋស្ស** | **អបច្ចំ** | **វាសិដ្ឋោ** ។ |
| បទដើម | បទចុង | បទតទ្ធិត |

វិធីប្រែមិនខុសគ្នាពីរបៀបប្រែវិគ្គហៈនៃនាមកិតកៈទេ ប្រែដូចខាងក្រោមនេះ

**អបច្ចំ** វីត្រកូល **វសិដ្ឋស្ស** របស់វសិដ្ឋ **វាសិដ្ឋោ** ឈ្មោះថា **វាសិដ្ឋោ**, **វាសិដ្ឋោ** =វីត្រកូលរបស់វសិដ្ឋ ។

ប្រែយ៉ាងនេះជាតទ្ធិតនាម បើចង់ឱ្យទៅជាតទ្ធិតគុណនាមត្រូវថែមអញ្ញបទ គឺនាមបទដទៃចូលមកក្នុងវិគ្គហៈនិងថែម **យ-ត** សព្វនាមចូលដូចខាងក្រោមនេះ

(យោ) **វសិដ្ឋស្ស អបច្ចំ** (សោ) **វាសិដ្ឋោ** (ជនោ) ។

*ប្រែដូច្នេះ (យោ ជនោ វីជន ឯណា)* **អបច្ចំ** *ជាត្រកូល* **វសិដ្ឋស្ស** *របស់វសិដ្ឋ (សោ ជនោ វីជន នោះ)* **វាសិដ្ឋោ** *ឈ្មោះថា* **វាសិដ្ឋោ**, **វាសិដ្ឋោ** (ជនោ) = *(ជន) ជាត្រកូលរបស់វសិដ្ឋ ។*

*សូមពិនិត្យមើល ក្នុងតទ្ធិតគុណនាមត្រូវថែមពាក្យប្រែថា "ជា..." ។*

*ពាក្យថា* **វសិដ្ឋ** *ជាឈ្មោះរបស់ឥសី ដូច្នេះបុគ្គលណាដែលកើតចេញពីត្រកូលនេះ ទាំងស្រីទាំងប្រុសហៅថា* **វាសិដ្ឋ** *។ មានស័ព្ទតទ្ធិតខ្លះទៀតដែលចុះ* **ណ** *បច្ច័យនិងតាំងវិគ្គហៈដូច* **វាសិដ្ឋោ** *គឺ* **គោតមោ** *=ត្រកូលនៃគោតមៈ,* **វាសុទេវោ** *=ត្រកូលនៃវសុទេវៈ,* **ពាលទេវោ** *= ត្រកូលនៃពលទេវៈ,* **ភារទ្វាជោ** *=វង្សនៃភារទ្វាជៈ ។*

*ចូរអ្នកសិក្សារៀនតាំងវិគ្គហៈនិងប្រែតាមបែប* **វាសិដ្ឋោ** *ដូចនៅខាងលើដោយខ្លួនឯងផង ដើម្បីឱ្យកើតជំនាញនិងមានការប៉ិនប្រសប់ ។ ម៉្យាងទៀត វិធីប្រែវិគ្គហៈតាមវិធីលោតប្រយោគដូចពោលហើយនេះ ឃើញថាមិនមានពាក្យ "ព្រោះហេតុនោះ" ទេ ព្រោះមិនមាន* **ឥតិ** *ស័ព្ទនៅជាមួយ សូមចាំទុកផងចុះ ។ ចំពោះបច្ច័យដទៃ ៗ ទៀតដែលនឹងពោលដល់នៅខាងមុខក៏មានគតិដូច* **វាសិដ្ឋ** *នេះដែរ ។ នាពេលក្រោយមិនប្រែលោតប្រយោគទៀតទេ គឺប្រែត្រឹមតែស័ព្ទប៉ុណ្ណោះ ចូរមានការយល់ដឹងតាមន័យនេះផង ។ សូមបញ្ជាក់ថាស័ព្ទដែលជាគោត្តតទ្ធិតនេះអាចប្រព្រឹត្តទៅបានទាំង ៣ លិង្គ បើជាមនុស្សប្រុសត្រូវបំបែកតាមបែប*

បុរិស, បើជាស្ត្រីត្រូវថែមស្រៈ ឦ ទៅជា **ភសិឌ្ឌី** ជាដើមរួចបំបែកតាមបែប **ធារី**, បើជាត្រកូលត្រូវបំបែកដូច **កុល** នបុំសកលិង្គ ។

***សូមបញ្ជាក់*** ពាក្យណាដែលមិនទាន់យកមកប្រើឬមិនទាន់បំបែក គឺដែលមិនទាន់ចុះវិភត្តិទេ ពាក្យនោះ ៗ ហៅថា "ស័ព្ទ" ប៉ុន្តែបើយកមកប្រើក្នុងប្រយោគហើយត្រូវហៅថា "បទ" ។

## ២. ណាយន បច្ច័យ

(កច្ច + ណាយន ) > កច្ចាយន

*វិ.* កច្ចស្ស អបច្ចំ កច្ចាយនោ =*ត្រកូលនៃកច្ចៈ ។*

( វច្ឆ + ណាយន ) > វច្ឆាយន

*វិ.* វច្ឆស្ស អបច្ចំ វច្ឆាយនោ =*ត្រកូលនៃវច្ឆៈ ។*

( មោគ្គលី + ណាយន ) > មោគ្គល្លាយន

*វិ.* មោគ្គល្លិយា អបច្ចំ មោគ្គល្លាយនោ =*ត្រកូលនៃមោគ្គល្លី ។*

## ៣. ណាន បច្ច័យ

កច្ច + ណាន > កច្ចាន

វច្ឆ + ណាន > វច្ឆាន

មោគ្គល្លី + ណាន > មោគ្គល្លាន

ទាំងបីស័ព្ទនេះមានវិធីតាំងវិគ្គហៈនិងប្រែដូច **ណាយន** បច្ច័យដែរ ។

## ៤. ណេយ្យ បច្ច័យ

(កត្តិកា + ណេយ្យ) > កត្តិកេយ្យ

វិ. កត្តិកាយ អបច្ចំ កត្តិកេយ្យោ =ត្រកូលនៃប្អូនស្រី ។

(វិនតា + ណេយ្យ) > វេនតេយ្យ

វិ. វិនតាយ អបច្ចំ វេនតេយ្យោ =ត្រកូលនៃវិនតា ។

(រោហិណី + ណេយ្យ) > រោហិណេយ្យ

វិ. រោហិណិយា អបច្ចំ រោហិណេយ្យោ =ត្រកូលនៃរោហិណី ។

## ៥. ណិ បច្ច័យ

(អក្ខ + ណិ) > ទក្ខិ

វិ. ទក្ខស្ស អបច្ចំ ទក្ខិ =ត្រកូលនៃទក្ខៈ ។

(វសវ + ណិ) > វាសវិ

វិ. វសវស្ស អបច្ចំ វាសវិ =ត្រកូលនៃវសវៈ ។

(វរុណ + ណិ) > វារុណិ

វិ. វរុណស្ស អបច្ចំ វារុណិ =ត្រកូលនៃវរុណៈ ។

## ៦. ណិក បច្ច័យ

(សក្យបុត្ត + ណិក) > សក្យបុត្តិក

វិ. សក្យបុត្តស្ស អបច្ចំ សាក្យបុត្តិកោ =ត្រកូលនៃសក្យៈបុត្រ ។

(ជាជបុត្ត + ណិក) > ជាជបុត្តិក

វិ. ជាជបុត្តស្ស អបច្ចំ ជាជបុត្តិកោ =ត្រកូលនៃកូនអ្នករបាំ ។

(ជិនទត្ត + ណិក) > ជេនទត្តិក

វិ. ជិនទត្តស្ស អបច្ចំ ជេនទត្តិកោ =ត្រកូលនៃជិនទត្ត ។

## ៧. ណវ បច្ច័យ

(ឧបកុ + ណវ) > ឱបកវ

វិ. ឧបកុស្ស អបច្ចំ ឱបកវោ =ត្រកូលនៃឧបកុ ។

(មនុ + ណវ) > មានវ

វិ. មនុនោ អបច្ចំ មានវោ =ត្រកូលនៃមនុ ។

(ភគ្គុ + ណវ) > ភគ្គវ

វិ. ភគ្គុនោ អបច្ចំ ភគ្គវោ =ត្រកូលនៃភគ្គុ ។

## ៨. ណេរ បច្ច័យ

(វិធវា + ណេរ) > វេធវេរ

វិ. វិជាយ អបច្ចំ វេជវោ =ត្រកូលនៃស្រីមេម៉ាយ ។

( **សមណា** + **ណេរ** ) > **សាមណេរ**

វិ. **សមណាស្ស** អបច្ចំ **សាមណេរោ** =ត្រកូលនៃសមណៈ ។

## កំណត់សម្គាល់

*រូបស័ព្ទរបស់តទ្ធិតទាំងអស់ខាងលើនេះជានាមនាម ។ វេលាប្រើត្រូវបំបែកតាមការន្ត, វិភត្តិ, លិង្គ និងវចនៈនៃសេចក្ដីក្នុងទីនោះ ៗ ។ បើប្រាថ្នាប្រើជាគុណនាមជាបទវិសេសនៈនៃបទនាមណា ក៏ត្រូវបំបែកឱ្យស្មើគ្នានឹងនាមជាប្រធាននោះ ៗ ជានិច្ច ។*

*កាលណាយកទៅប្រើក្នុងប្រយោគ ត្រូវលើកយកតែតទ្ធិតស័ព្ទ គឺយកទៅប្រើតែបទតទ្ធិតប៉ុណ្ណោះ មិនយកទាំងវិគ្គហៈផងទេ ពីព្រោះចុះបច្ច័យជំនួសដើម្បីកាត់បទឱ្យតិច គឺឱ្យខ្លីហើយ និងបច្ច័យនីមួយ ៗ ប្រាប់អត្ថប្រយោជន៍នៃស័ព្ទនោះ ៗ រួចជាស្រេចហើយដែរ ។ រឿងសំខាន់បំផុតគឺត្រូវចាំវិធីរូបសិទ្ធិ (វិធីប្រកបរូបស័ព្ទ) ឱ្យបាន ។ ស័ព្ទតទ្ធិតឯទៀត ៗ ក៏មានសេចក្ដីដូចខាងលើនេះទាំងអស់ ។*

**(គោត្តតទ្ធិតចប់)**

## ២. តរត្យាទិតទ្ធិត

ឈ្មោះថា **តរត្យាទិតទ្ធិត** នេះសម្រេចមកពី (**តរតិ** + **អាទិ** + **តទ្ធិត**) > **តរត្យាទិតទ្ធិត** (ផ្លាស់ ឥ នៃ **តិ** ជា យ > **ត្យ** បានជា **តរត្យ** + **អាទិ**) ។ **តរតិ** =ឆ្លង, **អាទិ**=ជាដើម ប្រែថា តទ្ធិតដែលមាន **តរតិ** ជាខាងដើម ។ ក្នុងទីនេះនឹងមិនរាប់តាមឈ្មោះមួយ ៗ ដូចក្នុងបករណ៍ឯទៀតទេ គឺបែកប្រភេទតាមវិធីតាំងវិគ្គហៈវិញ ដើម្បីឱ្យស្រួលយល់ ។

តទ្ធិតនេះមានបច្ច័យតែមួយតួគត់គឺ **ណិក** ជាគ្រឿងសម្គាល់និងប្រើជំនួសសព្ទបួនប្រភេទគឺ អាខ្យាតកិរិយា, កិតកិរិយា, នាមនាម និងគុណនាម ។ បើប្រើជំនួសនាមសព្ទណា នាមសព្ទនោះ ៗ ក្លាយជាគុណនាម ។ ប្រសិនបើនាមនោះ ៗ ជាប់ទាក់ទងនឹងមនុស្សឬសត្វមានជីវិតត្រូវប្រែថា "អ្នកដែល ..." ជានិច្ច ។ ការប្រកបរូបសព្ទជាមួយបច្ច័យជាណានុពន្ធមានអំណាចយ៉ាងម៉េច ចូរមើលក្នុងគោត្តតទ្ធិតខាងលើ ។

**ណិក** បច្ច័យនេះប្រើក្នុងសេចក្តីច្រើនយ៉ាង(អនេកត្ថ)ដូចជា ការលាយ, ការពាក់ព័ន្ធ, មធ្យោបាយរស់នៅ, មធ្យោបាយធ្វើដំណើរ, ទំនាក់ទំនង, ការលេងគ្រឿងភ្លេង, ការនាំយក, ទីកើតឬទីរស់នៅ, ការសិក្សា, ការប្រព្រឹត្តិ ជាដើម ។ មានវិធីតាំងវិគ្គហៈ ៤ បែបដូចខាងក្រោមនេះ

### វិធីតាំងវិគ្គហៈនៃតរត្យាទិតទ្ធិត

## ១. ប្រភេទប្រើជំនួសអាខ្យាតកិរិយា

១. បទដើមជាសាធារណនាម ត្រូវបំបែកតាមវិភត្តិផ្សេង ៗ ឱ្យត្រូវជាមួយសេចក្តីក្នុងវិគ្គហៈនោះ ៗ ។

២. បទចុងជាអាខ្យាតកិរិយា ត្រូវធ្វើសន្ធិជាមួយ **ឥតិ** ស័ព្ទ ។

៣. បទតទ្ធិតត្រូវចុះ **ណិក** បច្ច័យជំនួសកិរិយាស័ព្ទវិញ និងបំបែកជាបឋមាវិភត្តិឱ្យត្រូវតាមការន្តនោះ ៗ ។

ប្រសិនបើប្រើជំនួសអាខ្យាតកិរិយាត្រូវថែម **ឥតិ** ស័ព្ទចូលមកខាងចុងអាខ្យាតកិរិយា ដូចជា (**វសតិ** + **ឥតិ**) > **វសតីតិ** (ចូរមើលវិធីសរសេរ **ឥតិ** ស័ព្ទក្នុងមេរៀនទី ៣០) ។

(នាមនាម + កិរិយាអាខ្យាត + **ឥតិ**) > បទតទ្ធិត

១ ២ ៣

វ. **នាវាយ តរតីតិ នាវិកោ** ។

បទដើម បទចុង បទតទ្ធិត

១. (**នាវា** + **ណិក**) > **នាវិក**

វ. **នាវាយ តរតីតិ នាវិកោ** (**ជនោ**) =(ជន) អ្នកដែលឆ្លងដោយទូក (អ្នកដែលធ្វើដំណើរតាមទូក) ។

ក្នុងវិគ្គហៈ បទថា **នាវាយ តរតីតិ** មិនមានបទប្រធានទេ ដូច្នេះ ចាំបាច់ត្រូវរកបទប្រធានមកបញ្ចូលដើម្បីឱ្យប្រែបានសេចក្ដីល្អ និងភាគច្រើននិយមថែម **យ-ត** ចូលមក ឱ្យទៅជាប្រយោគ **យ-ត** ប្រែដូចខាងក្រោមនេះ

(**យោ ជនោ** វីជន ឯណា) **តរតិ** រមែងឆ្លង **នាវាយ** ដោយទូក **ឥតិ** ព្រោះហេតុនោះ (**សោ ជនោ** វីជន នោះ) **នាវិកោ** ឈ្មោះថា **នាវិកោ**, **នាវិកោ** (**ជនោ** វីជន) =អ្នកដែលឆ្លងដោយទូក (អ្នកដែលដើរទូក, អ្នកដែលរស់នៅលើទូក, អ្នកទូក ។ល។) ។

រីឯវិគ្គហៈដទៃទៀតនៅខាងក្រោមក៏ប្រែតាមន័យដូចគ្នា ចូរចាំទុកជាគោលទើបប្រែបានទាន់ចិត្ត តទៅនឹងប្រែតែសព្ទប៉ុណ្ណោះ ។

**២. (សកដ+ ណិក) > សាកដិក**

វិ. **សកដេន ចរតីតិ សាកដិកោ (ជនោ)** =(ជន) អ្នកដែលដើរដោយរទេះ (អ្នកដែលធ្វើកិច្ចការដោយប្រើរទេះ, អ្នករទេះ) ។

**៣. (បាទ + ណិក) > បាទិក**

វិ. **បាទេន ចរតីតិ បាទិកោ (ជនោ)** =(ជន) អ្នកដែលដើរដោយជើង (អ្នកដែលដើរ, ថ្មើរ) ។

**៤. (អក្ខ + ណិក) > អក្ខិក**

វិ. **អក្ខេន ទិព្វតីតិ អក្ខិកោ (ជនោ)** =(ជន) អ្នកដែលលេងដោយខ្លាច់ (អ្នកលេងបាស្កា) ។

**៥. (កាយ + ណិក) > កាយិក**

វិ. **កាយេ វត្តតីតិ កាយិកំ (កម្មំ)** =(កម្មំ) ដែលប្រព្រឹត្តទៅក្នុងកាយ ។

ក្នុងវិគ្គហៈនេះត្រូវថែម **យំ-តំ** ចូលមកឱ្យត្រូវគ្នានឹង **កាយិកំ** ដែលជានបុំសកលិង្គ និងមិនមានពាក្យប្រែថា "អ្នកដែល..." ទេ ពីព្រោះមិនទាក់ទងនឹងនាមដែលជាមនុស្សឬសត្វមានជីវិត ។

**៦. (មន + ណិក) > មនសិក**

វិ. **មនសិ វត្តតីតិ មនសិកំ (កម្មំ)** =(កម្មំ) ដែលប្រព្រឹត្តទៅក្នុងចិត្ត ។

**៧. (រាជគហ + ណិក) > រាជគហិក**

វិ. **រាជគហេ វសតីតិ រាជគហិកោ (ជនោ)**= (ជន) អ្នកដែលរស់នៅក្នុងក្រុងរាជគ្រឹះ (អ្នកនៅក្រុងរាជគ្រឹះ, អ្នករាជគ្រឹះ) ។

**៨. (វិនយ + ណិក) > វេនយិក**

វិ. **វិនយំ អធិតេតិ វេនយិកោ (ភិក្ខុ)** =(ភិក្ខុ) អ្នកដែលរៀនទ្រូវវិន័យ (អ្នកសិក្សាខាងវិន័យ) ។

**៩. (សិស + ណិក) > សីសិក**

វិ. **សីសេន វហតីតិ សីសិកោ (ជនោ)** =(ជន) អ្នកដែលនាំទៅដោយក្បាល (អ្នកទូល) ។

**១០. (កុម្ភ + ណិក) > កុម្ភិក**

វិ. **កុម្ភំ អរហតីតិ កុម្ភិកោ ( ជនោ )** =(ជន) អ្នកដែលនាំទៅនូវក្អម (ដែលដាក់ឥវ៉ាន់ក្នុងក្អម, អ្នកទូលក្អម) ។

**១១. ( លោក + ណិក ) > លោកិក**

វិ. **លោកាយ សំវត្តតីតិ លោកិកោ ( ធម្មោ )** =(ធម៌) ដែលប្រព្រឹត្តទៅព្រមដើម្បីសត្វលោក ។

**១២. ( ពលិស + ណិក ) > ពាលិសិក**

វិ. **ពលិសេន ជីវតីតិ ពាលិសិកោ ( ជនោ )** =(ជន) អ្នកដែលរស់នៅដោយទំពក់ (អ្នកនេសាទ) ។

**១៣. ( សកុណ + ណិក ) > សាកុណិក**

វិ. **សកុណេ ហន្ត្វា ជីវតីតិ សាកុណិកោ ( ជនោ )** =(ជន) អ្នកដែលសម្លាប់បក្សីកំពុងរស់ (ព្រានបក្សី) ។

**បញ្ជាក់** វិគ្គហៈនេះ **ណិក** បច្ច័យប្រើជំនួសពាក្យពីរម៉ាត់ព្រមគ្នា គឺកិតកិរិយា បានដល់ **ហន្ត្វា** =សម្លាប់ហើយ និងអាខ្យាតកិរិយាគឺ **ជីវតិ** =កំពុងរស់ ។

## ២. ប្រភេទប្រើជំនួសកិតកិរិយា

ក្នុងវិគ្គហៈត្រូវមាន

*១. បទដើមជាសាធារណនាម ត្រូវបំបែកតាមវិភត្តិផ្សេង ៗ ឱ្យត្រូវជាមួយសេចក្តីក្នុងវិគ្គហៈនោះ ៗ ។*

*២. បទចុងជាកិតកិរិយា មិនបាច់ប្រើ* **ឥតិ** *ទេ ។*

*៣. បទតទ្ធិតប្រើ* **ណិក** *បច្ច័យជំនួសនិងបំបែកជាបឋមាវិភត្តិឱ្យត្រូវតាមការន្តនោះ ៗ ។*

*(នាមនាម + កិតកិរិយា) > បទតទ្ធិត*

\ | /

១ ២ ៣

| | |

**វិ. តិលេហិ សំសដ្ឋំ តេលិកំ ។**

| | |

*បទដើម បទចុង បទតទ្ធិត*

១. (**តិល** + **ណិក**) > **តេលិក**

*វិ.* **តិលេហិ សំសដ្ឋំ តេលិកំ** (**ភោជនំ**) =(*ភោជន*)*ដែលលាយហើយដោយល្ង (អាហារលាយល្ង) ។*

*ប្រែលោតប្រយោគថា* (**យំ ភោជនំ** *វីភោជន ឯណា*) **សំសដ្ឋំ** *ដែលលាយហើយ* **តិលេហិ** *ដោយល្ង.ទ.* **តេលិកំ** *ឈ្មោះថា* **តេលិកំ**, **តេលិកំ** (**ភោជនំ** *វីភោជន*) *ដែលលាយហើយដោយល្ង ។*

២. (**កាយ** + **ណិក**) > **កាយិក**

*វិ.* **កាយេន កតំ កាយិកំ** (**កម្មំ**) = (*អំពើ*) *ដែលធ្វើហើយដោយកាយ ។*

៣. (វច + ណិក) > វាចសិក

វិ. វចសា កតំ វាចសិកំ (កម្មំ) =(អំពើ) ដែលធ្វើហើយដោយសំដី ។

៤. (រាជគហ + ណិក) > រាជគហិក

វិ. រាជគហេ ជាតោ រាជគហិកោ (ជនោ) =(ជន) អ្នកដែលកើតហើយក្នុងក្រុងរាជគ្រឹះ (អ្នកក្រុងរាជគ្រឹះ) ។

៥. (ទ្វារ + ណិក) > ទោវារិក

វិ. ទ្វារេ និយុត្តោ ទោវារិកោ (ជនោ) =(ជន) អ្នកដែលប្រកបហើយក្នុងទ្វារ (អ្នកចាំទ្វារ) ។

៦. (សុវណ្ណ + ណិក) > សោវណ្ណិក

វិ. សុវណ្ណេន កីតំ សោវណ្ណិកោ (ភណ្ឌំ) =(អីវ៉ាន់) ដែលជនទិញហើយដោយមាស ។

៧. (ពុទ្ធ + ណិក) > ពុទ្ធិក

វិ. ពុទ្ធេ បសន្នោ ពុទ្ធិកោ (ជនោ) =(ជន) អ្នកដែលជ្រះថ្លាហើយក្នុងព្រះពុទ្ធ ។

៨. (ជាល + ណិក) > ជាលិក

វិ. ជាលេន ហតោ ជាលិកោ (សត្តោ) =(សត្វ) ដែលសម្លាប់ហើយដោយសំណាញ់ ។

៩. (សុត្ត + ណិក) > សុត្តិក

វិ. **សុត្តេន ពន្ធោ សុត្តិកោ** (**សត្តោ**) =(សត្វ) ដែលចងហើយដោយចេស ។

## ៣. ប្រភេទប្រើជំនួសនាមនាម

ប្រសិនបើប្រើជំនួសនាមនាមត្រូវបំបែកស័ព្ទទាំងនេះជាបឋមាវិភត្តិ ឱ្យត្រូវតាមការន្តនិងលិង្គនោះ ៗ និងពុំចាំបាច់ថែម **ឥតិ** ទេ ។

ក្នុងវិគ្គហៈត្រូវមាន

១. បទដើមជាសាធារណនាម ត្រូវបំបែកជាបឋមាវិភត្តិតាមការន្ត និងលិង្គនោះ ៗ ។

២. បទកណ្ដាលត្រូវប្រើ **អស្ស** ប្រែថា "នៃជននោះ" ។

៣. បទចុងជាសាធារណនាម ត្រូវបំបែកជាបឋមាវិភត្តិតាមការន្ត និងលិង្គនោះ ៗ ។

៤. បទតទ្ធិតត្រូវចុះ **ណិក** បច្ច័យជំនួសស័ព្ទដែលលុបបាត់ទៅ និងបំបែកជាបឋមាវិភត្តិឱ្យត្រូវតាមការន្តនិងលិង្គនោះ ៗ ។

(នាមនាម + **អស្ស** + នាមនាម) > បទតទ្ធិត

១ ២ ៣ ៤

វិ. **មុគ្គរោ អស្ស អាវុធោ មុគ្គរិកោ** ។

បទដើម បទកណ្ដាល បទចុង បទតទ្ធិត

១. (មុគ្គរ + ណិក) > មុគ្គរិក

វិ. មុគ្គរោ អស្ស អាវុធោ មុគ្គរិកោ (ជនោ) =(ជន) អ្នកដែលមានអន្ទង់ជាអាវុធ ។

ប្រែលោតប្រយោគថា មុគ្គរោ រីអន្ទង់ អាវុធោ ជាអាវុធ អស្ស របស់ជននោះ (អត្ថិ មាន), (សោ ជនោ ជន នោះ) មុគ្គរោ ឈ្មោះថា មុគ្គរោ, មុគ្គរោ អ្នកដែលមានអន្ទង់ជាអាវុធ ។

២. (មុសល + ណិក) > មោសលិក

វិ. មុសលោ អស្ស អាវុធោ មោសលិកោ (ជនោ) =(ជន) អ្នកដែលមានអង្រែជាអាវុធ ។

៣. (វាត + ណិក) > វាតិក

វិ. វាតោ អស្ស អាពាធោ វាតិកោ (ជនោ) =(ជន) អ្នកដែលមានខ្យល់ជាអាពាធ ។

៤. (កុម្ភ + ណិក) > កុម្ភិក

វិ. កុម្ភោ អស្ស បរិមាណំ កុម្ភិកោ (វត្ថុ) =(វត្ថុ) មានដែលផ្ទាំងជាប្រមាណ (រង្វាស់ជាផ្ទាំង) ។

៥. វីណា + ណិក) > វេណិក

វិ. វីណា អស្ស សិប្បន្តិ វេណិកោ (ជនោ) =(ជន) អ្នកដែលមានពិណជាសិល្បៈ (អ្នកលេងពិណ) ។

៦. (គន្ធ + ណិក) > គន្ធិក

វិ. កណ្ឌោ អស្ស ភណ្ឌំ កណ្ឌិកោ (ជនោ) =(ជន) អ្នកដែលមានគ្រឿងក្រអូបជាភ័ណ្ឌ (អ្នកលក់គ្រឿងតែងសម្ងួស្ស) ។

## ៤. ប្រភេទប្រើជំនួសគុណនាមសុទ្ធ

### ១. (សង្ឃ + ណិក) > សង្ឃិក

វិ. សង្ឃស្ស សន្តកំ សង្ឃិក (វត្ថុ) =(វត្ថុ) ដែលជារបស់សង្ឃ។

ប្រែលោតប្រយោគ (យំ វត្ថុ រីវត្ថុ ឯណា) សន្តកំ ដែលជារបស់ សង្ឃស្ស នៃសង្ឃ (តំ វត្ថុ រីវត្ថុ នោះ) សង្ឃិកំ ឈ្មោះថា សង្ឃិកំ, សង្ឃិកំ ដែលជារបស់នៃសង្ឃ ។

ក្នុងវិគ្គហៈត្រូវថែម យំ-តំ យោគ វត្ថុ ដែលជាបទប្រធាន ពីព្រោះ សន្តកំ (វត្ថុប្រើប្រាស់) ជាគុណនាមសុទ្ធនិងជានបុំសកលិង្គ ត្រូវលុបបាត់ទៅហើយប្រើ ណិក ជំនួសវិញទៅជា សង្ឃិក ប្រែថា "ដែលជារបស់សង្ឃ" ។

### ២. (កោសល + ណិក) > កោសលិក

វិ. កោសលេ ឥស្សរោ កោសលិកោ (ជនោ) =(ជន) អ្នកដែលជាធំក្នុងដែនកោសល ។

## កំណាត់សម្គាល់

នាមស័ព្ទដែលប្រកបពី **ណិក** បច្ច័យក្នុងតទ្ធិតនេះជាគុណនាមតែម្យ៉ាង អាចបំបែកបានទាំងបីលិង្គ ឧទាហរណ៍. **ទោវារិក** ជា អការន្តបំបែកតាមបែប **បុរិស** គ្រប់ប្រការ ។ បើជាឥត្ថីលិង្គត្រូវចុះ **អា** បច្ច័យទៅជា **ទោវារិកា** បំបែកដូច **កញ្ញា** និងបើជានបុំសកលិង្គបំបែកដូច **កុល** គ្រប់ប្រការ ។

ចំណុចសំខាន់គឺត្រូវចាំពាក្យប្រែ(អាយតនិបាត)ឱ្យបានច្បាស់ ឧ. **កាយេន** យើងអាចដឹងបានភ្លាម ៗ ថាជាតតិយាវិភត្តិដោយសារចុងពាក្យជា **ឯន** ប្រែថា "ដោយ, តាម, គឺ, ដែល" យ៉ាងណាមួយស្រេចតែសេចក្តីក្នុងទីនោះ ៗ ។ **កាយេន** "ដោយកាយ" បើជា **កាយស្ស**, **កាយេសុ**, **កាយានំ** ត្រូវផ្លាស់ពាក្យប្រែទៅតាមវិភត្តិនោះ ៗ ទៅ ។

(តវត្យាទិតទ្ធិតចប់)

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ |
|---|---|
| **មាណវ** បុំ. | មនុស្សកម្លោះ |
| **តាវតឹស** បុំ. | ឋានតាវតិង្ស |
| **កនក** នបុំ. | មាស |

**កនកវិមាន** នបុំ. វិមានធ្វើពីមាស

**សូករិក** បុំ. អ្នកលក់ជ្រូក

**សាកុណិក** បុំ. ព្រានបក្សី

**ជាលិក** បុំ. អ្នកបង់សំណាញ់

**ពលក្ការ** បុំ. កិរិយាកំហែង

**កាសាវ** នបុំ. សំពត់ជ្រលក់ទឹកអំបត់

**មត្តិកា** ឥ. ដីឥដ្ឋ

**មត្តិកាបត្ត** បុំ. បាត្រធ្វើពីដីឥដ្ឋ

**ជិណ្ណាហារ** បុំ. អាហារគឺ...ឱ្យហើយ

**ជីវិកា** ឥ. អ្នករស់នៅ

**ភណ្ឌាគារិក** បុំ. អ្នករក្សាឃ្លាំង

**ទោវារិក** គុ. អ្នកប្រកបក្នុងទ្វារ, អ្នកយាមទ្វារ

**ឧបរិបាសាទ** បុំ. ខាងលើនៃប្រាសាទ

**អាគមន** នបុំ. ការមកដល់

**សណ្ឋាគារ** បុំ. រោងប្រជុំ

**វាលុ** បុំ. ដីខ្សាច់

**សក្យបុត្ត** បុំ. កូននៃសក្យត្រកូល

**សក្យកុល** នបុំ. ត្រកូលសក្យៈ

**អនាគារិយ** នបុំ. អ្នកគ្មានផ្ទះ, អ្នកបួស

សង្ឃិក គុ. ជារបស់សង្ឃ
កាយិក គុ. ប្រព្រឹត្តទៅក្នុងកាយ
កុររឃរដ្ឋគរ បុំ. (ឈ្មោះនគរ)
សោណ បុំ. (ឈ្មោះព្រាហ្មណ៍)
អបរភាគ បុំ. ចំណែកដទៃទៀត
កុជិកណ្ណ គុ. មានត្រចៀកយារ
ចាកជ គុ. ប្រាកដ, ជាក់ស្ដែង
មល្ល បុំ. ស្ដេចមល្ល:
អារញ្ញិក បុំ. អ្នកនៅព្រៃ
លង្កា ឥ. ស្រុកលង្កា
សមុទ្ទចារំ នបុំ. ខាងនាយសមុទ្រ
មាគធិក បុំ. អ្នកនៅមគធ:
មាគធ បុំ. អ្នកនៅមគធ:
សេណិយ បុំ. នាយពួក
ពិម្ពិសារ បុំ. ព្រះរាជាពិម្ពិសារ
រាជគហ បុំ. ក្រុងរាជគ្រឹះ
ចាដលិគាម បុំ. ស្រុកបាដលិ
កុណ្ឌិកា ឥ. ថូទឹក, កណ្ឌី
ចាវា ឥ. ស្រុកបាវា

មហាបជាបតិ ឥ. នាងមហាបជាបតី
មហាវន នបុំ. ឈ្មោះព្រៃមហាវ័ន
ឧរុវេលកស្សប បុំ. ព្រះឧរុវេលកស្សបៈ
យោជនិក គុ. ប្រកបដោយយោជន៍
សុវណ្ណមយ គុ. ធ្វើពីមាស
តាវតឹសទេវលោក បុំ. ទេវលោកឈ្មោះតាវតិង្ស
អាបាយិក គុ. អ្នកទទួលនូវទុក្ខក្នុងអបាយភូមិ
កាយិកមានសិក គុ. ប្រព្រឹត្តទៅក្នុងកាយនិងចិត្ត
មហាកច្ចាយនត្ថេរ បុំ. ព្រះមហាកច្ចាយនត្ថេរ
សុត្តន្តិក បុំ. អ្នកជំនាញខាងព្រះសូត្រ
វេនយិក បុំ. អ្នកជំនាញខាងវិន័យ
កោសិនារក បុំ. អ្នករស់នៅក្រុងកុសិនារា
មហាទុព្ភិក្ខភយ នបុំ. មហាទុរភិក្សភ័យ(អត់បាយ)
ទ្វាទសសហស្ស នបុំ. មានម៉ឺន ១២ ជាប្រមាណ
ព្រាហ្មណគហបតិក បុំ. ព្រាហ្មណ៍និងគហបតី
វេឡុវន នបុំ. ព្រៃឫស្សី, ឈ្មោះវត្តវេឡុវ័ន
គោតមី ឥ. ស្រីនៃពូជពង្សគោតម
កូដាគារ នបុំ. រោងប្រកបដោយកំពូល(មានដំបូល)
កូដាគារសាលា ឥ. សាលាជាផ្ទះមានកំពូល

# ធាតុស័ព្ទ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| កប្ប | សម្រេច,ចិញ្ចឹមជីវិត | ឧប + និ + សិ | ចូលទៅអាស្រ័យ |
| ប + សទ | ជ្រះថ្លា | បរិ + និ + វា | បរិនិព្វាន |
| វិ + ហរ | នៅ, អាស្រ័យនៅ | និ + បទ | កើត |
| ចជ | លះ | និ + វស | ស្លៀកពាក់ |
| អនុ+បទ | ដល់តាម, សម្រេច | អា + សិច | រោយ, ស្រោច(ទឹក) |

## លំហាត់នៃមេរៀនទី ៣៩

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើបច្ច័យមានប៉ុន្មានយ៉ាង គឺបច្ច័យអ្វីខ្លះ ?

២. តើតទ្ធិតដោយសង្ខេបមានប៉ុន្មានយ៉ាង ហៅដូចម្ដេចខ្លះ ?

៣. តើសាមញ្ញតទ្ធិតមានប៉ុន្មានយ៉ាង ? គឺតទ្ធិតអ្វីខ្លះ ?

៤. សាមញ្ញតទ្ធិតបើចែកជាពួក តើមានប៉ុន្មានពួក ?

៥. តើគោត្តតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

៦. តើបច្ច័យនោះ ៗ ចុះក្នុងអត្ថអ្វី ឬចុះជំនួសស័ព្ទអ្វី ?

៧. តើវិធីតាំងវិគ្គហៈរបស់គោត្តតទ្ធិតត្រូវប្រើស័ព្ទប្រភេទដូចម្ដេច ?

*៨. តើតវត្យាទិតទ្ធិតមានបច្ច័យប៉ុន្មានតួ ? គឺអ្វីខ្លះ ?*

*៩. តើតវត្យាទិតទ្ធិតមានរបៀបតាំងវិគ្គហៈប៉ុន្មានបែប ?*

*១០. បើចុះបច្ច័យជំនួសកិរិយាអាខ្យាតត្រូវតាំងវិគ្គហៈដូចម្ដេច ?*

*១១. បើចុះបច្ច័យជំនួសកិតកិរិយាត្រូវតាំងវិគ្គហៈដូចម្ដេច ?*

*១២. បើចុះបច្ច័យជំនួសនាមនាមត្រូវតាំងវិគ្គហៈដូចម្ដេច ?*

*១៣. បើចុះបច្ច័យជំនួសគុណនាមត្រូវតាំងវិគ្គហៈដូចម្ដេច ?*

### *ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. អយំ មាណវោ មយិ មនំ បសាទេត្វា កាលង្កត្វា តាវតឹសទេវលោកេ តឹសយោជនិកេ កនកវិមានេ និព្វត្តិស្សតិ ។

២. សូករិកា សាកុណិកា ជាលិកា ច សញ្ជិកំ ពលក្ការេន គហេត្វា ខាទន្តា ច ឥតោ ចវិត្វា អាបាយិកា ភវិស្សន្តិ ។

៣. ឯកូនតឹសវស្សោ ពោធិសត្តោ អត្តនោ ឯកមេវ បុត្តំ សព្វសម្បត្តិញ្ច បហាយ គន្ត្វា កាសាវ និវត្ថោ មត្តិកាបត្តំ អាទាយ អញ្ញេហិ ទិន្នាហារេន ជីវិតំ កប្បេសិ ។

៤. ភណ្ឌាគារិកោ រញ្ញោ ធនំ លភិត្វា មហន្តំ បាសាទំ ការេត្វា ទ្វារេ ទោវារិកំ ឋបេត្វា ឧបរិបាសាទគតោ កាយិកមានសិកំ សុខំ វិន្ទតិ ។

៥. មហាកច្ចាយនត្ថេរេ កុររឃរនគរំ ឧបនិស្សាយ វិហរន្តេ សោណោ នាម សេដ្ឋិបុត្តោ តស្ស សន្តិកេ បព្វជិត្វា

អបរភាគេ "សោណោ កុដិកណ្ណោ"តិ ចាកជោ អហោសិ ។

៦. អថ ខោ អាយស្មា អានន្ទោ កោសិនារកានំ មល្លានំ អារោចេសិ "អជ្ជ ខោ វាសិដ្ឋា រត្តិយា បច្ឆិមេ យាមេ តថាគតស្ស បរិនិព្វានំ ភវិស្សតី"តិ ។

៧. សុត្តន្តិកា វេនយិកា អារញ្ញិកា ច ពហវោ ភិក្ខវោ លង្កាយំ មហាទុព្ភិក្ខភយេ វត្តមានេ សមុទ្ទចារំ គន្ត្វា អត្តនោ ជីវិតំ រក្ខន្តា ធម្មវិនយំ ច រក្ខឹសុ ។

៨. ឥន្ទមន្តានំ អគ្គោ មហាមោគ្គល្លានត្ថេរោ ភគវតោ បរិនិព្វានតោ បុរេតរមេវ បរិនិព្វាយិ ។

៩. អថ ខោ តេសំ ទ្វាទសន្នហុតានំ មាគធិកានំ ព្រាហ្មណ-គហបតិកានំ ឯតទហោសិ "ឧរុវេលកស្សបោ មហាសមណេ ព្រហ្មចរិយំ ចរតី"តិ ។

១០. "អស្សោសិ ខោ រាជា មាគធោ សេណិយោ ពិម្ពិសារោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ រាជគហំ អនុប្បត្តោ"តិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ឥឡូវនេះ សាវ័ក.ទ. ក្នុងបាដលិគ្រាម បានឮហើយ នូវការមកដល់ក្នុងទីនោះ ពួកគេ.ទ. ទៅហើយ កាន់ទីនោះ អញ្ជើញហើយ នូវគាត់ទៅកាន់ រោងប្រជុំ ។*

២. កាលមកដល់ ក្នុងទីនោះ គេ.ទ. ចូលទៅហើយ ក្នុងរោងប្រជុំ មួយអន្លើ ដោយខ្សាច់ ថ្មី ក្រាលហើយ នូវកន្ទេល.ទ. ដាក់ហើយ នូវថូទឹក.ទ. ជិតទ្វារ ដុតហើយ នូវភ្លើង ។

៣. ព្រះតថាគត គ្រងហើយ នូវខ្លួន របស់ព្រះអង្គ កាន់យកហើយ នូវបាត្រ យាងទៅហើយ មួយអន្លើ ដោយភិក្ខុ.ទ. ទៅកាន់រោងប្រជុំ លាងហើយ នូវព្រះបាទ ទាំងពីរ ចូលទៅហើយ ក្នុងរោងប្រជុំ ប្រថាប់ហើយ ។

៤. ម្នាលអានន្ទ អ្នកចូរទៅ ក្នុងកាលឥឡូវនេះ អ្នក ចូរចូលទៅ ក្នុងក្រុង-កុសិនារា និង ចូរប្រាប់ ដល់ស្តេចមល្ល: នៃកុសិនារា ថា "ហៃវាសេដ្ឋ.ទ. ព្រះតថាគត នឹងបរិនិព្វាន ក្នុងថ្ងៃនេះ នាយាម ចុងក្រោយ នៃយប់" ។

៥. កាលគ្រានោះ លោកដ៏មានអាយុ មហាកស្សប: ធ្វើដំណើរ ផ្លូវឆ្ងាយ ពីស្រុកបាវា ទៅកាន់កុសិនារា មួយអន្លើ ដោយភិក្ខុសង្ឃ.ទ. ច្រើនរូប ។ លោកដ៏មានអាយុ មហាកស្សប: លះហើយ ពីផ្លូវ នោះ និង អង្គុយហើយ ជិតគល់ឈើ មួយដើម ។

៦. នាងមហាបជាបតី គោតមី កាត់ហើយ នូវសក់ ស្លៀកពាក់ហើយ នូវសំពត់ជ្រលក់ទឹកអំចត់ ពណ៌លឿង ចេញទៅហើយ មួយអន្លើ ដោយស្ត្រី នៃពួកសក្យ: ទៅហើយ កាន់កូដាគារសាលា នាព្រៃ មហាវ័ន ក្នុងក្រុងវេសាលី បានមកដល់ហើយ ។

៧. ម្នាលអានន្ទ ដូចជាផ្ទះ មាន ស្រី ច្រើន មាន ប្រុស តិច គឺចោរ ប្លន់ យ៉ាងងាយ ។ ម្នាលអានន្ទ ក្នុងសាសនា ណា កាលស្ត្រី ចេញ ចាកផ្ទះ ជាអ្នកគ្មានផ្ទះ និងរស់ ក្នុងធម៌ ក្តី ក្នុងវិន័យ ក្តី សាសនា នោះ នឹងមិនតាំងនៅ យូរឡើយ ។

៨. ពិម្ពិសារ ជាស្តេច នៃដែនមគធៈ កាន់យកហើយ នូវថូទឹក ធ្វើដោយ មាស មានទឹកពេញ ប្រូចហើយ នូវទឹក លើព្រះហស្ត ទាំងគូ របស់ព្រះពុទ្ធ បង្ហាញហើយ នូវសួន ជាទីរីករាយ ឈ្មោះវេឡុវ័ន ដល់ភិក្ខុ.ទ. មានព្រះពុទ្ធជាប្រធាន ។

(ចប់មេរៀនទី ៣៩)

## កំណាព្យដាស់តឿនស្មារតី

### តូចចង់ធ្វើធំ

អជងស្ស រសំ ខាធា អពលស្ស ហាតា ឯភា
អប្បញ្ញស្ស វាក្យា កាថា ឧម្មត្តកសមា ឥមេ ។

(ដកស្រង់ពីសៀវភៅ **គតិលោកា** ភាគ ៦ ទំព័រ ៣)

# មេរៀនទី ៤០

# អធិប្បាយអំពីតទ្ធិត (ត)

## ១.៣ រាគាទិតទ្ធិត

*ឈ្មោះថារាគាទិតទ្ធិតនេះមានន័យក្នុងដំណើរដូចគ្នានឹងតរត្យាទិ-តទ្ធិតដែរ ពីព្រោះមានពាក្យថា* **អាទិ** *សព្ទជាប់ជាមួយ ប្រាប់ឱ្យដឹងថាមាន* **រាគ** *(គ្រឿងជ្រលក់) សព្ទជាបទដើម ។ តទ្ធិតនេះមានបច្ច័យមួយតួគឺ* **ណ** *ជាគ្រឿងសម្គាល់ ប្រើជំនួសសព្ទទូទៅមិនកំណត់ ។ ការប្រកបរូបសព្ទជាមួយបច្ច័យមានតួ* **ណ** *មានអំណាចទីឃៈឬវិការៈយ៉ាងណានោះមិនពោលទៀតទេ ។ បច្ច័យនេះបើចុះចុងនាមសព្ទណាធ្វើឱ្យនាម-សព្ទនោះ ៗ ក្លាយជាគុណនាមជានិច្ច ។*

## វិធីតាំងវិគ្គហៈនៃរាគាទិតទ្ធិត

*គោលការណ៍តាំងវិគ្គហៈមានគតិដូចតរត្យាទិតទ្ធិតគឺមានរូបវិគ្គហៈ ៤ បែប (សូមមើលវិធីរៀងវិគ្គហៈក្នុងមេរៀនទី ៣៩ ខាងដើម) ដែរដែលនឹងអធិប្បាយដូចតទៅនេះ*

## ក. ប្រើជំនួសកិតកិរិយា

១. (កសាវ + ណ) > កាសាវ

វិ. កសាវេន រត្តំ កាសាវំ (វត្ថំ) =(សំពត់) ដែលជ្រលក់ហើយដោយទឹកអម្ចត់ (សំពត់កាសាវៈ) ។ ពាក្យថា ហាលិទ្ទ =ជ្រលក់ល្មាត, ជីល = ជ្រលក់ពណ៌ខៀវ ក៏មានរបៀបតាំងវិគ្គហៈដូចគ្នាដែរ ។

២. (មគធ + ណ) > មាគធ

វិ. មគធេ ជាតោ មាគធោ (ជនោ)=(ជន) អ្នកដែលកើតហើយក្នុងដែនមគធៈ (អ្នកមគធៈ) ។

៣. (កត្តិកា + ណ) > កត្តិក

វិ. កត្តិកាយ និយុត្តោ កត្តិកោ (មាសោ) =(ខែ) ដែលប្រកបហើយដោយផ្កាយកត្តិកា (ខែកត្តិក) ។

## ខ. ប្រើជំនួសអាខ្យាតកិរិយា

១. (វ្យាករណ + ណ) > វ្យាករណ

វិ. វេយ្យាករណំ អធិតេតិ វេយ្យាករណោ (ជនោ) =(ជន) អ្នកដែលរៀនវេយ្យាករណ៍ ។

**បញ្ជាក់.** វេយ្យាករណ សម្រេចមកពីនាមកិតកគឺ (វិ + ករ + យុ), ព្រឹទ្ធិ ឥ នៃ វិ ជា ឯ, ផ្លាស់ ឯ ជា អយ, ទីឃៈ អ នៃ យ ជា អា > អយា, ទៅជា វ្យា + ករណ សម្រេចជា វ្យាករណ ។ ពេលចុះ ណ បច្ច័យ

*ក្នុងតទ្ធិតមកទៀត ត្រូវផ្លាស់ អ នៃ វ ជា ឯ ហើយតម្រួត យ ជា យ្យ សម្រេចបានជា វេយ្យាករណោ ។*

២. ( ឧទុម្ពរ + ណ ) > ឱទុម្ពរ

*វិ.* ឧទុម្ពរា អស្មឹ សន្តីតិ ឱទុម្ពរោ (បទេសោ) =*(ប្រទេស) ដែលមានដើមល្វា ។*

៣. ( សំវច្ឆរ + ណ ) > សំវច្ឆរ

*វិ.* សំវច្ឆរំ អវេច្ច អធិតេតិ សំវច្ឆរោ (ជនោ) =*(ជន) អ្នកដែលរៀននូវឆ្នាំ ។*

**បញ្ជាក់** អវេច្ច *ជាកិតកិរិយាពួក* ត្វា *បច្ច័យសម្រេចមកពី* (អវ + ឥ + ត្យ > ច្ច ), *ព្រឹទ្ធិ* ឥ > ឯ, *ប្រែថា ដឹងហើយ ។*

*សូមមើលក្នុងមេរៀនទី ២០ នៅខាងដើមត្រង់ចំណុច ២.៩ ។*

## គ. ប្រើជំនួសនាមនាម

១. ( មហិស + ណ ) > មាហិស

*វិ.* មហិសស្ស ឥទំ មំសំ មាហិសំ =*សាច់នេះរបស់ក្របី (សាច់ក្របី) ។*

*ពាក្យថា* សោករ *=សាច់ជ្រូក,* សាកុណ *=សាច់បក្សី ក៏មានរបៀបតាំងវិគ្គហៈដូចគ្នាដែរ ។*

២. (មគធ + ណ) > មាគធ

វិ. មគធោ អស្ស និវាសោ មាគធោ =អ្នកដែលមានដែនមគធៈជាទីអាស្រ័យនៅ (អ្នកនគរមគធៈ) ។

៤. (ពុទ្ធ + ណ) > ពុទ្ធ

វិ. ពុទ្ធោ អស្ស ទេវតាតិ ពុទ្ធោ (ជនោ) =(ជន) ដែលមានព្រះពុទ្ធជាទេវតា ។

## ឃ. ប្រើជំនួសគុណនាម

១. (មគធ + ណ) > មាគធ

វិ. មគធេ ឥស្សរោ មាគធោ (ជនោ) =(ជន) អ្នកដែលជាធំក្នុងដែនមគធៈ ។

២. (មថុរ + ណ) > មាថុរ

វិ. មថុរាយំ ឥស្សរោ មាថុរោ (ជនោ) =(ជន) អ្នកដែលជាធំក្នុងដែនមថុរា ។

៣. (កុន្ត + ណ) > កុន្ត

វិ. កុន្តានំ វិសយោ កុន្តោ (ទេសោ) =(ប្រទេស) ដែលជាទីនៃសត្វក្រៀល ។

ស័ព្ទដែលសម្រេចពីតទ្ធិតនេះជាគុណនាម បំបែកតាមវិភត្តិនានា

*បានទាំងបីលិង្គ ។*

(*ភគាទិតទ្ធិតចប់*)

## ១.៤ ជាតាទិតទ្ធិត

*ឈ្មោះថាជាតាទិតទ្ធិតនេះមានន័យដូចតរត្យាទិតទ្ធិតដែរ ព្រោះមានពាក្យថា* **អាទិ** *ស័ព្ទជាប់ជាមួយដែរ ប្រាប់ឱ្យដឹងថាជាតទ្ធិតមាន* **ជាត** *ជាបទខាងដើម ។ តទ្ធិតនេះមានបច្ច័យ ៤ តួគឺ* **ឥម**, **ឥយ**, **ឥក**, **កិយ** *ជាគ្រឿងសម្គាល់ ។ បច្ច័យទាំង ៤ នេះប្រើជំនួសតែកិតកិរិយានិងអាខ្យាតកិរិយាប៉ុណ្ណោះ មិនប្រើជំនួសនាមឬគុណនាមទេ ។ រីឯវិធីតាំងវិគ្គហៈមានដំណើរដូចភគាទិតទ្ធិតដែរ ។ ចំពោះបទដើមអាចជាសាធារណនាមឬនិបាតក៏បាន ដូចឧទាហរណ៍តទៅនេះ*

### ក. ប្រើជំនួសកិតកិរិយា

១. ( **បុរ** + **ឥម** ) > **បុរិម**

*វិ.* **បុរេ ជាតោ បុរិមោ** ( **ជនោ** ) =(*ជន*) *អ្នកដែលកើតហើយ ក្នុងកាលមុន* (*អ្នកដែលកើតមុន*) *។*

២. ( **មជ្ឈ** + **ឥម** ) > **មជ្ឈិម**

វិ. មជ្ឈេ ជាតោ  មជ្ឈិមោ (ជនោ) =(ជន) អ្នកដែលកើតហើយក្នុងកាលកណ្ដាល (អ្នកដែលកើតកណ្ដាល) ។

៣. (បច្ឆា + ឥម) > បច្ឆិម

វិ. បច្ឆា ជាតោ បច្ឆិមោ (ជនោ) =(ជន) អ្នកដែលកើតហើយក្នុងកាលខាងក្រោយ (អ្នកដែលកើតក្រោយ) ។

៤. (អគ្គ + ឥម) > អគ្គិម

វិ. អគ្គេ និយុត្តោ អគ្គិមោ (ជនោ) =(ជន) អ្នកដែលប្រកបហើយក្នុងទីបំផុត (អ្នកដែលចុងគេ) ។

៥. (អគ្គ + ឥយ) > អគ្គិយ

វិ. អគ្គេ និយុត្តោ អគ្គិយោ (ជនោ) =(ជន) អ្នកដែលប្រកបហើយក្នុងទីបំផុត (អ្នកដែលចុងគេ) ។

៦. (មនុស្សជាតិ + ឥយ) > មនុស្សជាតិយ

វិ. មនុស្សជាតិយា ជាតោ មនុស្សជាតិយោ (ជនោ) =(ជន) អ្នកដែលកើតហើយ ដោយជាតិនៃមនុស្ស (មនុស្សជាតិ) ។

៧. (អស្សជាតិ + ឥយ) > អស្សជាតិយ

វិ. អស្សជាតិយា ជាតោ អស្សជាតិយោ (សត្តោ) =(សត្វ) ដែលកើតហើយ ដោយជាតិនៃសេះ (សត្វសេះ)។

៨. (បណ្ឌិតជាតិ + ឥយ) > បណ្ឌិតជាតិយ

វិ. បណ្ឌិតជាតិយា ជាតោ បណ្ឌិតជាតិយោ (ជនោ) =(ជន)

អ្នកដែលកើតហើយ ដោយជាតិនៃបណ្ឌិត ។

៩. ( អន្ត + ឥក ) > អន្តិក

វិ. អន្តេ និយុត្តោ អន្តិកោ (ជនោ) =(ជន) អ្នកដែលប្រកប ហើយក្នុងទីបំផុត (អ្នកដែលចុងគេ) ។

១០. ( អន្ធ + កិយ ) > អន្ធកិយ

វិ. អន្ធេ និយុត្តោ អន្ធកិយោ (ជនោ) =(ជន) អ្នកដែលប្រកប ហើយក្នុងទីងងឹត ។

១១. ( ជច្ចន្ធ + កិយ ) > ជច្ចន្ធកិយ

វិ. ជច្ចន្ធេ និយុត្តោ ជច្ចន្ធកិយោ (ជនោ) =(ជន) អ្នកដែល ប្រកបហើយក្នុងភាពងងឹតពីកំណើត (ដែលខ្វាក់ពីកំណើត) ។

ជច្ចន្ធ ជាបទសមាស មកពី ជាតិ + អន្ធ, ផ្លាស់ ស្រៈ ឥ នៃ តិ ជា យ > ត្យ > ច្ច និងរស្សៈស្រៈ អា នៃ ជា ទៅជា អ សម្រេចបាន ជច្ចន្ធ ។

## ខ. ប្រើជំនួសអាខ្យាតកិរិយា

ប្រសិនបើប្រើជំនួសអាខ្យាតកិរិយាត្រូវតាំងវិគ្គហៈដូចខាងក្រោម នេះ៖

១. ( អន្ធ + កិយ ) > អន្ធកិយ

*វិ.* **អគ្ឃោ អស្ស អត្ថីតិ អគ្ឃកិយោ** ( **ជនោ** ) =*(ជន) ដែលមានភាពថ្លៃ (ខ្ពង់) ។*

*ប្រែថា* **អគ្ឃោ** *វីភាពថ្លៃ* **អស្ស** *របស់ជននោះ* **អត្ថិ** *រមែងមាន* **ឥតិ** *ព្រោះហេតុនោះ (***សោ ជនោ** *វីជន នោះ)* **អគ្ឃកិយោ** *ឈ្មោះថា* **អគ្ឃកិយោ, អគ្ឃកិយោ** *(***ជនោ** *វីជន) មានភាពថ្លៃ ។*

**២. ( បុត្ត + ឥម ) > បុត្តិម**

*វិ.* **បុត្តោ អស្ស អត្ថីតិ បុត្តិមោ (ជនោ)** = *(ជន) ដែលមានបុត្រ ។*

**៣. ( អស្សជាតិ + ឥយ ) > អស្សជាតិយ**

*វិ.* **អស្សជាតិ អស្ស អត្ថីតិ អស្សជាតិយោ** ( **សត្តោ** ) =*(សត្វ) ដែលមានជាតិជាសេះ ។*

☸ *នៅក្នុងកច្ចាយនទូបត្ថម្ភកភាគ ២ មិនប្រើ* **អស្ស** *ទេ លោកប្រើ* **យស្ស** *វិញ ។*

## កំណាត់សម្គាល់

*១. បច្ច័យណាដែលផ្ដើមដោយស្រៈគឺ* **ឥម, ឥយ, ឥក** *កាលបើចុះជាមួយស័ព្ទណា ត្រូវផ្លាស់ជាស្រៈនិស្ស័យវិញ ដោយអំណាចនៃសន្ធិ ឧ.*( **មជ្ឈ + ឥម** ) > **មជ្ឈិម,** ( **មនុស្សជាតិ + ឥយ** ) > **មនុស្សជាតិយ** *(ចូរមើលត្រង់សរសន្ធិនៅខាងមុខ) ។*

២. ចំពោះ **កិយ** បច្ច័យត្រូវទុកឱ្យគង់រូបដើម (**អង្គ** + **កិយ**) > **អង្គកិយ** (ចូរមើលត្រង់ព្យញ្ជនសន្ធិ) ។

៣. ស័ព្ទតទ្ធិតដែលចុះបច្ច័យ ៤ តួនេះ ជាគុណនាមបំបែកតាមវិភត្តិផ្សេង ៗ បានទាំងបីលិង្គ ។

**(ជាតាទិតទ្ធិតចប់)**

## ១.៥ សមូហតទ្ធិត

សមូហតទ្ធិតនេះមានបច្ច័យ ៣ តួគឺ **កណ**, **ណ**, **តា** ជាគ្រឿងសម្គាល់ ប្រើជំនួសនាមស័ព្ទមួយម៉ាត់គឺ **សមូហ** ប្រែថា "ប្រជុំ, ក្រុម, ពួក, ហ្វូង" ។ វិធីប្រកបរូបស័ព្ទជាមួយណានុព័ន្ធបច្ច័យមានអំណាចឱ្យទីឃៈឬព្រឹទ្ធិបានដូច **ណ** បច្ច័យក្នុងគោត្តតទ្ធិតដែរ ។ វិធីរៀងវិគ្គហៈគឺដូចគ្នាទាំងអស់ដោយមានគោលការណ៍ដូចខាងក្រោមនេះ

## វិធីតាំងវិគ្គហៈនៃសមូហតទ្ធិត

១. បទដើមជានាមនាមបំបែកជាឆដ្ឋីវិភត្តិពហុវចនៈប្រែថា "របស់, នៃ" ជានិច្ច ។

២. បទចុងប្រើ **សមូហ** ស័ព្ទ ត្រូវបំបែកជាបឋមាវិភត្តិឯកវចនៈជា

**សមូហោ** ប្រែថា "ប្រជុំ, ក្រុម, ពួក, ហ្វូង" ប្រែណាមួយឱ្យសមតាមសេចក្ដី ។

៣. បទតទ្ធិតត្រូវលុប **សមូហ** ចោលហើយចុះបច្ច័យតួណាមួយជំនួសវិញនិងត្រូវបំបែកជាបឋមាវិភត្តិឯកវចនៈជានិច្ច ។

| ១ | ២ | ៣ |
|---|---|---|
| វិ. មនុស្សានំ | សមូហោ | មានុស្សកោ ។ |
| បទដើម | បទចុង | បទតទ្ធិត |

## ១. កណ បច្ច័យ

១. (មនុស្ស + កណ) > មានុស្សក

វិ. មនុស្សានំ សមូហោ មានុស្សកោ =ប្រជុំនៃមនុស្ស.ទ. ។

២. (មយូរ + កណ) > មាយូរក

វិ. មយូរានំ សមូហោ មាយូរកោ =ហ្វូងនៃក្ងោក.ទ. ។

៣. (កបោត + កណ) > កាបោតក

វិ. កបោតានំ សមូហោ កាបោតកោ =ហ្វូងនៃព្រាប.ទ. ។

## ២. ណ បច្ច័យ

១. (មនុស្ស + ណ) > មានុស្ស

២. ( មយូរ + ណ ) > មាយូរ

៣. ( កាចោត + ណ ) > កាចោត

*មានវិធីតាំងវិគ្គហៈនិងប្រែដូច* **កណ** *បច្ច័យដែរ ។ បទតទ្ធិតបំបែកជា* **មានុស្សោ, មាយូរោ, កាចោតោ** ។

## ៣. តា បច្ច័យ

១. ( គាម + តា ) > គាមតា

*វិ.* **គាមានំ សមូហោ គាមតា** *=ប្រជុំនៃស្រុក.ទ. ។*

២. ( ជន + តា ) > ជនតា

*វិ.* **ជនានំ សមូហោ ជនតា** *=ប្រជុំនៃជន.ទ. ។*

៣. ( សហាយ + តា ) > សហាយតា

*វិ.* **សហាយានំ សមូហោ សហាយតា** *=ពួកនៃសំឡាញ់.ទ. ។*

## កំណត់សម្គាល់

*សព្ទដែលចុះ* **ណ, កណ** *បច្ច័យនៃតទ្ធិតនេះជានាមនាមនិងជាសព្ទ* **អ** *ការន្តបុំលិង្គ អាចបំបែកក្នុងរូបវិភត្តិផ្សេង ៗ តាមបែប* **បុរិស** ។ *រីឯ* **តា** *បច្ច័យវិញជាសព្ទ* **អា** *ការន្តឥត្ថីលិង្គតែម្យ៉ាង ត្រូវបំបែកតាមបែប* **កញ្ញា** *គ្រប់វិភត្តិទាំងអស់ ។*

**(*សមូហតទ្ធិតចប់*)**

## ១.៦ ឋានតទ្ធិត

ឋានតទ្ធិត ប្រើបច្ច័យជំនួសស័ព្ទនោះ ៗ ប្រាប់ឱ្យដឹងនូវទីឋាន ។ **ឋាន** ប្រែថា "ទីតាំង" ។ តទ្ធិតនេះមានបច្ច័យ ២ តួគឺ **ឡិយ**, **ឌយ្យ** ។ ប្រើជំនួសស័ព្ទ ៤ ម៉ាត់គឺ **ឋាន** =ហេតុជាទីតាំង, **អរហតិ** =គួរ, **ហិត** = ប្រយោជន៍, **ករ** =មាន ។ **ហិត** និង **ករ** ពីរស័ព្ទនេះមានសំដែងក្នុងសទ្ទ-នីតិ ។ វិធីប្រកបរូបស័ព្ទជាមួយបច្ច័យពីរតួនេះ និយមចុះជាមួយស័ព្ទនាមកិតក:តែម៉្យាងគត់ ។

## វិធីតាំងវិគ្គហ:នៃឋានតទ្ធិត

១. បទដើមជានាមកិតក:ជានិច្ច បំបែកក្នុងរូបវិភត្តិនានាតាមដល់ការគួរ ។

២. បទចុងប្រើ **ឋាន** ស័ព្ទបំបែកជាបឋមាវិភត្តិឯកវចនៈនបុំសក-លិង្គមានរូបជា **ឋានំ** ប្រែថា "ទីតាំង" ។ បើប្រើ **អរហតិ** ជាអាខ្យាត-កិរិយា ត្រូវចុះ **ឥតិ** ស័ព្ទចូលមកទៅជា **អរហតីតិ** និងបើប្រើ **ករ** ត្រូវបំបែកជា **ករំ** ហើយលុបចេញ ។

៣. បទតទ្ធិតបំបែកជាបឋមាវិភត្តិឯកវចនៈជានិច្ច ។

## ១. ឡិយ ប្រើជំនួស ឋាន

១. (មទន + ឦយ) > មទនីយ

*វិ.* មទនស្ស ឋានំ មទនីយំ =*ជាទីតាំងនៃការស្រវឹង ។*

២. (ពន្ធន + ឦយ) > ពន្ធនីយ

*វិ.* ពន្ធនស្ស ឋានំ ពន្ធនីយំ =*ជាទីតាំងនៃការចង ។*

៣. (មោចន + ឦយ) > មោចនីយំ

*វិ.* មោចនស្ស ឋានំ មោចនីយំ =*ជាទីតាំងនៃការរួចចាក ។*

## ២. ឦយ, ឯយ្យ ប្រើជំនួស អរហតិ

១. (ទស្សន + ឦយ) > ទស្សនីយ

*វិ.* ទស្សនំ អរហតីតិ ទស្សនីយោ (ជនោ) =*(ជន) ដែលគួរនូវការឃើញឬការមើល ។*

២. (ទស្សន + ឯយ្យ) > ទស្សនេយ្យ

*វិ.* ទស្សនំ អរហតីតិ ទស្សនេយ្យោ (ជនោ) =*(ជន) ដែលគួរនូវការឃើញឬការមើល ។*

៣. (បូជន + ឦយ) > បូជនីយ

*វិ.* បូជនំ អរហតីតិ បូជនីយោ (ជនោ) =*(ជន) អ្នកដែលគួរនូវការបូជា ។*

៤. (បូជន + ឯយ្យ) > បូជនេយ្យ

វិ. បូជនំ អរហាតីតិ បូជនេយ្យោ (ជនោ) =(ជន) អ្នកដែលគួរនូវការបូជា ។

៨. (ទក្ខិណា + ឯយ្យ) > ទក្ខិណេយ្យ

វិ. ទក្ខិណំ អរហាតីតិ ទក្ខិណេយ្យោ (ជនោ) =(ជន) អ្នកដែលគួរនូវទក្ខិណា (ការឱ្យ) ។

## ៣. ឦយ ប្រើជំនួស ហិត និង ករ

១. (ឧបាទាន + ឦយ) > ឧបាទានីយ

វិ. ឧបាទានំ ហិតំ ឧបាទានីយំ =សេចក្តីទំនុកបម្រុងដល់ឧបាទាន ។

២. (ឧទរ + ឦយ) > ឧទរីយ

វិ. ឧទរេ ករំ ឧទរីយំ (ភោជនំ) =(ភាជន) ដែលមានក្នុងពោះ ។

បើប្រាថ្នាប្រែលោតប្រយោគ ខាងក្នុងរូបវិគ្គហៈត្រូវថែមអញ្ញបទគឺ យោ - សោ - ជនោ ចូលមកដែលប្រែដូច្នេះ

(យោ ជនោ វីជន ឯណា) អរហាតិ រមែងគួរ ទស្សនំ នូវកិរិយាឃើញ ឥតិ ព្រោះហេតុនោះ (សោ ជនោ វីជន នោះ) ទស្សនីយោ, ទស្សនេយ្យោ ឈ្មោះថា ទស្សនីយោ ឬ ទស្សនេយ្យោ, ទស្សនីយោ, ទស្សនេយ្យោ (ជនោ វីជន) គួរនូវការឃើញឬគួរនូវការមើល។

## កំណាត់សម្គាល់

*បទតទ្ធិតដែលសម្រេចពី* **ឡៀយ, ឯយ្យ** *បច្ច័យជាគុណនាមអាចបំបែកក្នុងរូបវិភត្តិផ្សេង ៗ បានទាំងបីលិង្គ ។ ការប្រើក្នុងប្រយោគនឹងមាននៅខាងមុខ ។*

*(ឋានតទ្ធិតចប់)*

## ១.៧ ពហុលតទ្ធិត

*ពហុលតទ្ធិតមានបច្ច័យ ១ តួគឺ* **អាលុ** *ប្រើជំនួសស័ព្ទគុណនាមពីរម៉ាត់គឺ* **ពហុល** *និង* **បកតិ** *។ បើប្រើជំនួស* **ពហុល** *ត្រូវប្រែថា "មាន ... ច្រើន" ។ បើប្រើជំនួស* **បកតិ** *ប្រែថា "មាន ... ជាប្រក្រតី" ។ ប្រែស្រដៀងនឹងតស្សីលសាធនៈក្នុងនាមកិតកៈដែរ ។*

## វិធីតាំងវិគ្គហៈនៃពហុលតទ្ធិត

*១. បទដើមជានាមនាមបំបែកជាបឋមាវិភត្តិតាមការន្តនិងលិង្គនៃនាមនោះ ៗ ។*

*២. បទកណ្តាលប្រើ* **ត** *ឬ* **ឯត** *សព្វនាមបំបែកជា* **អស្ស** *ឬ* **ឯតស្ស** *។*

៣. បទចុងប្រើ **ពហុល** (បំបែកឱ្យស្មើគ្នានឹងនៅខាងដើម) ឬប្រើ **បកតិ** ហើយលុបចោល ។

៤. បទតទ្ធិតចុះ **អាលុ** បច្ច័យជំនួស **ពហុល** ឬ **បកតិ** និង បំបែកជាបឋមាវិភត្តិឯកវចនៈតាម **ឱ** ការន្តនៃលិង្គនោះ ៗ ។

| ១ | ២ | ៣ | ៤ |
|---|---|---|---|
| (អភិជ្ឈា + | អស្ស/ឯត្ត + | ពហុលា/បកតិ) > | អភិជ្ឈាលុ |
| បទដើម | បទកណ្ដាល | បទចុង | បទតទ្ធិត |

## ១. អាលុ បច្ច័យប្រើជំនួស ពហុល

### ១. (អភិជ្ឈា + អាលុ) > អភិជ្ឈាលុ

វិ. **អភិជ្ឈា អស្ស ពហុលា អភិជ្ឈាលុ (ជនោ)** =(ជន) ដែលមានអភិជ្ឈាច្រើន ។

ប្រែថា **អភិជ្ឈា** រីអភិជ្ឈា **អស្ស** របស់ជននោះ **ពហុលា** ច្រើន (**សោ ជនោ** រីជន នោះ) **អភិជ្ឈាលុ** ឈ្មោះថា **អភិជ្ឈាលុ**, **អភិជ្ឈាលុ** (**ជនោ** រីជន) ដែលមានអភិជ្ឈាច្រើន ។

### ២. (ទយា + អាលុ) > ទយាលុ

វិ. **ទយា អស្ស ពហុលា ទយាលុ (ជនោ)** =(ជន) ដែលមានសេចក្ដីអាណិតច្រើន ។

៣. (សីត + អាលុ) > សីតាលុ

វិ. សីតំ ឯត្ថ ពហុលំ សីតាលុ (បទេសោ) =(*ប្រទេស*) *ដែលមានធាតុត្រជាក់ច្រើន ។*

## ២. អាលុ បច្ច័យប្រើជំនួស បកតិ

១. (អភិជ្ឈា + អាលុ) > អភិជ្ឈាលុ

វិ. អភិជ្ឈា អស្ស បកតិ អភិជ្ឈាលុ (ជនោ) =(*ជន*) *ដែលមានអភិជ្ឈាជាប្រក្រតី ។*

២. (សីត + អាលុ) > សីតាលុ

វិ. សីតំ ឯត្ថ បកតិ សីតាលុ (បទេសោ) =(*ប្រទេស*) *ដែលមានធាតុត្រជាក់ជាប្រក្រតី ។*

៣. (ធជ + អាលុ) > ធជាលុ

វិ. ធជោ ឯត្ថ បកតិ ធជាលុ (ចាសាទោ) =(*ប្រាសាទ*) *ដែលមានទង់ជាប្រក្រតី ។*

## កំណត់សម្គាល់

*សព្វតទ្ធិតនេះជាគុណនាមនិងជា ឧ ការន្តដែលត្រូវបំបែកក្នុងរូបវិភត្តិផ្សេង ៗ តាមបែប ឧ ការន្តទាំងបីលិង្គ ។*

*(ពហុលតទ្ធិតចប់)*

## ១.៨ សេដ្ឋតទ្ធិត

សេដ្ឋតទ្ធិតនេះមានបច្ច័យ ៥ តួគឺ **តរ**, **ឥយ**, **ឥយិស្សក**, **តម**, **ឥដ្ឋ** ។ បច្ច័យទាំង ៥ តួនេះសម្រាប់ចុះចុងគុណនាមម្យ៉ាងប៉ុណ្ណោះ គឺមិនមែនប្រើជំនួសស័ព្ទដូចតទ្ធិតឯទៀត ៗ ទេ ជាបច្ច័យសម្រាប់ប្រើប្រៀបធៀបគុណនាមឱ្យដឹងថាដូចជា ល្អ-អាក្រក់ យ៉ាងណា (ចូរមើលបទអធិប្បាយពីគុណនាមក្នុងមេរៀនទី ១០ ប្រកបផង) ។ បច្ច័យមួយតួ ៗ មានពាក្យប្រែដូចតទៅនេះ

### ១. តរ, ឥយ, ឥយិស្សក ប្រែថា "ជាង"

(**ចាប** + **តរ**) > **ចាបតរ**

(**ចាប** + **ឥយ**) > **ចាបិយ**

(**ចាប** + **ឥយិស្សក**) > **ចាបិយិស្សក**

ប្រែថា បាបជាង ឬ អាក្រក់ជាង ។

### ២. តម, ឥដ្ឋ ប្រែថា "បំផុត"

(**ចាប** + **តម**) > **ចាបតម**

(**ចាប** + **ឥដ្ឋ**) > **ចាបិដ្ឋ**

ប្រែថា បាបបំផុត, អាក្រក់បំផុត ។

# វិធីតាំងវិគ្គហៈនៃសេដ្ឋតទ្ធិត

*វិធីតាំងវិគ្គហៈរបស់បច្ច័យទាំងប្រាំតួនេះ មានពីរបែបស្រដៀងគ្នាដូចខាងក្រោមនេះ*

## បែបទី ១ ចុះ តរ, តយ, តយិស្សក

១. សព្វេ ឥមេ ចាចា អយមិមេសំ វិសេសេន ចាចោតិ ចាបតរោ (ជនោ) ។

២. សព្វេ ឥមេ ចាចា អយមិមេសំ វិសេសេន ចាចោតិ ចាបិយោ (ជនោ) ។

៣. សព្វេ ឥមេ ចាចា អយមិមេសំ វិសេសេន ចាចោតិ ចាបិយិស្សកោ (ជនោ) ។

*ប្រែដូច្នេះ* (យេ ជនា *វីជន.ទ. ឯណា*) សព្វេ *ទាំងអស់* ឥមេ *នេះ* ចាចា (*ជាមនុស្ស*)*អាក្រក់* អយំ *វីជននេះ* ចាចោ (*ជាមនុស្ស*)*អាក្រក់* វិសេសេន *ដោយវិសេស* ឥមេសំ *ជាងជន.ទ.នេះ* ឥតិ *ព្រោះហេតុនោះ* (សោ ជនោ *វីជន នោះ*) ចាបតរោ, ចាបិយោ, ចាបិយិស្សកោ *ឈ្មោះថា* ចាបតរោ, ចាបិយោ, ចាបិយិស្សកោ; ចាបតរោ, ចាបិយោ, ចាបិយិស្សកោ (ជនោ *វីជន*) *អាក្រក់ជាង* ។

# បែបទី ២ ចុះ តម, ឥដ្ឋ

**អយញ្ច ចាចោ អយញ្ច ចាចោ សព្វេ ឥមេ ចាចា អយមិមេសំ វិសេសេន ចាចោតិ ចាបតមោ, ចាបិដ្ឋោ (ជនោ) ។**

*ប្រែដូច្នេះ* **អយំ** (**ជនោ**) **ច** (*វីជន*) *នេះ ផង* **ចាចោ** (*ជាមនុស្ស*) *អាក្រក់* **អយំ** (**ជនោ**) **ច** (*វីជន*) *នេះ ផង* **ចាចោ** (*ជាមនុស្ស*)*អាក្រក់* **សព្វេ** *ទាំងអស់* **ឥមេ** *នេះ* **ចាចា** (*ជាមនុស្ស*) *អាក្រក់*, **អយំ** *វីជននេះ* **ចាចោ** (*ជាមនុស្ស*)*អាក្រក់* **វិសេសេន** *ដោយវិសេស* **ឥមេសំ** *ជាងជន .ទ. នេះ* **ឥតិ** *ព្រោះហេតុនោះ* (**សោ ជនោ** *វីជន នោះ*) **ចាបតមោ, ចាបិដ្ឋោ** =*ឈ្មោះថា* **ចាបតមោ, ចាបិដ្ឋោ, ចាបតមោ, ចាបិដ្ឋោ** (**ជនោ** *វីជន*) *អាក្រក់បំផុត ។*

*ខាងក្រោមនេះជាស័ព្ទខ្លះ ៗ ដែលប្រកបជាមួយនឹង* **តរ, ឥយ, ឥយិស្សក, តម, ឥដ្ឋ** *។ ខ្លះមានរូបប្រែប្រួលមិនប្រក្រតី ។*

| | | |
|---|---|---|
| (**បណ្ឌិត + តរ**) | > **បណ្ឌិតតរ** | *ឆ្លាតជាង* |
| (**បណ្ឌិត + តម**) | > **បណ្ឌិតតម** | *ឆ្លាតបំផុត* |
| (**ហីន + តរ**) | > **ហីនតរ** | *តូចឬថោកទាបជាង* |
| (**ហីន + តម**) | > **ហីនតម** | *តូចឬថោកទាបបំផុត* |
| (**បណីត + តរ**) | > **បណីតតរ** | *ថ្លៃថ្លាឬប្រណីតជាង* |
| (**អប្ប + ឥយ**) | > **កណិយ** | *តូចជាង* |

| | | |
|---|---|---|
| (អប្ប + ឥដ្ឋ) | > កណិដ្ឋ | ក្មេងជាង |
| (យុវ + ឥយ) | > កនិយ | តូចបំផុត |
| (យុវ + ឥដ្ឋ) | > កនិដ្ឋ | ក្មេងបំផុត |
| (បសដ្ឋ + ឥយ) | > សេយ្យ, ជេយ្យ | ប្រសើរជាង |
| (បសដ្ឋ + ឥដ្ឋ) | > សេដ្ឋ, ជេដ្ឋ | ប្រសើរបំផុត |
| (វុឌ្ឍ + ឥយ) | > ជេយ្យ | ចាស់ជាង |
| (វុឌ្ឍ + ឥដ្ឋ) | > ជេដ្ឋ | ចាស់បំផុត |
| (ពាឡ្ហ + ឥយ) | > សាធិយ | មាំមួនជាង |
| (ពាឡ្ហ + ឥដ្ឋ) | > សាធិដ្ឋ | មាំមួនបំផុត |
| (អន្តិក + ឥយ) | > នេទិយ | ជិតជាង |
| (អន្តិក + ឥដ្ឋ) | > នេទិដ្ឋ | ជិតបំផុត |

## កំណត់សម្គាល់

*ពាក្យថា* កណិយ, កណិដ្ឋ, កនិយ, កនិដ្ឋ, សេយ្យ, ជេយ្យ, សេដ្ឋ, ជេដ្ឋ, សាធិយ, សាធិដ្ឋ, នេទិយ, នេទិដ្ឋ *មានវិធីរូបសិទ្ធិប្លែកជាងស័ព្ទដទៃ ដូចខាងក្រោមនេះ*

១. កណិយ *សម្រេចមកពីស័ព្ទដើមថា* អប្ប ។ *ប៉ុន្តែផ្លាស់* អប្ប *ជា* កណ *និងចុះ* ឥយ *បច្ច័យ សម្រេចរូបជា* កណិយ =*តូចជាង ។*

បើចុះ ឥដ្ឋ បច្ច័យសម្រេចរូបទៅជា កណិដ្ឋ =តូចបំផុត ។

២. កនិយ សម្រេចមកពីស័ព្ទដើមថា យុវ ។ ប៉ុន្តែផ្លាស់ យុវ ជា កន និងចុះ ឥយ បច្ច័យ សម្រេចរូបជា កនិយ =ក្មេងជាង ។ បើចុះ ឥដ្ឋ បច្ច័យសម្រេចរូបទៅជា កនិដ្ឋ = ក្មេងបំផុត ។

៣. សេយ្យ សម្រេចមកពីស័ព្ទដើម បសត្ថ ។ ប៉ុន្តែផ្លាស់ បសត្ថ ជា ស និងចុះ ឥយ បច្ច័យ សម្រេចរូបជា សេយ្យ, ឬផ្លាស់ បសត្ថ ជា ជ ចុះ ឥយ បច្ច័យ សម្រេចរូបជា ជេយ្យ ប្រែថា ប្រសើរជាង, ព្រឹទ្ធិ ឥ > ឯ និងតម្រួតជា យ្យ ។ បើចុះ ឥដ្ឋ បច្ច័យសម្រេចរូបទៅជា សេដ្ឋ, ជេដ្ឋ ប្រែថា ប្រសើបំផុត ។

៤. ជេយ្យ សម្រេចមកពីស័ព្ទដើមថា វុឌ្ឍ ។ ប៉ុន្តែផ្លាស់ វុឌ្ឍ ជា ជ និងចុះ ឥយ បច្ច័យ សម្រេចរូបជា ជេយ្យ ប្រែថា ចាស់ជាង, ព្រឹទ្ធិ ឥ > ឯ ហើយតម្រួត យ ទៅជា ជេយ្យ ។ បើចុះ ឥដ្ឋ បច្ច័យសម្រេចរូបទៅជា ជេដ្ឋ ប្រែថា ចាស់បំផុត ។

៥. សាធិយ សម្រេចមកពីស័ព្ទដើម ពាឡ្ហ ។ ប៉ុន្តែផ្លាស់ ពាឡ្ហ ជា សាធ និងចុះ ឥយ បច្ច័យ សម្រេចរូបជា សាធិយ ប្រែថា មាំមួនជាង ។ បើចុះ ឥដ្ឋ បច្ច័យសម្រេចរូបជា សាធិដ្ឋ ប្រែថា មាំមួនបំផុត ។

៦. នេទិយ សម្រេចមកពីស័ព្ទដើមថា អន្តិក ។ ប៉ុន្តែផ្លាស់ អន្តិក ជា នេទ និងចុះ ឥយ បច្ច័យ សម្រេចរូបជា នេទិយ ប្រែថា ជិតជាង ។ បើចុះ ឥដ្ឋ បច្ច័យសម្រេចរូបជា នេទិដ្ឋ ប្រែថា ជិតបំផុត ។

## វិធីតាំងវិគ្គហ:

ត្រូវប្រើស័ព្ទដើមក្នុងវិគ្គហៈដូចគ្នា ដូចខាងក្រោមនេះ

**សព្វេ ឥមេ អប្បា អយមិមេសំ វិសេសេន អប្បោតិ កណិយោ ។**

(ជន.ទ.) ទាំងពួង នេះ (ជាអ្នក)តូច ជននេះ (ជាអ្នក)តូច ដោយវិសេស ជាងជន.ទ.នេះ ព្រោះហេតុនោះ ជននោះ ឈ្មោះថា **កណិយោ** =តូចជាង ។

វីពាក្យថា **សេយ្យ, ជេយ្យ, សាធិយ, នេទិយ** ក៏មានវីធីតាំងវិគ្គហៈដូចគ្នាដែរ គឺគ្រាន់តែប្តូរ **អប្បា** ជា **បសដ្ឋា** ឬ **វុឌ្ឍា** ឬ **ពាឡ្ហា** ឬ **អន្តិកា** និងផ្លាស់ **អប្បោតិ** ជា **បសដ្ឋោតិ** ឬ **វុឌ្ឍោតិ** ឬ **ពាឡ្ហោតិ** ឬ **អន្តិកោតិ** ប៉ុណ្ណោះ ។

ចំពោះ **កណិដ្ឋ, កនិដ្ឋ, សេដ្ឋ, ជេដ្ឋ, សាធិដ្ឋ, នេទិដ្ឋ** មានវិធីតាំងវិគ្គហៈនិងប្រែដូចគ្នានឹងបែបទី ២ ចុះ **តម ឥដ្ឋ** នៅខាងលើ គឺគ្រាន់តែប្តូរស័ព្ទដើមចេញ ដូចជាប្តូរ **ចាចោ** ទៅជា **អប្បោ** ជាដើមប៉ុណ្ណោះ ។ បទសម្រេចមកពីតទ្ធិតនេះបំបែកក្នុងរូបវិភត្តិផ្សេង ៗ បានទាំងបីលិង្គ ។

**(សេដ្ឋតទ្ធិតចប់)**

## ១.៩ បកតិតទ្ធិត

តទ្ធិតនេះមានបច្ច័យតែ ១ តួទេគឺ **មយ** និយមចុះចុងនាមនាមណាដែលជាវត្ថុសម្រាប់ផលិតឬធ្វើជាអ្វីមួយ ប្រើជំនួសពាក្យពីរម៉ាត់គឺ **បកត** និង **វិការ** ។ បើប្រើជំនួស **បកត** ប្រែថា "ដែលបុគ្គលធ្វើហើយ..." ឬ "ដែលសម្រេចហើយ..." ។ បើប្រើជំនួស **វិការ** ប្រែថា "ជាវិការៈ..." ។

## វិធីតាំងវិគ្គហៈនៃបកតិតទ្ធិត

១. បទដើមជានាមនាមបំបែកជាតតិយាវិភត្តិឬឆដ្ឋីវិភត្តិ ។

២. បទចុងប្រើ **បកតំ** ឬ **វិការោ** ។

៣. បទសម្រេចត្រូវចុះ **មយ** បច្ច័យរួចបំបែកជាបឋមាវិភត្តិ ។

១ ២ ៣

វិ. សុវណ្ណេន បកតំ/វិការោ សោវណ្ណមយំ ។

បទដើម បទចុង បទសម្រេច

## ១. មយ បច្ច័យប្រើជំនួស បកតំ

១. ( សុវណ្ណ + មយ ) > សោវណ្ណមយ

*វិ.* សុវណ្ណេន បកតំ សោវណ្ណមយំ ( ភាជនំ ) =(*ភាជន៍*) *ដែលបុគ្គលធ្វើហើយដោយមាស* (*ភាជន៍មាស*) ។

*ប្រែ* (*យំ* ភាជនំ *រីភាជន៍ ឯណា*) បកតំ *ដែលបុគ្គលធ្វើហើយ* សុវណ្ណេន *ដោយមាស*, (*តំ* ភាជនំ *រីភាជន៍ នោះ*) សោវណ្ណមយំ *ឈ្មោះថា* សោវណ្ណមយំ, សោវណ្ណមយំ (ភាជនំ *រីភាជន៍*) *ដែលបុគ្គលធ្វើហើយដោយមាស ឬ សម្រេចហើយពីមាស* (*ភាជន៍មាស*) ។

២. ( មត្តិកា + មយ ) > មត្តិកាមយ

*វិ.* មត្តិកាយ បកតំ មត្តិកាមយំ ( ភាជនំ ) =(*ភាជន៍*) *ដែលជនធ្វើហើយដោយដី* (*ភាជន៍ដី*) ។

៣. ( អយ + មយ ) > អយោមយ

*វិ.* អយសា បកតំ អយោមយំ ( ភាជនំ ) =(*ភាជន៍*) *ដែលគេធ្វើហើយដោយដែក* (*ភាជន៍ដែក*) ។

## កំណត់សម្គាល់

សុវណ្ណមយ > សោវណ្ណមយ *គឺព្រឹទ្ធិ* ឧ *នៃ* សុ *ជា* ឱ *តាមការនិយមរបស់ភាសា ។ រីឯ* ( អយ + មយ ) > អយោមយ *គឺផ្លាស់* អ *នៃ* យ *របស់* អយ *ជា* ឱ *តាមគោលការណ៍របស់មនោគណៈស័ព្ទ (ចូររកមើលត្រង់បកិណ្ណកស័ព្ទក្នុងមេរៀនទី ២៦ ក្នុងភាគ ១)* ។

## ២. មយ បច្ច័យប្រើជំនួស វិការ

វិ. សុវណ្ណស្ស វិការោ សោវណ្ណមយំ (ភាជនំ) =(ភាជន៍) ដែលជាវិការៈនៃមាស (ភាជន៍មាស) ។

វិ. មត្តិកាយ វិការោ មត្តិកាមយំ (ភាជនំ) =(ភាជន៍) ដែលជាវិការៈនៃដី (ភាជន៍ដី) ។

វិ. អយសោ វិការោ អយោមយំ (ភាជនំ) =(ភាជន៍) ដែលជាវិការៈនៃដែក (ភាជន៍ដែក) ។

សព្ទសម្រេចពីតទ្ធិតនេះជាគុណនាមអាចបំបែកបានទាំងបីលិង្គ ។

(បកតិតទ្ធិតចប់)

## នាមសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| សន្ទិដ្ឋិកា គុ. | អ្នកគួរឃើញដោយខ្លួនឯង |
| សុវណ្ណចេតិយ នបុំ. | ចេតិយ៍មាស |
| កម្ពលកញ្ចុក បុំ. | អាវក្រៅឬក្រោះធ្វើពីសំពត់កម្ពល |
| រថចក្កប្បមាណ នបុំ. | មានប្រមាណប៉ុនកង់នៃរថ |

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| ទារុអាទិ គុ. | មានឈើជាដើម |
| ទារុមយាទិ គុ. | ធ្វើអំពីឈើជាដើម |
| សោវណ្ណមយ គុ. | ធ្វើអំពីមាស |
| មណិមយ គុ. | ធ្វើអំពីកែវមណី |
| រជតមយ គុ. | ធ្វើអំពីប្រាក់ |
| លោហមយ គុ. | ធ្វើអំពីដែក |
| ទយាលុ គុ. | មានករុណាច្រើន |
| បច្ឆិមាភិមុខា គុ. | បែរមុខទៅទិសខាងលិច |
| ភទ្រ, ភទ្ទ គុ. | ល្អ, ចម្រើន |
| ទិសាបាមោក្ខ គុ. | ប្រមុខក្នុងទិស.ទ. |
| ឱជវន្ត គុ. | មានឱជា, មានរស |
| អរោគ គុ. | មិនមានរោគ |
| ឯកកា គុ. | ម្នាក់ឯង |
| ទូរ គុ. | ឆ្ងាយ |
| ចក្កយុគ នបុំ. | គូនៃកង់ |
| ឧបរិមតល នបុំ. | ផ្ទៃក្នុងខាងលើ |
| សុវណ្ណបទុម នបុំ. | ផ្កាឈូកមាស |
| បណីតបណីត នបុំ. | ប្រណីត ៗ, ឧត្តម ៗ |

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| ជីវក បុំ. | (ឈ្មោះ) |
| កោមារភច្ច បុំ. | (ឈ្មោះ) |
| ទេវទត្ត បុំ. | (ឈ្មោះ) |
| ចាលិលេយ្យក បុំ. | (ឈ្មោះ) |
| មញ្ចក បុំ. | គ្រែតូច |
| សីសច្ឆវី ឥ. | ស្បែកក្បាល |
| ចាណក បុំ. | សត្វល្អិត, ដង្កូវ |
| សីសាពាធ បុំ. | ជំងឺក្នុងក្បាល |
| កោដិគាម បុំ. | ស្រុកទីបំផុត |
| លិច្ឆវី បុំ. | អ្នកស្រុកលិច្ឆវី |
| ចាដលិគាមិក បុំ. | អ្នកស្រុកបាដលិ |
| អាវសថាគារ នបុំ. | រោងសំណាក់ |
| តេលិក បុំ. | អ្នកលក់ប្រេង |
| ធណ្ឌាលិក បុំ. | អ្នកលក់អង្ករ |
| ទ្វារចាលក បុំ. | ឆ្មាំទ្វារ |
| អគ្គសាវក បុំ. | អគ្គសាវ័ក |
| និយ្យានិក គុ. | អ្នកដឹកនាំ(ចេញចាកសង្សារ) |
| សហាភូ បុំ. | ការនៅជាមួយគ្នា |

## ធាតុស័ព្ទ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| និ + បទ | សម្រេច, ផលិត | ប + សទ | ជ្រះថ្លា |
| អនុ + កម្ប | អាណិត, អនុគ្រោះ | បរិ + ខិប | បិទបាំង, ព័ទ្ធ |
| ប + ខល | លាង, ជម្រះ | សំ + បទ | ដល់ព្រម |
| បុរ + ការ | ធ្វើនៅខាងមុខ | បដិ + ញា | សន្យា |
| និ + បទ | ដេក | ផល | ពុះ, ហែក, វះ |
| យុជ | ប្រកប | | |

## លំហាត់នៃមេរៀនទី ៤០

### *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើភាគាទិតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

*២. តើបច្ច័យនីមួយ ៗ ប្រើជំនួសស័ព្ទប្រភេទណាខ្លះ ?*

*៣. តើជាតាទិតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

*៤. តើបច្ច័យនីមួយ ៗ ប្រើជំនួសស័ព្ទប្រភេទណាខ្លះ ?*

*៥. តើសមូហតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

*៦. តើបច្ច័យនីមួយ ៗ ប្រើជំនួសអ្វី ? ស័ព្ទសម្រេចត្រូវប្រែដូចម្ដេចខ្លះ ?*

*៧. តើឋានតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

៨. តើបច្ច័យនីមួយ ៗ ប្រើជំនួសស័ព្ទអ្វីខ្លះ ?

៩. តើពហុលតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

១០. តើសេដ្ឋតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

១១. តើបច្ច័យនីមួយ ៗ សម្រាប់ចុះក្នុងស័ព្ទប្រភេទណា ?

១២. តើបកតិតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

១៣. តើបច្ច័យនីមួយ ៗ ប្រើជំនួសស័ព្ទអ្វីខ្លះ ?

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. យថា បន ទារុអាទីហិ និព្ពត្តានិ តានិ តានិ ភណ្ឌានិ ទារុមយាទីនិ នាម ហោន្តិ, តថា ឯតេបិ មនតោ និព្ពត្តត្តា មនោមយា នាម ។

២. "មាណវ, អហំ តេ សោវណ្ណមយំ វា មណិមយំ វា រជតមយំ វា លោហមយំ វា ចក្កយុគំ ទស្សាមី"តិ ព្រាហ្មណោ វទិ ។

៣. មាគធោ ពិម្ពិសារោ រាជា អត្តនោ បាសាទស្ស ឧបរិមតលេ ឋិតោ បិណ្ឌាយ ចរន្តំ ពោធិសត្តំ អនុគច្ឆន្តេ នាគរេ ទិស្វា "កិមេត"ន្តិ បុច្ឆិ ។

៤. ទយាលុ ភគវា មហាជនំ អនុកម្បន្តោ សព្វទា ឯកត្ថ អវសិត្វា តត្ថ តត្ថ វិចរន្តោ សន្ទិដ្ឋិកំ ធម្មំ ទេសេសិ ។

៥. បាដលិគាមិកាបិ ខោ ឧបាសកា បាទេ បក្ខាលេត្វា អាវសថាគារំ បវិសិត្វា បុរត្ថិមំ ភិត្តឹ និស្សាយ បច្ឆិមាភិមុខា

និសីទឹសុ, ភគវន្តំ យេវ បុរក្ខត្វា ។

៦. អស្សោសុំ ខោ វេសាលិកា លិច្ឆវី "ភគវា កិរ កោដិគាមំ អនុប្បត្តោ"តិ ។ អថ ខោ វេសាលិកា លិច្ឆវី ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា ។បេ។ វេសាលិយា និយឹសុ, ភគវន្តំ ទស្សនាយ ។

៧. តេន ខោ បន សមយេន រាជគហិកស្ស សេដ្ឋិស្ស សត្តវស្សិកោ សីសាពាធោ អហោសិ ។ ពហូ មហន្តា មហន្តា ទិសាបាមោក្ខា វេជ្ជា អាគន្ត្វា នាសក្ខឹសុ អរោគំ កាតុំ ។

៨. អថ ខោ ជីវកោ កោមារភច្ចោ សេដ្ឋឹ គហបតឹ មញ្ចកេ និបជ្ជាបេត្វា មញ្ចកេន សម្ពន្ធិត្វា សីសច្ឆវឹ ផាលេត្វា ។បេ។ ទេវចារណកោ នីហរិត្វា ជនស្ស ទស្សេសិ ។

៩. សេដ្ឋិបុត្តោ "និយ្យានិកំ វត ពុទ្ធសាសន"ន្តិ បសីទិត្វា យោជនិកំ សុវណ្ណចេតិយំ កម្ពលកញ្ចុកេន បរិក្ខិបិត្វា តត្ថ តត្ថ រថចក្កប្បមាណេហិ សុវណ្ណបទុមេហិ អលង្ការិ ។

១០. តស្មឹ សមយេ ចតុសត្តតិសហស្សជដិលា បណីតបណីតានិ ឱជវន្តានិ ផលផលានិ គហេត្វា អាចរិយស្ស សន្តិកំ សម្បត្តា ។

❁ នាសក្ខឹសុ < (ន + អសក្ខឹសុ) ។

## គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. អ្នកលក់ប្រេង វាយហើយ នូវធ្មាំទ្វារ របស់ឈ្មួញអង្ករ ជាមួយអាវុធ ដែលធ្វើហើយ ដោយដែក ។

២. ព្រាហ្មណ៍ មដ្ឋកុណ្ឌលី កើតហើយ ក្នុងវិមាន ដែលសម្រេចហើយ ដោយមាស ក្នុងឋានសួគ៌ តាវតិង្ស ព្រោះសេចក្តីជ្រះថ្លា និង សេចក្តីស្រឡាញ់ ក្នុងព្រះពុទ្ធ ។

៣. ព្រាហ្មណ៍ កំណាញ់ ជាឪពុក របស់មដ្ឋកុណ្ឌលី បានសន្យា ដើម្បី ឱ្យ នូវកងមួយគូ ធ្វើពីស្ពាន់, ឬ ធ្វើពីប្រាក់ ឬ ធ្វើពីមាស ដល់គេ ។

៤. កាលនោះ ទេវទត្ត អង្គុយហើយ សំដែង នូវធម៌, កាលលោក-ឃើញហើយ ពីចម្ងាយ នូវព្រះសារីបុត្ត និង ព្រះមោគ្គល្លាន កំពុងមក កាន់លោក លោកពោលហើយ ទៅកាន់ភិក្ខុ.ទ. ថា "ម្នាលភិក្ខុ.ទ. អ្នក.ទ. ចូរមើល សូម្បី រីអគ្គសាវ័ក របស់ព្រះ-សមណគោតម កំពុងមក ដើម្បីនៅជាមួយ នឹងយើង" ។

៥. ព្រះមានព្រះភាគ កាលគ្រង នូវព្រះកាយ ក្នុងពេលព្រឹក កាលយក នូវបាត្រនិងចីវរ យាងចូលទៅហើយ កាន់កោសម្ពី ដើម្បីបិណ្ឌ-បាត្រ ។ ព្រះអង្គ បានចេញទៅ តែមួយព្រះអង្គ កាន់ព្រៃ-បាលិលេយ្យក មិនបានប្រាប់ ដល់អ្នកបម្រើ និង ភិក្ខុ.ទ. ឡើយ ។

**(ចប់មេរៀនទី ៤០)**

# មេរៀនទី ៤១

# អធិប្បាយអំពីតទ្ធិត (ត)

## ១.១០ តទស្សត្ថិតទ្ធិត

*ឈ្មោះថា* **តទស្សត្ថិ** *នេះជាបទសន្ធិសម្រេចមកពី (***ត** + **អស្ស** + **អត្ថិ***) > ***តទស្សត្ថិ** *(បុះ ទ អាគម) បានដល់ការប្រើស័ព្ទជំនួស* **អត្ថិ** *មួយស័ព្ទប៉ុណ្ណោះ ។*

**អត្ថិ** *មកពី* **អស** *ធាតុ ប្រែថា "មាន" ។ វេលាតាំងវិគ្គហៈត្រូវចុះ* **ត** *សព្វនាមនិងបំបែកជា* **អស្ស** *នៅមុខ* **អត្ថិ** *ស័ព្ទជានិច្ច ទើបមានឈ្មោះថា* **តទស្សត្ថិតទ្ធិត** *ឬនឹងហៅថា* **អត្ថិតទ្ធិត** *ក៏បាន ពីព្រោះប្រើបច្ច័យជំនួស* **អត្ថិ** *ស័ព្ទប៉ុណ្ណោះ ។*

*តទ្ធិតនេះមានបច្ច័យ ៩ តួគឺ* **វី**, **ស**, **សី**, **ឥក**, **ល**, **រ**, **វន្តុ**, **មន្តុ**, **ណ** *។ ក្នុង ៩ តួនេះ មានបច្ច័យដូចតទ្ធិតឯទៀតពីរតួគឺ* **ឥក**, **ណ** *។ សូមចាំថាបច្ច័យទាំងប្រាំបួនតួនេះ បើចុះក្នុងស័ព្ទណាហើយ ត្រូវប្រែថា "មាន..." ខាងដើមស័ព្ទនោះ ៗ ជានិច្ច ។ វិធីតាំងវិគ្គហៈមានរបៀបដូចគ្នាទាំងអស់ដូចខាងក្រោមនេះ*

## វិធីតាំងវិគ្គហៈនៃតទស្សត្ថិតទ្ធិត

១. បទដើមជានាមនាមបំបែកជាបឋមាវិភត្តិតាម ការន្ត និង លិង្គ នោះ ៗ ។

២. បទកណ្តាលប្រើ **ត** សព្វនាមបំបែកជា **អស្ស** ឆដ្ឋីវិភត្តិសម្រាប់យោគនាមដទៃ ប្រែថា "របស់, នៃ" ។

៣. បទចុងប្រើ **អត្ថិ** ផ្សំជាមួយ **ឥតិ** ស័ព្ទទៅជា **អត្ថីតិ** ។

៤. បទតទ្ធិត ត្រូវចុះបច្ច័យតួណាមួយខាងចុង រួចបំបែកជាបឋមាវិភត្តិតាមការន្តនិងលិង្គនោះ ៗ ។

១ | ២ | ៣ | ៤

**មេធា** + **អស្ស** + (**អត្ថិ** + **ឥតិ**) > **មេធាវី**

បទដើម | បទកណ្តាល | បទចុង | បទតទ្ធិត

## ១. វី បច្ច័យ

(**មេធា** + **វី**) > **មេធាវី**

វិ. **មេធា អស្ស អត្ថីតិ មេធាវី** (**ជនោ**) =(ជន) អ្នកមានបញ្ញា ។

ប្រែដូច្នេះ **មេធា** វិបញ្ញា **អស្ស** របស់ជននោះ **អត្ថិ** មាន **ឥតិ** ព្រោះហេតុនោះ (**សោ ជនោ** វិជន នោះ) **មេធាវី** ឈ្មោះថា **មេធាវី**, **មេធាវី** (**ជនោ** វិជន) អ្នកមានបញ្ញា ។

បច្ច័យដទៃ ៗ ទៀតក៏មានវិធីប្រែដូចគ្នានេះ ប៉ុន្តែតទៅទៀតនឹងប្រែត្រឹមតែបទតទ្ធិតប៉ុណ្ណោះ ។

( មាយា + វី ) > មាយាវី

វិ. មាយា អស្ស អត្ថីតិ មាយាវី (ជនោ) =(ជន) អ្នកមានមាយា ។

## ២. ស បច្ច័យ

( សុមេធា + ស ) > សុមេធាស

វិ. សុមេធា អស្ស អត្ថីតិ សុមេធាសោ (ជនោ) =(ជន) អ្នកមានបញ្ញាល្អ ។

## ៣. សី បច្ច័យ

( តប + សី ) > តបស្សី

វិ. តបោ អស្ស អត្ថីតិ តបស្សី (ជនោ) =(ជន) អ្នកមានតបៈ ។

( តេជ + សី ) > តេជស្សី

វិ. តេជោ អស្ស អត្ថីតិ តេជស្សី (ជនោ) =(ជន) អ្នកមានតេជៈ ។

## ៤. ឥក បច្ច័យ

(ធញ្ញ + ឥក) > ធញ្ញិក

វិ. ធញ្ញោ អស្ស អត្ថីតិ ធញ្ញិកោ (ជនោ) =(ជន) អ្នកមានឈើប្រត់ ។

(អត្ថ + ឥក) > អត្ថិក

វិ. អត្ថោ អស្ស អត្ថីតិ អត្ថិកោ (ជនោ) =(ជន) អ្នកមានប្រយោជន៍ ។

## ៥. ឦ បច្ច័យ

(ធញ្ញ + ឦ) > ធញ្ញី

វិ. ធញ្ញោ អស្ស អត្ថីតិ ធញ្ញី (ជនោ) =(ជន) អ្នកមានឈើប្រត់ ។

(សុខ + ឦ) > សុខី

វិ. សុខំ អស្ស អត្ថីតិ សុខី (ជនោ) =(ជន) អ្នកមានសេចក្ដីសុខ ។

(ភោគ + ឦ) > ភោគី

វិ. ភោគោ អស្ស អត្ថីតិ ភោគី (ជនោ) =(ជន) អ្នកមានទ្រព្យ, អ្នកមានភោគ ។

## ៦. រ បច្ច័យ

(មធុ + រ ) > មធុរ

*វិ.* មធុំ អស្ស អត្ថីតិ មធុរោ (បូវោ) =(នំ) *ដែលមានរសផ្អែម ។*

(មុខ + រ) > មុខរ

*វិ.* មុខំ អស្ស អត្ថីតិ មុខរោ (ជនោ) =(ជន) *អ្នកមានមាត់ (បាន សំដី) ។*

## ៧. វន្តុ បច្ច័យ

(គុណ + វន្តុ) > គុណវន្តុ

*វិ.* គុណោ អស្ស អត្ថីតិ គុណវា (ជនោ) =(ជន) *អ្នកមានគុណ ។*

(ធន + វន្តុ) > ធនវន្តុ

*វិ.* ធនំ អស្ស អត្ថីតិ ធនវា (ជនោ) =(ជន) *អ្នកមានទ្រព្យ ។*

(បញ្ញា + វន្តុ) > បញ្ញាវន្តុ

*វិ.* បញ្ញា អស្ស អត្ថីតិ បញ្ញាវា (ជនោ) =(ជន) *អ្នកមានបញ្ញា ។*

(បុញ្ញ + វន្តុ) > បុញ្ញវន្តុ

*វិ.* បុញ្ញំ អស្ស អត្ថីតិ បុញ្ញវា (ជនោ) =(ជន) *អ្នកមានបុណ្យ ។*

*(ចូលមើលវិធីបំបែកនាមស័ព្ទត្រង់* ភគវន្តុ *ក្នុងមេរៀនទី ២៤)*

# ៨. មន្តុ បច្ច័យ

(អាយុ + មន្តុ) > អាយស្មន្តុ⎈

វិ. អាយុ អស្ស អត្ថីតិ អាយស្មា (ជនោ) =(ជន) អ្នកមានអាយុ ។

(សតិ + មន្តុ) > សតិមន្តុ

វិ. សតិ អស្ស អត្ថីតិ សតិមា (ជនោ) =(ជន) អ្នកមានសតិ ។

(ចក្ខុ + មន្តុ) > ចក្ខុមន្តុ

វិ. ចក្ខុ អស្ស អត្ថីតិ ចក្ខុមា (ជនោ) =(ជន) អ្នកមានចក្ខុ ។

(ជុតិ + មន្តុ) > ជុតិមន្តុ

វិ. ជុតិ អស្ស អត្ថីតិ ជុតិមា (ជនោ) =(ជន) អ្នកមានពន្លឺ, រុងរឿង ។

⎈ អាយស្មន្តុ (ផ្លាស់ ឧ នៃ យុ ជា អស (អាយស + មន្តុ) > អាយស្មន្តុ ។

# ៩. ណ បច្ច័យ

(សទ្ធា + ណ) > សទ្ធ

វិ. សទ្ធា អស្ស អត្ថីតិ សទ្ធោ (ជនោ) =(ជន) អ្នកមានសទ្ធា ។

(មច្ឆេរ + ណ) > មច្ឆេរ

វិ. មច្ឆេរំ អស្ស អត្ថីតិ មច្ឆេរោ (ជនោ) =(ជន) អ្នកមានសេចក្តីកំណាញ់ ។

# កំណត់សម្គាល់

ក្នុងសទ្ទនីតិប្រាប់ថាមានបច្ច័យ ១ តួទៀតគឺ **ឥមន្តុ** ដូចជា

(**បុត្ត** + **ឥមន្តុ**) > **បុត្តិមន្តុ** បំបែកជា **បុត្តិមា** =មានបុត្រ ។

(**ចាប** + **ឥមន្តុ**) > **ចាបិមន្តុ** បំបែកជា **ចាបិមា** =មានបាប ។

ក្នុងបច្ច័យទាំង ៩ តួនេះ តួខ្លះនិយមចុះចុងនាមស័ព្ទការន្តនេះ ខ្លះទៀតចុះក្នុងការន្តផ្សេង ។

១. **វី** បច្ច័យនិយមចុះខាងចុងនាមស័ព្ទជា **អា** ការន្តឥត្ថីលិង្គតែម៉្យាងដូចជា (**មេធា** + **វី**) > **មេធាវី** ។

២. **សី** បច្ច័យនិយមចុះខាងចុងពួកមនោគណនាមស័ព្ទ ដូចជា **តេជស្សី**, **តបស្សី** ជាដើម ។

៣. **វន្តុ** បច្ច័យនិយមចុះខាងចុងនាមស័ព្ទជា **អ**, **អា** ការន្តដូចជា (**បុញ្ញ** + **វន្តុ**) > **បុញ្ញវន្តុ**, (**បញ្ញា** + **វន្តុ**) > **បញ្ញវន្តុ** ជាដើមបំបែកដូច **ភគវន្តុ** ។

៤. **មន្តុ** បច្ច័យនិយមចុះខាងចុងនាមស័ព្ទជា **ឥ**, **ឧ** ការន្តដូចជា (**សតិ** + **មន្តុ**) > **សតិមន្តុ**, (**ចក្ខុ** + **មន្តុ**) > **ចក្ខុមន្តុ** ជាដើមបំបែកដូច **ភគវន្តុ** ។

៥. បទតទ្ធិតសម្រេចពីបច្ច័យទាំង ៩ តួនេះជាគុណនាមតែម៉្យាងវេលាបំបែកតាមវិភត្តិទាំងបីលិង្គ ត្រូវកាន់យកការន្តរបស់បទសម្រេចជាសំខាន់ ។ បើជាការន្តអ្វីត្រូវបំបែកតាមការន្តនិងឱ្យត្រូវតាមលិង្គនោះៗ ។

ប្រសិនបើជា **អ** ការន្តបុំលិង្គនិងចង់ឱ្យទៅជាឥត្ថីលិង្គត្រូវចុះ **អា** បច្ច័យ ដូចជា **សទ្ធ** > **សទ្ធា** បំបែកដូច **កញ្ញា** បានគ្រប់វិភត្តិ ។ បើជា **ឦ** ការន្តនិងចង់ឱ្យទៅជាឥត្ថីលិង្គត្រូវចុះ **ឥនី** ដូចជា **មេធាវី** > **មេធាវិនី** បំបែកដូច **នារី** គ្រប់វិភត្តិ និងបើចង់ឱ្យទៅជានបុំសកលិង្គត្រូវរស្សៈ **ឦ** > **ឥ** ដូចជា **មេធាវី** > **មេធាវិ** បំបែកដូចជា **អក្ខិ** បានគ្រប់វិភត្តិ ។

**បញ្ជាក់** ការប្រែវិគ្គហៈខាងលើ មានពាក្យថា "អ្នក/ដែល" នៅខាងដើមពាក្យថា "មាន" នេះ គឺថែមដើម្បីឲ្យទៅជាគុណនាមនៃភាសាខ្មែរពេញលក្ខណៈ ពីព្រោះមាននាមស័ព្ទនៅខាងដើម គឺ "ជន, នំ" ជាដើម ។

## គំរូបំបែកទាំងបីលិង្គ

| ស័ព្ទដើម | បុំលិង្គ | ឥត្ថីលិង្គ | នបុំ.លិង្គ | ពាក្យប្រែ |
|---|---|---|---|---|
| សទ្ធា | សទ្ធោ | សទ្ធា | សទ្ធំ | មានសទ្ធា |
| មេធាវី | មេធាវី | មេធាវិនី | មេធាវិ | មានបញ្ញា |
| ភោគ | ភោគី | ភោគិនី | ភោគិ | មានភោគ |
| សុខ | សុខី | សុខិនី | សុខិ | មានសុខ |
| គុណវន្តុ | គុណវា | គុណវតី | គុណវំ | មានគុណ |
| ជុតិមន្តុ | ជុតិមា | ជុតិមតី | ជុតិមំ | មានភាពរុងរឿង |

(តទស្សិតទ្ធិតចប់)

## ១.១១ បូរណតទ្ធិត

បូរណតទ្ធិតមានបច្ច័យ ៥ តួគឺ **តិយ, ថ, ឋ, ម, ឦ** ។ បច្ច័យនេះនិយមចុះខាងចុងបកតិសំខ្យានិងប្រើជំនួសពាក្យថា **បូរណ** មួយម៉ាត់ប្រែថា "ទី" ឬ "ជាទីពេញ" ។ បទតទ្ធិតដែលចុះបច្ច័យទាំងប្រាំតួនេះហៅថា **បូរណសំខ្យា** ខ្លះ **បូរណតទ្ធិត** ខ្លះ ។

បើប្រាថ្នាចង់ដឹងពីវិធីប្រើបកតិសំខ្យា សូមមើលមេរៀនទី ១២ និង ១៣ ថែមទៀតផងចុះ ។ ទីនេះពុំពោលទៀតទេ នឹងពោលតែវិធីប្រែនិងវិធីតាំងវិគ្គហៈរបស់បច្ច័យមួយតួ ៗ ឱ្យដឹងដូចតទៅនេះ

## វិធីតាំងវិគ្គហៈនៃបូរណតទ្ធិត

មានវិធីតាំងវិគ្គហៈដូចគ្នាទាំងអស់គឺខាងក្នុងវិគ្គហៈត្រូវមាន

១. បទដើមជាបកតិសំខ្យាបំបែកជាឆដ្ឋីវិភត្តិពហុវចនៈ ដែលមានទីបំផុតជា **-អន្នំ, -ឥន្នំ, -ឥណ្ណំ, -ឥណ្ណន្នំ** ប្រែថា "នៃ...ទាំងឡាយ" ។

២. បទចុងប្រើ **បូរណ** ស័ព្ទបំបែកជាបឋមាវិភត្តិឱ្យត្រូវតាមលិង្គនោះ ៗ ។

៣. បទតទ្ធិតចុះបច្ច័យតួណាមួយតាមការគួរ រួចបំបែកជាបឋមាវិភត្តិឯកវចនៈតាមការន្តនៃលិង្គនោះ ៗ ។

## ១. តិយ បច្ច័យ

( ទ្វិ > ទុ + តិយ ) > ទុតិយ

*វិ.* ទ្វិន្នំ បូរណោ ទុតិយោ ( ជនោ ) *=(ជន) ជាទីពេញនៃជន.ទ. ពីរ, (ជន) ទី ២ ។*

( តិ > ត + តិយ ) > តតិយ

*វិ.* តិណ្ណំ បូរណោ តតិយោ ( ជនោ ) *=(ជន) ជាទីពេញនៃ ជន.ទ.បី, (ជន) ទី ៣ ។*

## កំណត់សម្គាល់

តិយ *បច្ច័យសម្រាប់ចុះខាងចុងបកតិសំខ្យាពីរស័ព្ទប៉ុណ្ណោះគឺ* ទ្វិ *និង* តិ *។*

## ២. ថ បច្ច័យ

( ចតុ + ថ ) > ចតុត្ថ

*(តម្រួត* ត *លើ* ថ *ជា* ត្ថ*)*

*វិ.* ចតុន្នំ បូរណោ ចតុត្ថោ ( ជនោ ) *=(ជន) ជាទីពេញនៃជន.ទ. បួន, (ជន) ទី ៤។*

ថ *បច្ច័យចុះក្នុងបកតិសំខ្យាតែមួយស័ព្ទប៉ុណ្ណោះគឺ* ចតុ *។*

## ៣. ឋ បច្ច័យ

( ឆ + ឋ ) > ឆដ្ឋ

(ត្រូវតម្រួតជា ដ្ឋ)

វិ. ឆន្នំ បូរណោ ឆដ្ឋោ (ជនោ) =(ជន) ជាទីពេញនៃជន.ទ. ប្រាំមួយ, (ជន) ទី ៦ ។

ឋ បច្ច័យចុះបានតែជាមួយ ឆ ស័ព្ទមួយម៉ាត់ប៉ុណ្ណោះ ។

## ៤. ម បច្ច័យ

( បញ្ច + ម ) > បញ្ចម

វិ. បញ្ចន្នំ បូរណោ បញ្ចមោ (ជនោ) =(ជន) ជាទីពេញនៃ ជន.ទ.ប្រាំ, (ជន) ទី ៥ ។

ម បច្ច័យអាចចុះក្នុងបកតិសំខ្យាបានទូទៅក្រៅពីពោលខាងលើ ដូចជា **បឋម** =ទី ១, **សត្តម** =ទី ៧, **អដ្ឋម** =ទី ៨, **នវម** =ទី ៩ ជាដើម មានរូបវិគ្គហៈដូចគ្នាទាំងអស់ ។

## ៥. ឦ បច្ច័យ

( ឯកាទស + ឦ ) > ឯកាទសី

រ. **ឯកាទសន្នំ បូរណី ឯកាទសី** (**ឥត្ថី**) =(ស្រី) ជាទីពេញនៃស្រី.ទ.ដប់មួយ, (ស្រី) ទី ១១។

## កំណត់សម្គាល់

៧ បច្ច័យជាឥត្ថីលិង្គតែម្យ៉ាងសម្រាប់ចុះចុងបកតិសំខ្យាស័ព្ទចាប់ពី **ឯកាទស** ដល់ **អដ្ឋារស** ។ សំខ្យាទាំងនេះបើចុះ **ម** បច្ច័យវិញនោះគឺជា **អ** ការន្តបុំលិង្គនិងនបុំសកលិង្គដែលអាចបំបែកបានទាំងពីរលិង្គ ។ ពេលប្រើអធិប្បាយនាមស័ព្ទណាត្រូវបំបែកឱ្យមានវិភត្តិស្មើគ្នា ប៉ុន្តែបានតែខាងឯកវចនៈទេ ពីព្រោះបូរណសំខ្យាឬបូរណតទ្ធិតប្រើរាប់ចំនួនជាទីពេញប៉ុណ្ណោះ ដូចជា **បញ្ចមោ** (**ជនោ**) =(ជន) ទី ៥ គឺរាប់ចំពោះតែអ្នកទីប្រាំ មិនបានរាប់ទាំងអស់ទាំងប្រាំអ្នកឡើយ ។

ជាពិសេស វេលាប្រែវិគ្គហៈ បទបកតិសំខ្យាដែលបំបែកជាឆដ្ឋីវិភត្តិពហុវចនៈនោះ ត្រូវយោគនាមដទៃចូលមក បំបែកឱ្យមានវិភត្តិស្មើគ្នា ពីព្រោះបកតិសំខ្យាមានលក្ខណៈជាបទវិសេសនៈ(គុណស័ព្ទ) គឺរាប់ចំនួនឱ្យដឹងថាមានចំនួនប៉ុន្មាន ប្រើរាប់នាមអ្វីត្រូវយោគនាមនោះចូលមកដូចវិគ្គហៈថា **ទ្វិន្នំ បូរណោ ទុតិយោ** (**ជនោ**) គឺយោគ (**ជនានំ** = នៃជនទាំងឡាយ) ប្រែថា (ជន) ជាទីពេញ<u>នៃជនទាំងឡាយ</u>ពីរ, (ជន)

ទី ២, យ៉ាងនេះជាដើម ។ វិគ្គហៈដទៃ ៗ ទៀតក៏មានគតិដូចគ្នាដែរ ។

ចំពោះស័ព្ទថា **អឌ្ឍ** =កន្លះ បានអធិប្បាយក្នុងមេរៀនទី ១៣ រួចហើយ សូមរកមើលថែមផងចុះ ។

(**បូរណតទ្ធិតចប់**)

## ១.១២ សំខ្យាតទ្ធិត

តទ្ធិតនេះមានបច្ច័យមួយតួគឺ **កា** និយមចុះខាងចុងបកតិសំខ្យាស័ព្ទតែម្យ៉ាង ប្រើជំនួសពាក្យថា **បរិមាណ** ប្រែថា "មានប្រមាណ, មានចំនួន" ។ ចំពោះការរៀងវិគ្គហៈមានលក្ខណៈស្រដៀងគ្នានឹងរូបវិគ្គហៈនៃតទស្សត្ថិតទ្ធិតដែរ គឺត្រូវថែម ត សព្វនាមដែលបំបែកជា **អស្ស** និងសរសេរចូលជាមួយ **ឥតិ** ស័ព្ទទៀតទៅជា **អស្សាតិ** ។

## វិធីតាំងវិគ្គហៈនៃសំខ្យាតទ្ធិត

១. បទដើមជាបកតិសំខ្យាចំនួនប៉ុន្មានក៏បាន បំបែកជាបឋមាវិភត្តិពហុវចនៈ រៀងដាក់ទី ១ ។

២. បទកណ្តាលប្រើ **បរិមាណ** ជានបុំសកលិង្គបំបែកជាបឋមា-

វិភត្តិពហុវចនៈទៅជា **បរិមាណានិ** រៀងដាក់ទី ២ ។

៣. បទចុងប្រើ **ត** សព្វនាមបំបែកជា **អស្ស** សរសេរចូលជាមួយ **ឥតិ** ទៅជា **អស្សាតិ** សម្រាប់យោគនាមដទៃចូល ។

៤. បទតទ្ធិតចុះ **ក** បច្ច័យជំនួស បំបែកជាបឋមាវិភត្តិឯកវចនៈ ប្រែថា "មាន..." ដូចខាងក្រោមនេះ

១ ២ ៣ ៤

វិ. **ទ្វេ** + **បរិមាណានិ** + (**អស្ស** + **ឥតិ**) **ទ្វិកំ** ។

បទដើម បទកណ្ដាល បទចុង បទតទ្ធិត

(**ទ្វិ** + **ក**) > **ទ្វិក**

វិ. **ទ្វេ បរិមាណានិ អស្សាតិ ទ្វិកំ** (វត្ថុ) =(វត្ថុ) មានចំនួនពីរ ។

ប្រែ **បរិមាណានិ** រីចំនួនទាំងឡាយ **ទ្វេ** ពីរ **អស្ស** (វត្ថុស្ស នៃវត្ថុ) នោះ **ឥតិ** ព្រោះហេតុនោះ (តំ វត្ថុ រីវត្ថុ នោះ) **ទ្វិកំ** ឈ្មោះថា **ទ្វិកំ**, **ទ្វិកំ** (វត្ថុ រីវត្ថុ) មានចំនួនពីរ ។

(**តិ** + **ក**) > **តិក**

វិ. **តីណិ បរិមាណានិ អស្សាតិ តិកំ** (វត្ថុ) =(វត្ថុ) មានចំនួនបី ។

(**ចតុ** + **ក**) > **ចតុក្ក**

វិ. **ចត្តារិ បរិមាណានិ អស្សាតិ ចតុក្កំ** (វត្ថុ) =(វត្ថុ) មានចំនួនបួន ។

## កំណត់សម្គាល់

*បទតទ្ធិតប្រភេទនេះបើប្រែថា "មានប្រមាណ, មានចំនួន, មានបរិមាណ" គឺជាគុណនាម ។ បើប្រែថា "ពួក" ជានាមនាម ដូចជា* **ទ្វិក** *= ពួកពីរ,* **តិក** *=ពួកបី,* **បញ្ចក** *=ពួកប្រាំ,* **ឆក្ក** *=ពួកប្រាំមួយ ជាដើម ។*

*ការរៀងវិគ្គហៈមានរបៀបស្រដៀងគ្នា ខុសតែត្រង់ពុំចាំបាច់ថែម* **ឥតិ** *ស័ព្ទចូលមកទេ និងផ្លាស់ពាក្យប្រែពី* "**បរិមាណ** *=ប្រមាណ" ទៅជា "ពួក" ប៉ុណ្ណោះដូចជា វិ.* **តីណិ បរិមាណានិ អស្ស តិកំ** *(វត្ថុ) = ពួក.ទ. បីនៃវត្ថុនោះ ឈ្មោះថា វត្ថុពួកបី ។*

(*សំខ្យាតទ្ធិតចប់*)

## ១.១៣ វិភាគតទ្ធិត

*តទ្ធិតនេះប្រើបច្ច័យ ២ តួគឺ* **ធា**, **សោ** *។ ចំពោះ* **ធា** *បច្ច័យនិយមចុះចុងស័ព្ទបកតិសំខ្យាតែម៉្យាង,* **ធា** *បច្ច័យប្រើជំនួស* **វិភាគ** *ស័ព្ទប្រែថា "ដោយចំណែក" ។ រីឯ* **សោ** *បច្ច័យចុះចុងនាមស័ព្ទបានទូទៅជាគ្រឿងជំនួស* **វិភាគ** *មួយស័ព្ទ ។* **សោ** *បច្ច័យប្រើជំនួស* **វិភាគ** *ស័ព្ទប្រែថា "ដោយចំណែកដោយ..." ។ បច្ច័យពីរតួនេះជាអព្យយបច្ច័យ ដូច្នេះស័ព្ទ*

ដែលសម្រេចមកពុំចាំបាច់បំបែកតាមវិភត្តិផ្សេង ៗ ទេ ។ វេលាប្រែ ត្រូវខ្ចីពាក្យប្រែរបស់តតិយាវិភត្តិប្រែថា "ដោយ..." ។ មានវិធីតាំងវិគ្គហៈដូចគ្នាទាំងអស់ដូច្នេះ គឺទាំងបទដើមនិងបទចុងត្រូវបំបែកជាតតិយាវិភត្តិឯកវចនៈឬពហុវចនៈតាមសេចក្តីនោះ ៗ ដូចខាងក្រោមនេះ

## ធា បច្ច័យប្រើជំនួស វិភាគ

(ឯក + ធា) > ឯកធា

វិ. ឯកេន វិភាគេន ឯកធា =ដោយចំណែកមួយ ។

(ទ្វិ + ធា) > ទ្វិធា

វិ. ទ្វីហិ វិភាគេហិ ទ្វិធា =ដោយចំណែក.ទ.ពីរ ។

(សត្ត + ធា) > សត្តធា

វិ. សត្តេហិ វិភាគេហិ សត្តធា =ដោយចំណែក.ទ.ប្រាំពីរ ។

## សោ បច្ច័យប្រើជំនួស វិភាគ

(បទ + សោ ) > បទសោ

វិ. បទេន វិភាគេន បទសោ =ដោយចំណែកដោយបទ ។

(សុត្ត + សោ) > សុត្តសោ

វិ. សុត្តេន វិភាគេន សុត្តសោ =ដោយចំណែកដោយសូត្រ ។

ពាក្យថា **ព្យញ្ជនសោ** =ដោយចំណែកដោយព្យញ្ជនៈ, **ឋានសោ** =ដោយចំណែកដោយឋាន, **ឪឃសោ** =ដោយចំណែកដោយភាគវែង, **សព្វសោ** =ដោយចំណែកទាំងពួង ក៏មានវិគ្គហៈដូច **បទសោ** ដែរ ។

## កំណត់សម្គាល់

**ធា** បច្ច័យមានលក្ខណៈប្រហែល **វិធ** ស័ព្ទប្រែថា "មាន...បែប, មាន...យ៉ាង, មាន...ប្រការ" និយមចុះចុងបកតិសំខ្យាដូចជា **ឯកវិធា** = មានមួយបែប, **ទុវិធា** =មានពីរបែប, **តិវិធា** =មានបីបែប, **ចតុព្វិធា** = មានបួនបែប ជាដើម ។ គប្បីជ្រាបថាស័ព្ទដែលចុះ **វិធ** ជាគុណនាម អាចបំបែកក្នុងរូបវិភត្តិផ្សេង ៗ បានទាំងបីលិង្គ ។ រីឯស័ព្ទដែលចុះ **ធា** បច្ច័យជាអព្យយស័ព្ទបំបែកមិនបានទេ ។

២. **សោ** បច្ច័យវេលាចុះមក មានរូបប្រហែលគ្នានឹង **ស** អាគម ក្នុងមនោគណៈស័ព្ទដូចជា **មនសោ** =នៃចិត្ត, **អយសោ** =នៃដែក ជាដើម ។ សូមជ្រាបថា **សោ** នៃមនោគណៈត្រូវធដ្ឋវិភត្តិគឺផ្លាស់ **ស** វិភត្តិជា **ឱ** ប្រែថា "នៃ..." ។ រីឯ **សោ** បច្ច័យក្នុងវិភាគតទ្ធិតប្រែថា "ដោយចំណែកដោយ..." តែម៉្យាងនិងបំបែកមិនបានទេ បើមានរូបស័ព្ទយ៉ាងណាក៏ទុកជាយ៉ាងនោះ ។ អាស្រ័យហេតុនេះ តើយើងអាចដឹងបានដោយរបៀបណាថាពាក្យណាជាមនោគណៈ ពាក្យណាជាតទ្ធិត ព្រោះ

មានទីបំផុតជា **សោ** ដូចគ្នា ។ រឿងនេះត្រូវអាស្រ័យពាក្យប្រែជាគោល បើប្រែថា "នៃ" គឺជាមនោគណៈ ។ បើប្រែថា "ដោយ" គឺជាវិភាគតទ្ធិត ។

(វិភាគតទ្ធិតចប់)

## ១.១៨ ឧបមាតទ្ធិត

តទ្ធិតនេះមានបច្ច័យ ១ តួគឺ **អាយិតត្ត** ចុះចុងនាមស័ព្ទប្រើជំនួស **វិយ** ស័ព្ទប្រែថា "ដូច, បីដូច, ហាក់បីដូច" ជាពាក្យប្រៀបធៀបរវាងវត្ថុណាមួយទៅនឹងវត្ថុមួយទៀត ដើម្បីឱ្យដឹងច្បាស់លាស់ថែមទៀត ដូចមានឧទាហរណ៍ខាងក្រោមនេះ

**( ធុម + អាយិតត្ត ) > ធុមាយិតត្ត**

វិ. **ធុមោ វិយ ទិស្សតីតិ ធុមាយិតត្តំ** (**វត្ថុ**) =(វត្ថុ) ឃើញ ដូចផ្សែង ។

ប្រែ (**យំ វត្ថុ** រីវត្ថុ ឯណា) **ធុមោ វិយ ទិស្សតិ** រមែងឃើញ ដូចផ្សែង **ឥតិ** ព្រោះហេតុនោះ (**តំ វត្ថុ** រីវត្ថុ នោះ) **ធុមាយិតត្តំ** ឈ្មោះថា **ធុមាយិតត្តំ, ធុមាយិតត្តំ** (**វត្ថុ**) (រីវត្ថុ) ដូចផ្សែង ។

**( តិមិរ + អាយិតត្ត ) > តិមិរាយិតត្ត**

វិ. តិមិរំ វិយ និស្សតីតិ តិមិរាយិតត្តំ (វត្ថុ) =(វត្ថុ) ឃើញ ដូចអ័ព្ទ ។

(ឧបមាតទ្ធិតចប់)

## ១.១៨ និស្សិតតទ្ធិត

តទ្ធិតនេះមានបច្ច័យ ១ តួគឺ ល ចុះចុងនៃនាមស័ព្ទនិងសម្រាប់ប្រើជំនួស និស្សិត ស័ព្ទដែលប្រែថា "អាស្រ័យហើយ" ប្រើជំនួស ឋាន ប្រែថា "ជាទីតាំង" ។

### ល បច្ច័យប្រើជំនួស និស្សិត

( ទុដ្ឋុ + ល ) > ទុដ្ឋុល្ល

(តម្រួតជា ល្ល)

វិ. ទុដ្ឋុំ និស្សិតំ ទុដ្ឋុល្លំ ( កម្មំ ) =(អំពើ) អាស្រ័យហើយនូវសេចក្តីអាក្រក់ ។

( វេទ+ ល ) > វេទល្ល

(តម្រួតជា ល្ល )

*វិ.* វេទំ និស្សិតំ វេទល្វំ (សាសនំ) =(*ពាក្យប្រៀនប្រដៅ*) *អា-ស្រ័យហើយនូវប្រាជ្ញា ។*

## ៧ បច្ច័យប្រើជំនួស ហាន

*វិ.* ទុជ្ជស្ស ហានំ ទុជ្ជល្វំ (ការណំ) =(*ហេតុ*) *ជាទីតាំងនៃសេចក្ដីអាក្រក់ ។*

*វិ.* វេទស្ស ហានំ វេទល្វំ (ការណំ) =(*ហេតុ*) *ជាទីតាំងនៃប្រាជ្ញា ។*

## កំណត់សម្គាល់

*សូមសង្កេតមើលវិគ្គហៈទាំងពីរបែបខាងលើនេះមានលក្ខណៈខុសគ្នាបន្តិចគឺ ប្រសិនបើប្រើជំនួស* **និស្សិតំ** *នាមខាងដើមត្រូវមានរូបជាទុតិយាវិភត្តិ ព្រោះ* **និស្សិតំ** *ជាកិតកិរិយា និងបើប្រើជំនួស* **ហានំ** *ត្រូវមានរូបជាឆដ្ឋីវិភត្តិវិញនេះមកពី* **ហានំ** *ជានាមស័ព្ទ ។*

**(និស្សិតតទ្ធិតចប់)**

*(សាមញ្ញតទ្ធិតចប់ត្រឹមនេះ)*

## នាមសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| ពាហុសច្ច នបុំ. | ភាវៈជាអ្នករៀនច្រើន |
| បណ្ឌិច្ច នបុំ. | ភាវៈនៃបណ្ឌិត |
| មនុស្សត្ត នបុំ. | ភាវៈនៃមនុស្ស |
| រោគី បុំ. | អ្នកមានរោគ |
| ជិឃច្ឆកេសជ្ជ នបុំ. | ថ្នាំដែល...ឱ្យហើយ |
| អារោគ្យ នបុំ. | ភាវៈនៃអ្នកគ្មានរោគ |
| គេលញ្ញ នបុំ. | ជំងឺ |
| បិប្ផលិ, បិប្ផលី ឥ. | ដើមដីប្លី, ដើមល្វៀប |
| បិប្ផលិគុហា ឥ. | គុហាជិតដើមល្វៀប |
| សត្ថ នបុំ. | តម្រា, សាស្ត្រា |
| នានាសត្ថ នបុំ. | តម្រាផ្សេង ៗ |
| ចាតុរ នបុំ.,បុំ. | សេចក្ដីឆ្លាត, ជំនាញ |
| បល្លំក, បល្លង្ក បុំ. | គ្រែន, បល្ល័ង្ក |
| សាកច្ឆា ឥ. | ការសាកសួរ |
| ទាលិទ្ទិយ នបុំ. | ភាវៈនៃអ្នកទ័លក្រ |
| វេបុល្ល នបុំ. | ភាពចម្រើនលូតលាស់ |

| ស័ព្ទបាលី | ពាក្យប្រែ |
|---|---|
| អទិន្នាទាន នបុំ. | ការកាន់យកនូវវត្ថុគេមិនបានឱ្យ |
| កាលប្បវេទនា ឥ. | ការសំដែងនូវកាល |
| បន្ថក បុំ. | អ្នកដើរតាមផ្លូវ |
| នេបុញ្ញ នបុំ. | សេចក្តីប៉ិនប្រសប់ |
| អសិធារា ឥ. | មុខនៃដាវ |
| បរិព្វាជក បុំ. | បរិព្វាជក |
| ខណ បុំ. | ខណៈ |
| និកាយ បុំ. | និកាយ, ពួក, ក្រុម |
| មិច្ឆាទិដ្ឋិក បុំ. | អ្នកមិច្ឆាទិដ្ឋិ |
| អាភរណ នបុំ. | គ្រឿងប្រដាប់ |
| បរិចារិកា ឥ. | អ្នកបំរើស្រី |
| មិគទាយ បុំ. | ព្រៃម្រឹគ |
| ឥសិបតន នបុំ. | (ឈ្មោះ) |
| បថវោជា ឥ. | ឱជានៃផែនដី |
| កច្ឆប បុំ. | អណ្តើក |
| អជាតសត្តុ បុំ. | (ឈ្មោះ) |
| ចរបុរិស បុំ. | អ្នកស៊ើប |
| បន្ថឃាតក បុំ. | ចោរប្លន់តាមផ្លូវ |

| សព្ទបាលី | ពាក្យប្រែ |
|---|---|
| បវត្តិ ឥ. | ដំណឹង |
| ជម្ពូទីប បុំ. | ជម្ពូទ្វីប, ឥណ្ឌា |
| កេលញ្ញជាភិបីឡិត គុ. | បៀតបៀបក្រៃលែងដោយរោគ |
| បណ្ឌិតសមណព្រាហ្មណ បុំ. | បណ្ឌិតនិងសមណនិងព្រាហ្មណ៍ |
| មេត្តាសហគត គុ. | ប្រព្រឹត្តទៅមួយអន្លើដោយមេត្តា |
| និសីទម្ពវន គុ. | អង្គុយហើយក្នុងព្រៃស្វាយ |
| វត្ថាភរណ នបុំ. | សម្លៀកបំពាក់និងគ្រឿងប្រដាប់ |
| រម្ម គុ. | ជាទីរីករាយ |
| ទុល្លភ គុ. | ដោយលំបាក |
| អភិរូប គុ. | មានរូបស្អាត, មានរូបល្អ |
| វិរូប គុ. | មានរូបអាក្រក់ |
| ឯកេក គុ. | ម្តងមួយ ៗ |
| ឋបេត្វា កិត. | វៀរតែ, លើកតែ |
| បដ្ឋាយ និ. | ចាប់ផ្តើម, តាំងពី |

## ធាតុសព្ទ (គ)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| ឧប + ចិ | សន្សំ, ក, ពូន | ឆិទ | ដាច់, ធ្លុះ |
| បដិ + លភ | បានវិញ, សង | ផរ | ផ្សាយទៅ |
| ឧប + សេវ | ចូលទៅសេព | ខិប | បោះទៅ, ចោលទៅ |
| ប + កាស | ប្រកាស, ថ្លែង | ភូស | តាក់តែង, ប្រដាប់ |
| អធិ + ឋា | អធិដ្ឋាន | បរិ + ចរ | បម្រើ |
| ប + ឋា | តាំងមាំ, តាំងនៅ | តិម | ទទឹក, សើម |
| អភិ + បីឡ | បៀតបៀន | វិ + នស | វិនាស, ខូច |
| អនុ+ប+ទា | ឱ្យថែម, បរិច្ចាគ | អា + រភ | ប្រារព្ធ, ផ្តើម |
| បដិ + ហន | បៀតបៀន,កម្ចាត់ | តរហ | តិះដៀល |
| និ + មា | និម្មិត, តំណែង | ប + ចរ | ផ្សាយទៅ |
| សំ + ឈេ | ស្វាធ្យាយ | សុស | ស្ងួត, ហួត, ស្គម |
| បរិ + ឯស | ស្វែងរក | បេស | បញ្ជូនទៅ |

# លំហាត់នៃមេរៀនទី ៤១

## *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើតទស្សត្តិតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

*២. តើតទស្សត្តិតទ្ធិតមានវិធីតាំងវិគ្គហៈដូចម្តេចខ្លះ ?*

៣. តើបទតទ្ធិតនៃតទស្សត្ថិតទ្ធិតត្រូវប្រែថាយ៉ាងមេច ?

៤. តើបូរណតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

៥. តើបច្ច័យបូរណតទ្ធិតនេះទាំងអស់ប្រើជំនួសស័ព្ទអ្វី ?

៦. ចូរតាំងវិគ្គហៈជាបូរណតទ្ធិត ១ វិគ្គហៈ ។

៧. តើសំខ្យាតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

៨. តើបច្ច័យនៃសំខ្យាតទ្ធិតនេះប្រើជំនួសស័ព្ទអ្វី ?

៩. តើវិភាគតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?

១០. តើបច្ច័យនៃវិភាគតទ្ធិតនេះប្រើជំនួសស័ព្ទអ្វី ?

១១. តើឧបមាតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ? ប្រើជំនួសស័ព្ទអ្វី ?

១២. តើនិស្សិតតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ? ប្រើជំនួសស័ព្ទអ្វី ?

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. អាយស្មា អានន្ទត្ថេរោ ភគវតោ សាវកេសុ ពាហុសច្ចេន បណ្ឌិច្ចេន ច អគ្គោ អហោសិ ។

២. មេធាវិនី មាណវី ទុល្លភំ មនុស្សត្តំ លភិត្វា ពហុំ បុញ្ញំ ឧបចិនាតិ ។

៣. ពាតី វេជ្ជេន ជិន្នភេសជ្ជំ ឧបសេវិត្វា អារោគ្យំ បដិលភិត្វា អត្តនោ សោមនស្សំ បកាសេសិ ។

៤. ឯកទា មហាកស្សបត្ថេរោ កេលញ្ញេជាតិបីឡិតោ រាជគហតោ អវិទូរេ បិប្ផលិគុហាយំ វិហរិ ។

៥. មេធាវិនោ សិស្សា តរុណំ មហន្តំ ថាវរំ ទស្សេត្វា នានាសត្ថេសុ បាដវំ លភន្តិ ។

៦. យថា តស្មឹ គេហេ ឋបេត្វា មាណវកស្ស បល្លង្កំ អញ្ញំ កិញ្ចិ អាសនំ ន ទិស្សតិ តថា អធិដ្ឋាសិ ។

៧. តតោ បដ្ឋាយ យត្ថ យត្ថ បណ្ឌិតសមណព្រាហ្មណា អត្ថី"តិ វទន្តិ តត្ថ តត្ថ គន្ត្វា សាកច្ឆំ ការេន្តិ ។

៨. មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ។

៩. អធនានំ ធនេ អននុប្បទិយមានេ ទាលិទ្ទិយំ វេបុល្លំ អគមាសិ ទាលិទ្ទិយេ វេបុល្លំ គតេ អទិន្នាទានំ វេបុល្លំ អគមាសិ ។

១០. តស្ស ទីបន្តស្ស នាសិកា អសិធារាយ បដិហតា ទ្វិធា បជ្ជលិ ។

១១. សហស្សក្ខត្តុំ អត្តានំ និម្មិនិត្វាន បន្ថកោ
និសីទម្ពវនេ រម្មេ យាវ កាលប្បវេទនា ។

១២. ទេវតា តស្ស បុញ្ញេ បកាសេតុំ មហាជនេ
ធាតេសុំ ចោតកំ ទ្វត្តិក្ខត្តុំ បិ តំ អកា ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. កាលនោះ ពួកបរិព្វាជក.ទ. នៃនិកាយ អ្នកមិច្ឆាទិដ្ឋិ ជួបជុំព្រម-ហើយ នាថ្ងៃទី ១៤ នាថ្ងៃទី ១៥ និងថ្ងៃទី ៨ នៃពាក់កណ្ដាលខែ*

ស្វាធ្យាយហើយ នូវធម៌ របស់ពួកគេ ។

២. ខណៈនោះ នាងវិសាខា កាលមាន អាយុ ១៥ ឬ ១៦ ឆ្នាំ មកហើយ កាន់ទីនោះ ដើម្បីងូតទឹក ក្នុងស្ទឹង តាក់តែងហើយ នូវគ្រឿងប្រដាប់ .ទ. របស់នាង និង បម្រើហើយ ដោយអ្នកបម្រើ ៥០០នាក់ ។

៣. អ្នកបម្រើ.ទ. របស់អ្នក កាលរត់ មកហើយ កាន់សាលា នេះ, រឹសម្លៀកបំពាក់និងគ្រឿងប្រដាប់.ទ. មិនបានទទឹកទេ, ប៉ុន្តែ អ្នក មិនបានរត់ ឡើយ ។

៤. ម្នាលព្រាហ្មណ៍ កាលនោះ យើង ដើរទៅ មុខហើយ ក្នុងដំណើរ ពីទីមួយទៅទីមួយ ចូល ទៅជិតហើយ ពារាណសី ដើម្បីទៅ កាន់ព្រៃម្រឹគ ឥសិបតនៈ និងដើម្បីទៅ កាន់ទីណា ដែលព្រាហ្មណ៍ ប្រាំរូប បានរស់នៅ ។

៥. ឥឡូវនេះ ពិភពលោក កាលវិនាស វិនាស ៧ដង ដោយភ្លើង និង ៨ដង ដោយទឹក បន្ទាប់មក ៧ដង ដោយភ្លើង និង ៨ដង ដោយទឹក ទៀត ។

៦. ក្រោយពី សត្វ.ទ. ទាំងនេះ ប្រារព្ធ ដើម្បីស៊ី នូវឱជានៃផែនដី, ខ្លះ ប្រែជា មានរូបល្អខ្លះ ប្រែជា មានរូបអាក្រក់ខ្លះ, គ្រានោះ អ្នកមាន-រូបល្អ តិះដៀល អ្នកមានរូបអាក្រក់ ។

៧. កាលពេលយូរ កន្លងទៅហើយ ទឹក នៃត្រពាំង ទីនេះ ផង ទីនោះ ផង ហួតហើយ ត្រី.ទ. និង អណ្តើក.ទ. ផងដែរ ស្លាប់ហើយ

ម្ដងមួយ ៗ និង កើតហើយ ក្នុងព្រហ្មលោក ។

៨. បក្សី នោះ ហើរទៅហើយ ក្នុងទិសខាងកើត ក្នុងទិសខាងត្បូង ក្នុងទិសខាងលិច ក្នុងទិសខាងជើង ក្នុងខាងលើ ក្នុងទិសតូច.ទ. និង ប្រសិនបើ វា ឃើញ នូវផែនដី ក្នុងទីណា វា ហើរទៅ កាន់ទីនោះ ។

៩. ឥឡូវនេះ ដំណឹង ថា ព្រះថេរៈ ត្រូវចោរប្លន់តាមផ្លូវ សម្លាប់ហើយ ផ្សាយទៅហើយ ក្នុងជម្ពូទ្វីប, ស្ដេចអជាតសត្រូវ បញ្ជូនទៅហើយ នូវអ្នកស៊ើប ដើម្បីស្វែងរក ពួកគេ.ទ. ។

**(ចប់មេរៀនទី ៤១)**

# មេរៀនទី ៤២

# អធិប្បាយអំពីតទ្ធិត (តចប់)

## ២. ភាវតទ្ធិត

*តទ្ធិតនេះមានបច្ច័យ ៦ តួគឺ* **ត្ត, ត្តន, តា, ណ្យ, ណ, ត្តណ** *សម្រាប់ចុះខាងចុងស័ព្ទច្រើនប្រភេទគឺ នាមនាម, គុណនាម, កិតកិរិយា និង នាមកិតក: ដើម្បីប្រើជំនួស* **ភាវ** *ស័ព្ទតែមួយម៉ាត់គត់ ដែលប្រែថា "ការនៃ..." ជានិច្ច ។*

*បណ្ដាបច្ច័យទាំងនេះមានបច្ច័យបីតួជាណានុព័ន្ធ គឺមានតួ* **ណ** *ដែលមានអំណាចទីឃ:និងវិការ:ដូចគ្នានឹង* **ណ** *បច្ច័យក្នុងគោត្តតទ្ធិតដែរ ។ ចំពោះ* **ណ្យ** *បច្ច័យមានន័យវិចិត្រពិស្ដារជាង* **ណ** *តួឯទៀត ៗ ដែលនឹងអធិប្បាយនៅខាងមុខ ។ វិធីតាំងវិគ្គហ:មានរបៀបដូចគ្នាទាំងអស់ដូចតទៅនេះ*

## វិធីតាំងវិគ្គហ:នៃភាវតទ្ធិត

*១. បទដើមជានាមប្រភេទណាក៏បាន បំបែកជាឆដ្ឋីវិភត្តិតាមការន្ត និងលិង្គនោះ ៗ ប្រែថា "នៃ..." ។*

*២. បទចុងប្រើ* **ភាវ** *ស័ព្ទបំបែកជាបឋមាវិភត្តិប្រែថា "ភាវ: ឬ ភាព"*

ជានិច្ច ។

៣. បទតទ្ធិតត្រូវចុះបច្ច័យតួណាមួយជំនួសការស័ព្ទ បំបែកជាបឋមាវិភត្តិឯកវចនៈនបុំសកលិង្គតែម៉្យាង ។ វៀរតែ តា បច្ច័យដែលជាឥត្ថីលិង្គ ។

១ ២ ៣

ឧ. ចន្ទស្ស ភាវោ > ចន្ទត្តំ

បទដើម បទចុង បទតទ្ធិត

## ១. ត្ត បច្ច័យ

(ចន្ទ (នាម) + ត្ត) > ចន្ទត្ត

វិ. ចន្ទស្ស ភាវោ ចន្ទត្តំ =ភាវៈនៃដួងច័ន្ទ, ភាពជាព្រះច័ន្ទ ។

(មនុស្ស (នាម) + ត្ត) > មនុស្សត្ត

វិ. មនុស្សស្ស ភាវោ មនុស្សត្តំ =ភាវៈនៃមនុស្ស, ភាពជាមនុស្ស ។

(ទណ្ឌី (អត្ថិតទ្ធិត) + ត្ត) > ទណ្ឌិត្ត

វិ. ទណ្ឌិនោ ភាវោ ទណ្ឌិត្តំ =ភាវៈនៃអ្នកមានឈើច្រត់, ភាពជាអ្នកមានឈើច្រត់) ។

(ចាចក (នាមកិតក) + ត្ត) > ចាចកត្ត

វិ. ចាចកស្ស ភាវោ ចាចកត្តំ =ភាវៈនៃអ្នកចម្អិន, ភាពជាអ្នកចម្អិន ។

( នីល (គុណនាម) + ត្ត ) > នីលត្ត

វិ. នីលស្ស ភាវោ នីលត្តំ =*ភាវៈនៃ(វត្ថុ)ពណ៌ខៀវ, ភាពជាពណ៌ខៀវ ។*

## ២. ត្តន បច្ច័យ

( បុថុជ្ជន + ត្តន ) > បុថុជ្ជនត្តន

វិ. បុថុជ្ជនស្ស ភាវោ បុថុជ្ជនត្តនំ =*ភាវៈនៃបុថុជ្ជន, ភាពជាបុថុជ្ជន ។*

( វេទនា + ត្តន ) > វេទនត្តន

វិ. វេទនាយ ភាវោ វេទនត្តនំ =*ភាវៈនៃ(...)វេទនា, ភាពវេទនា ។*

## ៣. តា បច្ច័យ

( មុទុ + តា ) > មុទុតា

វិ. មុទុនោ ភាវោ មុទុតា =*ភាវៈនៃអ្នកទន់, ភាពជាអ្នកចិត្តទន់ ។*

( និទ្ទារាម + តា ) > និទ្ទារាមតា

វិ. និទ្ទារាមស្ស ភាវោ និទ្ទារាមតា =*ភាវៈនៃអ្នកត្រេកអរក្នុងការដេក, ភាពល្មោភដេក ។*

( សហាយ + តា ) > សហាយតា

វិ. សហាយស្ស ភាវោ សហាយតា =*ភាវៈនៃសំឡាញ់, ភាពជាសំឡាញ់ ។*

# ៤. ណ្យ បច្ច័យ

ណ្យ ជាបច្ច័យមានតួ ណ ជាប់ជាមួយមានអំណាចដូច ណ បច្ច័យក្នុងគោត្តតទ្ធិត ។ តែ ណ្យ នេះមានន័យពិស្តារជាង ណ តួដទៃទៀត ពីព្រោះ ណ ត្រូវលុបបាត់ទៅនៅសល់តែ យ ប៉ុណ្ណោះ ។ មានគតិដូច យ បច្ច័យក្នុងអាខ្យាតកិរិយាគឺត្រូវផ្សំ យ បច្ច័យជាមួយទីបំផុតធាតុដែលត្រូវផ្លាស់រូបទៅជាផ្សេង ៗ ។ ប៉ុន្តែ ណ្យ បច្ច័យក្នុងតទ្ធិតនេះកាលបើលុប ណ ទៅសល់នៅតែ យ ហើយយកទៅផ្សំជាមួយព្យញ្ជនៈទីបំផុតនៃស័ព្ទដើមដូចតទៅនេះ

១. ផ្លាស់ព្យញ្ជនៈទីបំផុតនៃស័ព្ទដើមនិង យ ទៅជារូបថ្មី ដូចឧទាហរណ៍ខាងក្រោមនេះ

(**បណ្ឌិត** + **ណ្យ**) > **បណ្ឌិច្ច** =*ភាវៈនៃបណ្ឌិត, ភាពជាបណ្ឌិត ។*

(**កុសល** + **ណ្យ**) > **កោសល្ល** =*ភាវៈនៃអ្នកឈ្លាស, ភាពជាអ្នកឈ្លាស ។*

(**សមណ** + **ណ្យ**) > **សាមញ្ញ** =*ភាវៈនៃសមណៈ, ភាពសាមញ្ញ ។*

(**សុហទ** + **ណ្យ**) > **សោហជ្ជ** =*ភាវៈនៃសំឡាញ់, ភាពជាសំឡាញ់ (ជនចិត្តល្អ) ។*

២. ផ្លាស់ យ ឱ្យដូចព្យញ្ជនៈទីបំផុតនៃស័ព្ទដើមហើយតម្រួតគ្នាដូចឧទាហរណ៍ខាងក្រោមនេះ

(ឧបមា + ណ្យ) > ឱបម្ម =ភាវៈនៃឧបមា, ភាពឧបមា ។

(បុរិស + ណ្យ) > ពោរិស្ស =ភាវៈនៃបុរស, ភាពជាប្រុស ។

(និបក + ណ្យ) > នេបក្ក =ភាវៈនៃអ្នកមានបញ្ញា, ភាពជាអ្នកមានបញ្ញា ។

៣. ទុក យ ឱ្យគង់រូបដូចឧទាហរណ៍ខាងក្រោមនេះ

(អរោគ + ណ្យ) > អរោគ្យ =ភាវៈនៃ(...)ឥតរោគ, ភាពគ្មានរោគ ។

(អាលស + ណ្យ) > អាលស្យ =ភាវៈនៃ(...)ខ្ជិល, ភាពខ្ជិល ។

(ឥណ + ណ្យ) > អាណ្យ =ភាវៈនៃបំណុល, ភាពជាបំណុល ។

(ទុស្សីល + ណ្យ) > ទុស្សីល្យ =ភាវៈនៃ(...)ទ្រុស្តសីល, ភាពទ្រុស្តសីល ។

វិធីតាំងវិគ្គហៈមានរបៀបដូចគ្នាដូចខាងក្រោមនេះ

បណ្ឌិតស្ស ភាវោ បណ្ឌិច្ចំ =ភាវៈនៃបណ្ឌិត ។

កុសលស្ស ភាវោ កោសល្លំ =ភាវៈនៃ(...)ឆ្លាត ។

សមណស្ស ភាវោ សាមញ្ញំ =ភាវៈនៃសមណ ។

សុហជស្ស ភាវោ សោហជ្ជំ =ភាវៈនៃសំឡាញ់ ។

បុរិសស្ស ភាវោ ពោរិស្សំ =ភាវៈនៃបុរស ។

ឧបមាយ ភាវោ ឱបម្មំ =ភាវៈនៃឧបមា ។

និបកស្ស ភាវោ នេបក្កំ =ភាវៈនៃអ្នកមានបញ្ញា ។

អរោគស្ស ភាវោ អរោគ្យំ =ភាវៈនៃ(...)ឥតរោគ ។

អាលសស្ស ភាវោ អាលស្សំ =*ការៈនៃ(...)ខ្ជិល ។*

ឥណស្ស ភាវោ អាណ្យំ =*ការៈនៃបំណុល (ឥ > អា)។*

ទុស្សីលស្ស ភាវោ ទុស្សីល្យំ =*ការៈនៃ(...)ទ្រុស្តសីល ។*

## ៥. ណ បច្ច័យ

(វិសម + ណ) > វេសម

*វិ.* វិសមស្ស ភាវោ វេសមំ =*ការៈនៃភាពមិនស្មើ, ភាពមិនស្មើ ។*

( សុចិ + ណ ) > សោច

*វិ.* សុចិនោ ភាវោ សោចំ =*ការៈនៃ(...)ស្អាត, ភាពស្អាត ។*

( មុទុ + ណ ) > មទ្ទវ

*វិ.* មុទុនោ ភាវោ មទ្ទវំ =*ការៈនៃ(...)ទន់, ភាពទន់ ។*

*(លុប ឧ នៃ មុ, ព្រឹទ្ធិ ឧ នៃ ទុ ជា ឱ > អវ ហើយតម្រួតជា ទ្ទ)*

## ៦. កណ បច្ច័យ

(រមណីយ + កណ) > រាមណីយក

*វិ.* រមណីយស្ស ភាវោ រាមណីយកំ =*ការៈនៃ(វត្ថុ)ដែលបុគ្គលគួររីករាយ ។*

(មនុញ្ញ + កណ) > មានុញ្ញក

*វិ.* មនុញ្ញស្ស ភាវោ មានុញ្ញកំ =*ការៈនៃ(វត្ថុ)ជាទីគាប់ចិត្ត ។*

# បច្ច័យពិសេស

*ក្រៅពីបច្ច័យខាងលើនេះ នៅមានបច្ច័យ ៣ តួទៀតគឺ* **ណិយ**, **ណេយ្យ**, **ឮ** *ប្រើជំនួស* **ភាវ** *ស័ព្ទដែរ ដែលសង្គ្រោះចូលក្នុងភាវតទ្ធិត នេះ ដូចមានឧទាហរណ៍ខាងក្រោមនេះ*

## ១. ណិយ បច្ច័យ

(វីរ + ណិយ) > វីរិយ

វិ. វីរស្ស ភាវោ វីរិយំ =*ភាវៈនៃសេចក្ដីក្លាហាន, ភាពក្លាហាន ។*

(អលស + ណិយ) > អាលសិយ

វិ. អលសស្ស ភាវោ អាលសិយំ =*ភាវៈនៃ(...)ខ្ជិល, ភាពខ្ជិល ។*

(បុរោហិត + ណិយ) > បុរោហិតិយ

វិ. បុរោហិតស្ស ភាវោ បុរោហិតិយំ =*ភាវៈនៃបុរោហិត, ភាពជាបុរោហិត ។*

## ២. ណេយ្យ បច្ច័យ

(សុចិ + ណេយ្យ) > សោចេយ្យ

វិ. សុចិនោ ភាវោ សោចេយ្យំ =*ភាវៈនៃ(វត្ថុ)ស្អាត, ភាពស្អាត ។*

(អធិបតិ + ណេយ្យ) > អាធិបតេយ្យ

វិ. អធិបតិនោ ភាវោ អាធិបតេយ្យំ =*ភាវៈនៃបុគ្គលជាអធិបតី, ភាពជាអធិបតី ។*

## ៣. ព្យ បច្ច័យ

(ទាស + ព្យ) > ទាសព្យ

*វិ.* ទាសស្ស ភាវោ ទាសព្យំ =*ភាវៈនៃអ្នកបម្រើ, ភាពជាអ្នកបម្រើ ។*

## កំណត់សម្គាល់

*១. បទតទ្ធិតសម្រេចពីភាវតទ្ធិតនេះជានាមនាម* **អ** *ការន្តនបុំសក-លិង្គតែម្យ៉ាង បំបែកដូច* **កុល** *គ្រប់វិភត្តិ ។ វៀរតែ* **តា** *បច្ច័យដែលជា* **អា** *ការន្តឥត្ថីលិង្គបំបែកដូច* **កញ្ញា** *។*

*២.* **កណ, ណ, តា** *បច្ច័យមានប្រើក្នុងតទ្ធិតជាច្រើន ហើយដែលអាចមើលឃើញយ៉ាងច្បាស់គឺក្នុង សមុហតទ្ធិត និង ភាវតទ្ធិត ។ ដូច្នេះស័ព្ទដែលប្រកបពីបច្ច័យទាំងនេះនឹងអាចប្រែបានពីរតទ្ធិត ឱ.*

**សហាយតា** *បើប្រែថា "ភាវៈនៃសំឡាញ់" គឺជា ភាវតទ្ធិត ។ បើប្រែថា "ប្រជុំឬពួកនៃសំឡាញ់" គឺជា សមូហតទ្ធិត ជាតទ្ធិតរូមតទ្ធិត ។*

**នាគរតា** *បើប្រែថា "ប្រជុំនៃជនដែលកើតក្នុងនគរ" គឺជាសមូហ-តទ្ធិត ដែលមានរាគាទិតទ្ធិតចូលជាមួយ ។ បើប្រែថា "ភាវៈនៃជនដែលកើតហើយក្នុងនគរ" គឺជាភាវតទ្ធិតដែលមានរាគាទិតទ្ធិតចូលជាមួយដែរ ។ ព្រោះហេតុនេះក្នុងមួយស័ព្ទអាចតាំងវិគ្គហៈបានដល់ទៅបីតទ្ធិតដូចខាងក្រោមនេះ*

**ឆគវេ ជាតោ ជាតវេ (ជជោ)** ។ ចុះ **ណា** បច្ច័យប្រើជំនួស **ជាត** *ស័ព្ទ នេះជា រាគាទិតទ្ធិត ។*

**ជាតរាជំ សម្ពូហោ ជាតវតា** ។ *នេះជា សមូហតទ្ធិត ។*

**ជាតស្ស ភាវោ ជាតវតា** ។ *នេះជា ភាវតទ្ធិត ។*

*ស័ព្ទឯទៀត ៗ គប្បីជ្រាបតាមសេចក្ដីដូចគ្នានេះផងចុះ ។*

*៣.* **ណា** *បច្ច័យមានប្រើក្នុងតទ្ធិតជាច្រើន ។ ក្នុងទីនេះនឹងធ្វើការប្រៀបធៀបដើម្បីឱ្យឃើញភាពផ្សេងគ្នាដូចខាងក្រោមនេះ*

*៣.១* **ណា** *បច្ច័យបើចុះក្នុងគោត្តតទ្ធិតប្រើជំនួស* **អបច្ច** *ប្រែថា "ត្រកូល" ដូចជា* **សាមណេរ** *=ត្រកូលនៃសមណៈ ។*

*៣.២* **ណា** *បច្ច័យបើចុះក្នុងរាគាទិតទ្ធិតប្រើជំនួសស័ព្ទបានទូទៅ ដូចជា* **មាគធ** *=ជាធំក្នុងដែនមគធៈ, ប្រើជំនួស* **ឥស្សរ** *។ បើប្រែថា "កើតហើយក្នុងដែនមគធៈ" គឺប្រើជំនួស* **ជាត** *ស័ព្ទ ។*

*៣.៣* **ណា** *បច្ច័យបើចុះក្នុងសមូហតទ្ធិតប្រែថា "ប្រជុំឬពួក" ដូចជា* **មាយូរ** *=ហ្វូងនៃក្ងោក ។*

*៣.៤* **ណា** *បច្ច័យបើចុះក្នុងតទស្សត្ថិតទ្ធិតឬអត្ថិតទ្ធិតប្រើជំនួស* **អត្ថិ** *ស័ព្ទប្រែថា "មាន" ដូចជា* **សទ្ធោ** *=មានសទ្ធា ។*

*៣.៥* **ណា** *បច្ច័យបើចុះក្នុងភាវតទ្ធិតប្រើជំនួស* **ភាវ** *ស័ព្ទប្រែថា "ភាវៈ" ដូចជា* **វេសម** *=ភាពមិនស្មើ ។*

*៤.* **ណិក** *បច្ច័យក៏មានចុះក្នុងតទ្ធិតជាច្រើនគឺ*

៤.១ **ណិក** បច្ច័យបើចុះក្នុងគោត្តតទ្ធិតប្រើជំនួស **អបច្ច** ប្រែថា "ត្រកូល" ដូចជា **នាដបុត្តិក** =ត្រកូលនៃនាដបុត្រ (ត្រកូលអ្នករបាំ) ។

៤.២ **ណិក** បច្ច័យបើចុះក្នុងតរត្យាទិតទ្ធិតប្រើជំនួសស័ព្ទទូទៅ ដូចជា **នាវិក** =ឆ្លងដោយទូក (ជំនួស **តរតិ**)., **សាកដិក** =ដើរដោយរទេះ (ជំនួស **ចរតិ**)., **កោសលិក** =ជាធំក្នុងដែនកោសល (ជំនួស **ឥស្សរ**)., **កាយិក** =កម្មដែលជនធ្វើដោយកាយ (ជំនួស **កត**) ។

៤.៣ **ណិក** បច្ច័យបើចុះក្នុងតទស្សត្ថិតទ្ធិតប្រើជំនួស **អត្ថិ** ប្រែថា "មាន" ដូចជា **ឧណ្ឌិក** =មានឈើច្រត់ ។

៥. **កណ** បច្ច័យកាលបើលុប **ណ** ទៅនៅសល់តែ **ក** មានប្រើក្នុងតទ្ធិតជាច្រើនដូចតទៅនេះ

៥.១ **កណ** បច្ច័យបើចុះក្នុងសមូហតទ្ធិតប្រើជំនួស **សមូហ** ស័ព្ទ ប្រែថា "ប្រជុំ, ពួក" ដូចជា **មានុស្សក** =ប្រជុំនៃមនុស្ស ។

៥.២. **កណ** បច្ច័យបើចុះក្នុងភាវតទ្ធិតប្រើជំនួស **ភាវ** ស័ព្ទប្រែថា "ភាវៈ" ដូចជា **រាមណីយក** =ភាវនៃវត្ថុដែលបុគ្គលគួរត្រេកអរ ។

៥.៣ **កណ** បច្ច័យបើចុះក្នុងសំខ្យាតទ្ធិតប្រើជំនួស **បរិមាណ** ប្រែថា "មានប្រមាណ" ជាគ្រឿងសម្រាប់រាប់ដូចជា **ទ្វិក** =មានប្រមាណពីរ, ពួកពីរ, **តិក** =មានប្រមាណបី, ពួកបី ជាដើម ។

**(ភាវតទ្ធិតចប់ត្រឹមនេះ)**

## ៣. អព្យយតទ្ធិត

*តទ្ធិតនេះមានបច្ច័យ ៣ តួគឺ* **ថា, ថំ, ថត្តា** *ឬ* **ថត្តា** *និយមចុះខាងចុងវិសេសនសព្វនាម ជាពិសេស* **ថា** *បច្ច័យចុះចុង* **យ, ត,** *រីឯ* **ថំ** *ចុះចុង* **កឹ** *និង* **ឥម** *ប្រើជំនួសស័ព្ទថា* **បការ** *ប្រែថា "ប្រការ" ។*

*តាមសេចក្ដីពិតនោះគឺនិបាតប្រាប់ប្រការហ្នឹងឯង ដូចជា* **យថា** *=ប្រការណា,* **តថា** *=ប្រការនោះ,* **កថំ** *=ប្រការអ្វី,* **ឥត្ថំ** *=ប្រការនេះ ជាដើម ដែលនិយមប្រើក្នុងប្រយោគឧបមេយ្យដោយច្រើន ជាអព្យយស័ព្ទពុំចាំបាច់បំបែកទេ គឺត្រូវទុកឱ្យគង់រូបដើមជាយ៉ាងនោះ ៗ ទើបហៅថា* **អព្យយស័ព្ទ** *ឬ* **អព្យយតទ្ធិត** *។ ចំណែកឯការតាំងវិគ្គហៈមានរបៀបដូច្នេះ*

## វិធីតាំងវិគ្គហៈនៃអព្យយតទ្ធិត

*១. បទដើមប្រើវិសេសនសព្វនាម* **យ, ត, កឹ, ឥម** *ដែលត្រូវបំបែកជាឯកវចនៈក្នុងរូបវិភត្តិទាំង ៧ តាំងពីបឋមាវិភត្តិដល់សត្តមីវិភត្តិ (មិនមានជាអាលបនវិភត្តិទេ) តាមវិគ្គហៈនោះ ៗ ។*

*២. បទចុងប្រើ* **បការ** *ដែលត្រូវបំបែកឱ្យមានវិភត្តិស្មើគ្នានឹងបទដើម ។*

*៣. បទតទ្ធិតត្រូវចុះបច្ច័យណាមួយ លុះវេលាប្រែត្រូវប្រើអាយតនិបាតនៃវិភត្តិនោះ ៗ ។*

## ថា បច្ច័យចុះខាងចុង យ ស័ព្ទ

ប.វិ. យោ បការោ យថា =វីប្រការណា ។

ទុ.វិ. យំ បការំ យថា =នូវប្រការណា ។

ត.វិ. យេន បការេន យថា =ដោយប្រការណា ។

ច.វិ. យស្ស បការស្ស យថា =ដល់ប្រការណា ។

បញ្ច.វិ. យស្មា បការស្មា យថា =អំពីប្រការណា ។

ឆ.វិ. យស្ស បការស្ស យថា =នៃប្រការណា ។

ស.វិ. យស្មឹ បការេ យថា =ក្នុងប្រការណា ។

## ថា បច្ច័យចុះខាងចុង ត ស័ព្ទ

ប.វិ. សោ បការោ តថា =វីប្រការនោះ ។

ទុ.វិ. តំ បការំ តថា =នូវប្រការនោះ ។

ត.វិ. តេន បការេន តថា =ដោយប្រការនោះ ។

ច.វិ. តស្ស បការស្ស តថា =ដល់ប្រការនោះ ។

បញ្ច.វិ. តស្មា បការស្មា តថា =អំពីប្រការនោះ ។

ឆ.វិ. តស្ស បការស្ស តថា =នៃប្រការនោះ ។

ស.វិ. តស្មឹ បការេ តថា =ក្នុងប្រការនោះ ។

ចំពោះ ថំ បច្ច័យមានរូបវិគ្គហៈដូច ថា បច្ច័យដែរ ។ ប៉ុន្តែ គឺ

ស័ព្ទត្រូវផ្លាស់ **កឹ** > **ក** សិនរួចទើបបំបែកដូច **យ** ស័ព្ទនៅខាងលើ ។ រីឯ **ឥម** ស័ព្ទត្រូវលុប **ម** ចេញហើយតម្រួត **ត** ទៅជា **ឥត្ថំ** ជានិច្ច ។ ក្នុងរូបវិគ្គហៈត្រូវបំបែក **ឥម** ស័ព្ទជាឯកវចនៈតាមបែប **ឥម** ស័ព្ទរៀងខាងដើម **បការ** ដូចខាងក្រោមនេះ

## ថំ បច្ច័យចុះខាងចុង កឹ ស័ព្ទ

ប.វិ. **កោ បការោ កថំ** =វីប្រការដូចម្ដេច ។

ទុ.វិ. **កំ បការំ កថំ** =នូវប្រការដូចម្ដេច ។

ត.វិ. **កេន បការេន កថំ** =ដោយប្រការដូចម្ដេច ។

ច.វិ. **កស្ស បការស្ស កថំ** =ដល់ប្រការដូចម្ដេច ។

បញ្ច.វិ. **កស្មា បការស្មា កថំ** =អំពីប្រការដូចម្ដេច ។

ឆ.វិ. **កស្ស បការស្ស កថំ** =នៃប្រការដូចម្ដេច ។

ស.វិ. **កស្មិំ បការេ កថំ** =ក្នុងប្រការដូចម្ដេច ។

## ថំ បច្ច័យចុះខាងចុង ឥម ស័ព្ទ

ប.វិ. **អយំ បការោ ឥត្ថំ** =វីប្រការនេះ ។

ទុ.វិ. **ឥមំ បការំ ឥត្ថំ** =នូវប្រការនេះ ។

ត.វិ. **ឥមិនា បការេន ឥត្ថំ** =ដោយប្រការនេះ ។

ច.វិ. ឥមស្ស បការស្ស ឥត្ថំ =ដល់ប្រការនេះ ។

បញ្ច.វិ. ឥមស្មា បការស្មា ឥត្ថំ =អំពីប្រការនេះ ។

ឆ.វិ. ឥមស្ស បការស្ស ឥត្ថំ =នៃប្រការនេះ ។

ស.វិ. អស្មឹ បការេ ឥត្ថំ =ក្នុងប្រការនេះ ។

## ថត្តា បច្ច័យចុះខាងចុងសព្វនាមទូទៅ

ប.វិ. យោ បការោ យថត្តា =វិប្រការណា ។

ប.វិ. សោ បការោ តថត្តា =វិប្រការនោះ ។

ប.វិ. អញ្ញោ បការោ អញ្ញថត្តា =វិប្រការដទៃ ។

ប.វិ. សព្វោ បការោ សព្វថត្តា =វិប្រការទាំងពួង ។

ប.វិ. ឥតរោ បការោ ឥតរថត្តា =វិប្រការក្រៅនេះ ។

។បេ។

## កំណត់សម្គាល់

សព្ទវិសេសនសព្វនាមឯទៀត ៗ ក៏អាចចុះ **ថា** បច្ច័យបានដែរ ដូចជា **សព្វថា** =វិប្រការទាំងពួង, **អញ្ញថា** =វិប្រការដ៏ទៃ, **ឥតរថា** =វិប្រការក្រៅនេះ ។

ចំពោះ **ថត្តា** បច្ច័យក្នុងគម្ពីរផ្សេង ៗ និយាយមិនត្រូវគ្នា ខ្លះថា **ថត្តា** ខ្លះថា **ថត្តា** ។

# សរុបចំណុចគួរចងចាំ

*១. តទ្ធិតដោយសង្ខេបមានបីយ៉ាងគឺ ១. សាមញ្ញតទ្ធិត, ២. ភាវតទ្ធិត, ៣. អព្យយតទ្ធិត ។*

*២. សាមញ្ញតទ្ធិតដោយពិស្ដារមាន ១៥ គឺ*

| | | |
|---|---|---|
| ១. គោត្តតទ្ធិត | ៦. ឋានតទ្ធិត | ១១. សំខ្យាតទ្ធិត |
| ២. តរត្យាទិតទ្ធិត | ៧. ពហុលតទ្ធិត | ១២. បូរណតទ្ធិត |
| ៣. រាគាទិតទ្ធិត | ៨. សេដ្ឋតទ្ធិត | ១៣. វិភាគតទ្ធិត |
| ៤. ជាតាទិតទ្ធិត | ៩. បកតិតទ្ធិត | ១៤. ឧបមាតទ្ធិត |
| ៥. សមូហតទ្ធិត | ១០. តទស្សត្ថិតទ្ធិត | ១៥. និស្សិតតទ្ធិត |

*៣. បច្ច័យនៃតទ្ធិតនីមួយ ៗ គួរចាំឱ្យបានព្រមជាមួយវិធីប្រកបរូបស័ព្ទផង ដូចខាងក្រោមនេះ*

*៣.១.* គោត្តតទ្ធិត *មានបច្ច័យ ៨ តួគឺ* ណ, ណាយន, ណាន, ណេយ្យ, ណិ, ណិក, ណវ, ណេរ ។

*៣.២.* តរត្យាទិតទ្ធិត *មានបច្ច័យ ១ តួគឺ* ណិក ។

*៣.៣.* រាគាទិតទ្ធិត *មានបច្ច័យ ១ តួគឺ* ណ ។

*៣.៤.* ជាតាទិតទ្ធិត *មានបច្ច័យ ៣ តួគឺ* ឥម, ឥយ, កិយ ។

*៣.៥.* សមូហតទ្ធិត *មានបច្ច័យ ៣ តួគឺ* កណ, ណ, តា ។

*៣.៦.* ឋានតទ្ធិត *មានបច្ច័យ ២ តួគឺ* ឦយ, ឯយ្យ ។

៣.៧. **ពហុលតទ្ធិត** មានបច្ច័យ ១ តួគឺ **អាលុ** ។

៣.៨. **សេដ្ឋតទ្ធិត** មានបច្ច័យ ៥ តួគឺ **តរ, តម, ឥយិស្សក, ឥយ, ឥដ្ឋ** ។

៣.៩. **បកតិតទ្ធិត** មានបច្ច័យ ១ តួគឺ **មយ** ។

៣.១០. **តទស្សត្ថិតទ្ធិត** មាន ៩ តួគឺ **វី, ស, សី, ឦ, រ, វន្តុ, មន្តុ, ណ** ។

៣.១១. **សំខ្យាតទ្ធិត** មានបច្ច័យ ១ តួគឺ **ក** ។

៣.១២. **បូរណតទ្ធិត** មានបច្ច័យ ៥ តួគឺ **តិយ, ថ, ឋ, ម, ឦ** ។

៣.១៣. **វិភាគតទ្ធិត** មានបច្ច័យ ២ តួគឺ **ធា, សោ** ។

៣.១៤. **ឧបមាតទ្ធិត** មានបច្ច័យ ១ តួគឺ **អាយិត្ត** ។

៣.១៥. **និស្សិតតទ្ធិត** មានបច្ច័យ ១ តួគឺ **ល** ។

៣.១៦. **ភាវតទ្ធិត** មានបច្ច័យ ៦ តួគឺ **ត្ត, ណ្យ, ត្តន, តា, ណ, កណ** ។

៣.១៧. **អព្យយតទ្ធិត** មានបច្ច័យ ៣ តួគឺ **ថា, ថំ, ថត្តា** (ឬ **ថត្តា**) ។

៣.១៨. បច្ច័យពិសេសដែលប្រើក្នុងភាវតទ្ធិតមាន ៣ តួគឺ **ណិយ, ណេយ្យ, ព្យ** ។

៤. បច្ច័យមានរូបដូចគ្នា ប៉ុន្តែប្រើក្នុងតទ្ធិតផ្សេង ៗ គ្នាមានដូចខាងក្រោមនេះ

៤.១. **ណ** បច្ច័យចុះក្នុងតទ្ធិត ៥ គឺ **គោត្តតទ្ធិត, រាគាទិតទ្ធិត, សមូហតទ្ធិត, តទស្សត្ថិតទ្ធិត, ភាវតទ្ធិត** ។

៤.២. **ណិក** បច្ច័យចុះក្នុងតទ្ធិត ២ គឺ **គោត្តតទ្ធិត, តរត្យាទិ-តទ្ធិត** ។

៤.៣. **ឥយ** បច្ច័យចុះក្នុងតទ្ធិត ២ គឺ **ជាតាទិតទ្ធិត** និង **សេដ្ឋ-តទ្ធិត** ។

៤.៤. **កណ** បច្ច័យចុះក្នុងតទ្ធិត ២ គឺ **សមូហតទ្ធិត** និង **ភាវ-តទ្ធិត** ។

៤.៥. **តា** បច្ច័យចុះក្នុងតទ្ធិត ២ គឺ **សមូហតទ្ធិត**និង**ភាវតទ្ធិត** ។

៤.៦. **ល** បច្ច័យចុះក្នុងតទ្ធិត ២ គឺ **តទស្សត្ថិតទ្ធិត** និង **បូរណ-តទ្ធិត** ។

៥. បច្ច័យដែលប្រហាក់ប្រហែលគ្នាក្នុងតទ្ធិតផ្សេង ៗ ដូច្នេះ

៥.១. **កណ** = **ក** ចុះក្នុងតទ្ធិត ៣ គឺ **សមូហតទ្ធិត, ភាវតទ្ធិត** និង **សំខ្យាតទ្ធិត** ។

៥.២. **ណិក** = **ឥក** ចុះក្នុង ៣ តទ្ធិតគឺ **គោត្តតទ្ធិត, តរត្យាទិ-តទ្ធិត** និង **តទស្សត្ថិតទ្ធិត** ។

៥.៣. **ណិយ** = **ឥយ** ចុះក្នុងតទ្ធិត ៣ គឺ **ភាវតទ្ធិត** (បច្ច័យពិសេស) និង **ជាតាទិតទ្ធិត** និង **សេដ្ឋតទ្ធិត** ។

៥.៤. **ណេយ្យ** = **ឯយ្យ** ចុះក្នុង តទ្ធិត ៣ គឺ **គោត្តតទ្ធិត, ឋាន-**

**តទ្ធិត** និង **ភាវតទ្ធិត** (*បច្ច័យពិសេស*) ។

*៦. តទ្ធិតនាមនាមមាន ៣ គឺ* **គោត្តតទ្ធិត, សមុហតទ្ធិត, ភាវ-តទ្ធិត**, *ក្រៅពីនេះជាតទ្ធិតគុណនាមទាំងអស់ ។*

*៧. ស័ព្ទសម្រេចពីបច្ច័យក្នុងតទ្ធិតទាំងអស់ដែលពោលរួចហើយនោះ ខ្លះជាតទ្ធិតនាមអាចប្រើជារបៀបនាមនាម ។ ប្រសិនបើជាគុណ-នាមអាចប្រើជារបៀបគុណនាម ប្រើអធិប្បាយនាមនាមនិងប្រើជាវិកតិ-កត្តាក៏បាន ។ ប៉ុន្តែកន្លែងខ្លះប្រើតែស័ព្ទគុណនាមដែលជាស័ព្ទសម្រេចមកពីតទ្ធិតគុណនាមប៉ុណ្ណោះ ពុំចាំបាច់មាននាមនាមនៅក្នុងប្រយោគនោះ ៗ ផងក៏បានដែរ ដូចទាហរណ៍ខាងក្រោមនេះ*

## ប្រយោគឧទាហរណ៍

**១. ឱឃោ យំ ទីបំ ន អភិកិរតិ, <u>មេធាវី</u> តំ ករេយ្យ ។**

*អន្លង់ទឹក រមែងមិនជន់លិច នូវកោះ(ទីពឹង) ណា, <u>អ្នកមានបញ្ញា</u> គប្បីធ្វើ នូវកោះ នោះ ។*

**២. យស្ស <u>ចាបិច្ឆតា</u> អត្ថិ, ចាបកម្មំ កាតុំ សក្កោតិ ។**

*<u>សេចក្តីប្រាថ្នាដ៏លាមក</u> មាន ចំពោះ(បុគ្គល)ណា, (បុគ្គលនោះ) រមែងអាច ដើម្បីធ្វើ នូវកម្ម ដែលលាមក(អាក្រក់) ។*

**(តទ្ធិតចប់ត្រឹមនេះ)**

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | | ពាក្យប្រែ |
|---|---|---|
| វិបត្តិ | ឥ. | សេចក្ដីវិនាស |
| អត្តវិបត្តិ | ឥ. | សេចក្ដីវិនាសនៃខ្លួន |
| បរវិបត្តិ | ឥ. | សេចក្ដីវិនាសនៃអ្នកដទៃ |
| បច្ចវេក្ខិត | គុ. | ដែលពិចារណា |
| អត្តសម្បត្តិ | ឥ. | សម្បត្តិនៃខ្លួន |
| បរសម្បត្តិ | ឥ. | សម្បត្តិនៃអ្នកដទៃ |
| អសទ្ធម្ម | បុំ. | ធម៌នៃអសប្បុរស |
| បរិយាទិន្ន | គុ. | ដែលគ្របសង្កត់ហើយ |
| បរិយាទិន្នចិត្ត | នបុំ. | ចិត្តគ្របសង្កត់ហើយ |
| អតេកិច្ឆ | គុ. | កែខៃមិនបាន |
| បាបិច្ឆតា | ឥ. | ភាវៈនៃអ្នកប្រាថ្នាដ៏លាមក |
| បាបមិត្តតា | ឥ. | ភាវៈនៃមិត្តអាក្រក់ |
| អបាយ | បុំ. | អបាយ |
| អាបាយិក | គុ. | អ្នកកើតក្នុងអបាយ |
| នេរយិក | គុ. | អ្នកកើតក្នុងនរក |

| សព្ទបាលី | | ពាក្យប្រែ |
|---|---|---|
| កប្ប | បុំ. | កាលដែលតាំងនៅយូរអង្វែង |
| កប្បដ្ឋ | បុំ. | ដែលតាំងនៅអស់កប្ប |
| លាភ | បុំ. | លាភ |
| យស | បុំ. | យស |
| សក្ការ | បុំ. | គ្រឿងសក្ការៈ |
| ចតុព្វិធ | គុ. | មាន ៤ យ៉ាង |
| កាមាវចរ | គុ. | ដែលត្រាច់ទៅក្នុងកាមភព |
| រូបាវចរ | គុ. | ដែលត្រាច់ទៅក្នុងរូបភព |
| អរូបាវចរ | គុ. | ដែលត្រាច់ទៅក្នុងអរូបភព |
| លោកុត្តរ | គុ. | ដែលឆ្លងឡើងចាកលោក |
| ទេវទត្ត | អ.ន. | ភិក្ខុទេវទត្ត |
| ភវ | បុំ. | សេចក្តីចម្រើន |
| អន្តោទេវតា | ឥ. | ទេវតាខាងក្នុង |
| សសុរ | បុំ. | ឪពុកក្មេក |
| សស្សុ | ឥ. | ម៉ែក្មេក |
| សុណិសា | ឥ. | កូនប្រសារស្រី |
| បូជនេយ្យ | គុ. | អ្នកគួរនូវការបូជា |

# លំហាត់នៃមេរៀនទី ៤២

## *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើការិតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

*២. តើបច្ច័យក្នុងការិតទ្ធិតទាំងនេះប្រើជំនួសស័ព្ទអ្វី ?*

*៣. តើបច្ច័យពិសេសក្នុងការិតទ្ធិតមានប៉ុន្មានតួ គឺអ្វីខ្លះ ?*

*៤. តើអព្យយតទ្ធិតមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?*

*៥. តើបច្ច័យក្នុងអព្យយតទ្ធិតនីមួយ ៗ សម្រាប់ចុះខាងចុងស័ព្ទជំពូកណា ?*

*៦. តើបច្ច័យក្នុងអព្យយតទ្ធិតនីមួយ ៗ ប្រើជំនួសស័ព្ទអ្វី ?*

*៧. តើ* **ធា** *បច្ច័យមានប្រើក្នុងតទ្ធិតអ្វីខ្លះ ?*

*៨. តើ* **ធិក** *បច្ច័យមានប្រើក្នុងតទ្ធិតអ្វីខ្លះ ?*

*៩. តើ* **កធា** *បច្ច័យវេលាចុះចុងស័ព្ទនោះ ៗ ត្រូវធ្វើដូចម្ដេច ?*

*១០.* **កឹ** *ស័ព្ទវេលាចុះបច្ច័យមកតើត្រូវធ្វើដូចម្ដេចសិន ?*

## *ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អត្តវិបត្តឹ បច្ចវេក្ខិតា ហោតិ ។ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បរវិបត្តឹ បច្ចវេក្ខិតា ហោតិ ។ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អត្តសម្បត្តឹ បច្ច-វេក្ខិតា ហោតិ ។ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បរសម្បត្តឹ

បច្ចវេក្ខិតា ហោតិ ។

២. អជ្ជហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវ-ទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ កតមេហិ អដ្ឋហិ លាភេន ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ អតេកិច្ឆោ អលាភេន ភិក្ខវេ យសេន ភិក្ខវេ អយសេន ភិក្ខវេ សក្ការេន ភិក្ខវេ អសក្ការេន ភិក្ខវេ បាបិច្ឆតាយ ភិក្ខវេ បាបមិត្តតាយ ភិក្ខវេ អភិភូតោ បរិយាទិន្ន-ចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្ន-ចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។

៣. តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ទេវតា.ទ. ច្យុតហើយ ចាកទេវលោក ព្រោះកិរិយាអស់ទៅ នូវបុណ្យ ខ្លះ តែងចូលដល់ នូវភាវៈជាមនុស្ស ខ្លះ តែងទៅ កាន់សុគតិ ។*

*២. មនុស្ស ខ្លះ ស្លាប់ហើយ រមែងចូលដល់ នូវគ៌ភ នៃមនុស្ស ខ្លះ ជាអ្នក មានកម្មអាក្រក់ រមែងចូលដល់ នូវនរក ។ រីអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។*

*៣. ជន.ទ. នេះ គឺឪពុក ម្តាយ គ្រូឧបជ្ឈាយ៍ និង អាចារ្យ ជាអ្នកគួរ-*

នូវការបូជា ។

៤. ជន ណា អាច ដើម្បីបូជា នូវអ្នកគួរនូវការបូជា សេចក្ដីចម្រើន នឹងមាន ដល់ជននោះ ។

៥. ទេវតាខាងក្នុង គឺឪពុកក្មេក និង ម៉ែក្មេក ជាអ្នកដែលកូនប្រសារស្រី គប្បីសំពះ និង បូជា ។

៦. កូនប្រសារស្រី ណា អាច ដើម្បីធ្វើ យ៉ាងនេះ សេចក្ដីចម្រើន នឹងមាន ដល់កូនប្រសារស្រី នោះ ។

**បរិ** + **និ** + **វាន** =បរិនិព្វាន, រលត់ជុំវិញ ។

**(ចប់មេរៀនទី ៤២)**

# មេរៀនទី ៤៣

# អធិប្បាយអំពីសញ្ញាវិធាន

*ក្នុងមេរៀនទី ១ នៃភាគ ១ បានអធិប្បាយអំពីអក្ខរៈខ្លះហើយ ។ វេលានេះនឹងអធិប្បាយសាថ្មីថែមទៀត ដើម្បីឱ្យអ្នកសិក្សាជ្រាបកាន់តែច្បាស់ ។*

## សញ្ញាវិធាន

*ពាក្យថា* **សញ្ញាវិធាន** *មកពីពាក្យថា* (**សញ្ញា** + **វិធាន**) *។ បទថា* **សញ្ញា** *ក្នុងទីនេះប្រែថា "ឈ្មោះ" និងបទថា* **វិធាន** *ប្រែថា "ការសាង, ការតាក់តែង, ការធ្វើ" បានដល់ ការធ្វើឬការសំដែងអំពីឈ្មោះរបស់តួអក្សរនិងឋានដែលអក្សរនោះ ៗ កើត រហូតដល់ការបញ្ចេញសំឡេង និងឈ្មោះខាងវេយ្យាករណ៍ ។*

## សារៈសំខាន់របស់អក្ខរៈ

*សារៈសំខាន់របស់ពាក្យថា* **អក្ខរ** *បើយកតាមសូត្រ (ទី ១) ដំបូងបំផុតនៃគម្ពីរកច្ចាយនៈតាំងថា* **អត្ថោ អក្ខរសញ្ញាតោ** *ប្រែថា សេចក្តីឬ(អត្ថ)ដឹងបានដោយអក្សរ ។ ក្នុងន័យថា បុគ្គលទាំងឡាយដឹងអត្ថន័យ*

ឬសេចក្ដីរបស់ពាក្យទាំងពួងបានដោយសារអក្សរ ប្រសិនបើអក្សរមានវិបត្តិ គឺសរសេរឬចារខុសតួអក្សរ នោះបុគ្គលមិនអាចដឹងអត្ថន័យបានទេ (អាចយល់ច្រឡំន័យផងក៏មាន) និងការឈ្លាសវៃក្នុងរឿងអក្សរមានគុណប្រយោជន៍ធំធេងណាស់ ដល់ការសិក្សានិងការយល់ដឹងនូវពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។

## ចំនួននៃអក្ខរៈ

អក្ខរៈឬអក្សរដែលមានសម្រាប់ប្រើប្រាស់ក្នុងភាសាបាលីមាន ៤១ តួឬអង្គ និងចែកជាពីរចំណែកគឺ សរៈឬស្រៈ ៨ តួ, ព្យញ្ជនៈ ៣៣ តួ ។

ស្រៈទាំង ៨ តួគឺ **អ អា ឥ ឦ ឧ ឩ ឯ ឱ** ។

ព្យញ្ជនៈទាំង ៣៣ តួគឺ **ក ខ គ ឃ ង, ច ឆ ជ ឈ ញ, ដ ឋ ឌ ឍ ណ, ត ថ ទ ធ ន, ប ផ ព ភ ម, យ រ ល វ ស ហ ឡ ំ** ។

<u>បញ្ជាក់</u> ក្នុង **គម្ពីរមោគ្គល្លានព្យាករណៈ** ប្រាប់ថាអក្ខរៈទាំងអស់មាន ៤៣ តួដោយថែមស្រៈ ២ តួទៀតគឺស្រៈ **ឯ** ខ្លីនិងស្រៈ **ឱ** ខ្លី ។ ក្នុងការសរសេរជាតួអក្សរខ្មែរយើងមិនមានរូបអក្សរបែបនេះទេ ។ ប៉ុន្តែស្រៈ ២ តួនេះមានសំឡេងស្មើនឹង **ឯ** ក្នុងពាក្យថា **មេត្តា**, **ឱ** ក្នុងពាក្យថា **ឱដ្ឋ** ឬថាស្មើនឹងស្រៈ **ឯត** (អេត)និងស្រៈ **ឱត** (អោត) តែម្ដងក៏បាន ។

រីឯព្យញ្ជនៈវិញ គម្ពីរជាភាសាអង់គ្លេសខ្លះប្រាប់ថាមាន ៣៤ តួគឺ

ថែម ឡ្ហ នេះមួយទៀត ។

## អត្ថន័យរបស់អក្ខរៈ

ពាក្យថាអក្ខរៈមានន័យពីរយ៉ាងគឺទី ១ "មិនអស់" ទី ២ "មិនរឹង" ។ ក្នុងសេចក្ដីថា អក្សររបស់ភាសាបាលីសូម្បីមានត្រឹមតែ ៤១ តួក៏ដោយក៏សរសេរកត់ត្រាព្រះពុទ្ធវចនៈមិនចេះអស់ និង មិនរឹង គឺអាចប្រើក្នុងការស្វែងយល់នូវអត្ថដ៏ល្អិតសុខុមបានយ៉ាងងាយ ។

## លក្ខណៈរបស់ស្រៈ

ស្រៈទាំង ៨ តួនោះមានសំឡេង ២ យ៉ាងគឺ សំឡេងខ្លី និង សំឡេងវែង ។

ស្រៈ ៣ តួគឺ **អ ឥ ឧ** ជាស្រៈមានសំឡេងខ្លី ហៅថា ស្រៈរស្សៈ ។ លោកឱ្យឈ្មោះថា **រស្សៈ** ពីព្រោះស្រៈបីតួនេះមានការបញ្ចេញសំឡេងក្នុងរយៈពេលខ្លី គឺប្រៀបស្មើនឹងការផ្ទាត់ម្រាមដៃម្ដងឬការព្រិចភ្នែកម្ដង និងអាចរាប់ថាមាន ១ មាត្រា ។

ស្រៈ ៥ តួគឺ **អា ឦ ឩ ឯ ឱ** ជាស្រៈមានសំឡេងវែង ហៅថា ស្រៈទីឃៈ ពីព្រោះស្រៈប្រាំតួនេះមានការបញ្ចេញសំឡេងក្នុងរយៈពេលវែង

គឺប្រៀបស្មើនឹងការផ្ទាត់ម្រាមដៃពីរដង ឬការព្រិចភ្នែកពីរដង និងអាចរាប់ថាមាន ២ មាត្រា ។

ប្រសិនបើចែកបន្តទៀត គឺ ស្រៈសុទ្ធ, ស្រៈអសុទ្ធ, ស្រៈសំយុត្ត ។

ស្រៈសុទ្ធ បានដល់ ស្រៈដែលប្រើបានតែជាស្រៈគឺស្រៈ **អ អា** ។

ស្រៈអសុទ្ធ បានដល់ ស្រៈដែលប្រើបានពីរយ៉ាង ប្រើជាស្រៈផង ជាព្យញ្ជនៈផង គឺ **ឥ ឦ ឧ ឩ** ។ ស្រៈបួនតួនេះ បើប្រើខាងដើមបទដែលផ្ដើមដោយព្យញ្ជនៈ រក្សារូបជាស្រៈដដែល ដូចខាងក្រោមនេះ

(**វិ** + **ករោតិ**) > **វិករោតិ** =រមែងផ្លាស់ប្ដូរ, កែច្នៃ ។

(**វិ** + **ហរតិ**) > **វិហរតិ** = រមែងនៅ ។

(**សុ** + **ករ**) > **សុករ** = ងាយ, ស្រួល ។

(**សុ** + **បតិ**) > **សុបតិ** = រមែងដេក ។

(**សុ** + **គត**) > **សុគត** = ដែលទៅល្អហើយ ។

ប៉ុន្តែបើប្រើខាងដើមបទដែលផ្ដើមដោយស្រៈវិញ មិនរក្សារូបជាស្រៈដដែលទេ គឺស្រៈ **ឥ ឦ** ផ្លាស់ជា **យ** និងស្រៈ **ឧ ឩ** ផ្លាស់ជា **វ** ដូចខាងក្រោមនេះ

(**វិ** + **អា** + **ករោតិ**) > **ព្យាករោតិ** = ធ្វើឱ្យច្បាស់ ។

(**វិ** + **អា** + **ហរតិ**) > **ព្យាហរតិ** = និយាយ, ពោល ។

(**សុ** + **អា** + **គត**) > **ស្វាគត** = មកល្អហើយ ។

(**សុ** + **អាការ**) > **សវាការ** = មានអាការៈល្អ ។

ស្រៈសំយុត្ត បានដល់ ស្រៈដែលផ្សំគ្នារវាងស្រៈសុទ្ធនិងស្រៈអសុទ្ធ គឺ (អ ឬ អា + ឥ) ឬ (អ ឬ អា + ឦ) ទៅជា ឯ និង (អ ឬ អា + ឧ) ឬ (អ ឬ អា + ឩ) ទៅជា ឱ ដូចខាងក្រោមនេះ

(ប + ឥក្ខតិ) > បេក្ខតិ = ក្រឡេកមើល ។

(ជិ + អ + តិ) > ជេតិ =នាំទៅ ។

(សហ + ឧទរ) > សហោទរ = បងប្អូន ។

(មហា + ឧទធិ) > មហោទធិ = សមុទ្រ ។

## វណ្ណៈ ឬ រូបរបស់ស្រៈ

វណ្ណៈ ក្នុងទីនេះមានន័យថា អក្សរ ។ ស្រៈទាំង ៨ តួខាងលើនេះ លោកចែកតាមវណ្ណៈ គឺឱ្យឈ្មោះ គិតតាមឋានដែលស្រៈនោះ ៗ កើត ដូចខាងក្រោមនេះ

| | | |
|---|---|---|
| ស្រៈ អ អា | មានឈ្មោះថា | អ វណ្ណៈ ។ |
| ស្រៈ ឥ ឦ | មានឈ្មោះថា | ឥ វណ្ណៈ ។ |
| ស្រៈ ឧ ឩ | មានឈ្មោះថា | ឧ វណ្ណៈ ។ |

ស្រៈមួយគូ ៗ ខាងលើនេះមានឈ្មោះម្យ៉ាងទៀតថា **សវណ្ណៈ** ។ ចំពោះស្រៈ ឯ និង ឱ មិនមានគូគ្នាទេ ហៅថា **អសវណ្ណៈ** ។ ឈ្មោះថា **សវណ្ណៈ** អាចហៅម្យ៉ាងទៀតថា **សរូប** គឺរូបស្មើគ្នា និង **អសវណ្ណៈ** អាច

ហៅម្យ៉ាងទៀតថា **អសរូប** គឺរូបមិនស្មើគ្នា ។ **សវណ្ណ** ឬ **សរូប** គឺស្រៈដែលមានករណៈ (**ករណ** គឺអវយវៈធ្វើឲ្យចេញសំឡេង នឹងអធិប្បាយនៅខាងមុខ) ដូចគ្នា ។ **អសវណ្ណ** ឬ **អសរូប** គឺស្រៈដែលមានករណៈផ្សេងគ្នា ។

អសរូប នៃស្រៈ អ អា គឺស្រៈ ឥ ឦ ឧ ឩ ឯ ឱ ។

អសរូប នៃស្រៈ ឥ ឦ គឺស្រៈ អ អា ឧ ឩ ឯ ឱ ។

អសរូប នៃស្រៈ ឧ ឩ គឺស្រៈ អ អា ឥ ឦ ឯ ឱ ។

អសរូប នៃស្រៈ ឯ គឺស្រៈ អ អា ឥ ឦ ឧ ឩ ឱ ។

អសរូប នៃស្រៈ ឱ គឺស្រៈ អ អា ឥ ឦ ឧ ឩ ឯ ។

## លក្ខណៈរបស់ព្យញ្ជនៈ

ព្យញ្ជនៈទាំង ៣៣ តួនោះ, ព្យញ្ជនៈ ២៥ តួចាប់ពី ក ដល់ ម ចែកជា ៥ វគ្គ, ក្នុងមួយវគ្គ ៗ មាន ៥ តួ ហៅថា វគ្គ ដូចខាងក្រោមនេះ

ក វគ្គ គឺ ក ខ គ ឃ ង ។

ច វគ្គ គឺ ច ឆ ជ ឈ ញ ។

ដ វគ្គ គឺ ដ ឋ ឌ ឍ ណ ។

ត វគ្គ គឺ ត ថ ទ ធ ន ។

ប វគ្គ គឺ ប ផ ព ភ ម ។

ព្យញ្ជនៈដែលនៅសល់ ៨ តួទៀតមិនចាត់ចូលក្នុងវគ្គទេ ហៅថា **អវគ្គ** គឺ **យ រ ល វ ស ហ ឡ ំ** ។

## និគ្គហិត

ព្យញ្ជនៈទី ៣៣ ដែលមានរាងដំមូលនិងដែលហើរទៅតាមស្រៈ បើហៅតាមសាសនវោហារថា **និគ្គហិត** ។ ប៉ុន្តែបើតាមក្បួនសទ្ទសាស្ត្រវិញហៅថា **អនុស្វារ** ។ និគ្គហិតនេះអាចបញ្ចេញសំឡេងដោយពុំចាំ-បាច់បើកមាត់បាន ។

## ការបញ្ចេញសំឡេងរបស់ស្រៈនិងព្យញ្ជនៈ

## គរុ និង លហុ

ភាពធ្ងន់ឬស្រាលក្នុងការបញ្ចេញសំឡេងភាសាបាលី ហៅថា **គរុ** ប្រែថា ធ្ងន់ និង **លហុ** ប្រែថា ស្រាល ។

**គរុ** បានដល់ការបញ្ចេញសំឡេងវែងឬទីឃៈមានចំណុចសម្គាល់ដូចតទៅនេះ

១. ស្រៈទីឃៈទាំងអស់គឺ **អា ឦ ឩ ឯ ឱ** មិនថាប្រើតែឯងឬនៅជាមួយព្យញ្ជនៈទេ ហៅថា **គរុ** ឧ. **អា ឦ ឩ ឯ ឱ វា ជី ភូ អាហារោ** ។

២. ស្រៈរស្សៈ ៣ តួគឺ **អ ឥ ឧ** តាមពិតជាលហុ ប៉ុន្តែបើប្រើនៅខាងដើមព្យញ្ជនៈសំយោគគឺតម្រួតគ្នាពីរតួ ស្រៈបីតួនេះក្លាយជាគរុវិញ ឧ. **ពុទ្ធោ**, **ហុត្វា**, **យស្ស**, **ឥក្ខមតិ** ជាដើម ។ សូមជ្រាបថា ស្រៈ **ឧ** នៃ **ពុ** និង **ហុ**, ស្រៈ **អ** នៃ **យ** និង **ឥ** ក្នុងពាក្យទាំងនេះក្លាយជាគរុហើយ ។ ដូច្នេះវេលាអានឬសូត្រ ត្រូវអានឬសូត្រឱ្យវែងដូចជាទីឃៈ គឺ ២ មាត្រា។

៣. ស្រៈរស្សៈ ៣ តួគឺ **អ ឥ ឧ** បើប្រើនៅខាងដើមនិគ្គហិតក៏ក្លាយជាគរុដែរ ឧ. **កតំ**, **ឥមំ**, **សុខំ** ។ ស្រៈ **អ** នៃ **ក**, ស្រៈ **ឥ** និងស្រៈ **ឧ** នៃ **សុ** ក្នុងពាក្យទាំងនេះជាគរុ ដូច្នេះត្រូវអានឬសូត្រឱ្យវែងដូចជាទីឃៈ ។

៤. ស្រៈរស្សៈ ៣ តួគឺ **អ ឥ ឧ** ប្រសិនបើមិនមានព្យញ្ជនៈសំ-យោគឬនិគ្គហិតនៅខាងចុងទេ ជាលហុគឺស្រាល ឧ. **បចតិ**, **វធតុ** ។

## ព្យាង្គ (Syllable)

ពាក្យសំដីទាំងឡាយដែលពោលចេញមកគឺជាព្យាង្គ ៗ ។ ព្យាង្គគឺជាសំឡេងដែលប្រកបឡើងពីស្រៈ ឬប្រជុំនៃសំឡេងដែលប្រកបឡើងពីស្រៈជាមួយនឹងព្យញ្ជនៈមួយតួឬច្រើនតួ ។ ក្នុងពាក្យថា **អាបជ្ជតិ** មាន ៤ ព្យាង្គគឺ **អា-បជ៑-ជ-តិ** ។ ទាំងបួនព្យាង្គនេះ ព្យាង្គទី ១ **អា** ប្រកបឡើងពីស្រៈ, ព្យាង្គទី ២ **បជ៑** ប្រកបឡើងពីព្យញ្ជនៈនិងស្រៈនិងព្យញ្ជនៈ (តួ **ជ** ក្នុងព្យាង្គនេះមិនមានសូរទេ គ្រាន់តែជាតួប្រកបប៉ុណ្ណោះ) និង

ព្យាង្គទី ៣ ជ, ព្យាង្គទី ៤ **តិ** ប្រកបឡើងពីព្យញ្ជនៈនិងស្រៈ ។

ព្យាង្គនីមួយ ៗ អាចជាព្យាង្គបើកឬបិទក៏បានដូចខាងក្រោមនេះ

ព្យាង្គបើក បានដល់ ព្យាង្គណាដែលមានសូរស្រៈខាងចុង ។ រីឯព្យាង្គបិទ បានដល់ ព្យាង្គណាដែលមានព្យញ្ជនៈមិនមានសូរឬនិគ្គហិតខាងចុង ។

ក្នុងឧទាហរណ៍ខាងលើនេះ ព្យាងទី ១, ៣, ៤ គឺ **អា**-, -**ជ**, -**តិ** ជាព្យាង្គបើក ។ រីឯព្យាង្គទី ២ -**បជ**- ជាព្យាង្គបិទពីព្រោះមានព្យញ្ជនៈមិនមានសូរខាងចុង ។

## គរុព្យាង្គនិងលហុព្យាង្គ

**គរុព្យាង្គ** បានដល់ ព្យាង្គទាំងឡាយណាដែលមានសូរស្រៈទីឃៈ ឬព្យញ្ជនៈឬក៏និគ្គហិតនៅខាងចុង ឧ. **អា-ជិច-ចោ** (**អាជិច្ចោ**) ។ ទាំងអស់មានបីព្យាង្គ និងព្យាង្គនីមួយ ៗ ជាគរុព្យាង្គ ពីព្រោះ **អា**- និង -**ចោ** មានស្រៈទីឃៈជាខាងចុង និង **ជិច** មានព្យញ្ជនៈមិនមានសូរខាងចុង ។

**លហុព្យាង្គ** បានដល់ ព្យាង្គទាំងឡាយណាដែលមានសូរស្រៈរស្សៈខាងចុង ឧ. **ឧ-ប-រិ** (**ឧបរិ**) ទាំងបីព្យាង្គនេះ ព្យាង្គនីមួយ ៗ ជាលហុព្យាង្គ ពីព្រោះមានខាងចុងជាស្រៈរស្សៈ ។

ក្នុងភាសាបាលី ព្យាង្គបិទទាំងឡាយណាដែលមានស្រៈទីឃៈ ត្រូវ

បានចាត់ជាគរុព្យាង្គ (ធ្ងន់) ព្រោះដូច្នោះ ស្រៈនោះ ៗ ត្រូវបានរស្សៈ ដូចក្នុងការប្រកបរូបជាកវិស្សន្តិនៃ **ធា** ធាតុគឺ (**ធា** + **អ** + **ស្សតិ**) បានរូបជា (**ធាស្សតិ**) ដែលមានបីព្យាង្គគឺ **ធាស៑-ស-តិ** ។ ព្យាង្គទី ១ **ធាស៑** មានស្រៈទីឃៈ ដូច្នេះចាត់ថាធ្ងន់ហួស ត្រូវតែរស្សៈស្រៈ **អា** ជា **អ** ទើបឃើញប្រើក្នុងរូបជា **ធស្សតិ** ដូច្នេះវិញ ។

ព្យាង្គបិទទាំងឡាយណាដែលជាស្រៈរស្សៈ និងព្យាង្គបើកទាំងឡាយណាដែលជាស្រៈទីឃៈជាគរុព្យាង្គដូចគ្នា គឺធ្ងន់ស្មើគ្នា ពីព្រោះការបញ្ចេញសូរមានរយៈស្មើគ្នា ។ ដូច្នេះព្យាង្គ **ធត៑-** ក្នុងពាក្យថា **ធត្ត** និង **ធា** ក្នុងពាក្យថា **ធាតុំ** ជាគរុដូចគ្នា ។ ភាពស្មើគ្នានេះហើយដែលបណ្ដាលឱ្យមានការផ្លាស់ប្ដូរយ៉ាងច្រើនដូចខាងក្រោមនេះ

១. ស្រៈទីឃៈនៃព្យាង្គបើកជួនកាលអាចរស្សៈនិងត្រូវតម្រួតព្យញ្ជនៈជាប់នោះ ដូចជា **មហាផលំ** (**ម-ហា-ផ-លំ**) > **មហប្ផលំ**, **សូយតិ** (**សូ-យ-តិ**) > **សុយ្យតិ**, **ឌីយតិ** (**ឌី-យ-តិ**) > **ឌិយ្យតិ** ជាដើម ។

២. ស្រៈរស្សៈនៃព្យាង្គបិទជួនកាលអាចទីឃៈ និងព្យញ្ជនៈនៅជាប់នោះត្រូវបានសម្រួល ដូចជា **កត្តព្វំ** (**កត៑-តព៑-វំ**) > **កាតព្វំ**, **កត្តុំ** (**កត៑--តុំ**) > **កាតុំ**, **សំភតោ** (**សំ-ភ-តោ**) > **សាភតោ** ជាដើម ។

៣. ស្រៈទីឃៈនៃព្យាង្គបើកនិងស្រៈរស្សៈនៃព្យាង្គបិទ ជួនកាលត្រូវបានជំនួសដោយនិគ្គហិត ដូចជា **អកាសុំ** (**អ-កា-សុំ**) > **អកំសុ**, **វិធស្សេតិ** (**វិ-ធស៑-សេ-តិ**) > **វិធំសេតិ** ជាដើម ។

បញ្ជាក់ នេះគ្រាន់តែជាផ្លូវសម្រាប់ពិចារណាប៉ុណ្ណោះ ពុំមែនជាក្រិត្យ ដាច់ខាតថាស័ព្ទបាលីសុទ្ធតែប្រព្រឹត្តទៅដូច្នេះទាំងអស់ទេ ។

## សថិល និង ធនិត

ភាពស្រាលឬធ្ងន់នៃព្យញ្ជនៈ ហៅថា **សថិល** ប្រែថា សំឡេង ស្រាល និង **ធនិត** ប្រែថា សំឡេងធ្ងន់ ។

ព្យញ្ជនៈពួកសថិលមានការបញ្ចេញសំឡេងផ្ទប់នឹងឋាន(ឬទីតាំង កើតសំឡេង)តិច ៗ បានដល់ ព្យញ្ជនៈតួទី ១ និងទី ៣ នៃវគ្គគឺ **ក គ ច ជ ដ ឌ ត ទ ប ព** ។

រីឯពួកធនិតវិញមានការបញ្ចេញសំឡេងផ្ទប់នឹងឋានច្រើនជាងពួក សថិលបន្តិច និងមានខ្យល់កាយចេញមកផង បានដល់ ព្យញ្ជនៈតួទី ២ និងទី ៤ នៃវគ្គគឺ **ខ ឃ ឆ ឈ ឋ ឍ ថ ធ ផ ភ** ។

ចំណែកព្យញ្ជនៈតួទី ៥ នៃវគ្គគឺ **ង ញ ណ ន ម** ជា **ធាសិក** ។

ចំពោះព្យញ្ជនៈពួកអវគ្គវិញ មិនឃើញលោកចាត់ថាជាសថិលឬ ធនិតទេ ។

## ឃោសៈ និង អឃោសៈ

(Aspirate and Unaspirate)

ភាពមិនកង់រំពង់នៃសំឡេងរបស់ព្យញ្ជនៈ ហៅថា **អឃោស** ប្រែថា មិនរំពង់ និងភាពកង់រំពង់ ហៅថា **ឃោស** ប្រែថា រំពង់ ។

១. ព្យញ្ជនៈដែលជា **អឃោស** គឺមានសំឡេងមិនកង់រំពង់ បានដល់ ព្យញ្ជនៈតួទី ១ និងទី ២ នៃវគ្គគឺ **ក ខ ច ឆ ដ ឋ ត ថ ប ផ** និង **ស** ។

២. ព្យញ្ជនៈដែលជា **ឃោស** គឺមានសំឡេងកង់រំពង់ បានដល់ ព្យញ្ជនៈតួទី ៣ ទី ៤ និងទី ៥ នៃវគ្គគឺ **គ ឃ ង ជ ឈ ញ ឌ ឍ ណ ទ ធ ន ព ភ ម** និង **យ រ ល វ ហ ឡ** ។

៣. ចំពោះនិគ្គហិត (ំ) លោកមិនចាត់ជាឃោសៈឬអឃោសៈទេ នេះជាមតិខាងសាសនា ប៉ុន្តែខាងសទ្ទសាស្ត្រវិញហៅថា **អនុស្វារ** ចាត់ជាព្យញ្ជនៈឃោសៈ ។

## សម្ព័ន្ធ និង វិវត្តិតៈ

ពាក្យដែលពោលឡើងដោយការចងបទដើមជាមួយបទមួយទៀតខាងចុង ដូចជាពោលថា **អជាចបិណ្ឌិកស្សាភាមេ** ។ នេះជាពាក្យមានពីរបទគឺ **អជាចបិណ្ឌិកស្ស** មួយបទនិង **អាភាមេ** មួយបទដែរ ប៉ុន្តែត្រូវអ្នកពោលប្រាថ្នាធ្វើឱ្យទៅជាមួយបទដោយចងភ្ជាប់គ្នាទើបហៅថា **សម្ពន្ធ** ។

ឧទាហរណ៍ខាងលើនេះ បើអ្នកពោលមិនប្រាថ្នាចងភ្ជាប់គ្នាធ្វើឱ្យ

ទៅជាមួយបទទេ ពោលជាពាក្យរាយថា **អនាថបិណ្ឌិកស្ស** អាការមេយ៉ាងនេះហៅថា **វត្តិត** ។

## វិមុត្តៈ

ការបញ្ចេញសំឡេងដោយបើកមាត់និងមិនមានការបង្អាប់អវយវៈឱ្យធ្វើសំឡេង បានដល់ពួកស្រៈទីឃៈមាន **អា** ជាដើមក្នុងព្យាង្គថា **តា** នៃពាក្យថា **ឆម្ភដ្ឋិតា** ហៅថា **វិមុត្ត** ។

## ឋាន ករណៈ និង បយតនៈ

វណ្ណៈឬអក្ខរៈនីមួយ ៗ អាចបញ្ចេញសំឡេងឡើងបាន ត្រូវមាន **ឋាន** **ករណៈ** និង **បយតនៈ** ។ **ឋាន** បានដល់ ទីតាំងដែលសំឡេងកើត ។ **ករណៈ** បានដល់ អវយវៈដែលជួយធ្វើសំឡេងឲ្យលាន់ឮឡើង គឺ អណ្តាត ។ **បយតនៈ** បានដល់ ការព្យាយាមបន្លឺសំឡេង ។

## ឋាននៃអក្ខរៈ

(The Organs of articulation)

តួអក្សរទាំង ៤១ នោះមានទីតាំងកើតរៀង ៗ ខ្លួន ។ ខ្លះមានទីតាំងកើតត្រឹមតែមួយ ខ្លះទៀតមានទីតាំងកើតដល់ទៅពីរ ។

## ឯកដ្ឋានអក្ខរៈ

(អក្សរកើតក្នុងឋានមួយ)

១. អក្សរ ៨ តួគឺ **អ អា ក ខ គ ឃ ង** និង **ហ** កើតនៅត្រង់ក ហៅថា **កណ្ឋជ** (អក្សរកើតត្រង់ក) ។ បានន័យថាអក្សរទាំងនេះមានសំឡេងលាន់ឮឡើងនៅបំពង់ក ដែលមានគល់អណ្ដាតបះឡើងទៅបិទបំពង់ខ្យល់ ហើយរង់ចាំស្រៈលាន់ឮឡើងទើបបញ្ចេញខ្យល់ព្រមជាមួយនិងសំឡេង ។

២. អក្សរ ៨ តួគឺ **ឥ ឦ ច ឆ ជ ឈ ញ** និង **យ** កើតនៅត្រង់ពិដាន ហៅថា **តាលុជ** (អក្សរកើតត្រង់ពិដាន) ។ បានន័យថាអក្សរទាំងនេះមានសំឡេងលាន់ឮឡើង ដែលមានផ្នែកកណ្ដាលនៃអណ្ដាតង៍ឡើងទៅប៉ះនឹងពិដានឬក្រអូមមាត់ខាងលើដើម្បីបិទខ្យល់ ប៉ុន្តែការបិទនេះត្រូវទម្លាយដោយស្រៈ ទើបចេញជាសំឡេង ។

៣. អក្សរ ៧ តួគឺ **ដ ឋ ឌ ឍ ណ រ** និង **ឡ** កើតនៅត្រង់អញ្ចាញធ្មេញខាងលើ ហៅថា **មុទ្ធជ** (អក្សរកើតត្រង់អញ្ចាញធ្មេញ) ។ បានន័យថាអក្សរទាំងនេះមានសំឡេងលាន់ឮឡើង ដែលមានផ្នែកជិត

ចុងនៃអណ្ដាតឯងឡើងទៅប៉ះនឹងពិដានផ្នែកខាងមុខដើម្បីបិទខ្យល់ ។

៤. អក្សរ ៧ តួគឺ **ត ថ ទ ធ ន ល** និង **ស** កើតនៅត្រង់ធ្មេញ ឬប្រទល់ធ្មេញ ហៅថា **ទន្តជ** (អក្សរកើតត្រង់ធ្មេញ) ។ បានន័យថាអក្សរទាំងនេះមានសំឡេងលាន់ឮឡើង គឺមានផ្នែកចុងអណ្ដាតបះទៅមុខប៉ះនឹងធ្មេញល្មមតែសំឡេងលាន់ឮចេញបាន ។

៥. អក្សរ ៧ តួគឺ **ឧ ឩ ប ផ ព ភ ម** កើតនៅត្រង់បបូរមាត់ ហៅថា **ឱដ្ឋជ** (អក្សរកើតត្រង់បបូរមាត់) ។ បានន័យថាអក្សរទាំងនេះមានសំឡេងលាន់ឮឡើងបានដោយត្រូវបិទមាត់ហើយបើកវិញ ។

៦. អក្សរ ១ តួគឺ ំ កើតនៅត្រង់ច្រមុះ ហៅថា **នាសិកដ្ឋានជ** ឬ **នាសិកជ** (អក្សរកើតត្រង់ច្រមុះ) ។ បានន័យថាអក្សរនេះមានសំឡេងលាន់ឮឡើងបានដោយពុំចាំបាច់បើកមាត់ទេ គឺមានខ្យល់ចេញតាមច្រមុះ ។

អក្សរទាំងឡាយខាងលើនេះកើតក្នុងឋានមួយប៉ុណ្ណោះ ហៅថា **ឯកដ្ឋានជ** ។

## ទ្វិដ្ឋានអក្ខរៈ

(អក្សរកើតក្នុងឋានពីរ)

១. អក្សរ ១ តួគឺ **ឯ** កើតនៅត្រង់កផងនិងពិដានផង ពីព្រោះ **ឯ**

*នេះកើតពីស្រៈ (អ + ឥ) ទើបហៅថា* **កណ្ឋតាលុជ** *(អក្សរកើតត្រង់កនិងពិដាន) ។ បានន័យថាអក្សរនេះមានសំឡេងលាន់ឮឡើងបាន គឺត្រូវមានអណ្ដាតប៉ះនឹងពិដានផង ។*

*២. អក្សរ ១ តួគឺ* **ឱ** *កើតនៅត្រង់កផងនិងបបូរមាត់ផង ពីព្រោះ* **ឱ** *នេះកើតពីស្រៈ (អ + ឧ) ទើបហៅថា* **កណ្ឋោដ្ឋជ** *(អក្សរកើតត្រង់កនិងបបូរមាត់) ។ បានន័យថាអក្សរនេះមានសំឡេងលាន់ឮឡើងបាន គឺត្រូវប្រើបបូរមាត់បិទផងបើកផង ។*

*៣. អក្សរ ១ តួគឺ វ កើតនៅត្រង់ធ្មេញផងនិងបបូរមាត់ផង ហៅថា* **ទន្តោដ្ឋជ** *(អក្សរកើតត្រង់ធ្មេញនិងបបូរមាត់) ។ បានន័យថាអក្សរនេះមានសំឡេងលាន់ឮឡើងបានគឺត្រូវប្រើធ្មេញនិងបបូរមាត់បិទបើកផង។*

*៤. អក្សរ ៥ តួគឺ* **ង ញ ណ ន ម** *កើតនៅត្រង់ឋាននៃខ្លួននិងត្រង់ច្រមុះផង ហៅថា* **សកដ្ឋានជាសិកដ្ឋានជ** *(អក្សរកើតត្រង់ឋាននៃខ្លួននិងច្រមុះ) ។ បានន័យថាអក្សរទាំងនេះមានសំឡេងលាន់ឮឡើងបាន គឺត្រូវចេញខ្យល់តាមច្រមុះផង ។*

*អក្សរទាំងឡាយខាងលើនេះកើតក្នុងឋានពីរ ហៅថា* **ទ្វិដ្ឋានជ** *។*

*៤. អក្សរ ១ តួគឺ* **ហ** *ប្រសិនបើប្រើរួមគ្នាជាមួយនឹងវគ្គន្តព្យញ្ជនៈ ៤ តួគឺ* **ញ ណ ន ម** *និងអវគ្គគឺ* **យ ល វ ឡ** *ដូចក្នុងពាក្យថា* **តញ្ហិ, តណ្ហា, ន្ហាត្វា, តុម្ហាកំ, មុយ្ហតិ, វុល្ហតេ, អវ្ហយតិ, វុឡ្ហ** *។ល។ ហៅថា* **ឧរសិជ** *ឬ* **ឧរជ** *(អក្សរកើតត្រង់ទ្រូងឬខ្វំទ្រូង) ។*

# អឌ្ឍសរ

(ស្រៈអឌ្ឍៈ)

(Semi-vowels)

ស្រៈអឌ្ឍៈ បានដល់ ព្យញ្ជនៈណាដែលអាចប្រើផ្លាស់ប្ដូរជាមួយស្រៈបាន ។ បើយល់តាមវិធីរបស់ភាសាសំស្ក្រឹតប្រាប់ថាមាន **អឌ្ឍសរ** បួនតួគឺ **យ ',រ ល វ** ។ ស្រៈអឌ្ឍៈបួនតួនេះមានដំណើរកើតឡើងដូចខាងក្រោមនេះ

**យ** កើតពីស្រៈ **ឥ** និង **អ** ដោយការអានប្រមៀលស្រៈ **ឥ** យ៉ាងរហ័សទៅលើស្រៈ **អ** ទៅជា **អ៊ិ-អៈ** សម្រេចបានជា **យ** ។

**រ** កើតពីស្រៈ **ឫ** និង **អ** ដោយការអានប្រមៀលស្រៈ **ឫ** (ស្រៈសំស្ក្រឹត) យ៉ាងរហ័សទៅលើស្រៈ **អ** ទៅជា **រឹ-អៈ** សម្រេចបានជា **រ** ។

**ល** កើតពីស្រៈ **ឭ** និង **អ** ដោយការអានប្រមៀលស្រៈ **ឭ** (ស្រៈសំស្ក្រឹត)យ៉ាងរហ័សទៅលើស្រៈ **អ** ទៅជា **លឹ-អៈ** សម្រេចបានជា **ល** ។

**វ** កើតពីស្រៈ **ឧ** និង **អ** ដោយការអានប្រមៀលស្រៈ **ឧ** យ៉ាងរហ័សទៅលើស្រៈ **អ** ទៅជា **អ៊ុ-អៈ** សម្រេចបានជា **វ** ។

## ករណៈនៃអក្ខរៈ

អវយវៈដែលជួយធ្វើឱ្យមានសំឡេង ហៅថា **ករណ** ។ ករណៈនៃអក្សរទាំង ៤១ តួនោះមាន ៤ យ៉ាងគឺ **ជិវ្ហាមជ្ឈ**, **ជិវ្ហោបគ្គ**, **ជិវ្ហគ្គ** និង **សកដ្ឋាន** ។

១. **ជិវ្ហាមជ្ឈ** បរិវេណកណ្ដាលអណ្ដាតជាករណៈរបស់ពួកអក្សរតាលុជៈ ។

២. **ជិវ្ហោបគ្គ** បរិវេណជិតចុងនៃអណ្ដាតជាករណៈរបស់ពួកអក្សរមុទ្ធជៈ ។

៣. **ជិវ្ហគ្គ** បរិវេណចុងអណ្ដាតជាករណៈរបស់ពួកអក្សរទន្តជៈ ។

៤. **សកដ្ឋាន** (ឋានរបស់ខ្លួន)ជាករណៈរបស់ពួកអក្សរកណ្ឋជៈ, ឱដ្ឋជៈ, **ឃ**, **ឌ**, **វ** និង ំ (និគ្គហិត) ។

## និស្សយៈ និង និស្សិត

**និស្សយ** ប្រែថា ទីអាស្រ័យ, ទីពឹង បានដល់ ស្រៈទាំង ៨ តួ គឺថាស្រៈទាំងនេះជាទីអាស្រ័យឬទីពឹងរបស់ព្យញ្ជនៈ ពីព្រោះស្រៈអាចចេញសំឡេងដោយខ្លួនឯងបាន ។ បើឥតមានស្រៈជួយទេ ព្យញ្ជនៈមិនអាចចេញសំឡេងបានឡើយ ។ ការរាប់តួព្យញ្ជនៈនីមួយ ៗ ដែលយើងធ្លាប់រាប់ថា កៈ ខៈ គៈ ឃៈ ងៈ ជាដើមនោះ សុទ្ធតែមានស្រៈ អៈ អាស្រ័យទើបស្រៈទាំងអស់មានឈ្មោះថា **និស្សយ** ។

**និស្សិត** ប្រែថា អាស្រ័យហើយ ជាឈ្មោះរបស់ព្យញ្ជនៈ ពីព្រោះព្យញ្ជនៈមិនអាចចេញសំឡេងដោយខ្លួនឯងបានទេ ដូចបានពោលរួចហើយនៅខាងលើ ។

ប៉ុន្តែចំពោះស្រៈវិញ ថ្វីត្បិតតែអាចចេញសំឡេងដោយខ្លួនឯងបានក៏ដោយ ក៏ត្រូវមានព្យញ្ជនៈអាស្រ័យផងដែរទើបធ្វើឱ្យការនិយាយស្តីប្រព្រឹត្តទៅបាន ។ ពីព្រោះថា ស្រៈអាចចេញសំឡេងបានមែន តែបានត្រឹមប៉ុន្មានម៉ាត់ប៉ុណ្ណោះ ដូចជាក្នុងភាសាខ្មែរយើងថា **អាក់ ៗ** (អ) ក្នុងការឃាត់ឬបង្អាក់ដំណើរក្នុងរឿងអ្វីមួយ ។ **អា** ជាពាក្យទ្រគោះប្រើក្នុងការហៅអ្នកណាមួយមិនសមគួរថា អានេះ, អានោះ ឬ ជាពាក្យលាន់មាត់ដូចជាថា អា ! មិនយកទេ ។ **អូ** ជាពាក្យលាន់មាត់ដូចជាថា អូ មែនហើយ ! ។ **ឯ** (ខ្មែរថា អែ) ដូចជាថា ឯលិច, ឯកើត ។ **ឱ** ជាពាក្យលាន់មាត់ដូចជាថា ឱហ្ន៎ ! ជាដើម ។

ដូច្នេះស្រៈនិងព្យញ្ជនៈត្រូវតែពឹងពាក់គ្នាទៅវិញទៅមក ។

## តារាងអំពីឋាននិងករណៈនៃ
## អក្សរភាសាបាលី

# ឯកដ្ឋានអក្ខរ

| អក្ខរៈ | ឋាន | ករណៈ |
|---|---|---|
| អ អា ក ខ គ ឃ ង ហ | កណ្ឋ (ក) | *កណ្ឋៈ(សកដ្ឋាន)* |
| ឥ ឦ ច ឆ ជ ឈ ញ យ | តាលុ (ពិដាន) | *ជិវ្ហាមជ្ឈៈ* |
| ដ ឋ ឌ ឍ ណ ឡ | មុទ្ធ(អញ្ចាញធ្មេញ) | *ជិវ្ហោបគ្គៈ* |
| ត ថ ទ ធ ន ល | ទន្ត (ធ្មេញ) | *ជិវ្ហគ្គៈ* |
| ឧ ឩ ប ផ ព ភ ម | ឱដ្ឋ (បបូរមាត់) | *ឱដ្ឋៈ (សកដ្ឋាន)* |
| ◌ំ | នាសិក (ច្រមុះ) | *នាសិកៈ(សកដ្ឋាន)* |

# ទ្វិដ្ឋានអក្ខរ

| អក្ខរៈ | ឋាន | ករណៈ |
|---|---|---|
| ឯ | កណ្ឋ + តាលុ | *កណ្ឋៈ + ជិវ្ហាមជ្ឈៈ* |
| ឱ | មុទ្ធ + ឱដ្ឋ | *កណ្ឋៈ + ឱដ្ឋៈ* |
| វ | ទន្ត + ឱដ្ឋ | *ជិវ្ហគ្គៈ + ឱដ្ឋៈ* |
| ង ញ ណ ន ម | សកដ្ឋាន + នាសិក | *សកដ្ឋាន + នាសិកៈ* |

# សំឡេងរបស់ព្យញ្ជនៈ

| ព្យញ្ជនៈវគ្គ | | | | | ព្យញ្ជនៈអវគ្គ | | |
|---|---|---|---|---|---|---|---|
| អឃោសៈ | | ឃោសៈ | | | អឃោសៈ | ឃោសៈ | វិមុត្ត |
| សថិល | ធនិត | សថិល | ធនិត | សថិល,វិមុត្ត | | | |
| ក | ខ | គ | ឃ | ង | ស | យ រ | |
| ច | ឆ | ជ | ឈ | ញ | | ល វ | |
| ដ | ឋ | ឌ | ឍ | ណ | | ហ ឡ | ◌ំ |
| ត | ថ | ទ | ធ | ន | | | |
| ប | ផ | ព | ភ | ម | | | |

(ចប់មេរៀនទី ៤៣)

# មេរៀនទី ៨៤

# អធិប្បាយអំពីសន្ធិ

## (Euphonic Combination)

*ពាក្យថា* **សន្ធិ** *សម្រេចមកពី (***សំ** + **ធា** + **ឥ***) ជានាមកិតក: ប្រែថា "ការត, តំណ" បានដល់ ការតតួអក្សរនឹងតួអក្សរឬបទ (ពាក្យ) នឹងបទឱ្យជាប់គ្នា ក្នុងគោលបំណងធ្វើឱ្យមានការងាយស្រួលដើម្បីតែងឆ័ន្ទ (កាព្យ) ឱ្យមានសំឡេងពីរោះស្រស់ស្រាយ ។ តាមធម្មតាពាក្យក្នុងភាសាបាលីខ្លះមានច្រើនព្យាង្គ ដូច្នេះដើម្បីឱ្យនិយាយលឿនបាន ត្រូវតែធ្វើសន្ធិ គឺតភ្ជាប់គ្នាដោយកាត់តួអក្សរចោលខ្លះ ឱ្យតិចជាងមុន ប៉ុន្តែមិនអាចធ្វើទៅដោយគ្មានបែបបទទេ ។ សន្ធិជាការតភ្ជាប់អក្ខរ:និងអក្ខរ: ប៉ុណ្ណោះ មិនប្រាថ្នាបង្កើតអត្ថន័យថ្មីទេ ដូចមានគោលការណ៍តទៅនេះ*

## ប្រភេទនៃសន្ធិ

**សន្ធិ** *ប្រសិនបើចែកជាចំណែកធំ ៗ មាន ៣ យ៉ាងគឺ* **សរសន្ធិ, ព្យញ្ជនសន្ធិ, និគ្គហិតសន្ធិ** ។

១. **សរសន្ធិ** *បានដល់ បទសន្ធិណាដែលមានការតស្រៈនឹងស្រៈ ។*

២. **ព្យញ្ជនសន្ធិ** *បានដល់ បទសន្ធិណាដែលបទដើមមានទីបំផុតជាស្រៈតនឹងបទចុងដែលផ្ដើមដោយព្យញ្ជនៈ ។*

៣. **និគ្គហិតសន្ធិ** បានដល់ បទសន្ធិណាដែលបទដើមមានទីបំផុតជានិគ្គហិតតនឹងបទចុងដែលផ្ដើមដោយស្រៈឬព្យញ្ជនៈក៏បាន ឬហៅ **វោមិស្សកសន្ធិ** ឬ **សាធារណសន្ធិ** ក៏បាន ។

សន្ធិនេះអាចកំណត់ហៅម្យ៉ាងទៀតដូចខាងក្រោមនេះ

១. **បទសន្ធិ** បានដល់ សន្ធិណាដែលមានការតបទនឹងបទ ដូចជា **ត ត្រ + អយំ** ទៅជា **ត ត្រាយំ** ឬហៅថា **ពហិសន្ធិ** ក៏បាន ។

២. **វណ្ណសន្ធិ** បានដល់ សន្ធិណាដែលមានការតអក្ខរៈនឹងអក្ខរៈ ដូចជា **ខត្តិយា** ទៅជា **ខត្យា** ឬហៅថា **អន្តោសន្ធិ** ក៏បាន ។

## សន្ធិកិរិយោបករណ៍

(Combination Rules)

វិធីសន្ធិខាងលើនេះត្រូវការឧបករណ៍ដើម្បីប្រើក្នុងការត ហៅថា **សន្ធិកិរិយោបករណ** មាន ៨ យ៉ាងដូចខាងក្រោមនេះ

| ឈ្មោះឧបករណ៍ | ពាក្យប្រែ |
|---|---|
| ១. លោបោ | (លុប) លុបបំបាត់តួអក្សរចោល ។ |
| ២. អាទេសោ | (អាទេសៈ) ផ្លាស់ស្រៈទៅជាព្យញ្ជនៈ ។ |
| ៣. អាគមោ | (ចុះអាគម) ចុះតួអក្សរថែម ។ |

៤. វិការោ (វិការៈ) ផ្លាស់តួអក្សរឱ្យខុសរូបដើម ។

៥. បកតិ (ប្រក្រតី) ទុកអក្សរឱ្យគង់រូបដើមតាមធម្មតា ។

៦. ទីឃោ (ទីឃៈ) ធ្វើស្រៈឱ្យវែង ។

៧. រស្សោ (រស្សៈ) ធ្វើស្រៈឱ្យខ្លី ។

៨. សំយោគោ (សំយោគ) តម្រួតតួអក្សរ ។

បណ្ដាសន្ធិទាំងបីប្រភេទខាងលើនេះ មិនប្រើសន្ធិកិរិយោបករណ៍នេះដូចគ្នាទាំងអស់ទេ តែខ្លះប្រើតិចនិងខ្លះប្រើច្រើន ។

សន្ធិកិរយោបករណ៍នេះ គម្ពីរសទ្ទនីតិប្រាប់ថាមាន ១០ យ៉ាងគឺ

១. បុព្វំ សូរដើម

២. បរំ សូរចុង

៣. លោបោ លុប

៤. អាគមោ ចុះអក្សរថ្មី

៥. សញ្ញោគោ តម្រួតអក្សរ

៦. វិយោគោ លុបអក្សរតម្រួត

៧. បរឞយនំ ការផ្សំអក្សរដើមជាមួយអក្សរចុង

៨. វិបរិយយោ ការផ្លាស់សូរ

៩. វិការោ ការផ្លាស់ពីអក្សរមួយទៅជាអក្សរមួយទៀត

១០. វិបរីតោ ការផ្លាស់ត្រឡប់រកដើមវិញ ដូចជា ឃ > ឥ, ឱ > ឧ, អវ > ឱ, អវ > ឧ ឬ ឩ ។

# វិធីធ្វើសន្ធិ

មុនដំបូងត្រូវញែកយកព្យញ្ជនៈចេញពីស្រៈសិន ឧទាហរណ៍

**កោ** ញែកយក **ក** ចេញចាក **ឱ** ទៅជា **ក** និង **ឱ**។

**ឯតំ** ញែកយក **ត** ចេញចាក ំ ទៅជា **ឯត** និង ំ។

បន្ទាប់មកយកតួព្យញ្ជនៈដូចជា **ក**, **ត** ទៅផ្សំជាមួយអក្សរដើមនៃបទចុងតាមសមគួរដែលអាចផ្សំបាន ។

## ១. សរសន្ធិ

## (Vowel Combination)

បទសន្ធិដែលជាសរសន្ធិនេះជាការតស្រៈនិងស្រៈដូចគ្នា សំដៅយកស្រៈទីបំផុតនៃបទដើមតភ្ជាប់ជាមួយស្រៈខាងដើមរបស់បទចុង គឺសន្មតិឱ្យឈ្មោះ ២ យ៉ាងគឺ

១. **បុព្វសរ** (ស្រៈដើម) បានដល់ ស្រៈទីបំផុតរបស់បទខាងដើម ។

២. **បរសរ** (ស្រៈចុង) បានដល់ ស្រៈខាងដើមរបស់បទខាងចុង ។

## កំណត់សម្គាល់

ការសរសេរភាសាបាលីជាតួអក្សរខ្មែរមានស្រៈពីរយ៉ាងគឺ ស្រៈ-

និស្ស័យ និង ស្រៈពេញតួ ។ ស្រៈនិស្ស័យអាចសរសេរខាងលើផង ខាងក្រោមផង ឬខាងឆ្វេងផង ខាងស្តាំនៃតួព្យញ្ជនៈផងក៏បាន ។ ចំពោះស្រៈ អ ទៀតសោតមិនមានរូបឱ្យឃើញទេ មានតែសំឡេង ។ អាស្រ័យហេតុនេះដើម្បីឱ្យងាយយល់ សូមចាំទុកថា **បុព្វសរ** កំណត់យកតាមការអានបញ្ចេញសំឡេងដែលសឱ្យឃើញថាបទដើមមួយណាក៏ដោយក៏មានទីបំផុតជាស្រៈទាំងអស់ ។ រីឯ **បរសរ** គឺកំណត់យកតែបទណាដែលផ្តើមដោយស្រៈពេញតួប៉ុណ្ណោះ បើមិនផ្តើមដោយស្រៈពេញតួទេមិនរាប់ថាជាស្រៈចុងឡើយ ត្រូវចាត់ថាស័ព្ទនោះ ៗ ផ្តើមដោយព្យញ្ជនៈវិញ ។ ម៉្យាងទៀតបើបទចុងមិនមែនជាអព្យយស័ព្ទទេ ចាំបាច់ត្រូវបំបែកជាបឋមាវិភត្តិដូចមានឧទាហរណ៍ខាងក្រោមនេះ

( **យស្ស** + **ឥន្ទ្រិយានិ** ) > **យស្សិន្ទ្រិយានិ**

បទដើម | បទចុង | បទសន្ធិ

បទសន្ធិនេះលុបស្រៈ អ របស់ **យស្ស** ចេញ ។

សរសន្ធិនេះប្រើឧបករណ៍ទាំងឡាយ ដែលពោលហើយនៅខាងលើ វៀរតែសំយោគោមិនអាចប្រើបាន ពីព្រោះស្រៈមិនអាចប្រើតម្រួតគ្នាទេ ។

# ស្រៈស្មើគ្នានិងស្រៈមិនស្មើគ្នា

១. ស្រៈស្មើគ្នាគឺស្រៈដែលជាគូនឹងគ្នា ដូចជា

(អ = អ, អ = អា) ឬ (អា = អា, អា = អ) ។

(ឥ = ឥ, ឥ = ឦ) ឬ (ឦ = ឦ, ឦ = ឥ) ។

(ឧ = ឧ, ឧ = ឩ) ឬ (ឩ = ឩ, ឩ = ឧ) ។

២. ស្រៈមិនស្មើគ្នាគឺស្រៈដែលមិនមែនជាគូនឹងគ្នា ដូចជា អ ≠ ឥ, អ ≠ ឧ, អ ≠ ឯ, អ ≠ ឱ ឬក៏ ឥ ≠ អ, ឥ ≠ ឧ ជាដើម ។

## ១.១ សរលោបសន្ធិ

សរលោបសន្ធិ បានដល់ សន្ធិណាដែលមានការលុបស្រៈ មាន ២ យ៉ាងគឺ បុព្វសរលោបសន្ធិ និង បរសរលោបសន្ធិ ។

ក. បុព្វសរលោបសន្ធិ បានដល់ ការតដោយការលុបស្រៈដើមព្រោះស្រៈចុង ។ សន្ធិបែបនេះ ភាគច្រើនមានស្រៈមិនស្មើគ្នា ដូចឧទាហរណ៍តទៅនេះ

លុប អ ស្រៈដើម ដូចជា

យស្សិន្ទ្រិយានិ < (យស្ស + ឥន្ទ្រិយានិ)

អជ្ជុទោសថោ < (អជ្ជ + ឧទោសថោ)

អមនុស្សុបទ្ទវោ < (អមនុស្ស + ឧបទ្ទវោ)

តេនុបសង្កមិ < (តេន + ឧបសង្កមិ)

លុប អា ស្រៈដើម ដូចជា

បញ្ញិន្ទ្រិយានិ < (បញ្ញា + ឥន្ទ្រិយានិ)

តទុដ្ឋហិ < (តទា + ឧដ្ឋហិ)

សញ្ញុបមានោ < (សញ្ញា + ឧបមានោ)

លុប ឥ ស្រៈដើម ដូចជា

ឧទធូមិយោ < (ឧទធិ + ឩមិយោ)

អគ្គាហិតោ < (អគ្គិ + អាហិតោ)

ចតូហាបាយេហិ < (ចតូហិ + អបាយេហិ)

លុប ឦ ស្រៈដើម ដូចជា

ភិក្ខុនោវាទោ < (ភិក្ខុនី + ឱវាទោ)

មិគិរ < (មិគី + ឥរ)

រាជិនូរូ < (រាជិនី + ឩរូ)

លុប ឧ ស្រៈដើម ដូចជា

សមេតាយស្មា < (សមេតុ + អាយស្មា)

ធាតាយតនានិ < (ធាតុ + អាយតនានិ)

ធាតិន្ទ្រិយានិ < (ធាតុ + ឥន្ទ្រិយានិ)

លុប ឱ ស្រៈដើម ដូចជា

ជម្ពាធានិ < ( ជម្ពូ + អាធានិ )

ជម្ពីរិត ភាគេន < ( ជម្ពូ + ឦរិត ភាគេន )

លុប ឯ ស្រៈដើម ដូចជា

មុជីវិតា < ( មេ + ឧជីវិតា )

មោកាសោ < ( មេ + ឱកាសោ )

លុប ឱ ស្រៈដើម ដូចជា

ឯសាវុសោ < (ឯសោ + អាវុសោ )

អសង្គេត្ត < ( អសង្គោ + ឯត្ត )

តយស្ស < ( តយោ + អស្ស )

*ខ. បរសរលោបសន្ធិ បានដល់ ការតដោយការលុបស្រៈចុង ព្រោះស្រៈដើម ។ សន្ធិបែបនេះ ភាគច្រើនមានស្រៈមិនស្មើគ្នា ដូចមាន ឧទាហរណ៍ខាងក្រោមនេះ*

លុប អ ស្រៈចុង ដូចជា

ឥតិបិ < (ឥតិ + អបិ )

សោហំ < ( សោ + អហំ )

វន្ទេហំ < ( វន្ទេ + អហំ )

វន្ទិយត្ថំ < ( វន្ទិយ + អត្ថំ )

ជនម្មត្ថិ < ( ជនំ មេ + អត្ថិ )

នត្ថិ < ( ន + អត្ថិ )

ទុក្ខស្សន្តំ < ( ទុក្ខស្ស + អន្តំ )

អកាតញ្ញូសិ < ( អកាតញ្ញូ + អសិ )

លុប អា ស្រៈចុង ដូចជា

តថាគតោ < ( តថា + អាគតោ )

មោគ្គល្លានោសិ < ( មោគ្គល្លានោ + អសិ )

លុប ឥ ស្រៈចុង ដូចជា

ជានិមេ < (ជានិ + ឥមេ), តីណិមានិ < ( តីណិ + ឥមានិ )

ឆាយាវ < ( ឆាយា + ឥវ ), ចក្ខុន្ទ្រិយំ < ( ចក្ខុ + ឥន្ទ្រិយំ )

ចត្តារោមេ < ( ចត្តារោ + ឥមេ ), សីហោវ < ( សីហោ + ឥវ )

លុប ឧ ស្រៈចុង ដូចជា

មាតុប្បដ្ឋានំ < ( មាតុ + ឧបដ្ឋានំ )

លុប ឯ ស្រៈចុង ដូចជា

ចាគោវ < ( ចាគោ + ឯវ ), សញ្ញេវ < ( សញ្ញេ + ឯវ )

កាថេវ កា ? < ( កាថា + ឯវ កា ), មេតំ < ( មេ + ឯតំ )

## ១.២ សរាទេសសន្ធិ

សន្ធិនេះ បានដល់ បទសន្ធិខ្លះដែលមានការផ្លាស់ គឺអាទេសៈជាព្យញ្ជនៈមាន ២ យ៉ាងគឺ **បុព្វសរាទេសសន្ធិ** និង **បរសរាទេសសន្ធិ**។

ក. **បុព្វសរាទេសសន្ធិ** បានដល់ ការតដោយកការអាទេសស្រៈដើមជាព្យញ្ជនៈ ។

ក.១ បើស្រៈដើមជា ឥ, ឦ និងមានស្រៈចុងមិនស្មើគ្នា អាទេសគឺផ្លាស់ ឥ, ឦ ទៅជា យ ។ បើស្រៈចុងជាស្រៈរស្សៈនិងមិនមានព្យញ្ជនៈសំយោគចុងទេ ត្រូវទីឃៈស្រៈចុងនោះផងដែរ ដូចជា

**ទាស្យាហោសិ** < (**ទាសី** + **អហោសិ**)

**វ្យាកាសិ** < (**វិ** + **អាកាសិ**)

**សត្តម្យត្ថេ** < (**សត្តមី** + **អត្ថេ**)

ក.២ បើស្រៈដើមជា ឥ ឦ ឯ និងមានស្រៈចុងមិនស្មើគ្នា អាចអាទេស គឺផ្លាស់ ឥ ឦ ឯ ជា យ ។ បើស្រៈដើមអាស្រ័យនឹងព្យញ្ជនៈសំយោគ ត្រូវលុបព្យញ្ជនៈសំយោគនោះ ៗ ដែលមានរូបដូចគ្នាមួយតួចេញ ដូចជា

**អគ្យាគារំ** < (**អគ្គិ** + **អគារំ**)

**សោត្យត្ថុ** < (**សោត្ថិ** + **អត្ថុ**)

**បដិសណ្ឋារវុត្យស្ស** < (**បដិសណ្ឋារវុត្តិ** + **អស្ស**)

ក.៣ បើបទដើមមានទីបំផុតជា **តិ** ដូចជា **អតិ**, **ឥតិ**, **បតិ** ជាដើម អាទេសស្រៈ ឥ នៃ **តិ** ជា **យ** បានរូបជា **ត្យ** រួចផ្លាស់ទៅជា **ច្ច** ដូចជា

អច្ចន្តំ < (អតិ > អច្ច + អន្តំ)

ឥច្ចស្ស < (ឥតិ > ឥច្ច + អស្ស)

ឥច្ចាទិ < (ឥតិ > ឥច្ច + អាទិ)

បច្ចាហរតិ < (បតិ > បច្ច + អាហរតិ)

បច្ចុត្តរិត្វា < (បតិ > បច្ច + ឧត្តរិត្វា)

*ប៉ុន្តែបើស្រៈចុងជា ឥ ឦ មិនអាទេសដូចខាងលើទេ ត្រូវទីឃៈវិញ ដូចជា*

ឥតីតិ < (ឥតិ + ឥតិ), អតីតោ < (អតិ + ឥតោ)

បតីតោ < (បតិ + ឥតោ), អតីរិតំ < (អតិ + ឦរិតំ)

*ក.៤ បើបទដើមមានទីបំផុត ទិ, ទី ដូចជា យទិ, នទី ជាដើម ត្រូវអាទេសស្រៈ ឥ, ឦ នៃ ទិ, ទី ជា យ បានរូបជា ទ្យ រួចផ្លាស់ទៅជា ជ្ជ ដូចជា*

យជ្ជេវំ < (យទិ > យជ្ជ + ឯវំ)

នជ្ជា < (នទី > នជ្ជ + អា)

*ក.៥ បើបទដើមមានទីបំផុត ធិ ដូចជា អធិ, ពោធិ ជាដើម ត្រូវអាទេសស្រៈ ឥ នៃ ធិ ជា យ បានរូបជា ធ្យ រួចផ្លាស់ទៅជា ជ្ឈ ដូចជា*

អជ្ឈាគមា < (អធិ > អជ្ឈ + អាគមា)

អជ្ឈោកាសោ < (អធិ > អជ្ឈ + ឱកាសោ)

អជ្ឈាហរតិ < (អធិ > អជ្ឈ + អាហរតិ)

ពោជ្ឈង្គា < (ពោជិ > ពោជ្ឈ + អង្គា)

*ក.៦ បើបទដើមមានទីបំផុត* **ភិ** *ដូចជា* **អភិ** *ជាដើម ត្រូវអាទេស ស្រៈ* **ឥ** *នៃ* **ភិ** *ជា* **យ** *បានរូបជា* **ភ្យ** *រួចផ្លាស់ទៅជា* **ព្ភ** *ដូចជា*

អព្ភុគច្ឆតិ < (អភិ > អព្ភ + ឧគច្ឆតិ)

អព្ភោកាសោ < (អភិ > អព្ភ + ឱកាសោ)

អព្ភាចិក្ខនំ < (អភិ > អព្ភ + អាចិក្ខនំ)

អព្ភុឌីរិតំ < (អភិ > អព្ភ + ឧឌីរិតំ)

*ក.៧ បើបទដើមមានទីបំផុត* **បិ** *ដូចជា* **អបិ** *ជាដើមត្រូវអាទេសៈ ស្រៈ* **ឥ** *នៃ* **បិ** *ជា* **យ** *បានរូបជា* **ប្យ** *រួចផ្លាស់ទៅជា* **ប្ប** *ដូចជា*

អប្បេកច្ចេ < (អបិ > អប្ប + ឯកច្ចេ)

អប្បេកជា < (អបិ > អប្ប + ឯកជា)

**កំណត់ចំណាំ** *ចាប់ពី ក.៣ ដល់ ក.៧ អាចធ្វើដូចខាងលើបានចំពោះតែមានស្រៈចុង ។ ប្រសិនបើបទចុងជាព្យញ្ជនៈវិញ មានវិធីផ្សេងទៀតមានអធិប្បាយខាងមុខ នៅក្នុងព្យញ្ជនសន្ធិ ។*

*ក.៨ បើស្រៈដើមជា* **ឯ** *មានស្រៈចុងមិនស្មើគ្នា អាទេសគឺផ្លាស់ជា* **យ** *ដូចជា*

ត្យាហំ < (តេ + អហំ), ម្យាយំ < (មេ + អយំ)

បព្វត្យាហំ < (បព្វតេ + អហំ), ត្យស្ស < (តេ + អស្ស)

ក្យស្ស < (កេ + អស្ស)

❁ ប៉ុន្តែស្រៈ ឯ នៃ យេ មិនត្រូវអាទេសទេ គឺលុបស្រៈ ឯ ចេញ និងខ្លះត្រូវទីឃៈស្រៈចុងផងដូចជា

យស្ស < (យេ + អស្ស), យស្សុ < (យេ + អស្សុ)

យាភិវទន្តិ < (យេ + អភិវទន្តិ)

ក.៩ បើស្រៈដើមជា ឧ ឩ មានស្រៈចុងមិនស្មើគ្នា អាទេសគឺផ្លាស់ ឧ ឩ ជា វ និងពេលខ្លះត្រូវទីឃៈស្រៈចុងនោះ ៗ ផងដូចជា

អន្វេតិ < (អនុ + ឯតិ)

ពហ្វាពាធា < (ពហុ + អាពាធា)

ស្វាក្ខាតោ < (សុ + អក្ខាតោ)

ចក្ខ្វាយតនំ < (ចក្ខុ + អាយតនំ)

ក.១០ បើស្រៈដើមជា ឱ មានស្រៈចុងមិនស្មើគ្នា អាទេសគឺផ្លាស់ ឱ ជា វ ដូចជា

ក្វត្ថ < (កោ + អត្ថ)

អថខ្វស្ស < (អថខោ + អស្ស)

ស្វាហំ < (សោ + អហំ)

យាវតក្វស្ស < (យាវតកោ + អស្ស)

ចំណាំ ស្រៈ ឧ ឩ ឱ ដែលអាទេសជា វ នេះ បានចំពោះតែពេលណាដែលព្យញ្ជនៈដូចជា ក, ខ, ត, ថ, ទ, យ, ស, ហ អាស្រ័យជាមួយប៉ុណ្ណោះ ។

*ប៉ុន្តែពេលខ្លះមិនត្រូវធ្វើអាទេសទេ គឺលុបស្រៈចុងចេញតាមសរៈ-លោបសន្ធិ ដូចជា*

**ហេតុត្តោ** < (**ហេតុ** + **អត្តោ**), **បិស្ស** < (**បិ** + **អស្ស**)

**កោសិ** < (**កោ** + **អសិ**), **ធាតុត្តោ** < (**ធាតុ** + **អត្តោ**)

**កិលន្តោស្មិ** < (**កិលន្តោ** + **អស្មិ**), **តេហំ** < (**តេ** + **អហំ**)

*តែជួនកាលលុបស្រៈដើមតាមបុព្វសរលោបសន្ធិដូចជា*

**ហេតិន្ទ្រិយានិ** < (**ហេតុ** + **ឥន្ទ្រិយានិ**)

**ខន្ធធាតាយតនានិ** < (**ខន្ធធាតុ** + **អាយតនានិ**)

*ខ.* **បរសរាទេសសន្ធិ** *បានដល់ ការតដោយផ្លាស់ស្រៈចុងជាព្យញ្ជនៈ ។*

*ផ្លាស់ស្រៈ* **ឯ** *ជា* **រិ** *តែក៏ត្រូវរស្សៈស្រៈដើមផងដែរដូចជា*

**យថរិវ** < (**យថា** + **ឯវ**), **តថរិវ** < (**តថា** + **ឯវ**)

## ១.៣ សរាគមសន្ធិ

**សរាគមសន្ធិ** *បានដល់ សន្ធិខ្លះដែលមានការតដោយចុះស្រៈថែម ។ ស្រៈដែលប្រើជាអាគមមានពីរគឺស្រៈ* **អ ឱ** *។*

*ក. បើ* **ឱ** *ជាស្រៈដើមនិងបទចុងជាព្យញ្ជនៈ អាចលុបស្រៈ* **ឱ** *ហើយចុះ* **អ** *អាគមវិញដូចជា*

**សសីលោ** < ( សោ + **សីលោ** ), **សបញ្ញោ** < ( សោ + **បញ្ញោ** )

**ឯសធម្មោ** < ( ឯសោ + **ធម្មោ** ), **សមុនិ** < ( សោ + **មុនិ** )

*ខ. បើ អ ជាស្រៈដើមនិងបទចុងជាព្យញ្ជនៈ អាចលុបស្រៈ អ ហើយចុះ ឱ អាគមមកវិញដូចជា*

**បរោសហស្សំ** < ( បរ + **សហស្សំ** )

**សរោសតំ** < ( សរ + **សតំ** )

*ឧទាហរណ៍ខាងលើនេះមិនមែនជាសរសន្ធិទេ គឺជាព្យញ្ជនសន្ធិ ព្រោះយកព្យញ្ជនៈនៃបទចុងធ្វើជានិមិត្តដើម្បីលុបស្រៈខាងដើម (មានអធិប្បាយនៅខាងមុខ) តែដោយសារអាគមដែលចុះជាស្រៈ ទើបយកមកពោលក្នុងនេះដើម្បីឱ្យត្រូវនឹងឈ្មោះថា* **សាគមសន្ធិ** ។

## ១.៤ សរវិការសន្ធិ

**សរវិការសន្ធិ** *បានដល់ សន្ធិខ្លះដែលមានការតដោយផ្លាស់ស្រៈឱ្យក្លាយចាករូបដើមទៅជាស្រៈដទៃ (ផ្សេងពីអាទេសដែលផ្លាស់ស្រៈជាព្យញ្ជនៈ) មាន ២ យ៉ាងគឺ* **បុព្វសរវិការសន្ធិ** *និង* **បរសរវិការសន្ធិ** ។ *វិការសន្ធិនេះប្រព្រឹត្តឡើងនៅពេលដែលស្រៈទាំងពីរមិនស្មើគ្នា បើស្រៈ អ ឬ អា ផ្សំនឹងស្រៈ ឥ ឬ ឦ ក្លាយជា ឯ និងស្រៈ (អ + ឧ ឬ ឩ) > ឱ ។*

ក. **បុព្វសរវិការសន្ធិ** បានដល់ ការតដោយផ្លាស់ស្រៈដើមឱ្យទៅជាស្រៈដទៃ ។

ក.១ បើស្រៈដើមជា ឥ ឬ ឦ វិការៈជា ឯ ហើយលុបស្រៈចុងដូចជា

**មុនេលយោ** < ( **មុនិ** + **អាលយោ** )

**អតេវញ្ញោហិ** < ( **អតិ** + **ឥវ** + **អញ្ញោហិ** )

ក.២ បើស្រៈដើមជា ឧ ឬ ឩ វិការៈជា ឱ ហើយលុបស្រៈចុងដូចជា

**សោត្ថិ** < ( **សុ** + **អត្ថិ** )

ខ. **បរសរវិការសន្ធិ** បានដល់ ការតដោយផ្លាស់ស្រៈចុងឱ្យទៅជាស្រៈដទៃ ។

ខ.១ បើស្រៈចុងជា ឥ ឬ ឦ វិការៈជា ឯ រួចលុបស្រៈដើមចេញដូចជា

**ពន្ធុស្សេវ** < ( **ពន្ធុស្ស** + **ឥវ** ), **ជិនេរិតំ** < ( **ជិន** + **ឦរិតំ** )

**ឧបេក្ខតិ** < ( **ឧប** + **ឥក្ខតិ** ), **តស្សេជំ** < ( **តស្ស** + **ឥជំ** )

ខ.២ បើស្រៈចុងជា ឧ ឬ ឩ វិការៈជា ឱ រួចលុបស្រៈដើមចេញដូច

**ចន្ទោទយោ** < ( **ចន្ទ** + **ឧទយោ** ), **នោបេតិ** < ( **ន** + **ឧបេតិ** )

**ឧទកោមិ** < ( **ឧទក** + **ឩមិ** ), **កាត្តោទកំ** < ( **កាត្ត** + **ឧទកំ** )

**យថោទកេ** < ( **យថា** + **ឧទកេ** )

ខ.៣ ប្រសិនបើស្រៈចុងមានព្យញ្ជនសំយោគគឺតម្រួតគ្នា នោះពុំចាំបាច់វិការៈទេដូចជា

**ជីវិតិន្ទ្រិយំ** < (ជីវិត + ឥន្ទ្រិយំ)

**ពុទ្ធុប្បាទោ** < (ពុទ្ធ + ឧប្បាទោ)

**ចិត្តុប្បាទោ** < (ចិត្ត + ឧប្បាទោ)

**ទេវិន្ទោ** < (ទេវ + ឥន្ទោ)

*សរវិការសន្ធិនេះអាចចាត់ថាជាសរលោបសន្ធិក៏បានដែរ ប៉ុន្តែបើតាមក្រិត្យ កាលណាស្រៈ អ ឬ អា ធ្វើសន្ធិជាមួយស្រៈ ឥ ឬ ឦ ត្រូវក្លាយជាស្រៈ ឯ និងបើស្រៈ អ ឬ អា ជាមួយនឹង ឧ ឬ ឩ ក្លាយជា ឱ ដូចមានឧទាហរណ៍ខាងលើស្រាប់ ។*

## ១.៨ សរបកតិសន្ធិ

***សរបកតិសន្ធិ*** *បានដល់ សន្ធិខ្លះដែលមានការតដោយទុកស្រៈឱ្យនៅដូចដើម មានតែមួយបែបទេដូចជា*

**កោ ឥមំ** < (កោ + ឥមំ)

**មច្ចុនោ បជំ** < (មច្ចុនោ + បជំ)

**នោ អតិក្កមោ** < (នោ + អតិក្កមោ)

**អថ ខោ អាយស្មា** < (អថ ខោ + អាយស្មា)

*បទសន្ធិនេះបុរាណមិនសរសេរជាប់គ្នាទេ ប៉ុន្តែលោកចាត់ជាបទសន្ធិដែរ ។*

## ១.៦ សរទីឃសន្ធិ

***សរទីឃសន្ធិ*** *បានដល់ បទសន្ធិខ្លះដែលមានការតដោយធ្វើស្រៈឱ្យវែង មានពីរយ៉ាងគឺ* ***បុព្វសរទីឃសន្ធិ*** *និង* ***បរសរទីឃសន្ធិ*** *។*

*ក.* ***បុព្វសរទីឃសន្ធិ*** *បានដល់ ការតដោយទីឃៈស្រៈដើម គឺបើស្រៈទាំងពីរមិនស្មើគ្នាទេ អាចទីឃៈស្រៈដើមបាន តែត្រូវលុបស្រៈចុងចេញដូចជា*

**សាធូតិ** < (**សាធុ** + **ឥតិ**), **វិជ្ជូវ** < (**វិជ្ជុ** + **ឥវ**)
**កឹសូធ** < (**កឹសុ** + **ឥធ**), **វីតិជាមេតិ** < (**វិ** + **អតិជាមេតិ**)
**ទេវាតិ** < (**ទេវ** + **ឥតិ**), **លោកស្សាតិ** < (**លោកស្ស** + **ឥតិ**)

*ខ.* ***បរសរទីឃសន្ធិ*** *បានដល់ ការតដោយទីឃៈស្រៈចុង គឺបើស្រៈទាំងពីរមិនស្មើគ្នាទេ អាចទីឃៈស្រៈចុងបាន តែត្រូវលុបស្រៈដើមចេញដូចជា*

**ឥធាជាហំ** < (**ឥធាជិ** + **អហំ**),
**តថូបមំ** < (**តថា** + **ឧបមំ**)
**អប្បស្សុតាយំ** < (**អប្បស្សុតោ** + **អយំ**)
**សចាយំ** < (**សចេ** + **អយំ**)

*គ. បើស្រៈទាំងពីរស្មើគ្នា ភាគច្រើនទីឃៈស្រៈចុង ប៉ុន្តែត្រូវលុបស្រៈដើមចេញ ដូចជា*

**តទាហំ** < (**តទា** + **អហំ**), **តត្រាយំ** < (**តត្រ** + **អយំ**)

**ពហូបការោ** < (**ពហុ** + **ឧបការោ**)

**យានីធ** < (**យានិ** + **ឥធ**)

## ១.៧ សររស្សសន្ធិ

*សររស្សសន្ធិ បានដល់ បទសន្ធិខ្លះដែលមានការតដោយធ្វើស្រៈឱ្យខ្លី មានពីរយ៉ាងគឺ* ***បុព្វសររស្សសន្ធិ*** *និង* ***បរសររស្សសន្ធិ*** *។*

*ក.* ***បុព្វសររស្សសន្ធិ*** *បានដល់ ការតដោយរស្សៈស្រៈដើម គឺបើស្រៈទាំងពីរជាស្រៈទីឃៈ អាចរស្សៈស្រៈដើមបាន ដូចជា*

**យថរិវ** < (**យថា** + **ឯវ**), **តថរិវ** < (**តថា** + **ឯវ**)

*ទាំងទីឃសរសន្ធិនិងរស្សសរសន្ធិត្រូវប្រើវិធីលោបសន្ធិផងដែរ ។*

## ១.៨ សរវិបរិតោសន្ធិ

*សរវិបរិតោសន្ធិ បានដល់ សន្ធិខ្លះដែលផ្លាស់ព្យញ្ជនៈឱ្យត្រឡប់ជាស្រៈវិញគឺ អវ* > (**ឧ**, **ឩ**, **ឱ**) *ដូចជា*

**ឧញ្ញាតំ** < (*អវ* + **ញាតំ**), **ឩហាតោ** < (*អវ* + **ហាតោ**)

**ឱនទ្ធា** < (*អវ* + **នទ្ធា**), **ឱវទតិ** < (*អវ* + **វទតិ**)

**(*សរសន្ធិចប់*)**

# អសន្ធិ

**អសន្ធិ** បានដល់ បទសន្ធិណាដែលលោកមិនមានបំណងឱ្យធ្វើសន្ធិ គឺតបទចូលគ្នាជាមួយបទដូចក្នុងករណីតទៅនេះ

១. បើបទដើមជាស័ព្ទអាលបនៈនិងមិនមាន **ឥតិ** ជាបទចុង ឬមិននៅក្នុងឆ័ន្ទទេ ដូចជា

**( សារិបុត្ត + ឥធេកច្ចោ ) = សារិបុត្ត ឥធេកច្ចោ**

២. បើស្រៈដើមជាទីឃៈនិងដែលមិនមែនជាបទសមាស រួមទាំងស័ព្ទនិបាតដែលមានទីបំផុតជាស្រៈទីឃៈផងដែរ ដូចជា

**( គាថា + អជ្ឈភាសិ ) = គាថា អជ្ឈភាសិ**

**( អបេ + អបាម្ហិ ) = អបេ អបាម្ហិ**

៣. បើស្រៈដើមជា **ឥ ឧ** និងមានកិរិយាស័ព្ទប្រាប់អតីតកាលជាបទចុងដូចជា

**( គាថាហិ + អជ្ឈភាសិ ) = គាថាហិ អជ្ឈភាសិ**

**( សត្ថុ + អបាសិ ) = សត្ថុ អបាសិ**

៤. ក្នុងទីដែលនឹងខូចឆ័ន្ទ ឬក្នុងទីដែលសូត្រមិនស្រួល ដូចជា

**សព្វេ សង្ខារា អនិច្ចា យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

ក្នុងឧទាហរណ៍នេះជាគាថាដែលមាន ៤ បាទ ។ ត្រង់ចុងបាទទី

២ គឺស្រៈ **ឥ** នៃបទថា **បស្សតិ** លោកមិនធ្វើសន្ធិជាមួយ **អថ** នៃបទដើមរបស់បាទទី ៣ ទៅជា **បស្សត្យាថ** ទេ ។ ពីព្រោះវេលាសូត្រមកដល់ត្រង់ចុងបាទទី ២ នេះលោកឱ្យបង្អង់ការសូត្របន្តិច គឺយតិកាលដើម្បីបញ្ចប់វគ្គ ។

៥. ក្នុងទីដែលមិនមានបំណងធ្វើសន្ធិ ។

## វិធីប្រែសន្ធិស័ព្ទ

កាលបើបានជួបបទសន្ធិនៅក្នុងប្រយោគណាមួយ មុននឹងប្រែស័ព្ទសន្ធិនោះ ៗ ត្រូវចងចាំចំណុចសំខាន់ ៣ ប្រការដូចខាងក្រោមនេះ

១. បទសន្ធិណាដែលមិនមែនជាបទសមាស (មានអធិប្បាយនៅខាងមុខ) ឬមិនមានឧបសគ្គនាំមុខទេ វេលាប្រែត្រូវញែកចេញពីគ្នាតាមស័ព្ទដើមសិន ទើបប្រែដូចជា **ឯសធម្មោ** > **ឯសោ ធម្មោ**, **ចត្តារីមានិ** > **ចត្តារិ ឥមានិ**, **ម្យាយំ** > **មេ អយំ** យ៉ាងនេះជាដើម ។

២. ប្រសិនបើបទសន្ធិនោះ ៗ ជាបទសមាស នោះពុំចាំបាច់ញែកចេញពីគ្នាទេ ពីព្រោះសមាសជាវិធីបំព្រួញស័ព្ទចាប់ពីពីរបទឡើងទៅចូលគ្នាដើម្បីធ្វើឱ្យខ្លី ក្លាយជាស័ព្ទថ្មីមួយទៅហើយ មិនប្រាថ្នាឱ្យញែកចេញវិញទេ ។ វេលាប្រែត្រូវប្រែតាមបែបសមាសនោះ ៗ ដូចជា

**កតោបការោ** (មកពី **កត** + **ឧបការ**) ប្រែថា "អ្នកមានឧបការគុណដែលធ្វើហើយ" ដូច្នេះជាដើម ។

៣. ប្រសិនបើមានបទឧបសគ្គនាំមុខក៏ពុំចាំបាច់ញែកដែរ ដូចជា **សុចរិត** =ប្រព្រឹត្តល្អ, **ទុច្ចរិត** =ប្រព្រឹត្តអាក្រក់, ដូច្នេះជាដើម ។

## នាមស័ព្ទ (ត)

| ស័ព្ទលី | ពាក្យប្រែ |
|---|---|
| **លង្កាទីប** បុំ. | កោះលង្កា |
| **លង្កិក** គុ. | អ្នកកោះលង្កា |
| **ចេតិយង្គណ** នបុំ. | ឃឿនចេតិយ៍ |
| **សព្វបឋមំ** និ. | ដំបូងបំផុត |
| **និពទ្ធំ** និ. | ជានិច្ច |
| **វេសាលិកាសី** បុំ. | អ្នកស្រុកវេសាលី |
| **រោគុបទ្ទវ** បុំ. | អន្តរាយដោយរោគ |
| **ទេហនិស្សិត** គុ. | អាស្រ័យក្នុងកាយ |
| **សត្ថសាលា** ឥ. | សាលារៀន |
| **កុម្ភឃោសក** បុំ. | (ឈ្មោះ) |

## ធាតុស័ព្ទ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| និ + ធិប | ទុក, ទុកដាក់ | ប + ពុធ | រលឹក, តើន |
| ភជ | ចែក | អន្តរ + ធេ | បាត់ទៅ, សូន្យទៅ |
| ការ | សង់, ធ្វើ | ប + ញា | តាក់តែង, ចាត់ចែង |
| អភិ + ហារ | នាំមក | វិ + ហាធ | បៀតបៀន |

## លំហាត់នៃមេរៀនទី ៤៤

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើសន្ធិមានប៉ុន្មានយ៉ាង គឺសន្ធិអ្វីខ្លះ ?

២. តើសន្ធិកិរិយោបករណ៍មានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

៣. តើសរសន្ធិជាការតដូចម្ដេច ?

៤. តើសរសន្ធិប្រើឧបករណ៍បានប៉ុន្មានយ៉ាង គឺឧបករណ៍អ្វីខ្លះ ?

៥. តើសរលោបសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

៦. តើសរាទេសសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

៧. តើសរវិការសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

៨. តើបកតិសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

*៩. តើសរាគមសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។*

*១០. តើសរទីឃសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។*

*១១. តើសររស្សសន្ធិមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។*

*១២. តើសរវិបរិតោសន្ធិជាសន្ធិដូចម្តេច ?*

*ខ. ចូរប្រែប្រយោគខាងក្រោមនេះជាភាសាខ្មែរ និងចូរញែកបទណាដែលជាបទសន្ធិ ។ សូមជ្រាបថាបទសន្ធិខ្លះជាព្យញ្ជនសន្ធិឬនិគ្គហិតសន្ធិដែលមានពោលក្នុងមេរៀនបន្ទាប់ ។*

១. តេសំ ទ្វិន្នំ និវេសនេសុ ពហុន្នំ ភិក្ខូនំ បញ្ញត្តានេវាសនានិ ហោន្តិ ។

២. បុត្តា មត្ថិ ធនម្មត្ថិ ឥតិ ពាលោ វិហញ្ញតិ ។

៣. បុរា វេសាលិវាសីនំ មហន្តោ រោគុបទ្ទវោ អហោសិ ។

៤. សព្វេ មយំ ធម្មំ សុត្វា តំ សាធុកំ មនសិ ករិស្សាម ។

៥. សព្វម្បិទំ អម្ហាកំ គេហនិស្សិតំ វិនស្សតិ ។

៦. "នោហេតំ ភន្តេ"តិ ភិក្ខូ ភគវតោ វទឹសុ ។

៧. ទាសេនាហដានិ ទារូនិ គហេត្វា ទាសី យាគុំ បចិ ។

៨. យទាហំ នគរំ អគមាសឹ តទេកោ បុរិសោ មម ឆត្តំ គណ្ហិ ។

៩. ទារកា បុប្ផានោចិតុំ វនំ គន្ត្វា សេតានិបិ នីលានិបិ បុប្ផានាហរឹសុ ។

១០. "តេន អាវុសោ គណ្ហាថ មេ បត្តចីវរ"ន្តិ ថេរោ អាហ ។

១១. ថេរោ ធាសាយ តេលំ អាសិញ្ចន្តោ និសិន្នកោរ អាសិញ្ចិត្វា អង្គោតាមំ ចារិសិ ។

១២. អធាថបិណ្ឌិកោបិ វិសាខាបិ មហាឧកាសិកា និពទ្ធំ ធិវស្ស ទ្វេ វារេ តថាគតស្សុបដ្ឋានំ គច្ឆន្តិ ។

១៣. ឧត្តណ្ហិតុកាមា ធារកា ចាគោរុដ្ឋាយ តិពិត្វា កុញ្ចិត្វា សត្តសាលំ គច្ឆន្តិ ។

១៤. កុម្ភឃោសកោរ កាលស្សេវ វុដ្ឋាយ រាជគហានគរេ កម្មការេ បពោធេសិ ។

១៥. មហាមហិន្ទត្ថេរោ អញ្ញេហិ ចតូហិ បព្វជិតេហិ សទ្ធឹ លង្កាធីបំ អាគន្ត្វា ជិនេរិតំ សទ្ធម្មំ លង្កិកានំ ទេសេសិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី និង ចូរចងជាបទសន្ធិ ចំពោះបទណាដែលអាចចងបាន ។*

*១. ខ្ញុំ បានទៅហើយ កាន់ភូមិ, សំឡាញ់ របស់ខ្ញុំ ម្នាក់ បានឱ្យហើយ នូវសៀវភៅ ដល់ខ្ញុំ ។*

*២. សត្វ.ទ. ទាំងពួង កាលលះ នូវកាយ របស់គេ.ទ. ក្នុងទីបំផុតនៃជីវិត បាត់ទៅ ។*

*៣. ក្មេងស្រី.ទ. នាំមកហើយ នូវផ្កា.ទ. ពណ៌ខៀវនិងក្រហម ឱ្យហើយ ដល់ម្ដាយនិងឪពុក របស់ពួកគេ.ទ. ។*

*៤. ផ្លែស្វាយ.ទ. ដប់ផ្លែ គឺឪពុក ទិញហើយ គឺម្ដាយ ចែកហើយ ដល់*

កូនប្រុសនិងកូនស្រី.ទ. ។

៥. អាសនៈ.ទ. ច្រើន គឺគេ ចាត់ចែងហើយ សម្រាប់ភិក្ខុ.ទ. ក្នុងវត្តជេតវ័ន ។

៦. ព្រះសារីបុត្តត្ថេរ បានពោល ដល់ភិក្ខុ.ទ. ថា "ម្នាលអាវុសោ មិនដូច្នោះទេ" ។

៧. ព្រះមហាថេរៈ បានពោល ដល់អ្នកស្រុក.ទ. ថា "ថ្ងៃស្អែក យើងនឹងទៅ កាន់សាវត្ថី" ។

៨. ភិក្ខុ តែងតើន ពីព្រលឹម ចាប់ផ្ដើម ដើម្បីបោស នូវខឿន ជុំវិញនៃចេតិយ៍ ។

៩. ព្រះធម៌ គឺព្រះពុទ្ធ សំដែងហើយ គឺសរសេរ ដំបូងបំផុត ក្នុងសៀវភៅ ក្នុងរជ្ជកាល នៃព្រះបាទវដ្ដគាមនី អភយ នៃលង្កា ។

១០. ខ្ញុំ កាលមាន នូវជំងឺ ទទួលទានហើយ នូវថ្នាំ ពីគ្រូពេទ្យ អស់២០ថ្ងៃ ខ្ញុំ ជាហើយ ។

១១. លោកសេដ្ឋី អនាថបិណ្ឌិក និង ឧបាសិកាវិសាខា សង់ហើយ នូវវត្ត ពីរ ជិតក្រុងសាវត្ថី ថ្វាយហើយ នូវវត្តពីរនោះ ដល់ព្រះពុទ្ធ ។

១២. ព្រះពុទ្ធ សំដែងហើយ ដល់ជនទាំងពួង ណា មកហើយ កាន់វត្ត ។

១៣. ព្រះពុទ្ធ ប្រថាប់ហើយ ក្នុងវត្តទាំងពីរនោះ អស់២៦វស្សា និងទទួល នូវការឧបត្ថម្ភ ពីគ្រួរសារ ទាំងពីរ ។

១៤. មិគារៈ ឪពុកក្មេក របស់នាងវិសាខា ទុកហើយ នូវនាង ក្នុងនាទីជា

ម្ដាយ របស់គាត់, នាង គឺនាំមក នូវឈ្មោះថា "មិគារមាតា" ។

(ចប់មេរៀនទី ៤៤)

## កំណាព្យដាស់តឿនស្មារតី

ព្រលឹតលូតវែងកុំភ្លេចទឹក  បណ្ឌិតចេះសន្ធឹកកុំភ្លេចគ្រូ ។

# មេរៀនទី ៨៥

# អធិប្បាយអំពីសន្ធិ (តចប់) និង ព្យញ្ជនាគមវិធី, ព្យញ្ជនាទេសវិធី

## ២. ព្យញ្ជនសន្ធិ

(Consonantal Combination)

*ពាក្យថាព្យញ្ជនសន្ធិនេះ មិនមែនជាការតព្យញ្ជនៈនិងព្យញ្ជនៈទេ បានដល់ ការតស្រៈនិងព្យញ្ជនៈ ព្រោះយកព្យញ្ជនៈនៃបទចុងធ្វើជានិមិត្ត បានសេចក្ដីថាបទដើមជាស្រៈ គឺដូចគ្នានឹងសរសន្ធិដែរ ។ ប៉ុន្តែមានបទចុងជាពាក្យផ្ដើមដោយព្យញ្ជនៈ ដូចជា* **ខគ្គ**, **បិត**, **ជោតិ**, **ភិក្ខុ**, **កុមារ**, **សេដ្ឋី**, **មាស**, **បុរិស** *ជាដើម ។ ពាក្យដូច្នេះហៅថាផ្ដើមដោយព្យញ្ជនៈ ។*

*សន្ធិនេះប្រើសន្ធិកិរិយោបករណ៍ ៤ យ៉ាងគឺ* **ឱយោ**, **រស្សោ**, **សំយោគោ**, **បកតិ** *។*

## ២.១ សរទីឃព្យញ្ជនសន្ធិ

**សរទីឃព្យញ្ជនសន្ធិ** *បានដល់ បទសន្ធិដែលមានការតដោយ*

*ទីឃៈស្រៈដើម ប្រសិនបើស្រៈដើមជាស្រៈរស្សៈ មិនមែនទីឃៈព្យញ្ជនៈទេ ពីព្រោះព្យញ្ជនៈមិនអាចទីឃៈបាន ។ ប៉ុន្តែដោយសារបទចុងផ្តើមដោយព្យញ្ជនៈ ទើបហៅថា* **សរទីឃព្យញ្ជនសន្ធិ** *ដូចជា*

**ស្វារក្ខំ < ( សុ + រក្ខំ ), និព្វត្តតី ទុក្ខំ < ( និព្វត្តតិ + ទុក្ខំ )**
**ខន្តី បរមំ < ( ខន្តិ + បរមំ ), មុនី ចរេ < ( មុនិ + ចរេ )**
**មញ្ញតី ពាលោ < ( មញ្ញតិ + ពាលោ ), ទូរក្ខំ < ( ទុ + រក្ខំ )**

## ២.២ សររស្សព្យញ្ជនសន្ធិ

**សររស្សព្យញ្ជនសន្ធិ** *បានដល់ បទសន្ធិដែលមានការតដោយរស្សៈស្រៈដើម ប្រសិនបើស្រៈដើមជាស្រៈទីឃៈ ជាមួយបទចុងដែលជាព្យញ្ជនៈ មិនមែនរស្សៈព្យញ្ជនៈទេ ទើបហៅថា* **សររស្សព្យញ្ជនសន្ធិ** *ដូចជា*

**ភោវាទិ នាម < ( ភោវាទី + នាម )**
**យិដ្ឋំ វ ហុតំ វ < ( យិដ្ឋំ វា + ហុតំ វា )**
**យថាភាវិ គុណេន សោ < ( យថា + ភាវី + គុណេន សោ )**

*ចំពោះ* **សោ** *និង* **ឯសោ** *ត្រូវលុបស្រៈ* **ឱ** *នៃ* **សោ** *និង* **ឯសោ** *ហើយចុះ* **អ** *អាគមវិញដូចជា*

ឯស ធម្មោ < (ឯសោ + ធម្មោ)

ស មុនិ < (សោ + មុនិ)

ស សីលវា < (សោ + សីលវា)

ឯស បត្តោ < (ឯសោ + បត្តោ)

## ២.៣ សំយោគព្យញ្ជនសន្ធិ

*ពាក្យថា* **សំយោគ** *ប្រែថា "តម្រួត" ដូច្នេះសន្ធិនេះ បានដល់ការតបទដោយការតម្រួតព្យញ្ជនៈបទចុងជាពីរតួ ដែលមាន ២ បែបគឺ* **សទិសព្យញ្ជនសំយោគសន្ធិ, អសទិសព្យញ្ជនសំយោគសន្ធិ ។**

*ក.* **សទិសព្យញ្ជនសំយោគសន្ធិ** *បានដល់ ការតដោយធ្វើការតម្រួតព្យញ្ជនៈដែលមានរូបស្មើគ្នា ឧទាហរណ៍* **ក** *តម្រួតជា* **ក្ក, គ** *តម្រួតជា* **គ្គ** *ជាដើម ដូចជា*

ទុក្ការំ < (ទុ + ការំ), អនុគ្គហោ < (អនុ + គហោ)

បរិច្ចជតិ < (បរិ + ចជតិ), វិញ្ញាណំ < (វិ + ញាណំ)

ឧបទ្ទវោ < (ឧប + ទវោ), ឥធប្បមាទោ < (ឥធ + បមាទោ)

និម្មលោ < (និ + មលោ), អប្បស្សុតោ < (អប្ប + សុតោ)

*ខ.* **អសទិសព្យញ្ជនសំយោគសន្ធិ** *បានដល់ ការតដោយការ*

តម្រួតព្យញ្ជនៈដែលមានរូបមិនស្មើគ្នា ឧទាហរណ៍ ដ តម្រួតជា ដ្ឋ, ប តម្រួតជា ប្ផ ជាដើមដូចជា

តត្រដ្ឋិតោ < (តត្រ + ឋិតោ), និប្ផលំ < (និ + ផលំ)

រូបក្ខន្ធោ < (រូប + ខន្ធោ), សេតច្ឆត្តំ < (សេត + ឆត្តំ)

និជ្ជរោ < (និ + ជរោ), សុប្បតិដ្ឋិតោ < (សុ + បតិដ្ឋិតោ)

ទុព្ភិក្ខំ < (ទុ + ភិក្ខំ), បឋមជ្ឈានំ < (បឋម + ឈានំ)

គ. ប្រសិនបើស្រៈដើមជាទីឃៈ រមែងត្រូវរស្សៈដូចជា

បរក្កមោ < (បរា + កមោ), អសាទោ < (អា + សាទោ),

មហប្ផលំ < (មហា + ផលំ), យថក្កមំ < (យថា + កមំ)

តណ្ហក្ខយោ < (តណ្ហា + ខយោ), អក្ខាតោ < (អា + ខាតោ)

ឃ. ទោះជាយ៉ាងណាក៏ដោយក្នុងភាសានីមួយ ៗ តែងមានការលើកលែង គឺមិនធ្វើតាមចំណុចគខាងលើបានដូចជា

វេទនាខន្ធោ < (វេទនា + ខន្ធោ)

សញ្ញាក្ខន្ធោ < (សញ្ញា + ខន្ធោ)

ង. ប្រសិនបើព្យញ្ជនៈជា វ ត្រូវតម្រួតជា ព្វ ដូចជា

និព្វាយតិ < (និ + វាយតិ), និព្វានំ < (និ + វានំ)

ទុព្វិនិច្ឆយោ < (ទុ + វិនិច្ឆយោ)

ច. ប្រសិនបើមានព្យញ្ជនៈតម្រួតគ្នា ៣ តួ ត្រូវលុបតួណាដែលដូចគ្នាមួយតួចេញ ដូចជា

អគ្យាគារំ < អគ្គ្យាគារំ < (អគ្គិ + អាគារំ)

សោត្យត្ថុ < សោត្ថ្យត្ថុ < (សោត្ថិ + អត្ថុ)

វុត្យស្ស < វុត្ត្យស្ស < (វុត្តិ + អស្ស)

សូមសង្កេតមើលព្យញ្ជនសំយោគសន្ធិនេះ និយមប្រើជាមួយបទសន្ធិណាដែលមានបទដើមជាឧបសគ្គសព្ទ ។ ការធ្វើទ្វេភាវៈគឺការធ្វើអក្សរឲ្យទៅជាពីរតួដូចមានខាងលើនេះ គឺធ្វើឡើងដើម្បីឱ្យងាយស្រួលដល់ការពោល ធ្វើឱ្យមានសំឡេងតជាប់គ្នាមិនដាច់ ចៀសវាងការរអាក់រអួល ។

## ២.៤ បកតិព្យញ្ជនសន្ធិ

**បកាតិព្យញ្ជនសន្ធិ** បានដល់ ការតដោយទុកឱ្យនៅតាមរូបដើម គឺរក្សាស្រៈដើមនិងព្យញ្ជនៈនៃបទចុងឱ្យនៅដូចដើម ដូចជា

មនោបុព្វង្គមា ធម្មា < (មនោបុព្វង្គមា ធម្មា)

តិណ្ណោ ចារង្គតោ < (តិណ្ណោ ចារង្គតោ)

មច្ចុនោ បជំ < (មច្ចុនោ បជំ)

សាធុ ទស្សនំ < (សាធុ ទស្សនំ)

(ព្យញ្ជនសន្ធិចប់)

# ៤. និគ្គហិតសន្ធិ ឬ វោមិស្សកសន្ធិ

(Mixed Combination)

**និគ្គហិតសន្ធិ** *បានដល់ ការតស័ព្ទដែលមានបទដើមមានទីបំផុតជានិគ្គហិត(ំ) ជាមួយនឹងបទចុងដែលផ្ដើមដោយស្រៈឬព្យញ្ជនៈក៏បានដោយប្រើសន្ធិកិរិយោបករណ៍ដូចជា* **អាទេសោ, បកតិ, លោបោ** *ដូចនឹងអធិប្បាយតទៅនេះ*

## ៤.១ និគ្គហិតាទេសសន្ធិ

**និគ្គហិតាទេសសន្ធិ** *បានដល់ បទសន្ធិដែលមានការតដោយធ្វើអាទេសនិគ្គហិតរបស់បទដើមទៅជាព្យញ្ជនៈ គឺ*

*៤.១.១ បើបទចុងផ្ដើមជាមួយព្យញ្ជនៈវគ្គ និយមធ្វើអាទេសនិគ្គហិតជាវគ្គន្តព្យញ្ជនៈ គឺព្យញ្ជនៈទី ៥ នៃវគ្គនោះ ៗ ដូចជា*

**ទីបង្ករោ** < (**ទីបំ** + **ករោ**), **ឯវម្មេ សុតំ** < (**ឯវំ** + **មេ សុតំ**)

**រណញ្ជហោ** < (**រណំ** + **ជហោ**), **សណ្ឋានំ** < (**សំ** + **ឋានំ**)

**អមតន្ទទោ** < (**អមតំ** + **ទទោ**), **តម្ផលំ** < (**តំ** + **ផលំ**)

**សយញ្ជាតោ** < (**សយំ** + **ជាតោ**), **តន្ធនំ** < (**តំ** + **ធនំ**)

*៤.១.២ បើបទចុងជា* **យ** *ធ្វើអាទេសនិគ្គហិតនិង* **យ** *ជា* **ញ្ញ** *ដូចជា*

**សញ្ញោគោ** < (**សំ** + **យោគោ**), **យញ្ញទេវ** < (**យំ** + **យទេវ**)

សញ្ញោជនំ <(សំ + យោជនំ), តេសញ្ញេវ <(តេសំ + យេវ)

អានន្តរិកញ្ញំ អាហុ <(អានន្តរិកំ + យំ + អាហុ)

*៤.១.៣ បើបទចុងជា ល ធ្វើអាទេសនិគ្គហិតនិង ល ជា ល្ល ដូចជា*

សល្លហុកោ <(សំ + លហុកោ), បុល្លិង្គំ <(បុំ + លិង្គំ)

បដិសល្លីនោ <(បដិ + សំ + លីនោ)

*៤.១.៤ បើបទចុងជា ហ ធ្វើអាទេសនិគ្គហិតជា ញ ដូចជា*

តញ្ហិ តស្ស <(តំ + ហិ តស្ស), ឯវញ្ហិ វោ <(ឯវំ + ហិ វោ)

*៤.១.៥ បើបទចុងជា ឯ ធ្វើអាទេសនិគ្គហិតនិង ឯ ទៅជា ញ្ញ ឬ ជាចុះ យ អាគមដូច*

បច្ចត្តញ្ញេវ <(បច្ចត្តំ + ឯវ), សតញ្ញេវ <(សតំ + ឯវ)

ឯកញ្ញេវ <(ឯកំ + ឯវ), តង្ខណញ្ញេវ <(តំ + ខណំ + ឯវ)

*៤.១.៦ បើបទចុងជាស្រៈ អាចធ្វើអាទេសនិគ្គហិតជា ទ ឬ ម បាន ដូចជា*

ឯតទវោច <(ឯតំ + អវោច), តទន្តា <(តំ + អន្តា)

យទិទំ <(យំ + ឥទំ), កិមេតំ <(កឹ + ឯតំ)

តទត្ថុ <(តំ + អត្ថុ), តមត្ថុ <(តំ + អត្ថុ)

តមហំ <(តំ + អហំ), យមិទំ ឬ យទិទំ <(យំ +ឥទំ)

*៤.១.៧ ស្រៈនៃបទចុងខ្លះត្រូវលុបចេញ ។ ប្រសិនបើលុបស្រៈចុងចេញហើយ អាចធ្វើអាទេសនិគ្គហិតជា ម ឬ ទ ដូចជា*

អភិនន្ទុន្តិ < (អភិនន្ទុំ + ឥតិ),    ចក្កមិវ < (ចក្កំ + ឥវ)
ឧត្តរិម្បិ < (ឧត្តរឹ + អបិ),    ត្វមសិ < (ត្វំ + អសិ)
ហលន្ទានិ < (ហលំ + ឥទានិ),    ឥទម្បិ < (ឥទំ + អបិ)

## ៤.២ និគ្គហិតបកតិសន្ធិ

**និគ្គហិតបកតិសន្ធិ** *បានដល់ បទសន្ធិដែលមានការតដោយការរក្សាទុកនិគ្គហិតឱ្យនៅតាមរូបដើម ទោះបីជាបទចុងជាព្យញ្ជនៈឬស្រៈក៏ដោយ ដូចជា*

សមជំ កតោ < (សមជំ + កតោ),    ធម្មំ ចរេ < (ធម្មំ + ចរេ)
សំយោជនំ < (សំ + យោជនំ),    សំយុត្តំ < (សំ + យុត្តំ)
តំ និព្វុតំ < (តំ + និព្វុតំ),    តំ ពុទ្ធំ < (តំ + ពុទ្ធំ)

## ៤.៣ និគ្គហិតលោបសន្ធិ

**និគ្គហិតលោបសន្ធិ** *បានដល់ បទសន្ធិដែលមានការតដោយការលុបនិគ្គហិតចេញ មាន ២ យ៉ាងគឺ លុបនិគ្គហិតនៃបទដើម និងលុបស្រៈនៃបទចុង ដូចខាងក្រោមនេះ*

*លុបនិគ្គហិតនៃបទដើម និងបើសិនបទចុងជាស្រៈរស្សៈមិនមាន*

ព្យញ្ជនៈតម្រួតនៅជាប់ទេ និយមទីឃៈតាមការគួរដូចជា

**វិទូនក្តំ** < (**វិទូនំ** + **អក្តំ**), **អធាសាហំ** < (**អធាសឹ** + **អហំ**)

**តាសាហំ** < (**តាសំ** + **អហំ**), **ឯវាហំ** < (**ឯវំ** + **អហំ**)

**អរិយសច្ចាន ទស្សនំ** < (**អរិយសច្ចានំ** + **ទស្សនំ**)

**ពុទ្ធាន សាសនំ** < (**ពុទ្ធានំ** + **សាសនំ**)

**(ចប់និគ្គហិតសន្ធិ)**

## ព្យញ្ជនាគមវិធី

(Consonantal Insertions)

តាមពិត វិធីនេះគឺជាសន្ធិទាំងឡាយដែលបានពោលរៀបរាប់នៅខាងលើរួចហើយដែរ ជាពិសេសសរសន្ធិ ។ ប៉ុន្តែក្នុងទីនេះសូមហៅថា **ព្យញ្ជណាគមវិជី** វិញ (បានដល់ វិធីចុះព្យញ្ជនៈជាអាគម គឺចុះតួអក្សរថ្មីថែមចូលមកទៀត) ដោយយល់ឃើញថា បទសន្ធិប្រភេទនេះមិនត្រឹមតែប្រើកិរិយោបករណ៍ដែលមានសម្រាប់ប្រើប៉ុណ្ណោះទេ គឺមានទាំងចុះព្យញ្ជនៈជាអាគមទៀត ។ ព្យញ្ជនៈដែលអាចប្រើជាអាគមនោះគឺ **ក**, **ត**, **ទ**, **ន**, **ម**, **យ**, **រ**, **វ**, **ហ**, **ឡ**, ◌ំ ។

### ១. ចុះ គ អាគម

បគេវ < (បា + ឯវ), អតិប្បគោខោ < (អតិប្ប + ខោ)

បុថគេវ < (បុថ + ឯវ), បុថគយំ < (បុថ + អយំ)

### ២. ចុះ ត អាគម

តស្មាតិហ < (តស្មា + ឥហ), អជ្ជតគ្គេ < (អជ្ជ + អគ្គេ)

### ៣. ចុះ ទ អាគម

អត្តទត្ថោ < (អត្ត + អត្ថោ), តាវទេវ < (តាវ + ឯវ)

សម្មាទញ្ញា < (សម្មា + អញ្ញា), សកិទេវ < (សកិ + ឯវ)

### ៤. ចុះ ន អាគម

ឥតោនាយតិ < (ឥតោ + អាយតិ)

ចិរន្នាយតិ < (ចិរំ + អាយតិ)

### ៥. ចុះ ម អាគម

ឥធមិជ្ឈតិ < (ឥធ + ឥជ្ឈតិ), លហុមេស្សតិ < (លហុ + ឯស្សតិ)

ភាយតិមេវ < (ភាយតិ + ឯវ), កសាមិវ < (កសា + ឥវ)

### ៦. ចុះ យ អាគម

នយិទំ < (ន + ឥទំ), វុឌ្ឍិយេវ < (វុឌ្ឍិ + ឯវ)

នយិមស្ស < (ន + ឥមស្ស), មាយេវំ < (មា + ឯវំ)

យថាយិទំ < (យថា + ឥទំ), សន្តិយេវ < (សន្តិ + ឯវ)

### ៧. ចុះ រ អាគម

និរុត្តរោ < (និ + ឧត្តរោ),   សត្តិរេវ < (សត្តិ + ឯវ)

អារគ្គេរិវ < (អារគ្គេ + ឥវ), បុនរេវ < (បុន + ឯវ)

ធាតុរហោសិ < (ធាតុ + អហោសិ)

ទុរក្ខាតោ < (ទុ + អក្ខាតោ)

### ៨. ចុះ វ អាគម

តិវង្គុលំ < (តិ + អង្គុលំ),   ភទ្ទាវុទិក្ខតិ < (ភទ្ទា + ឧទិក្ខតិ)

បវុច្ចតិ < (ប + ឧច្ចតិ),   ភូវាទាយ < (ភូ + អាទាយ),

វុទិក្ខតិ < (ឧ + ទិក្ខតិ) . *(មានតែ វ ទេអាចចុះខាងដើមបាន)*

### ៩. ចុះ ហ អាគម

សុហុជ្ជុ ច < (សុ + ឧជ្ជុ ច),   បុថហេវ < (បុថ + ឯវ)

សុហុដ្ឋិតំ < (សុ + ឧដ្ឋិតំ)

### ១០.ចុះ ឡ អាគម

ឆឡភិញ្ញា < (ឆ + អភិញ្ញា),   ឆឡំសោ < (ឆ + អំសោ)

### ១១.ចុះ និគ្គហិត អាគម

ចក្ខុំ ឧទបាទិ < (ចក្ខុ + ឧទបាទិ),  អវំសិរោ < (អវ + សិរោ)

យាវញ្ចិធ < (យាវ + ច + ឥធ), អណុំថូលានិ < (អណុ + ថូលានិ)

មនោបុព្វង្គមា < (មនោ + បុព្វ + គមា)

# ព្យញ្ជនាទេសវិធី

## (Interchange of Letters)

*តាមពិតនេះក៏ជាសន្ធិដែរ ហៅថា* **វណ្ណសន្ធិ** *ប៉ុន្តែក្នុងទីនេះឲ្យឈ្មោះថា* **ព្យញ្ជនាទេស** *ព្រោះឃើញមានការផ្លាស់ប្តូរតួអក្សរពីមួយទៅមួយទៀតក្នុងបទតែមួយ ដូចខាងក្រោមនេះ*

*ផ្លាស់* ក *ទៅជា* ខ *ដូចជា* និកមតិ > និខមតិ ។

*ផ្លាស់* ក *ទៅជា* ង *ដូចជា* សកត្តបសុតោ > សងត្តបសុតោ ។

*ផ្លាស់* ខ *ទៅជា* ឃ *ដូចជា* និខណ្ណុ > និឃណ្ណុ ។

*ផ្លាស់* គ *ទៅជា* ក *ដូចជា* កុលុបគោ > កុលុបកោ,
សីសូបគំ > សីសូបកំ ។

*ផ្លាស់* ជ *ទៅជា* ឌ *ដូចជា* បសេនជី > បសេនឌី ។

*ផ្លាស់* ជ *ទៅជា* យ *ដូចជា* និជំបុត្តំ > និយំបុត្តំ ។

*ផ្លាស់* ណ *ទៅជា* ឡ *ដូចជា* តរុណោ > តរុឡោ ។

*ផ្លាស់* ត *ទៅជា* ក *ដូចជា* និយតោ > និយកោ,
ជាមតោ > ជាមកោ ។

*ផ្លាស់* ត *ទៅជា* ដ្ឋ *ដូចជា* ភតោ > ភដ្ឋោ ។

*ផ្លាស់* ត *ទៅជា* ដ *ដូចជា* បហតោ > បហដោ,
ទុក្កតំ > ទុក្កដំ ។

ផ្លាស់ ត ទៅជា ធ ដូចជា គន្តព្វោ > គន្ធព្វោ ។

ផ្លាស់ ត ទៅជា រ ដូចជា អត្តជោ > អត្រជោ ។

ផ្លាស់ ធ ទៅជា ត ដូចជា សុគធោ > សុគតោ,

កុសីធោ > កុសីតោ,

តថាគធោ > តថាគតោ ។

ផ្លាស់ ធ ទៅជា ដ ដូចជា កម្មាសធម្មំ > កម្មាសដម្មំ ។

ផ្លាស់ ធ ទៅជា ទ្រ ដូចជា ភទ្ធោ > ភទ្រោ ។

ផ្លាស់ ធ ទៅជា រ ដូចជា សន្ធិសីធោ > សន្ធិសីរោ ។

ផ្លាស់ ធ ទៅជា ណ ដូចជា បធិធានំ > បណិធានំ ។

ផ្លាស់ ធ ទៅជា ហ ដូចជា រុធិរ > រុហិរ, សាធុ > សាហុ ។

ផ្លាស់ ប ទៅជា ផ ដូចជា និប្បតិ > និប្ផតិ ។

ផ្លាស់ ប ទៅជា ម ដូចជា វនប្បតិ > វនម្បតិ ។

ផ្លាស់ ប ទៅជា វ ដូចជា កាបញ្ញំ > កាវញ្ញំ ។

ផ្លាស់ ម ទៅជា ប ដូចជា (ចិរំ + បវាសី) > ចិរម្បវាសី > ចិរប្បវាសី,

(ហត្ថី + បភិន្នំ) > ហត្ថិម្បភិន្នំ > ហត្ថិប្បភិន្នំ ។

ផ្លាស់ យ ទៅជា ក ដូចជា សយំ > សកំ, សយេ > សកេ ។

ផ្លាស់ យ ទៅជា ជ ដូចជា គវយោ > គវជោ ។

ផ្លាស់ យ ទៅជា ព ដូចជា ជលាយុ > ជលាពុ ។

ផ្លាស់ យ ទៅជា វ ដូចជា អាយុធំ > អាវុធំ,

ទីឃាយុកុមារោ > ទីឃារុកុមារោ ។

*ផ្លាស់ រ ទៅជា ល ដូចជា* បរិបណ្ណោ > បលិបណ្ណោ,

មហាសរោ > មហាសលោ,

បរាយតិ > បលាយតិ ។

*ផ្លាស់ ល ទៅជា ឡ ដូចជា* សីហលោ > សីហឡោ ។

*ផ្លាស់ វ ទៅជា ព ដូចជា* កុវតោ > កុព្វតោ ។

*ផ្លាស់ វ, វិ ទៅជា ប ដូចជា* វិចេស្សតិ > បចេស្សតិ,

បច្ចវេក្ខណា > បច្ចបេក្ខណា ។

## កំណត់សម្គាល់

*សូមអ្នកសិក្សាជ្រាបថា ការផ្លាស់ប្តូរតួអក្សរដូចបានពោលមកខាងលើនេះពុំមែនជាច្បាប់ទូទៅទេ ប៉ុន្តែគួរយល់ដឹងនូវការប្រែប្រួលខ្លះ ៗ ហើយពាក្យខ្លះទៀតសោតអាចប្រើបានទាំងពីរបទដូចជា* **សយំ** *ប្រើជា* **សកំ** *ក៏បាន ។*

*នៅមានការផ្លាស់ប្តូរតួអក្សរដែលជាតួតម្រួតជាច្រើនទៀត ដូចជា* **អត្ថកថា > អដ្ឋកថា, (ពោធិ + អង្គោ) > ពោធ្យង្គោ > ពោជ្ឈង្គោ** *ជាដើម ។ ការផ្លាស់ប្តូរតួអក្សរដែលជាតួតម្រួតនេះពុំសូវជាលំបាកពេកទេ ប្រសិនបើអ្នកសិក្សាយល់ពីព្យញ្ជនសំយោគបានល្អហើយ ។*

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ |
|---|---|
| បេម នបុំ. | សេចក្ដីស្រឡាញ់ |
| តុលា ឥ. | ជ្ញីង, ជញ្ជីង |
| បរិសា ឥ. | បរិស័ទ |
| តណ្ហង្ករោ បុំ. | ព្រះពុទ្ធព្រះនាមតណ្ហង្ករៈ |
| មេធង្ករោ បុំ. | ព្រះពុទ្ធព្រះនាមមេធង្ករៈ |
| សរណង្ករោ បុំ. | ព្រះពុទ្ធព្រះនាមសរណង្ករៈ |
| ទីបង្ករោ បុំ. | ព្រះពុទ្ធព្រះនាមទីបង្ករៈ |
| ចក្កវត្តិ បុំ. | ស្ដេចចក្រព័ត្តិ |
| កិកី បុំ. | សត្វត្រដេវរិច |
| វាលធិ បុំ. | កន្ទុយ |
| ចាមរី បុំ. | គោរោមវែង ៗ |
| វិសារទ បុំ. | សេចក្ដីក្លៀវក្លា |
| វេរ នបុំ. | ពៀរ, វេរា |
| វ្យាម បុំ | ព្យាម (រង្វាស់) |

## ធាតុស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អធិ + អា + វស | នៅគ្រប់គ្រង | បរិ + វជ | វៀរ, ចៀសវៀង |
| សំ + វិទ | មានព្រម | អភិ + ជ្ឈ | ត្រេកអរចំពោះ |
| វិ + ប + មុច | ផុតស្រឡះ | ប + គហ | ផ្គងឡើង |
| វណ្ណ | ចម្រើន, រុងរឿង | អនុ + ឥ | ទៅតាម |

## លំហាត់នៃមេរៀនទី ៤៥

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើព្យញ្ជនសន្ធិមានន័យដូចម្ដេច ?

២. តើព្យញ្ជនសន្ធិប្រើសន្ធិកិរិយោបករណ៍អ្វីខ្លះ ?

៣. តើនិគ្គហិតសន្ធិមានន័យដូចម្ដេច ?

៤. តើនិគ្គហិតសន្ធិប្រើសន្ធិកិរិយោបករណ៍អ្វីខ្លះ ?

៥. តើព្យញ្ជនាគមវិធីជាអ្វី ?

៦. តើព្យញ្ជនៈដែលអាចប្រើជាអាគមមានប៉ុន្មានតួ គឺអ្វីខ្លះ ?

៧. តើព្យញ្ជនាទេសវិធីជាអ្វី ? សូមឱ្យឧទាហរណ៍ខ្លះ ។

### ខ. ចូរធ្វើសន្ធិជាមួយស័ព្ទទាំងឡាយខាងក្រោមនេះ

| | |
|---|---|
| ពហុ + សុតោ | បុគ្គលា + ធម្មទសា |
| សោ + យាតិ | សម្មា + បជានំ |
| ទុ + ករំ | បញ្ច + ឧទ្ធា |
| មហា + ធនោ | សុ + បដិវិទ្ធោ |

*គ. ចូរញែកបទសន្ធិទាំងឡាយខាងក្រោមនេះ*

| | | |
|---|---|---|
| បគ្គហរតិ | បញ្ចិន្ទ្រិយានិ | តាតាតិ |
| មហព្ភរំ | សត្តុត្តមោ | សទ្ធីធ |
| សប្បុរិសោ | សុរិយោទយោ | មិតីរ |
| អស្សាសោ | ធម្មានុស្សតិ | ហន្ទាហំ |
| មហព្ពលោ | អត្រាហំ | តតោហំ |
| វិញ្ញាណក្ខន្ធោ | យានិមានិ | ហតចក្ខុស្មិ |
| អប្បដិបុគ្គលោ | ចត្តារោមេ | នេវ តាវាហំ |
| បគ្គណ្ហាតិ | យ្វាហំ | សម្មទក្ខាតោ |

*ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. សចាយំ កុមារោ អគារំ អជ្ឈាវសតិ រាជា ភវិស្សតិ ចក្កវត្តី ។

២. សម្មា ឥទានាហំ វិហារំ គន្ត្វា ថេរំ តយា កតបណ្ណសាលាយំ និសន្នកំ ទិស្វា អាគតោម្ហិ ។

៣. តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ បញ្ញាវុទ្ធិយា វឌ្ឍិស្សាមាតិ ។

៤. តយោ មេ ភិក្ខវេ តិលាជាសំ វិជ្ជមានា លោកស្មឹ ។បេ។
តយោ មេ តិលានុបមា បុគ្គលា ។

៥. អណ្ឌំ រក្ខន្តី កិកីវ វាលធឹ រក្ខន្តោ ចាមរីវ តុម្ហេបិ សាធុកំ
អត្តនោ សីលំ រក្ខថ ។

៦. យាវតក្វស្ស កាយោ, តាវតក្វស្ស ព្យាមោ ។

៧. ទាយកោ ទានបតិ យញ្ញទេវ បរិសំ ឧបសង្កមតិ ។បេ។
វិសារទោវ ឧបសង្កមតិ ។

៨. អញ្ញាយ ច បនាហំ សមណានំ សក្យបុត្តិយានំ ធម្មំ ឯវាហំ
តស្មា ធម្មវិនយា អបក្កន្តោ ។

៩. តណ្ហង្ករោ មេធង្ករោ សរណង្ករោ ទីបង្ករោ"តិ ចត្តារោ ពុទ្ធា
ឯកស្មិញ្ញេវ កប្បេ ឧប្បជ្ជឹសុ ។

១០. ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ
អភិនន្ទុន្តិ ។

១១. យថា ហិ មូលេ អនុបទ្ទវេ ទឡ្ហេ ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ និព្វត្តិ ទុក្ខំ ឥទំ បុនប្បុនំ ។

១២. ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

១៣. បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ?

១៤. យោ ច តុលំវ បគ្គយ្ហ វរំ អាទាយ បណ្ឌិតោ
ចាបានិ បរិវជ្ជេតិ ស មុនី តេន សោ មុនិ ។
១៥. តតោ ជំ សុខំ អច្ចេតិ ឆាយាវ អនុបាយិនី ។

(ចប់មេរៀនទី ៤៥)

# កំណាព្យដាស់តឿនស្មារតី

ត្រូវដាក់ខ្លួន ឃើញគេ កុំមើលងាយ
ទោះផ្សេងជាតិ សាសនា ទីកំណើត
ទុកជាក្រ តូចទាប ខ្សោយវិជ្ជា
ត្រូវមេត្តា ប្រាស្រ័យ ចិត្តត្រជាក់ ។

អ្នកប្រាជ្ញឥតខន្តី ដូចដំរីឥតភ្លុក
កិលេសដឹកមុខ ដូចអ្នកគុកជាប់ខ្នោះ ។

# មេរៀនទី ៤៦

# អធិប្បាយអំពីសមាស

(Compounds)

***សមាស*** *បានដល់ វិជ្ជាវេយ្យាករណ៍មួយប្រភេទទៀតដែលអ្នកសិក្សាគប្បីដឹង គឺការនាំយកស័ព្ទផ្សេង ៗ ចាប់តាំងពី ២ បទឡើងទៅយកមកបំប្រួញចូលគ្នា ក្នុងន័យថាបង្រួមចូលគ្នាឱ្យខ្លីជាពាក្យតែមួយ ។ ប្រសិនបើយើងមិនយល់ចូលចិត្តនាមស័ព្ទឱ្យបានល្អទេ ដល់វេលាប្រែបទសមាសនឹងពិបាកថែមទៀតជាក់ជាមិនខាន ជាពិសេសរឿងការន្តនិងវិធីបំបែកក្នុងរូបវិភត្តិផ្សេង ៗ នោះ ។*

*ស័ព្ទដែលអាចយកមកបំប្រួញចូលគ្នាបានគឺស័ព្ទគ្រប់ប្រភេទមាននាមនាម, គុណនាម, សព្វនាម, កិតកិរិយា, នាមកិតក, តទ្ធិត, និបាត, ឧបសគ្គ និង សមាសនាមខ្លួនឯងក៏អាចធ្វើសមាសបានដែរ ។*

*ពាក្យថា* ***សមាស*** *ប្រែថា "ការបំប្រួញ" ជានាមកិតកៈ សម្រេចមកពី* ***សំ*** *បុព្វបទ, ផ្លាស់និគ្គហិតនៃ* ***សំ*** *ជា* ***ម*** *ទៅជា* ***សម*** *និង* ***អស*** *ធាតុក្នុងន័យថា "បំប្រួញ, សង្ខេប", ចុះ* ***ណ*** *បច្ច័យ, រួចទីឃៈ* ***អ*** *ដើមធាតុជា* ***អា*** *ទៅជា* ***សមាស***, (***សំ*** + ***អស*** + ***ណ***) > ***សមាស*** *ជាកម្មរូប-កម្មសាធនៈ ឬ ភាវរូប-ភាវសាធនៈ ដែលមានវិគ្គហៈថា*

វិ. តេន សមសិយតេតិ (សោ) សមាសោ (សទ្ទោ) (ស័ព្ទ) ដែលគេបំប្រួញដោយល្អ ហៅថា សមាស ។

ប្រែ យោ (សទ្ទោ រីស័ព្ទ) ឯណា តេន ដែលគេ សមសិយតេ បំប្រួញដោយល្អ ឥតិ ព្រោះហេតុនោះ (សោ សទ្ទោ រីស័ព្ទ នោះ) សមាសោ ឈ្មោះថា សមាស, សមាស (សទ្ទោ ស័ព្ទ) ដែលត្រូវបំប្រួញ ។

បទថា សមាស នេះមានវិគ្គហៈច្រើនយ៉ាងដូចខាងក្រោម

សមសិយតេតិ សមាសោ ។

សមសនំ សមាសោ ។

សមសនំ សំខិបិនំ វា សមាសោ ។

សមសីយតីតិ សមាសោ ។

សមស្សេតេតិ សមាសោ ។

ការបំប្រួញស័ព្ទជាច្រើនស័ព្ទចូលគ្នាតែមួយ ដែលហៅថាសមាសនេះត្រូវតែចងជាវិគ្គហៈតាមប្រភេទនៃសមាសនោះ ៗ ដូចគ្នានឹងតទ្ធិតដែរ ។ ប៉ុន្តែតទ្ធិតមិនបំប្រួញស័ព្ទទេ គ្រាន់តែចុះបច្ច័យជំនួសស័ព្ទ ធ្វើឱ្យខ្លីប៉ុណ្ណោះ ។ ចំពោះសមាសវិញ គឺបំប្រួញស័ព្ទជាច្រើនស័ព្ទឱ្យចូលគ្នារាប់ចាប់ពី ២ ស័ព្ទឡើងទៅ ដើម្បីកាត់ព្យាង្គខាងចុងរបស់បទដើមឱ្យតិច ធ្វើឱ្យរូបស័ព្ទស្រស់ស្រាយមានសេចក្ដីច្បាស់លាស់ខាងសម្ពន្ធ ជួយឱ្យយើងប្រែភាសាបាលីបានត្រឹមត្រូវ ទើបបានសមាសមានសារៈសំខាន់

ក្នុងនាទីចុងក្រោយនេះ ដែលអ្នកសិក្សាគប្បីរៀន ។

ចំណុចដែលគួរយល់ដឹងនិងចងចាំក្នុងគ្រាដំបូងនៃរឿងសមាសគឺ ពាក្យថា ស័ព្ទ និង បទ ។

## ស័ព្ទ និង បទ

ពាក្យថា **ស័ព្ទ** បានដល់រូបដើមនៃពាក្យនីមួយ ៗ ដែលមិនទាន់ចុះវិភត្តិនៅឡើយ មានត្រឹមតែស្រៈទីបំផុតរបស់ពាក្យ ដូចជាពាក្យថា **បុរិស**, **កញ្ញា**, **មុនិ**, **ជារី**, **គរុ**, **វធូ** ជាដើម រួមទាំងនិបាតផងដែរហៅថា **ស័ព្ទ** ។

ពាក្យថា **បទ** បានដល់ពាក្យគ្រប់ប្រភេទ ប្រសិនបើជានាមនាម គឺមានចុះវិភត្តិនានារួចហើយដូចជា (**បុរិស** + **សិ**) > **បុរិសោ**, (**បុរិស** + **ស** + **ស**) > **បុរិសស្ស** ដូច្នេះជាដើមហៅថា **បទ** ។

ស័ព្ទនិងបទមានការទាក់ទងជាមួយរូបវិគ្គហៈរបស់សមាសដូចតទៅនេះ

## វិធីតាំងវិគ្គហៈនៃសមាស

ការរៀងវិគ្គហៈរបស់សមាសគឺរៀងដូចប្រយោគធម្មតា ដែលត្រូវប្រកបដោយ បទប្រធាន និង បទអធិប្បាយ គឺ បទវិសេសនៈ ។ បទ

អធិប្បាយបទប្រធានរៀងដាក់នៅខាងដើមគឺខាងស្តាំ ឬខាងឆ្វេងគឺខាងចុងក៏បាន ស្រេចតែសេចក្តីត្រឹមត្រូវក្នុងទីនោះ ៗ ដូចឧទាហរណ៍ខាងក្រោមនេះ

**១. ឧច្ចោ រុក្ខោ** > **ឧច្ចរុក្ខោ** =ដើមឈើខ្ពស់ ។

| បទអធិប្បាយ | បទប្រធាន | បទសមាស | ពាក្យប្រែ |
|---|---|---|---|

**២. បុរិសោ លាមកោ** > **បុរិសលាមកោ** =ប្រុសអាក្រក់ ។

| បទប្រធាន | បទអធិប្បាយ | បទសមាស | ពាក្យប្រែ |
|---|---|---|---|

សូមសង្កេតមើល ក្នុងឧទាហរណ៍ទី ១ មានបទអធិប្បាយនៅខាងដើម ។ រីឯក្នុងឧទាហរណ៍ទី ២ វិញមានបទអធិប្បាយនៅខាងចុង ។

## បុព្វបទ និង ឧត្តរបទ

ពាក្យថា **បុព្វបទ** (**បុព្វ** =ដើម, មុន + **បទ** =បទ) បានដល់ បទដែលនៅខាងដើម ឬ បទដើម ។ រីឯពាក្យថា **ឧត្តរបទ** (**ឧត្តរ** =ចុង + **បទ** =បទ) បានដល់ បទដែលនៅខាងចុង ឬ បទចុង ។

បទសមាសក្នុងឧទាហរណ៍ខាងលើ កាលនៅដាច់ពីគ្នាជាបទ ៗ គឺបទថា **ឧច្ចោ** ជា ***បុព្វបទ*** និងបទថា **រុក្ខោ** ជា***ឧត្តរបទ*** ។ បទនីមួយ ៗ

ហៅថា **អធុបធ** (បទតូច) ក៏បាន ។ លុះដល់តនូវអនុបទទាំងពីរឱ្យទៅជា **ឧច្ចរុក្ខោ** ក៏សម្រេចបានជាបទសមាស គឺសម្រេចមកពីរូបវិគ្គហៈនោះឯង ហៅថា **បធសមាស** ។

ដូច្នេះគប្បីចង់ចាំថា ក្នុងរូបវិគ្គហៈរបស់សមាសមួយ ៗ ត្រូវមានទាំង **បុព្វបធ**, **ឧត្តរបធ** និង **បធសមាស** ជានិច្ច ។

ប្រសិនបើអ្នកសិក្សាមិនយល់ចូលចិត្តនូវសេចក្ដីដូចបានពោលនេះទេ នោះនឹងហៅឈ្មោះសមាសមិនត្រូវទេ ។ ដូច្នេះមុនដំបូងបង្អស់ត្រូវយល់ពីរបៀបបំប្រួញបទសមាសជាទូទៅសិនថា តើមានលក្ខណៈដូចម្ដេចខ្លះ ?

## លុត្តសមាស និង អលុត្តសមាស

សមាសមាន ២ យ៉ាងគឺ **លុត្តសមាស** និង **អលុត្តសមាស** ។

១. **លុត្តសមាស** បានដល់ បទសមាសណាដែលត្រូវលុបវិភត្តិខាងចុងរបស់បុព្វបទឱ្យសល់ត្រឹមតែស្រៈទីបំផុតនៃស័ព្ទ គឺរូបដើម រួចបំប្រួញចូលជាមួយនឹងឧត្តរបទឱ្យទៅជាមួយបទ ឧ. **ពុទ្ធស្ស សាវកោ** បំប្រួញជា **ពុទ្ធសាវកោ** =សាវ័ករបស់ព្រះពុទ្ធ ។ យ៉ាងនេះ ហៅថា **លុត្តសមាស** ប្រែថា "បំប្រួញដោយលុបវិភត្តិរបស់បុព្វបទ" ។

នេះឃើញថាបុព្វបទជា **ពុទ្ធស្ស** មានចុះវិភត្តិខាងចុងគឺ **ស** និង

ចុះ **ស** អាគមផង (**ពុទ្ធ** + **ស** + **ស**) > **ពុទ្ធស្ស** ហើយយកមកបំប្រួញចូលជាមួយនឹង **សាវកោ** ទៅជា **ពុទ្ធសាវកោ** ដូច្នេះជាដើម ។

២. **អលុត្តសមាស** បានដល់ បទសមាសណាដែលមិនលុបវិភត្តិរបស់បុព្វបទទេ គឺគ្រាន់តែនាំយកមកតភ្ជាប់គ្នាធម្មតា ៗ ដូចជា **ពុទ្ធានំ សាសនំ** > **ពុទ្ធានំ សាសនំ** =ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ.ទ. ។ យ៉ាងនេះ ហៅថា **អលុត្តសមាស** ប្រែថា "បំប្រួញដោយវិធីមិនលុបវិភត្តិ" មានរូបដើមមកយ៉ាងណាទុកឱ្យគង់រូបដើមជាយ៉ាងនោះ ។

ឧទាហរណ៍នេះឃើញថា **ពុទ្ធានំ** មានចុះវិភត្តិខាងចុងគឺ **នំ** (**ពុទ្ធ** + **នំ**) > **ពុទ្ធានំ** ពេលយកមកបំប្រួញជាបទសមាស ពុំចាំបាច់លុប **នំ** ចោលទេ អាចយកមកតភ្ជាប់គ្នាជាមួយ **សាសនំ** បានទៅជា **ពុទ្ធានំ សាសនំ** ដូច្នេះជាដើម ។

ក្នុងសទ្ទសាស្រ្តទាំងឡាយពោលថា **អលុត្តសមាស** នេះ បំប្រួញតែអត្ថរបស់បទប៉ុណ្ណោះ មិនបំប្រួញរូបរបស់បទឲ្យចូលគ្នា គឺពុំចាំបាច់សរសេរជាប់គ្នាទេ ។

## ស្រៈ អា, ឦ, ឩ ក្នុងបទសមាស

ការបំប្រួញបទសមាសដូចដែលបានពោលហើយនេះ ភាគច្រើនមានការទាក់ទងនឹងស្រៈទីបំផុតនៃបុព្វបទ ជាពិសេសស្រៈ **អា**, **ឦ**, **ឩ**

ហើយនឹងវិធីសន្ធិដូចនឹងអធិប្បាយខាងក្រោមនេះ

ប្រសិនបើក្នុងវិគ្គហៈ បុព្វបទមានទីបំផុតជាស្រៈ **អា**, **ឦ**, **ឩ** វេលាបំប្រួញចូលគ្នានឹងឧត្តរបទ មានករណីត្រូវដឹងដូចតទៅនេះ

១. បទណាមានស្រៈ **អា** ជាទីបំផុត មានវិធីធ្វើសមាស ២ យ៉ាងគឺ

១.១ ប្រសិនបើបុព្វបទជាគុណនាម (គឺគុណនាមភាគច្រើនជា អ ការន្ត) ឬវិសេសនសព្វនាម (អ ការន្ត) ប្រើជាបទវិសេសនៈរបស់ឧត្តរបទដែលជា **អា** ការន្តឥត្ថីលិង្គ នៅក្នុងវិគ្គហៈ ត្រូវចុះ **អា** បច្ច័យឱ្យមានការន្តដូចគ្នាសិន រួចទើបចុះវិភត្តិឲ្យត្រូវតាមអត្ថដែលត្រូវការ ។ ប៉ុន្តែនាវេលាបំប្រួញចូលជាមួយឧត្តរបទឱ្យទៅជាសមាស ត្រូវរស្សៈស្រៈ **អា** របស់បុព្វបទគឺបទវិសេសននោះ ៗ ជា **អ** ដូចរូបដើមវិញ ឧ.

**អញ្ញតរា កញ្ញា** > **អញ្ញតរកញ្ញា** =ក្រមុំដទៃ ។

ក្នុងឧទាហរណ៍ខាងលើនេះឃើញថា **អញ្ញតរា** ជាវិសេសនសព្វ-នាមដែលមានរូបដើមជា **អញ្ញតរ** ។ វេលាយកមកប្រើជាបទវិសេសនៈរបស់ **កញ្ញា** ដែលជា **អា** ការន្តឥត្ថីលិង្គ ទើបត្រូវចុះ **អា** បច្ច័យតាមបទប្រធាន លុះដល់វេលាបំប្រួញចូលគ្នាត្រូវរស្សៈជា **អញ្ញតរ** វិញ ។

១.២ ប្រសិនបើបុព្វបទជានាមនាម **អា** ការន្តឥត្ថីលិង្គស្រាប់ដែលយកមកប្រើជាបទវិសេសនៈ ពេលបំប្រួញចូលគ្នាជាមួយឧត្តរបទពុំចាំ-បាច់រស្សៈទេ គ្រាន់លុបវិភត្តិចេញឱ្យមានរូបជា **អា** ការន្តតាមរូបដើម

វិញប៉ុណ្ណោះ ឧ.

**កញ្ញានំ សហស្សំ** > **កញ្ញាសហស្សំ** =ពាន់នៃក្រមុំ ។
**តារានំ គណោ** > **តារាគណោ** =គណៈនៃតារា ។

ឧទាហរណ៍ខាងលើនេះសឱ្យឃើញថា **កញ្ញានំ** ក្តី **តារានំ** ក្តី មានរូបដើមជា **កញ្ញា** និង **តារា** ដែលជា **អា** ការន្តឥត្ថីលិង្គបំបែកជា **កញ្ញានំ** និង **តារានំ** ។ វេលាបំប្រួញចូលនឹងឧត្តរបទ ត្រូវលុបតែវិភត្តិខាងចុងគឺ **នំ** ប៉ុណ្ណោះ រីឯ **អា** ការន្តវិញគង់នៅដូចដើម ។

២. បទណាមានស្រៈ **ឦ** ជាទីបំផុត មានវិធីធ្វើសមាស ២ យ៉ាងគឺ

២.១ ប្រសិនបើបុព្វបទមានទីបំផុតជា **ឦ** បទសម្រេចមកពី **ឦ** បច្ច័យក្នុងតទស្សត្ថិតទ្ធិតដូចជា **សេដ្ឋី**, **ហត្ថី** ជាដើមនិងដែលសម្រេចមកពី **ណី** បច្ច័យក្នុងនាមកិតកៈដូចជា **យោគី**, **យោធី** ជាដើម វេលាបំប្រួញចូលជាមួយឧត្តរបទត្រូវរស្សៈ **ឦ** > **ឥ** វិញ ឧ.

**សេដ្ឋិនោ បុត្តោ** > **សេដ្ឋិបុត្តោ** =បុត្ររបស់សេដ្ឋី ។
**យោគិនោ វត្តំ** > **យោគិវត្តំ** =វត្ត(កិច្ចបដិបត្តិ)របស់យោគី ។

ដូច្នេះបទដើមគឺ **សេដ្ឋិនោ** និង **យោគិនោ** ត្រូវលុបវិភត្តិនៃបុព្វ-បទគឺ **ស** > **នោ** បាត់ទៅហើយ នៅសល់តែ **ឦ** ការន្តតាមរូបដើម ។ វេលាបំប្រួញចូលជាមួយឧត្តរបទត្រូវរស្សៈ **ឦ** > **ឥ** វិញ **សេដ្ឋិបុត្តោ**, **យោគិវត្តំ** ។ ស័ព្ទឯទៀត ៗ គប្បីជ្រាបតាមន័យនេះផងចុះ ។

*២.២ ប្រសិនបើបុព្វបទមានទីបំផុតជា ឦ ដែលជានាមនាមសុទ្ធ ឬដែលសម្រេចមកពីបច្ច័យដូចជា* **សី, តាវី, ឥនី** *ដែលជា ឦ ការន្ត ឥត្ថីលិង្គឬបុំលិង្គដោយចំ ៗ នោះ វេលាបំប្រួញចូលជាមួយឧត្តរបទត្រូវទុក ឦ ការន្តឱ្យគង់តាមរូបដើម ឧ.*

ឧទាហរណ៍នៃ ឦ បុំលិង្គ

**តបស្សិនោ កិច្ចំ** > **តបស្សីកិច្ចំ** =*កិច្ចរបស់អ្នកមានការព្យាយាម ។*

**មេធាវិនោ សុខំ** > **មេធាវីសុខំ** =*សេចក្ដីសុខរបស់អ្នកមានបញ្ញា ។*

ឧទាហរណ៍នៃ ឦ ឥត្ថីលិង្គ

**នទិយា តីរំ** > **នទីតីរំ** =*ច្រាំងនៃទន្លេ ។*

**ភេរិយា សទ្ទោ** > **ភេរីសទ្ទោ** =*សំឡេងនៃស្គរ ។*

**ភិក្ខុនីនំ សីលំ** > **ភិក្ខុនីសីលំ** =*សីលរបស់ភិក្ខុនី ។*

**ឥត្ថិយា សទ្ទោ** > **ឥត្ថីសទ្ទោ** =*សំឡេងរបស់ស្រី ។*

*៣. បទណាមានស្រៈ ឩ ជាទីបំផុត មានវិធីធ្វើសមាស ២ យ៉ាងគឺ*

*៣.១ ប្រសិនបើបុព្វបទមានទីបំផុតជា ឩ ទោះជានាមនាមសុទ្ធ ៗ ឬសម្រេចមកពីបច្ច័យក្នុងនាមកិតកៈក៏ដោយ ពេលបំប្រួញចូលជាមួយឧត្តរបទពុំចាំបាច់រស្សៈទេ ត្រូវទុកស្រៈ ឩ ឱ្យគង់រូបតាមការន្តដើមទាំងពីរលិង្គ ឧ.*

ឧទាហរណ៍នៃ ឧ. បុំលិង្គ

**កាតញ្ញូ ច កាតវេទី ច > កាតញ្ញូកាតវេទី** =ជនទាំងកតញ្ញូទាំងកតវេទី ។

ឧទាហរណ៍នៃ ឧ. ឥត្ថីលិង្គ

**វធុយា សទ្ទោ > វធូសទ្ទោ** =សំឡេងរបស់ស្រីក្មេង ។

សព្ទឯទៀត ៗ ក៏គប្បីជ្រាបតាមន័យនេះផងចុះ ។

## សន្ធិក្នុងសមាស

ការបំប្រួញសព្ទចាប់តាំងពី ២ បទឡើងទៅឱ្យជាមួយបទដោយវិធីលុបវិភត្តិចុងពាក្យដូចពោលមកហើយនោះ ត្រូវអាស្រ័យគោលសន្ធិ គឺ សរសន្ធិ ព្យញ្ជនសន្ធិ និង និគ្គហិតសន្ធិ (ចូរមើលក្នុងមេរៀនទី ៤៤, ៤៥ ខាងដើម)ដើម្បីកាត់ស្រៈនិងតួអក្សរឱ្យតិចនិងឱ្យមានសមួស្សដោយហេតុផល ៣ ប្រការគឺ ដើម្បីសេចក្ដីពីរោះរបស់ភាសា, ដើម្បីប្រើតួអក្សរឱ្យតិចជាងមុន, ដើម្បីតម្រួតតួអក្សរឱ្យត្រូវតាមគោលព្យញ្ជនសំយោគដូចមានឧទាហរណ៍តទៅនេះ

### ១. ដើម្បីសេចក្ដីពិរោះរបស់ភាសា

ទេវានំ ឥន្ទោ > ទេវានមិន្ទោ = *ទេវតាធំជាងទេវតា ។*

អញ្ញតរា ឥត្ថី > អញ្ញតរិត្ថី = *ស្រីដទៃ ។*

នីលំ ឧប្បលំ > នីលុប្បលំ = *ផ្កាឈូកខៀវ ។*

២. ដើម្បីកាត់បទឱ្យតិចជាងមុន

បញ្ច ឥន្ទ្រិយានិ > បញ្ចិន្ទ្រិយានិ = *ឥន្ទ្រីយ៍ប្រាំ ។*

៣. ដើម្បីតម្រូតតួអក្សរឱ្យត្រូវតាមគោលព្យញ្ជនសំយោគ

*កវគ្គ,* បុញ្ញស្ស ខេត្តំ > បុញ្ញក្ខេត្តំ = *ស្រែនៃបុណ្យ ។*

*ចវគ្គ,* វឌ្ឍមានកា ឆាយា > វឌ្ឍមានកច្ឆាយា = *ស្រមោលកំពុងចម្រើន ។*

*ដវគ្គ,* សេដ្ឋិនោ ឋានំ > សេដ្ឋិដ្ឋានំ = *ដំណែងរបស់សេដ្ឋី ។*

*តវគ្គ,* សារីបុត្តោ ថេរោ > សារីបុត្តត្ថេរោ = *ព្រះសារីបុត្តត្ថេរៈ ។*

*បវគ្គ,* មហន្តំ ផលំ > មហប្ផលំ = *ផ្លែធំ ។*

*សូមរកមើលក្នុងអក្ខរវិធីនៅខាងដើមបង្អស់ស្តីពីព្យញ្ជនសំយោគប្រកបផង ។*

## បុំលិង្គ ឬ ឥត្ថីលិង្គ

*ក្នុងករណីណាមានបុព្វបទជាស័ព្ទទ្វិលិង្គ ដែលជាបុំលិង្គក៏បាន*

និងជាឥត្ថីលិង្គក៏បាននោះ  បើយកមកប្រើជាបុព្វបទគឺបទវិសេសនៈឱ្យនាមជាឥត្ថីលិង្គ វេលារៀងក្នុងវិគ្គហៈ ត្រូវបំបែកជាឥត្ថីលិង្គតាមឧត្តរបទ ប៉ុន្តែបទសមាសត្រូវយករូបជាបុំលិង្គវិញ ឧ.

**ខត្តិយា កុមារី** > **ខត្តិយកុមារី** =កុមារីដែលជាក្សត្រីយ៍ ។
**ព្រាហ្មណី កញ្ញា** > **ព្រាហ្មណកញ្ញា** =ក្រមុំដែលជាព្រាហ្មណ៍ ។
**នាគី មាណវិកា** > **នាគមាណវិកា** =ក្រមុំនៃត្រកូលនាគ ។

ប្រសិនបើជាអសាធារណនាម(ឈ្មោះ)វិញមិនមានការផ្លាស់ប្តូរទេ
**នន្ទា បោក្ខរណី** > **នន្ទាបោក្ខរណី** =ស្រះនន្ទា ។
**នន្ទា ទេវី** > **នន្ទាទេវី** =ក្សត្រីយ៍នន្ទា ។

ក្រឹត្យក្រមផ្សេង ៗ ដូចពោលហើយនេះ ជាវិធីសម្រាប់ប្រើក្នុងការបំប្រួញបទសមាសទូទៅ តែនៅមិនទាន់ដល់កម្រិតដែលដឹងបានថាបទណាជាសមាសអ្វីនៅឡើយទេ ។ ពីព្រោះស័ព្ទដែលយកមកបំប្រួញជាបទសមាសដូចប្រាកដនៅខាងលើនោះ  ត្រូវសម្រេចពីរូបវិគ្គហៈរបស់សមាសនីមួយ ៗ ដូចមានឈ្មោះហៅខាងក្រោមនេះ

## សមាស ៦ ប្រភេទ

បទសមាស បើរាប់តាមឈ្មោះសំខាន់ ៗ មាន ៦ ប្រភេទគឺ

១. **កម្មធារយសមាស** ៤. **ទ្វន្ទសមាស**
២. **ទិគុសមាស** ៥. **អព្យយីភាវសមាស**
៣. **តប្បុរិសសមាស** ៦. **ពហុព្វីហិសមាស**

*ឈ្មោះសមាសទាំង ៦ នេះអាចហៅខ្លី ៗ ថា* **កម្មធារយ, ទិគុ, តប្បុរិស, ទ្វន្ទ, អព្យយីភាវ, ពហុព្វីហិ** *ក៏បាន ដើម្បីឱ្យងាយចាំ និង បន្តទៅទៀតត្រូវដឹងថា សព្ទដែលអាចនាំយកមកបំប្រួញជាបទសមាស ទាំងអស់មាន ៤ ប្រភេទគឺ*

*១. នាមសព្ទគ្រប់ប្រភេទរួមទាំងតទ្ធិតផងដែរ ។*

*២. ឧបសគ្គនិងនិបាតពួកខ្លះ ។*

*៣. នាមកិតក: (រៀរតែប្រកបពី* **តវេ តុំ** *បច្ច័យ) ។*

*៤. កិតកិរិយា (រៀរតែប្រកបពី* **ត្វាទិ** *បច្ច័យ) ។*

*កាលបើនាំយកសព្ទប្រភេទដូចពោលនេះ មកបំប្រួញចូលគ្នាជាបទតែមួយ គេនឹងអាចដឹងថាបទនោះ ៗ ជាសមាសអ្វីនិងតាំងវិគ្គហ:ឱ្យត្រូវគ្នានឹងសមាសនោះបាន ព្រោះសមាសនីមួយ ៗ ប្រាប់វិធីរៀងវិគ្គហ: និងវិធីប្រែដូចតទៅនេះ*

## ១. កម្មធារយសមាស

## (Descriptive Determinate Compounds)

សមាសនេះមានលក្ខណៈពិសេស ៣ ប្រការគឺ

១. ក្នុងរូបវិគ្គហៈប្រើស័ព្ទសំខាន់ ២ បទ ដែលបំបែកជាបឋមាវិភត្តិឱ្យមានការន្តនិងលិង្គស្មើគ្នាជានិច្ច ។

២. ក្នុងរូបវិគ្គហៈមានបទមួយជាប្រធាន និងបទមួយទៀតជាបទវិសេសនៈ (គុណបទ) ឬទាំងពីរបទជាវិសេសនៈដោយមានបទដទៃជាប្រធានក៏បាន ។

៣. បទសមាសដែលសម្រេចពីវិគ្គហៈនេះ បំបែកជាបឋមាវិភត្តិតាមការន្តនិងលិង្គនោះ ៗ ។

សរុបទៅគឺមាន **បុព្វបទ** (បទដើម), **ឧត្តរបទ** (បទចុង) និង **សមាសបទ** ដូចពោលហើយខាងដើម ។ បទសមាសណាឋិតក្នុងលក្ខណៈ ៣ ប្រការនេះ ហៅថា **កម្មធារយសមាស** ដូចមានវិធីតាំងវិគ្គហៈយ៉ាងច្បាស់លាស់ដែលនឹងអធិប្បាយតទៅនេះ

## កម្មធារយសមាស ៦ យ៉ាង

កម្មធារយសមាស បើចែកតាមរូបវិគ្គហៈមាន ៦ យ៉ាងគឺ

១.១ **វិសេសនបុព្វបទកម្មធារយសមាស** បានដល់ សមាសណាដែលមានបុព្វបទជាបទវិសេសនៈនិងមានឧត្តរបទជាបទប្រធាន ។

១.២ **វិសេសនុត្តរបទកម្មធារយសមាស** បានដល់ សមាស

ណាដែលមានឧត្តរបទជាបទវិសេសនៈនិងមានបុព្វបទជាបទប្រធាន ។

១.៣ **វិសេសនោភយបទកម្មធារយសមាស** បានដល់ សមាសណាដែលទាំងពីរបទជាបទវិសេសនៈនិងមានបទដទៃជាប្រធាន ។

១.៤ **វិសេសនោបមបទកម្មធារយសមាស** បានដល់ សមាសណាដែលមានបទមួយជាបទឧបមាប្រើជាបទវិសេសនៈ ។

១.៥ **សម្ភាវនកម្មធារយសមាស** បានដល់ សមាសណាដែលមានបុព្វបទជាបទសម្ភាវនៈ(ពាក្យសរសើ)និងមានឧត្តរបទជាប្រធាន ។

១.៦ **អវធារណកម្មធារយសមាស** បានដល់ សមាសណាដែលមានបុព្វបទជាបទអវធារណៈនិងមានឧត្តរបទជាបទប្រធាន ។

## កំណត់សម្គាល់

ឈ្មោះសមាសទាំង ៦ យ៉ាងនេះសូមចងចាំឱ្យបានល្អ ព្រោះកាលបើយើងជួបសមាសក្នុងទីណាក៏ដោយ បើមានរូបលក្ខណៈត្រូវគ្នានឹងឈ្មោះណាមួយនៃឈ្មោះទាំង ៦ នេះ គប្បីជ្រាបថាគឺជាកម្មធារយសមាសហ្នឹងឯង ព្រោះឈ្មោះនីមួយ ៗ មានវិធីតាំងវិគ្គហៈនិងវិធីប្រែដូចតទៅនេះ

## ១.១ វិសេសនបុព្វបទកម្មធារយៈ

មានវិធីធ្វើសមាស ៥ បែបដូចមានឧទាហរណ៍ខាងក្រោមនេះ

*ក. បុព្វបទប្រើស័ព្ទនានាជាបទវិសេសនៈនិងឧត្តរបទប្រើនាមនាមជាបទប្រធាន ឧ.*

(ទលិទ្ទ *គុ.* + មនុស្ស *ន.*) > ទលិទ្ទមនុស្ស

*វិ.* ទលិទ្ទោ មនុស្សោ > ទលិទ្ទមនុស្សោ =*មនុស្សទ័លក្រ ។*

(នីល *គុ.* + ឧប្បល *ន.*) > នីលុប្បល

*វិ.* នីលំ ឧប្បលំ > នីលុប្បលំ =*ផ្កាឧប្បលខៀវ ។*

(អញ្ញតរ *វិ.សព្វ.* + ឥត្ថី *ន.*) > អញ្ញតរិត្ថី

*វិ.* អញ្ញតរា ឥត្ថី > អញ្ញតរិត្ថី =*ស្រីដទៃ ។*

(ទុតិយ *តទ្ធិ.* + ថេរ *ន.*) > ទុតិយត្ថេរ

*វិ.* ទុតិយោ ថេរោ > ទុតិយត្ថេរោ =*ព្រះថេរអង្គទីពីរ ។*

(ខត្តិយ *ន.* + នារី *ន.*) > ខត្តិយនារី

*វិ.* ខត្តិយា នារី > ខត្តិយនារី =*ស្រីជាក្សត្រីយ៍ ។*

(ការ *ន.* + ជន *ន.*) > ការជន

*វិ.* ការោ ជនោ > ការជនោ =*ជនអ្នកធ្វើការ, ការជន ។*

(ញាត *កិត.* + មនុស្ស *ន.*) > ញាតមនុស្ស

*វិ.* ញាតា មនុស្សា > ញាតមនុស្សា =*មនុស្ស.ទ.គឺ(ជន)ស្គាល់ហើយ ។*

(ភោជ្ជ *កិត.* + ឱទន *ន.*)> ភោជ្ជោទន

*វិ.* ភោជ្ជោ ឱទនោ > ភោជ្ជោទនោ =*បាយគឺ(គេ)ស៊ីហើយ ។*

ខ. ប្រសិនបើបុព្វបទជា **មហន្ត** (=ធំ) ក្នុងវិគ្គហៈត្រូវបំបែកក្នុងរូបវិភត្តិនោះ ៗ ឱ្យស្មើគ្នានឹងបទប្រធាន ។ ប៉ុន្តែក្នុងបទសមាសត្រូវផ្លាស់ជា **មហា** និងប្រសិនបើឧត្តរបទជាព្យញ្ជនសំយោគឬត្រូវធ្វើសំយោគ នោះត្រូវផ្លាស់ជា **មហា** ឧ.

វិ. **មហន្តោ ថេរោ** > **មហាថេរោ** =ព្រះថេរៈជាធំ, មហាថេរៈ ។

វិ. **មហន្តី បឋវី** > **មហាបឋវី** =ផែនដីធំ, មហាប្រថពី ។

វិ. **មហន្តំ ភយំ** > **មហព្ភយំ** =ភ័យធំ, មហាភ័យ ។

គ. អាចលុបតួអក្សរខ្លះនៃបទដើមឬបទវិសេសនៈ ដោយទុកត្រឹមតែអក្សរមួយព្យាង្គខាងដើមបង្អស់ ឧ.

វិ. **កុច្ឆិតំ កម្មំ** > **កុកម្មំ** =កម្មដែលបណ្ឌិតគួរខ្ពើម ( **កុច្ឆិត** > **កុ** ) ។

វិ. **កុច្ឆិតា ទិដ្ឋិ** > **កុទិដ្ឋិ** =ទិដ្ឋិដែលបណ្ឌិតគួរខ្ពើម (**កុច្ឆិត** > **កុ** ) ។

វិ. **សន្តោ បុរិសោ** > **សប្បុរិសោ** =បុរសអ្នកស្ងប់ហើយ (**សន្ត** > **ស**) ។

វិ. **បធានំ វចនំ** > **ធាវចនំ** =ពាក្យជាប្រធាន (**បធាន** > **ប** > **ធា**) ។

ឃ. បើបុព្វបទជាឧបសគ្គយកមកប្រើជាវិសេសនបុព្វបទ ខាងក្នុងវិគ្គហៈត្រូវចុះ **ក** ចុងឧបសគ្គនោះ ៗ ហើយបំបែកឱ្យមានវិភត្តិដូចបទប្រធាន ។ ប៉ុន្តែក្នុងបទសមាសត្រូវលុប **ក** ចេញវិញ ឧ.

វិ. **ឧបកោ រាជា** > **ឧបរាជា** =ស្តេចជិត, ស្តេចបន្ទាប់, ឧបរាជ ។

វិ. **អធិកោ រាជា** > **អធិរាជា** =ស្តេចជាធំ, អធិរាជ ។

ង. អាចប្រើអសាធារណនាមជាបទវិសេសនៈហៅថា **ឧបនាម** ក៏

បាន ឱ.

(ពុទ្ធឃោស + អាចរិយ) > ពុទ្ធឃោសាចរិយ

វិ. ពុទ្ធឃោសោ អាចរិយោ > ពុទ្ធឃោសាចរិយោ =*ព្រះពុទ្ធឃោសាចារ្យ ។*

(សារីបុត្ត + ថេរ) > សារីបុត្តេរ

វិ. សារីបុត្តោ ថេរោ > សារីបុត្តេរោ =*ព្រះថេរសារីបុត្ត ។*

(ពិម្ពិសារ + រាជ) > ពិម្ពិសាររាជ

វិ. ពិម្ពិសារោ រាជា > ពិម្ពិសាររាជា =*ស្តេចពិម្ពិសារ ។*

(សុមេធ + បណ្ឌិត) > សុមេធបណ្ឌិត

វិ. សុមេធោ បណ្ឌិតោ > សុមេធបណ្ឌិតោ =*សុមេធបណ្ឌិត ។*

*ច. ប្រសិនបើទាំងពីរបទជាឥត្ថីលិង្គ ត្រូវតាំងវិគ្គហៈនិងសរសេរបទសមាសដូចបានអធិប្បាយនៅខាងលើត្រង់បុំលិង្គឬឥត្ថីលិង្គ ។*

## កំណត់សម្គាល់

*រាល់បទសមាសដែលសម្រេចមកពីវិគ្គហៈទាំងឡាយខាងលើនេះ ហៅថា* **វិសេសនបុព្វបទកម្មធារយសមាស** *ជាសមាសដែលអាចបំបែកបានគ្រប់វិភត្តិតាមការន្តនិងលិង្គនោះ ៗ ។ សព្វឯទៀត ៗ គប្បីជ្រាបតាមន័យនេះ ។*

## ១.២ វិសេសនុត្តរបទកម្មធារយៈ

សមាសនេះ (វិសេសន + ឧត្តរ + បទ) > **វិសេសនុត្តរបទ** មានឧត្តរបទជាបទវិសេសនៈនិងមានបុព្វបទជាប្រធាន មានរូបវិគ្គហៈ ដូចវិសេសនបុព្វបទដែរ គឺគ្រាន់តែផ្លាស់បុព្វបទជាបទប្រធានរៀងនៅខាងដើម និងបទវិសេសនៈរៀងនៅខាងចុងវិញ ឧ.

(**ជម្ម** ន. + **វិសេស** គុ.) > **ជម្មវិសេស**

វិ. **ជម្មោ វិសេសោ** > **ជម្មវិសេសោ** =ជំមវិសេស ។

(**នរ** ន. + **វរ** គុ.) > **នរវរ**

វិ. **នរោ វរោ** > **នរវរោ** =ជនប្រសើរ ។

(**មនុស្ស** ន. + **ទលិទ្ទ** គុ.) > **មនុស្សទលិទ្ទ**

វិ. **មនុស្សោ ទលិទ្ទោ** > **មនុស្សទលិទ្ទោ** =មនុស្សទ័លក្រ ។

(**សត្ត** ន. + **វិសេស** គុ.) > **សត្តវិសេស**

វិ. **សត្តោ វិសេសោ** > **សត្តវិសេសោ** =សត្វវិសេស (មនុស្ស) ។

(**កុល** ន. + **ឧច្ច** គុ.) > **កុលុច្ច**

វិ. **កុលំ ឧច្ចំ** > **កុលុច្ចំ** =ត្រកូលខ្ពស់ ។

(**កុល** ន. + **នីច** គុ.) > **កុលនីច**

វិ. **កុលំ នីចំ** > **កុលនីចំ** =ត្រកូលទាប ។

## កំណត់សម្គាល់

*សមាសដែលសម្រេចពីរូបវិគ្គហៈទាំងនេះ ហៅថា* **វិសេសនុត្តរ-បទកម្មធារយសមាស** *ជាសមាសនាម ព្រោះមានបទប្រធានពេញបរិបូរណ៍ ។ ស័ព្ទឯទៀត ៗ ក៏គប្បីជ្រាបតាមសេចក្តីនេះ ។*

## ១.៣ វិសេសនោភយបទកម្មធារយៈ

*សមាសនេះ* (**វិសេសន + ឧភយ + បទ**) > **វិសេសនោភយ-បទ** *មានបទទាំងពីរជាវិសេសនៈ និងមានបទដទៃជាប្រធាន ។ ក្នុងសេចក្តីថា ក្នុងវិគ្គហៈមានតែគុណនាមទាំងពីរបទ ដូច្នេះត្រូវរកនាមនាមដទៃដែលសមរម្យមកបំពេញ និងបំបែកឱ្យមានវិភត្តិស្មើគ្នា ។ អាស្រ័យហេតុនេះខាងក្នុងរូបវិគ្គហៈនៃសមាសនេះត្រូវថែម* **ច** *ស័ព្ទប្រែថា "និង" ខាងចុងគុណនាមទាំងពីរបទ ។ បើ* **ច** *ឋិតនៅចុងបទណា វេលាប្រែត្រូវអានគួបជាមួយបទនោះ ៗ និងត្រូវប្រែថា "... ផង ... ផង" ។ ប៉ុន្តែបទសមាសត្រូវលុប* **ច** *ស័ព្ទចេញ ឧ.*

(**សីត** *គុ.* + **ឧណ្ហ** *គុ.*) > **សីតុណ្ហ**

*វិ.* **សីតោ ច ឧណ្ហោ ច** > **សីតុណ្ហោ** (**បុរិសោ**) =(*បុរស*) *ស្គមផងខ្មៅផង ។*

(**តុច្ឆ** *គុ.* + **ហាច្ឆ** *គុ.*) > **តុច្ឆហាច្ឆ**

វិ. **តុដ្ឋោ ច ហដ្ឋោ ច** > **តុដ្ឋហដ្ឋោ** (បុគ្គលោ) =(បុគ្គល) ត្រេកអរហើយផងសើចផង ។

(**សីត** គុ. + **សមដ្ឋ** គុ.) > **សីតសមដ្ឋ**

វិ. **សីតញ្ច សមដ្ឋញ្ច** > **សីតសមដ្ឋំ** (ឋានំ) =(ទី) ដែលត្រជាក់ផងរអិលផង ។

## កំណត់សម្គាល់

បទសមាសដែលសម្រេចពីរូបវិគ្គហៈទាំងនេះ ហៅថា **វិសេសោភយបទកម្មធារយសមាស** ជាសមាសគុណនាមតែម៉្យាង អាចបំបែកតាមវិភត្តិបានទាំង ៣ លិង្គ ។ ស័ព្ទឯទៀត ៗ សូមជ្រាបតាមន័យនេះ ។

## ១.៨ វិសេសនោបមបទកម្មធារយៈ

សមាសនេះ (**វិសេសន** + **ឧបម** + **បទ**) > **វិសេសនោបមបទ** មានបទឧបមាជាបទវិសេសនៈ ក្នុងសេចក្ដីថាមានពាក្យប្រៀបធៀបជាបទវិសេសនៈ ក្នុងរូបជានាមនាមក៏បាន ជាគុណនាមក៏បាន ។ ដូច្នេះ ខាងក្នុងរូបវិគ្គហៈនៃសមាសនេះ ត្រូវថែម **ឥវ** ឬ **វិយ** ស័ព្ទប្រែថា "ដូច, ដូចជា" នៅខាងចុងបទឧបមានោះ ៗ ។ ប៉ុន្តែបទសមាសត្រូវលុប **ឥវ** ឬ

វិយ *ស័ព្ទចេញ មាន ២ ប្រភេទគឺ* ឧបមាបុព្វបទ *និង* ឧបមានុត្តរ-បទ ។

## ១.៤.១ ឧបមាបុព្វបទកម្មធារយៈ

*សមាសនេះមានបទដើមជាបទឧបមា ឧ.*

(សង្ខ *ន.* + បណ្ឌរ *គុ.*) > សង្ខបណ្ឌរ

*វិ.* សង្ខំ ឥវ បណ្ឌរំ > សង្ខបណ្ឌរំ ( ខីរំ ) =(*ទឹកដោះស្រស់) សដូចស័ង្ខ ។*

(កាក *ន.* + សូរ *គុ.*) > កាកសូរ

*វិ.* កាកោ ឥវ សូរោ > កាកសូរោ ( ជនោ ) =*(ជន)ក្លៀវក្លាដូចក្អែក ។*

(អច្ឆរា *ន.* + សោភណា *គុ.*) > អច្ឆរសោភណា

*វិ.* អច្ឆរា ឥវ សោភណា > អច្ឆរសោភណា ( កញ្ញា ) =*(ស្រីក្រមុំ)ស្អាតដូចជាស្រីអប្សរ ។*

(ទិព្វ *ន.* + ចក្ខុ *ន.*) > ទិព្វចក្ខុ

*វិ.* ទិព្វំ ឥវ ចក្ខុ > ទិព្វចក្ខុ =*ចក្ខុដូចទិព្វ ។*

(បេត *ន.* + មនុស្ស *ន.*) > បេតមនុស្ស

*វិ.* បេតោ ឥវ មនុស្សោ > បេតមនុស្សោ =*មនុស្សដូចប្រេត ។*

## កំណត់សម្គាល់

*បទសមាសសម្រេចមកពីរូបវិគ្គហៈទាំងនេះ ហៅថា* **ឧបមាបុព្វ-បទកម្មធារយសមាស** *អាចជាសមាសគុណនាមផងនិងជាសមាស-នាមផង ។ សូមសង្កេតមើលឧទាហរណ៍ពីរខាងចុងក្នុងរូបវិគ្គហៈឥត មានថែមអញ្ញបទទេ ។ ម្យ៉ាងទៀត វិធីតាំងវិគ្គហៈនៃសមាសនេះអាច ប្រើ* **វិយ** *ជំនួសឱ្យ* **ឥវ** *បាន ពីព្រោះប្រែបានន័យដូចគ្នា ឧ.*

(**អជិច្ច** *ន.* + **ពុទ្ធ** *ន.*) > **អជិច្ចពុទ្ធ**

*វិ.* **អជិច្ចោ វិយ ពុទ្ធោ** > **អជិច្ចពុទ្ធោ** =*ព្រះពុទ្ធដូចព្រះអាទិត្យ ។*

(**ចន្ទ** *ន.* + **មុខ** *ន.*) > **ចន្ទមុខ**

*វិ.* **ចន្ទោ វិយ មុខោ** > **ចន្ទមុខោ** =*មុខដូចព្រះច័ន្ទ ។*

(**សីហ** *ន.* + **មុនិ** *ន.*) > **សីហមុនិ**

*វិ.* **សីហោ វិយ មុនិ** > **សីហមុនិ** =*អ្នកប្រាជ្ញដូចជាសិង្ហ ។*

(**នាគ** *ន.* + **ពុទ្ធ** *ន.*) > **នាគពុទ្ធ**

*វិ.* **នាគោ វិយ ពុទ្ធោ** > **នាគពុទ្ធោ** =*ព្រះពុទ្ធដូចនាគ ។*

### ១.៤.២ ឧបមានុត្តរបទកម្មធារយៈ

*សមាសនេះមានឧត្តរបទជាបទឧបមា*

(នរ + សីហ) > នរសីហ

វិ. នរោ សីហោ ឥវ > នរសីហោ =មនុស្សដូចជាសីហៈ ។

(បញ្ញា + ចាសាទ) > បញ្ញាចាសាទ

វិ. បញ្ញា ចាសាទោ ឥវ > បញ្ញាចាសាទោ =បញ្ញាដូចជាប្រាសាទ ។

(ញាណ + ចក្ខុ) > ញាណចក្ខុ

វិ. ញាណំ ចក្ខុ ឥវ > ញាណចក្ខុ =ញាណដូចចក្ខុ ។

សូមសង្កេតមើលរបៀបរៀងវិគ្គហៈខាងលើនេះ ខុសពីឧបមាបុព្វបទបន្តិចត្រង់ការរៀង ឥវ ឬ វិយ នៅខាងចុងបទទាំងពីរ ។

បទសមាសសម្រេចពីវិគ្គហៈទាំងនេះ ត្រូវលុប ឥវ ឬ វិយ ចេញ ហៅថា ឧបមានុត្តរបទកម្មធារយសមាស ជាសមាសនាម ។

## កំណាត់សម្គាល់

បទសមាសខ្លះអាចប្រែបានច្រើនយ៉ាង ដូចបទថា កាកសូរោ បើប្រែថា "ក្អែកជាសត្វក្លៀវក្លា" នេះជាវិសេសនុត្តរបទកម្មធារយសមាស ដែលមានវិគ្គហៈថា កាកោ សូរោ កាកសូរោ ។ បើប្រែថា "ក្លៀវក្លាជាងក្អែក ឬ ប្រទេសមានក្អែកជាសត្វក្លៀវក្លា" នោះជាសមាសប្រភេទដទៃ (នឹងពោលនៅខាងមុខ) ។

*ចំណុចសំខាន់ឋិតលើសេចក្ដីរបស់ប្រយោគ បើប្រែទៅស៊ីគ្នានឹងសមាសណា ក៏តាំងវិគ្គហៈនិងប្រែជាសមាសនោះ ៗ ទៅ ។ គប្បីចាំវិធីរៀងវិគ្គហៈរបស់សមាសនីមួយ ៗ ឱ្យបានច្បាស់លាស់ល្អដូចដែលបានពោលរួចហើយដែលនឹងមិនពោលទៀតទេ ។*

## ១.៥ សម្ភាវនបុព្វបទកម្មធារយសមាស

*សមាសនេះ បានដល់ សមាសដែលមានបុព្វបទជាបទសម្ភាវនៈ មានឧត្តរបទជាបទប្រធាន ។ ពាក្យថា* **សម្ភាវន** *ប្រែថា "ការសសើរ, ការលើក" ។ សមាសនេះមានចំណុចសំខាន់ត្រូវចាំគឺ វេលាចងវិគ្គហៈត្រូវចុះបទថា (* **អយំ** *)* **ឥតិ** *ស័ព្ទត្រូវប្រែថា "ថា" ជានិច្ច ។ វេលាបំប្រួញចូលជាមួយឧត្តរបទត្រូវលុបបទ (* **អយំ** *)* **ឥតិ** *ចេញដូចខាងក្រោមនេះ*

**( សមណ + សញ្ញា ) > សមណសញ្ញា**

*វិ.* **សមណោ ( អយំ ) ឥតិ សញ្ញា > សមណសញ្ញា** *=សេចក្ដីសម្គាល់ថា (អញ) ជាសមណៈ ។*

**(សត្ត + សញ្ញា ) > សត្តសញ្ញា**

*វិ.* **សត្តោ ឥតិ សញ្ញា > សត្តសញ្ញា** *=សេចក្ដីសម្គាល់ថាជាសត្វ ។*

**(ភិក្ខុ + បដិញ្ញា ) > ភិក្ខុបដិញ្ញា**

វិ. **ភិក្ខុ (អហំ) ឥតិ បដិញ្ញា > ភិក្ខុបដិញ្ញា** =សេចក្តីប្តេជ្ញាថា (អញ) ជាភិក្ខុ ។

**(មំស + សញ្ញា) > មំសសញ្ញា**

វិ. **មំសំ ឥតិ សញ្ញា > មំសសញ្ញា** =សេចក្តីសម្គាល់ថាជាសាច់ ។

**(ខត្តិយ + មាន) > ខត្តិយមាន**

វិ. **ខត្តិយោ (អហំ) ឥតិ មានោ > ខត្តិយមានោ** =មានះថា (អញ) ជាក្សត្រិយ៍ ។

ប្រែឱ្យយល់ងាយថា **មានោ** វីមានះ **ឥតិ** ថា (**អហំ** វីអញ) **ខត្តិយោ** ជាក្សត្រិយ៍ **ខត្តិយមានោ** ឈ្មោះថា **ខត្តិយមានោ**, **ខត្តិយ-មានោ** =មានះថា(អញ)ជាក្សត្រិយ៍ ។

បទសមាសនេះ បើឃើញតែរូបស័ព្ទអាចប្រែជាសមាសដទៃបាន ដូចជា **សមណសញ្ញា** បើប្រែថា "សេចក្តីសម្គាល់របស់សមណៈ" និង **ខត្តិយមាន** ប្រែថា "មានះរបស់ក្សត្រិយ៍" ដូច្នេះក៏បាន តែនោះចាត់ជាសមាសផ្សេងវិញ (មានពោលនៅខាងមុខ) ។ ចំណុចសំខាន់ត្រូវប្រែពីឧត្តរបទទៅរកបុព្វបទ ។

ដើម្បីឱ្យដឹងថាជាសមាសនេះឬមិនមែន សូមពិចារណាមើលថា តើបុព្វបទអាចប្រែគួបជាមួយ **ឥតិ** ស័ព្ទដែលប្រែថា "ថា" បានសេចក្តីពីរោះឬទេ និងសូមសង្កេតមើលបទចុងទៀត ពីព្រោះភាគច្រើនសមាសប្រភេទនេះនិយមប្រើពាក្យមានសេចក្តីថា "សេចក្តីសម្គាល់ថា..., គឺថា...,

"សម្មតិថា..., ពាក្យថា..., ដឹងថា..." ដូច្នេះជាដើមជាឧត្តរបទ ។ បើអាចប្រើពាក្យថា "ថា=**ឥតិ**" រាំងត្រង់ចន្លោះបុព្វបទនិងឧត្តរបទបាន សមាសនោះ ៗ ជា **សម្ភាវនសមាសបុព្វបទកម្មធារយសមាស** នេះហើយ ។ បទសមាសសម្រេចមកពីវិគ្គហៈនេះហៅថា **សម្ភាវនបុព្វបទកម្មធារយ-សមាស** ជាសមាសនាម ព្រោះមានបទប្រធានពេញបរិបូរណ៍ ។ ស័ព្ទឯទៀត ៗ គប្បីជ្រាបតាមន័យនេះ ។

## ១.៦ អវធារណបុព្វបទកម្មធារយសមាស

អវធារណបុព្វបទសមាសនេះ បានដល់ បទសមាសដែលមានបុព្វបទជាបទអវធារណៈ ។ ពាក្យថា **អវធារណ** ប្រែថា "ឃាត់" ដោយប្រើ **ឯវ** ស័ព្ទប្រែថា "...គឺ..." រាំងបុព្វបទពីឧត្តរបទដែលជាបទប្រធាន ។ ទាំងបុព្វបទនិងឧត្តរបទនិយមប្រើស័ព្ទជានាមនាមដែលមានន័យស្មើគ្នាក្នុងសេចក្តីថាអាចប្រើជំនួសគ្នាបាន ឧ.

វិ. **បញ្ញា ឯវ អាភា** > **បញ្ញាអាភា** =ពន្លឺគឺបញ្ញា ។
វិ. **ពុទ្ធោ ឯវ រតនំ** > **ពុទ្ធរតនំ** =កែវគឺព្រះពុទ្ធ ។
វិ. **ធម្មោ ឯវ រតនំ** > **ធម្មរតនំ** =កែវគឺព្រះធម៌ ។
វិ. **សង្ឃោ ឯវ រតនំ** > **សង្ឃរតនំ** =កែវគឺព្រះសង្ឃ ។
វិ. **ធម្មោ ឯវ ចក្កោ** > **ធម្មចក្កោ** =ចក្រគឺព្រះធម៌ ។

## កំណត់សម្គាល់

ពាក្យថា **ឯវ** ជានិបាតស័ព្ទប្រាប់សេចក្តីហាមឃាត់ប្រែថា "មែនពិត" ខាងសម្ពន្ធហៅថា **អវធារណត្ថ** =មានសេចក្តីថាហាម ។ ប៉ុន្តែពេលប្រើក្នុងរូបវិគ្គហៈនេះ ត្រូវប្រែថា "គឺ" ដើម្បីឃាត់សេចក្តីដទៃដូចជា **ជម្មចក្កោ** =ចក្រគឺធម៌ ។ ពាក្យថា **ចក្ក** =ចក្រ, កង់ មានទូទៅ ប៉ុន្តែក្នុងសមាសនេះហាមឃាត់ទុក គឺឱ្យយកចក្រប្រៀបធៀបតែជាមួយនឹងធម៌ប៉ុណ្ណោះ ។

បទសមាសមកពីវិគ្គហៈនេះហៅថា **អវធារណបុព្វបទកម្មធារយសមាស** ។ ចំណុចសំខាន់គឺមានពាក្យប្រែថា "...គឺ..." នៅរាំងបុព្វបទនិងឧត្តរបទជានិច្ច ។ បើប្រែខុសពីខាងលើនេះ ឧ. **បញ្ញាអាភា** បើប្រែថា "ពន្លឺនៃបញ្ញា" នោះគឺជាឆដ្ឋីតប្បុរិសសមាស (មានពោលនៅខាងមុខ) ។ ស័ព្ទឯទៀត ៗ សូមជ្រាបតាមសេចក្តីនេះ ។

## វិធីប្រែនិងតាំងវិគ្គហៈ
## នៃកម្មធារយសមាស

ការតាំងវិគ្គហៈរបស់កម្មធារយសមាសមាន ២ បែប គឺបែបសង្ខេបនិងពិស្តារ ។

## ១. វិសេសនបុព្វបទកម្មធារយសមាស

### ១.១ បែបសង្ខេប

*ប្រើតែពីរបទគឺ បទប្រធាន និង បទវិសេសនៈ ប៉ុណ្ណោះ ឧ.*

វិ. **មហន្តោ ថេរោ > មហាថេរោ** =*ព្រះថេរៈជាធំ ។*

### ១.២ បែបពិស្តារ

*លោកឱ្យថែម* **ច** *ស័ព្ទប្រែថា "ផង" និង* **ត** *សព្វនាមបំបែកជា* **សោ** *ឬ* **តំ** *ទៅតាមលិង្គនិងប្រែថា "នោះ" និង* **ឥតិ** *ស័ព្ទប្រែថា "ព្រោះហេតុនោះ" ឧ.*

វិ. **មហន្តោ ច សោ ថេរោ ចាតិ > មហាថេរោ ។**

*វិព្រះថេរៈ នោះ ផង ជាធំ ផង ព្រោះហេតុនោះ ឈ្មោះថា* **មហាថេរោ** (*ព្រះថេរៈជាធំ*) ។

*សូមសង្កេតមើលមានការថែម* **ច** *ស័ព្ទឱ្យថែមដល់ទៅពីរកន្លែង គឺ ទីចុងបទវិសេសនៈនិងចុងបទប្រធាន ។ ចំពោះ* **ច** *ស័ព្ទចុងបទប្រធាន ត្រូវសរសេរចូលជាមួយ* **ឥតិ** *ស័ព្ទជា* (**ច** + **ឥតិ**) > **ចាតិ** *ជានិច្ច ។ រូបវិគ្គហៈរបស់កម្មធារយសមាសឯទៀត ៗ ក៏មានវិធីរៀងវិគ្គហៈបែបដូចគ្នា ដូចខាងក្រោមនេះ*

## ២. វិសេសនុត្តរបទកម្មធារយសមាស

បែបសង្ខេប: សត្តោ វិសេសោ > សត្តវិសេសោ =*សត្វវិសេស ។*

បែបពិស្តារ: សត្តោ ច សោ វិសេសោ ចាតិ > សត្តវិសេសោ=*សត្វនោះ ផង ដែលវិសេស ផង ព្រោះហេតុនោះ ឈ្មោះថា* សត្តវិសេសោ ។

### ៣. វិសេសនោភយបទកម្មធារយសមាស

បែបសង្ខេប: សីតញ្ច សមដ្ឋញ្ច > សីតសមដ្ឋំ (ហាធំ) =*(ទឹ)ត្រជាក់ផង រអិលផង ។*

បែបពិស្តារ: សីតញ្ច តំ សមដ្ឋញ្ចាតិ > សីតសមដ្ឋំ ។

### ៤. វិសេសនោបមបទកម្មធារយសមាស

បែបសង្ខេប: សង្ខំ ឥវ បណ្ឌរំ > សង្ខបណ្ឌរំ (ខីរំ) =*(ទឹកដោះ)សដូចស័ង្ខ ។*

បែបពិស្តារ: សង្ខញ្ច ឥវ តំ បណ្ឌរញ្ចាតិ > សង្ខបណ្ឌរំ ខីរំ ។

### ៥. សម្ភាវនបុព្វបទកម្មធារយសមាស

បែបសង្ខេប: ខត្តិយោ (អហំ) ឥតិ មានោ > ខត្តិយមានោ =*មានះថា (អញ)ជាក្សត្រិយ៍ ។*

បែបពិស្តារ: ខត្តិយោ ច (អហំ)ឥតិ សោ មានោ ចាតិ >ខត្តយមានោ

### ៦. អវធារណបុព្វបទកម្មធារយសមាស

**បែបសង្ខេប: ពុទ្ធោ ឯវ រតនំ > ពុទ្ធរតនំ** =*កែវគឺព្រះពុទ្ធ ។*

**បែបពិស្តារ: ពុទ្ធោ ច ឯវ តំ រតនញ្ចាតិ > ពុទ្ធរតនំ ។**

*ស័ព្ទឯទៀត ៗ គប្បីយកតាមវិធីនេះដូចគ្នា ។ ប៉ុន្តែនិយមរៀងវិគ្គហៈបែបសង្ខេប ពីព្រោះអាចប្រែបានសេចក្តីដូចគ្នា ។*

(*កម្មធារយសមាសចប់ត្រឹមនេះ*)

## លំហាត់នៃមេរៀនទី ៤៦

### *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

១. *តើពាក្យថា* **សមាស** *ប្រែថាយ៉ាងម៉េច ?*

២. *តើសមាសនិងសន្ធិខុសគ្នាដូចម្តេច ?*

៣. *វិធីធ្វើសមាសមាន ២ បែបគឺ* **លុត្តសមាស** *និង* **អលុត្តសមាស** *តើមានកិច្ចខុសគ្នាយ៉ាងណាខ្លះ ?*

៤. *ចំពោះស័ព្ទដែលមានការន្តជា* **អា, ឦ** *និង* **ឩ** *វេលាយកមកធ្វើជាបទសមាស តើត្រូវធ្វើដូចម្តេចខ្លះ ?*

៥. *ចំពោះស័ព្ទដែលជាទ្វិលិង្គ វេលាយកមកធ្វើជាបទសមាសតើត្រូវធ្វើដូចម្តេចខ្លះ ?*

៦. ដោយចំណែកធំ ៗ សមាសមាន ៦ យ៉ាងតើមានឈ្មោះអ្វីខ្លះ ?
៧. តើស័ព្ទដែលអាចយកមកធ្វើជាបទសមាសគឺស័ព្ទប្រភេទណាខ្លះ ?
៨. កម្មធារយសមាសមាន ៦ យ៉ាងតើមានឈ្មោះហៅដូចម្ដេចខ្លះ ?
៩. តើកម្មធារយសមាសដែលមានបុព្វបទជាបទវិសេសនៈជាសមាស អ្វី ? សូមឱ្យឧទាហរណ៍ ។
១០. តើកម្មធារយសមាសដែលមានឧត្តរបទជាបទវិសេសនៈជាសមាស អ្វី ? សូមឱ្យឧទាហរណ៍ ។
១១. តើកម្មធារយសមាសដែលមានបទទាំងពីរជាបទវិសេសនៈនិងមាន បទដទៃជាប្រធាន តើជាសមាសអ្វី ? សូមឱ្យឧទាហរណ៍ ។
១២. តើកម្មធារយសមាសដែលមានបទឧបមាជាបទវិសេសនៈ មាន ឧត្តរបទជាបទប្រធាន ជាសមាសអ្វី ? សូមឱ្យឧទាហរណ៍ ។
១៣. តើកម្មធារយសមាសដែលមានបុព្វបទជាបទសម្ភាវនៈ មានឧត្តរ-បទជាបទប្រធាន ជាសមាសអ្វី ? សូមឱ្យឧទាហរណ៍ ។
១៤. តើកម្មធារយសមាសដែលមានបុព្វបទជាបទអវធារណៈ មាន ឧត្តរបទជាបទប្រធាន ជាសមាសអ្វី ? សូមឱ្យឧទាហរណ៍ ។
១៥. ចូរតាំងវិគ្គហៈរបស់កម្មធារយសមាសទាំង ៦ យ៉ាងបែបពិស្ដារ ៦ វិគ្គហៈតាមឈ្មោះហៅទាំង ៦ នោះ ៗ ។

**(ចប់មេរៀនទី ៤៦)**

# មេរៀនទី ៤៧

# អធិប្បាយអំពីសមាស (ត)

## ២. ទិគុសមាស

(Numeral Determinate compounds)

*ទិគុសមាសនេះមានគតិដូចកម្មធារយសមាសគ្រប់ប្រការ ទាំងការបំប្រួញនិងវិធីរៀងវិគ្គហៈ ។ ប៉ុន្តែអ្វីដែលខុសប្លែកនោះ គឺបុព្វបទប្រើតែបកតិសំខ្យាគុណនាមចាប់ពី* **ឯក** *រហូតដល់* **អដ្ឋនវុតិ** *ប៉ុណ្ណោះ, រីឯឧត្តរបទជានាមនាមតាមធម្មតា ។ ពាក្យថា* **ទិគុ** *សម្រេចមកពីបកតិ-សំខ្យាគឺ (* **ទ្វិ** > **ទិ** + **គុណ** *)* > **ទិគុណ** *=ចំណែកពីរ, វេលាធ្វើសមាសលុប* **ណ** *បាត់ទៅ ។ សមាសនេះមានបំប្រួញតែបកតិសំខ្យាចូលជាមួយនាមនាមតែម៉្យាង ដែលមានវិធីរៀងវិគ្គហៈតាមឈ្មោះ ២ បែបគឺ* **សមាហារទិគុសមាស** និង **អសមាហារទិគុសមាស** ។

## វិធីរៀងវិគ្គហៈរបស់ទិគុសមាស

### ២.១ សមាហារទិគុសមាស

*ពាក្យថា* **សមាហារ** *ប្រែថា "រួបរួម" ក្នុងសេចក្តីថា បទសមាស*

*នេះជាពាក្យប្រមូលក្រសោបន័យចូលតែមួយ ។ ក្នុងវិគ្គហៈមានបុព្វបទជាបកតិសំខ្យានិងមានឧត្តរបទជានាមនាមពហុវចនៈជាតួប្រធាន ។ បទសមាសសម្រេចពីវិគ្គហៈនៃសមាសនេះមានអត្ថជាឯកវចនៈ ដែលត្រូវបំបែកជានបុំសកលិង្គឯកវចនៈជានិច្ច ។ ទោះបីជានាមនាមជាប្រធាននោះ ៗ មានលិង្គអ្វីក៏ដោយ ដូច្នេះហើយទើបហៅថា* **សមាហារ** *ឧ.*

*វិ.* **បញ្ច ពលានិ** > **បញ្ចពលំ** =*កម្លាំងប្រាំ ។*

*វិ.* **តយោ លោកា** > **តិលោកំ** =*លោកបី ។*

*វិ.* **ចត្តារោ មគ្គា** > **ចតុមគ្គំ** =*មគ្គបួន ។*

*វិ.* **បញ្ច សតានិ** > **បញ្ចសតំ** =*រយប្រាំ (ប្រាំរយ) ។*

## ២.២ អសមាហារទិគុសមាស

*ពាក្យថា* **អសមាហារ** *ប្រែថា "មិនរួបរួម" ក្នុងសេចក្ដីថាបទសមាសនេះជាពាក្យមិនប្រមូលក្រសោបបន័យចូលតែមួយទេ ដូចក្នុងបទថា* **បញ្ចិន្ទ្រិយានិ** *=ឥន្ទ្រីយ៍ប្រាំ គឺរាប់ឥន្ទ្រីយ៍មួយ ៗ ដាច់ពីគ្នា ។ សមាសនេះខុសពីសមាហារទិគុ ត្រង់ដែលបទសមាសមកពីវិគ្គហៈនេះត្រូវបំបែកជាពហុវចនៈ ប៉ុន្តែក៏មានជាឯកវចនៈផងដែរ និងដែលត្រូវទុកឱ្យគង់រូបតាមដើម ពីព្រោះនៅតែមានអត្ថជាពហុវចនៈដដែល ឧ.*

វិ. បញ្ច ពលានិ > បញ្ចពលានិ =កម្លាំងប្រាំទាំងឡាយ ។

វិ. ឯកោ បុគ្គលោ > ឯកបុគ្គលោ =បុគ្គលម្នាក់ ។

វិ. ឆ អាយតនានិ > ឆឡាយតនានិ =អាយតនៈប្រាំមួយទាំង-ឡាយ។

បទសមាសនេះជានាមនាមអាចបំបែកតាមវិភត្តិផ្សេង ៗ ដែលអាចសង្កេតឃើញយ៉ាងងាយ ពីព្រោះមានបុព្វបទជាបកតិសំខ្យាតែម៉្យាង ។ សូមសំគាល់ដូច្នេះថា **កម្មធារយសមាស** មាននាទីបំប្រួញគុណនាម ឬនាមនាមជាមួយនឹងនាមនាមឱ្យទៅជាបទតែមួយ ។ រីឯ **ទិគុសមាស** មាននាទីបំប្រួញបកតិសំខ្យាជាមួយនឹងនាមនាមឱ្យទៅជាបទតែមួយ ។ នេះជាចំណុចគួរចងចាំ វេលាជួបស័ព្ទប្រភេទនេះក្នុងទីណាក៏អាចប្រែបានភ្លាម ៗ ដោយញែកស័ព្ទតាំងវិគ្គហៈឱ្យត្រូវតាមល័ក្ខខ័ណ្ឌដូចពោលរួចហើយ ។

(ទិគុសមាសចប់)

## ៣. តប្បុរិសសមាស

## (Dependent Determinate Compounds)

**តប្បុរិស** តាមរូបស័ព្ទមកពី ( **ត** + **បុរិស** ) > **តប្បុរិស** មានវិគ្គហៈថា **តស្ស បុរិសោ** > **តប្បុរិសោ** ប្រុសរបស់គេ ។ សមាសនេះប្រើស័ព្ទច្រើនប្រភេទមិនកំណត់ទេ ។

វិធីបំប្រួញមានគតិដូចកម្មធារយសមាសដែរ ប៉ុន្តែមានវិធីរៀងរូបវិគ្គហៈផ្សេងគ្នាពីកម្មធារយសមាសនិងទិគុសមាសបន្តិច គឺបុព្វបទត្រូវបំបែកតាមវិភត្តិនោះ ៗ មាន ៦ ចាប់ពីទុតិយាវិភត្តិដល់សត្តមីវិភត្តិ ។ ចំណែកឯឧត្តរបទជាបឋមាវិភត្តិតែម៉្យាងប៉ុណ្ណោះ ដូច្នេះហើយទើបហៅថា **តប្បុរិសសមាស** ដែលចែករូបវិគ្គហៈជា ៦ ប្រភេទតាមឈ្មោះរបស់វិភត្តិដូចខាងក្រោមនេះ

| | |
|---|---|
| **៣.១ ទុតិយាតប្បុរិសមាស** | **៣.៤ បញ្ចមីតប្បុរិសមាស** |
| **៣.២ តតិយាតប្បុរិសមាស** | **៣.៥ ឆដ្ឋីតប្បុរិសមាស** |
| **៣.៣ ចតុត្ថីតប្បុរិសមាស** | **៣.៦ សត្តមីតប្បុរិសមាស** |

ការឱ្យឈ្មោះរូបវិគ្គហៈដូចខាងលើនេះ គឺយកតាមឈ្មោះរបស់វិភត្តិនៃបុព្វបទ ព្រោះបុព្វបទត្រូវបំបែកទៅតាមវិភត្តិណាមួយជានិច្ច ។ វីឯបឋមាវិភត្តិមិនមានទេ ពីព្រោះសម្រាប់ប្រើជាមួយសមាសបីប្រភេទគឺ **កម្មធារយសមាស**, **ទិគុសមាស** និង **ទ្វន្ទសមាស** ប៉ុណ្ណោះ ។

ប្រសិនបើបានជួបស័ព្ទនេះនៅទីណា និងចង់ជ្រាបថាជាតប្បុរិស-សមាសណាមួយនោះ ត្រូវញែកបុព្វបទចេញពីឧត្តរបទ រួចហើយប្រែ

បុព្វបទនិងឧត្តរបទបញ្ចូលគ្នាមើលថា តើពាក្យប្រែរបស់វិភត្តិគឺអាយត-និបាតណាមួយត្រូវសមរម្យជាងគេបំផុត ក៏ជាបទរបស់តប្បុរិសសមាសនោះហើយ ដូចមានវិធីតាំងវិគ្គហៈនិងឧទាហរណ៍តទៅនេះ

## វិធីតាំងវិគ្គហៈនិងប្រែរបស់តប្បុរិសសមាស

## ៣.១ ទុតិយាតប្បុរិសសមាស

សមាសនេះក្នុងវិគ្គហៈមានបុព្វបទជានាមនាម ដែលត្រូវបំបែកជាទុតិយាវិភត្តិជានិច្ច មានអាយតនិបាតប្រែថា "នូវ, ដល់, ញ៉ាំង, អស់, ចំពោះ, នឹង" ជាដើម ។ មានឧត្តរបទជាគុណនាមសុទ្ធឬកិតកិរិយាដែលប្រើជាបទគុណ ត្រូវបំបែកជាបឋមាវិភត្តិនិងមានបទដទៃ(អញ្ញបទ)ជាប្រធាន ឧ.

(**សុខ** ន. + **បត្ត** កិត.) > **សុខប្បត្ត**

វិ. **សុខំ បត្តោ** > **សុខប្បត្តោ (បុរិសោ)** =(បុរស) ដល់ហើយសេចក្ដីនូវសុខ ។

វិ. **គាមំ គតោ** > **គាមគតោ (បុរិសោ)** =(បុរស) ទៅហើយកាន់ភូមិ ។

វិ. **រត្តឹ សោភណោ** > **រត្តិសោភណោ (ចន្ទោ)** =(ដួងច័ន្ទ) ល្អអស់រាត្រី ។

# ៣.២ តតិយាតប្បុរិសសមាស

សមាសនេះក្នុងវិគ្គហៈមានបុព្វបទជានាមនាម ដែលត្រូវបំបែកជាតតិយាវិភត្តិជានិច្ច មានអាយតនិបាតប្រែថា "ដោយ, តាម, ដែល, ជាមួយ, ព្រោះ, មាន" ជាដើម ។ មានឧត្តរបទជានាមនាមឬកិតកិរិយា បំបែកជាបឋមាវិភត្តិ ឧ.

(អសិ ន. + កលហ ន.) > អសិកលហ

វិ. អសិនា កលហោ > អសិកលហោ =ជម្លោះដោយដាវ ។

(សល្ល ន. + វិទ្ធ កិត.) > សល្លវិទ្ធ

វិ. សល្លេន វិទ្ធោ > សល្លវិទ្ធោ (សត្តោ) =(សត្វ) មុតហើយដោយព្រួញ ។

# ៣.៣ ចតុត្ថីតប្បុរិសសមាស

សមាសនេះក្នុងវិគ្គហៈមានបុព្វបទជានាមនាម ដែលត្រូវបំបែកជាចតុត្ថីវិភត្តិ មានអាយតនិបាតប្រែថា "ដើម្បី" និងមានឧត្តរបទជានាម-នាមបំបែកជាបឋមាវិភត្តិ ឧ.

វិ. អាគន្តុកស្ស ភត្តំ > អាគន្តុកភត្តំ =ភត្តដើម្បីអ្នកទើបមកដល់។

វិ. គិលានស្ស ភេសជ្ជំ > គិលានភេសជ្ជំ =ថ្នាំដើម្បីអ្នកឈឺ ។

វិ. មតកស្ស ភត្តំ > មតកភត្តំ =ភត្តដើម្បីអ្នកស្លាប់ ។

*នាមកិតក:ដែលចុះ* **តុំ** *បច្ច័យផ្សំនឹង* **កាម, កាមតា** *ប្រែថា "សេចក្ដីប្រាថ្នា" ក៏ចាត់ជាចតុត្ថីតប្បុរិសនេះដែរ វេលាបំប្រួញត្រូវលុបនិគ្គហិតចេញទុកតែ* **តុ** *ឧ.*

*វិ.* **គន្តុំ កាមោ** > **គន្តុកាមោ** =*សេចក្ដីប្រាថ្នាដើម្បីទៅ ។*

*វិ.* **សោតុំ កាមតា** > **សោតុកាមតា** =*សេចក្ដីប្រាថ្នាដើម្បីស្ដាប់ ។*

*វិ.* **វត្តុំ កាមោ** > **វត្តុកាមោ** =*សេចក្ដីប្រាថ្នាដើម្បីពោល ។*

*វិ.* **ទាតុំ កាមតា** > **ទាតុកាមតា** =*សេចក្ដីប្រាថ្នាដើម្បីឱ្យ ។*

*បទសមាសនេះជានាមនាមព្រោះមានបទប្រធានពេញបរិបូរណ៍ ។*

## ៣.៤ បញ្ចមីតប្បុរិសសមាស

*សមាសនេះក្នុងវិគ្គហ:មានបុព្វបទជានាមនាម ដែលត្រូវបំបែកជាបញ្ចមីវិភត្តិ ប្រែថា "ពី, ចាក, ជាង, ហេតុ" ជាដើម និងមានឧត្តរបទជានាមនាម, គុណនាមឬសព្វនាម បំបែកជាបឋមាវិភត្តិឱ្យត្រូវតាមការន្តនិងលិង្គនោះ ៗ ឧ.*

*វិ.* **អគ្គិម្ហា ភយំ** > **អគ្គិភយំ** =*ភ័យអំពីភ្លើង (អគ្គីភ័យ) ។*

*វិ.* **ចោរម្ហា ភយំ** > **ចោរភយំ** =*ភ័យអំពីចោរ ។*

*វិ.* **តស្មា អញ្ញោ** > **តទញ្ញោ** (**បុគ្គលោ**) =*(បុគ្គល) ដទៃអំពី (បុគ្គល)នោះ ។*

វិ. **កាកស្ស សូរោ > កាកសូរោ (ឯរោ)** =(នរៈ) ក្លាជាងក្អែក ។

វិ. **ពន្ធនា មុត្តោ > ពន្ធនមុត្តោ (សត្តោ)** =(សត្វ) រួចហើយពីគ្រឿងចង (=រួចពីចំណង) ។

បទសមាសនេះជានាមនាមនិងគុណនាម អាចបំបែកក្នុងរូបវិភត្តិផ្សេង ៗ បានគ្រប់វិភត្តិតាមការន្តនិងលិង្គនោះ ៗ ។

## ៣.៥ ឆដ្ឋីតប្បុរិសសមាស

សមាសនេះ ក្នុងវិគ្គហៈមានបុព្វបទជានាមនាម ដែលត្រូវបំបែកជាឆដ្ឋីវិភត្តិ ប្រែថា "នៃ, របស់" និងមានឧត្តរបទជានាមនាមបំបែកជាបឋមាវិភត្តិតាមការន្តនិងលិង្គនោះ ៗ ដូចជា

វិ. ពុទ្ធស្ស សាវកោ > ពុទ្ធសាវកោ =សាវ័ករបស់ព្រះពុទ្ធ ។

វិ. សេដ្ឋិនោ បុត្តោ > សេដ្ឋិបុត្តោ =បុត្ររបស់សេដ្ឋី ។

វិ. ចោរស្ស ភយំ > ចោរភយំ =ភ័យរបស់ចោរ ។

វិ. រញ្ញោ បុត្តោ > រាជបុត្តោ =ឱរសរបស់ព្រះរាជា ។

វិ. រុក្ខស្ស សាខា > រុក្ខសាខា =មែកនៃឈើ ។

វិ. បញ្ញាយ អាភា > បញ្ញាអាភា =ពន្លឺនៃបញ្ញា ។

## ៣.៦ សត្តមីតប្បុរិសសមាស

សមាសនេះក្នុងវិគ្គហៈមានបុព្វបទជានាមនាម ដែលត្រូវបំបែកជាសត្តមីវិភត្តិ ប្រែថា "ក្នុង, ជិត, លើ, កាល" ជាដើម និងមានឧត្តរបទជានាមនាមបំបែកជាបឋមាវិភត្តិតាមការន្តនិងលិង្គនោះ ៗ ឧ.

វិ. រុក្ខេ សកុណោ > រុក្ខសកុណោ =បក្សីលើដើមឈើ ។

វិ. រូបេ សញ្ញា > រូបសញ្ញា =សេចក្តីសម្គាល់ក្នុងរូប ។

វិ. គាមេ អាវាសោ > គាមាវាសោ =វត្តជិតភូមិ ។

វិ. វនស្មឹ បុប្ផំ > វនបុប្ផំ =បុប្ផាក្នុងព្រៃ (=ផ្កាព្រៃ) ។

វិ. នទិយំ មច្ឆា > នទីមច្ឆា =ត្រីក្នុងស្ទឹង ។

វិ. ឧក្ខលិយំ ភត្តំ > ឧក្ខលិភត្តំ =បាយក្នុងឆ្នាំង ។

បទសមាសនេះជានាមនាមតែម៉្យាង បំបែកក្នុងរូបវិភត្តិផ្សេង ៗ បានគ្រប់វិភត្តិតាមការន្តនិងលិង្គនោះ ៗ ។

## ឧបបទសមាស ឬ ឧបបទតប្បុរិសសមាស

ដូចបានអធិប្បាយរួចហើយថា នាមកិតកៈខ្លះ ត្រូវមានសទ្ទុបបទនៅខាងដើម នាមកិតកៈបែបនេះក៏ជាបទសមាសដែរហៅថា **ឧបបទ-សមាស ឬ ឧបបទតប្បុរិសសមាស** ក៏បាន ។ បទសមាសដូច្នេះមានបុព្វបទជាស័ព្ទផ្សេង ៗ បំបែកជាទុតិយាវិភត្តិ និងមានឧត្តរបទជាធាតុ-ស័ព្ទដែលមានចុះបច្ច័យនោះ ៗ ផង ។ ចំពោះវិគ្គហៈសូមរកមើលវិធី

*តាំងវិគ្គហៈក្នុងនាមកិតកៈចាប់ពីមេរៀនទី ៣២ ដល់ទី ៣៨ ខាងក្រោម ជាឧទាហរណ៍ខ្លះ ៗ*

**ធម្មំ ចារី** > **ធម្មចារី** =*អ្នកប្រព្រឹត្តនូវធម៌ ។*

**ទីបំ ករោ** > **ទីបង្ករោ** =*អ្នកធ្វើនូវទីពឹង ។*

**កម្មំ ករោ** > **កម្មការោ** =*អ្នកធ្វើនូវការងារ ។*

**ភយំ ទស្សី** > **ភយទស្សី** =*អ្នកឃើញនូវភ័យ ។*

*(តប្បុរិសសមាសចប់)*

## ៤. ទ្វន្ទ្វសមាស

(Copulative or Aggregative Compounds)

*ពាក្យថា* **ទ្វន្ទ្វ** *បើតាមរូបស័ព្ទមកពីបកតិសំខ្យាគឺ* **ទ្វិ** + **ទ្វិ**, *ផ្លាស់ជា* **ទ្វ** + **ទ្វ**, *ចុះ* **ន** *អាគមតាមក្បួនព្យញ្ជនសំយោគសម្រេចជា* **ទ្វន្ទ្វ** *ប្រែថា "ពីរ ៗ" ។ ក្នុងសេចក្តីថា សមាសនេះមាននាទីបំប្រួញនាមនាមដែលជាគូគ្នាដូចជា ព្រះអាទិត្យគូនឹងព្រះច័ន្ទ ទើបបានឈ្មោះថា* **ទ្វន្ទ្វសមាស** *ប្រែថា "បំប្រួញនាមស័ព្ទជាពាក្យគូគ្នា"* មាន ២ *យ៉ាងគឺ* **សមាហារទ្វន្ទ្វ-សមាស** *និង* **អសមាហារទ្វន្ទ្វសមាស** *។*

# វិធីតាំងវិគ្គហៈនៃទ្វន្ទសមាស

១. បទណាជា ឥ ឬ ឧ ការន្តរៀងជាបុព្វបទ ។

២. បទណាមានព្យាង្គតិចជាងគេរៀងមុនគេ ។

៣. បទណាជា ឦ ឬ ឩ ការន្ត វេលាបំប្រួញជាបទសមាសត្រូវរស្សៈជា ឥ ឬ ឧ ។

៤. បើបុព្វបទជាឥត្ថីលិង្គក្នុងបទសមាសត្រូវផ្លាស់ជាបុំលិង្គវិញ ។

៥. បើបុព្វបទនិងឧត្តរបទជានាមនាម ដែលជាគូនឹងគ្នាចាប់ពី ២ សព្ទឡើងទៅ បទនីមួយ ៗ ត្រូវបំបែកជាបឋមាវិភត្តិជានិច្ច ។

៦. មួយបទ ៗ ក្នុងរូបវិគ្គហៈ ត្រូវមាន ច សព្ទរៀងខាងចុងជាមួយគ្រប់ ៗ បទប្រែថា "ផង" ។ កាលបើបំប្រួញជាបទមួយហើយត្រូវលុប ច សព្ទចេញ ប្រែថា "និង" វិញ ។

សមាសនេះអាចបំប្រួញបទលើសពីពីរឡើងទៅ ។

## ៤.១ សមាហារទ្វន្ទសមាស

**សមាហារ** ប្រែថា "រួបរួម" មានគតិដូចទិគុសមាសគឺបុព្វបទឬឧត្តរបទក្នុងរូបវិគ្គហៈទោះជាមាន ការន្ត, លិង្គ, វចនៈអ្វីក៏ដោយដែលជាបទប្រធាន វេលាបំប្រួញចូលជាមួយបទមួយទៀតហើយ បទសមាស

*ត្រូវបំបែកជាឯកវចននបុំសកលិង្គជានិច្ច ពីព្រោះបទសមាសនេះមាន ន័យជាក្រុម ឧ.*

*វិ.* **បត្តោ ច ចីវរញ្ច > បត្តចីវរំ** *=បាត្រនិងចីវរ ។*

*វិ.* **ជរា ច មរណញ្ច > ជរាមរណំ** *=ចាស់និងសេចក្ដីស្លាប់ ។*

*វិ.* **ឆវិ ច មំសញ្ច លោហិតញ្ច > ឆវិមំសលោហិតំ** *=ស្បែកនិង សាច់និងឈាម ។*

*វិ.* **សមថោ ច វិបស្សនា ច > សមថវិបស្សនំ** *=សមថនិង វិបស្សនា ។*

## ៤.២ អសមាហារទ្វន្ទសមាស

**អសមាហារ** *ប្រែថា "មិនរួបរួម" មានវិធីរៀងវិគ្គហៈដូចសមាហារ ដែរ ប៉ុន្តែបទសមាសត្រូវបំបែកជាបឋមាវិភត្តិពហុវចនៈឱ្យត្រូវតាមការន្ត និងលិង្គនោះ ៗ ពីព្រោះបទសមាសនេះមានន័យទីទៃពីគ្នាតាមរូបស័ព្ទ ដើម ឧ.*

*វិ.* **មាតា ច បិតា ច > មាតាបិតរោ** *=មាតានិងបិតា.ទ. ។*

*វិ.* **ចន្ទិមា ច សុរិយោ ច > ចន្ទិមសុរិយា** *=ព្រះច័ន្ទនិងព្រះ អាទិត្យ.ទ. ។*

*វិ.* **សមណោ ច ព្រាហ្មណោ ច > សមណព្រាហ្មណា** *= សមណនិងព្រាហ្មណ៍.ទ. ។*

វិ. **សារីបុត្តោ ច មោគ្គល្លានោ ច > សារីបុត្តមោគ្គល្លានា** = *ព្រះសារីបុត្រនិងព្រះមោគ្គល្លាន.ទ.។*

វិ. **ភិក្ខុ ច សាមណេរោ ច > ភិក្ខុសាមណេរា** =*ភិក្ខុនិងសាមណេរ.ទ.។*

វិ. **បណ្ណំ ច បុប្ផំ ច ផលំ ច > បណ្ណបុប្ផផលានិ** =*ស្លឹកនិងផ្កានិងផ្លែ.ទ.។*

វិ. **ទេវោ ច មនុស្សោ ច នាគោ ច អសុរោ ច គន្ធព្វោ ច > ទេវមនុស្សនាគាសុរគន្ធព្វា** =*ទេវតានិងមនុស្សនិងនាគនិងអសុរនិងគន្ធព្វ.ទ.។*

## កំណត់សម្គាល់

*បទសមាសនេះជានាមនាមសុទ្ធ ដែលអាចសង្កេតឃើញយ៉ាងងាយ ពីព្រោះនិយមបំប្រួញស័ព្ទនាមនាមប្រភេទដែលមានសេចក្ដីជាគូគ្នាដូចជា មាតាគូនឹងបិតា, ឧបាសកគូនឹងឧបាសិកា ជាដើម ។ មានពាក្យប្រែថា "និង" ជានិច្ចដូចជា ភិក្ខុនិងសាមណេរ, ឧបាសកនិងឧបាសិកា ។ល។*

*ចំណុចខុសគ្នារវាងទិគុសមាសនិងទ្វន្ទសមាស គឺថា ទិគុសមាសប្រើបកតិសំខ្យាជាបុព្វបទនិងមាននាមនាមជាឧត្តរបទ ក្នុងវិគ្គហៈមានបទប្រធានមួយតួ មិនមាន ច ស័ព្ទទេ ។ រីឯទ្វន្ទសមាសវិញក្នុងរូបវិគ្គហៈ*

គ្រប់បទទាំងអស់ជាបទប្រធាន មាន ៥ ស័ព្ទផង ទោះជាមានប៉ុន្មានបទក៏មិនកំណត់ទេ ។

សមាសក្រៅពីនេះមិនអាចបំប្រួញបទលើសពីពីរស័ព្ទបានទេ វៀរតែ **មិស្សកសមាស** (សមាសចម្រុះ)ដែលនឹងអធិប្បាយនៅខាងមុខ ។

(ទ្វន្ទសមាសចប់)

## ឯកសេសសមាស

អសមាហារទ្វន្ទសមាសនេះនៅមានវិធីពិសេសមួយបែបទៀត គឺបំប្រួញដោយការទុកឱ្យនៅសល់ត្រឹមតែមួយបទប៉ុណ្ណោះ ដែលហៅថា **ឯកសេសសមាស** (ឯក + សេស + សមាស) ប្រែថា "វិធីបំប្រួញដោយទុកឱ្យសល់នៅតែមួយបទ" ។ បទសមាសនេះត្រូវបំបែកជាពហុវចនៈជានិច្ចដែលមានបួនយ៉ាងទៀតគឺ **បុព្វកសេសសមាស, បរកសេសសមាស, សរូបេកសេសសមាស** និង **វិរូបេកសេសសមាស** ។

### ១. បុព្វេកសេសសមាស

បុព្វេកសេសសមាស (បុព្វ + ឯក + សេស + សមាស)

*ប្រែថា "វិធីបំប្រួញដោយលុបបទចុងទុកឱ្យនៅសល់តែបទដើម" ឧ.*

*វិ.* **សារីបុត្តោ ច មោគ្គល្លានោ ច > សារីបុត្តា** *=ព្រះសារីបុត្តនិងព្រះមោគ្គល្លាន.ទ.ៗ*

*វិ.* **ទាយកោ ច ទាយិកា ច > ទាយកា** *=ទាយកនិងទាយិកា.ទ. ៗ*

*វិ.* **មាតា ច បិតា ច > មាតរោ** *=មាតានិងបិតា.ទ. ៗ*

## ២. បរេកសេសសមាស

បរេកសេសសមាស (បរ + ឯក + សេស + សមាស) *ប្រែថា "វិធីបំប្រួញដោយលុបបទដើមទុកឱ្យនៅសល់តែបទចុង" ឧ.*

*វិ.* **ឧបាសកោ ច ឧបាសិកា ច > ឧបាសិកា** *=ឧបាសកនិងឧបាសិកា.ទ. ៗ*

*វិ.* **សារីបុត្តោ ច មោគ្គល្លានោ ច > មោគ្គល្លានា** *=ព្រះសារីបុត្តនិងព្រះមោគ្គល្លាន.ទ.ៗ*

*វិ.* **សមណោ ច ព្រាហ្មណោ ច > ព្រាហ្មណា** *=សមណនិងព្រាហ្មណ៍.ទ. ៗ*

## ៣. សរូបេកសេសសមាស

សរូបេកសេសសមាស (សរូប + ឯក + សេស + សមាស) ប្រែថា "វិធីបំប្រួញដោយលុបរូបស័ព្ទដែលមានរូបដូចគ្នាទុកឱ្យសល់នៅតែមួយបទ" ឧ.

វិ. វជ្ជុ ច វជ្ជុ ច > វជ្ជុយោ =ខ្សែនិងខ្សែ.ទ. ។

វិ. យុគញ្ច យុគញ្ច > យុគានិ =នឹមនិងនឹម.ទ. ។

## ៤. វិរូបេកសេសសមាស

វិរូបេកសេសសមាស (វិរូប + ឯក + សេស + សមាស) ប្រែថា "វិធីបំប្រួញដោយលុបសព្ទដើមចេញ ហើយប្រើសព្ទថ្មីមានរូបផ្សេងពីសព្ទដើមជំនួសវិញ" និយមប្រើបកតិសំខ្យាដើម្បីធ្វើឱ្យចំនួនទ្វេឡើង ឧ.

វិ. បញ្ច ច បញ្ច ច > ទស =ដប់ (ប្រាំនិងប្រាំ) ។

វិ. ទស ច ទស ច > វីស, វីសតិ =ម្ភៃ (ដប់និងដប់) ។

វិ. ទស ច ទស ច ទស ច > តឹស, តឹសតិ =សាមសិប (ដប់និងដប់និងដប់) ។

(ឯកសេសសមាសចប់)

# មជ្ឈេលោបសមាស

**មជ្ឈេលោបសមាស** *ប្រែថា "សមាសដែលលុបបទកណ្ដាលចោល" គឺជាតតិយាតប្បុរិសសមាសដែរ តែមានវិធីពិសេសម្យ៉ាង គឺថា បើបទសមាសណាដែលតាំងវិគ្គហៈរួចហើយ ប្រែមិនបានសេចក្ដីច្បាស់លាស់ដូចជាបទថា* **អស្សរថ** *បើតាំងវិគ្គហៈតាមតតិយាតប្បុរិសសមាស មានរូបដូចខាងក្រោមនេះ*

*វិ.* **អស្សេន រថោ > អស្សរថោ** *ប្រែថា "រទេះដោយសេះ" ។*

*ពាក្យប្រែនេះស្ដាប់មិនបានសេចក្ដីល្អទេ ឬប្រែមួយបែបទៀតថា "រទេះនិងសេះ" ក៏បាន ។ ប៉ុន្តែពាក្យប្រែនេះមិនមែនជាតតិយាតប្បុរិសសមាសទេ គឺជាពាក្យប្រែរបស់ទ្វន្ទសមាសដែលអធិប្បាយរួចហើយនៅខាងលើ ។ អាស្រ័យហេតុនេះ ដើម្បីធ្វើឱ្យសមាសនេះអាចប្រែរួចស្ដាប់បានពីរោះល្អ ត្រូវថែមកិតកិរិយាណាដែលមានពាក្យប្រែសមល្មមចូលនឹងបុព្វបទបាន ថែមចូលមកក្នុងចន្លោះរវាងនៃបុព្វបទនិងឧត្តរបទខាងក្នុងរូបវិគ្គហៈ ។ លុះដល់វេលាបំប្រួញបុព្វបទចូលជាមួយឧត្តរបទត្រូវលុបកិតកិរិយាដែលថែមចូលមកនោះចោល ទើបបញ្ញត្តិខាងវេយ្យាករណ៍ ហៅថា* **មជ្ឈេលោបសមាស** *ប្រែថា "បំប្រួញដោយវិធីលុបស័ព្ទនៅកណ្ដាល" ។ ក្នុងករណីបទថា* **អស្សរថ** *ខាងលើត្រូវថែមពាក្យថា* **យុត្តោ** *ប្រែថា "ទឹមហើយ" ចូលមក ដូចឧទាហរណ៍ខាងក្រោមនេះ*

( អស្ស + រថ ) > អស្សរថ

វិ. អស្សេន (យុត្តោ) រថោ > អស្សរថោ =រទេះ (ដែលជនទឹមហើយ)ដោយសេះ, រទេះសេះ ។

វិ. សន្តកេន (តុដ្ឋោ) ភិក្ខុ > សន្តកភិក្ខុ =ភិក្ខុ (អ្នកត្រេកអរហើយ) ដោយវត្ថុកំពុងមាន ។

វិ. មោហេន (សម្បយុត្តំ) ចិត្តំ > មោហចិត្តំ =ចិត្ត (ដែលប្រកបព្រមហើយ) ដោយមោហៈ (ចិត្តមោហៈ) ។

វិ. កដ្ឋេន (កតោ) អគារោ > កដ្ឋាគារោ =អាគារ (ដែលគេធ្វើហើយ) ដោយឈើ, រោងឈើ ។

សូមសង្កេតមើលបទសមាសខាងលើនេះ ឃើញថាសមាសបាលីនិងសមាសខ្មែរយើង ប្រើស័ព្ទបញ្ច្រាស់គ្នា ។ ក្នុងភាសាខ្មែរក៏មានការបំប្រួញសមាសដូចភាសាបាលីដែរ ដូចជា អ្នកដើរដោយជើង បំប្រួញទៅជា ថ្មើរជើង, សត្វកើតក្នុងទឹក បំប្រួញជា សត្វទឹក ដូច្នេះជាដើម ។

## ឧភយតប្បុរិសសមាស
## ឬ ងបុព្វបទកម្មធារយសមាស

សមាសនេះមាន ង និបាតបដិសេធប្រែថា “មិន, មិនមែន” ជាបុព្វ-

បទនិងមានឧត្តរបទជានាមនាមដែលប្រើជាបទគុណ ហើយនឹងមានបទដទៃជាប្រធានក្នុងវិគ្គហៈ ។ វេលាបំប្រួញចូលជាមួយឧត្តរបទមានវិធីផ្លាស់ ន ទៅជារូបដទៃ ២ យ៉ាងគឺ

## ១. ផ្លាស់ ន > អ

ប្រសិនបើឧត្តរបទផ្ដើមដោយព្យញ្ជនៈត្រូវផ្លាស់ ន > អ ជានិច្ច ឧ.

វិ. ន ព្រាហ្មណោ > អព្រាហ្មណោ (អយំ ជនោ) =(ជន នេះ) មិនមែនជាព្រាហ្មណ៍ ។

វិ. ន ផាសុកំ > អផាសុកំ (ឥទំ ទុក្ខំ) =(ទុក្ខ នេះ) មិនមែនជាសេចក្ដីសប្បាយ ។

វិ. ន កុសលំ > អកុសលំ (ឥទំ កម្មំ) =(អំពើ នេះ) មិនល្អ ។

## ២. ផ្លាស់ ន > អន

ប្រសិនបើឧត្តរបទផ្ដើមដោយស្រៈត្រូវផ្លាស់ ន > អន ជានិច្ច ឧ.

វិ. ន អស្សោ > អនស្សោ (អយំ សត្តោ) =(សត្វ នេះ) មិនមែនជាសេះ ។

វិ. ន អរិយោ > អនរិយោ (អយំ បុគ្គលោ) =(បុគ្គល នេះ) មិន

*មែនជាព្រះអរិយៈ ។*

វិ. ន ឥដ្ឋោ > អនិដ្ឋោ (ឥទំ អារម្មណំ) =(*អារម្មណ៍ នេះ*) មិនជាទីប្រាថ្នា ។

*បទសមាសនេះជាគុណនាមបំបែកតាមវិភត្តិផ្សេង ៗ បានទាំងបីលិង្គ ។ យើងនឹងសង្កេតឃើញសមាសនេះដោយងាយ ពីព្រោះមាន* ន *បដិសេធចូលជាមួយបទនាមទើបហៅថា* **ឧភយតប្បុរិសសមាស** *ឬ* **នបុព្វបទកម្មធារយសមាស** *។ សមាសនេះគឺជាកម្មធារយនិងទិគុសមាសហ្នឹងឯង ប្លែកតែមាន* ន *ជាបុព្វបទប៉ុណ្ណោះ ។ ប៉ុន្តែបើ* ន *ប្រើបដិសេធបទគុណនាមឬកិរិយាប្រែថា "មិនមាន ឬ ឥតមាន" វិញ នោះជា* **នបុព្វបទពហុព្វីហិសមាស** *ដែលនឹងមានពោលនៅខាងមុខ ។*

## ប្រយោគឧទាហរណ៍

១. <u>មហាបុរិសោ</u> <u>ទលិទ្ទមនុស្សេ</u> ទិស្វា តេសំ ទានំ អទាសិ ។

*<u>មហាបុរស</u> ឃើញហើយ <u>នូវមនុស្សទ័លក្រ.ទ.</u> បានឱ្យហើយ នូវទាន ដល់គេ.ទ. នោះ ។*

២. ធម្មចារី <u>តិលោកេសុ</u> សុខំ វិន្ទតិ ។

*បុគ្គលអ្នកមានប្រក្រតីប្រព្រឹត្តនូវធម៌ តែងទទួលបាន(ប្រសប់) នូវសេចក្ដីសុខ <u>ក្នុងលោកបី.ទ.</u> ។*

៣. ទីឃាយុកោ ហោតុ រាជបុត្តោ ។

*សូមព្រះរាជឱរស មាន ព្រះជន្មាយុយឺនយូរ ។*

៤. សារីបុត្តមោគ្គល្លានា អម្ហាកំ សត្ថុ អគ្គសាវកា អហេសុំ ។

*ព្រះសារីបុត្តនិងព្រះមោគ្គល្លាន.ទ. ជាព្រះសាវ័កដ៏លើស របស់ព្រះសាស្តា របស់យើង.ទ. ។*

*សូមសង្កេតមើលបទសមាសខាងក្រោមនេះ ថាតើជាបទសមាសអ្វី ? តាំងរូបវិគ្គហៈដូចម្តេច ?*

មហាបុរិសោ, ឥសិទ្ធមនុស្សោ, តិលោកេសុ, រាជបុត្តោ, សារីបុត្តមោគ្គល្លានា, អគ្គសាវកា ។

## លំហាត់នៃមេរៀនទី ៤៧

### *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើទិគុសមាសជាការបំប្រួញស័ព្ទប្រភេទណា ?*

*២. តើតប្បុរិសសមាសមានប៉ុន្មានយ៉ាង និងមានឈ្មោះហៅដូចម្តេចខ្លះ ?*

*៣. តើមជ្ឈេលោបសមាសមានប៉ុន្មានយ៉ាង និងតើមានលក្ខណៈខុសគ្នាយ៉ាងម៉េច?*

*៤. តើទ្វន្ទសមាសជាការបំប្រួញស័ព្ទប្រភេទណា ?*

៥. តើឯកសេសសមាសជាសមាសប្រភេទណា ? និងមានប៉ុន្មានយ៉ាង?

៦. តើមជ្ឈេលោបសមាសជាសមាសប្រភេទណា ? មានប៉ុន្មានយ៉ាង ?

ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ និងបទណាជាបទសមាស សូមប្រាប់ឈ្មោះថាជាសមាសអ្វី (មានបទសមាសខ្លះមិនទាន់បានរៀននៅឡើយទេ) ។

១. ពុទ្ធាទិច្ចេ អនុទិតេ ចន្ទសុរិយសតានិបិ មោក្ខមគ្គំ បកាសេតុំ ន សក្កោន្តិ ។

២. មហាបុរិសេ មហាពោធឹ ឧបសង្កមន្តេ មហាបឋវី មហារវំ រវមានា កម្បិ ។

៣. ធម្មាសោកមហារាជា អនេកសហស្សេ អស្សមណេ នីហរិត្វា ពុទ្ធសាសនំ និម្មលំ អកាសិ ។

៤. ពុទ្ធនាតោ អនាថបិណ្ឌិកមហាសេដ្ឋិនា ការិតេ ជេតវន-មហាវិហារេ ឯកូនវីសតិវស្សានិ វសិ ។

៥. សារីបុត្តត្ថេរោ សមាបត្តិសុខេន បិប្ផលិគុហាយំ សត្តាហំ វីតិនាមេសិ ។

៦. ពុទ្ធឃោសាចរិយោ ជម្ពូទីបតោ សីហឡទីបំ អាគន្ត្វា អនុរាធបុរេ មហាវិហារេ វសន្តោ តិបិដកបាឡិយា អដ្ឋកថាយោ មាគធភាសាយ លិខិ ។

៧. វដ្តគាមិនីអភយមហារញ្ញោ កាលេ ពហវោ មហាថេរា

មាតុលជនបទេ អាលោកកុហាយំ សន្និបតិត្វា ពុទ្ធវចនំ តាលបណ្ណេសុ លិខឹសុ ។

៨. តិត្ថិយា រត្តចន្ទនេហិ មណ្ឌបំ ការាបេត្វា តំ នីលុប្បលេហិ ឆាទេត្វា មហាជនស្ស បាដិហារិយំ ទស្សេស្សាមា"តិ តត្ថ អដ្ឋំសុ ។

៩. មហាមោគ្គល្លានត្ថេរោ អត្តនោ ឥទ្ធិពលេន សក្កស្ស ទេវរញ្ញោ វេជយន្តបាសាទំ កម្បេសិ ។

១០. ទេវទត្តត្ថេរោ រាជគហនគរេ អជាតសត្តុកុមារំ បសាទេត្វា មហាលាភំ ឧប្បាទេសិ ។

១១. សិទ្ធត្ថកុមារោ ឧរុវេលាជនបទេ នេរញ្ជរានទីតីរេ អស្សត្ថរុក្ខស្ស មូលេ និសីទិត្វា វេសាខបុណ្ណមិយា បច្ឆិមយាមេ អភិសម្ពោធឹ បាបុណិ ។

១២. កិសាគោតមី នាម ខត្តិយកញ្ញា បទក្ខិណំ ករោន្តស្ស មហាសត្តស្ស រូបសិរឹ ទិស្វា ឯកំ គាថំ អាហ ។

១៣. បណ្ឌិតោ ឧប្បាទិតជនញ្ច អាហាជជនញ្ច អាទាយ នគរំ ឯវ អគមាសិ ។

១៤. ជរសក្កោ អម្ពេ មត្តេ កត្វា មហាសមុទ្ទបិដ្ឋេ ឋិបិត្វា អម្ហាកំ ទេវនគរំ គណ្ហិ ។ មយំ តេន សទ្ធឹ យុជ្ឈិត្វា អម្ហាកំ ទេវនគរំ ឯវ គណ្ហិស្សាម ។

១៥. តស្ស គមនមគ្គេ សិម្ពលីវនំ តាលវនំ វិយ ញ្ជិត្វា សមុទ្ទបិដ្ឋេ
បតិ ។ សុបណ្ណោបាតកា សមុទ្ទបិដ្ឋេ បរិវត្តន្តា មហារវំ
រវឹសុ ។

១៦. មហាមាយាទេវី ។បេ។ តណ្ហោទកេន នហាយិត្វា ចត្តារិ
សតសហស្សានិ វិស្សជ្ជេត្វា មហាទានំ ទត្វា និបណ្ណា ។បេ។
ឥមំ សុបិនំ អទ្ទស ។

១៧. ទ្វិន្នំ បន នគរានំ អន្តរេ ឧភយនគរវាសីនំបិ លុម្ពិនីវនំ នាម
មង្គលសាលវនំ អត្ថិ ។

១៨. សកលំ លុម្ពិនីវនំ ចិត្តលតាវនសទិសំ មហានុភាវស្ស
រញ្ញោ សុសជ្ជិតាបានមណ្ឌលំ វិយ អហោសិ ។

*(ចប់មេរៀនទី ៤៧)*

# មេរៀនទី ៤៨

# អធិប្បាយអំពីសមាស (ត)

## ៥. អព្យយីភាវសមាស

## (Adverbial Compounds)

*អព្យយីភាវសមាស បានដល់ សមាសណាដែលមានឧបសគ្គឬនិបាតជាបុព្វបទ មានឧត្តរបទជានាមនាម បំប្រួញឱ្យជាបទមួយ (គឺការបំប្រួញអព្យយសព្ទជាមួយនឹងនាមនាម) មាន ២ យ៉ាងគឺ* **ឧបសគ្គបុព្វកាព្យយីភាវសមាស** *និង* **និបាតបុព្វកាព្យយីភាវសមាស** *។*

*១.* **ឧបសគ្គបុព្វកា** *ក្នុងន័យថាមានបុព្វបទជាឧបសគ្គ ។*

*២.* **និបាតបុព្វកា** *ក្នុងន័យថាមានបុព្វបទជានិបាត ។*

## វិធីតាំងវិគ្គហៈនៃអព្យយីភាវសមាស

*១. រៀងបទនាមនាមដែលត្រូវបំបែកជាទុតិយាឬចតុត្ថីឬក៏ឆដ្ឋីវិភត្តិជាបុព្វបទ ។*

*២. រៀងបទឧបសគ្គឬនិបាតឬក៏សព្ទណាមួយដែលមានសេចក្ដីស្មើនឹងឧបសគ្គឬនិបាតនោះ ៗ ជាឧត្តរបទ ។*

៣. បទសមាសត្រូវត្រឡប់យកឧត្តរបទ គឺឧបសគ្គឬនិបាតនោះ ៗ មកដាក់នៅខាងដើមនាមនាមវិញ និងត្រូវបំបែកជាបឋមាវិភត្តិឯកវចនៈ នបុំសកលិង្គជានិច្ច ។

៤. ប្រសិនបើជាស្រៈ **អា** ត្រូវរស្សៈជា **អ** ។

៥. ប្រសិនបើជាស្រៈ **ឦ** ត្រូវរស្សៈជា **ឥ** និងស្រៈ **ឩ** រស្សៈជា **ឧ** ។

បទសមាសនេះមានអត្ថន័យជាកិរិយាវិសេសន៍ ឧ.

(**បព្វត** (នាម) + **តិរោ** (និបាត)) > **តិរោបព្វត**

វិ. **បព្វតស្ស តិរោ** > **តិរោបព្វតំ** =ខាងក្រៅនៃភ្នំ ។

## ៥.១ ឧបសគ្គបុព្វកាព្យយីភាវសមាស

សមាសនេះមានបុព្វបទជាឧបសគ្គនិងមានឧត្តរបទជានាមនាម ។ ក្នុងរូបវិគ្គហៈត្រូវរៀងដាក់បទនាមនាមខាងដើម បទឧបសគ្គរៀងដាក់ខាងចុងជាបទប្រធាន ។ ដោយសារតែឧបសគ្គជាអព្យយស័ព្ទបំបែកមិនបាននោះ ដូច្នេះត្រូវរកបទនាមឬបទកិរិយាស័ព្ទដែលមានពាក្យប្រែមានសេចក្តីដូចឧបសគ្គមកជំនួស មាន ៣ ប្រភេទគឺ

ក. ប្រភេទប្រើនាមបទដទៃជាប្រធានក្នុងរូបវិគ្គហៈជំនួសឧបសគ្គ មាន ២ ស័ព្ទ គឺ **អភាវ**, **សមីប** ។

ក.១ **អភាវ** ប្រែថា សេចក្តីមិនមាន(នាម) ប្រើជំនួស **និ** (ឧបសគ្គ) =មិនមាន ឧ.

វិ. **ទោសស្ស អភាវោ** > **និទ្ទោសំ** =សេចក្តីមិនមាននៃទោស (ការមិនមានទោស)។

វិ. **ភយស្ស អភាវោ** > **និព្ភយំ** =កិរិយាមិនមាននៃភ័យ (ការមិនមានភ័យ) ។

ក.២ **សមីប** ប្រែថា ទីជិត(នាម) ប្រើជំនួស **ឧប** (ឧបសគ្គ) =ជិត ។

វិ. **គុន្នំ សមីបំ** > **ឧបគុ** =ទីជិតនៃគោ ។

វិ. **វធូ សមីបំ** > **ឧបវធុ** =ទីជិតនៃស្រីក្រមុំ ។

វិ. **នគរស្ស សមីបំ** > **ឧបនគរំ** =ទីជិតនៃនគរ ។

ខ. ប្រភេទប្រើកិរិយាក្នុងរូបវិគ្គហៈជំនួសឧបសគ្គមាន ៣ សព្ទគឺ **អធិវត្តតិ, អនុវត្តតិ, បដិវត្តតិ** ។

ខ.១ **អធិវត្តតិ** (អាខ្យាតកិរិយា) ប្រែថា ប្រព្រឹត្តសង្កត់ ប្រើជំនួស **អធិ** =សង្កត់ (ឧបសគ្គ) ឧ.

វិ. **អត្តានំ អធិវត្តតីតិ** > **អជ្ឈត្តំ** (វត្ថុ)=(វត្ថុ)ប្រព្រឹត្តសង្កត់នូវខ្លួន (ខាងក្នុង, ចំពោះខ្លួន) ។

ខ.២ **អនុវត្តតិ** (អាខ្យាតកិរិយា) ប្រែថា ប្រព្រឹត្តតាម ប្រើជំនួស **អនុ** =តាម (ឧបសគ្គ) ឧ.

វិ. **វាតំ អនុវត្តតីតិ** > **អនុវាតំ** (វត្ថុ) =(វត្ថុ) ប្រព្រឹត្តតាមនូវខ្យល់

(តាមខ្យល់) ។

ខ.៣ **បដិវត្តតិ** (អាខ្យាតកិរិយា) ប្រែថា ប្រព្រឹត្តច្រាស ប្រើជំនួស **បដិ** =ច្រាស (ឧបសគ្គ) ឧ.

វិ. **សោតំ បដិវត្តតីតិ** > **បដិសោតំ** (**ជាវា**) =(ទូក)ប្រព្រឹត្តច្រាស់នូវខ្សែ(ទឹក) (ច្រាស់ខ្សែទឹក) ។

គ. ប្រភេទដែលប្រើឧបសគ្គក្នុងរូបវិគ្គហៈជាប្រធានចំ ៗ បាន ឧ.

វិ. **រថស្ស អនុ** > **អនុរថំ** =ខាងក្រោយនៃរថ ។

វិ. **កុមារិយា អធិ** > **អធិកុមារិ** =ក្រៃលែងនៃក្មេងស្រី ។

វិ. **វាតស្ស បដិ** > **បដិវាតំ** =បញ្ច្រាស់នៃខ្យល់ ។

វិ. **វាតស្ស អនុ** > **អនុវាតំ** =បណ្ដោយតាមនៃខ្យល់ ។

## កំណត់សម្គាល់

ពាក្យថា **អនុថេរោ** =ព្រះថេរអ្នកតូចប្អូន (អនុថេរ) មិនមែនជាអព្យយីភាវសមាសទេ ពីព្រោះបទនេះមិនបានបំបែកជានបុំសកលិង្គទេ តែជាវិសេសនបុព្វបទកម្មធារយសមាស ដោយការធ្វើឧបសគ្គឱ្យទៅជាវិសេសនៈគឺចុះ **ក** ចុង **អនុ** ទៅជា **អនុកោ ថេរោ** > **អនុថេរោ** ។

បទអព្យយីភាវសមាសនេះជាសមាសនាម និងសមាសគុណនាមបំបែកតាមបែប **អ** ការន្តនបុំសកលិង្គដូច **កុល** គ្រប់វិភត្តិ ។

## ២. និបាតបុព្វកាព្យយីភាវសមាស

*សមាសនេះមាននិបាតស័ព្ទជាបុព្វបទ មាននាមនាមជាឧត្តរបទ ។ ការរៀងវិគ្គហៈមានគតិដូចឧបសគ្គបុព្វកៈដែរ តែមានលក្ខណៈពិសេស ៣ ប្រភេទគឺ*

*២.១ ប្រភេទដែលប្រើនិបាតក្នុងរូបវិគ្គហៈជាប្រធានចំ ៗ បាន ឧ.*

*វិ.* **កត្តស្ស បច្ឆា > បច្ឆាកត្តំ** *=វេលាខាងក្រោយនៃកត្ត ។*

*វិ.* **ឯករស្ស ពហិ > ពហិឯករំ** *=ខាងក្រៅនៃនគរ ។*

*វិ.* **គេហស្ស អន្តោ > អន្តោគេហំ** *=ខាងក្នុងនៃផ្ទះ ។*

*២.២ ប្រភេទដែលប្រើនាមច្រើនបទជំនួសនិបាត ២ ស័ព្ទគឺ* **យាវ, តាវ** *។* **យាវ***=ត្រឹមណា, ជំនួសដោយ* **យត្តក***=ប៉ុនណា និង* **បរិច្ឆេទ***= កំណត់ ។* **តាវ** *=ប៉ុណ្ណោះ, ត្រឹមនោះ ជំនួសដោយ* **តត្តក** *និង* **បរិច្ឆេទ** *ឧ.*

*វិ.* **ជីវស្ស យត្តកោ បរិច្ឆេទោ > យាវជីវំ** *=កំណត់ប៉ុនណានៃជីវិត, ជីវិតប៉ុនណា (មួយជីវិត) ។*

*វិ.* **កាលស្ស តត្តកោ បរិច្ឆេទោ > តាវកាលំ** *=កំណត់ត្រឹមនោះនៃកាល (កាលប៉ុណ្ណោះ) ។*

*វិ.* **អត្ថស្ស យត្តកោ បរិច្ឆេទោ > យាវអត្ថំ** *=កំណត់ប៉ុនណានៃការប្រាថ្នា (ប្រាថ្នាប៉ុនណា) ។*

*២.៣ ប្រភេទប្រើនាមនាមតែមួយបទគឺ* **បដិចាដិ** *ជានាមនាមប្រែ*

ថា លំដាប់, តាម" ជំនួសនិបាត យថា ឱ.

បសាទស្ស បដិបាដិ > យថាបសាទំ =តាមលំដាប់នៃសេចក្តីជ្រះថ្លា ។

ពលស្ស បដិបាដិ > យថាពលំ =តាមលំដាប់នៃកម្លាំង ។

សត្តិយា បដិបាដិ > យថាសត្តិ =តាមលំដាប់នៃសមត្ថភាព ។

សទ្ធាយ បដិបាដិ > យថាសទ្ធំ =តាមលំដាប់នៃសទ្ធា ។

វុឌ្ឍានំ បដិបាដិ > យថាវុឌ្ឍំ =តាមលំដាប់នៃមនុស្សចាស់ ។

ពាក្យថា យថាវុឌ្ឍំ នេះអាចតាំងវិគ្គហៈម៉្យាងទៀតថា

វុឌ្ឍានំ បដិបាដិយា យេ យេ វុឌ្ឍា យថាវុឌ្ឍំ =មនុស្សចាស់.ទ. ណា (ដែលអន្តុយហើយ) តាមលំដាប់នៃមនុស្ស.ទ. (មនុស្សចាស់.ទ. នោះ) ឈ្មោះថា យថាវុឌ្ឍំ, យថាវុឌ្ឍំ =តាមលំដាប់នៃមនុស្សចាស់ ។

(អព្យយីភាវសមាសចប់)

## ៦. ពហុព្វីហិសមាស

(Relative or Attributive Compounds)

ការបំប្រួញនាមនាមចូលជាមួយគុណនាមក្តី ជាមួយកិតកិរិយាក្តី

ឬចូលជាមួយនាមនាមក្តី និងប្រសិនបើបំប្រួញជាបទសមាសរួចហើយ ក្លាយជាគុណនាម ប្រែថា "មាន..." នៅខាងដើមនិងដែលមានបទដ៏ទៃទៀតជាបទប្រធាន ហៅថា **ពហុព្វីហិសមាស** ។

បើរាប់តាមលក្ខណៈមាន ៥ ប្រភេទគឺ ១. តុល្យាធិករណពហុព្វីហិសមាស, ២. ឆដ្ឋីឧបមាពហុព្វីហិសមាស, ៣. ភិន្នាធិករណពហុព្វីហិសមាស, ៤. នបុព្វបទពហុព្វីហិសមាស, ៥. សហបុព្វបទពហុព្វីហិសមាស ។

បទសម្រេចមកពីពហុព្វីហិសមាសសុទ្ធតែមានពាក្យប្រែថា "មាន" នៅខាងដើមដូចគ្នាទាំងអស់ មិនមានពាក្យអាយតនិបាតណាមួយនៅឱ្យយើងដឹងថាជាពហុព្វីហិសមាសអ្វីទេ ពីព្រោះមានបទដ៏ទៃទៀតជាប្រធាន ។ ប្រសិនបើចង់ជ្រាបថាបទណាជាពហុព្វីហិសមាសអ្វី ត្រូវអាស្រ័យការតាំងវិគ្គហៈ ។ ការតាំងវិគ្គហៈមានលក្ខណៈប្លែកគ្នាបន្តិច ៗ ដែលនឹងអធិប្បាយដូចតទៅនេះ

## ៦.១ តុល្យាធិករណពហុព្វីហិសមាស

សមាសនេះចែកជា ៦ យ៉ាង មានឈ្មោះហៅតាមឈ្មោះរបស់វិភត្តិនាម រាប់តាំងពីទុតិយាវិភត្តិដល់សត្តមីវិភត្តិគឺ ១. ទុតិយាតុល្យាធិករណពហុព្វីហិសមាស, ២. តតិយាតុល្យាធិករណពហុព្វីហិសមាស,

៣. ចតុត្ថីតុល្យាធិករណពហុព្វីហិសមាស, ៤. បញ្ចមីតុល្យាធិករណ-ពហុព្វីហិសមាស, ៥. ឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស, ៦. សត្តមី-តុល្យាធិករណពហុព្វីហិសមាស ។

ឈ្មោះនីមួយ ៗ នេះអាចហៅខ្លី ៗ ថា **ទុតិយាពហុព្វីហិ.** តែប៉ុណ្ណោះក៏បាន ។

## គោលការណ៍តាំងវិគ្គហៈ

១. បុព្វបទជាបទវិសេសនៈ(ច្រើនជាកិតកិរិយា) ត្រូវបំបែកឱ្យមានលិង្គ, វចនៈនិងវិភត្តិស្មើនឹងឧត្តរបទ ត្រូវរៀងដាក់ទី ១ ។

២. ឧត្តរបទ(ជានាមនាម) ត្រូវបំបែកជាឯកវចនៈឬក៏ពហុវចនៈឱ្យត្រូវតាមការន្តនិងលិង្គនោះ ៗ ត្រូវរៀងដាក់ទី ២ ។

៣. ត្រូវថែម **យ** ស័ព្ទបន្ទាប់ពីឧត្តរបទ បំបែកតាមឈ្មោះដែលហៅតាមវិភត្តិនោះ ៗ ត្រូវរៀងដាក់ទី ៣ ។

៤. ត្រូវថែម **ត** ស័ព្ទមួយទៀតបំបែកជា **សោ** រៀងដាក់ទី ៤ ។

៥. បទសមាសត្រូវបំបែកជាបឋមាវិភត្តិឯកវចនៈតាមលិង្គ, វចនៈ, និងវិភត្តិស្មើគ្នានឹងអញ្ញបទ ត្រូវរៀងដាក់ទី ៥ ។

៦. អញ្ញបទគឺនាមនាមដែលថែមចូលមក ត្រូវដាក់ក្នុងវង់ក្រចក រៀងដាក់ទី ៦ ។

*សូមមើលឧទាហរណ៍* **អាគតសមណោ** *ខាងក្រោមនេះ*

**ឧទាហរណ៍ទី ១**

| ១ | ២ | ៣ | ៤ | | ៥ | ៦ |
|---|---|---|---|---|---|---|
| **អាគតា** | **សមណា** | **យំ** | **សោ** | > | **អាគតសមណោ** | **(អាវាសោ) ។** |
| *បទដើម* | *បទចុង* | *យ* | *ត* | | *បទសមាស* | *អញ្ញបទ(ប្រធាន)* |

*ប្រែលោតប្រយោគថា* **សមណា** *វិសមណៈ.ទ.* **អាគតា** *ដែលមក ហើយ* **យំ** (**អាវាសំ** *កាន់អាវាស*) *ណា*, **សោ** (**អាវាសោ** *វិអាវាស*) *នោះ* **អាគតសមណោ** *ឈ្មោះថា* **អាគតសមណោ**, **អាគតសមណោ** (**អាវាសោ** *វិអាវាស*) *=មានសមណៈមកហើយ ។*

*សមាសនេះមានឈ្មោះថា* **ទុតិយាតុល្យាធិករណពហុព្វីហិ-សមាស** *ពីព្រោះមាន* **យ** *ស័ព្ទបំបែកជា* **យំ** *ដែលជាទុតិយាវិភត្តិ ហើយនឹងដោយសារមានកិតបទ* **អាគតា** *ប្រែថា "មកហើយ" ។ ដើម្បីឱ្យបានច្បាស់លាស់ថែមទៀតត្រូវដាក់សំនួរមួយថា "តើមកហើយកាន់ទីណា ?" ចម្លើយក្នុងទីនេះពីប្រយោគខាងលើគឺ កាន់អាវាស ។ មកពីមានពាក្យអាយតនិបាតថា "កាន់" ជាពាក្យប្រែរបស់ទុតិយាវិភត្តិនេះហើយ ដែលបញ្ជាក់ថាជា* **ទុតិយាតុល្យាធិករណពហុព្វីហិសមាស** *។*

**ឧទាហរណ៍ទី ២**

| ១ | ២ | ៣ | ៤ | | ៥ | ៦ |
|---|---|---|---|---|---|---|
| **អាគតា** | **សមណា** | **យស្មា** | **សោ** | > | **អាគតសមណោ** | **(អារាមោ) ។** |
| បទដើម | បទចុង | យ | ត | | បទសមាស | អញ្ញបទ(ប្រធាន) |

*ប្រែលោតប្រយោគថា* **សមណា** *វីសមណៈ.ទ.* **អាគតា** *ដែលមកហើយ* **យស្មា** (**អារាមស្មា** *ចាកអារាម*) *ណា* **សោ** (**អារាមោ** *វីអារាម*) *នោះ* **អាគតសមណោ** *ឈ្មោះថា* **អាគតសមណោ**, **អាគតសមណោ** (**អារាមោ** *វីអារាម*) *មានសមណមកហើយ ។*

*សមាសនេះមានឈ្មោះថា* **បញ្ចមីតុល្យាធិករណពហុព្វីហិសមាស** *ពីព្រោះមាន* **យ** *ស័ព្ទបំបែកជា* **យស្មា** *ជាបញ្ចមីវិភត្តិ ហើយនឹងមានកិតបទ* **អាគតា** *ប្រែថា "មកហើយ" ។ ដើម្បីឱ្យច្បាស់លាស់ថែមទៀតត្រូវដាក់សំនួរមួយថា "តើមកហើយចាកទីណា ?" ចម្លើយចំពោះប្រយោគខាងលើនេះគឺ ចាកអារាម ។ ព្រោះតែពាក្យអាយតនិបាតប្រែថា "ចាក..." ជាពាក្យប្រែរបស់បញ្ចមីវិភត្តិនេះហើយដែលបញ្ជាក់ថាជា* **បញ្ចមីតុល្យាធិករណពហុព្វីហិសមាស** *។*

*ដូច្នេះសឱ្យឃើញថាបទសមាសមួយម៉ាត់អាចប្រែបានច្រើនយ៉ាងនេះជារឿងពិបាកក្នុងការសម្រេចចិត្ត ដើម្បីតាំងវិគ្គហៈឱ្យត្រូវចំតែម្តង ។ ប៉ុន្តែយើងអាចធ្វើសេចក្តីពិបាកនេះឱ្យរួមតូចបន្តិចបាន ព្រោះថាបើតាមឧទាហរណ៍ខាងលើ បទសមាសពួកនេះមានវិគ្គហៈជាគូនឹងគ្នា ដូចខាង*

ក្រោមនេះ

១. **ទុតិយាតុល្យាធិករណពហុព្វីហិ.** *ជាគូនឹង*

៥. **បញ្ចមីតុល្យាធិករណពហុព្វីហិ.** ។

២. **តតិយាតុល្យាធិករណពហុព្វីហិ.** *ជាគូនឹង*

៤. **ចតុត្ថីតុល្យាធិករណពហុព្វីហិ.** ។

៣. **ឆដ្ឋីតុល្យាធិករណពហុព្វីហិ.** *ជាគូនឹង*

៧. **សត្តមីតុល្យាធិករណពហុព្វីហិ.** ។

ចំណុចគួរកត់សម្គាល់ផងដែរគឺស័ព្ទកិតកិរិយា ពីព្រោះកិតកិរិយាស័ព្ទនីមួយ ៗ អាចហៅរកពាក្យអាយតនិបាតត្រឹមតែពីរឬបីប៉ុណ្ណោះដូចជា **កាតំ** អាចប្រែថា "ធ្វើហើយ<u>ដោយ</u>" ឬ "ធ្វើហើយ<u>ចំពោះ</u>" ។ល។ ពាក្យថា "ដោយ" ប្រាប់ថាជាតតិយាវិភត្តិ គឺជា តតិយាតុល្យាធិករណពហុព្វីហិសមាស ។ រីឯពាក្យថា "ចំពោះ" ប្រាប់ថាជាចតុត្ថីវិភត្តិ គឺជាចតុត្ថីតុល្យាធិករណពហុព្វីហិសមាស យ៉ាងនេះជាដើម ។

សូមសង្កេតមើលរូបវិគ្គហៈតទៅទៀត ពីទុតិយាតុល្យាធិករណពហុព្វីហិសមាសដល់សត្តមីតុល្យាធិករណពហុព្វីហិសមាសប្រកបថែមទៀតឱ្យយល់ចូលចិត្ត ដូចតទៅនេះ

## ៦.១.១ ទុតិយាពហុព្វីហិសមាស

**វិ. គតោ ជនោ យំ សោ** > **គតជនោ (គាមោ)** =(ស្រុក) មានជនទៅហើយ ។

**វិ. សម្បត្តា ភិក្ខូ យំ សោ** > **សម្បត្តភិក្ខុ (អាវាសោ)** = (អាវាស) មានភិក្ខុដល់ព្រមហើយ ។

**វិ. ឧបគតា កញ្ញា យំ សា** > **ឧបគតកញ្ញា (សាលា)**= សា លា) មានកញ្ញាចូលទៅហើយ ។

**វិ. រុឡ្ហា លតា យំ សោ** > **រុឡ្ហលតោ (រុក្ខោ)** =(ដើមឈើ) មានវល្លិឡើងហើយ ។

## កំណត់សម្គាល់

*បទសមាសនេះជាគុណនាមតែម៉្យាង បំបែកក្នុងរូបវិភត្តិផ្សេង ៗ បានទាំងបីលិង្គ ។ ចំពោះការប្រែវិគ្គហៈត្រូវយក* **យ** *ជាស័ព្ទសំខាន់ ។ បើ* **យ** *បំបែកក្នុងរូបវិភត្តិណា បទសមាសមានឈ្មោះតាមវិភត្តិនោះ ៗ ។* **យ** *ស័ព្ទក្នុងឧទាហរណ៍ទាំងឡាយខាងលើ មានរូបជា* **យំ** *ជាទុតិយា-វិភត្តិ ទើបបានសមាសនេះ ហៅថា* **ទុតិយាតុល្យធិករណពហុព្វីហិសមាស** *។ រីឯការប្រើក្នុងប្រយោគវិញនឹងបានជួបនាឱកាសខាងមុខ ។*

## ៦.១.២ តតិយាពហុព្វីហិសមាស

*វិ.* **<u>កតំ</u> បុញ្ញំ យេន សោ > កតបុញ្ញោ** ( **បុគ្គលោ** ) =(*បុគ្គល*) *មានបុណ្យធ្វើហើយ ។*

*វិ.* **<u>ជិតានិ</u> ឥន្ទ្រិយានិ យេន សោ > ជិតិន្ទ្រិយោ** ( **សមណោ** ) =(*សមណ:*) *មានឥន្ទ្រីយ៍ឈ្នះហើយ ។*

*វិ.* **<u>អាហិតោ</u> អគ្គិ យេន សោ > អាហិតគ្គិ** ( **ព្រាហ្មណោ** ) = (*ព្រាហ្មណ៍*) *មានភ្លើងបូជាហើយ ។*

*ឬក៏រៀងបទវិសេសន:ជាឧត្តរបទវិញក៏បាន ដូចជា*

*វិ.* **ហត្ថា <u>ឆិន្នោ</u> យេន សោ > ហត្ថឆិន្នោ** ( **បុគ្គលោ** ) =(*បុគ្គល*) *មានដៃដាច់ហើយ ។*

*វិ.* **វិសំ <u>បីតំ</u> យេន សោ > វិសបីតោ** ( **សរោ** ) =(*ព្រួញ*) *មានពិសត្រាំហើយ ។*

*វិ.* **អគ្គិ <u>អាហិតោ</u> យេន សោ > អគ្គយាហិតោ** ( **ព្រាហ្មណោ** ) =(*ព្រាហ្មណ៍*) *មានភ្លើងបូជាហើយ ។*

## កំណត់សម្គាល់

*សមាសនេះជាគុណនាម ទោះបីមាននាមស័ព្ទជាបុព្វបទឬជាឧត្តរបទក៏ដោយ ប្រែថា "មាន..." ។ បើនាមស័ព្ទនៅខាងដើមត្រូវប្រែពីដើមទៅចុងវិញ ។ យ ស័ព្ទក្នុងវិគ្គហ:ទាំងអស់ខាងលើបំបែកជា* យេន *ជា*

តតិយាវិភត្តិ ទើបសមាសនេះហៅថា **តតិយាតុល្យាធិករណពហុព្វី-ហិសមាស** ។ បទសមាសពួកនេះភាគច្រើនមានបទវិសេសនៈជាកិត-កិរិយាប្រភេទដែលអាចប្រែបានសេចក្ដីជាកម្មវាចកៈ សូមមើលការប្រែបែបលោតប្រយោគទុកឱ្យមើលខាងក្រោមនេះ

ប្រែលោតប្រយោគថា **បុញ្ញំ** វីបុណ្យ **យេន** (**បុគ្គលេន** ដែលបុគ្គល)ណា **កតំ** ធ្វើហើយ **សោ** (**បុគ្គលោ** វីបុគ្គល) នោះ **កត-បុញ្ញោ** ឈ្មោះថា **កតបុញ្ញោ**, **កតបុញ្ញោ** (**បុគ្គលោ** វីបុគ្គល) មានបុណ្យធ្វើហើយ ។

ស័ព្ទឯទៀត ៗ ក៏គប្បីជ្រាបតាមសេចក្ដីនេះដូចគ្នា សូមអ្នកសិក្សាសាកល្បងប្រែខ្លួនឯងផងចុះ ។ បើយល់ចូលចិត្តត្រឹមតែមួយបទក៏អាចប្រែស័ព្ទឯទៀត ៗ បានជាពិតប្រាកដ និងចំណុចសំខាន់គឺមានពាក្យប្រែថា "មាន..." ។

## ៦.១.៣ ចតុត្ថីពហុព្វីហិសមាស

វិ. **កតំ ទណ្ឌកម្មំ យស្ស សោ** > **កតទណ្ឌកម្មោ** (**សិស្សោ**) =(សិស្ស) មានទណ្ឌកម្ម(គឺអាចារ្យ)ធ្វើហើយ ។

វិ. **ទិន្នោ សុង្កោ យស្ស សោ** > **ទិន្នសុង្កោ** (**រាជា**) =(ព្រះរាជា) មានសួយ(គឺអ្នកនគរ)ថ្វាយហើយ ។

វិ. សញ្ញាតោ សំវេគោ យស្ស សោ > សញ្ញាតសំវេគោ (ជនោ) =(ជន) មានសង្វេគកើតព្រមហើយ ។

វិ. ឧប្បន្នោ លាភោ យស្ស សោ > ឧប្បន្នលាភោ (ភិក្ខុ) =(ភិក្ខុ) មានលាភកើតឡើងហើយ ។

## កំណាត់សម្គាល់

បទសមាសនេះជាគុណនាម ពីព្រោះ **យ** ស័ព្ទបំបែកជា **យស្ស** ក្នុងរូបជាចតុត្ថីវិភត្តិប្រែថា "ដល់, ដើម្បី, ចំពោះ" ទើបហៅថា **ចតុត្ថីតុល្យាធិករណពហុព្វីហិសមាស** ។

សូមមើលការប្រែបទសមាសពួកនេះ គឺមានសេចក្តីពីរយ៉ាង មួយជាកម្មវាចកៈនិងមួយទៀតជាកត្តុវាចកៈ និងដែលមានចំណុចឱ្យសង្កេតឃើញបាន គឺត្រង់បទវិសេសនៈ(បទកិតកិរិយា) ។

ប្រសិនបើបទវិសេសនៈក្នុងរូបវិគ្គហៈជាកិតកិរិយា ដែលប្រកបពីសកម្មធាតុ វិគ្គហៈនោះ ៗ មានសេចក្តីជាកម្មវាចកៈ ។ វេលាប្រែបទសមាសត្រូវថែមអញ្ញបទគឺតួអនភិហិតកត្តាណាមួយ ដែលមានសេចក្តីសមនឹងប្រយោគឱ្យត្រូវតាមគោលការណ៍ប្រែរបស់កម្មវាចកៈ ។ តែបើប្រកបពីអកម្មធាតុវិញ វិគ្គហៈនោះ ៗ ជាកត្តុវាចកៈ សូមមើលគំរូប្រែខាងក្រោមនេះ

កម្ម. ឧណ្ណាកាម្ពំ វិទណ្ណកម្ម (អាចរិយេន គឺអាចារ្យ) កាតំ ធ្វើហើយ យស្ស (សិស្សស្ស ដល់សិស្ស) ណា សោ (សិស្សោ វីសិស្ស) នោះ កាតឧណ្ណាកាម្មោ ឈ្មោះថា កាតឧណ្ណាកាម្មោ, កាតឧណ្ណា-កាម្មោ (សិស្សោ វីសិស្ស) មានទណ្ឌកម្ម(គឺអាចារ្យ)ធ្វើហើយ ។

កត្តុ. លាភោ វីលាភ ឧប្បន្នោ ដែលកើតហើយ យស្ស (ភិក្ខុ-នោ ដល់ភិក្ខុ) ណា, សោ (ភិក្ខុ វីភិក្ខុ) នោះ ឧប្បន្នលាភោ ឈ្មោះថា ឧប្បន្នលាភោ, ឧប្បន្នលាភោ (ភិក្ខុ វីភិក្ខុ) មានលាភកើតហើយ ។

*សព្វឯទៀត ៗ គប្បីជ្រាបតាមសេចក្តីនេះ ចំណែកឯកិតកិរិយាដែលជាកត្តុវាចកៈវិញ ត្រូវប្រែតាមគោលរបស់កត្តុវាចកៈ ។*

## ៦.១.៤ បញ្ចមីពហុព្វីហិសមាស

*វិ.* និគ្គតា ជនា យស្មា សោ > និគ្គតជនោ (គាមោ) =(*ភូមិ*) *មានជនចេញចាកហើយ ។*

*វិ.* បតិតានិ ផលានិ យស្មា សោ > បតិតផលោ (រុក្ខោ) = (*ដើមឈើ*) *មានផ្លែជ្រុះហើយ ។*

*វិ.* ជាតា ជីតា យាយ សា > ជាតជីតា (មាតា) =(*ម្តាយ*) *មានកូនស្រីកើតហើយ ។*

## កំណាត់សម្គាល់

*បទសមាសនេះជាគុណនាម ព្រោះ* **យ** *ស័ព្ទបំបែកជា* **យស្មា** *ក្នុងរូបជាបញ្ចមីវិភត្តិប្រែថា "ពី, ចេញ, ចាក...." ទើបហៅថា* **បញ្ចមីតុល្យាធិករណពហុព្វីហិសមាស** ។

*សូមមើលវិធីប្រែលោតប្រយោគត្រង់* **អាគតសមណោ** *ឧទាហរណ៍ទី ២ ខាងលើ ។ ចំណុចគួរឱ្យសង្កេតគឺបទវិសេសនៈទាំងបីបទក្នុងវិគ្គហៈទាំងបីនេះ ជាស័ព្ទត្រូវការអាយតនិបាតថា "ពី, ចេញ, ចាក" ជាដើមដែលជាអាយតនិបាតរបស់បញ្ចមីវិភត្តិ ។*

## ៦.១.៥ ឆដ្ឋីពហុព្វីហិសមាស

*វិ.* **សន្តំ ចិត្តំ យស្ស សោ > សន្តចិត្តោ (ភិក្ខុ)** =*(ភិក្ខុ) មានចិត្តស្ងប់ហើយ។*

*វិ.* **ខីណា អាសវា យស្ស សោ > ខីណាសវោ (ភិក្ខុ)** =*(ភិក្ខុ) មានអាសវៈអស់ហើយ ។*

*វិ.* **និក្ខន្តោ កិលេសោ យស្ស សោ > និក្កិលេសោ (ភិក្ខុ)**= *(ភិក្ខុ) មានកិលេសចេញហើយ ។*

*វិ.* **ឆិន្នា ហត្ថា យស្ស សោ > ឆិន្នហត្ថោ (បុគ្គលោ)** =*(បុគ្គល) មានដៃដាច់ហើយ ។*

# កំណត់សម្គាល់

*ពីព្រោះ* **យ** *ស័ព្ទបំបែកជា* **យស្ស** *ក្នុងរូបជាឆដ្ឋីវិភត្តិប្រែថា "នៃ, របស់" ទើបហៅថា* **ឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ។**

*ប្រែលោតប្រយោគថា* **ចិត្តំ** *វីចិត្ត* **សន្តំ** *ស្ងប់ហើយ* **យស្ស** (**ភិក្ខុស្ស**) *របស់ភិក្ខុ ណា* **សោ** (**ភិក្ខុ** *វីភិក្ខុ*) *នោះ* **សន្តចិត្តោ** *ឈ្មោះថា* **សន្តចិត្តោ, សន្តចិត្តោ** (**ភិក្ខុ** *វីភិក្ខុ*) *មានចិត្តស្ងប់ហើយ ។*

**និក្កិលេស** *ក្នុងរូបវិគ្គហៈសម្រេចមកពី* **និក្ខន្ត** *កាលបើបំប្រួញជាមួយ* **កិលេស** *ត្រូវលុប* **ខន្ត** *ឱ្យសល់ត្រឹមតែ* (**និ** + **កិលេស**) > **និក្កិលេស** *មានដំណើរដូច* (**កុច្ឆិតំ** + **កម្មំ**) > **កុកម្មំ** *ដែរ ។*

**និក្ខន្ត** *មកពី* (**និ** + **ខម** + **ត**) *ទៅជា* **និក្ខន្ត** *=ចេញហើយ ។*

## ៦.១.៦ សត្តមីពហុព្វីហិសមាស

*វិ.* **បិតំ សីលំ យស្មឹ សោ** > **បិតសីលោ** (**ភិក្ខុ**) =(*ភិក្ខុ*) *មានសីលតាំងនៅហើយ។*

*វិ.* **បិតំ បេមំ យស្មឹ សា** > **បិតបេ្បមា** (**ឥត្ថី**) =(*ស្រី*) *មានសេចក្តីស្រឡាញ់តាំងនៅហើយ ។*

*វិ.* **ពហូ ជនា យស្មឹ សោ** > **ពហុជនោ** (**គាមោ**) =(*ភូមិ*) *មានជនច្រើន ។*

វិ. សម្បន្នានិ សស្សានិ យស្មឹ សោ > សម្បន្នសស្សោ (ជនបទោ) =(ជនបទ) មានសន្ទូងដល់ព្រមហើយ ។

## កំណត់សម្គាល់

ពីព្រោះ យ ស័ព្ទបំបែកជា យស្មឹ ក្នុងរូបជាសត្តមីវិភត្តិប្រែថា "ក្នុង..." ទើបហៅថា **សត្តមីតុល្យាធិករណពហុព្វីហិសមាស** ។

ប្រែលោតប្រយោគថា **សីលំ** វីសីល **ឋិតំ** តាំងនៅហើយ **យស្មឹ** (**ភិក្ខុស្មឹ** ក្នុងភិក្ខុ) ណា **សោ** (**ភិក្ខុ** វីភិក្ខុ) នោះ **ឋិតសីលោ** ឈ្មោះថា **ឋិតសីលោ**, **ឋិតសីលោ** (**ភិក្ខុ** វីភិក្ខុ) មានសីលតាំងនៅហើយ ។

## កំណត់សម្គាល់ពិសេស

វិធីប្រែវិគ្គហៈនិងហៅឈ្មោះត្រូវមើល យ ស័ព្ទ ។ បើ យ បំបែកក្នុងរូបវិភត្តិណា ប្រែចេញពាក្យអាយតនិបាតនិងហៅចេញឈ្មោះរបស់វិភត្តិនោះ ៗ ទៅ ។ ចំពោះបុព្វបទនិងឧត្តរបទក្នុងវិគ្គហៈនឹងជាឯកវចនៈឬពហុវចនៈក៏បាន តែបទសមាសត្រូវមានវចនៈនិងវិភត្តិស្មើគ្នានឹងអញ្ញបទដែលមាននាទីជាបទប្រធានជានិច្ច ។

តុល្យាធិករណពហុព្វីហិសមាសនេះ នៅមានវិធីតាំងវិគ្គហៈពីរបីយ៉ាងទៀត ដូចមានឧទាហរណ៍ខាងក្រោម

*១. ក្នុងវិគ្គហៈអាចផ្លាស់ យ ទៅជា ឥម បានដោយត្រូវបំបែកឱ្យត្រូវតាមឈ្មោះនោះ ៗ ដូចជា*

វិ. អាគតា សមណា ឥមំ អារាមំ សោយំ > អាគតសមណោ (អារាមោ) ។

វិ. បិតំ បេមំ អស្សំ ឥត្ថីយំ សាយំ > បិតប្បេមោ (ឥត្ថី) ។

*២. បែបប្រើ ឥតិ ដោយសរសេរចូលជាមួយ យ ស័ព្ទនិងពុំចាំបាច់ប្រើ ត ស័ព្ទទេដូចជា*

វិ. អាគតា សមណា យន្តិ > អាគតសមណោ (អារាមោ) ។

វិ. បិតំ បេមំ យស្សន្តិ > បិតប្បេមា (ឥត្ថី) ។

*៣. បែបប្រើ ឥតិ ដោយសរសេរចូលជាមួយ ឥម ស័ព្ទនិងពុំចាំបាច់ប្រើ ត ស័ព្ទទេដូចជា*

វិ. អាគតា សមណា ឥមន្តិ > អាគតសមណោ (អារាមោ) ។

វិ. បិតំ បេមំ អស្សន្តិ > បិតប្បេមា (ឥត្ថី) ។

## ឥត្ថីលិង្គទៅជាបុំលិង្គ

*៤. ប្រសិនបើបទចុងជាឥត្ថីលិង្គ តែមានបទប្រធានគឺអញ្ញបទជាបុំលិង្គឬនបុំសកលិង្គ បទសមាសត្រូវបំបែកតាមលិង្គរបស់ប្រធាន គឺបុំលិង្គឬក៏នបុំសកលិង្គដែរដូចជា*

វិ. **មហន្តី បញ្ញា យស្ស សោ** > **មហាបញ្ញោ (បុគ្គលោ)** = (បុគ្គល)មានបញ្ញាច្រើន ។

វិ. **បហូតា ជិវ្ហា យស្ស សោ** > **បហូតជិវ្ហោ (កុមារោ)** = (កុមារ)មានអណ្ដាតធំ ។

វិ. **អចលា សទ្ធា យស្ស សោ** > **អចលសទ្ធោ (បុគ្គលោ)** = (បុគ្គល) មានជំនឿមិនកម្រើក ។

វិ. **ទីឃា ជង្ឃា យស្ស សោ** > **ទីឃជង្ឃោ (បុរិសោ)** =(បុរស) មានស្មងវែង ។

៥. ប៉ុន្តែបើអញ្ញបទជាឥត្ថីលិង្គវិញត្រូវរក្សាឬបំបែកបទចុងនេះជាឥត្ថីលិង្គដូចជា

វិ. **ឧបគតា កញ្ញា យំ សា** > **ឧបគតកញ្ញា (សាលា)** = (សាលា) មានកញ្ញាចូលទៅហើយ ។

វិ. **បិតំ បេមំ យស្សំ សា** > **បិតបេ្បមា (ឥត្ថី)** =(ស្រី) មានសេចក្ដីស្រឡាញ់តាំងនៅហើយ ។

## វិធីចុះបច្ច័យក្នុងសមាស

៦. ប្រសិនបើបទចុងជាឥត្ថីលិង្គដែលជា ឦ, ឩ, ការន្តនិង តុ ក្នុងបទសមាស និយមចុះ **ក** បច្ច័យក្នុងអត្ថសកត្ថ គឺត្រូវស្សៈ ឦ > ឥ,

ឃ > ឌ ដូចឧទាហរណ៍ខាងក្រោមនេះ

វិ. ពហវោ នទីយោ យស្មឹ សោ > ពហុនទិកោ (ជនបទោ) = (ជនបទ) មានទន្លេច្រើន ។

វិ. ពហូ វធុយោ យស្ស សោ > ពហុវធុកោ (បុរិសោ) = (បុរស) មានប្រពន្ធច្រើន ។

វិ. អបគតោ សត្ថា យស្មា សោ > អបគតសត្ថុកំ (ធម្មោ) = (ធម៌) មានគ្រូទៅប្រាសហើយ (ស្លាប់) ។

(តុល្យាធិករណពហុព្វីហិសមាសចប់)

## លំហាត់នៃមេរៀនទី ៤៨

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើអព្យយីភាវសមាសជាការបំប្រួញស័ព្ទប្រភេទណា ?

២. តើអព្យយីភាវសមាសមានប៉ុន្មានយ៉ាង ?

៣. តើពហុព្វីហិសមាសមានប៉ុន្មានយ៉ាង ? តើមានឈ្មោះហៅដូចម្ដេចខ្លះ ?

៤. តើតុល្យាធិករណពហុព្វីហិសមាសមានប៉ុន្មានយ៉ាង ? តើមានឈ្មោះហៅដូចម្ដេចខ្លះ ?

*៥. តើតុល្យាធិករណពហុព្វីហិសមាសមានវិធីតាំងវិគ្គហៈរបៀបណាខ្លះ ?*

*ខ. ចូរប្រែប្រយោគខាងក្រោមនេះជាភាសាខ្មែរ*

១. ពោធិសត្តោ បន ធម្មាសនតោ ឱតរន្តោ ធម្មកថិកោ វិយ ។បេ។ ទ្វេហត្ថេ ទ្វេចាទេ ច បសារេត្វា ។បេ។ កាសិករត្តេ និក្ខិត្តមណិរតនំ វិយ ជោតន្តោ មាតុកុច្ឆិតោ និក្ខមិ ។

២. អថេកទិវសំ ពោធិសត្តោ ឧយ្យានភូមឹ គន្តុកាមោ សារថឹ អាមន្តេត្វា "រថំ យោជេហី"តិ អាហ ។

៣. សុរនរមហិតោ សត្ថា ភិក្ខុសហស្សបរិវុតោ អាកិណ្ណ-មនុស្សំ រាជគហនគរំ ចាវិសិ ។

៤. អារូឡ្ហវាណិជា មហានាវា និរុបទ្ទវេន មហាសមុទ្ទំ តរិត្វា សត្តាហេន ជម្ពូទីបំ សម្បាបុណិ ។

៥. សបរិវារោ រាជា អឌ្ឍមាសំ អន្តោបុរា និក្ខមិត្វា នានា-តរុសណ្ឌមណ្ឌិតំ ទិជគណាកូជិតំ ឧយ្យានំ គច្ឆតិ ។

៦. ពហវោ ព្រាហ្មណា ពហិនគរតោ អន្តោនគរំ បវិសិត្វា យាវទត្ថំ ភុញ្ជិត្វា សកសកគេហានិ អគមឹសុ ។

៧. ទុស្សីលា យាវជីវំ អកុសលានិ កត្វា បរំ មរណា និរយេ ឧប្បជ្ជិត្វា អតិកដុកទុក្ខំ វិន្ទន្តិ ។

៨. សម្ពុទ្ធបរិនិព្វានតោ វស្សសតច្ចយេន វេសាលិវាសិនោ

វជ្ជិបុត្តកា ភិក្ខូ សាសនេ អព្ពុទំ ឧប្បាទេសុំ ។

៩. តស្មឹ សមយេ សត្ថា អនុបុព្វេនាគន្ត្វា អនាថបិណ្ឌិកេន មហាសេដ្ឋិនា ការិតេ ជេតវនមហាវិហារេ វិហរតិ មហាជនំ សគ្គមគ្គេ ច មោក្ខមគ្គេ ច បតិដ្ឋាបយមានោ ។

១០. ឆឡភិញ្ញាប្បត្តា បញ្ចសតខីណាសវា អន្តោវស្សំ រាជគហសមីបេ វសន្តា ធម្មវិនយសង្គីតឹ អកំសុ ។

១១. តទា សាវត្ថិយំ សត្តមនុស្សកោដិយោ វសន្តិ, តេសុ អរិយសាវកានំ ទ្វេយេវ កិច្ចានិ អហេសុំ, បុរេភត្តំ ទានំ ទេន្តិ, បច្ឆាភត្តំ គន្ធមាលាទិហត្ថា វត្ថភេសជ្ជបានកាទី គាហាបេត្វា ធម្មស្សវនត្ថាយ គច្ឆន្តិ ។

(ចប់មេរៀនទី ៤៨)

# មេរៀនទី ៤៩

# អធិប្បាយអំពីសមាស (ត)

## ៦.២ ឆដ្ឋីឧបមាពហុព្វីហិសមាស

*ឆដ្ឋីឧបមាពហុព្វីហិសមាសនេះស្រដៀងគ្នានឹងឆដ្ឋីតុល្យាធិករណពហុព្វីហិសមាសដែរ មានខុសត្រង់ត្រូវថែមពាក្យឧបមាចូលមក ដូចមានវិធីតាំងវិគ្គហៈខាងក្រោមនេះ*

*១. បុព្វបទជានាមនាម ជាបទឧបមា ត្រូវបំបែកជាឆដ្ឋីវិភត្តិរៀងដាក់ទី ១ ។*

*២. បទកណ្ដាលជានាមនាម ជាបទឧបមាមួយទៀត ត្រូវបំបែកជាបឋមាវិភត្តិ និងមាន* **ឥវ** *ស័ព្ទប្រែថា "ដូច...", "ដូចជា..." ខាងចុងផង ត្រូវរៀងដាក់ទី ២ ។*

*៣. ឧត្តរបទជាពាក្យដូចគ្នានឹងបទកណ្ដាល បំបែកជាបឋមាវិភត្តិដែររៀងដាក់ទី ៣ ។*

*៤. ត្រូវថែម* **យ** *បំបែកជា* **យស្ស** *រៀងដាក់ទី ៤ និង* **ត** *បំបែកជា* **សោ** *រៀងដាក់ទី ៥ ។*

*៥. បទសមាសត្រូវយកបុព្វបទ និងបទកណ្ដាលបំប្រួញចូលគ្នារួចបំបែកជាបឋមាវិភត្តិរៀងដាក់ទី ៦ ។*

*សូមមើលឧទាហរណ៍*

## សុវណ្ណវណ្ណោ

១ ២ ៣ ៤ ៥ ៦

វិ. សុវណ្ណស្ស វណ្ណោ ឥវ វណ្ណោ យស្ស សោ > សុវណ្ណវណ្ណោ (ភគវា) ។

បុព្វបទ បទកណ្ដាល ឧត្តរបទ យ ត បទសមាស

*ប្រែលោតប្រយោគថា* **វណ្ណោ** *វីសម្បុរ (សម្បុរស្បែក)* **យស្ស** (**ភគវតោ** =*របស់ព្រះមានព្រះភាគ) អង្គណា* **សុវណ្ណស្ស-វណ្ណោ-ឥវ** *ដូចសម្បុរនៃមាស* **សោ** (**ភគវា** *វីព្រះមានព្រះភាគ) អង្គនោះ* **សុវណ្ណ-វណ្ណោ** *ឈ្មោះថា* **សុវណ្ណវណ្ណោ**, **សុវណ្ណវណ្ណោ** (**ភគវា** *វីព្រះមានព្រះភាគ)* *មានសម្បុរដូចជាសម្បុរនៃមាស ។*

*វិ.* **ព្រហ្មុនោ សូរោ ឥវ សូរោ យស្ស សោ > ព្រហ្មស្សរោ** (**ភគវា**) =*(ព្រះភគវា) មានសំឡេងដូចជាសំលេងនៃព្រហ្ម ។*

*វិ.* **សូករស្ស សីសំ ឥវ សីសំ យស្ស សោ > សូករសីសោ** (**បេតោ**) =*(ប្រេត) មានក្បាល(=សិរៈ)ដូចជាក្បាលនៃជ្រូក ។*

*វិ.* **និគ្រោធស្ស បរិមណ្ឌលោ ឥវ បរិមណ្ឌលោ យស្ស សោ > និគ្រោធបរិមណ្ឌលោ** (**រាជកុមារោ**) =*(រាជកុមារ) មានបរិមណ្ឌល (វង់មូល)ដូចជាបរិមណ្ឌលនៃដើមជ្រៃ ។*

*ឬក៏ប្រើបុព្វបទតែមួយបទដោយបំបែកជាបឋមាឬឆដ្ឋីវិភត្តិក៏បាន*

វិ. សុវណ្ណស្ស ឥវ វណ្ណោ យស្ស សោ > សុវណ្ណវណ្ណោ (ភគវា) ។

វិ. និគ្រោធោ ឥវ បរិមណ្ឌលោ យស្ស សោ > និគ្រោធបរិ-មណ្ឌលោ (រាជកុមារោ) ។

វិ. សង្ខោ វិយ បណ្ឌរំ យស្ស សោ > សង្ខបណ្ឌរំ (វត្ថំ) = (សំពត់) មានពណ៌សដូចជាស័ង្ខ ។

វិ. កាកោ វិយ សូរោ យស្ស សោ > កាកសូរោ (បុរិសោ) =(បុរស) មានភាពក្លាហានដូចជាក្អែក ។

## កំណត់សម្គាល់

១. ឥវ ស័ព្ទអាចផ្លាស់ជា វិយ វិញក៏បានដូចឧទាហរណ៍ពីរចុងក្រោយ ។

២. វិគ្គហៈនៃឆដ្ឋីឧបមាពហុព្វីហិសមាសនេះ បើដកពាក្យឧបមាចេញ ក៏ក្លាយជាឆដ្ឋីតប្បុរិសសមាសភ្លាមដូចជា សូករស្ស សីសំ > សូករសីសំ =ក្បាលនៃជ្រូក ដូច្នេះជាដើម ។

ស័ព្ទឯទៀត ៗ គប្បីជ្រាបតាមនយ័នេះ ។

## ៣. ទិន្នាធិករណពហុព្វីហិសមាស

ភិន្នាធិករណពហុព្វីហិសមាសនេះ មានលក្ខណៈខុសពីតុល្យាធិ-ករណបន្ថិច គឺត្រង់ថាសមាសនេះបំប្រួញនាមនាមចូលជាមួយនាមនាមដូចគ្នា មិនអាចប្រើគុណនាមឬកិតកិរិយាបានទេ ។ ប៉ុន្តែក្នុងវិគ្គហៈបុព្វ-បទមានវិភត្តិផ្សេងគ្នាពីឧត្តរបទ និងអាចបំបែកក្នុងវិភត្តិណាមួយចាប់ពីទុតិយាដល់សត្តមីវិភត្តិ ។ រីឯឧត្តរបទត្រូវបំបែកជាបឋមាវិភត្តិតែម្យ៉ាងប្រើជាបទប្រធានទើបមានឈ្មោះថា**ភិន្នាធិករណពហុព្វីហិសមាស** ដោយសារពាក្យថា **ភិន្ន** ប្រែថា "ផ្សេងគ្នា" នោះឯង ។ បទសមាសនេះបើមានឧត្តរបទបំបែកជាទុតិយាដល់ឆដ្ឋីវិភត្តិ ត្រូវប្រែថា "មាន...អស់...", ឬ "មាន...រហូត..." ។ តែបើមានឧត្តរបទជាសត្តមីវិភត្តិវិញត្រូវប្រើពាក្យប្រែថា "មាន...ក្នុង...", ឬ "មាន...លើ..." ជាដើម ។ បទសមាសនេះជាគុណនាមបំបែកជាបឋមាវិភត្តិ និងមានបទដទៃជាប្រធាន ។ វិធីតាំងវិគ្គហៈមាន ២ បែប ។

## គោលការណ៍តាំងវិគ្គហៈ

### បែបទី ១

១. បុព្វបទជានាមនាមបំបែកក្នុងវិភត្តិណាមួយរៀងដាក់ទី ១ ។

២. ឧត្តរបទជានាមនាមដែរ ត្រូវបំបែកជាបឋមាវិភត្តិតែម្យ៉ាង និងរៀងដាក់ទី ២ ។

៣. **ត** សព្វនាមបំបែកជា **អស្ស** រួចសរសេរចូលជាមួយ **ឥតិ** ទៅជា **អស្សាតិ** រៀងដាក់ទី ៣ ។

៤. បទសមាសបំបែកជាបឋមាវិភត្តិឯកវចនៈតាម ការន្ត និង លិង្គ នោះ ៗ ។

១ ២ ៣ ៤

វិ. **ឯករត្តឹ វាសោ អស្សាតិ > ឯករត្តិវាសោ (បុគ្គលោ) ។**

បុព្វបទ ឧត្តរបទ **ត+ឥតិ** បទសមាស

ប្រែថា **វាសោ** រីកិរិយានៅ **អស្ស (បុគ្គលស្ស** របស់បុគ្គល) នោះ **ឯករត្តឹ** អស់មួយយប់ **ឥតិ** ព្រោះហេតុនោះ **សោ (បុគ្គលោ** រីបុគ្គល) នោះ **ឯករត្តិវាសោ** ឈ្មោះថា **ឯករត្តិវាសោ, ឯករត្តិវាសោ (បុគ្គ-លោ** រីបុគ្គល) មានកិរិយានៅអស់មួយយប់ ។

វិ. **សមានេន សំវាសោ អស្សាតិ > សមានសំវាសោ (ជនោ)** =(ជន) មានកិរិយានៅរួមដោយស្មើគ្នា ។

វិ. **ឆត្តំ បាណិម្ហិ អស្សាតិ > ឆត្តបាណិ (បុគ្គលោ)** =(បុគ្គល) មានឆ័ត្រក្នុងដៃ ។

វិ. **ទានេ អជ្ឈាសយោ អស្សាតិ > ទានអជ្ឈាសយោ (បុគ្គ-លោ)** =(បុគ្គល) មានអធ្យាស្រ័យក្នុងទាន ។

សមាសបែបនេះនឹងហៅថា **ឧតិយាភិន្នាធិករណពហុព្វីហិសមាស** ក៏បាន ព្រោះ **ឯករត្ថ** ជាទុតិយាវិភត្តិឬហៅថា **ឆដ្ឋីភិន្នាធិករណពហុព្វីហិសមាស** ក៏បាន ព្រោះមាន **ត** សព្វនាមបំបែកជាឆដ្ឋីវិភត្តិ ។

## បែបទី ២

រៀងរូបវិគ្គហៈតាមបែបតុល្យាធិករណពហុព្វីហិសមាសដែរដោយថែម **យ ត** ស័ព្ទចូលមកក្នុងវិគ្គហៈ គឺត្រូវបំបែក **យ** ស័ព្ទជាឆដ្ឋីវិភត្តិដូចតុល្យាធិករណពហុព្វីហិសមាសដែរ ឧ.

វិ. **ឧរសិ លោមានិ យស្ស សោ > ឧរសិលោមោ (ព្រាហ្មណោ)** ។

ប្រែថា **លោមានិ** រោមទ. **ឧរសិ** ត្រង់ទ្រូង **យស្ស** (**ព្រាហ្មណស្ស** របស់ព្រាហ្មណ៍) ណា (**អត្ថិ** មាន) **សោ** (**ព្រាហ្មណោ** រីព្រាហ្មណ៍) នោះ **ឧរសិលោមោ** ឈ្មោះថា **ឧរសិលោមោ**, **ឧរសិលោម** (**ព្រាហ្មណោ** រីព្រាហ្មណ៍) មានរោមត្រង់ទ្រូង ។

វិ. **អសិ ហត្ថេ យស្ស សោ > អសិហត្ថោ (ជនោ)** =(ជន) មានដាវក្នុងដៃ ។

## កំណត់សម្គាល់

បទនាមនាមក្នុងកិន្នាធិករណពហុព្វីហិសមាសនេះ ទាំងពីរបទមិនមានវិភត្តិដូចគ្នាទេ និងពេលខ្លះទាំងពីរបទក្នុងរូបវិគ្គហៈប្រែមិនបានសេចក្តីល្អទេ ក្នុងករណីដូច្នេះ លោកឱ្យថែមអាខ្យាតកិរិយាចូលមកទើបប្រែបានល្អ សូមមើលឧទាហរណ៍ខាងលើ ។ ស័ព្ទឯទៀត ៗ គប្បីជ្រាបតាមនយ័នេះ ។

## ៤. នបុព្វបទពហុព្វីហិសមាស

គ្រាន់តែឃើញឈ្មោះក៏ដឹងភ្លាមថា សមាសនេះមានបុព្វបទជា ន ដូចគ្នានឹងឧភយតប្បុរិសសមាស ដែលបានពោលពីខាងដើមរួចហើយដែរ ។ ប៉ុន្តែមានអត្ថន័យផ្សេងគ្នាត្រង់ ន-បុព្វបទក្នុងឧភយតប្បុរិសនោះប្រើបដិសេធនាមនាមប្រែថា "មិនមែន" ។ ចំណែក ន-បុព្វបទពហុព្វីហិ-សមាសវិញ ប្រែថា "មិនមាន......", ឬ "មាន...មិនមាន" ដូចឧទាហរណ៍ថា "មនុស្សនេះមិនមានទីពឹង" ឬក៏ "មានទីពឹងមិនមាន" យ៉ាងនេះជាដើម ។

## វិធីតាំងវិគ្គហៈ

១. បុព្វបទជា ន និបាតស័ព្ទប្រើប្រកបជាមួយអាខ្យាតកិរិយា រៀងដាក់ទី ១ ។

២. បទកណ្តាលប្រើ ត ឬ ឯត សព្វនាមបំបែកជាឆដ្ឋីវិភត្តិមានរូបជា តស្ស, ឯតស្ស (សម្រាប់យោគនាមដទៃ) រៀងដាក់ទី ២ ។

៣. ឧត្តរបទជានាមនាមបំបែកជាបឋមាវិភត្តិតាមការន្ត និង លិង្គនោះ ៗ និងត្រូវថែម ឥតិ ស័ព្ទចូលមកខាងចុងដោយសរសេរចូលគ្នានឹងនាមនាម រៀងដាក់ទី ៣ ។

៤. ចំពោះ ន ស័ព្ទបើបំប្រួញចូលជាមួយឧត្តរបទណាដែលផ្តើមដោយព្យញ្ជនៈ ត្រូវផ្លាស់ ន > អ ដូចជា (ន + ផាសុក) > អផាសុក និងប្រសិនបើឧត្តរបទផ្តើមដោយស្រៈវិញត្រូវផ្លាស់ ន > អន ដូចជា (ន + អស្សោ) > អនស្សោ ។

| ១ | ២ | ៣ | |
|---|---|---|---|
| វិ. នត្ថិ (ន + អត្ថិ) | តស្ស | ផាថោតិ | > អផាថោ (បុគ្គលោ) ។ |
| បុព្វបទ | កណ្តាល | ឧត្តរបទ | បទសមាស |

វិ. នត្ថិ ឯតស្ស អស្សោតិ > អនស្សោ (គាមោ) =(ភូមិ) មានសេះមិនមាន (=គ្មានសេះ) ។

វិ. នត្ថិ ឯតស្ស បុត្តោតិ > អបុត្តកោ (បុគ្គលោ) =(បុគ្គល) មានកូនមិនមាន (=គ្មានកូន, ចុះ ក បច្ច័យ) ។

វិ. នត្ថិ តស្ស ផាសុកន្តិ > អផាសុកំ (ចិត្តំ) =(ចិត្ត) មានសេចក្តីសប្បាយមិនមាន (=មានទុក្ខ) ។

*វិ.* **នត្ថិ តស្ស បដិបុគ្គលោតិ > អប្បដិបុគ្គលោ (ភគវា)** *=(ព្រះមានព្រះភាគ) មានបុគ្គលប្រៀបមិនមាន ។*

*វិ.* **នត្ថិ តស្ស សមោតិ > អសមោ (ភគវា)** *=(ព្រះមានព្រះភាគ) មានអ្នកស្មើមិនមាន (=គ្មានអ្នកស្មើ) ។*

*ប្រែលោតប្រយោគថា* **សមោ** *រីអ្នកស្មើ* **តស្ស** *(ភគវតោ របស់ព្រះមានព្រះភាគ) អង្គនោះ* **នត្ថិ** *មិនមាន* **ឥតិ** *ព្រោះហេតុនោះ (សោ* **ភគវា** *រីព្រះមានព្រះភាគ) អង្គនោះ* **អសមោ** *ឈ្មោះថា* **អសមោ, អសមោ** *(***ភគវា** *រីព្រះមានព្រះភាគ) មានអ្នកស្មើមិនមាន ។*

*វិគ្គហៈឯទៀត ៗ គប្បីជ្រាបតាមន័យនេះ ។*
*ឬក៏ប្រើអាខ្យាតកិរិយាក្រៅពី* **អស** *ធាតុក៏បានដូចជា*

*វិ.* **ន វិជ្ជតេ វុឌ្ឍិ ឯត្ថាតិ > អវុឌ្ឍិកោ (ជនបទោ)** *=(ជនបទ) មានភ្លៀងមិនមាន (=គ្មានភ្លៀង) ។*

**ន វិជ្ជតេ** *ប្រែថា "មិនមាន" ដូច* **នត្ថិ** *ដែរ ។*

## ៥. សហបុព្វបទពហុព្វីហិសមាស

*សមាសនេះមានបុព្វបទជា* **សហ** *និងដែលជានិបាតស័ព្ទ ប្រែថា "មួយអន្លើ" ទើបហៅថា* **សហបុព្វបទពហុព្វីហិសមាស** *ដូច្នេះ ។*

វេលាបំប្រួញចូលជាមួយនាមនាមហើយត្រូវលុប **ហ** ចោលឱ្យនៅសល់តែ **ស** ប៉ុណ្ណោះ ។

## វិធីតាំងវិគ្គហៈ

១. បុព្វបទប្រើ **សហ** ស័ព្ទរៀងដាក់ទី ១ ។

២. ឧត្តរបទជានាមនាមបំបែកជាតតិយាវិភត្តិជានិច្ច រៀងដាក់ទី ២

៣. ត្រូវថែម **យ** ស័ព្ទ បំបែកជាបឋមាវិភត្តិឱ្យមានការន្ត, លិង្គ និងវចនៈស្មើគ្នានឹងអញ្ញបទជានិច្ច ។

៤. ត្រូវថែមអាខ្យាតកិរិយាគឺ **វត្តតិ** ប្រែថា "ប្រព្រឹត្តទៅ" ចូលមកព្រមជាមួយ **ឥតិ** ស័ព្ទទៅជា **វត្តតីតិ** រៀងដាក់ទី ៤ ។

៥. បទសមាសបំបែកជាបឋមាវិភត្តិតាមការន្តនិងលិង្គនោះ ៗ ។

១ ២ ៣ ៤ ៥

**វិ. សហ បរិវារេន យោ វត្តតីតិ > សបរិវារោ ( ភិក្ខុ ) ។**

បុព្វបទ ឧត្តរបទ យ បទសមាស

**វិ. សហ បរិវារេន យោ វត្តតីតិ > សបរិវារោ ( ភិក្ខុ )** =(ភិក្ខុ) ប្រព្រឹត្តទៅមួយអន្លើដោយបរិវារ ។

**វិ. សហ បុត្តេន យោ វត្តតីតិ > សបុត្តោ ( បិតា )**=(បិតា) ប្រព្រឹត្តទៅមួយអន្លើដោយកូនប្រុស ។

វិ. **សហ មច្ឆេរេន យំ វត្តតីតិ** > **សមច្ឆេរំ ( ចិត្តំ )** =(ចិត្ត) ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីកំណាញ់ ។

វិ. **សហ រញ្ញា យា វត្តតីតិ** > **សរាជិកា ( បរិសា )** =(បរិស័ទ) ប្រព្រឹត្តទៅមួយអន្លើដោយស្ដេច ។

វិ. **សហ ភរិយាយ យោ វត្តតីតិ > សភរិយា ( បុរិសោ )** = (បុរស) ប្រព្រឹត្តទៅមួយអន្លើដោយភរិយា ។

វិ. **សហ សាមិកេន យា វត្តតីតិ** > **សសាមិកា ( ឥត្ថី )** =(ស្រី) ប្រព្រឹត្តទៅមួយអន្លើដោយស្វាមី ។

ប្រែជាគំរូដូច្នេះ **យា** ( **ឥត្ថី** រីស្រី) ណា **វត្តតិ** ប្រព្រឹត្តទៅ **សហ សាមិកេន** មួយអន្លើ ដោយស្វាមី **ឥតិ** ព្រោះហេតុនោះ (**សា ឥត្ថី** រីស្រី នោះ) **សសាមិកា** ឈ្មោះថា **សសាមិកា**, **សសាមិកា** (**ឥត្ថី** រីស្រី ) ប្រព្រឹត្តិទៅមួយអន្លើដោយស្វាមី ។

ឬនឹងប្រែថា "មាន..." ក៏បានដូចជា **សសាមិកា** =ស្រីមានស្វាមី, **សធនំ ( កុលំ )** =ត្រកូលមានទ្រព្យ ។ ស័ព្ទឯទៀត ៗ គប្បីជ្រាបតាមសេចក្ដីនេះ ។

## ពហុព្វីហិសមាសពិសេស

នៅមានពហុព្វីហិសមាសខ្លះទៀតដែលមិនសូវមានពោលឱ្យជ្រាប

សូមមើលសេចក្ដីអធិប្បាយខាងក្រោមនេះ

## ៦. សំខ្យានយបទពហុព្វីហិសមាស

សមាសនេះមានបុព្វបទ ២ បទដែលជាសំខ្យាស័ព្ទ មាន វា ស័ព្ទ រាំងក្នុងចន្លោះ ប្រើដើម្បីប្រាប់ចំនួនគឺបរិមាណរបស់នាមនាម ដែលជាឧត្តរបទ ឬបំប្រួញនាមស័ព្ទណាដែលប្រាប់ចំនួនរួចហើយក៏បាន វេលាបំប្រួញចូលគ្នាត្រូវលុប វា ស័ព្ទចេញ ។ ចំពោះសំខ្យាស័ព្ទត្រូវបំបែកតាមលិង្គរបស់នាមជាប្រធាន ប៉ុន្តែបទសមាសត្រូវប្រើរូបស័ព្ទដើមវិញ ឧ.

វិ. ទ្វេ វា តយោ វា បត្តា ទ្វិត្តិបត្តា =ពីរបាត្រឬបីបាត្រ ។
វិ. ទ្វីហំ វា តីហំ វា ទ្វីហាតីហំ =ពីរថ្ងៃឬបីថ្ងៃ ។
សត្តដ្ឋមាសា =ប្រាំពីរប្រាំបីខែ ។
ឯកយោជនទ្វិយោជជាតិ =មួយយោជន៍ពីរយោជន៍ ។

## ៧. តិបទពហុព្វីហិសមាស

នេះជាការបំប្រួញពាក្យបីម៉ាត់ចូលគ្នាឱ្យជាបទមួយ ទើបហៅថា **តិបទពហុព្វីហិសមាស** ដូចឧទាហរណ៍ខាងក្រោមនេះ

១. **បរក្កមេន$_{១}$ អធិគតា$_{២}$ សម្បទា$_{៣}$ យេហិ តេ ភវន្តិ** > **បរក្កមាធិគតសម្បទា (មហាបុរិសា)** = *គុណសម្បត្តិ ដែលមហាបុរស.ទ. ណា បានហើយ ដោយសេចក្តីព្យាយាម មហាបុរសទាំងនោះឈ្មោះថា* **បរក្កមាធិគតសម្បទា** = *មានគុណសម្បត្តិដែលខ្លួនបានហើយដោយសេចក្តីព្យាយាម ។*

២. **ឱណិតោ$_{១}$ បត្តតោ$_{២}$ ចាណិ$_{៣}$ យេន សោ** > **ឱណិតបត្ត-ចាណិ (ភិក្ខុ)** =(*ភិក្ខុ*) *មានដៃយកចេញហើយពីបាត្រ ។*

*ក្នុងឧទាហរណ៍ទី ១ បំប្រួញបទ* **បរក្កមេន អធិគតម្បទា សម្បទា** > **បរក្កមាធិគតសម្បទា** ។

*រីឯឧទាហរណ៍ទី ២ បំប្រួញបទ* **ឱណិតោ បត្តតោ ចាណិ** > **ឱណិតបត្តចាណិ** ។

## ៨. ព្យតិហារលក្ខណពហុព្វីហិសមាស

*សមាសនេះបំប្រួញពាក្យពីរម៉ាត់ដែលដូចគ្នា មាន* **ច** *ស័ព្ទរាំងក្នុងចន្លោះដូចទ្វន្ទសមាសដែរ ។ ប៉ុន្តែប្រើក្នុងសេចក្តីផ្សេងគ្នា ដូចមានឧទា-ហរណ៍ខាងក្រោមនេះ*

១. **កេសេសុ ច កេសេសុ ច គហេត្វា ឥទំ យុទ្ធំ បវត្តតីតិ** > **កេសាកេសី** ។ *ការប្រយុទ្ធ នេះ ប្រព្រឹត្តទៅ ដោយចាប់ហើយ នូវ*

សក់.ទ. ផង និងសក់.ទ. ផង ព្រោះហេតុនោះ ឈ្មោះថា **កេសាកេសី** (ការបោចសក់គ្នាទៅវិញទៅមក) ។

២. **ទណ្ឌេហិ ទណ្ឌេហិ បហរិត្វា ឥទំ យុទ្ធំ បវត្តតីតិ** > **ទណ្ឌាទណ្ឌី** ។ ការប្រយុទ្ធ នេះ ប្រព្រឹត្តទៅ ដោយវាយហើយ ដោយដំបង.ទ. និងដំបង.ទ. ព្រោះហេតុនោះ ឈ្មោះថា **ទណ្ឌាទណ្ឌី** ។ (ការវាយគ្នាដោយដំបងនិងដំបង) ។

សូមសង្កេតមើលបទសមាសនេះ ស័ព្ទទាំងពីរបទដូចគ្នាមែន តែបុព្វបទត្រូវមានរូបជាពហុវចនៈ ។ រីឯឧត្តរបទត្រូវផ្លាស់ជា ឦ ការន្តវិញ និងអព្យយកិរិយា(ត្វាទិបច្ច័យ) ត្រូវប្រែថា "ដោយ...ហើយ" ដើម្បីឱ្យមានសេចក្តីស្តាប់បានល្អ ។

## ៩. ទិសន្តរាឡត្ថពហុព្វីហិសមាស

សមាសនេះធ្វើការបំប្រួញឈ្មោះទិសធំនានាដើម្បីប្រាប់ទិសតូច ៗ ដូចមានខាងក្រោមនេះ

១. **បុព្វស្សា ច ទក្ខិណស្សា ច ទិសាយ យទន្តរាឡំ សាយំ** > **បុព្វទក្ខិណា** (**វិទិសា**) ។ ទិសឆៀង ណា នៅ រវាង ទិសបូព៌ និងទិសទក្សិណ ទិសឆៀង នោះ ឈ្មោះថា **បុព្វទក្ខិណា** =ទិសខាងកើតឆៀងខាងត្បូង (ទិសអគ្នេយ៍) ។

ដូច្នេះក៏អាចមានបទសមាសថា **បុព្វុត្តរា** =ទិសឦសាន ។
ប៉ុន្តែ **អបរទក្ខិណា** =ទិសនីរតី, **អបរុត្តរា** =ទិសពាយ័ព្យ ។

## សរុបសេចក្ដីរបស់សមាស

វិធីបំប្រួញបទសមាសនានាដូចពោលហើយទាំងអស់នេះ គប្បីកត់ចំណាំវិធីតាំងវិគ្គហៈរបស់សមាសនីមួយ ៗ ឱ្យបានល្អ ។ សូមចាំថាសមាសនីមួយ ៗ អាចបំប្រួញស័ព្ទចូលជាមួយគ្នាបានមិនលើសពី ២ ស័ព្ទទេ (វៀរតែ **ទ្វន្ទសមាស** ដែលអាចបំប្រួញលើសពី ២ ស័ព្ទបាន និង **តិបទពហុព្វិហិសមាស**) ។

បទសមាសគ្រប់ប្រភេទដូចបានសិក្សារួចហើយនេះ អាចយកទៅបំប្រួញចូលជាមួយនឹងស័ព្ទដទៃទៀត ឬក៏បទសមាសដូចគ្នាម្ដងទៀតបាន និយមហៅថា សមាសមានផ្ទៃ ឬហៅថា សមាសត្រួតសមាស ។ ប៉ុន្តែក្នុងសៀវភៅនេះនឹងហៅថា **មិស្សកសមាស** វិញដែលនឹងមានអធិប្បាយនៅខាងមុខ ។

## ចំណុចគួរចងចាំ

ការសិក្សាបទសមាសទាំងឡាយរហូតមក មានចំណុចគួរធ្វើការចងចាំដូចតទៅ

១. បទសមាសដែលសម្រេចមកពីកម្មធារយសមាស អាចប្រើបាន ៣ បែបគឺ

១.១ ប្រើជានាមនាម បានដល់ បទសមាសសម្រេចពី វិសេសន-បុព្វបទ, វិសេសនុត្តរបទ, សម្ភាវនបុព្វបទ, អវធារណាបុព្វបទ ។

១.២ ប្រើជាគុណនាមតែម៉្យាង បានដល់ បទសមាសសម្រេចពី វិសេសោភយបទ ។

១.៣ ប្រើជានាមនាមក៏បានជាគុណនាមក៏បាន បានដល់ បទសមាសសម្រេចមកពី វិសេសោបមបទកម្មធារយសមាស ។

២. បទសមាសដែលមានបុព្វបទជាបទប្រធានគឺ

២.១ វិសេសនុត្តរបទកម្មធារយសមាស ។

២.២ ឧបមាបុព្វបទសមាស នៃ វិសេសនោបមបទកម្មធារយ-សមាស វិគ្គហៈខ្វះ ។

២.៣ ឧបមានុត្តរបទសមាស នៃ វិសេសនោបមបទកម្មធារយ-សមាស ។

៣. បទសមាសដែលមានឧត្តរបទជាបទប្រធានគឺ

៣.១ វិសេសនបុព្វបទកម្មធារយសមាស ។

៣.២ ឧបមាបុព្វបទ នៃ វិសេសនោបមបទកម្មធារយសមាស ។

៣.៣ សម្ភាវនបុព្វបទកម្មធារយសមាស ។

៣.៤ អវធារណាបុព្វបទកម្មធារយសមាស ។

៣.៥ **តប្បុរិសសមាស** វិគ្គហៈខ្លះគឺ ចតុត្ថី. បញ្ចមី. ឆដ្ឋី និង សត្តមីតប្បុរិស ។

**២. បទសមាសដែលមានបទដទៃជាបទប្រធានគឺ**

២.១ **វិសេសនោភយបទកម្មធារយសមាស** ។

២.២ **តប្បុរិសសមាស** គឺ ទុតិយាតប្បុរិស. និង តតិយាតប្បុរិស-សមាស ។

២.៣ **ពហុព្វីហិសមាស** ទាំងអស់គឺពី ទុតិយា. ដល់ សត្តមីពហុ-ព្វីហិសមាស និង ឧបមា., ន-បុព្វបទ. ព្រមទាំងឆដ្ឋីកិន្នាធិករណពហុព្វី-ហិសមាសផងដែរ ។

**៥. បទសមាសដែលមានឧបសគ្គនិងនិបាតជាបុព្វបទគឺ**

៥.១ **ន-បុព្វបទកម្មធារយសមាស** ។

៥.២ **ឧភយតប្បុរិសសមាស** (ន-បុព្វបទកម្មធារយសមាស) ។

៥.៣ **ន-បុព្វបទពហុព្វីហិសមាស, សហ-បុព្វបទពហុព្វីហិ-សមាស** ។

៥.៤ **អព្យយីភាវសមាស** ។

**៦. បទសមាសដែលអាចបំប្រួញច្រើនស័ព្ទបានគឺ ទ្វន្ទសមាស ។**

**៧. បទសមាសដែលលុបឱ្យនៅសល់តែមួយបទគឺ ឯកសេស-សមាស ។**

**៨. បទសមាសដែលត្រូវបំបែកជាឯកវចនៈនបុំសកលិង្គតែម្យ៉ាង**

មាន ៣ គឺ

៨.១ សមាហារទិគុសមាស ។

៨.២ សមាហារទ្វន្ទសមាស ។

៨.៣ អព្យយីភាវសមាស ។

៩. បទសមាសដែលចាត់ជា

៩.១ នាមនាមគឺ ទិគុសមាស, ទ្វន្ទសមាស ។

៩.២ គុណនាមគឺ ពហុព្វីហិសមាស ទាំងអស់ ។

៩.៣ នាមនាមផងជាគុណនាមផងគឺ

(១) កម្មធារយសមាសទាំងអស់ ។

(២) តប្បុរិសសមាសទាំងអស់ ។

(៣) អព្យយីភាវសមាសទាំងអស់ ។

(សមាសទាំង ៦ ប្រភេទចប់ដោយបរិបូណ៌ត្រឹមនេះ)

## លំហាត់នៃមេរៀនទី ៤៩

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើតុល្យាធិករណពហុព្វីហិសមាស និង ភិន្នាធិករណពហុព្វីហិ-សមាសមានលក្ខណៈខុសដូចម្ដេច ?

២. តើមានចំណុចសង្កេតដូចម្ដេច ដើម្បីឱ្យដឹងថាបទសមាសណាមួយ នោះជាឧភយតប្បុរិសសមាស ឬ ទ្វន្ទ្វសមាស ឬក៏ជា ពហុព្វីហិ-សមាស ?

៣. តើសង្កេតមើលយ៉ាងណាឱ្យដឹងថាសមាសណាមួយជា វិសេសនោ-ភយបទកម្មធារយសមាស ឬជា ទ្វន្ទ្វសមាស ?

៤. ចូរសង្កេតមើលបទសមាសទាំងឡាយខាងក្រោមនេះថាជាសមាសអ្វីខ្លះនិងចូរតាំងវិគ្គហៈមកមើល

| | |
|---|---|
| កិលាឧកេសឆ្នំ | រូបសញ្ញា |
| កាតបុញ្ញោ (ជនោ) | ឧចាសកា |
| ឆត្តចាណិ (បុរិសោ) | ពហុជនោ (គាមោ) |
| ឧបឧតរំ | សប្បុរិសោ |
| អង្គវជិរោ | សុខប្បត្តោ (បុរិសោ) |
| អារុឡ្ហតិណំ (វនំ) | ជញ្ញាកសិ |
| អសិកាលរោហា | សបរិវារោ (ភិក្ខុ) |

(ចប់មេរៀនទី ៤៩)

# មេរៀនទី ៤០

# អធិប្បាយអំពីសមាស (តចប់)

## មិស្សកសមាស

## (Complex Compounds)

*បទសមាសទាំងឡាយដែលបានអធិប្បាយរួចមកហើយនោះ អាចយកមកបំប្រួញជាមួយនឹងសព្ទណាមួយថែមទៀត ឬក៏បំប្រួញចូលជាមួយបទសមាសដូចគ្នាណាមួយទៀត ដែលអាចជាបុព្វបទឬជាឧត្តរបទនៃសមាសថ្មីក៏បាន សមាសបែបនេះហៅថា* **មិស្សកសមាស** *ប្រែថា សមាសចម្រុះ ។ ក្នុងបករណ៍ខ្មែរនិងបរទេសខ្លះនិយមហៅថា សមាសមានផ្ទៃ ឬហៅថា សមាសត្រួតសមាស ។*

*មិស្សកសមាសនេះមិនកំណត់ថា ត្រូវបំប្រួញសមាសប៉ុន្មានបទ ឬ ប្រើបានតែសមាសប្រភេទណាមួយជាមួយនឹងសមាសណាមួយទៀតទេ គឺស្រេចតែសេចក្ដីក្នុងទីនោះ ៗ ។ ដើម្បីឱ្យងាយយល់ចូលចិត្ត លោកបានប្រៀបប្រដូចទៅនឹងពោះ(ផ្ទៃ)របស់មនុស្សយើង ពីព្រោះពោះត្រូវប្រកបដោយ ក្រពះ, ពោះវៀនតូច-ធំ, ថ្លើម, លំពែង, ថង់មូត្រ ជាដើមឬដូចជាស្ត្រីមានពរផ្ទៃ ទើបលោកឱ្យឈ្មោះថា សមាសមានផ្ទៃ ឬ ផើម ។*

*បើនិយាយមួយបែបទៀត លោកប្រៀបប្រដូចនឹងការទទួលទាន*

អាហារដូចជាបាយជាដើម ។ បាយដុំទី ១ រមែងធ្លាក់ទៅដល់បាតក្រពះ រីដុំក្រោយ ៗ ទៀតត្រួតគ្នាជាបន្តបន្ទាប់ឡើងលើ គឺមួយជាន់ត្រួតមួយជាន់ទៀតទើបបានលោកហៅថា សមាសត្រួតសមាស ។ ដូច្នេះសមាសបែបនេះត្រូវមានសមាសក្រៅដែលដូចជាពោះមនុស្ស និងសមាសក្នុងដែលដូចជាអាហារយើងបានទទួលទានចូលទៅនោះ ។ សមាសក្រៅមានតែមួយទេគឺ សមាសបទថ្មី ដែលបំប្រួញសមាសនានាចូលគ្នានោះ ចំណែកឯសមាសក្នុងអាចមានច្រើនបទមិនកំណត់ឡើយ ។

## វិធីញែកមិស្សកសមាស

បទសមាសទាំងអស់សម្រេចមកពីពាក្យ ២ ម៉ាត់បំប្រួញចូលគ្នាឱ្យកើតជាសមាសមួយបទ(វៀរតែទ្វន្ទសមាសនិងតិបទពហុព្វីហិសមាស)។

ប៉ុន្តែបើមានពាក្យ ៣ ម៉ាត់គឺត្រូវតែមានសមាសពីរបទ, បើមាន ៤ ម៉ាត់គឺមានសមាសបីបទ, បើមាន ៥ ម៉ាត់គឺមានសមាសបួនបទ ។ល។ ចំពោះឈ្មោះសមាសនោះ ៗ វិញ លុះត្រាតែតាំងវិគ្គហៈទើបដឹងច្បាស់ថាមានឈ្មោះអ្វី ដូច្នេះត្រូវតែតាំងវិគ្គហៈមើល ពីព្រោះវិគ្គហៈមានសារៈសំខាន់ណាស់ ។ សូមរកមើលវិធីនីមួយ ៗ ក្នុងមេរៀនខាងដើម ។

ខាងក្រោមនេះនឹងអធិប្បាយពីរបៀបញែកមិស្សកសមាសទុកជាគំរូ ឧទាហរណ៍ បទថា **សត្តវិសេសភោជកោ** (បុគ្គលោ) ។

ឧទាហរណ៍ទី ១ បទថា **សត្តវិសេសភោជកោ** (បុត្តលោ)

មុនគេបង្អស់គឺត្រូវញែកសមាសនេះចេញពីគ្នាទៅជាបទ ៗ សិនទៅជា **សត្ត** + **វិសេស** + **ភោជក** (+ សិ វិ.) (បុត្តលោ) ។

១. **សត្ត** =សត្វ, ២. **វិសេស** =វិសេស, ៣. **ភោជក** =អ្នកស៊ី ។

## វិធីពិចារណា

ក្រោយពីញែកចេញពីគ្នាហើយឃើញថាមាន ៣ បទ (មិនទាន់រាប់ **បុត្តលោ** ទេ) ដូច្នេះបើតាមការអធិប្បាយខាងលើ ត្រូវមានសមាស ២ គឺសមាសក្រៅមួយ និងសមាសក្នុងមួយ ។

បន្ទាប់មកទៀតសាកល្បងប្រែមើលសិន ពេលប្រែត្រូវប្រែពីឧត្តរ-បទច្រាសទៅរកបុព្វបទ ។ ក្នុងទីនេះប្រែថា **ភោជកោ** =អ្នកស៊ី, **សត្ត** = នូវសត្វ, **វិសេស** =ដែលវិសេស "អ្នកស៊ីនូវសត្វដែលវិសេស" ។ សួរថាតើមានសមាសអ្វីខ្លះ ? ដើម្បីឱ្យបានដឹងត្រូវតាំងវិគ្គហៈឱ្យត្រូវតាមគោលរបស់សមាសនោះ ៗ ដូចតទៅនេះ

## វិធីតាំងវិគ្គហៈនៃមិស្សកសមាស

របៀបតាំងវិគ្គហៈមានចំណុចត្រូវចងចាំគឺថា បទណាប្រែក្រោយគេបង្អស់ត្រូវតាំងវិគ្គហៈមុនគេបង្អស់ ។ រីបទណាប្រែមុនគេបង្អស់ត្រូវ

តាំងវិគ្គហៈក្រោយគេវិញ ដូច្នេះការប្រែគឺ ផ្ទុយគ្នានឹងការតាំងវិគ្គហៈ ។ បទដែលប្រែក្រោយគេគឺ "សត្វដែលវិសេស" ដូច្នេះត្រូវតាំងវិគ្គហៈមុនថា

វិ.ទី ១. **សត្តោ វិសេសោ** > **សត្តវិសេសោ** =សត្វដែលវិសេស ។

នេះជា **វិសេសនុត្តរបទកម្មធារយសមាស** ព្រោះមានបទ **សត្តោ** ជាបទប្រធាន និង **វិសេសោ** ជាបទវិសេសនៈនៅខាងចុង ទើបហៅដូច្នេះ ។ បន្ទាប់មកយកបទសមាសរបស់វិគ្គហៈទី ១ នេះបំប្រួញចូលជាមួយ **ភោជកោ** ទៀតដែលមានវិគ្គហៈថា

វិ.ទី ២. **សត្តវិសេសំ ភោជកោ** > **សត្តវិសេសភោជកោ** (**បុគ្គលោ**) =(បុគ្គល) អ្នកស៊ីនូវសត្វដែលវិសេស ។

នេះជា **ទុតិយាតប្បុរិសសមាស** ព្រោះមានបុព្វបទក្នុងរូបជាទុតិយាវិភត្តិ និងមានឧត្តរបទជាគុណបទ ហើយនឹងមានបទដទៃជាប្រធាន ទើបហៅដូច្នេះ ។

ឥឡូវនេះបានបទសមាស ២ ហើយ ប៉ុន្តែត្រូវសួរទៀតថា តើសមាសមួយណាជាសមាសក្រៅនិងមួយណាជាសមាសក្នុង ? ត្រូវយល់ចូលចិត្តថា បើសមាសណាតាំងវិគ្គហៈក្រោយគេបង្អស់សមាសនោះ ៗ ជាសមាសក្រៅ ។ រីឯសមាសដ៏ទៃទៀតជាសមាសក្នុងបន្តបន្ទាប់តាមលំដាប់គ្នា ។ ចម្លើយឆ្លើយថា ទុតិយាតប្បុរិសសមាស ជាសមាសក្រៅ និង វិសេសនុត្តរបទកម្មធារយសមាស ជាសមាសក្នុង ។ ប្រសិនបើយក

**បុគ្គល** មកបំប្រួញចូលថែមផង៍ ទៅជា **សត្តវិសេសភោជកបុគ្គលោ** រួមគ្នាមាន ៤ បទ ត្រូវជា ៣ សមាសដែលប្រែថា "បុគ្គលអ្នកស៊ីនូវសត្វដែលវិសេស" មានវិគ្គហៈថា

វិ. ១. **សត្តោ វិសេសោ > សត្តវិសេសោ** =សត្វដែលវិសេស (វិសេសនុត្តរបទកម្មធារយសមាស) ។

វិ. ២. **សត្តវិសេសំ ភោជកោ > សត្តវិសេសភោជកោ (បុគ្គលោ)** =(បុគ្គល)អ្នកស៊ីនូវសត្វដែលវិសេស (ទុតិយាតប្បុរិសសមាស) ។

វិ. ៣. **សត្តវិសេសភោជកោ បុគ្គលោ > សត្តវិសេសភោជកបុគ្គលោ** =បុគ្គលអ្នកស៊ីនូវសត្វដែលវិសេស (វិសេសនបុព្វបទកម្មធារយសមាស) ។

ដូច្នេះឃើញថាចម្លើយដែលឆ្លើយបានភ្លាមគឺថា **សត្តវិសេសភោជកបុគ្គលោ** ជា ***វិសេសនបុព្វបទកម្មធារយសមាស*** ជាសមាសក្រៅតែម្តង៍ ។ រីទុតិយាតប្បុរិសសមាស ក្លាយជាសមាសក្នុង៍ និង៍វិសេសនុត្តរបទកម្មធារយសមាសជាសមាសក្នុង៍មួយជាន់បន្តទៀតតាមលំដាប់គ្នា ។

## ការសង្កេត

សូមសង្កេតមើល **សត្ត + វិសេស + ភោជក + បុគ្គល** (+ សិ វិ.)

មានតគ្នាដល់ទៅ ៤ បទ ជាសមាសត្រួតសមាសដល់ទៅ ៣ សមាសឬ ៣ ជាន់ដូចដុំបាយដែលត្រួតលើគ្នានៅក្នុងក្រពះរបស់យើងជាជាន់ ៗ ។ បាយដុំទី ១ នឹងនៅជាន់ក្រោមបង្អស់ រីឯបាយដុំចុងក្រោយគេនឹងនៅខាងលើបំផុត ។ ផ្ទុយទៅវិញបើយើងត្រឡប់ម៉ាត់ក្រពះចុះ បាយដុំទី ១ នឹងនៅខាងលើវិញម្តង ។ ចំណែកឯបាយដុំចុងក្រោយគេបង្អស់នឹងនៅខាងក្រោមម្តងវិញ ។ យ៉ាងណាមិញការរៀងវិគ្គហៈរបស់មិស្សកសមាសនេះ ត្រូវតាំងពីសមាសក្នុងគេបង្អស់ចេញមកសមាសក្រៅមួយម្តង ៗ តាមលំដាប់ដូចនៅខាងលើ ។ បទសមាសឯទៀត ៗ ក៏មានគតិដូចគ្នានេះទាំងអស់ សូមចាំទុកផងចុះ ។

### ឧទាហរណ៍ទី ២ បទថា **សព្វរត្តិសោភណោ** (ចន្ទោ)

វិ.ទី ១ **សព្វា រត្តិ** > **សព្វរត្តិ** =រាត្រីទាំងពួង (ពេញរាត្រី) ។

វិ.ទី ២. **សព្វរត្តី សោភណោ** > **សព្វរត្តិសោភណោ** (ចន្ទោ) =(ដួងច័ន្ទ) ល្អអស់រាត្រីទាំងពួង (នេះជាទុតិយាតប្បុរិសសមាស) ។

ប្រសិនបើយក **ចន្ទោ** មកបំប្រួញចូលថែមទៀតទៅជា

វិ.ទី ៣. **សព្វរត្តិសោភណោ ចន្ទោ** > **សព្វរត្តិសោភណ-ចន្ទោ** =ដួងច័ន្ទល្អអស់រាត្រីទាំងពួង ។

(ក្នុងសេចក្តីថាដួងច័ន្ទរះល្អពេញមួយយប់) មានវិសេសនបុព្វបទកម្មធារយសមាស ជាសមាសក្រៅ, ទុតិយាតប្បុរិសសមាស ជាសមាស

ក្នុងទី ១ និងមានវិសេសនបុព្វបទកម្មធារយសមាសជាសមាសក្នុងមួយជាន់បន្តទៀត ។

ឧទាហរណ៍ទី ៣ បទថា **សីតសមជ្ជហានបរិជ្ជោ (ភិក្ខុ)**

វិ.ទី ១ **សីតញ្ច សមជ្ជញ្ច > សីតសមជ្ជំ (ហានំ)** =(ទី) ត្រជាក់ផងរអិលផង ។ នេះជាវិសេសនោភយបទកម្មធារយសមាស ។

វិ.ទី ២. **សីតសមជ្ជំ ហានំ > សីតសមជ្ជហានំ** =ទីត្រជាក់ផងរអិលផង (នេះជាវិសេសនបុព្វបទកម្មធារយសមាស) ។

វិ.ទី ៣. **សីតសមជ្ជហានំ បរិជ្ជោ > សីតសមជ្ជហានបរិជ្ជោ (ភិក្ខុ)** =(ភិក្ខុ) ចូលទៅហើយកាន់ទីត្រជាក់ផងរអិលផង ។ នេះមានទុតិយាតប្បុរិសសមាសជាសមាសក្រៅ និងមានវិសេសនោភយបទកម្មធារយសមាសជាសមាសក្នុងទី ១ ហើយនឹងមានវិសេសនបុព្វបទកម្មធារយសមាសនៅខាងក្នុងបន្ទាប់មួយជាន់ទៀត ។

ប្រសិនបើយក **ភិក្ខុ** មកបំប្រួញចូលថែមទៀតទៅជា

វិ.ទី ៤. **សីតសមជ្ជហានបរិជ្ជោ ភិក្ខុ > សីតសមជ្ជហានបរិជ្ជភិក្ខុ** =ភិក្ខុចូលទៅហើយកាន់ទីត្រជាក់ផងរអិលផង(នេះមានវិសេសនបុព្វបទកម្មធារយសមាសជាសមាសក្រៅបំផុត និងមានទុតិយាតប្បុរិសសមាសនៅខាងក្នុងជាន់ទី ១ មានវិសេសនបុព្វបទកម្មធារយសមាស

ខាងក្នុងជាន់ទី ២ ហើយនឹងមានវិសេសនោភយបទកម្មធារយសមាស នៅខាងក្នុងបង្អស់ ។

## កំណត់សម្គាល់

ឧទាហរណ៍បទមិស្សកសមាសដូចពោលរួចហើយនេះ ជាសមាសដែលប្រែពីឧត្តរបទទៅរកបុព្វបទ ។ ប៉ុន្តែសមាសខ្លះត្រូវប្រែពីបុព្វបទទៅរកឧត្តរបទក៏មាន ហើយខ្លះទៀតចាប់ប្រែពីបទកណ្តាលរួចត្រឡប់មកប្រែបុព្វបទហើយបែរទៅរកឧត្តរបទវិញក៏មានដែរ ។ នេះក៏ព្រោះសមាសខ្លះមានបទនីមួយ ៗ ក្នុងវិគ្គហៈជានាមនាមដូចគ្នា ហើយមានបទវិសេសនៈតែមួយបទរួមគ្នា ។ ក្នុងករណីបែបនេះត្រូវបំប្រួញបទដែលជានាមនាមចូលគ្នាជាបទមួយសិន បន្ទាប់មកបំប្រួញបទដែលជាបទវិសេសនៈចូលទៀតជាក្រោយ រួចហើយទើបបំប្រួញចូលជាមួយបទសមាសដទៃទៀត ។ បទសមាសប្រភេទនេះមុនតាំងវិគ្គហៈ ត្រូវជញ្ជឹងគិតមើលថាស័ព្ទណាប្រែដូចម្តេចទើបបានសេចក្តីល្អ ។ ប្រសិនបើពាក្យប្រែនោះត្រូវគ្នាសមនឹងសមាសប្រភេទណា តាំងវិគ្គហៈទៅតាមសមាសនោះ ៗ ទៅ ដូចមានឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍ទី ១. **មហាបុរិសសជ្ឈបរិបុណ្ណោ** (គាមោ)

*វិ.ទី ១.* **បុរិសានំ សង្ឃោ** > **បុរិសសង្ឃោ** =*ក្រុមនៃបុរស, (នាម + នាម) (នេះជាឆដ្ឋីតប្បុរិសសមាស) ។*

*វិ.ទី ២.* **មហន្តោ បុរិសសង្ឃោ** > **មហាបុរិសសង្ឃោ** =*ក្រុមនៃបុរសច្រើន (គុ. + សមាស) (ជាវិសេសនបុព្វបទកម្មធារយសមាស) ។*

*វិ.ទី ៣* **មហាបុរិសសង្ឃេន បរិបុណ្ណោ** > **មហាបុរិសសង្ឃបរិបុណ្ណោ (គាមោ)** =*(ភូមិ) បរិបូណ៌ហើយដោយក្រុមនៃបុរសច្រើន (សមាស + កិតកិរិយា) (នេះជាតតិយាតប្បុរិសសមាស) ។*

*វិ.ទី ៤* **មហាបុរិសសង្ឃបរិបុណ្ណោ គាមោ** > **មហាបុរិសសង្ឃបរិបុណ្ណគាមោ** = *ភូមិដែលបរិបូណ៌ហើយដោយក្រុមនៃបុរសច្រើន (សមាស + នាម) (នេះជាវិសេសនបុព្វបទកម្មធារយសមាស) ។*

*បទសមាសនេះអាចចង់វិគ្គហៈជាពហុព្វីហិសមាសបន្តទៀតបាន ដូចខាងក្រោមនេះ*

*វិ.ទី ៥.* **មហាបុរិសសង្ឃបរិបុណ្ណោ គាមោ យស្ស សោ** > **មហាបុរិសសង្ឃបរិបុណ្ណគាមោ (និគមោ)** = (និគម) មានភូមិដែល*បរិបូណ៌ហើយដោយក្រុមនៃបុរសច្រើន (នេះជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ជាសមាសក្រៅបង្អស់ ។*

*ប្រសិនបើផ្លាស់* **យស្ស សោ** *ជា* **យស្មឹ សោ** *ឱ្យជាសត្តមីតុល្យាធិករណពហុព្វីហិសមាសក៏បាន ។*

ឧទាហរណ៍ទី ២. **បវត្តិតបវរធម្មចក្កោ** (**ភគវា**)

ដំបូងបំផុតត្រូវញែកស័ព្ទចេញពីគ្នាសិនជា **បវត្តិត** + **បវរ** + **ធម្ម** + **ចក្ក** (+ **សិ** វិ.) មាន ៤ បទ ដូច្នេះត្រូវមាន ៣ សមាសគឺតតិយាតុល្យាធិករណពហុព្វីហិសមាសជាសមាសក្រៅ មានអវធារណបុព្វបទកម្មធារយសមាស និងវិសេសនបុព្វបទកម្មធារយសមាសជាសមាសក្នុង ដែលមានវិគ្គហៈតាមលំដាប់ដូច្នេះ

វិ. **ធម្មោ ឯវ ចក្កំ** > **ធម្មចក្កំ** =ចក្រគឺធម៌ (អវធារណបុព្វបទកម្មធារយសមាស) ។

វិ. **បវរំ ធម្មចក្កំ** > **បវរធម្មចក្កំ** =ចក្រគឺធម៌ដ៏ប្រសើរ (វិសេសនបុព្វបទកម្មធារយសមាស) ។

វិ. **បវត្តិតំ បវរធម្មចក្កំ យេន សោ** > **បវត្តិតបវរធម្មចក្កោ** (**ភគវា**) ប្រែថា (ព្រះមានព្រះភាគ) មានចក្រគឺធម៌ដ៏ប្រសើរដែលព្រះអង្គឱ្យប្រព្រឹត្តទៅហើយ (ជាតតិយាតុល្យាធិករណពហុព្វីហិសមាស) ។

## អាទិ ស័ព្ទក្នុងសមាស

មានសមាសមួយបែបដែលមាន **អាទិ** ស័ព្ទជាប់នៅខាងចុង ។ បើមានក្នុងបទណា បទនោះ ៗ ត្រូវប្រែថា "មាន......ជាដើម" ។ ភាគច្រើនជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ដូចជា

## ១. ជិព្ហចក្ខុឱលោកជាជិ (ភិក្ខុ)

*សមាសនេះជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ជាសមាសក្រៅ មានឧបមាបុព្វបទកម្មធារយសមាស និង តតិយាតប្បុរិសសមាសនៅខាងក្នុង ដូចមានវិគ្គហៈតាមលំដាប់ខាងក្រោមនេះ*

**ជិព្ហ + ចក្ខុ + ឱលោកន + អាជិ** (+ សិ វិ.)

**ឧបមាបុព្វបទកម្ម.** *វិ.* **ជិព្ហំ ឥវ ចក្ខុ > ជិព្ហចក្ខុ** =*ភ្នែកដូចជាទិព្វ ។*

**តតិយាតប្បុរិស.** *វិ.* **ជិព្ហចក្ខុនា ឱលោកនំ > ជិព្ហចក្ខុឱលោកនំ** =*ការមើលដោយចក្ខុដូចជាទិព្វ ។*

**ឆដ្ឋីតុល្យធិករណ.** *វិ.* **ជិព្ហចក្ខុឱលោកនំ អាជិ យស្ស តំ > ជិព្ហ-ចក្ខុឱលោកជាជិ (ភិក្ខុំ)** =(*ភិក្ខុ*) *មានការមើលដោយចក្ខុដូចជាទិព្វជាដើម ។*

## ២. គន្ធមាលាជិហត្ថា (មនុស្សា)

*សមាសនេះជាឆដ្ឋីភិន្នាធិករណពហុព្វីហិសមាស ជាសមាសក្រៅ មានអសមាហារទ្វន្ទសមាស និង ឆដ្ឋីតុល្យាធិករណពហុព្វីហិសមាសនៅខាងក្នុង ដូចមានវិគ្គហៈតាមលំដាប់ខាងក្រោមនេះ*

**គន្ធ + មាលា + អាជិ + ហត្ថ** (+ យោ វិ.)

**អសមាហារទ្វន្ទ.** *វិ.* **គន្ធោ ច មាលា ច > គន្ធមាលា** =*គ្រឿងក្រអូប និងកម្រងផ្កា ។*

ឆដ្ឋីតុល្យធិករណ. វិ. គន្ធមាលា អាទយោ យេសំ តានិ > គន្ធ-មាលាទីនិ (វត្ថូនិ) =(វត្ថុ.ទ.) មានគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ។

ឆដ្ឋីភិន្នាធិករណ. វិ. គន្ធមាលាទីនិ ហត្ថេសុ យេសំ តេ > គន្ធ-មាលាទិហត្ថា (មនុស្សា) =(មនុស្ស.ទ.) មានវត្ថុមានគ្រឿងក្រអូបនិងកម្រងផ្កាជាដើមក្នុងដៃ ។

សព្ទឯទៀត ៗ គប្បីជ្រាបតាមន័យនេះផងចុះ ។

## ភេទ សព្ទក្នុងសមាស

មានសមាសមួយបែបទៀតមាន ភេទ សព្ទជាប់នៅខាងចុង ដូចគ្នានឹង អាទិ សព្ទដែរ ។ សមាសប្រភេទនេះប្រែបានពីរយ៉ាងគឺ

១. ប្រែថា "ផ្សេងដោយ..." ត្រូវប្រែមុន ជាតតិយាតប្បុរិសសមាស ។

២. ប្រែថា "........ជាប្រភេទ" ត្រូវប្រែក្រោយ ជាឆដ្ឋីតុល្យាធិករណ-ពហុព្វីហិសមាស ដូចមានឧទាហរណ៍ខាងក្រោមនេះ

### ១. ចីវរជាតិភេទំ (ធាតុំ)

បទនេះជាតតិយាតប្បុរិសសមាស ជាសមាសក្រៅ និងមានទុតិ-យាតប្បុរិសសមាស, ឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ហើយនឹងវិសេសនបុព្វបទកម្មធារយសមាសនៅខាងក្នុង គឺ

ចីវរ + ជាត + អាទិ + ភេទ (+ សិ វិ.)

ទុតិយាតប្បុរិស. វិ. ចីវរាជិ ជាតំ > ចីវរជាតំ ។

ឆដ្ឋីតុល្យាធិករណ. វិ. ចីវរជាតំ អាទិ យស្ស តំ > ចីវរជាតាទិ (ជាតំ)។

វិសេសនបុព្វបទកម្ម. វិ. ចីវរជាតាទិ ជាតំ > ចីវរជាតាទិជាតំ ។

តតិយាតប្បុរិស. វិ. ចីវរជាតាទិជាតេន ភេទំ > ចីវរជាតាទិភេទំ (ជាតំ) = (ការឱ្យ) ផ្សេងដោយការឱ្យមានការឱ្យនូវចីវរជាដើម ។

២. សលាកភត្តជាតាទិភេទំ (ជាតំ)

*បទនេះជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ជាសមាសក្រៅមានទុតិយាតប្បុរិសសមាស, ឆដ្ឋីតុល្យាធិករណពហុព្វីហិសមាសហើយនឹងវិសេសនបុព្វបទកម្មធារយសមាសនៅខាងក្នុង គឺ*

សលាកភត្ត + ជាត + អាទិ + ភេទ (+ សិ វិ.)

ទុតិយាតប្បុរិស. វិ. សលាកភត្តំ ជាតំ > សលាកភត្តជាតំ ។

ឆដ្ឋីតុល្យាធិករណ. វិ. សលាកភត្តជាតំ អាទិ យស្ស តំ > សលាកភត្តជាតាទិ (ជាតំ) ។

វិសេសនបុព្វបទកម្ម. វិ. សលាកភត្តជាតាទិ ជាតំ > សលាកភត្តជាតាទិជាតំ ។

ឆដ្ឋីតុល្យាធិករណ. វិ. សលាកភត្តជាតាទិជាតំ ភេទំ យស្ស តំ > សលាកភត្តជាតាទិភេទំ (ជាតំ) =(*ការឱ្យ*) *មានការឱ្យនូវសលាក-*

កត្តុជាដើមជាប្រភេទ ។

## បមាណ, មត្ត ស័ព្ទក្នុងសមាស

បើមាន **បមាណ** ឬ **មត្ត** ស័ព្ទដែលប្រែថា "ប្រមាណ" ជាប់នៅខាងចុងបទណា សមាសនោះ ៗ ច្រើនជាឆដ្ឋីតុល្យាធិករណពហុព្វីហិ-សមាសជានិច្ច ដូចជា

### ១. កាយាលសិយប្បមាណោ (បុគ្គលោ)

នេះជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ជាសមាសក្រៅ មានតតិយាតប្បុរិសសមាសនៅខាងក្នុងគឺ

តតិយាតប្បុរិស. វិ. **កាយេន អាលសិយំ** > **កាយាលសិយំ** = សេចក្តីខ្ជិលដោយកាយ ។

ឆដ្ឋីតុល្យ. វិ. **កាយាលសិយំ បមាណំ យស្ស សោ** > **កាយា-លសិយប្បមាណោ** (បុគ្គលោ) =(បុគ្គល) មានសេចក្តីខ្ជិលដោយកាយជាប្រមាណ ។

### ២. តិការុតប្បមាណោ (រុក្ខោ)

នេះក៏ជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ជាសមាសក្រៅ មានសមាហារទិគុសមាសនៅខាងក្នុងគឺ

សមាហារទិគុ. វិ. **តិណ្ណំ គាវុតានំ** > **តិគាវុតំ** =*បីគាវុត ។*

ឆដ្ឋីតុល្យាធិករណ. វិ. **តិគាវុតំ បមាណំ យស្ស សោ** > **តិគាវុតប្បមាណោ** (**រុក្ខោ**) =*(ដើមឈើ) មានប្រមាណបីគាវុត ។*

## សង្កេត

*ការបំប្រួញរវាងបទ* **អាទិ** *ជាមួយនឹង* **ហត្ថ** *ក្តី, ឬរវាង* **អាទិ** *ជាមួយ* **ភេទ** *ក្តី, ច្រើនជាមជ្ឈេលោបសមាស គឺបទដែលថែមចូលមក តែងលុបចេញ ទើបមិនប្រាកដរូបស័ព្ទនៅក្នុងបទសមាស ។ ប៉ុន្តែដល់វេលាប្រែត្រូវថែមចូលមក ។* **បមាណ** *ស័ព្ទក្នុងសមាសខ្លះក៏លុបបាត់ទៅដែរដូចជាបទថា*

**បញ្ចសតភិក្ខុបរិវារោ** (**សត្ថា**) =*(ព្រះសាស្តា) មានភិក្ខុមានរយប្រាំជាប្រមាណជាបរិវារ ។*

*ដូចឃើញហើយនៅក្នុងសមាសមិនមាន* **បមាណ** *ស័ព្ទដូចពាក្យប្រែផងទេ គឺត្រូវលុបចេញបាត់ទៅ ។ សូមសង្កេតមើលពាក្យប្រែមានពាក្យថា "មានភិក្ខុ" ប្រែឡើងមុន ព្រោះជាឆដ្ឋីតុល្យាធិករណពហុព្វីហិសមាសជាសមាសក្រៅ និងមានសមាហារទិគុសមាស, ឆដ្ឋីតុល្យាធិករណពហុព្វីហិសមាស ហើយនឹងវិសេសនបុព្វបទកម្មធារយសមាសនៅខាងក្នុង ពីព្រោះឃើញពាក្យប្រែថា "មាន...មាន..." ដល់ទៅពីរដង*

*ទើបជាឆដ្ឋីតុល្យាធិករណៈទាំងពីរដូចមានវិធីតាំងវិគ្គហៈត្រួតគ្នា ដូច្នេះ*

សមាហារទិគុ. វិ. **បញ្ច សតានិ** > **បញ្ចសតំ** ។

ឆដ្ឋីតុល្យធិករណ. វិ. **បញ្ចសតំ បមាណំ យេសំ តេ** > **បញ្ចសតប្បមាណា** (**ភិក្ខូ**) ។

វិសេសនបុព្វបទកម្ម. វិ. **បញ្ចសតប្បមាណា ភិក្ខូ** > **បញ្ចសតភិក្ខូ** (*លុប* **បមាណា** *ចេញ*) ។

ឆដ្ឋីតុល្យធិករណ. វិ. **បញ្ចសតភិក្ខូ បរិវារា យស្ស សោ** > **បញ្ចសតភិក្ខុបរិវារោ** (**សត្ថា**) ។

*ស័ព្ទដទៃទៀតគប្បីជ្រាបតាមន័យនេះ ។ អ្នកសិក្សាត្រូវព្យាយាមហ្វឹកហាត់មើលបទសមាសធម្មតា ៗ ប្រភេទនីមួយ ៗ ដែលពោលហើយពីខាងដើមឱ្យដឹងថាសមាសនោះ ៗ មានឈ្មោះអ្វី និងត្រូវតាំងវិគ្គហៈយ៉ាងណា ព្រមទាំងមើលបទសន្ធិនិងបទតទ្ធិតទៀតផង ទើបអាចប្រែបទមិស្សកសមាសឬសមាសមានផ្ទៃ ដូចដែលពោលរួចហើយនេះបានល្អត្រឹមត្រូវ ។ ពីព្រោះសមាសខ្លះក៏មានស័ព្ទតទ្ធិតនៅខាងក្នុងដែលត្រូវប្រាប់វិគ្គហៈរបស់តទ្ធិតផងដែរ ដូចជា*

**អជវីរិយោ** (**អយំ ជនោ**) =(*ជន នេះ*) *មិនមែនជាអ្នកមានសេចក្ដីព្យាយាម ។*

*សមាសនេះមាន ១-បុព្វបទកម្មធារយសមាសជាសមាសក្រៅ និងមានភាវតទ្ធិត និង ១-បុព្វបទពហុព្វីហិសមាសនៅខាងក្នុង ដូច្នេះ*

តាវតទ្ធិត (**ណិយ** បច្ច័យ) វិ. **វិរស្ស ភាវោ** > **វីរិយំ** =ការប្រព្រឹត្តទៅរបស់អ្នកក្លា ។

ឧ-បុព្វបទពហុព្វីហិ. វិ. **ឧត្ថិ តស្ស វីរិយន្តិ** > **អវីរិយោ** (**ជនោ**) ។

ឧ-បុព្វបទកម្មធារយ. វិ. **ឧ អវីរិយោ** > **អឧវីរិយោ** (**អយំ ជនោ**) ។

តាមឧទាហរណ៍ដែលបានអធិប្បាយមកប៉ុណ្ណេះ គង់នឹងធ្វើឱ្យអ្នកសិក្សាយល់ចូលចិត្តរឿងសមាសបាលីបានល្អហើយ ។ ប្រសិនបើនៅពុំទាន់យល់ល្អទេ សូមអានសាឡើងវិញជាថ្មីថែមទៀត ដើម្បីឱ្យយល់ចូលចិត្តច្បាស់លាស់ ទើបអាចប្រែភាសាបាលីក្នុងគម្ពីរផ្សេង ៗ មានគម្ពីរធម្មបទដ្ឋកថាជាដើមបាន ជាពិសេសកាលបើរៀនចប់សមាសដែលជាវិជ្ជាចុងក្រោយបំផុតក្នុងសៀវភៅនេះ គឺល្មមឡើងប្រែធម្មបទហើយ ។ អ្នកសិក្សានឹងជួបជាមួយបទសន្ធិ បទតទ្ធិត និងបទសមាសពាសពេញទាំងអស់ ។ ប្រសិនបើយើងតាំងវិគ្គហៈរបស់សមាសមិនត្រូវទេ នោះនឹងប្រែមិនបានល្អ ធ្វើឱ្យស្ទះជាប់ស័ព្ទ ។ ដូច្នេះ ទើបអ្នកសិក្សាខ្វះត្រូវសរសេរពាក្យប្រែនិងទន្ទេញឱ្យចាំទុក ព្រោះខ្វះមូលដ្ឋានខាងវេយ្យាករណ៍ហ្នឹងឯង ។ សូមអ្នកសិក្សាត្រូវដឹងនូវចំណុចសំខាន់នៃការរៀនភាសាបាលីគឺបិតនៅត្រង់ **អាខ្យាត**, **កិតក**, **សន្ធិ**, **តទ្ធិត** និង **សមាស** ។

ប្រសិនបើសិក្សារួចហើយ តែនៅមិនទាន់យល់ចូលចិត្តបានល្អទេ អ្នកសិក្សាគួរត្រឡប់ទៅរកសិក្សាសាឡើងវិញត្រង់ចំណុចណាដែលនៅមិនទាន់ចេះចាំច្បាស់លាស់នៅឡើយ ។

*ដើម្បីអះអាងឱ្យឃើញថាសមល្មមផ្តើមប្រែធម្មបទបានហើយ និង ដើម្បីឱ្យដឹងថា នឹងជួបស័ព្ទដែលសម្រេចចរូបមកពី* **អាខ្យាត, កិតក, សន្ធិ, តទ្ធិត** *និង* **សមាស** *សូមលើកយកគាថាទី ១ នៃព្រះគាថាធម្មបទមកសាកល្បងប្រែដែលមានជាគាថាដូច្នេះថា*

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទន្តិ ។**
**អយំ ធម្មទេសនា កត្ថ ភាសិតាតិ ។**

*សូមសង្កេតមើលថាតើមានបទណាខ្លះដែលជា នាមនាម, គុណនាម និងបទណាខ្លះជា អាខ្យាត, កិតកៈ, សន្ធិ, តទ្ធិត និង សមាស ។ ពីព្រោះក្នុងគាថានេះមានគ្រប់វិជ្ជាដែលបានបរិយាយតាំងពីមេរៀនទី ១ រហូតដល់មេរៀនទី ៥០ នេះរួចហើយ ។ នៅក្នុងទីនេះនឹងចង្អុលបង្ហាញឱ្យឃើញត្រឹមតែមួយបទប៉ុណ្ណោះ ឱ្យដឹងថាតើសម្រេចរូបមកពីអ្វី នោះគឺបទថា* **មនោបុព្វង្គមា** (**ធម្មា**) *។ មុនអ្វី ៗ ទាំងអស់សាកល្បងញែកស័ព្ទចេញពីគ្នាសិនជា* **មនោ** + **បុព្វ** (+ ំ *អា.*) + **គមា** *ហើយប្រែមើលមួយស័ព្ទ ៗ ទៅដូច្នេះ* **មនោ** =*ចិត្ត,* **បុព្វ** =*មុន, ដើម,* **គម** =*ដល់ ។*

*រួមសេចក្តីទៅថា "ចិត្តដល់មុន" នៅស្តាប់ន័យមិនទាន់បានថាអ្វីជាអ្វីនៅឡើយ ។ បន្ទាប់មកថែមអញ្ញបទគឺ* **ធម្មា** *ចូលមកហើយប្រែឱ្យត្រូវ*

តាមរូបវិគ្គហៈនៃបទសមាស **មនោបុព្វង្គមា** (**ធម្មា**) =(ធម៌ទាំងឡាយ) មានចិត្តជាសភាវៈដល់មុន ។ ពាក្យថា "ជាសភាវៈ" ជាពាក្យសម្រាប់ជួយប្រែបទវិកតិកត្តាដូចដែលបានសិក្សារួចហើយក្នុងមេរៀនទី ១០ ។

កាលបើប្រែបានសេចក្ដីដោយផ្ដើមពាក្យថា "មាន........" ដូច្នេះ គឺបញ្ជាក់ឱ្យឃើញថាសម្រេចមកពីឆដ្ឋីតុល្យាធិករណពហុព្វីហិសមាសជាសមាសក្រៅ មានវិសេសនបុព្វបទកម្មធារយសមាស នៅខាងក្នុងគឺ

**វិសេសនបុព្វបទកម្ម.** *វិ.* **បុព្វោ គមោ** > **បុព្វង្គមោ** =កិរិយាដល់មុន ឈ្មោះថា **បុព្វង្គមោ**, **បុព្វង្គមោ** =រីកិរិយាដល់មុន (តាមវិធីសំយោគសន្ធិត្រូវតម្រួត **ង** ព្រោះ **គ** នៅខាងចុងទៅជា **បុព្វង្គម**) ។

**ឆដ្ឋីតុល្យាធិករណ.** *វិ.* **មនោ បុព្វង្គមោ យេសំ តេ** > **មនោបុព្វង្គមា** (**ធម្មា**) ប្រែដូច្នេះ **មនោ** រីចិត្ត **បុព្វង្គមោ** ជាសភាវៈដល់មុន **យេសំ ធម្មានំ** នៃធម៌ទាំងឡាយនោះ ឯណា **តេ ធម្មា** រីធម៌ទាំងឡាយ នោះ **មនោបុព្វង្គមា** ឈ្មោះថា **មនោបុព្វង្គមា**, **មនោបុព្វង្គមា** (អានផ្លូន) **ធម្មា** រីធម៌ទាំងឡាយ **មនោបុព្វង្គមា** មានចិត្តជាសភាវៈដល់មុន, តែនិយមប្រែថា "មានចិត្តជាប្រធាន" ។

បទក្រៅពីនេះសម្រេចមកពីអ្វីខ្លះ សូមស្វែងយល់ចូលចិត្តដោយខ្លួនឯងផងចុះ ។

(**សមាសវិធីចប់ត្រឹមនេះ**)

(**ចប់មេរៀនទី ៩០**)

## សេចក្ដីបញ្ជាក់

*នៅក្នុងភាគ ១ ត្រង់មេរៀនទី ២ បានប្រាប់ថានឹងអធិប្បាយអំពីវិធីប្រើ និងប្រែនាមនាមដែលបំបែកហើយឲ្យពិស្ដារ ។ ប៉ុន្តែក្នុងទីនេះមិនបាន អធិប្បាយជូនសិក្សាទេ ពីព្រោះសៀវភៅមានកម្រាស់ក្រាស់ល្មមហើយ ប្រសិនបើនាំមកជូនទៀត សៀវភៅនេះនឹងក្រាស់ហួស ។ អាស្រ័យហេតុនេះសូមមេត្តាអភ័យទោសផង ។ ដើម្បីឲ្យបានជ្រាបរឿងប្រើនេះសូមរកមើលក្នុងសៀវភៅសម្ពន្ធមាលា ។*

**សៀវភៅ**

**"រៀនភាសាបាលីបែបទំនើប"**

**ចប់បរិបូណ៌**

# កំណាព្យដាស់តឿនស្មារតី

ចូរតស៊ូ ក្នុងហេតុការណ៍ ដែលប្រសព្វ
ទោះជាជួប រឿងអាក្រក់ ច្រើនយ៉ាងណា
មានះស៊ូ ដោយចិត្តរឹង និងរីករាយ
មិនញញ័រញញាប់ គង់ប្រសព្វ ជ័យជោគអឺយ ។

**ទីឃោ ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលានសង្សារោ សទ្ធម្មំ អវិជានតំ ។**

*យប់យូរនៃអ្នកមិនលក់ឯង យោជន៍យូរឆ្ងាយវែងនៃអ្នកចរ*
*សង្សារយូរឆ្ងាយនៃអ្នកនិករ ពាលពុំចេះធម៌ទៅនិព្វាន ។*
*អ្នកដេកចង់ក្រោកថាយប់យូរ អ្នកដើរគិតគួរថាយោជន៍ឆ្ងាយ*
*ពាលាពុំចេះធម៌ទាំងឡាយ សង្សារវែងឆ្ងាយពីនិព្វាន ។*

*ដកស្រង់ពីសៀវភៅ* **គតិលោក** *ភាគ៧ ទំព័រ២៦*

# វាក្យានុក្រម

## អក្សរសង្ខេប

ឥ. ឥត្ថីលិង្គ

កិ.វិ. កិរិយាវិសេសន៍

គុ. គុណនាម

នបុំ. នបុំសកលិង្គ

និ. និបាត

បុំ. បុំលិង្គ

សព្វ. សព្វនាម

| | |
|---|---|
| អការណា | នបុំ. កិរិយាមិនធ្វើ |
| អកិញ្ចន | គុ. មិនមានកិលេស |
| អក្កោសក | បុំ. អ្នកជេរ |
| អក្ខរ | នបុំ. អក្សរ |
| អគ្គសាវក | បុំ. អគ្គសាវ័ក |
| អង្គណ | នបុំ. ទីធ្លា, ទីលាន |
| អច្ចិ | ឥ. អណ្តាតភ្លើង |
| អជ | បុំ. ពពែឈ្មោល |
| អជា | ឥ. ពពែញី |

អជាតសត្តុ បុំ. (ឈ្មោះ)

អជេយ្យ គុ. មិនអាចឈ្នះ

អញ្ជលីករណីយ គុ. ដែលគួរនូវអញ្ជលីកម្ម

អដ្ឋក បុំ. ដែនអដ្ឋកៈ

អដ្ឋកនាគរ បុំ. អ្នកនគរអដ្ឋកៈ

អតិទេវ បុំ. ទេវតាជាប្រមុខ

អតិទេវបុត្ត បុំ. បុត្រនៃទេវតាជាប្រមុខ

អតេកិច្ឆ គុ. កែខៃមិនបាន

អត្តភាវ បុំ. ភាពនៃខ្លួន, អត្តភាព

អត្តមន គុ. មានចិត្តជារបស់ខ្លួន

អត្តវិបត្តិ ឥ. សេចក្តីវិនាសនៃខ្លួន

អត្តសម្បត្តិ ឥ. សម្បត្តិនៃខ្លួន

អត្ថ បុំ. ប្រយោជន៍

អត្ថញ្ញូ គុ. អ្នកដឹងនូវប្រយោជន៍

អថ និ. គ្រានោះ, កាលនោះ, តមក

អថ និ. បើ,បើជា (ជំនួស សចេ )

អថវា និ. ឬ, មួយវិញទៀត, ម្យ៉ាងទៀតថា

អថេកាជីវសំ អព្យ. ចុងផុតនៃថ្ងៃ

អថោ និ. មួយវិញទៀត

អទស្សន នបុំ. កិរិយាមិនឃើញ

អទិន្នាទាន នបុំ. ការកាន់យកនូវវត្ថុគេមិនបានឱ្យ

អទុក្ខមសុខ គុ. ដែលមិនជាទុក្ខមិនជាសុខ

អទ្ធា និ. ដោយពិត, ប្រាកដ

អធោ និ. ខាងក្រោម

អនញ្ញាថាសី បុំ. អ្នកមិនចិញ្ចឹមអ្នកដទៃ

អនត្តមន គុ. អ្នកមានចិត្តមិនជារបស់ខ្លួន

អនន្តលិក្ខចរ គុ. ជាអ្នកត្រាច់ទៅក្នុងអាកាស

អនាគាមី គុ. ជាអ្នកនឹងមិនមកជាប្រក្រតី

អនាគារិយ នបុំ. អ្នកគ្មានផ្ទះ, អ្នកបួស

អនិច្ចសញ្ញា ឥ. សេចក្តីសម្គាល់ថាមិនទៀង

អនុក្កម បុំ. លំដាប់, អនុក្រម

អនុគាមិក គុ. អ្នកទៅតាម

អនុត្តរ គុ. មិនមានបុគ្គលក្រៃលែងជាង

អនុធម្មចារី បុំ. អ្នកមានកិរិយាប្រព្រឹត្តតាមធម៌ជាប្រក្រតី

អនុបុព្វ គុ. លំដាប់, តមក

អន្តរសន្ធិ ឥ. ចន្លោះនៃភ្លៅ

អន្តរា និ. ចន្លោះ, រវាង

អន្តេវាសិក បុំ. សិស្ស

អន្តោ និ. ខាងក្នុង

អន្តោទេវតា ឥ.ទេវតាខាងក្នុង

អន្តោនិវេសនដ្ឋាន បុំ. ខាងក្នុងនៃនិវេសន៍

អបរភាគ បុំ. ចំណែកដទៃទៀត

អបាយ បុំ. នរក, អបាយ

អបិ, បិ និ. ដែរ, ខ្លះ, ក៏បាន, ក៏មាន, ក៏ដោយ, ក្រែង, ថ្វីបើ, ជួនជា

អបិច និ. អើក៏, មួយវិញទៀត, ពុំនោះសោត

អប្បមត្ត គុ. ដែលមិនប្រមាទហើយ

អប្បេវ នាម និ. កាលបើ, ដូចម្តេចហ្ន៎

អភិជ្ឈាលុ គុ. លោភ

អភិទោសិកា បុំ. យប់នៃថ្ងៃម្សិល

អភិធម្ម បុំ. ធម៌ដ៏ក្រៃលែង, អភិធម្ម

អភិរូប គុ. មានរូបស្អាត, មានរូបល្អ

អម្ពុ នបុំ. ទឹក

អម្មោ និ. អ្នកដ៏ចំរើន

អយ បុំ., នបុំ. ដែក

អរហត្តគ្គហណ នបុំ. កិរិយាកាន់យកនូវព្រះអរហត្ត

អរិយមគ្គញាណគ្គិ បុំ. ភ្លើងគឺអរិយមគ្គញាណ

អរិយសាវកា បុំ. អរិយសាវ័ក

អរូបាវចរ គុ. ដែលត្រាច់ទៅក្នុងអរូបភព
អរោគ គុ. មិនមានរោគ
អលំ និ. កុំ, កុំឡើយ, ល្មមហើយ, ណ្ហើយ
អវស្សំ និ. ដោយពិត, មែន
អវិទូរ គុ. ជិត, ក្បែរ
អសទ្ធម្ម បុំ. ធម៌នៃអសប្បុរស
អសមាហិត គុ. មិនជាអ្នកមានចិត្តដំកល់មាំ
អសិធារា ឥ. មុខនៃដាវ
អស្ស បុំ. សេះឈ្មោល
អស្សា ឥ. សេះញី
អស្សុ នបុំ. ទឹកភ្នែក
អហេ និ. ហឺយ, រឺយ
អហោ និ. ក្រៃពេក, ឱ
អាគមន នបុំ. ការមកដល់
អាចរិនី ឥ. គ្រូស្រី
អាចរិយ បុំ. គ្រូប្រុស
អាទុ និ. ឬថា, ឬក៏
អាបាយិក គុ. អ្នកកើតក្នុងអបាយ
អាពាធ បុំ. ឈឺ, អាពាធ

អាភរណា នបុំ. គ្រឿងប្រដាប់
អាម, អាមន្ត និ.អើ, ចាស, បាទ, ករុណា, ព្រះករុណា, ករុណាវិសេស
អាយតិ និ. តទៅមុខ, ក្នុងពេលខាងមុខ
អាយតឹ និ. តទៅមុខ, ក្នុងពេលខាងមុខ
អារញ្ញិក បុំ. អ្នកនៅព្រៃ
អារា និ. ឆ្ងាយ, ពីចម្ងាយ
អារោគ្យ នបុំ. ភាវៈនៃអ្នកគ្មានរោគ
អាវសថាគារ នបុំ. រោងសំណាក់
អាវិ និ. ច្បាស់, ប្រាកដ, ជាក់
អាវុសោ និ. ម្នាលលោកដ៏មានអាយុ
អាហុនេយ្យ គុ. ដែលគួរសក្ការបូជា
អាឡ្ហក បុំ. មាត្រាវង្វាស់មួយប្រភេទ (មួយអាឡ្ហកស្មើនឹង ៤ នាឡិ) ។
ឥជ្ឈ និ. ដូចជាតឿន, ហ៎, ហ៎ចុះ, ចុះ, អញ្ជើញ
ឥតិ និ. ព្រោះហេតុនោះ, ដូចនេះថា
ឥត្ថន្នាម គុ.មានឈ្មោះយ៉ាងនេះ
ឥវ និ. ដូច, ដូចជា, ប្រដូច
ឥសិបតន នបុំ. (ឈ្មោះ)
ឧច្ចំ និ. ខ្ពស់
ឧត្តាន គុ. ផ្ងារ, រាក់, រីករាយ

ឧទយ បុំ.ការរះ, ការកើត

ឧទាហុ និ. ឬថា, ឬក៏

ឧទ្ធំ និ. ខាងលើ

ឧទ្ធច្ច គុ. មានមានះ

ឧបនគរ នបុំ. ទីជិតក្រុង, ទីជិតនគរ

ឧបរិ និ. ខាងលើ

ឧបរិបាសាទ បុំ. ខាងលើនៃប្រាសាទ

ឧបរិមតល នបុំ. ផ្ទៃក្នុងខាងលើ

ឧបាយ បុំ. មាយា, ឧបាយ

ឧយ្យានបាល បុំ. អ្នករក្សាសួន

ឧរ បុំ.,នបុំ. ទ្រូង

ឧរុវេលកស្សប បុំ. ព្រះឧរុវេលកស្សបៈ

ឧក្កដ្ឋ បុំ. វែក

ឯកក គុ. ម្នាក់ឯង

ឯកេក គុ. ម្តងមួយ ៗ

ឯត្តាវតា និ. មានប្រមាណប៉ុណ្ណោះ

ឯវ និ. មែន, មែនពិត

ឯវំ និ. យ៉ាងនេះ, យ៉ាងនោះ, ដូច្នោះ

ឯវំ និ. ដោយប្រការនេះ, ដោយប្រការដូច្នេះ

ឱជវន្តុ គុ. មានឱជា, មានរស

ឱរំ និ. ត្រើយអាយ, ខាងអាយ

កុមារ បុំ. ក្មេងប្រុស

គោជិតាម បុំ. ស្រុកទីបំផុត

កុមារី ឥ. ក្មេងស្រី

កុម្ភការ បុំ. ស្មូនផ្ទាំងប្រុស

កុម្ភការិនី ឥ. ស្មូនផ្ទាំងស្រី

ខត្តិយ បុំ. ក្សត្រប្រុស

ខត្តិយានី ឥ. ក្សត្រស្រី

ខិប្បំ និ. យ៉ាងរហ័ស, ប្រញាប់

កិរ និ. បានឮថា, ឮថា, មានសេចក្ដីដំណាលថា

ខលុ និ. បានឮថា, ឮថា, មានសេចក្ដីដំណាលថា

កឹ និ. ឬ, អ្វី, ហេតុអ្វី, ដូចម្ដេច

កថំ និ. យ៉ាងណា, ដូចម្ដេច

កច្ចិ និ. ឬ, ដែរឬ, ខ្វះដែរ

ខោ និ. ឯង

ក្វចិ និ. ខ្វះ

កិញ្ចាបិ និ. ប្រាកដហើយ, សូម្បីតិចតួច

កីវ និ. ប៉ុន្មាន, ប៉ុនណា

**កិត្តាវតា** និ. មានប្រមាណប៉ុន្មាន

**កថំ** និ. ដោយប្រការដូចម្តេច

**កិច្ច** នបុំ. ការងារ, កិច្ច

**គន្តុកាម** បុំ. អ្នកប្រាថ្នាដើម្បីទៅ

**កាមភោគី** បុំ. អ្នកបរិភោគកាម

**កាមភោគិសេយ្យា** ឥ. ដំណេកនៃអ្នកបរិភោគកាម

**កតម** វិ.ស. ដូចម្តេច, អ្វីខ្លះ

**កាសីគាមក** គុ. អ្នកស្រុកកាសី

**កុម្ភការកុល** នបុំ. ត្រកូលស្មូនឆ្នាំង

**កុម្ភការកម្ម** នបុំ. កិច្ចការស្មូនឆ្នាំង

**កិលញ្ជ** បុំ. កន្ទេល

**កច្ឆប** បុំ. អណ្តើក

**កតិ** និ. ប៉ុន្មាន, ចំនួនប៉ុន្មាន

**កថន** នបុំ. ការពោល

**កនក** នបុំ. មាស

**កនកវិមាន** នបុំ. វិមានធ្វើពីមាស

**កប្ប** បុំ. កាលដែលតាំងនៅយូរអង្វែង

**កប្បដ្ឋ** បុំ. ដែលតាំងនៅអស់កប្ប

**កម្ពលកញ្ចុក** បុំ. អាវក្រៅឬក្រោះធ្វើពីសំពត់កម្ពល

កម្មសន្និចយ បុំ. *ការសន្សំនូវកម្ម*

កាមាវចរ គុ. *ដែលត្រាច់ទៅក្នុង៍កាមភព*

កាយិក គុ. *ប្រព្រឹត្តទៅក្នុង៍កាយ*

កាយិកមានសិក គុ. *ប្រព្រឹត្តទៅក្នុង៍កាយនិង៍ចិត្ត*

កាលប្បវេឆនា ឥ. *ការសំដែង៍នូវកាល*

កាសាវ នបុំ. *សំពត់ជ្រលក់ទឹកអំបត់*

កិកី បុំ. *សត្វត្រដេវវិច*

កុដិកណ្ណា គុ. *មានត្រចៀកយារ*

កុណ្ឌិកា ឥ. *ចូទឹក, កណ្ឌី*

កុម្មាស បុំ. *នំកុម្មាស*

កុម្ភឃោសក បុំ. *(ឈ្មោះ)*

កុររឃរនគរ បុំ. *(ឈ្មោះនគរ)*

កុសលាកុសលកម្ម នបុំ. *កម្មជាកុសលនិង៍អកុសល*

កុសលស្សូបសម្បទា ឥ. *ការញុាំង៍កុសលឲ្យដល់ព្រម*

កុហក បុំ. *អ្នកកុហក*

កូដាគារ នបុំ. *រោង៍ប្រកបដោយកំពូល(មានដំបូល)*

កូដាគារសាលា ឥ. *សាលាជាផ្ទះមានកំពូល*

កោមារភច្ច បុំ. *(ឈ្មោះ)*

កោសិជារក បុំ. *អ្នករស់នៅក្រុង៍កុសិនារា*

ខណា បុំ. *ខណៈ*

ខយធម្ម គុ. *ដែលមានការអស់ទៅជាធម្មតា*

ខយវយ បុំ. *កិរិយាអស់ទៅនិងកិរិយាសូន្យទៅ*

គណាយ គុ. *កាលរាប់*

គតិ ឥ. *កិរិយាទៅ, គតិ*

គន្ថធុរ នបុំ. *ធុរៈគឺការរៀនគម្ពីរ, គន្ថធុរៈ*

គន្ធមាលាធិហត្ថ គុ. *មានគ្រឿងសក្ការៈគឺកម្រងផ្កាជាដើមក្នុងដៃ*

គហបតានី ឥ. *គហបតីស្រី*

គហបតិ បុំ. *គហបតីប្រុស*

គាមនិគម បុំ. *ស្រុកនិងនិគម*

គុណវតី ឥ. *ស្រីអ្នកមានគុណ*

គុណវា បុំ. *ប្រុសអ្នកមានគុណ*

គុណាតិរេកសម្បទា ឥ. *ការដល់ព្រមដោយគុណក្រៃលែង*

គេលញ្ញ នបុំ. *ជំងឺ*

គេលញ្ញជាតិបីឡិត គុ. *បៀតបៀបក្រៃលែងដោយរោគ*

គោតមី ឥ. *ស្រីនៃពូជពង្សគោតម*

គោប បុំ. *អ្នករក្សានូវគោ*

ច និ. *ផង, ក៏, មែនពិត, មួយទៀត*

ចក្កយុគ នបុំ. *គូនៃកង់*

| | |
|---|---|
| ចក្កវត្តិ | *បុំ. ស្ដេចចក្រពត្តិ* |
| ចតុព្វិធ | *គុ. មាន ៤ យ៉ាង* |
| ចរបុរិស | *បុំ. អ្នកស៊ើប* |
| ចាមរី | *បុំ. គោរោមវែង ៗ* |
| ចេ | *និ. បើ* |
| ចេត | *បុំ., នបុំ. ចិត្ត* |
| ចេតសាសម្បជា | *ឥ. ការដល់ព្រមគឺចេតនា* |
| ចេតិយង្គណ | *នបុំ. ឃឿនចេតីយ៍* |
| ចោរភយ | *នបុំ. ភ័យអំពីចោរ* |
| ឆឡេត្តុកាម | *បុំ. ប្រាថ្នាដើម្បីបោះចោល* |
| ឆន្ទ | *បុំ. សេចក្ដីប្រាថ្នា* |
| ឆវ | *បុំ. សព, ខ្មោច* |
| ជម្ពុទីប | *បុំ. ជម្ពូទ្វីប, ឥណ្ឌា* |
| ជណ្ណុ | *នបុំ. ជង្គង់* |
| ជាណុ | *នបុំ. ជង្គង់* |
| ជាឥតា | *ឥ. ប្រជុំនៃជន* |
| ជាលិក | *បុំ. អ្នកបង់សំណាញ់* |
| ជីវក | *បុំ. (ឈ្មោះ)* |
| ជីវិកា | *ឥ. អ្នករស់នៅ* |

ជេ និ. នៃមេ, នៃហង

ឈាន នបុំ. ការសម្ងឹងនូវអារម្មណ៍, ឈាន

ញាតក បុំ. ប្រុសជាញាតិ

ញាតិកា ឥ. ស្រីជាញាតិ

ញាតិទាសី ឥ. នាងបំរើជាញាតិ

ឋាន នបុំ. ទីតាំង,ទីឋាន

តក្ការ គុ. ជាអ្នកធ្វើនូវ...

តត្ថ និ. ហ៎, ហ៎ចុះ, ចុះ

តណ្ហាង្ករោ បុំ. ព្រះពុទ្ធព្រះនាមតណ្ហាង្ករៈ

តថា និ. ដូច្នោះ, យ៉ាងនោះ, ដោយប្រការដូច្នោះ

តថាគតសេយ្យា ឥ. ដំណេកនៃតថាគត

តទា និ. ក្នុងកាលនោះ

តប បុំ. ការដុតកិលេស

តបស្សី បុំ. អ្នកមានតបៈ

តម បុំ., នបុំ. ភាពងងឹត

តាវ និ. ដរាបនោះ, ត្រឹមនោះ

តាវតា និ. មានប្រមាណប៉ុណ្ណោះ

តាវតឹស បុំ. ឋានតាវតិង្ស

តាវតឹសទេវលោក បុំ. ទេវលោកឈ្មោះតាវតិង្ស

តាវទេវ និ. កំណត់ត្រឹមនោះ

តិរោ និ. ខាងក្រៅ

តុ និ. ក៏, ប៉ុន្តែ, ចំណែកឯ, មួយវិញទៀត

តុលា ឥ. ជ្ញីម, ជញ្ជីញ

តេជ បុំ. ភ្លើង, តេជៈ

តេនហិ និ. ហ៎, បើដូច្នោះ, អញ្ចើញ, ព្រោះហេតុនោះ

តេបិដក នបុំ. ព្រះត្រៃបិដក

តេលិក បុំ. អ្នកលក់ប្រេង

ថទ្ធ គុ. រឹងប៉ឹង, រឹងរូស

ថាម បុំ. កម្លាំង

ថុតិ ឥ. សេចក្ដីសរសើរ

ថោក គុ. តិចតួច, បន្តិចបន្តួច

ទក្ខិណេយ្យ គុ. ដែលគួរនូវទក្ខិណាទាន

ទណ្ឌលិក បុំ. អ្នកលក់អង្ករ

ទយាលុ គុ. មានករុណាច្រើន

ទានកាល បុំ. កាលជាទីឱ្យ

ទាយក បុំ. អ្នកឱ្យ

ទារក បុំ. ក្មេងប្រុស

ទារិកា ឥ. ក្មេងស្រី

ទារុអាទិ គុ. មានឈើជាដើម

ទារុមយាទិ គុ. ធ្វើអំពីឈើជាដើម

ទាលិទ្ទិយ នបុំ. ភាវៈនៃអ្នកទ័លក្រ

ទាស បុំ. ខ្ញុំបំរើប្រុស

ទាសី ឥ. ខ្ញុំបំរើស្រី

ទាឡិទ្ទិយ នបុំ. ភាពក្រីក្រ

ទិនករ បុំ. ព្រះអាទិត្យ

ទិន្នភេសជ្ជ នបុំ. ថ្នាំដែល...ឱ្យហើយ

ទិន្នាហារ បុំ. អាហារគឺ...ឱ្យហើយ

ទិវា និ. ថ្ងៃ, ក្នុងវេលាថ្ងៃ

ទិសាចាមោក្ខ គុ. ប្រមុខក្នុងទិស.ទ.

ទីឃ គុ.,បុំ. វែង, យូរ

ទីបង្ករោ បុំ. ព្រះពុទ្ធព្រះនាមទីបង្ករៈ

ទីបិ បុំ. ខ្លាដំបង(ឈ្មោល)

ទុជ្ជន បុំ. មនុស្សអាក្រក់

ទុគ្គម គុ. ដែលទូន្មានដោយលំបាក

ទុរនុពោធ គុ. ដឹងដោយកម្រ

ទុរន្នយ គុ. ដែលដឹងបានដោយលំបាក

ទុល្លភ គុ. ដោយលំបាក

ទុស្សីល គុ. ទ្រុស្តសីល

ទូរ គុ. ឆ្ងាយ

ទេវ បុំ. ទេវតាប្រុស

ទេវទត្ត បុំ. (ឈ្មោះ), អ.ន. ភិក្ខុទេវទត្ត

ទេវទមិដ្ឋ បុំ. ទេវតាធំជាងទេវតាទាំងឡាយ

ទេវមនុស្ស បុំ. ទេវតានិងមនុស្ស

ទេវលោក បុំ. លោកជាទីនៅនៃទេវតា

ទេវី ឥ. ទេវតាស្រី

ទេហនិស្សិត គុ. អាស្រ័យក្នុងកាយ

ទោវារិក គុ. អ្នកប្រកបក្នុងទ្វារ, អ្នកយាមទ្វារ

ទោស បុំ. សេចក្តីប្រទូស្ត, ទោស

ទ្វាទសនហុត នបុំ. មានម៉ឺន ១២ ជាប្រមាណ

ទ្វារចាលក បុំ. ឆ្មាំទ្វារ

ធម្មញ្ញូ គុ. អ្នកដឹងនូវធម៌

ធម្មធរ បុំ. អ្នកទ្រទ្រង់នូវធម៌

ធម្មស្សវន នបុំ. ការស្តាប់ធម៌

ធម្មស្សវនដ្ឋាន បុំ. ទីជាទីស្តាប់នូវធម៌

ធម្មានុបស្សី បុំ. អ្នកឃើញតាមនូវធម៌ជាប្រក្រតី

ធារណា នបុំ. ការទ្រទ្រង់, ការចេះចាំ

ធុរ នបុំ. ធុរៈ

ន និ. មិន, មិនមែន, ពុំ, ឥត, ខាន

នង្គុដ្ឋ នបុំ. កន្ទុយសត្វ

ននុ និ. មិនមែនឬ, ក្រែង, ...ទេដឹង

នរ បុំ. ប្រុស

នាថ បុំ. អ្នកគ្រប់គ្រង

នានា និ. ផ្សេង ៗ, ទីទៃ ៗ

នានាសត្ថ នបុំ. គម្រាផ្សេង ៗ

នារី ឥ. នារី

នាវិក បុំ. នាវិកប្រុស

នាវិកា ឥ. នាវិកស្រី

និកាយ បុំ. ពួក, ក្រុម, និកាយ

និពទ្ធំ និ. ជានិច្ច

និយ្យានិក គុ. អ្នកដឹកនាំ(ចេញចាកសង្សារ)

និរាហារ គុ. មិនមានអាហារ

និរុបធិ គុ. ដែលមិនមានឧបធិ

និរុបធិក បុំ. អ្នកមិនមានកិលេស

និព្វេធធម្ម គុ. ដែលមានការរលត់ទៅជាធម្មតា

និព្វេធសមាបត្តិវហា គុ. ដែលជាអ្នកគួរដល់នូវនិព្វេធ

និសាការ បុំ. ព្រះច័ន្ទ
និសីទម្ពវេន គុ. អង្គុយហើយក្នុងព្រៃស្ងាយ
នីចំ និ. ទាប
នុ និ. ហ្ន, ហ៎, ហ៎ះ, ហ្ន៎ះ, ហ្ន៎, អេះ, ...ទេដឹង
នូន និ. នៃ, ដោយពិត, មែន
នេបុញ្ញ នបុំ. សេចក្តីប៉ិនប្រសប់
នេរយិក គុ. អ្នកកើតក្នុងនរក
នោ និ. មិន, មិនមែន, ពុំ, ឥត, ខាន
បច្ចយសន្និចយ បុំ. ការសន្សំនូវបច្ច័យ
បច្ចយសម្បទា ឥ. ការដល់ព្រមគឺបច្ច័យ
បច្ចវេក្ខិត គុ. ដែលពិចារណា
បច្ឆា និ. ខាងក្រោយ
បច្ឆាភាគ បុំ. កាលជាចំណែកខាងក្រោយ
បច្ឆិមាភិមុខា គុ. បែរមុខទៅទិសខាងលិច
បញ្ញានុរូប គុ. សមគួរដល់ប្រាជ្ញា
បដិច្ចសមុប្បន្ន គុ. ដែលអាស្រ័យបច្ច័យកើតឡើងហើយ
បដិលេខន នបុំ. សំបុត្រតបវិញ
បដិរាជ បុំ. ស្តេចជាសត្រូវ
បដ្ឋាយ និ. ចាប់ផ្តើម, តាំងពី

បបរោជា ឥ. ឱជានៃផែនដី

បណីតបណីត នបុំ. ប្រណីត ៗ, ឧត្តម ៗ

បណ្ឌិច្ច នបុំ. ភាវៈនៃបណ្ឌិត

បណ្ឌិតសោតុ បុំ. អ្នកស្តាប់ជាបណ្ឌិត

បត្ថនា ឥ. សេចក្តីប្រាថ្នា

បត្ថិត គុ. ដែលតាំងទុកហើយ, ដែលប្រាថ្នាហើយ

បទ នបុំ. សំដី, បទ

បទនិក្ខេប នបុំ. ដានជើង

បទីប បុំ. ចង្កៀង, ប្រទីប

បន និ. ក៏, ចំណែកឯ, ប៉ុន្តែ, ប៉ុន្តែថា

បន្តសេនាសនាភិរត គុ. អ្នករីករាយក្នុងសេនាសនៈដ៏ស្ងាត់

បន្ថក បុំ. អ្នកដើរតាមផ្លូវ

បន្ថឃាតក បុំ. ចោរប្លន់តាមផ្លូវ

បភូតិ និ. ចាប់ដើម, តាំងពី

បមត្ត គុ. ដែលប្រមាទហើយ

បយ បុំ.,នបុំ. ទឹកដោះ

បរម្មុខា និ. កំបាំង, កំបាំងពីមុខ

បរវិបត្តិ ឥ. សេចក្តីវិនាសនៃអ្នកដទៃ

បរសម្បត្តិ ឥ. សម្បត្តិនៃអ្នកដទៃ

បរសុវេ, បរស្វេ និ. ខាងស្អែក, ថ្ងៃខានស្អែក
បរិចារកា ឥ. អ្នកបំរើស្រី
បរិព្វាជក បុំ. បរិព្វាជក
បរិព្វាជិកា ឥ. បរិព្វាជិកា
បរិភាសក បុំ. អ្នកប្រទេច
បរិយាជិន្ន គុ. ដែលគ្របសង្កត់ហើយ
បរិយាជិន្នចិត្ត នបុំ. ចិត្តគ្របសង្កត់ហើយ
បរិសញ្ញូ គុ. អ្នកដឹងនូវការធ្វើខ្លួនជាបរិស័ទ
បរិសបរិយន្ត បុំ. ជាយនៃបរិស័ទ
បរិសា ឥ. បរិស័ទ
បលុទ្ធភាវ បុំ. ភាវជាប់នៅហើយ
បល្វំក, បល្វង្គ បុំ. ក្អែន, បល្ល័ង្ក
បវត្តិ ឥ. ដំណឹង
បស្ស បុំ.,នបុំ. ខាង, ម្ខាង
បស្សតា គុ. កាលឃើញឬមើល
បាកដ គុ. ប្រាកដ, ជាក់ស្តែង
បាដលិគាម បុំ. ស្រុកបាដលិ
បាដលិគាមិក បុំ. អ្នកស្រុកបាដលិ
បាដវ បុំ.,នបុំ. សេចក្តីឆ្លាត, ជំនាញ

ចាណាកា បុំ. សត្វល្អិត, ដង្កូវ

ចាណាតិចាតី បុំ. អ្នកសម្លាប់សត្វ

ចាតលិបុត្តកា បុំ. អ្នកស្រុកបាតលីបុត្រ

ចាតោ និ. ពេលព្រឹក, អំពីព្រឹក

ចាដីយ នបុំ. ទឹកផឹក

ចាបជម្ម បុំ. ធម៌អាក្រក់

ចាបមិត្តតា ឥ. ភាវៈនៃមិត្តអាក្រក់

ចាបិច្ឆតា ឥ. ភាវៈនៃអ្នកប្រាថ្នាដ៏លាមក

ចារំ និ. ត្រើយនាយ, ខាងនាយ

ចាលកា បុំ. អ្នករក្សា

ចាលិលេយ្យកា បុំ. (ឈ្មោះ)

ចាវា ឥ. ស្រុកបាវា

ចាហុនេយ្យ គុ. ដែលគួរដល់ការរាប់រក

បិប្ផលិ, បិប្ផលី ឥ. ដើមជីប្ទី, ដើមល្មៀប

បិប្ផលិគុហា ឥ. គុហាជិតដើមល្មៀប

បិសុណាវាច បុំ. ពាក្យញុះញង់

បីតិសុខ នបុំ. សុខកើតពីបីតិ

បុគ្គលបរោបរញ្ញូ គុ. អ្នកចេះជ្រើសរើសនូវបុគ្គល

បុញ្ញក្ខេត្ត នបុំ. ស្រែបុណ្យ

បុត្តទារ បុំ. បុត្រនិងភរិយា

បុត្តធីតុ ឥ. កូនប្រុសនិងកូនស្រី

បុន និ. ទៀត

បុនប្បុនំ និ. រឿយ ៗ, ញឹកញយ

បុនទិវសេ បុំ. ក្នុងថ្ងៃស្អែក

បុរិន្ទទ បុំ. អ្នកឱ្យហើយក្នុងកាលមុន

បូជនេយ្យ គុ. អ្នកគួរនូវការបូជា

បេតសេយ្យា ឥ. ដំណេកនៃប្រេត

បេម នបុំ. សេចក្ដីស្រឡាញ់

ផរុសវាច បុំ. ពាក្យបៀតបៀន

ផាណិតខណ្ឌ បុំ. ដុំស្ករអំពៅ

ភណេ និ. នៃនាយ

ភណ្ឌាគារិក បុំ. អ្នករក្សាឃ្លាំង

ភទ្ទ, ភទ្រ គុ. ល្អ, ចម្រើន

ភន្តេ, ភទន្តេ និ. បពិត្រព្រះអង្គដ៏ចម្រើន, បពិត្រព្រះអង្គ

ភវ បុំ. សេចក្ដីចម្រើន

ភិត្តិ ឥ. ជញ្ជាំង

ភិយ្យោ និ. ក្រៃលែង

ភិយ្យោសោ និ. ក្រៃលែង

ពលក្ការ បុំ. កិរិយាកំហែង

ពហិ និ. ខាងក្រៅ

ពហិទ្ធា និ. ខាងក្រៅ

ពហិក និ. ខាងក្រៅ

ពាហុសច្ច នបុំ. ភាវៈជាអ្នករៀនច្រើន

ពាឡ្ហតិលាន គុ. ឈឺធ្ងន់, ឈឺខ្លាំង

ពិម្ពិសារ បុំ. ព្រះរាជាពិម្ពិសារ

ពុទ្ធប្បមុខ នបុំ. មានព្រះពុទ្ធជាប្រធាន

ពុទ្ធមាមកា បុំ. អ្នករាប់អាននូវព្រះពុទ្ធ

ពុទ្ធវចន នបុំ. ព្រះពុទ្ធវាចា, ពុទ្ធវចនៈ, ព្រះត្រៃបិដក

ពោធិសត្ត បុំ. ព្រះពោធិសត្វ

ព្យញ្ជន នបុំ. ព្យញ្ជនៈ

ព្យាបន្នចិត្ត នបុំ. ចិត្តព្យាបាទ

ព្រហ្មចារិនី ឥ. អ្នកបួសស្រី

ព្រហ្មចារី បុំ. អ្នកបួសប្រុស

ព្រហ្មទេវ បុំ. ទេវតាក្នុងឋានព្រហ្ម

ព្រាហ្មណគហបតិកា បុំ. ព្រាហ្មណ៍និងគហបតី

មច្ឆេរមលបរិយុដ្ឋិត បុំ. មន្ទិលគឺសេចក្ដីកំណាញ់សង្កត់ហើយ

មញ្ចកា បុំ. គ្រែតូច

មណិមយ គុ. ធ្វើអំពីកែវមណី

មត្តិកា ឥ. ដីឥដ្ឋ

មត្តិកាបត្ត បុំ. បាត្រធ្វើពីដីឥដ្ឋ

មធុមក្ខិតតិណា បុំ. ឃ្មុំនិងរុយនិងស្មៅ

មន បុំ.,នបុំ. ចិត្ត

មនុស្ស បុំ. មនុស្សប្រុស

មនុស្សត្ត នបុំ. ភាវៈនៃមនុស្ស

មនុស្សភាវ បុំ. ភាពជាមនុស្ស

មនុស្សភូត គុ. ដែលកើតជាមនុស្ស

មនុស្សលោក បុំ. លោកជាទីនៅនៃមនុស្ស

មនុស្សី ឥ. មនុស្សស្រី

មរណភយ នបុំ. ភ័យដល់ការស្លាប់

មល នបុំ. ប្រេះ

មល្ល បុំ. ស្តេចមល្លៈ

មហាកច្ចាយនត្ថេរ បុំ. ព្រះមហាកច្ចាយនត្ថេរ

មហាទុព្ភិក្ខភយ នបុំ. មហាទុរភិក្សភ័យ(អត់បាយ)

មហាបជាបតិ ឥ. នាងមហាបជាបតី

មហាបាល បុំ. នាយមហាបាល

មហាវន នបុំ. ឈ្មោះព្រៃមហាវ័ន

មហាសេដ្ឋី បុំ. *សេដ្ឋីធំ, មហាសេដ្ឋី*

មា និ. *កុំ*

មាគធ បុំ. *អ្នកនៅមគធៈ*

មាគធិក បុំ. *អ្នកនៅមគធៈ*

មាតាបិតុ បុំ. *ម្តាយនិងឪពុក*

មាណវ បុំ. *មនុស្សកម្លោះ*

មាណវី ឥ. *ស្រីក្រមុំ*

មាតុល បុំ. *មា(ខាងម្តាយ)*

មាតុលានី ឥ. *មីង(ខាងម្តាយ)*

មាមក គុ. *អ្នករាប់រក*

មាលាការ បុំ. *អ្នកធ្វើនូវកម្រងផ្កា*

មិគទាយ បុំ. *ព្រៃម្រឹគ*

មិច្ឆាទិដ្ឋិក បុំ. *អ្នកមិច្ឆាទិដ្ឋិ*

មិច្ឆា និ. *ខុស*

មិច្ឆាចារី បុំ. *អ្នកប្រព្រឹត្តខុស*

មិច្ឆាទិដ្ឋិក បុំ. *អ្នកយល់ឃើញខុស*

មុទ, មោទ បុំ. *រីករាយ, ត្រេកអរ,*

មុធា និ. *ទទេ*

មុសា និ. *កុហក, មិនពិត*

មុសាវាទី បុំ. អ្នកពោលពាក្យកុហក

មូសិក បុំ. កណ្តុរឈ្មោល

មូសិកា ឥ. កណ្តុរញី

មេត្តាសហគត គុ. ប្រព្រឹត្តទៅមួយអន្ទើដោយមេត្តា

មេឃង្ករោ បុំ. ព្រះពុទ្ធព្រះនាមមេឃង្ករៈ

មេធាវិនី ឥ. អ្នកប្រាជ្ញស្រី

មេធាវី បុំ. អ្នកប្រាជ្ញប្រុស

មោហ បុំ. សេចក្តីវង្វេង, មោហៈ

យក្ខ បុំ. យក្សប្រុស

យក្ខិនី ឥ. យក្សស្រី

យគ្ឃេ និ. សូមព្រះរាជតេជៈ,សូមទានមេត្តាប្រោស, ទានប្រោស

យថា និ. ដូចជា, យ៉ាងណា, យ៉ាងណាមិញ, ដោយប្រការណា

យថាកម្មំ កិ.វិ. តាមកម្ម, តាមអំពើ

យថាជីវំ កិ.វិ. តាមការរស់នៅ

យថាពលំ កិ.វិ. តាមកម្លាំង

យថាវុឌ្ឍំ កិ.វិ. តាមវ័យ

យថាសត្តិ កិ.វិ. តាមសមត្ថភាព

យថាសុខំ កិ.វិ. តាមស្រួល

យទា និ. ក្នុងកាលឯណា

យទិ និ. បើ, ប្រសិនបើ, ទោះបី

យន្នូន និ. បើដូច្នោះ, ដូចម្ដេចហ្ន៎

យុវតី ឥ. ស្រីក្រមុំ

យុវា បុំ. ប្រុសកម្លោះ

យស បុំ. កេរ្តិ៍ឈ្មោះ, យស

យាចក បុំ. អ្នកសុំ, ស្មូម

យាវ និ. ដរាបណា, ត្រឹមណា

យាវតា និ. មានប្រមាណប៉ុនណា

យាវទេវ និ. កំណត់ត្រឹមណា

យេភុយ្យេន និ. ដោយច្រើន, ច្រើនតែ

យោជនិក គុ. ប្រកបដោយយោជន៍

រថការក បុំ. ជាងធ្វើរទេះ

រថចក្កប្បមាណ នបុំ. មានប្រមាណប៉ុនកង់នៃរថ

រជតមយ គុ. ធ្វើអំពីប្រាក់

រហោ និ. ទីកំបាំង, ទីស្ងាត់

រាគ បុំ. តម្រេក, រាគៈ

រាជ បុំ. ស្ដេចប្រុស

រាជគហ បុំ. ក្រុងរាជគ្រឹះ

រាជិនី ឥ. ស្ដេចស្រី

រូចារចរ គុ. ដែលត្រាច់ទៅក្នុងរូបភព

រម្ម គុ. ជាទីរីករាយ

រេ, អរេ និ. អាចម្រៃ, មេចម្រៃ, រឺយ, រឺចសម្ដី, វាចា

រោគី បុំ. អ្នកមានរោគ

រោគុបទ្ទវ បុំ. អន្តរាយដោយរោគ

លង្កា ឥ. ស្រុកលង្កា

លង្កាទីប បុំ. កោះលង្កា

លង្កិកា គុ. អ្នកកោះលង្កា

លប បុំ. អ្នកនិយាយឥតបានការ

លាភ បុំ. លាភ

លិច្ឆវី បុំ. អ្នកស្រុកលិច្ឆវី

លោកុត្តរ គុ. ដែលឆ្លងឡើងចាកលោក

លោហាមយ គុ. ធ្វើអំពីដែក

វ និ. ពិត, មែន, គ្រាន់តែ, ប៉ុណ្ណោះ

វត និ. ហ្ន៎, អើហ្ន៎, យី, យីអើ

វត្ថាភរណា នបុំ. សម្លៀកបំពាក់និងគ្រឿងប្រដាប់

វត្ថុសម្បទា ឥ. ការដល់ព្រមគឺវត្ថុ

វយ បុំ.,នបុំ. ជំនាន់, វ័យ

វយធម្ម គុ. ដែលមានការអន់ថយទៅជាធម្មតា

| | |
|---|---|
| វរុណ | បុំ. នាមព្រះវរុណ |
| វរុណានី | ឥ. នាមព្រះវរុណ |
| វសុ | នបុំ. ទ្រព្យ, សម្បត្តិ |
| វា | និ. ក្តី, ឬ, ខ្វះ, ក៏ដោយ, ក៏បាន, ពុំនោះសោត |
| វាលធិ | បុំ. កន្ទុយ |
| វាលុ | បុំ. ដីខ្សាច់ |
| វិក្ខិត្ត | គុ. រាយមាយហើយ |
| វិនា | និ. វៀរ, គ្មាន, វៀរលែងតែ, ដោយគ្មាន |
| វិបត្តិ | ឥ. សេចក្តីវិនាស |
| វិបស្សនា | ឥ. បញ្ញាជាគ្រឿងឃើញច្បាស់, វិបស្សនា |
| វិបស្សនាធុរ | នបុំ. ធុរៈគឺការចម្រើនវិបស្សនា |
| វិយ | និ. ដូច, បីដូច, ប្រហែលដូច |
| វិរាគធម្ម | គុ. ដែលមានការប្រាសចាកតម្រេកជាធម្មតា |
| វិរូប | គុ. មានរូបអាក្រក់ |
| វិវេកជ | គុ. ដែលកើតហើយព្រោះភាពស្ងាត់ |
| វិសដ | គុ. ដោរជន់ឬផ្សាយហើយ |
| វិសារទ | បុំ. សេចក្តីក្លៀវក្លា |
| វិសុទ្ធិ | ឥ. សេចក្តីស្អាត |
| វុដ្ឋិតកាល | បុំ. វេលាចេញ |

វេ និ. ឡើយ, ហើយ, ហ៎ះ

វេទនា ឥ. ការដឹង, ការសោយ, វេទនា

វេនយិក បុំ. អ្នកជំនាញខាងវិន័យ

វេបុល្ល នបុំ. ភាពចម្រើនលូតលាស់

វេរ នបុំ. ពៀរ, វេរា

វេសាលិក បុំ. អ្នកស្រុកវេសាលី

វេសាលិវាសី បុំ. អ្នកស្រុកវេសាលី

វេឡុវន នបុំ. ព្រៃឫស្សី, ឈ្មោះវត្តវេឡុវ័ន

វោ និ. វើយ, យី, ហ្ន៎ះ, ហ្ន៎

ព្យាម បុំ. ព្យាម (រង្វាស់)

សកល គុ. ទាំងអស់, ទាំងស្រុង

សកឹ កិ.វិ. មួយគ្រា, ម្តង

សក្ក បុំ. សក្កទេវរាជ

សក្ការ បុំ. គ្រឿងសក្ការៈ

សក្យកុល នបុំ. ត្រកូលសក្យៈ

សក្យបុត្ត បុំ. កូននៃសក្យត្រកូល

សង្ខត គុ. ដែលបច្ច័យតាក់តែងហើយ

សិង្គី គុ. អ្នកមានស្នេហ៍, វាងវៃ

សង្ឃិក គុ. ជារបស់សង្ឃ

សចិត្តបរិយោទបន នប៉ុ. ការធ្វើចិត្តនៃខ្លួនឱ្យល្អស្អាត
សចេ និ. បើ, ប្រសិនបើ
សច្ចវាទី ប៉ុ. អ្នកមានវាចាពិត
សញ្ញោជន នប៉ុ. ការប្រកប, ការចង
សណិកំ កិ.វិ. តិច ៗ, លប ៗ, សន្សឹម ៗ, ថ្នម ៗ
សណ្ឋាគារ ប៉ុ. រោងប្រជុំ
សតក្ខត្តុំ កិ.វិ. មួយរយដង, មួយរយលើក
សតិមតី ឥ. ស្រីអ្នកមានសតិ
សតិមា ប៉ុ. ប្រុសអ្នកមានសតិ
សត្តាហ នប៉ុ. សប្តាហ៍, ប្រាំពីរថ្ងៃ
សត្ថ នប៉ុ. តម្រា, សាស្ត្រា
សត្ថសាលា ឥ. សាលារៀន
សទ្ធឹ និ. ជាមួយ, មួយអន្លើ
សន្ទិដ្ឋិក គុ. អ្នកគួរឃើញដោយខ្លួនឯង
សន្និចយ ប៉ុ. ការសន្សំ
សប្បុរិស ប៉ុ. បុរសអ្នកស្ងប់, សប្បុរស
សព្វ សព្វ. ទាំងពួង
សព្វបឋមំ និ. ដំបូងបំផុត
សព្វបាប នប៉ុ. បាបទាំងពួង

សម គុ. ស្មើ

សមណ បុំ. អ្នកស្ងប់

សមណព្រាហ្មណ បុំ. សមណនិងព្រាហ្មណ៍

សមន្តា និ. ជុំវិញ

សមន្នាគត គុ. ដែលប្រកបព្រមហើយ

សមាបត្តិ ឥ. សមាបត្តិ

សមុទ្ទចារំ នបុំ. ខាងនាយសមុទ្រ

សម្បតិ និ. អម្បាញ់មិញ

សម្បទា ឥ. ការដល់ព្រម, សម្បទា

សម្ផប្បលាបី បុំ. អ្នកពោលពាក្យរោយរាយ

សម្មជ្ជនី ឥ. អំបោស

សម្មទក្ខាត គុ. ដែល...ពោលហើយដោយល្អ

សម្មា និ. ត្រូវ, ត្រឹមត្រូវ

សម្មាសម្ពុទ្ធ គុ. ដែលត្រាស់ដឹងឯងនិងដោយប្រពៃ

សម្មុខា និ. ចំពោះមុខ, នៅមុខ

សយំ និ. ឯង, ខ្លួនឯង

សរណង្ករោ បុំ. ព្រះពុទ្ធព្រះនាមសរណង្ករៈ

សល្លហុកវុត្តី គុ. អ្នកមានកិរិយាប្រព្រឹត្តស្រាល

សវិចារ គុ. មានការពិចារណា

សវិតក្ក គុ. មានការត្រិះរិះ

សសុរ បុំ. ឪពុកក្មេក

សស្សុ ឥ. ម៉ែក្មេក

សហ និ. ជាមួយ, មួយអន្លើ

សហត្ថ បុំ. ដៃនៃខ្លួន

សាកច្ឆា ឥ. ការសាកសួរ

សាកុណិក បុំ. ព្រានបក្សី

សាតច្ចកិរិយាវស បុំ. សមត្ថភាពនៃការធ្វើបន្តគ្នា

សាមញ្ញ នបុំ. ភាវនៃសមណៈ

សាមំ និ. ឯង, ខ្លួនឯង

សាយំ និ. ល្ងាច, ក្នុងពេលល្ងាច

សិប្បី បុំ. សិប្បករសិរក្បាល, សិរ

សីលវតី ឥ.ស្រីអ្នកមានសីល

សីលវា បុំ. ប្រុសអ្នកមានសីល

សីសច្ឆវី ឥ. ស្បែកក្បាល

សីសាពាធ បុំ. ជំងឺក្នុងក្បាល

សីហសេយ្យា ឥ. ដំណេកនៃសិង្ហ

សុ និ. ហ៎, ហ៎ះ, ហ្ន៎ះ

សុជន បុំ. មនុស្សល្អ

សុណិសា ឥ. កូនប្រសារស្រី
សុត្ត នបុំ. សូត្រ
សុត្តន្តិក បុំ. អ្នកជំនាញខាងព្រះសូត្រ
សុទំ និ. បានឮថា, ឮថា,មានសេចក្ដីដំណាលថា
សុរិយោទយ បុំ. ពេលព្រះអាទិត្យរះ
សុវណ្ណការ បុំ. ជាងមាស
សុវណ្ណចេតិយ នបុំ. ចេតិយ៍មាស
សុវណ្ណបទុម នបុំ. ផ្កាឈូកមាស
សុវណ្ណមយ គុ. ធ្វើពីមាស
សុវិមុត្តចិត្តោ គុ. មានចិត្តផុតស្រឡះល្អហើយ
សុវេ និ. ថ្ងៃស្អែក, ក្នុងថ្ងៃស្អែក
សូករិក បុំ. អ្នកលក់ជ្រូក
សេនាបតិបុត្ត បុំ. កូននៃសេនាបតី
សេយ្យថីទំ និ. យ៉ាងណានេះ, ដូចម្ដេចនេះ, គឺអ្វីខ្លះ ?
សេ និ. ហ្នឹះ, ហ៎ះ, ហ៎, សិន
សេណិយ បុំ. នាយពួក
សេយ្យថា និ. ដូចជា, ដូចម្ដេចមិញ, យ៉ាងណាមិញ
សេយ្យា ឥ. ការដេក, ដំណេក
សោណ បុំ. (ឈ្មោះព្រាហ្មណ៍)

សោតាបត្តិផល នបុំ. សោតាបត្តិផល

សោវណ្ណមយ គុ. ធ្វើអំពីមាស

សំវរ បុំ. ការសង្រួម

ស្វាតន គុ. នឹងមានក្នុងថ្ងៃស្អែក

ស្វេ និ. ថ្ងៃស្អែក, ក្នុងថ្ងៃស្អែក

ហន្ទ និ. ហ៎, បើដូច្នោះ, អញ្ជើញ

ហវេ និ. ហើយ, វើយ, យី, ហ៎ះ, ហ្ន៎ះ

ហិ និ. ក៏, ពិត, មែន, មែនពិត, ព្រោះ, ដ្បិត, សេចក្ដីថា, ឯង, ហ្នឹងឯង

ហិយ្យោ និ. ម្សិលមិញ

ហីយោ និ. ម្សិលមិញ

ហុរំ និ. លោកដ៏ទៃ, លោកខាងមុខ

ហេ និ. ហើយ, វើយ

ហេដ្ឋា និ. ខាងក្រោម, ខាងក្រោយ

# អាខ្យាតកិរិយានុក្រម

អក្កោសតិ (អា + កុស + អ + តិ) *ជេរ*

អច្ចាជាយ *កិត.* (អតិ + អា + ជា + ត្វា) *គង់លើគ្នាហើយ, ត្រួតហើយ*

អជ្ឈាវសតិ (អធិ + អា + វស + អ + តិ) *នៅគ្រប់គ្រង*

អធិគច្ឆតិ (អធិ + គម + អ + តិ) *បាន, លុះ*

អធិដ្ឋាតិ (អធិ + ឋា + អ + តិ) *អធិដ្ឋាន*

អនុកម្បតិ (អនុ + កម្ប + អ + តិ) *អាណិត, អនុគ្រោះ*

អនុបក្ខិបិត្វា *កិត.* (អនុ + ប + ខិប + ឥ + ត្វា) *ស៊កហើយ, សៀត-ហើយ*

អនុបជ្ជតិ (អនុ + បទ + យ + តិ) *ដល់តាម, សម្រេច*

អនុប្បទាតិ, អនុប្បទេតិ (អនុ + ប+ ទា + អ + តិ) *ឱ្យថែម, បរិច្ចាគ*

អនុវិលោកេតិ (អនុ + វិ + លោក + ណេ + តិ) *ផ្ងាកតាមមើល*

អនុសាសតិ (អនុ + សាស + អ + តិ) *ប្រៀនប្រដៅ*

អន្តរធាយតិ (អន្តរ + ធេ + អ + តិ) *បាត់ទៅ, សូន្យទៅ*

អបិទហតិ (អបិ + (ធា > ទហ) + អ + តិ) *បិទ, ឃុំ*

អព្ភុន្នាមេតិ (អភិ + ឧ + នម + ណេ + តិ) *ទាញ, ចាប់ទុក*

អភិក្កមតិ (អភិ + កម + អ + តិ)*ឈានទៅមុខ*

អភិត្ថវតិ (អភិ + ថុ + អ + តិ) *ស្ញើចសរសើរ*

អភិនន្ទតិ (អភិ + នន្ទ + អ + តិ) *ត្រេកអរចំពោះ*

អភិបីឡេតិ (អភិ + បីឡ + ណេ + តិ) *បៀតបៀន*

អភិភវតិ (អភិ + ភូ + អ + តិ) *ញាំញី, គ្របសង្កត់*

អភិហរតិ (អភិ + ហរ + អ + តិ) *នាំមក, នាំទៅ*

អន្តរជាយតិ (អន្តរ + ជេ + អ + តិ) *បាត់ទៅ, សូន្យទៅ*

អន្វេតិ (អនុ + ឥ + អ + តិ) *ទៅតាម*

អាភិរតិ (អា + ភិរ + អ + តិ) *រោយ, ប្រូច(ទឹក)*

អាជាវតិ (អា + ជាវ + អ + តិ) *រត់ទៅមក*

អារភតិ (អា + រភ + អ + តិ) *ប្រារព្ធ, ផ្ដើម*

ឧដ្ឋហាតិ (ឧ + ឋា + អ + ឋា អា. + តិ) *តាំងឡើង, ក្រោកឡើង*

ឧដ្ឋាតិ (ឧ + ឋា + អ + តិ) *តាំងឡើង, ក្រោកឡើង*

ឧបចិណាតិ (ឧប + ចិ + ណា + តិ) *សន្សំ, ក, ពូន*

ឧបនិសេវតិ (ឧប + និ + សិ + អ + តិ) *ចូលទៅអាស្រ័យ, គប់រក*

ឧបបជ្ជតិ (ឧប + បទ + យ + តិ) *កើតទៀត*

ឧបលិម្បតិ (ឧប + លិប + ំ + អ + តិ) *ប្រឡាក់, ជាប់*

ឧបសម្បជ្ជតិ (ឧប + សំ + បទ + យ + តិ) *ចូលទៅដល់ព្រម*

ឧបសេវតិ (ឧប + សេវ + អ តិ) *ចូលទៅសេព, សេពគប់*

កប្បេតិ (កប្ប + ណេ + តិ) *សម្រេច, ចិញ្ចឹមជីវិត, ចាត់ចែង*

កម្បេតិ (កម្ប + ណេ + តិ) *ញ័រ, កក្រើក*

ករោតិ (ករ + ឱ + តិ) *សង់, ធ្វើ*

កិលិស្សតិ (កិលិស + យ + តិ) សៅហ្មង

ខិបតិ (ខិប + អ + តិ) បោះទៅ, ចោលទៅ

គរហតិ (គរហ + អ + តិ) តិះដៀល

ចជតិ (ចជ + អ + តិ) លះ

ឆិន្ទតិ (ឆិទ + ំ + អ + តិ) ដាច់, ផ្តុះ

ជោតតិ (ជុត + អ + តិ) ភ្លឺ, រុងរឿង

ឌយ្ហតិ (ឌហ + យ + តិ) ឆេះ, ដុត, រលាក

តប្បតិ (តប + យ + តិ) ដុតកម្តៅ, ចាំងពន្លឺ

តុស្សតិ (តុស + យ + តិ) ត្រេកអរ

តេមេតិ (តិម + ណេ + តិ) ទទឹក, សើម

និក្ខិបតិ (និ + ខិប + អ + តិ) ទុក, ទុកដាក់

និបជ្ជតិ (និ + បទ + យ + តិ) ដេក

និប្បជ្ជតិ (និ + បទ + យ + តិ) កើត

និប្ផជ្ជតិ (និ + បទ + យ + តិ) សម្រេច, ផលិត

និព្វត្តតិ (និ + វត្ត + អ + តិ) បង្កើត, ប្រព្រឹត្ត

និម្មិនាតិ (និ + មា + នា + តិ) និម្មិត, តំណែង

និវត្តតិ (និ + វត្ត + អ + តិ) ត្រឡប់, វិលវិញ

និវាសេតិ (និ + វស + ណេ + តិ) ស្លៀកពាក់

បកាសតិ (ប + កាស + អ + តិ) ប្រកាស, ថ្លែង

បខាលេតិ (ប + ខល + ណេ + តិ) លាង, ជម្រះ

បគ្គយ្ហតិ (ប + គហ + ណ្ហា + តិ) ផ្គង់ឡើង

បញ្ញាបេតិ (ប + ញា + ណាបេ + តិ) តាក់តែង, ចាត់ចែង

បដិជាណាតិ (បដិ + (ញា > ជា) + ណា + តិ) សន្យា

បដិពុជ្ឈតិ (បដិ + ពុធ + យ + តិ) ភ្ញាក់, រលឹក

បដិយាទេតិ (បដិ + យត + ណេ + តិ) ចាត់ចែង,តាក់តែង

បដិលភតិ (បដិ + លភ + អ + តិ) បានវិញ, សង

បដិហញ្ញតិ (បដិ + ហន + យ + តិ) បៀតបៀន,កម្ចាត់

បតតិ (បត + អ + តិ) រលំ, ធ្លាក់, ជ្រុះ

បតិដ្ឋាតិ (ប + ឋា + អ + តិ) តម្កល់ទុក, តាំងទុក

បត្ថរតិ (ប + ថរ + អ + តិ) ផ្សាយទៅ

បពុជ្ឈតិ (ប + ពុធ + យ + តិ) រលឹក, តើន

បរាជេតិ, បរាជយតិ (បរា + ជិ + អ + តិ) ចាញ់, បរាជ័យ

បរិកិរតិ (បរិ + កិរ + អ តិ) ខ្ចាត់ខ្ចាយ

បរិក្ខិបតិ (បរិ + ខិប + អ + តិ) បិទបាំង, ព័ទ្ធ

បរិចរតិ (បរិ + ចរ + អ + តិ) បម្រើ

បរិធាវតិ (បរិ + ធាវ + អ + តិ) រត់ជុំវិញ

បរិនិព្វាតិ (បរិ + និ + វា + អ + តិ) បរិនិព្វាន

បរិភាសតិ (បរិ + ភាស + អ + តិ) ប្រទេច, ជេរ

បរិយេសតិ (បរិ + ឯស + អ + តិ) ស្វែងរក

បរិវជ្ជេតិ (បរិ + វជ្ជ + ណេ + តិ) វៀរ, ចៀសវៀង

បរិវិសតិ (បរិ + វិស + អ + តិ) បំរើ,អង្គាស, ថ្វាយ

បរិសុជ្ឈតិ (បរិ + សុជ + យ + តិ) ស្អាត, សម្អាត, បន្សុទ្ធ

បវត្តតិ (ប + វត្ត + អ + តិ) ប្រព្រឹត្តទៅ

បសាទេតិ (ប + សទ + ណេ + តិ) ជ្រះថ្លា

បសំសតិ (ប + សំស + អ + តិ) សរសើរ

ចាយេតិ (ចា + ណេ + តិ) ឱ្យផឹក

បុរក្ខរោតិ (បុរ + ការ + ឱ + តិ) ធ្វើនៅខាងមុខ, សរសើរ

បីឡេតិ (បីឡ + ណេ + តិ) បៀតបៀន

បេសេតិ (បេស + ណេ + តិ) បញ្ជូនទៅ

ផរតិ (ផរ + អ + តិ) ផ្សាយទៅ

ផលេតិ (ផល + ណេ + តិ) ពុះ, ហែក, វះ

ភាជេតិ (ភាជ + ណេ + តិ) ចែក

ភូសេតិ (ភូស + ណេ + តិ) តាក់តែង, ប្រដាប់

មិលាយតិ (មិលេ + អ + តិ) ស្រពោន, ស្វិត

យោជេតិ (យុជ + ណេ + តិ) ប្រកប, ចង

វឌ្ឍតិ (វឌ្ឍ + អ + តិ) ចម្រើន, រុងរឿង

វត្តតិ (វត្ត + អ + តិ) ប្រព្រឹត្ត

វិកសតិ (វិ + កស + អ + តិ) *រីក (ផ្កា)*

វិចរតិ (វិ + ចរ + អ + តិ) *ត្រាច់ទៅ, ប្រព្រឹត្ត*

វិនស្សតិ (វិ + នស + យ + តិ) *វិនាស, ខូច*

វិន្ទតិ (វិទ + ◌ំ + អ + តិ) *ប្រសព្វ, បាន*

វិប្បកិរតិ (វិ + ប + កិរ + អ + តិ) *រោយរាយ, ខ្ចាត់ខ្ចាយ*

វិប្បមុត្ត *កិត.* (វិ + ប + មុច + ត) *ផុតស្រឡះហើយ*

វិភជតិ (វិ + ភជ + អ + តិ) *ចែក, រំលែក, ញែក*

វិវេចេតិ (វិ + វិច + ណេ + តិ) *ញែកចេញ, រិះគន់*

វិហញ្ញតិ (វិ + ហន + យ + តិ) *បៀតបៀន*

វិហរតិ (វិ + ហរ + អ + តិ) *នៅ, អាស្រ័យនៅ*

សង្គណ្ហាតិ (សំ + គហ + ណ្ហា + តិ) *សង្គ្រោះ*

សជ្ឈាយតិ (សំ + ឈេ + អ + តិ) *ស្វាធ្យាយ*

សន្តប្បេតិ (សំ + តប្ប + ណេ + តិ) *រីករាយ, ពេញចិត្ត*

សន្និធេតិ (សំ + និ + ធា + ឃ + តិ) *សន្សំទុក*

សប្បតិ (សប្ប + អ + តិ) *វារ, លូន*

សមុដ្ឋាតិ (សំ + ឧ + ឋា + អ + តិ) *តាំងឡើង, កើត*

សម្បជ្ជតិ (សំ + បទ + យ + តិ) *ដល់ព្រម*

សម្បាវេតិ (សំ + ប + វរ + ណេ + តិ) *ថ្វាយ, ប្រគេន*

សម្បាបុណាតិ (សំ + ប + អាប + ឧណា + តិ) *ដល់ព្រម, ទាន់*

**សម្មជ្ជតិ** ( **សំ** + **មជ្ជ** + **អ** + **តិ** ) *បោស*

**សុទេសេតិ** ( **សុ** + **ទិស** + **ណេ** + **តិ** ) *សម្ដែងល្អ*

**សុនិហិត** *កិត.* ( **សុ** + **និ** + ( **ធា** > **ហ** ) + **ឥ** *អា.* + **ត** ) *កប់ទុកល្អ-ហើយ*

**សុស្សតិ** ( **សុស** + **យ** + **តិ** ) *ស្ងួត, ហួត, ស្គម*

**សំវសតិ** ( **សំ** + **វស** + **អ** + **តិ** ) *នៅរួម*

**សំវិជ្ជតិ** ( **សំ** + **វិជ** + **យ** + **តិ** ) *មានព្រម*

**សំហរតិ** ( **សំ** + **ហរ** + **អ** + **តិ** ) *លាយ, រួបរួម*

# ☜វេយ្យាករណតជួនី☞


អឃោសៈ ៤៤៧

អឌ្ឍសរ ៤៥៣

អត្ថយត្ថសាមញ្ញតទ្ធិត ៣២៥

អត្ថិតទ្ធិត ៣៨៦

អធិករណសាធន ១៤០

អនាទរកិរិយា ២០

អនុស្សរេនត្ថនិបាត ៦៣

អនេកត្ថនិបាត ៦៩

អនេកត្ថប្រយោគ ៨៣

អនេកត្ថសាមញ្ញតទ្ធិត ៣២៥

អបច្ចត្ថសាមញ្ញតទ្ធិត ៣២៥

អបាទានសាធន ១៤០

អបេក្ខត្ថ ៩១

អព្ភន្តរកិរិយា ១៨

អព្យយតទ្ធិត ៤២៤

អព្យយបច្ច័យ ១២៣

អព្យយស័ព្ទ ២៧

អព្យយីភាវសមាស ៥៦០

អលុត្តសមាស ៥០៩
អវធារណបុព្វបទកម្មធារយសមាស ៥៣០
អសន្ធិ ៤៧៧
អសមាហារទិគុសមាស ៥៣៧
អសមាហារទ្វន្ទសមាស ៥៤៧
អសរូប ៤៤២
អសវណ្ណ ៤៤១
អាការ, អាការន្ត ១០៩
អាគមោ ៤៥៩
អាគមោបកតិ ៤៦០
អាទេសោ ៤៥៩
អាទ្យន្ត ១០៦
អាលបនត្ថវាចកនិបាត ៥៣
ឥត្ថម្ភូតកិរិយា ១៩
ឥតិភាគ ១៤២
ឧណាទិបច្ច័យ ២៩៩
ឧត្តរបទ ៥០៧
ឧបបទតប្បុរិសសមាស ៥៤៤
ឧបបទសមាស ៥៤៤

ឧបមាតទ្ធិត ៤០៣
ឧបមានុត្តរបទកម្មធារយ: ៥២៦
ឧបមានុបមេយ្យត្ថនិបាត ៨៦
ឧបមាបុព្វបទកម្មធារយ: ៥២៥
ឧបមាពហុព្វីហិសមាស ៥៨៤
ឧបសគ្គ ២៧
ឧបសគ្គធ្វើអត្ថរបស់ធាតុឲ្យប្លែក ៣៧
ឧបសគ្គបុព្វកាព្យយីភាវសមាស ៥៦១
ឧបសគ្គបៀតបៀនអត្ថរបស់ធាតុ ៣៦
ឧបសគ្គមានអត្ថស្របតាមធាតុ ៣៧
ឧភយតប្បុរិសសមាស ៥៥៣
ឧយ្យោជនត្ថនិបាត ៦៩
ឯកដ្ឋាន អក្ខរ ៤៥០
ឯកដ្ឋានជ ៤៥១
ឯកត្ថប្រយោគ ៨១
ឯកសេសសមាស ៥៤៩
ឱដ្ឋជ ៤៥១
កណ្ឋជ ៤៥០
កណ្ឋតាលុជ៤៥២

កណ្ឌោជ្ឈជ៤៥២

កត្តុរូប ១៣៩, ១៤០

កត្តុរូប-អធិករណសាធន ២២៥

កម្មរូប-អធិករណសាធន ២២៥, ២២៦

កត្តុរូប-អបាទានសាធនៈ ២២៣

កត្តុរូប-កត្តុសាធន ១៤៥

កត្តុរូប-កត្តុសាធន ១៨៦

កត្តុរូប-ករណសាធនៈ ២១៧

កត្តុរូប-តស្សីលសាធន ១៤២

កត្តុរូប-សម្បទានសាធន ២២០

កម្មធារយសមាស ៥១៦

កម្មរូប ១៣៩

កម្មរូប-អធិករណសាធន ១៤១

កម្មរូប-កម្មសាធន ១៤១

កម្មរូប-កម្មសាធន ១៨៦

កម្មរូប-កម្មសាធន ១៤២

កម្មរូប-ករណសាធនៈ ២១៨

កម្មរូប-ករណសាធន ១៤១

កម្មរូប-សម្បទានសាធន ២២០, ២២១

កម្មរូប-សម្បទានសាធន ១៤១

កម្មសាធន ១៤០

កម្មសាធន ១៨៦, ១៨៩

ករណៈ ៤២៩

ករណៈនៃអក្ខរៈ ៤៥៣

ករណសាធន ១៤០

កាលត្ថវាចកនិបាត ៥៤

កិច្ចបច្ច័យ ១៣៨

កិតកិច្ចបច្ច័យ ១៣៨

កិតនាម ១៣៧

កិតបច្ច័យ ១៣៨

កិតបច្ច័យ ៣២១

គរហត្ថ ៩២

គរុ ៤២៣

គរុព្យាង្គ ៤២៥

គោត្តតទ្ធិត ៣២៥

ឃោសៈ ៤២៧

ឋានត្ថវាចកនិបាត ៥៧

ឋានតទ្ធិត ៣៦៥

ឋាន ៤៤៩

ឋាននៃអក្ខរៈ ៤៤៩

ចតុត្ថីតប្បុរិសសមាស ៥៤១

ចតុត្ថីពហុព្វីហិសមាស ៥៧៣

ឆដ្ឋីតប្បុរិសសមាស ៥៤៣

ឆដ្ឋីពហុព្វីហិសមាស ៥៧៦

ឆដ្ឋីកិន្នាធិករណពហុព្វីហិសមាស ៥៨៦

ជាតាទិតទ្ធិត ៣៥៨

ជិវ្ហគ្គ ៤៥៤

ជិវ្ហោបគ្គ ៤៥៤

ជិវ្ហាមជ្ឈ ៤៥៤

ញាបនហេតុកំ ១១៦

ញាបនហេតុកាយ ១១៦

តតិយាតប្បុរិសសមាស ៥៤១

តតិយាពហុព្វីហិសមាស ៥៧១

តទស្សត្ថិតទ្ធិត ៣៨៦

តទ្ធិត ៣២០

តប្បុរិសសមាស ៥៣៨

តរត្យាទិតទ្ធិត ៣៣៥

តស្សីលសាធន ១៤០

តាលុជ ៤៥០

តិបទពហុព្វីហិសមាស ៥៩៥

តុល្យាធិករណពហុព្វីហិសមាស ៥៦៦

ទន្តជ ៤៥១

ទន្តោដ្ឋជ ៤៥២

ទិគុសមាស ៥៣៦

ទិសន្តរាឡត្ថពហុព្វីហិសមាស ៥៩៧

ទីឃោ ៤៦០

ទុតិយាតប្បុរិសសមាស ៥៤០

ទុតិយាពហុព្វីហិសមាស ៥៧០

ទ្វន្ទសមាស ៥៤៥

ទ្វិដ្ឋាន អក្ខរ ៤៥១

ទ្វិដ្ឋានជ ៤៥២

ធនិត ៤៤៧

ធាត្វត្ថពាធក ៣៦

ធាត្វត្ថវិសេសក ៣៧

ធាត្វត្ថានុវត្តក ៣៧

នបុព្វបទកម្មធារយសមាស ៥៥៣

នបុព្វបទពហុព្វីហិសមាស ៥៩០
នានត្ថនិបាត ៧៧
នាមកិតក ១៣៧
នាសិកជ ៤៥១
នាសិកដ្ឋាន ជ៤៥១
និ ឧបសគ្គ ៣៩
និគ្គហិត ៤៤៣
និគ្គហិតសន្ធិ ៤៥៩
និគ្គហិតសន្ធិ ៤៩០
និគ្គហិតបកតិសន្ធិ ៤៩២
និគ្គហិតលោបសន្ធិ ៤៩២
និគ្គហិតាទេសសន្ធិ ៤៩០
និទស្សន  ១១៣
និទស្សនត្ថ ១១៣
និបាត ៥២
និបាតបុព្វកាព្យយីភាវសមាស ៥៦៤
និស្សយ ៤៥៤
និស្សិត ៤៥៥
និស្សិតតទ្ធិត ៤០៤

បកតិតទ្ធិត ៣៧៧

បកតិព្យញ្ជនសន្ធិ ៤៨៩

បការត្ថនិបាត ៨៩

បការ ឬ បការត្ថ ១១៥

បច្ចេកបច្ច័យ ឬ បច្ច័យដោយឡែក ២៦៩

បញ្ចមីតប្បុរិសសមាស ៥៤២

បញ្ចមីពហុព្វីហិសមាស ៥៧៥

បដិសេធនត្ថវាចកនិបាត ៦០

បទ ៥០៦

បទបូរណនិបាត ៧២

បធាននយកិរិយា ១៦

បទសន្ធិ ៤៥៩

បយតន: ៤៤៩

បរនយនំ ៤៦០

បរសរ ៤៦២

បរសរទីឃសន្ធិ ៤៧៥

បរសរលោបសន្ធិ ៤៦៥

បរសរវិការសន្ធិ ៤៧៣

បរសរាទេសសន្ធិ ៤៧១

បរិកប្បនិបាត ៦៤, ៨៤
បរិសមាបន្ន ១១៧
បរេកសេសសមាស ៥៥០
បរំ ៤៦០
បុច្ឆនត្ថនិបាត ៦៦
បុនរុត្តិស័ព្ទ ១៣២
បុព្វបទ ៥០៧
បុព្វសរ ៤៦២
បុព្វសរទីឃសន្ធិ ៤៧៥
បុព្វសររស្សសន្ធិ ៤៧៦
បុព្វសរលោបសន្ធិ ៤៦៣
បុព្វសរវិការសន្ធិ ៤៧៣
បុព្វសរាទេសសន្ធិ ៤៦៧
បុព្វេកសេសសមាស ៥៤៩
បុព្វំ ៤៦០
បូរណតទ្ធិត ៣៩៤
បូរណសំខ្យា ៣៩៤
ពហុព្វីហិសមាស ៥៦៥
ពហុលតទ្ធិត ៣៦៨

ព្យញ្ជនសន្ធិ ៤៥៨
ព្យញ្ជនាគមវិធី ៤៩៣
ព្យញ្ជនាទេស ៤៩៦
ព្យតិហារលក្ខណពហុព្វីហិសមាស ៥៩៦
ព្យាង្គ ៤៤៤
ភាវតទ្ធិត ៤១៤
ភាវរូប ១៣៩
ភាវរូប ១៩៨
ភាវរូបភាវសាធន ១៤១, ១៤២
ភាវសាធន ១៤០
មជ្ឈេលោបសមាស ៥៥២
មុទ្ធជ ៤៥០
មនោគណ ១
មិស្សកសមាស ៦០៣
រស្សៈ ៤៦០
រាគាទិតទ្ធិត ៣៥៤
រូបវិគ្គហ ១៣៩
លក្ខណកិរិយា ២១
លហុ ៤៤៣

លហុព្យាង្គ ៤៤៥

លុត្តសមាស ៥០៨

លោបោ ៤៦០, ៤៥៩

វណ្ណៈ ៤៤១

វណ្ណសន្ធិ ៤៥៩

វវត្ថិតៈ ៤៤៨

វិកប្បត្ថ ៩៣

វិការោ ៤៦០

វិគ្គហ ១៣៩

វិធីចុះ អ បច្ច័យ ២២៨

វិធីចុះ ឥ បច្ច័យ ២៣៣

វិធីចុះកិតកិច្ចបច្ច័យ ២២៨

វិធីចុះ ក្វិ បច្ច័យ ១៤៦

វិធីចុះ ខ បច្ច័យ ១៩២

វិធីចុះ ណ បច្ច័យ ២៤២

វិធីចុះ ណី បច្ច័យ ១៥៩

វិធីចុះ ណ្យ បច្ច័យ ២០១

វិធីចុះ ណ្វុ បច្ច័យ ១៦៥

វិធីចុះ តវេ និង តុំ បច្ច័យ ២៦២

វិធីចុះ តិ បច្ច័យ ២៥២
វិធីចុះ តុ បច្ច័យ ១៧១
វិធីចុះ យុ បច្ច័យ ២៥៨
វិធីចុះ រូ បច្ច័យ ១៧៧
វិធីតាំងវិគ្គហៈនៃអធិករណសាធនៈ ២២៥
វិធីតាំងវិគ្គហៈនៃ អ បច្ច័យ ២៣១
វិធីតាំងវិគ្គហៈនៃអបាទានសាធនៈ ២២២
វិធីតាំងវិគ្គហៈនៃអព្យយតទ្ធិត ៤២៤
វិធីតាំងវិគ្គហៈនៃ ឥ បច្ច័យ
វិធីតាំងវិគ្គហៈនៃកត្តុរូប-កត្តុសាធនៈ ១៤២
វិធីតាំងវិគ្គហៈនៃកត្តុរូប-កម្មសាធនៈ ១៨៦
វិធីតាំងវិគ្គហៈនៃកត្តុរូប-តស្សីលសាធនៈ ១៥២
វិធីតាំងវិគ្គហៈនៃកម្មរូប-កម្មសាធនៈ ១៨៩
វិធីតាំងវិគ្គហៈនៃកម្មសាធនៈ១៨៦
វិធីតាំងវិគ្គហៈនៃករណសាធនៈ ២១៦
វិធីតាំងវិគ្គហៈនៃ ខ បច្ច័យ ១៩៥
វិធីតាំងវិគ្គហៈនៃគោត្តតទ្ធិត ៣២៨
វិធីតាំងវិគ្គហៈនៃឋានតទ្ធិត ៣៦៥
វិធីតាំងវិគ្គហៈនៃ ណ បច្ច័យ ២៤៦

វិធីតាំងវិគ្គហៈនៃ ណ្យ បច្ច័យ ២០៥
វិធីតាំងវិគ្គហៈនៃ ណុ បច្ច័យ ១៦៧
វិធីតាំងវិគ្គហៈនៃតទស្សត្ថិតទ្ធិត ៣៨៦
វិធីតាំងវិគ្គិហៈនៃតរត្យាទិតទ្ធិត ៣៣៥
វិធីតាំងវិគ្គហៈនៃតស្សីលសាធនៈ ១៥២
វិធីតាំងវិគ្គហៈនៃ តិ បច្ច័យ ២៥៥
វិធីតាំងវិគ្គហៈនៃ តុ បច្ច័យ ១៧៤
វិធីតាំងវិគ្គហៈនៃបកតិតទ្ធិត ៣៧៧
វិធីតាំងវិគ្គហៈនៃបូរណតទ្ធិត ៣៩៤
វិធីតាំងវិគ្គហៈនៃពហុលតទ្ធិត ៣៦៨
វិធីតាំងវិគ្គហៈនៃភាវតទ្ធិត ៤១៤
វិធីតាំងវិគ្គហៈនៃភាវសាធនៈ ១៩៨
វិធីតាំងវិគ្គហៈនៃរាគាទិតទ្ធិត ៣៥៤
វិធីតាំងវិគ្គហៈនៃ រូ បច្ច័យ ១៧៩
វិធីតាំងវិគ្គហៈនៃសមាស ៥០៦
វិធីតាំងវិគ្គហៈនៃសមាសរូប-តស្សីលសាធនៈ ១៥៤
វិធីតាំងវិគ្គហៈនៃសមូហតទ្ធិត ៣៦២
វិធីតាំងវិគ្គហៈនៃសម្បបាទានសាធនៈ ២១៩
វិធីតាំងវិគ្គហៈនៃសេដ្ឋតទ្ធិត ៣៧២

វិធីតាំងវិគ្គហៈនៃសំខ្យាតទ្ធិត ៣៩៨
វិធីប្រែប្រយោគវិគ្គហៈ ១៤៤
វិបរិយយោ ៤៦០
វិបរីតោ ៤៦០
វិភាគតទ្ធិត ៤០០
វិមុត្តៈ ៤៤៩
វិយោគោ ៤៦០
វិរូបេកសេសសមាស ៥៥១
វិសេសនបុព្វបទកម្មធារយៈ ៥១៨
វិសេសនុត្តរបទកម្មធារយៈ ៥២២
វិសេសនោបមបទកម្មធារយៈ ៥២៤
វិសេសនោភយបទកម្មធារយៈ ៥២៣
វោមិស្សកសន្ធិ ៤៩០
សកដ្ឋាន ៤៥៤
សកដ្ឋាននាសិកដ្ឋានជ ៤៥២
សង្ករប្រយោគ ៨១
សញ្ញាជោតក ១១៣
សញ្ញាវិធាន ៤៣៧
សញ្ញោគោ ៤៦០

សត្តមីតប្បុរិសសមាស ៥៤៣
សត្តមីពហុព្វីហិសមាស ៥៧៧
សថិល ៤៤៧
សទ្ទុបបទ ១៤៣
សន្ធិ ៤៥៨
សន្ធិកិរិយោបករណ៍ ៤៥៩
ស័ព្ទ ៥០៦
ស័ព្ទកាលសត្តមី ១៣១
សម្ព័ន្ធ ៤៤៨
សមាបន្ន ១១៧
សមាស ៥០៤
សមាសកិរិយា ៤៥
សមាសរូប ១៣៩
សមាសរូបតស្សើលសាធន ១៤១
សមាហារទិគុសមាស ៥៣៦
សមាហារទ្វន្ទ្វសមាស ៥៤៦
សមុច្ចយត្ថ ៩២
សម្ហូតទ្ធិត ៣៦២
សម្បទានសាធន ១៤០

សម្ភាវនត្ថ ៩២
សម្បជិច្ឆនត្ថនិបាត ៦៨
សម្ភាវនបុព្វបទកម្មធារយសមាស ៥២៨
សរទីឃព្យញ្ជនសន្ធិ ៤៨៥
សរទីឃសន្ធិ ៤៧៥
សរបកតិសន្ធិ ៤៧៤
សររស្សព្យញ្ជនសន្ធិ ៤៨៦
សររស្សសន្ធិ ៤៧៦
សរលោបសន្ធិ ៤៦៣
សរវិការសន្ធិ ៤៧២
សរវិបរិតោសន្ធិ ៤៧៦
សរសន្ធិ៤៦១, ៤៥៨
សរាគមសន្ធិ ៤៧១
សរាទេសសន្ធិ ៤៦៦
សរូប ១១១, ៤២១
សរូបេកសេសសមាស ៥៥០
សវណ្ណ ៤២១
សហបុព្វបទពហុព្វីហិសមាស ៥៩២
សាធន ១៣៩

សាធនភាគ ១២២

សាធនស័ព្ទ ១២៣

សាធារណសន្ធិ ២៥៩

សាមញ្ញតទ្ធិត ៣២២

សំខ្យាតទ្ធិត ៣៩៨

សំខ្យាកយបទពហុព្វីហិសមាស ៥៩៥

សំខ្យាសាមញ្ញតទ្ធិត ៣២៥

សំយោគព្យញ្ជនសន្ធិ ២៨៧

សំយោគោ ២៦០

សេដ្ឋតទ្ធិត ៣៧១

ស្រះអសុទ្ធ ២២០

ស្រះសុទ្ធ ២២០

ស្រះសំយុត្ត ២២១

ហេត្វត្ថ ឬ ហេត្វត្ថវាចក ១១២

# ឈ្មោះសៀវភៅប្រើប្រាស់ក្នុងការរៀបរៀង

សៀវភៅជាភាសាខ្មែរ

ចាលីវេយ្យាករណ៍ *ព្រពុទ្ធវង្ស* សេខ នាង ។

កច្ចាយនូបត្ថម្ភកា ភាគ *១, ២ ព្រះសាសនសោភ័ណ* ជួន ណាត ។

បធានុក្រមជម្មបទ *ភាគ ១, ២, ៣ ព្រះគ្រូសេរីសោភ័ណ* គិម តូរ ។

វិជីប្រែចាលី *ឃុនសុវត្ថិវេទី* ឃូរ អ៊ុន ។

សម្ពន្ធមាលា *លោកគ្រូ អ៊ុក ជា* ។

វចនានុក្រមខ្មែរ *ភាគ ១ និង ២* ពុទ្ធសាសនបណ្ឌិត្យ ។

សៀវភៅជាភាសាថៃ

សៀវភៅរៀនភាសាចាលីដោយខ្លួនឯង *ប្រ:ឱស្ថ បុញ្ញកក្តី* ។

វចនានុក្រម ចាលី-ថៃ សម្រាប់អ្នកសិក្សា *ជវិន្ទ្រ ស:រ:ខាំ* ។

វចនានុក្រម គិរិយាអាខ្យាត *ផាន់ទ្វី ប៉. ហ៊ុងសមប៊ុន* ។

វចនានុក្រម គិរិយាគិតក *ផាន់ទ្វី ប៉. ហ៊ុងសមប៊ុន* ។

វេយ្យាករណ៍ចាលី *តាមគម្ពីរ* កច្ចាយនវេយ្យាករណ៍,
មោគ្គល្លានវេយ្យាករណ៍ និង
សទ្ទនីតិបករណ៍ *សាស្ត្រាចារ្យវង*
*បណ្ឌិត សុភាផាន់ (សុភាពណ្ណ)* ។

## សៀវភៅជាភាសាអង់គ្លេស


The New Pali course Book 1&2, Prof. A. P. Buddhadatta, Maha Nayaka Thera.

The Higher Pali course for Advance students, Prof. A. P. Buddhadatta, Maha Nayaka Thera.

An Elementary Pali course, Narada Thera.

Pali Primer, Lily de Silver.

Pali Made Easy, Balangoda Ananda Maitreya.

Practical Grammar of the Pali Language, Chales Duroiselle.

Pali Grammar for Students, Steven Collins.

Pali Grammar, Vito Perniola.

Introduction to Pali, Antony Kennedy Warder.

Concise pali-English Dictionary, Prof. A. P. Buddhadatta, Maha Nayaka Thera.

Pali-English Dictionary, Rhys Davis and William Sted.

# ឈ្មោះសប្បុរសជនចូលបោះពុម្ពសៀវភៅ

| លរ | នាម | ទីកន្លែង | ប្រាក់ |
|---|---|---|---|
| ១ | ភិក្ខុ **សុសំវុតោ** វត ពិសិដ្ឋ ឧទ្ទិសកុសលជូនញោម ប្រុស ដែលទើបធ្វើមរណៈកាល | ប្រទេសថៃ | $500 US |
| ២ | លោក ឧទ្ទេសាចារ្យ ញឹម ថារី និងឧបាសិកា ទុន សារិន ព្រមទាំងបុត្រាបុត្រី | ស៊ីដនីយ៍ Australia | $500 AU |
| ៤ | លោក សាន់ វណ្ណា អ្នកស្រី សេង សុខា និងបុត្រាបុត្រី | វិលហ្វីងផិន អាល្លឺម៉ង់ | 300 អឺរ៉ូ |
| ៥ | ឧបាសក រឹត ពុំ និង ឧបាសិកា សុខ វន ព្រមទាំងកូននិងចៅ | វែល្លិងតុន New Zealand | $300 NZ |
| ៦ | គ្រួសារ ឧបាសិកា សុខ អឿន សុខ ហុង សុខ លីម សុខ លី ព្រមទាំងកូននិងចៅ | វែល្លិងតុន New Zealand | $400 NZ |
| ៧ | ឧបាសិកា កុត វឿន | វែល្លិងតុន New Zealand | $160 NZ |

| | | | |
|---|---|---|---|
| ៨ | ឧបាសិកា សុខ ឡៃស្រ៊ិន និង កូនចៅ ព្រមទាំងពុទ្ធរិស័ទថ្ងៃសីល | វែលិងតុន<br>New Zealand | $145 NZ |
| ៩ | លោកស្រី វ៉ាន់ដានិងលោកសុភាពព្រមទាំងកូនៗ | វែលិងតុន<br>New Zealand | $110 NZ |
| ១០ | ឧបាសិកា ហួយ និង ឧបាសក អ៊ិម | កាលីហ្វញ៉ា<br>USA | $100 NZ |
| ១១ | ឧបាសិកា កុត សាខន | វែលិងតុន<br>New Zealand | $100 NZ |
| ១២ | ឧបាសិកា អៀ នារ ព្រមទាំងកូននិងចៅ | វែលិងតុន<br>New Zealand | $100 NZ |
| ១៣ | ឧបាសិកា អ៊ុំច សាន់ | វែលិងតុន<br>New Zealand | $100 NZ |
| ១៤ | ឧបាសិកា ប៉ាចសួន | វែលិងតុន<br>New Zealand | $100 NZ |
| ១៥ | ឧបាសិកា ពៅ ស៊ី អ៊ីម ឧបាសក កែវ ឱសថា និង កូនចៅ | ផាលមើស្តុនណស<br>New Zealand | $100 NZ |
| ១៦ | ឧបាសិកា ប៉ូច ចន្ថា | អារ៉ី ហ្សូណា<br>USA | $100 US |

| | | | |
|---|---|---|---|
| ១៧ | ឧបាសិកា ឆាយ គឹម លាង និង ឧបាសក ចឹក ថន និង ឧបាសិកា ផៃ សុខហេង | វែលិងតុន New Zealand | $70 NZ |
| ១៨ | ឧបាសិកា ឈួន ធឿន និង ឧបាសក ធឿន ព្រមទាំងកូនចៅ | វែលិងតុន New Zealand | $70 NZ |
| ១៩ | ឧបាសិកា យូ សុខុម | វែលិងតុន New Zealand | $60 NZ |
| ២០ | ឧបាសក ឈុនស្រ៊ុន | វែលិងតុន New Zealand | $60 NZ |
| ២១ | ឧបាសិកាសួន ប៉ែតព្រមទាំងគ្រួសារ | វែលិងតុន New Zealand | $50 NZ |
| ២២ | ឧបាសិកា យូ សុខុម | វែលិងតុន New Zealand | $50 NZ |
| ២៣ | លោកស្រី អៀ វាសនានិងលោក វណ្ណៈ ព្រមទាំងកូនៗ | វែលិងតុន New Zealand | $50 NZ |
| ២៤ | លោកស្រី អៀ រំដួលនិងលោកកុត សុភាព្រមទាំងកូនៗ | វែលិងតុន New Zealand | $50 NZ |
| ២៥ | ឧបាសក ដា វ៉ន និង ឧបាសិកា នួន សាមីព្រមទាំងកូន | វែលិងតុន New Zealand | $50 NZ |

| | | | |
|---|---|---|---|
| ២៦ | លោកស្រី វណ្ណៈនិងលោក សាក់ព្រមទាំងកូន | វែល្លិងតុន<br>New Zealand | $50 NZ |
| ២៧ | លោក កុត សុផលនិងលោកស្រី សុខា | វែល្លិងតុន<br>New Zealand | $50 NZ |
| ២៨ | ឧបាសិកា ម៉ុក នាងលាកព្រម ទាំងកូននិងចៅ | វែល្លិងតុន<br>New Zealand | $50 NZ |
| ២៩ | ឧបាសិកា ម៉ុក នាងលន់ | វែល្លិងតុន<br>New Zealand | $50 NZ |
| ៣០ | ឧបាសិកា ថាច់ សុខធី រតនា និងលោកអាចារ្យ ស៊ិន គង់ ព្រមកូនចៅ | វែល្លិងតុន<br>New Zealand | $50 NZ |
| ៣១ | ឧបាសិកា ថាច់ សុខធី សារិន និងកូនចៅ | វែល្លិងតុន<br>New Zealand | $50 NZ |
| ៣២ | ឧបាសិកា អ៊ិម សុគី | វែល្លិងតុន<br>New Zealand | $40 NZ |
| ៣៣ | អ្នកស្រី អ៊ិម បុផាស៊ី និងកូនទាំង២ | វែល្លិងតុន<br>New Zealand | $40 NZ |
| ៣៤ | ឧបាសិកា ពោ ហៀង | វែល្លិងតុន<br>New Zealand | $20 NZ |

| | | | |
|---|---|---|---|
| ៣៥ | ឧបាសិកា សុខ សៃ វ៉ាន | វែល្លិងតុន New Zealand | $20 NZ |
| ៣៦ | លោកស្រី ដែននិងស្វាមីព្រម ទាំងកូន | វែល្លិងតុន New Zealand | $20 NZ |
| ៣៧ | ឧបាសិកា អ៊ំ វន ឧបាសក ពុំ | វែល្លិងតុន New Zealand | $15 NZ |
| ៣៨ | ឧបាសិកាសុខ វន | វែល្លិងតុន New Zealand | $10 NZ |
| ៣៩ | ឧបាសិកា គឹមសាន | វែល្លិងតុន New Zealand | $5 NZ |

## ឈ្មោះសប្បុរសជន (បន្ថែម)

| លរ | នាម | ទីកន្លែង | ប្រាក់ |
|---|---|---|---|
| ១ | ព្រះ មហាសុទេវោ សុទេព សុរពង្ស | វែល្លិងតុន New Zealand | $ 200 NZ |
| ២ | ភិក្ខុ ម៉ន វិចិត្រ | វែល្លិងតុន New Zealand | $ 100.7NZ |
| ៣ | ភិក្ខុ ញាណសារោ មុំ យ៉ាពុំង | វែល្លិងតុន New Zealand | $ 100 NZ |
| ៤ | លោកអាចារ្យ កែវ ឱសថា | ផាលមើស្តុន | $ 100 NZ |

| | | | |
|---|---|---|---|
| | ឧបាសិកា ពៅ ស៊ី អ៊ីមនិង កូចចៅ | ណាស New Zealand | |
| ៥ | លោក ពៅ ប៊ឹក អ្នកស្រី យុង សុភាពនិងកូចចៅ | ផាលមើស្តុន ណាស New Zealand | $ 100 NZ |
| ៦ | លោក កែវ ម៉ី អ្នកស្រី តុក វ៉ុន និងកូចៅ | ផាលមើស្តុន ណាស New Zealand | $ 100 NZ |
| ៧ | លោក អ៊ឹង ទិត្យ អ្នកស្រី តៃ និងកូន | ផាលមើស្តុន ណាស New Zealand | $ 100 NZ |
| ៨ | លោក ពៅ សេង៉រ៉ុង អ្នកស្រី វន សូភាពនិងកូនចៅ | ផាលមើស្តុន ណាស New Zealand | $ 50 NZ |
| ៩ | លោក ស៊ុន ខេងលី អ្នកស្រី ឡាយ គី និងកូចៅ | ផាលមើស្តុន ណាស New Zealand | $ 50 NZ |
| ១០ | លោក ពៅ ផាន និង អ្នកស្រី ឳក លីម | ផាលមើស្តុន ណាស New Zealand | $ 50 NZ |
| ១១ | លោក ទឹម រដ្ឋា អ្នកស្រី លីន និងកូន | ផាលមើស្តុន ណាស New Zealand | $ 50 NZ |

| | | | |
|---|---|---|---|
| ១២ | ឧបាសិកា ឡុង ង៉ែត និងកូនចៅ | ផាលមើស្តុនណស New Zealand | $ 50 NZ |
| ១៣ | លោក មាស វុត្ថា អ្នកស្រី សុខ ឃីនិងកូន | ផាលមើស្តុនណស New Zealand | $ 50 NZ |
| ១៤ | លោកអាចារ្យ យុង ដេង និង ឧបាសិកា ឡុង វ៉ា | ផាលមើស្តុនណស New Zealand | $ 50 NZ |
| ១៥ | ឧបាសិកា ស៊ុន ឡុកចិបនិង កូនចៅ | ផាលមើស្តុនណស New Zealand | $ 50 NZ |
| ១៦ | លោកស៊ីឡុន អ្នកស្រី ស៊ីថាន កែវនិងកូនចៅ | ផាលមើស្តុនណស New Zealand | $ 50 NZ |
| ១៧ | ឧបាសិកា អ៊ឹម អុល | កំពុងធំ កម្ពុជា | $ 50 NZ |
| ១៨ | លោក ចាន់ ហឿន និងអ្នកស្រី ហុង ណារីនិងកូនចៅ | ផាលមើស្តុនណស New Zealand | $ 40 NZ |
| ១៩ | លោក ឡុង និត្យ និង អ្នកស្រី ពៅ | ផាលមើស្តុនណស New Zealand | $ 30 NZ |

| | | | |
|---|---|---|---|
| ២០ | លោក ស្រី អេម និងអ្នកស្រី កែវ ផាត | ផាលមើស្តុន ណាស New Zealand | $ 30 NZ |
| ២១ | លោក ស៊ុំ ដារ៉ុំ និងអ្នកស្រី ពន់ លន់ | ផាលមើស្តុន ណាស New Zealand | $ 30 NZ |
| ២២ | លោកសារឿន ទេព្វ និង គ្រួសារ | ផាលមើស្តុន ណាស New Zealand | $ 30 NZ |
| ២៣ | លោក ផេង ផុន និង អ្នកស្រី សំណា | ផាលមើស្តុន ណាស New Zealand | $ 30 NZ |
| ២៤ | លោក ដា សែ អ្នកស្រី លី ស៊ីណាតនិងកូន | ផាលមើស្តុន ណាស New Zealand | $ 30 NZ |
| ២៥ | ឧបាសិកា ប៉ែន លន់ | ផាលមើស្តុន ណាស New Zealand | $ 25 NZ |
| ២៦ | ឧបាសិកា ប៉ែន លី | ផាលមើស្តុន ណាស New Zealand | $ 25 NZ |

| | | | |
|---|---|---|---|
| ២៧ | លោក ជួន មឿន និងអ្នកស្រី ឡាយ យាន | ផាលមើស្តុនណស<br>New Zealand | $ 20 NZ |
| ២៨ | លោក ឡាយ សៀន អ្នកស្រី យិន សុខជា | ផាលមើស្តុនណស New Zealand | $ 20 NZ |
| ២៩ | លោក សូថាត កុលឹម អ្នកស្រី យុង សារី | ផាលមើស្តុនណស<br>New Zealand | $ 20 NZ |
| ៣០ | លោក យីន សៀន និង អ្នកស្រី ពៅ ទាវ | ផាលមើស្តុនណស New Zealand | $ 20 NZ |
| ៣១ | លោក ឡុង នឿន និងអ្នកស្រី ណុប សាមឿន | ផាលមើស្តុនណស<br>New Zealand | $ 20 NZ |
| ៣២ | លោក ពុធ សាយ និងអ្នកស្រី អៀវ សូខុន | ផាលមើស្តុនណស<br>New Zealand | $ 20 NZ |

# ឈ្មោះសប្បុរសជនអូស្ត្រាលី (បន្ថែម)

| លរ | នាម | ទីកន្លែង | ប្រាក់ |
|---|---|---|---|
| ១ | ភិក្ខុ សីលបាវរោ ឡូញ ផល្លី<br>ភិក្ខុ ញាណសរណោ ខឿប បូ<br>ភិក្ខុ កល្យាណធរោ កៅ ពៅ | ស៊ីដនីយ៍<br>Australia | $210 AU |
| ២ | ឧបាសិកា ទុន យេន | ស៊ីដនីយ៍<br>Australia | $200 AU |
| ៣ | ឧបាសក ប៉ុច វឿត ឧបាសិកា ញូង សៀងម៉េង | ស៊ីដនីយ៍<br>Australia | $150 AU |
| ៤ | ឧបាសក មង្គ ផន ឧបាសិកា ឃូ គិមលាភ | ស៊ីដនីយ៍<br>Australia | $100AU |
| ៥ | ឧបាសិកា ឯម ផាន់យ៉ា | ស៊ីដនីយ៍<br>Australia | $50 AU |
| ៦ | ឧបាសិកា លឹម សូភាព និង កូនចៅ | ស៊ីដនីយ៍<br>Australia | $ 50 AU |
| ៧ | ឧបាសក សុត ថា ឧបាសិកា សុត អ៊ឹម | ស៊ីដនីយ៍<br>Australia | $ 50 AU |
| ៨ | ឧបាសិកា កុប យ៉ានី និងកូន ចៅ | ស៊ីដនីយ៍<br>Australia | $ 50 AU |

| | | | |
|---|---|---|---|
| ៩ | លោក ឡិប សុខតុង អ្នកស្រី អ៊ា តាជឹង | ស៊ីដនីយ៍ Australia | $ 50 AU |
| ១០ | អ្នកស្រី ខុម ញ៉ឹប | ស៊ីដនីយ៍ Australia | $50 AU |
| ១១ | លោក វ៉ាន់ វេន អ្នកស្រី សួន ធា | ស៊ីដនីយ៍ Australia | $50 AU |
| ១២ | អ្នកស្រី តែម ពិសីនិងកូនចៅ | ស៊ីដនីយ៍ Australia | $50 US |
| ១៣ | ឧបាសិកា ស៊ូ អេម និងកូនចៅ | ស៊ីដនីយ៍ Australia | $30 AU |
| ១៤ | លោក យីសាម៉ុន និងអ្នកស្រី ខឹម ឡៃ | ស៊ីដនីយ៍ Australia | $30 AU |
| ១៥ | ឧបាសិកា យិន យុន ឧបាសិកា យស់ សារឿន | ស៊ីដនីយ៍ Australia | $20 AU |
| ១៦ | ឧបាសិកា ប៉ាល់ គិមស៊ាន | ស៊ីដនីយ៍ Australia | $20 AU |
| ១៧ | ឧបាសិកា អ៊ុច រ៉ុន | ស៊ីដនីយ៍ Australia | $20 AU |
| ១៨ | ឧបាសក ពូនស្រេង ឧបាសិកា សុខ ឡាង | ស៊ីដនីយ៍ Australia | $20 AU |

| | | | |
|---|---|---|---|
| ១៩ | ឧបាសិកា ស៊ូ ចន្ទា | ស៊ីដនីយ៍ Australia | $20 AU |
| ២០ | ឧបាសិកា នូ ធុច | ស៊ីដនីយ៍ Australia | $20 AU |
| ២១ | ឧបាសក ស៊ូ យាន ឧបាសិកា ស៊ូ សុផល | ស៊ីដនីយ៍ Australia | $20 AU |
| ២២ | ឧបាសក កែម លាង | ស៊ីដនីយ៍ Australia | $20 AU |
| ២៣ | ឧបាសិកា សុខ ប៊ុណ្ណា | ស៊ីដនីយ៍ Australia | $20 AU |
| ២៤ | ឧបាសិកា ហេង ចាន់ថន | ស៊ីដនីយ៍ Australia | $20 AU |
| ២៥ | អ្នកស្រី គីម ធីអ៊ីង | ស៊ីដនីយ៍ Australia | $20 AU |
| ២៦ | អ្នកស្រី អ៊ុង ធឿម | ស៊ីដនីយ៍ Australia | $20 AU |
| ២៧ | លោកតា វ៉េត ឌិត | ស៊ីដនីយ៍ Australia | $15 AU |
| ២៨ | ឧបាសក ជា តុង និងភរិយា | ស៊ីដនីយ៍ Australia | $10 AU |

| | | | |
|---|---|---|---|
| ២៩ | ឧបាសក សយ អ៊ីម | ស៊ីដនីយ៍ Australia | $10 AU |
| ៣០ | ឧបាសិកា កៅ អៀងណៃ | ស៊ីដនីយ៍ Australia | $10 AU |
| ៣១ | ឧបាសិកា សេង ប៊ុនលី | ស៊ីដនីយ៍ Australia | $10 AU |
| ៣២ | ឧបាសក ស៊ិន សាន | ស៊ីដនីយ៍ Australia | $10 AU |
| ៣៣ | លោក ស៊ីនឿន អ្នកស្រី មុំ | ស៊ីដនីយ៍ Australia | $10 AU |
| ៣៤ | លោក ត្រឹង ជីង អ្នកស្រី ហៀង | ស៊ីដនីយ៍ Australia | $10 AU |
| ៣៥ | លោកយាយ គី ញ៉ៀន | ស៊ីដនីយ៍ Australia | $5 AU |
| ៣៦ | អ្នកស្រី អ៊ុក កន្ទារ៉ា | ញូហ្ស៊ីឡែន | $ 60 NZ |
| ៣៧ | ប្អូនស្រី ណាង ព្រមទាំងក្រុមគ្រួសារ | ភ្នំពេញ | $ 300 US |
| ៣៨ | ឧបាសកកែវ គៀម និងឧបាសិកាសូត្រ ម៉ើ | កាណាដា | ២ ក្បាល |
| ៣៩ | ឧបាសិកាឡុង សឿង និងឧបាសក អ៊ុត អឿត | កាណាដា | ២ ក្បាល |

# រៀនភាសាបាលី

# បែបទំនើប

# ភាគ ២

រៀបរៀងដោយ


ញឹម ជារី



ព.ស.២៥៦០ គ.ស.២០១៦

សុត្តំ ធាតុ គណោ ណ្វាទិ នាមលិង្គានុសាសនំ
យស្ស តិដ្ឋតិ ជិវ្ហគ្គេ ស ព្យាករណកេសរី ។

សូត្រ ធាតុ បទមាលា (ការបែកបទ) បច្ច័យ នាម លិង្គនិងការវិនិច្ឆ័យ រមែងតាំងនៅត្រង់ចុងអណ្តាតរបស់កុលបុត្រឯណា, កុលបុត្រនោះ ជារាជសីហ៍ក្នុងព្រៃ(ធំ) គឺវេយ្យាករណ៍ ។


បោះពុម្ពលើកទី១ ចំនួន ៦៥០ ក្បាល
សម្រាប់ជាធម្មទានតែបុណ្ណោះ
ផ្សាយចេញពីវត្តពុទ្ធជ័យមហានាថ ទីក្រុងវែល្លិងតុន ញូហ្ស៊ីឡិន

First print 650 books for free distribution only by


Wat Buddachayamahanath Monastery, Wellington, New Zealand (+64) 3836 854
Sydney, Australia (+61 ) 29610 1029, Battambong, Cambodia (+855) **17 73 22 44**
watkhmerwellington@gmail.com **www.watkhwellington.wordpress.com**



ISBN 978-99963-864-8-0